ការអត្ថាធិប្បាយព្រះគម្ពីរអាស៊ានជាសេរី

# សាសនាពិត

# និង

# [illegible]

ដោយ ចេ. ឌី. ក្រោលី

សាសនាពិត៖ អត្ថាធិប្បាយកណ្ឌយ៉ូហានទី១ ទី២ និង ទី៣
សាសនាក្លែងក្លាយ៖ ក្រុមខុសឆ្គងនៅអាស៊ី និងពិភពលោក

**True Religion and Counterfeit Religion**
By J.D. Crowley

True Religion: Commentary on 1, 2, and 3 John
Counterfeit Religion: Cults in Asia and and Around the World

## គ្មាននរណាចង់ចាញ់ការបោកបញ្ឆោតដោយលុយក្លែងក្លាយនោះទេ។ ចុះសាសនាក្លែងក្លាយវិញ?



នៅពេលដែលធនាគារបង្រៀនបុគ្គលិកឲ្យស្គាល់លុយក្លែងក្លាយ គេមិនឲ្យបុគ្គលិកមើល និងប៉ះលុយក្លែងក្លាយមុននោះទេ គឺឲ្យពួកគេមើល និងប៉ះលុយពិតជាច្រើនម៉ោងមុនសិន។

ដូចគ្នាដែរ មុននឹងយើងសិក្សាអំពីសាសនាក្លែងក្លាយនីមួយៗនៅផ្នែកទី២នៃសៀវភៅនេះ យើងនឹងមើល និងប៉ះសាសនាពិតតាមរយៈសាវ័កយ៉ូហានក្នុងផ្នែកទី១ជាមុនសិន។ ក្នុងកណ្ឌយ៉ូហានទី១ ទី២ និង ទី៣ សាវ័កយ៉ូហានបានផ្ដល់នូវសំណួរវិនិច្ឆ័យរាប់សិបដល់យើង ដើម្បីឲ្យយើងអាចស្គាល់សាសនាក្លែងក្លាយ ដែលកំពុងចូលមកក្នុងប្រទេសរបស់យើង។

គោលបំណងនៃការវិនិច្ឆ័យរបស់សាវ័កយ៉ូហាន គឺសេចក្ដីស្រឡាញ់៖ សេចក្ដីស្រឡាញ់ចំពោះព្រះ សេចក្ដីស្រឡាញ់ចំពោះក្រុមជំនុំ សេចក្ដីស្រឡាញ់ចំពោះក្រុមគ្រួសារ និងសេចក្ដីស្រឡាញ់ចំពោះអ្នកដែលចាញ់ការបោកបញ្ឆោត និងរងគ្រោះថ្នាក់ដោយសារគ្រូក្លែងក្លាយ និងសេចក្ដីបង្រៀនក្លែងក្លាយនោះ។

**«សៀវភៅនេះ គឺជាជំនួយដ៏ធំសម្បើមដល់គ្រីស្ទបរិស័ទទាំងអស់ ដែលចង់បង្ហាញភាពខុសគ្នារវាងគ្រីស្ទសាសនាពិត និងគ្រីស្ទសាសនាក្លែងក្លាយ ដែលកំពុងមានឥទ្ធិពលលើក្រុមជំនុំទូទាំងពិភពលោក។»**

លោកបណ្ឌិត Bruce A. Ware, Professor of Christian Theology, Southern Seminary, Louisville, Kentucky, USA

**ចេ. ឌី. ក្រោលី** បានរស់នៅខេត្តរតនគិរី ប្រទេសកម្ពុជា អស់រយៈពេល ២៧ ឆ្នាំមកហើយ។ លោកជានាយកវិទ្យាស្ថានគ្រូគង្វាលរតនគិរី។

ASEAN Commentary Series

ISBN 0-9727182-9-X

9 780972 718295

# សាសនាពិត
# និង
# សាសនាក្លែងក្លាយ

**ដោយ ចេ. ឌី. ក្រោលី**

ផ្នែកទី១

## សាសនាពិត

ការអត្ថាធិប្បាយកណ្ឌយ៉ូហានខ្សែទី១ ទី២ និង ទី៣
ដោយផ្តោតលើការវិនិច្ឆ័យអំពីគ្រូក្លែងក្លាយ

ផ្នែកទី២

## សាសនាក្លែងក្លាយ

ក្រុមខុសឆ្គងនៅអាស៊ី និងពិភពលោក

# សាសនាពិត និង សាសនាក្លែងក្លាយ

ការអត្ថាធិប្បាយកណ្ឌយ៉ូហានទី១ ទី២ និង ទី៣

(ការអត្ថាធិប្បាយព្រះគម្ពីរអាស៊ានជាស៊េរី)

ដោយ ចេ. ឌី. ក្រោលី

រក្សាសិទ្ធិ ©2021 J.D. Crowley

ISBN 0-9727182-9-X (Khmer Version)

**True Religion and Counterfeit Religion**
Commentary on 1, 2, and 3 John
(ASEAN Bible Commentary Series)

**TrueReligionCounterfeitReligion@yahoo.com**

សម្រង់ព្រះគម្ពីរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ KHOV ឆ្នាំ១៩៥៤។ សម្រង់ឯទៀតដកស្រង់ចេញពី KHSV ឆ្នាំ ១៩៩៧/២០០៥ និង RKOV ឆ្នាំ២០១៦។ រក្សាសិទ្ធិដោយសមាគមព្រះគម្ពីរកម្ពុជា។

បទគម្ពីរសរសេរជាអក្សរទ្រេត។ ការគូសបន្ទាត់ពីក្រោមខគម្ពីរ ឬការប្រើអក្សរក្រាស់(bold) ត្រូវបានបន្ថែមដោយអ្នកនិពន្ធ។

តួអត្ថបទប្រើពុម្ពអក្សរ Battambang និងចំណងជើងខ្លឹមសារអត្ថបទ ប្រើពុម្ពអក្សរ Nokora។

សៀវភៅនេះក៏មានជាភាសាអង់គ្លេសផងដែរ។ សូមមើលទំព័រចុងក្រោយសម្រាប់សៀវភៅ និងធនធានផ្សេងៗឯទៀត។

**សម្គាល់អំពីការប្រើពាក្យ«សាសនា»៖** ពាក្យសាសនាមានអត្ថន័យជាច្រើន ព្រមទាំងអត្ថន័យអវិជ្ជមាន គឺការព្យាយាមរបស់មនុស្សជាតិ ដើម្បីបានសេចក្ដីសង្គ្រោះ តាមរយៈការប្រព្រឹត្តល្អ និងវិធីផ្សេងៗ ហើយនិងអត្ថន័យវិជ្ជមាន គឺជំនឿពិតលើព្រះគ្រីស្ទ ដែលមានភ័ស្តុតាងនៃការប្រព្រឹត្តល្អ។ ឧទាហរណ៍ នៅកណ្ឌយ៉ាកុប ១:២៦ លោកយ៉ាកុបនិយាយអំពី *«សាសនា...អត់ប្រយោជន៍»* តែក្នុងខបន្ទាប់គាត់និយាយអំពី *«សាសនាដែលបរិសុទ្ធ ហើយឥតសៅហ្មង នៅចំពោះព្រះដ៏ជាព្រះវរបិតា»*។ នៅក្នុងសៀវភៅនេះ យើងនឹងប្រើពាក្យ «សាសនា» ក្នុងអត្ថន័យទាំងពីរតាមបរិបទ។ យើងក៏នឹងប្រើពាក្យសាសនាក្នុងអត្ថន័យទូទៅដែរគឺ «ប្រព័ន្ធនៃជំនឿ និងការគោរពប្រតិបត្តិ»។

សូមឧទ្ទិសសៀវភៅនេះជូន

លោក ង៉ែត សារិទ្ធ

# មាតិកា

## ផ្នែកទី១ សាសនាពិត

### ការអត្ថាធិប្បាយកណ្ឌយ៉ូហានទី១ ទី២ និង ទី៣


អារម្ភកថា......................................................................................................៦

សេចក្តីផ្តើមអំពីកណ្ឌគម្ពីរយ៉ូហានខ្សែទី១ ទី២ និង ទី៣..............................................១០

បុព្វកថា៖ ព្រះដែលមានព្រះជន្មគង់នៅអស់កល្បបានយាងមក | ១:១-៥......................២៩

ការវិនិច្ឆ័យប្រាំយ៉ាង ដើម្បីស្គាល់គ្រូក្លែងក្លាយ និងគោលជំនឿក្លែងក្លាយ | ១:៦-២:១១ ..៤៤

ការប្រឆាំងនឹងគ្រូក្លែងក្លាយជាបញ្ហាបែបគ្រួសារ | ២:១២-១៤....................................៦៦

ការអាក្រក់ខាងលោកិយ និងការអាក្រក់ខាងអាទទឹងនឹងព្រះគ្រីស្ទ | ២:១៥-១៩............៧១

ព្រះវិញ្ញាណបរិសុទ្ធជួយឲ្យយើងយកឈ្នះលើការបង្រៀនខុសឆ្គង | ២:២០-២៣............៨៦

ចូរនៅជាប់នឹងដំណឹងល្អដើម ហើយកុំស្វែងរកអ្វីដែលថ្មី | ២:២៤-២៨..........................៩១

ការកើតពីព្រះ៖ គន្លឹះនៃការអនុវត្តន៍នៅក្នុងសំបុត្រយ៉ូហាន | ២:២៩-៣:៣....................៩៦

ភ័ស្តុតាងទី១៖ អ្នកណាដែលកើតពីព្រះនឹងបរិសុទ្ធ | ៣:៤-១០...............................១០៤

ភ័ស្តុតាងទី២៖ អ្នកណាដែលកើតពីព្រះ នឹងស្រឡាញ់អ្នកដទៃ | ៣:១១-២៤............១១៣

ភ័ស្តុតាងទី៣៖ អ្នកណាដែលកើតពីព្រះនឹងជឿ ហើយបង្រៀនសេចក្តីពិត | ៤:១-៦.....១២៧

ព្រះជាសេចក្តីស្រឡាញ់ | ៤:៧-២១...........................................................................១៣៥

ចូរឲ្យបរិសុទ្ធ! ជឿសេចក្តីពិត! ស្រឡាញ់ព្រះ! ស្រឡាញ់អ្នកដទៃ! | ៥:១-២១..............១៥១

តើកណ្ឌគម្ពីរយ៉ូហានខ្សែទី២ និងទី៣ បង្រៀនអ្វីខ្លះពីគ្រូក្លែងក្លាយ?...............................១៦៨

# ផ្នែកទី២ សាសនាក្លែងក្លាយ

## ព្រះគ្រីស្ទក្លែងក្លាយ


អាន់ សាំងហុង និង «ព្រះមាតា» (Ahn Sahng-Hong and “Mother God”).......១៩១

អាប៉ូឡូ គីបូឡូយ (Apollo Quiboloy).......................................................២០៧

លី ម៉ាន់ហ៊ី (Lee Man-hee)..........................................................................២១៧

សាន់ ម្យ៉ុង មូន (Sun Myung Moon)............................................................២២៥

ពួកជំនុំព្រះដ៏មានគ្រប់ព្រះចេស្ដា (Church of Almighty God).........................២៣៨

ស្មរបន្ទាល់ព្រះយេហូវ៉ា (Jehovah's Witnesses)............................................២៥១

សាសនាមរមន (Mormonism).......................................................................២៦២


## គោលជំនឿក្លែងក្លាយ


ប៉ាក អុក ស៊ូ (Pak Ock Soo and Good News Mission)..............................២៧៥

ដំណឹងល្អចម្រុងចម្រើន និង គ្រូចម្រុងចម្រើន (Prosperity Gospel)...................២៨៥

ក្រុមជំនុំសាវកថ្មី (New Apostolic Church)...................................................៣១១

គ្រីស្ទសាសនាសេរីនិយម (Liberal Christianity)..............................................៣១៩

**ឧបសម្ពន្ធ ១៖** ក្រុមពីរដែលជឿព្រះត្រៃឯក តែបន្ថែមគោលលទ្ធិថ្មី៖

សេវេន ដេយ អាត់វេនទីស្ទ (Seventh Day Adventism)................៣៤០

ក្រុមជំនុំរ៉ូម៉ាំងកាតូលិក (Roman Catholicism)..............................៣៥១

**ឧបសម្ពន្ធ ២៖** ឥស្លាមសាសនា (Islam)...........................................................៣៦៥

**ឧបសម្ពន្ធ ៣៖** ខគម្ពីរអំពីគ្រូក្លែងក្លាយនិងការបង្រៀនខុសឆ្គង ....................................៣៧៣

**ឧបសម្ពន្ធ ៤៖** ទំនាក់ទំនងបែបគ្រួសារក្នុងក្រុមជំនុំនៅយ៉ូហាន ទី១.............................៣៧៤

**ឧបសម្ពន្ធ ៥៖** ប្រយោគវិនិច្ឆ័យនៅយ៉ូហាន ទី១.......................................................៣៧៩

គោលជំនឿនៃពួកសាវក និង គោលជំនឿក្រុមប្រឹក្សាណៃសៀ........................................៣៨៤

# អារម្ភកថា

ហេតុអ្វីបានជាមានដំណឹងល្អក្លែងក្លាយ និងព្រះគ្រីស្ទក្លែងក្លាយច្រើនដូច្នេះ? គឺមូលហេតុដូចគ្នាដែលមានក្រដាសប្រាក់១០០ដុល្លារក្លែងក្លាយច្រើនដែរ៖ ពីព្រោះមានតំលៃខ្ពស់ណាស់! អារក្សសាតាំងដឹងថា ដំណឹងល្អរបស់ព្រះគ្រីស្ទ គឺជារបស់ដ៏មានតម្លៃបំផុតនៅក្នុងពិភពលោក។ ដំណឹងល្អគឺជា *«ព្រះចេស្តានៃព្រះ សំរាប់នឹងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿ»* (រ៉ូម ១:១៦) ហើយអារក្សសាតាំងស្អប់ដំណឹងល្អនោះដោយអស់ពីចិត្ត។ ដូច្នេះគ្រប់ទីកន្លែងដែលដំណឹងល្អទទួលបានជោគជ័យ សាតាំងដឹកនាំគ្រូក្លែងក្លាយ ឲ្យបង្កើតដំណឹងល្អក្លែងក្លាយ និងព្រះគ្រីស្ទក្លែងក្លាយ។

ហេតុនេះហើយបានជាមានក្រុមខុសឆ្គងជាច្រើន ដែលមកពី អាមេរិក កូរ៉េ ចិន និងអាហ្វ្រិក។ តំបន់ទាំងនោះ គឺជាកន្លែងដែលដំណឹងល្អបានទទួលជោគជ័យយ៉ាងខ្លាំង។ ក្រុមខុសឆ្គងចូលចិត្តបញ្ឆោតគ្រីស្ទបរិស័ទថ្មី។ តើពួកគេរកគ្រីស្ទបរិស័ទថ្មីនៅឯណា? គឺនៅកន្លែងណាដែលដំណឹងល្អកំពុងរីកចម្រើនឡើង។ កាលពីសាមសិបឆ្នាំមុន ប្រទេសកម្ពុជា មិនសូវមានក្រុមខុសឆ្គងទេ ពីព្រោះមិនសូវមានគ្រីស្ទបរិស័ទថ្មីសម្រាប់ក្រុមខុសឆ្គងលួចឡើយ។ ការលួចសមាជិកក្រុមជំនុំ គឺជាមធ្យោបាយចម្បងដែលក្រុមខុសឆ្គងលូតលាស់។ ប៉ុន្តែបច្ចុប្បន្ននេះ មានគ្រីស្ទបរិស័ទរាប់សែននាក់ និងក្រុមជំនុំរាប់ពាន់ ដូច្នេះក្រុមខុសឆ្គងបានលុកលុយដោយព្រះគ្រីស្ទក្លែងក្លាយ និងដំណឹងល្អក្លែងក្លាយរបស់ពួកគេ។

## ស្គាល់ដំណឹងល្អពិត ដើម្បីស្គាល់ដំណឹងល្អក្លែងក្លាយ

ប៉ុន្តែ ធ្វើដូចម្តេច ឲ្យយើងអាចដឹងថា ក្រុមណាផ្សាយអំពីព្រះគ្រីស្ទពិត ហើយក្រុមណាផ្សាយអំពីព្រះគ្រីស្ទក្លែងក្លាយ? ដើម្បីស្គាល់ព្រះគ្រីស្ទក្លែងក្លាយ យើងត្រូវតែស្គាល់ព្រះគ្រីស្ទពិត និងដំណឹងល្អពិតយ៉ាងច្បាស់ជាមុនសិន។

ស្ថាប័នហិរញ្ញវត្ថុដឹងថា វាមានសារៈសំខាន់ខ្លាំងណាស់ ដែលបុគ្គលិករបស់ពួកគេស្គាល់ក្រដាសប្រាក់ក្លែងក្លាយ ដូច្នេះពួកគេបណ្តុះបណ្តាលបុគ្គលិករបស់ពួកគេអស់ជាច្រើនម៉ោង។ ប៉ុន្តែក្នុងកំឡុងពេលបណ្តុះបណ្តាលនោះ តើបុគ្គលិកសិក្សាក្រដាសប្រាក់ក្លែងក្លាយទេ? មិនច្រើនប៉ុន្មានទេ។ ផ្ទុយទៅវិញ បុគ្គលិកចំណាយពេលស្ទើរតែទាំងអស់ដើម្បីសិក្សាពីក្រដាសប្រាក់ពិតប្រាកដ គឺ វាមើលទៅដូចម្តេច ស្ទាបដូចម្តេច មានសម្លេងដូចម្តេច ហើយថែមទាំងមានក្លិនដូចម្តេច។ បន្ទាប់ពីអស់រាប់ម៉ោងក្នុងការពិនិត្យមើលតែក្រដាសប្រាក់ពិតប្រាកដ នោះបុគ្គលិកនឹងស្គាល់ក្រដាសប្រាក់ក្លែងក្លាយភ្លាម។

ដូចគ្នាដែរ គ្រូបង្រៀនគ្រីស្ទបរិស័ទ ត្រូវតែស្គាល់ដំណឹងល្អពិត និងព្រះគ្រីស្ទពិតយ៉ាងច្បាស់លាស់ ហើយត្រូវបង្រៀនពីដំណឹងល្អពិត និងព្រះគ្រីស្ទពិតដល់សមាជិកក្រុមជំនុំជានិច្ច ដើម្បីឲ្យសមាជិកអាចនឹងស្គាល់ដំណឹងល្អក្លែងក្លាយ ព្រះគ្រីស្ទក្លែងក្លាយភ្លាមបាន។ យើងប្រើមធ្យោបាយដូចគ្នានៅក្នុងសៀវភៅនេះ។ មុននឹងសិក្សាពីដំណឹងល្អក្លែងក្លាយនៅក្នុងផ្នែកទី២នៃសៀវភៅនេះ យើងនឹងសិក្សាពីដំណឹងល្អពិតពីកណ្ឌយ៉ូហានខ្សែទី១ ទី២ និង ទី៣ ជាមុនសិន។

បើយើងផ្លាស់ប្តូរនិមិត្តរូបពីលុយទៅជាសុខភាពវិញ កណ្ឌគម្ពីរយ៉ូហានខ្សែទី១ ប្រៀបធៀបទៅនឹងវ៉ាក់សាំងដែលការពារខាងព្រលឹងវិញ្ញាណ។ ការសិក្សាដំណឹងល្អពិតនៅក្នុងយ៉ូហានទី១ ប្រៀបដូចជាការទទួលវ៉ាក់សាំង ដែលនឹងការពារយើងពីជំងឺនៃការបង្រៀនខុសឆ្គង។

ការអត្ថាធិប្បាយនេះ គឺមានគោលបំណងអនុវត្តជាក់ស្តែង។ គោលដៅរបស់ខ្ញុំ គឺដើម្បីជួយគ្រីស្ទបរិស័ទបំពេញគោលបំណងរបស់សាវកយ៉ូហានសម្រាប់ក្រុមជំនុំដែលបានទទួលសំបុត្រនេះ គឺដើម្បីស្គាល់គ្រីស្ទសាសនាក្លែងក្លាយ និងមានជ័យជំនះលើវា។ ក្នុងគោលដៅនេះ សៀវភៅនេះគឺជាសៀវភៅណែនាំអំពីកណ្ឌយ៉ូហានទី១ ច្រើនជាងការអត្ថាធិប្បាយពេញលេញ។ អ្នកនឹងយល់អំពីការផ្ដោតតូចចង្អៀតនេះ នៅពេលអ្នកសិក្សាតាមសៀវភៅនេះ។

សូមឲ្យមេគង្វាលចៀមរក្សាអ្នករាល់គ្នាក្នុង *«សេចក្ដីជំនឿ ដែលបានប្រគល់មកពួកបរិសុទ្ធ១ដងជាសំរេច»* (យូដាស ៣)។

ចេ. ឌី. ក្រោលី J.D. Crowley
រតនគិរី ព្រះរាជាណាចក្រកម្ពុជា
២០២១

## សេចក្ដីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណចំពោះ Frontline Mission ដែលបានផ្តល់ថវិកាដើម្បីឲ្យគ្រប់គ្រូគង្វាលនៅប្រទេសកម្ពុជាអាចទទួលបានសៀវភៅនេះ។ ខ្ញុំក៏ថ្លែងអំណរគុណចំពោះ កញ្ញា ញាណ គឹមសាន លោក ដួង ស៊ីថា លោក លន់ ឈុនលីម លោក ទុយ ផានី និង លោកស្រី ឃិម ក្រោលី ដែលបានជួយបកប្រែ និងកែសម្រួលសៀវភៅនេះ។

ជាពិសេស ខ្ញុំសូមអរគុណដល់ប្រធានការិយាល័យរបស់ខ្ញុំ អស់រយៈពេល ២០ ឆ្នាំមកហើយ គឺលោក ង៉ែត សារិទ្ធ ជាគ្រូគង្វាល ស្វាមី ឪពុក អ្នកបកប្រែ និងមិត្តភ័ក្តិ ដ៏ស្មោះត្រង់។ ខ្ញុំសូមឧទ្ទិសសៀវភៅនេះជូនលោកដោយក្តីស្រលាញ់។

ផ្នែកទី១

# សាសនាពិត

## ការអត្ថាធិប្បាយកណ្ឌយ៉ូហានទី១ ទី២ និង ទី៣
## ដោយផ្តោតលើការវិនិច្ឆ័យអំពីគ្រូក្លែងក្លាយ

# សេចក្តីផ្តើមអំពីកណ្ឌយ៉ូហានទី១ ទី២ និង ទី៣

ពេលយើងអានកណ្ឌគម្ពីរយ៉ូហានខ្សែទី១ ហើយដល់ឃ្លាចុងក្រោយបង្អស់ នោះយើងនឹងឃើញពាក្យដែលគួរឲ្យភ្ញាក់ផ្អើល៖ *«កូនតូចៗរាល់គ្នាអើយ ចូរឲ្យអ្នករាល់គ្នារក្សាខ្លួនឲ្យផុតពីរូបព្រះចេញ»*។ លោកយ៉ូហាន មិនបាននិយាយអ្វីទាំងអស់អំពីរូបព្រះនៅក្នុងសំបុត្រទាំងមូល ស្រាប់តែគាត់បានលើកអំពីរូបព្រះនៅក្នុងប្រយោគចុងក្រោយទៅវិញ ! ប៉ុន្តែនៅពេលយើងគិតឲ្យស៊ីជម្រៅអំពីកណ្ឌគម្ពីរយ៉ូហានខ្សែទី១ នោះយើងនឹងឃើញថា សំបុត្ររបស់សាវកយ៉ូហានទាំងមូល គឺសម្រាប់ការពារខ្លួនពីរូបព្រះ គឺព្រះក្លែងក្លាយរបស់គ្រូខុសឆ្គង។

តើឃ្លាដំបូងនៃកណ្ឌគម្ពីរយ៉ូហានខ្សែទី១គឺជាអ្វី? *«ឯសេចក្តីដែលមានតាំងពីដើមមកដែលយើងខ្ញុំបានឮ ហើយភ្នែកបានឃើញក៏បានមើលហើយដៃបានប៉ះពាល់...»* លោកយ៉ូហាន កំពុងតែមានប្រសាសន៍ អំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយពាក្យ *«ពីដើម»* ដែលគាត់និយាយនោះ គឺជាដើមដំបូង ដែលគ្មានដើមដំបូងឡើយ។ អ្នកនិពន្ធជនជាតិយូដាពីបុរាណធ្លាប់ពិពណ៌នាអំពីព្រះថា «ព្រះដែលគង់នៅតាំងពីដើមដំបូង» ដែលមានន័យថា «ព្រះដែលគង់នៅអស់កល្បជានិច្ច»។ លោកយ៉ូហាន ប្រើរបៀបនិយាយដូចគ្នានោះអំពីព្រះយេស៊ូវ។ ដូច្នេះ នៅក្នុងប្រយោគដំបូងនៃសំបុត្រនេះ លោកយ៉ូហាន បង្រៀនថា ព្រះយេស៊ូវគឺជាអង្គដែលគង់នៅអស់កល្បជានិច្ចដែលគ្មានដើម និងគ្មានទីបញ្ចប់ គឺអាលផា និងអូមេកា (វិវរណៈ ២១:៦)។

**មានតែព្រះដែលគង់នៅអស់កល្បជានិច្ចដែលសមនឹងទទួលការថ្វាយបង្គំ**

នៅពេលយើងភ្ជាប់ឃ្លាចុងក្រោយនៃកណ្ឌគម្ពីរយ៉ូហានខ្សែទី១ *(«ចូរ...រក្សាខ្លួនឲ្យផុតពីរូបព្រះចេញ»)* ទៅនឹងឃ្លាដំបូង *(«សេចក្ដីដែលមានតាំងពីដើមមក»)* នោះយើងនឹងចាប់ផ្ដើមយល់ពីគោលការណ៍ដ៏ធំមួយនៃកណ្ឌនេះ៖ «មានតែព្រះដែលគង់នៅអស់កល្បជានិច្ច ដែលសមនឹងការថ្វាយបង្គំរបស់យើង»។ ឬតាមបែបអវិជ្ជមាន៖ «ព្រះជាម្ចាស់មិនបានបង្កើតមនុស្ស ឲ្យថ្វាយបង្គំព្រះក្លែងក្លាយដែលមិនស្ថិតស្ថេរអស់កល្បជានិច្ចឡើយ»។ ឬនិយាយម្យ៉ាងទៀត មានតែអ្វីដែលស្ថិតស្ថេរអស់កល្បជានិច្ច ដែលមានសិរីរុងរឿង និងគុណតម្លៃល្មម ដើម្បីធ្វើឲ្យមនុស្សពេញចិត្តទាំងស្រុងអស់កល្បជានិច្ច។ អ្វីៗដែលមានដើមដំបូង ឬមានទីបញ្ចប់ មិនសមទទួលការថ្វាយជីវិតរបស់យើងទេ ហើយមិនអាចទ្រទ្រង់សេចក្ដីស្រឡាញ់ដ៏នៅអស់កល្បរបស់យើងបានឡើយ។ ការថ្វាយបង្គំអ្វីដែលបណ្ដោះអាសន្ន នឹងនាំឲ្យមានការខកចិត្តយ៉ាងខ្លាំង។ ឧទាហរណ៍៖

**ទ្រព្យសម្បត្តិមិនស្ថិតស្ថេរអស់កល្បឡើយ។** គឺវាមានការចាប់ផ្ដើម និងទីបញ្ចប់។ បើអ្នកក្រាបថ្វាយបង្គំទ្រព្យសម្បត្តិរបស់អ្នក នោះអ្នកនឹងខកចិត្ត ពីព្រោះព្រះបានបង្កើតអ្នកឲ្យគោរពថ្វាយបង្គំអ្វីដែលស្ថិតស្ថេរអស់កល្បជានិច្ច គឺព្រះជាម្ចាស់ផ្ទាល់។

**ការរួមភេទមិនស្ថិតស្ថេរអស់កល្បឡើយ។** វាមានការចាប់ផ្ដើម និងទីបញ្ចប់។ បើអ្នកធ្វើឲ្យការរួមភេទ ទៅជារឿងសំខាន់បំផុតក្នុងជីវិតអ្នក នោះអ្នកនឹងខកចិត្តទាំងស្រុង ពីព្រោះការទាំងនោះ មិនស្ថិតស្ថេរឡើយ។ ព្រះបានបង្កើតអ្នកឲ្យគោរពថ្វាយបង្គំអ្វីដែលស្ថិតស្ថេរអស់អស់កល្បជានិច្ច គឺព្រះជាម្ចាស់ផ្ទាល់។

**អំណាច និងកិត្យានុភាពក៏មិនស្ថិតស្ថេរអស់កល្បឡើយ។** អំណាចមនុស្សទាំងអស់នឹងមកដល់ទីបញ្ចប់ ហើយអ្នកដែលស្វែងរកអំណាច នឹងខកចិត្ត

ទាំងស្រុង។ ព្រះមិនបានបង្កើតអ្នកឲ្យថ្វាយបង្គំអ្វីដែលមិនស្ថិតស្ថេរដូចជាអំណាច និងកិត្យានុភាពនោះឡើយ។

**ព្រះគ្រីស្ទក្លែងក្លាយមិនស្ថិតស្ថេរអស់កល្បឡើយ។** ព្រះគ្រីស្ទក្លែងក្លាយទាំងអស់ ដែលយើងនឹងសិក្សាក្នុងសៀវភៅនេះ មានការចាប់ផ្ដើម និងទីបញ្ចប់។ អស់អ្នកណាដែលដើរតាមព្រះគ្រីស្ទក្លែងក្លាយ នឹងខកចិត្តទាំងស្រុង ពីព្រោះមានតែព្រះដ៏គង់នៅអស់កល្បជានិច្ចប៉ុណ្ណោះ ដែលអាចជួយសង្គ្រោះអ្នក ហើយបំពេញចិត្តអ្នកបាន។

រវាងឃ្លាដំបូង អំពីព្រះយេស៊ូវដែលគង់នៅអស់កល្ប និងឃ្លាចុងក្រោយ អំពីរូបព្រះ លោកយ៉ូហាន បង្រៀនយើងយ៉ាងច្រើនអំពី ព្រះដ៏គង់នៅអស់កល្ប ដែលមានតែទ្រង់មួយអង្គប៉ុណ្ណោះ ដែលសក្ដិសមនឹងការថ្វាយបង្គំរបស់យើង។ ហើយលោកយ៉ូហានក៏ធ្វើឲ្យយើងឃើញការកុហករបស់គ្រូក្លែងក្លាយ ដែលចង់ឲ្យយើងថ្វាយបង្គំព្រះគ្រីស្ទក្លែងក្លាយដែរ។

## តើលោកយ៉ូហានជានរណា?

តាមទស្សនៈរបស់ក្រុមជំនុំបុរាណកណ្ឌយ៉ូហានខ្សែទី១ត្រូវបាននិពន្ធដោយលោកយ៉ូហាន ជាសាវកនៃព្រះគ្រីស្ទ ជាប្អូនរបស់យ៉ាកុប ហើយជាកូនរបស់សេបេដេ (ម៉ាកុស ១០:៣៥) គឺជាសាវកយ៉ូហានដដែលដែលបាននិពន្ធកណ្ឌយ៉ូហានដំណឹងល្អ និងកណ្ឌវិវរណៈ។

## ហេតុអ្វីបានជាលោកយ៉ូហានសរសេរកណ្ឌគម្ពីរយ៉ូហានខ្សែទី១?

យើងមិនបាច់ឆ្ងល់ហេតុអ្វីបានលោកយ៉ូហានសរសេរសំបុត្រយ៉ូហានខ្សែទី១ទេ គាត់ប្រាប់យើងថា គាត់សរសេរដើម្បីឲ្យគ្រីស្ទបរិស័ទអាចនឹងទទួលការបួនយ៉ាង៖

១. **អំណរ។** *«យើងខ្ញុំក៏សរសេរសេចក្ដីទាំងនេះផ្ញើមកអ្នករាល់គ្នា ដើម្បីឲ្យសេចក្ដីអំណររបស់អ្នករាល់គ្នាបានពោរពេញឡើង»* (១:៤)។

២. **ភាពបរិសុទ្ធ។** *«កូនតូចៗរាល់គ្នាអើយ ដែលខ្ញុំសរសេរសេចក្ដីទាំងនេះផ្ញើមក នោះដើម្បីកុំឲ្យអ្នករាល់គ្នាធ្វើបាបទៀត»* (២:១)។

៣. **សេចក្ដីពិត។** *«ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា ពីដំណើរនៃពួកអ្នកដែលនាំអ្នករាល់គ្នាឲ្យវង្វេង»* (២:២៦)។

៤. **ការធានាជីវិតអស់កល្បជានិច្ច។** *«ខ្ញុំបានសរសេរសេចក្ដីទាំងនេះ ផ្ញើមកអ្នករាល់គ្នាដែលជឿដល់ព្រះនាមព្រះរាជបុត្រានៃព្រះ ដើម្បីឲ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ចហើយ»* (៥:១៣)។

តើអ្នកណាមិនចង់បាន អំណរ ភាពបរិសុទ្ធ សេចក្ដីពិត និងជីវិតអស់កល្ប? មានតែព្រះដែលគង់នៅអស់កល្បប៉ុណ្ណោះ ដែលអាចផ្ដត់ផ្ដង់ការទាំងបួនយ៉ាងនេះបាន។

លោកយ៉ូហានដឹងថា អារក្សសាតាំងនឹងបង្កើត ព្រះគ្រីស្ទក្លែងក្លាយ និងដំណឹងល្អក្លែងក្លាយ ដើម្បីលួចយកអំណរ ភាពបរិសុទ្ធ សេចក្ដីពិត និងជីវិតអស់កល្បពីគ្រីស្ទបរិស័ទ។ គ្រូខុសឆ្គង ដែលមានព្រះគ្រីស្ទខុសឆ្គង បានលួចចូលក្រុមជំនុំខ្លះរបស់លោកយ៉ូហានហើយ។ ដូច្នេះជាការសំខាន់ណាស់ ដែលគាត់ត្រូវជួយក្រុមជំនុំនេះឲ្យស្គាល់គ្រូខុសឆ្គងនោះ។ ការសិក្សា និងការធ្វើតាម ការព្រមានរបស់លោកយ៉ូហានអំពីគ្រូខុសឆ្គង នៅក្នុងកណ្ឌគម្ពីរយ៉ូហានខ្សែទី១ នឹងនាំយើងមកកាន់តែជិតព្រះយេស៊ូវដ៏ពិត ដែលទ្រង់តែមួយប៉ុណ្ណោះ ដែលអាចនាំយើងឲ្យមានអំណរ ភាពបរិសុទ្ធ សេចក្ដីពិត និងជីវិតអស់កល្ប។

## ព្រឹត្តិការណ៍ពិបាកទើបតែបានកើតឡើងនៅក្នុងក្រុមជំនុំ

នៅពេលអ្នកអានកណ្ឌគម្ពីរយ៉ូហានខ្សែទី១ អ្នកឃើញថា ព្រឹត្តិការណ៍ដ៏ឈឺចាប់បានកើតឡើងនៅក្នុងក្រុមជំនុំរបស់លោកយ៉ូហាន។ នេះគឺជាតម្រុយពីយ៉ូហានខ្សែទី១។ (ខ្ញុំបានដាក់ផ្កាយមួយនៅចំណុចសំខាន់បំផុត)៖

១. គ្រូបង្រៀនខ្លះនៅក្នុងក្រុមជំនុំបានធ្វើការអះអាងយ៉ាងមុតមាំ ដែលមិនត្រូវនឹងការបើកសម្ដែងរបស់ព្រះយេស៊ូវអំពីព្រះជាម្ចាស់។ ឃ្លាវិនិច្ឆ័យ *«បើយើងនិយាយ...»* ឬ *«អ្នកណានិយាយ...»* មាន៦ដងនៅក្នុង២០ខដំបូងនេះ។

២. ថ្មីៗនេះគ្រីស្ទបរិស័ទបានឈ្នះលើគ្រូខុសឆ្គងទាំងនេះ (២:១៣,១៤ និង ៥:៤)។

៣. គ្រូខុសឆ្គងទាំងនេះ បានបង្រៀនទទឹងនឹងការបើកសម្ដែងរបស់ព្រះគ្រីស្ទ ដែលត្រូវបានផ្ដល់ឲ្យតាមរយៈលោកយ៉ូហាន និងពួកសាវកឯទៀតដែលជាសាក្សីផ្ទាល់ភ្នែក។ គ្រូខុសឆ្គងផ្ដល់ព្រះគ្រីស្ទផ្សេង គឺ *«អង់ទីគ្រីស្ទ»* (២:១៨)។

*៤. ដោយការអស្ចារ្យនៃព្រះ អ្នកជឿពិតប្រាកដ អាចបណ្ដេញគ្រូខុសឆ្គងទាំងនេះចេញពីក្រុមជំនុំ ប៉ុន្តែគ្រូខុសឆ្គងច្បាស់ជាបានយកសមាជិកក្រុមជំនុំជាច្រើនទៅជាមួយ (២:១៩)។

៥. គ្រូក្លែងក្លាយទាំងនេះបានបដិសេធគោលការណ៍បង្រៀនរបស់ពួកសាវកដែលថា ព្រះយេស៊ូវជាព្រះគ្រីស្ទ ដែលបានយាងមកក្នុងសាច់ឈាម (២:២២ និង ៤:២)។

៦. គ្រូខុសឆ្គងទាំងនេះនៅតែព្យាយាមមានឥទ្ធិពលលើគ្រីស្ទបរិស័ទដែលនៅសល់ (២:២៦)។

៧. គ្រីស្ទបរិស័ទត្រូវវិនិច្ឆ័យគ្រូខុសឆ្គងទាំងនេះ និងការបង្រៀនរបស់ពួកគេ ស្របតាមទីបន្ទាល់ដើមរបស់ពួកសាវក (៤:១-៦)។

## **កណ្ឌគម្ពីរយ៉ូហានខ្សែទី១ជួយយើងក្នុងការវិនិច្ឆ័យអំពីជំនឿខុសឆ្គង និងគ្រូខុសឆ្គង**

លើសជាងពាក់កណ្ដាលនៃ១០៥ខក្នុងកណ្ឌគម្ពីរយ៉ូហានខ្សែទី១ ត្រូវបានសរសេរដើម្បីជួយយើងឲ្យចេះវិនិច្ឆ័យរវាងការបង្រៀនខុសឆ្គង និងត្រឹមត្រូវ។ នេះជាមូលហេតុដែលពាក្យ *«បើសិន...»* និង *«បើសិនជាយើងនិយាយ...»* និង *«អ្នកណាដែលថា...»* និង *«យើងដឹងសេចក្ដីនេះដោយ...»*។ល។ មានជាញឹកញាប់នៅក្នុងសំបុត្រយ៉ូហាន។

ព្រះចង់ឲ្យយើងទាំងអស់គ្នាក្លាយជាអ្នកប្រសប់ក្នុងការវិនិច្ឆ័យរវាងការពិត និងការខុសឆ្គង ហើយនិងគ្រូពិត និងគ្រូខុសឆ្គង។ (សូមមើលឧបសម្ពន្ធ ៥ ដែលមានបញ្ជីពាក្យវិនិច្ឆ័យទាំងអស់ក្នុងយ៉ូហានខ្សែទី១)។

## **ក្រុមក្លែងក្លាយលាក់បាំងនូវគោលលទ្ធិអាក្រក់បំផុត ដើម្បីលួចសមាជិកក្រុមជំនុំ**

ក្រុមខុសឆ្គងថ្មី ចូលមកហាក់ដូចជារៀងរាល់ឆ្នាំ ដើម្បីលួចអំណរ ភាពបរិសុទ្ធ សេចក្ដីពិត និងជីវិតអស់កល្ប របស់យើង។ ពួកគេឆ្លាតណាស់តាមវិធីពីរយ៉ាង៖

១. **តាមធម្មតាពួកគេទៅផ្ទះពួកអ្នកជឿព្រះយេស៊ូវហើយ។** ហេតុអ្វី? ពីព្រោះការលួចផ្លែឈើរបស់អ្នកដទៃ ស្រួលជាងការដាំចម្ការដោយខ្លួនឯង!

២. **ពួកគេលាក់ជំនឿអាក្រក់បំផុតរបស់ពួកគេ។** ពួកគេចង់ឲ្យយើងគិតថាជំនឿរបស់គេស្រដៀងនឹងយើង ហើយគេគ្រាន់តែចង់ជួយយើងឲ្យយល់ពីគ្រីស្ទសាសនាកាន់តែប្រសើរឡើង។ គេថែមទាំងប្រើពាក្យ និងឈ្មោះដដែលដែលយើងប្រើដូចជា «ព្រះយេស៊ូវ» «ព្រះជាម្ចាស់» «ព្រះវិញ្ញាណបរិសុទ្ធ» «សេចក្ដីសង្គ្រោះ» «រស់ពីស្លាប់ឡើងវិញ» និង«ជ្រមុជទឹក» ប៉ុន្តែពួកគេបានបង្វែរអត្ថន័យនៃពាក្យ និងឈ្មោះទាំងនេះឲ្យខុសពីអត្ថន័យនៅក្នុងព្រះគម្ពីរ។ ពួកគេ

ខ្លះថែមទាំងប្រើព្រះគម្ពីរដូចគ្នាដែលយើងប្រើ ប៉ុន្តែពួកគេជ្រើសរើសតែខគម្ពីរខ្លះៗ ដែលគេចូលចិត្ត ហើយក៏បំភាន់អត្ថន័យនៃខទាំងនោះ។ ពេលខ្លះពួកគេសន្យាថា នឹងផ្តល់អាហារ និងប្រាក់ខែដល់អ្នកដែលសុខចិត្តចាកចេញពីក្រុមជំនុំរបស់ខ្លួន ហើយចូលរួមជាមួយក្រុមពួកគេវិញ។ **ប៉ុន្តែក្នុងករណីទាំងអស់ ពួកគេលាក់បាំងនូវគោលលទ្ធិដែលគួរឲ្យស្អប់ខ្ពើមបំផុតរបស់គេ។ តែគោលលទ្ធិទាំងនេះ ដែលពួកគេចង់លាក់រហូតដល់ពេលក្រោយ គឺជាគោលលទ្ធិដែលយើងត្រូវសួរពួកគេមុន។**

នៅក្នុងការសិក្សាកណ្ឌគម្ពីរយ៉ូហានខ្សែទី១នេះ យើងនឹងរៀនប្រើប្រយោគវិនិច្ឆ័យ នៅក្នុងកណ្ឌគម្ពីរយ៉ូហានខ្សែទី១ និងកណ្ឌគម្ពីរឯទៀត ដើម្បីសួរគ្រូខុសឆ្គងនូវសំណួរដ៏សំខាន់ជាងគេ ដូចជា៖ តើព្រះជាអ្នកណា? តើព្រះយេស៊ូវជាអ្នកណា? តើព្រះវិញ្ញាណបរិសុទ្ធជាអ្នកណា? តើព្រះបន្ទូលរបស់ព្រះជាអ្វី? តើយើងត្រូវធ្វើអ្វីដើម្បីបានសង្គ្រោះ? តើព្រះគ្រីស្ទរបស់អ្នកជាពូជពង្សរបស់ស្តេចដាវីឌឬ? តើព្រះគ្រីស្ទរបស់អ្នកបានរស់ពីស្លាប់ឡើងវិញទេ នៅពេលគាត់ស្លាប់?

ពួកគ្រូខុសឆ្គងមិនចង់ឲ្យយើងសួរសំណួរទាំងនេះទេ។ ពេលខ្លះពួកគេនឹងនិយាយកាត់យើងយ៉ាងឈ្លើយ ហើយប្រាប់យើងឲ្យនៅស្ងៀម ហើយស្តាប់ពួកគេវិញ។ ប៉ុន្តែសំណួរវិនិច្ឆ័យរបស់លោកយ៉ូហាន គឺជាសំណួរសំខាន់បំផុត ហើយយើងត្រូវតែសួរសំណួរនោះ។

> **ឧទាហរណ៍៖** មុនដំបូងពួកក្រុមខុសឆ្គង អាន់ សាំងហុង មិនចង់និយាយអំពីជំនឿប្រមាថរបស់គេដែលថា បុរសជនជាតិកូរ៉េម្នាក់ឈ្មោះ អាន់ សាំងហុង ដែលបានស្លាប់ក្នុងឆ្នាំ១៩៨៥ គឺជាព្រះគ្រីស្ទនោះទេ។ តាមធម្មតាពួកគេលាក់ព័ត៌មាននេះ។ ពួកគេដឹងថា បើសិនពួកគេនិយាយអំពីរឿងនេះមុន នោះគ្រីស្ទបរិស័ទពិតទាំងអស់ នឹងបដិសេធពួកគេភ្លាមៗ ពីព្រោះព្រះគ្រីស្ទពិត ត្រូវតែមកតាមរយៈពូជពង្សរបស់ស្តេចដាវីឌនៃ

ជនជាតិអ៊ីស្រាអែល។ ផ្ទុយទៅវិញ ពួកគេចង់និយាយយ៉ាងខ្លាំងអំពីជំនឿរបស់ពួកគេដែលថា មនុស្សត្រូវតែថ្វាយបង្គំព្រះនៅថ្ងៃសៅរ៍ មិនមែនថ្ងៃអាទិត្យទេ។ ប៉ុន្តែតើសំណួរណាសំខាន់ជាង សំណួរអំពីការថ្វាយបង្គំនៅថ្ងៃណា ឬ សំណួរអំពីតើអ្នកណាជាព្រះគ្រីស្ទពិត?

**ឧទាហរណ៍មួយទៀត៖** ពួកមរមនចូលចិត្តប្រើឈ្មោះ «ព្រះយេស៊ូវ» និង«ព្រះ» ដើម្បីធ្វើឲ្យយើងគិតថា សាសនារបស់ពួកគេស្រដៀងនឹងសាសនារបស់យើងដែរ។ ប៉ុន្តែពួកគេចង់លាក់បាំងជំនឿរបស់ពួកគេដែលថា យេស៊ូវរបស់ពួកគេ គឺជាបងរបស់អារក្សសាតាំងខាងវិញ្ញាណ! គេក៏ចង់លាក់នូវជំនឿរបស់ពួកគេផងដែរថា ពីមុនព្រះរបស់ពួកគេ គឺជាមនុស្សធម្មតាដែលបានក្លាយជា«ព្រះ» មួយ ហើយថា បុរសមរមនស្មោះត្រង់ទាំងអស់ក៏អាចក្លាយជា ព្រះ បានដែរ! ហើយពួកគេប្រាកដជាមិនចង់ប្រាប់អ្នកពីជំនឿរបស់គេដែលថា អ័ដាមបានធ្វើ**ការល្អ** នៅពេលគាត់មិនស្តាប់បង្គាប់ព្រះ ហើយបរិភោគផ្លែឈើនោះ! បើសិនជាពួកមរមនប្រាប់យើងពីជំនឿប្រមាថទាំងនេះពីដំបូង នោះគ្មានគ្រីស្ទបរិស័ទណាដែលនឹងស្តាប់គេទេ។

**ឧទាហរណ៍មួយទៀត៖** ក្រុមស្មរបន្ទាល់ព្រះយេហូវ៉ាក៏និយាយថា ពួកគេជឿលើ«ព្រះយេស៊ូវ»ដែរ។ ប៉ុន្តែគេមិនប្រាប់យើងថា យេស៊ូវរបស់គេមិនគង់នៅតាំងពីអស់កល្បទេ តែជារបស់ដែលព្រះបានបង្កើតពីសូន្យមក។ ព្រះយេស៊ូវរបស់គេជាទេវតាឈ្មោះមីកែល ដែលក្រោយមកទេវតានេះបានកើតមកជាមនុស្សឈ្មោះ យេស៊ូវ នៅភូមិបេថ្លេហិម។ ពួកគេបង្រៀនថា ព្រះកាយរបស់ព្រះយេស៊ូវ មិនបានរស់ពីស្លាប់ឡើងវិញទេ។ បើស្មរបន្ទាល់ព្រះយេហូវ៉ាប្រាប់យើងអំពីជំនឿប្រមាថទាំងនេះពីដំបូង នោះគ្រីស្ទបរិស័ទនឹងបដិសេធភ្លាមៗ ដូច្នេះពួកគេលាក់សេចក្តីទាំងនេះរហូតដល់ពេលក្រោយ។

**មុខពូថៅ**



ហេតុអ្វីបានជាក្រុមខុសឆ្គងលាក់ជំនឿគួរឲ្យស្អប់ខ្ពើមរហូតដល់ពេលក្រោយ? ដើម្បីឆ្លើយសំណួរនេះ ខ្ញុំនឹងប្រើឧទាហរណ៍អំពីការពុះឧសដោយប្រើពូថៅ។ មុខពូថៅគឺស្តើង និងមុត ដែលងាយស្រួលចូលក្នុងឈើ តែខ្នងពូថៅវិញគឺក្រាស់ និងស្មើសម្រាប់ដំដែកគោល។ ចុះបើអ្នកព្យាយាមពុះឧសដោយប្រើខ្នងពូថៅវិញយ៉ាងម៉េចដែរ? អ្នកនឹងបរាជ័យទាំងស្រុង។ មានតែមុខពូថៅដែលស្តើង ហើយមុតប៉ុណ្ណោះ ដែលអាចចូលក្នុងឈើ ហើយបំបែកវា។

គ្រូខុសឆ្គងទាំងនេះ ក៏ដូចគ្នាដែរ។ ពួកគេបានចាប់ផ្តើមការសន្ទនារបស់ពួកគេដោយនិយាយពីជំនឿដែលមិនសូវសំខាន់ ឬមិនធ្វើឲ្យអន់ចិត្ត។ ជំនឿទាំងនេះប្រៀបនឹងមុខពូថៅដែលងាយចូល។ ពួកគេប្រើពាក្យដែលយើងស្គាល់ហើយ ដូចជា «ព្រះយេស៊ូវ» «ព្រះជាម្ចាស់» និង«ការរស់ឡើងវិញ» ដើម្បីឲ្យយើងគិតថា ជំនឿរបស់គេ ស្រដៀងនឹងជំនឿយើងដែរ។ ហើយគេក៏បង្រៀនយើង ពីគោលលទ្ធិតូចតាចដែលមិនសូវសំខាន់។ ឬគេនឹងសួរសំណួរដល់យើងដើម្បីឲ្យយើងចាប់ផ្តើមសង្ស័យពីសេចក្តីសង្គ្រោះរបស់យើង ហើយចាប់អារម្មណ៍នឹងការបង្រៀនរបស់គេ។ ពួកគេក៏អាចអូសទាញចិត្តយើងដោយចែកអង្ករ ឬសន្យាឲ្យប្រាក់ខែ។ ទាំងអស់នេះគឺជាមុខពូថៅ។

ទាល់តែពេលក្រោយ ទើបគេបង្ហាញគោលជំនឿអាក្រក់ៗរបស់គេ ដែលប្រៀបនឹងខ្នងពូថៅ។ គោលលទ្ធិទាំងនោះ ច្បាស់ជាអាក្រក់បំផុត ដែលមិនអាចចូលក្រុមជំនុំ ហើយបំបែកក្រុមជំនុំ ដូចដែលខ្នងពូថៅ មិនអាចចូលបំបែកឈើដែរ។

ប៉ុន្តែកុំភ្លេច៖ បើមុខពូថៅចូលទៅក្នុងឈើ នោះខ្នងពូថៅដែលក្រាស់នឹងចូលតាមក្រោយភ្លាម ហើយបំបែកឈើនោះ។ និយាយម្យ៉ាងទៀត បើយើងទទួលការបង្រៀន

តូចតាចរបស់ក្រុមខុសឆ្គង មិនយូរប៉ុន្មានយើងនឹងទទួលការបង្រៀនអាក្រក់បំផុតរបស់ពួកគេ គឺជំនឿដែលនឹងបំបែកយើងពីសេចក្ដីពិត ហើយបញ្ជូនយើងទៅស្ថាននរក។

## ព្រះគឺជាពន្លឺ និង ព្រះគឺជាសេចក្ដីស្រឡាញ់

លោកយ៉ូហាន ធ្វើបន្ទាល់ប្រាប់យើងនៅក្នុងខដំបូងនៃយ៉ូហានខ្សែទី១ថា អង្គមួយដែលគង់នៅអស់កល្បជានិច្ច *(«តាំងពីដើមមក»)* បានយាងមកផែនដីជាមនុស្សដើម្បីសម្ដែងអំពីព្រះពិតដល់មនុស្សយើង។ លោកយ៉ូហាន និងសាក្សីផ្សេងទៀត បានឃើញទ្រង់ បានមើល បានប៉ះ និងស្ដាប់ទ្រង់រាល់ថ្ងៃ អស់រយៈពេល៣ឬ៤ឆ្នាំ! អ្វីៗទាំងអស់ដែលអង្គនេះបានសម្ដែងក្នុងបីឆ្នាំនោះ អំពីព្រះ លោកយ៉ូហានបានសង្ខេបជា ពាក្យវេទសាស្ត្រធំពីរ៖ **ព្រះជាពន្លឺ** (១:៥) ហើយ **ព្រះជាសេចក្ដីស្រឡាញ់** (៤:៨)។ លោកយ៉ូហាន ប្រើសេចក្ដីពិតទាំងពីរនេះ ដើម្បីជួយយើងឲ្យវិនិច្ឆ័យរវាង គ្រូពិត និងគ្រូក្លែងក្លាយ ហើយគ្រីស្ទបរិស័ទពិត និងគ្រីស្ទបរិស័ទក្លែងក្លាយ។

**ព្រះគឺជាពន្លឺ៖** ពាក្យ «ពន្លឺ» នៅក្នុងព្រះគម្ពីរ ពេលខ្លះជារូបភាពនៃ**ភាពបរិសុទ្ធ** និងពេលខ្លះជារូបភាពពី **សេចក្ដីពិត** (ទំនុកដំកើង ៣៧:៦; ៤៣:៣; ១១៩:១០៥,១៣០; សុភាសិត ៤:១៨; ៦:២៣; អេសាយ ៩:២; ដានីយ៉ែល ៥:១១; ម៉ាថាយ ៥:១៦; យ៉ូហាន ៣:១៩-២១ ។ល។ )។ ដូច្នេះបើព្រះជាពន្លឺ មានន័យថា ទ្រង់បរិសុទ្ធ និងពិត ហើយអ្នកណាដែលកើតពីព្រះ នឹងស្វែងរក**ភាពបរិសុទ្ធ** និងជឿ**សេចក្ដីពិត** ហើយគ្រូបង្រៀនដែលមកពីព្រះ នឹងរស់នៅក្នុងជីវិតដ៏បរិសុទ្ធ ហើយបង្រៀន និងជឿសេចក្ដីពិត។

**ព្រះគឺជាសេចក្ដីស្រឡាញ់៖** ដោយសារព្រះជាសេចក្ដីស្រឡាញ់ អ្នកណាដែលកើតពីព្រះ នឹងស្រឡាញ់ព្រះ ហើយនិងស្រឡាញ់គ្នាទៅវិញទៅមក ហើយគ្រូ

បង្រៀនដែលមកពីព្រះនឹងបង្រៀនអ្នកស្ដាប់ ដោយពាក្យសំដី និងគំរូ ឲ្យស្រឡាញ់ព្រះ និងស្រឡាញ់គ្នា។

ដូច្នេះការពិតទាំងអស់នេះ ក្លាយជាប្រព័ន្ធរបស់យើង ក្នុងការវិភាគ និងយល់ពីគម្ពីរយ៉ូហានខ្សែទី១ ទី២ និង ទី៣ ហើយនឹងអនុវត្តតាម។

**សំបុត្ររបស់លោកយ៉ូហាន គឺប្រៀបធៀបដូចជាសំណាញ់សុវត្ថិភាព**

លោកយ៉ូហានបានសរសេរកណ្ឌគម្ពីរយ៉ូហានខ្សែទី១ ដោយធ្វើដូចសំណាញ់សុវត្ថិភាព ដើម្បីកុំឲ្យយើងធ្លាក់ចូលក្នុងការកុហករបស់គ្រូក្លែងក្លាយ ហើយបន្ទាប់មកធ្លាក់ក្នុងនរក។ ប្រហែលអ្នកធ្លាប់ឃើញសំណាញ់សុវត្ថិភាព ដែលចេញនៅចំហៀងអាគារខ្ពស់ដែលកំពុងសាងសង់ កុំឲ្យកម្មករធ្លាក់។ សំណាញ់សុវត្ថិភាព តែងតែត្រូវបានភ្ជាប់ ៤ ឬ៥កន្លែងយ៉ាងមាំ ដើម្បីការពារមនុស្សពីការធ្លាក់ចូលក្នុងគ្រោះថ្នាក់ ដូចជាសំណាញ់នៅក្នុងរូបថតនេះ។

ជារៀងរាល់ឆ្នាំ ក្មេងៗរាប់សិបនាក់ បានស្លាប់ដោយសារតែពួកគេបានវាទៅអាងហែលទឹកនៅខាងក្រោយផ្ទះ ហើយធ្លាក់ចូលទៅក្នុងទឹក។ តែនៅក្នុងរូបភាពនេះ ក្មេងមិនស្លាប់ទេ ពីព្រោះឳពុកម្ដាយបានដាក់សំណាញ់សុវត្ថិភាព។



កណ្ឌគម្ពីរយ៉ូហានខ្សែទី១ រួមនឹងគម្ពីរទាំងមូល ប្រៀបនឹងសំណាញ់សុវត្ថិភាព ដើម្បីការពារយើងពីការបង្រៀនខុសឆ្គង។ ដូចដែលអ្នកឃើញ

នៅក្នុងរូបខាងក្រោម ជ្រុងសំណាញ់សុវត្ថិភាពរបស់លោកយ៉ូហាន ត្រូវបានភ្ជាប់យ៉ាងមាំទៅនឹងចំណុច៤៖




«ចូរបរិសុទ្ធ» «ជឿការពិត» «ស្រឡាញ់ព្រះ» និង«ស្រឡាញ់គ្នា»។ ចំណុចទាំងបួននេះ លេចធ្លោពីសេចក្ដីប្រកាសសំខាន់ពីរនៅក្នុងកណ្ឌគម្ពីរយ៉ូហានខ្សែទី១ *«ព្រះគឺជាពន្លឺ»* និង *«ព្រះគឺជាសេចក្ដីស្រឡាញ់»*។

ខ្សែទាំងអស់នៅក្នុងសំណាញ់សុវត្ថិភាពរបស់លោកយ៉ូហាន ត្រូវបានត្បាញគ្នានៅកណ្ដាលកន្លែងដែលយើងឃើញពាក្យថា «កើតពីព្រះ»។ ការកើតពីព្រះដោយព្រះវិញ្ញាណបរិសុទ្ធ គឺជាគន្លឹះអនុវត្តន៍របស់កណ្ឌគម្ពីរយ៉ូហានខ្សែទី១។ មានផ្លូវតែមួយដែលយើង អាចក្លាយជា មនុស្សបរិសុទ្ធ ដែលជឿសេចក្ដីពិត ស្រឡាញ់ព្រះ និងស្រឡាញ់គ្នា គឺកើតជាថ្មីពីព្រះ។ *«បើអ្នករាល់គ្នាដឹងថា ទ្រង់សុចរិត នោះត្រូវតែយល់ឃើញថា អស់អ្នកណាដែលប្រព្រឹត្តតាមសេចក្ដីសុចរិតនោះ គេបានកើតពីទ្រង់មកដែរ»* (១យ៉ូហាន ២:២៩)។

អ្នកដែលធ្វើសំណាញ់សុវត្ថិភាព ធ្វើឲ្យខ្សែនីមួយៗត្បាញភ្ជាប់គ្នានឹងខ្សែឯទៀតទាំងអស់ ហើយភ្ជាប់នឹងកន្លែងចង៤។ ដូចគ្នាដែរ លោកយ៉ូហាន ត្បាញចំណុចទាំងប្រាំយ៉ាងជាមួយគ្នានៅគម្ពីរយ៉ូហានខ្សែទី១។ លោកចង់ឲ្យយើងឃើញថា ក្រុមជំនុំពិត និងគ្រូបង្រៀនដ៏ពិត នឹងត្បាញចំណុចទាំងប្រាំយ៉ាងនេះជាមួយគ្នា ក្នុងជីវិត និងសេចក្ដីបង្រៀនរបស់ពួកគេ។

## សាវកយ៉ូហាន មិនអនុញ្ញាតឲ្យយើងជ្រើសរើសសេចក្តីពិតខ្លះ ហើយបដិសេធសេចក្តីពិតខ្លះនោះឡើយ

គ្រីស្ទបរិស័ទខ្លះចូលចិត្តជ្រើសរើសសេចក្តីពិតខ្លះពីគម្ពីរតាមចំណូលចិត្ត ឧទាហរណ៍ មនុស្សខ្លះចូលចិត្តនិយាយថា «ខ្ញុំស្រឡាញ់ព្រះ ប៉ុន្តែគ្រីស្ទបរិស័ទតែងតែធ្វើឲ្យខ្ញុំខកចិត្ត ដូច្នេះខ្ញុំមិនទៅវិហារទៀតទេ ខ្ញុំថ្វាយបង្គំនៅផ្ទះវិញ»។ ប៉ុន្តែលោកយ៉ូហាន មិនឲ្យយើងធ្វើដូច្នេះទេ។ ជារឿយៗនៅក្នុងកណ្ឌគម្ពីរយ៉ូហានខ្សែទី១ លោកយ៉ូហាន ចងភ្ជាប់ បញ្ញត្តិ «ស្រឡាញ់ព្រះ» ជាមួយនឹងបញ្ញត្តិ «ស្រឡាញ់គ្នា» ដូចនៅក្នុង ១យ៉ូហាន ៤:២០៖ *«បើអ្នកណាថា ខ្លួន**ស្រឡាញ់ព្រះតែស្អប់ដល់បងប្អូនវិញ** អ្នកនោះជាអ្នកកុហក ដ្បិតអ្នកណាដែលមិនស្រឡាញ់បងប្អូនដែលបានមើលឃើញទៅហើយ នោះធ្វើម្តេចឡើយ ឲ្យស្រឡាញ់ដល់ព្រះដែលមើលមិនឃើញទៅបាន»*។ រូបខាងក្រោមនេះប្រើប្រួញដើម្បីបង្ហាញយើងថា ១យ៉ូហាន ៤:២០ ផ្សារភ្ជាប់ ការ «ស្រឡាញ់ព្រះ» និងការ «ស្រឡាញ់គ្នា»។




*«បើអ្នកណាថា **ខ្លួនស្រឡាញ់ព្រះ តែស្អប់ដល់បងប្អូនវិញ** អ្នកនោះជាអ្នកកុហក»។ ( ១យ៉ូហាន ៤:២០ )*

មនុស្សខ្លះទៀតនិយាយថា គេស្រឡាញ់ព្រះ ប៉ុន្តែគេចង់បដិសេធបទបញ្ញត្តិខ្លះរបស់ទ្រង់វិញ។ ប៉ុន្តែនៅ១យ៉ូហាន ៥:៣ក លោកយ៉ូហាននិយាយថា អ្នកណាដែលពិតជា**ស្រឡាញ់ព្រះ** នោះនឹងមាន**ភាពបរិសុទ្ធ**ដែរ៖ *«ដ្បិតនេះហើយជាសេចក្តីស្រឡាញ់ដល់ព្រះ គឺឲ្យយើងកាន់តាមអស់ទាំងបញ្ញត្តរបស់ទ្រង់»*។




*«នេះហើយជា**សេចក្ដីស្រឡាញ់ដល់ព្រះ***
*គឺឲ្យយើង**កាន់តាមអស់ទាំងបញ្ញត្តរបស់ទ្រង់**»។ (១យ៉ូហាន ៥:៣ ក)*

មនុស្សឯទៀតចូលចិត្តនិយាយថា «ខ្ញុំមិនចូលចិត្តគោលលទ្ធិច្រើនប៉ុន្មានទេ ពីព្រោះគោលលទ្ធិបំបែកបំបាក់យើង។ ខ្ញុំគ្រាន់តែចង់ស្រឡាញ់មនុស្សវិញ»។ តែលោកយ៉ូហានមិនអនុញ្ញាតឲ្យយើងញែក «ស្រឡាញ់គ្នា» និង «ជឿការពិត» នោះទេ ពីព្រោះបើយើងពិតជាស្រឡាញ់គេ យើងចង់ឲ្យគេជឿសេចក្ដីពិតដែលនាំឲ្យគេមានសេរីភាព។ សូមស្ដាប់៖ *«ឯបញ្ញត្តិទ្រង់នោះគឺថា ត្រូវឲ្យយើង**ជឿ**ដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃទ្រង់ ហើយត្រូវ**ស្រឡាញ់គ្នា**ទៅវិញទៅមក ដូចជាទ្រង់បានបង្គាប់មកហើយ»*។ ព្រួញក្នុងរូបនេះ បង្ហាញពីការចងភ្ជាប់របស់លោកយ៉ូហាន រវាងគោលជំនឿ និងសេចក្ដីស្រឡាញ់។




*«ត្រូវឲ្យយើង**ជឿ**ដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃទ្រង់*
*ហើយត្រូវ**ស្រឡាញ់គ្នា**»។ (១យ៉ូហាន ៣:២៣)*

មនុស្សខ្លះអះអាងថា គេស្រឡាញ់មនុស្សឯទៀត ប៉ុន្តែនៅពេលអ្នកក្រឡេកមើលជីវិតរបស់ពួកគេឃើញថា ពួកគេត្រាប់តាមលោកិយ ហើយមិនបរិសុទ្ធទេ។ ប៉ុន្តែលោកយ៉ូហានមានប្រសាសន៍នៅក្នុង១យ៉ូហាន ៣:១២(ខ)ថា ភាពបរិសុទ្ធ និងសេចក្ដីស្រឡាញ់ ត្រូវតែដើរជាមួយគ្នារហូត៖ *«ហេតុអ្វីបានជា [កាអ៊ីន] **សម្លាប់គាត់***

*[ស្អប់អេបិល]? ពីព្រោះ**ការប្រព្រឹត្តរបស់គាត់សុទ្ធតែអាក្រក់** ហើយការរបស់ប្អូនសុទ្ធតែល្អវិញប៉ុណ្ណោះ»*។ ការដែលកាអ៊ីនគ្មានភាពបរិសុទ្ធ បាននាំឲ្យគាត់ស្អប់ប្អូន និងសម្លាប់ប្អូនខ្លួនឯង។ ដូច្នេះ ចូរ«បរិសុទ្ធ» និង«ស្រឡាញ់គ្នា» ត្រូវភ្ជាប់គ្នារហូត ដូចក្នុងរូបនេះ។




*«ហេតុអ្វីបានជា [កាអ៊ីន] **សម្លាប់**គាត់ [ស្អប់អេបិល]?*
*ពីព្រោះ**ការប្រព្រឹត្តរបស់គាត់សុទ្ធតែអាក្រក់**»។ (១យ៉ូហាន ៣:១២ខ)*

គ្រូក្លែងក្លាយខ្លះនៅសម័យលោកយ៉ូហានអះអាងថា ពួកគេស្រឡាញ់ព្រះ ប៉ុន្តែពួកគេបដិសេធទីបន្ទាល់របស់ព្រះផ្ទាល់ អំពីព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ។ នៅក្នុង១យ៉ូហាន ៥:១០ លោកយ៉ូហានបង្រៀនថា អ្នកដែលពិតជាស្រឡាញ់ព្រះអម្ចាស់ ក៏នឹងជឿលើសេចក្ដីពិតអំពីព្រះយេស៊ូវគ្រីស្ទដែរ៖ *«អ្នកណាដែល**ជឿ**ដល់ព្រះរាជបុត្រានៃព្រះ នោះមានសេចក្ដីបន្ទាល់នៅក្នុងខ្លួនហើយ តែអ្នកណាដែលមិនជឿសោះ នោះឈ្មោះថា **បានធ្វើឲ្យទ្រង់ទៅជាអ្នកកុហកវិញ** ពីព្រោះមិនបានជឿដល់សេចក្ដីបន្ទាល់ដែលទ្រង់បានធ្វើពីដំណើរព្រះរាជបុត្រានៃទ្រង់»*។ អ្នកណាដែលមិនជឿសេចក្ដីពិតរបស់ព្រះអំពីព្រះយេស៊ូវ អ្នកនោះមិនស្រឡាញ់ព្រះទេ តាមពិតគាត់ហៅព្រះអង្គថា ជាអ្នកកុហកវិញ។ លោកយ៉ូហានផ្សារភ្ជាប់ «ស្រឡាញ់ព្រះ» និង «ជឿការពិត» ដូចក្នុងរូបនេះ។




*«អ្នកណាដែលមិន**ជឿ**សោះ នោះឈ្មោះថា
បានធ្វើឲ្យទ្រង់ទៅជា**អ្នកកុហក**វិញ»។ (១យ៉ូហាន ៥:១០)*

គ្រូក្លែងក្លាយជាច្រើនអះអាងថា ខ្លួន«កើតពីព្រះ» ហើយ «ស្គាល់ព្រះអម្ចាស់» និង «មកពីព្រះ»។ ប៉ុន្តែនៅពេលដែលអ្នកក្រឡេកមើលជីវិតរបស់ពួកគេ អ្នកឃើញថា ពួកគេមិនដេញតាមភាពបរិសុទ្ធ និងសេចក្ដីពិតទេ។ ហើយពួកគេក៏មិនស្រឡាញ់ព្រះ និងអ្នកដទៃនោះដែរ។ លោកយ៉ូហានមានប្រសាសន៍ថា មនុស្សគ្រប់គ្នាដែល**កើតពីព្រះ**នឹងមានលក្ខណៈ៤យ៉ាង គឺ ភាពបរិសុទ្ធ សេចក្ដីពិត ការស្រឡាញ់ព្រះ និងការស្រឡាញ់អ្នកដទៃ។ សូមស្ដាប់ នៅក្នុង១យ៉ូហាន ៣:១០ ៖ *«គឺយ៉ាងនោះហើយដែលនឹងសំគាល់ថា ជាពួក**កូនព្រះ**ឬពួកកូនអារក្សទៅបាន ឯអ្នកណាដែលមិន**ប្រព្រឹត្តសេចក្តីសុចរិត** ហើយមិន**ស្រឡាញ់ដល់បងប្អូន** នោះមិនមែនមកពីព្រះទេ»*។ នៅក្នុងខនេះលោកបានភ្ជាប់បណ្ដាញ ការ«កើតពីព្រះ» ជាមួយនឹង «ចូរបរិសុទ្ធ» និង «ស្រឡាញ់គ្នា» ដូចក្នុងរូបទាំងពីរនេះ។




*«អ្នកណាដែលមិន**ប្រព្រឹត្តសេចក្តីសុចរិត** ...មិនមែន**មកពីព្រះ**ទេ»។ (១យ៉ូហាន ៣:១០ ខ)*




*«អ្នកណាដែល...មិនស្រឡាញ់ដល់បងប្អូន នោះ មិនមែនមកពីព្រះទេ»។ ( ១យ៉ូហាន ៣:១០ គ )*

សំណាញ់សុវត្ថិភាពដែលមិនត្បាញភ្ជាប់គ្នានៅកណ្ដាល និងចងយ៉ាងមាំនៅជ្រុង នឹងត្រូវបរាជ័យ។ លោកយ៉ូហានស្រឡាញ់យើង គាត់ចង់ឲ្យយើងពេញដោយអំណរ។ នៅក្នុងជំពូកទាំងប្រាំនៃកណ្ឌគម្ពីរយ៉ូហានខ្សែទី១ ហើយក្នុងយ៉ូហានខ្សែទី២ និងយ៉ូហានខ្សែទី៣ផង យើងនឹងឃើញលោកយ៉ូហានត្បាញទាំងប្រាំចំណុចបញ្ចូលគ្នាម្ដងហើយម្ដងទៀត ដើម្បីបង្កើតសំណាញ់សុវត្ថិភាពដ៏រឹងមាំសម្រាប់យើង។

ក្នុងការសិក្សាកណ្ឌគម្ពីរយ៉ូហានខ្សែទី១ ពេលណាយើងឃើញថា លោក យ៉ូហានកំពុងផ្សារភ្ជាប់គោលការណ៍ពីរជាមួយគ្នា យើងនឹងគូសព្រួញលើសំណាញ់សុវត្ថិភាពរបស់លោកយ៉ូហាន ដើម្បីបង្ហាញការដែលលោកយ៉ូហានផ្សារភ្ជាប់នោះ ដូចដែលយើងបានធ្វើនៅឧទាហរណ៍ខាងលើ។

នៅទំព័រ២៨ អ្នកនឹងឃើញសំណាញ់សុវត្ថិភាពពេញលេញរបស់លោកយ៉ូហាន ដែលមានគ្រប់ដំណ ដែលខ្ញុំបានឃើញក្នុងកណ្ឌគម្ពីរយ៉ូហានខ្សែទី១ ទី២ និងទី៣ ជាមួយនឹងជំពូក និងខផងដែរ។ ព្រះស្រឡាញ់យើងខ្លាំងណាស់ ដែលទ្រង់បានផ្ដល់សំណាញ់សុវត្ថិភាពដ៏រឹងមាំដល់យើង ដើម្បីការពារយើងពីគ្រូក្លែងក្លាយ។

ទីបញ្ចប់ ហេតុអ្វីបានជាលោកយ៉ូហាន លោកប៉ុល លោកពេត្រុស និងលោកយូដាស មិនដែលខានព្រមាន ក្រុមជំនុំអំពីការបង្រៀនក្លែងក្លាយ និងគ្រូក្លែងក្លាយ? ពីព្រោះព្រះយេស៊ូវគ្រីស្ទ ដែលជាម្ចាស់របស់ពួកគាត់ មិនដែលខានព្រមានពួកគាត់ ពីគ្រូ

ក្លែងក្លាយឡើយ។ នៅពេលពួកសិស្សបានសួរអំពីគ្រាចុងក្រោយ ការព្រមានដំបូងរបស់ព្រះយេស៊ូវ គឺអំពីព្រះគ្រីស្ទក្លែងក្លាយ៖ *«ចូរប្រយ័ត្ន ក្រែងអ្នកណានាំអ្នករាល់គ្នាឲ្យវង្វេង ដ្បិតនឹងមានមនុស្សជាច្រើន យកឈ្មោះខ្ញុំមកនិយាយថា ខ្ញុំនេះជាព្រះគ្រីស្ទ ហើយអ្នកទាំងនោះនឹងនាំមនុស្សជាច្រើនឲ្យវង្វេងចេញផង»* (ម៉ាថាយ ២៤:៤-៥)។ (ហើយមើល ម៉ាថាយ ៧:១៥-២០; ១៦:១១-១២; ២៣:១-២៩; ២៤:១១, ២៣-២៧; លូកា ៦:២៦ ។ល។ )។

សូមកុំភ្លេចថា យើងមានសត្រូវដ៏ពូកែ និងឆ្លាតវាងវៃដែលចង់លួចអំណរ ភាពបរិសុទ្ធ សេចក្តីពិត និងជីវិតអស់កល្បរបស់យើង ហើយទីបញ្ចប់នាំឲ្យយើងទៅស្ថាននរក។ វាមិនដែលឈប់បង្កើតព្រះគ្រីស្ទក្លែងក្លាយ និងគ្រូក្លែងក្លាយ ព្រមទាំងគ្រីស្ទបរិស័ទក្លែងក្លាយឡើយ។ បើយើងចង់បង្រៀនដូចជាព្រះយេស៊ូវបានបង្រៀន ហើយបើយើងចង់ស្រឡាញ់ចៀមយើង ដូចជាព្រះយេស៊ូវស្រឡាញ់ចៀមរបស់ទ្រង់ នោះយើងមិនត្រូវឈប់ព្រមានអំពីគ្រូក្លែងក្លាយឡើយ។

ឥឡូវសូមសិក្សាសំបុត្រដ៏អស្ចារ្យនេះជាមួយគ្នាពីខមួយទៅខមួយ ហើយឃើញពីរបៀបដែលសាវកយ៉ូហាន បានត្បាញសំណាញ់សុវត្ថិភាពនៃសេចក្តីស្រឡាញ់សម្រាប់អំណរអស់កល្បជានិច្ចរបស់យើង។


«ព្រះជាពន្លឺ»
1:5
ចូរបរិសុទ្ធ
ជឿការពិត
1:6
2:14c
3:4
3:23a
5:5
5:4b
2 Jn 4
1:6
1:7
2:1
2:3,4
2:6
2:15
2:17b
2:29
3:6
3:7,8
3:9,10a
3:23,24
5:4a
5:18
3 Jn 11
1:6
2:17
2:19,20
2:23,24
2:27 anointing
4:2-3
4:5,6
4:15,16a
5:1a
5:10
5:13
2 Jn 9,10,11
"ជីវិត"
1:1,2
2:17,25
3:14,15
5:11,12,13,20
"ព្រះវរបិតា"
1:2,3
2:1,13,15,16
22,23,24
"ព្រះវិញ្ញាណ"
2:20,27
3:24
4:2,6,13
5:6,8
កើតពីព្រះ
3:1-2
"ព្រះរាជបុត្រា" និង សេចក្ដីសង្គ្រោះ
1:7 ព្រះលោហិតនៃព្រះយេស៊ូវ
1:9 ការអត់ទោសបាប
2:1 ព្រះដ៏ជាជំនួយយើង
2:2;4:10 ដង្វាយធួននឹងបាប
2:17,25 ជីវិតអស់កល្បជានិច្ច
3:1 សេចក្ដីស្រឡាញ់របស់ព្រះ
3:3 កូនរបស់ព្រះ
3:5 អំពើបាបបានដកហូត
3:7 រស់ជាសុចរិត
3:8b ការងាររបស់អារក្សត្រូវបាន បំផ្លាញ
3:14 ផុតពីសេចក្ដីស្លាប់ទៅដល់ជីវិត
3:15 ជីវិតអស់កល្បជានិច្ច
4:6 ស្គាល់ព្រះជាម្ចាស់
4:9,14 ព្រះចាត់ព្រះរាជបុត្រា
4:13 ព្រះបានប្រទានព្រះវិញ្ញាណ
2:5
4:21
5:3
2 Jn 1
3:23
3:19
3:18
3:11
2:11
2:9,10
5:1b
5:10
3:12b
3:23b
4:17
3:10b
3:12
3:14
3:15,16
3:17
4:7
4:8
4:11
4:12
4:10
4:16b
4:17,18
4:19
5:21
4:21
5:2b
2 Jn 6
2 Jn 5
3:17
4:20
4:21
5:1b
5:2a
ស្រឡាញ់ព្រះ
ស្រឡាញ់គ្នា
4:8
«ព្រះជាសេចក្ដីស្រឡាញ់»

# បុព្វកថា៖
# ព្រះដែលមានព្រះជន្មគង់នៅអស់កល្បបានយាងមក ហើយទ្រង់ជាពន្លឺ និងសេចក្តីស្រឡាញ់

## ១យ៉ូហាន ១:១-៥

*១យ៉ូហាន ១:១*
*ឯសេចក្តីដែលមានតាំងពីដើមមក ដែលយើងខ្ញុំបានឮ ហើយភ្នែកបានឃើញ ក៏បានមើល ហើយដៃបានប៉ះពាល់ ខាងឯព្រះបន្ទូលនៃជីវិត...*

លោកយ៉ូហានមិនបានចាប់ផ្តើមសំបុត្ររបស់គាត់ ដោយនិយាយអំពី**ការកុហកនៃក្រុមក្លែងក្លាយ**ទេ ប៉ុន្តែគឺអំពី**សេចក្តីពិត**នៃជំនឿព្រះគ្រីស្ទវិញ ជាពិសេសសេចក្តីពិតដែលថា ព្រះយេស៊ូវបានយាងមកពីស្ថានសួគ៌ ដើម្បីសម្តែងពីព្រះជាម្ចាស់ដល់មនុស្សជាតិ។

ព្រះយេស៊ូវ ពីស្រុកណាសារ៉ែត ដែលជាព្រះគ្រីស្ទ(ព្រះមែស៊ី) ហើយជាព្រះរាជបុត្រានៃព្រះ គឺជាចំណុចសំខាន់ជាងគេក្នុងដំណឹងល្អពិត។ លោកយ៉ូហាននិយាយអំពីព្រះគ្រីស្ទនេះ នៅពេលគាត់និយាយថា *«ឯសេចក្តីដែលមានតាំងពីដើមមកដែលយើងខ្ញុំបានឮ ហើយភ្នែកបានឃើញ ហើយដៃបានប៉ះពាល់ ខាងឯព្រះបន្ទូលនៃជីវិត...»*។ (សូមសម្គាល់ពីការស្រដៀងគ្នាជាច្រើន រវាងបុព្វកថា នៅកណ្ឌនេះ និងបុព្វកថានៅកណ្ឌគម្ពីរយ៉ូហានដំណឹងល្អ)។

# ព្រះរាជបុត្រាដែលគង់នៅអស់កល្បជានិច្ចបានកើតជាមនុស្ស

## ព្រះរាជបុត្រាដែលគង់នៅអស់កល្បជានិច្ច...

សូមចាំថា ឃ្លាដែលថា *«តាំងពីដើមមក»* គឺជារបៀបដែលជនជាតិយូដា និយាយអំពីព្រះដែលគង់នៅអស់កល្បជានិច្ច ហើយគ្មានទីចាប់ផ្ដើមឡើយ (សូមមើល យ៉ូហាន ១:១ ដែរ)។ អ៊ីចឹងលោកយ៉ូហានកំពុងនិយាយថា ព្រះរាជបុត្រានៃព្រះមិនដែលមានការចាប់ផ្ដើមឡើយ។ ទ្រង់គង់នៅអស់កល្បជានិច្ច។ មុនពេលព្រះរាជបុត្រានៃព្រះបានបង្កើតពួកទេវតាមក នោះទ្រង់គង់នៅហើយ។ មុនពេលព្រះរាជបុត្រានៃព្រះបានបង្កើតផ្ទៃមេឃ និងផែនដីមក នោះទ្រង់គង់នៅហើយ។ មានតែព្រះដែលគង់នៅតាំងពីអស់កល្បជានិច្ច ដែលអាចមានវត្តមាន *«តាំងពីដើមមក»*។

## ...បានកើតជាមនុស្ស

ប៉ុន្តែ ឧបន្ទាប់មក លោកយ៉ូហានមានប្រសាសន៍ដែលអស្ចារ្យពេកស្ទើរតែជឿមិនបាន។ ព្រះរាជបុត្រានៃព្រះដែលមិនដែលមានដើមកំណើតនេះ **បានកើតជាមនុស្ស** ហើយបានរស់នៅក្នុងចំណោមយើងរាល់គ្នា ដើម្បីសម្ដែងតួអង្គព្រះដល់យើង។ ទ្រង់ថែមទាំងបានជ្រើសរើសក្រុមសាក្សីជាផ្លូវការ ដើម្បីស្ដាប់ទ្រង់ មើលទ្រង់ ឃើញទ្រង់ ហើយថែមទាំងបានប៉ះទ្រង់ទៀតផង។ ពាក្យ «យើង» នៅក្នុងខ១-៤ សំដៅទៅសាក្សីទាំងនេះ។ យើងហៅពួកនេះថា ពួកសាវក ហើយលោកយ៉ូហានជាម្នាក់ក្នុងចំណោមពួកគេ។ យើងមិនត្រូវញែកព្រះយេស៊ូវ និងសាក្សីពិសេសរបស់ទ្រង់ចេញពីគ្នាឡើយ។ គ្រីស្ទសាសនាពិត គឺជាសាសនារបស់ព្រះយេស៊ូវ និងពួកសាវកដែលព្រះអង្គបានជ្រើសរើស។

*«ដែលយើងខ្ញុំបានឮ...បានឃើញ...បានប៉ះ...»* សូមកត់សម្គាល់ថា ព្រះយេស៊ូវមិនគ្រាន់តែលេចមកឲ្យសាក្សីឃើញមួយភ្លែត ដូចជាខ្មោចនោះទេ ប៉ុន្តែទ្រង់គង់នៅជាមួយពួកគេទាំងយប់ទាំងថ្ងៃអស់រយៈពេល៣ឬ៤ឆ្នាំ! យើងខ្លះធ្លាប់មានបទពិសោធន៍ធ្វើជាសាក្សីបញ្ជាក់ពីគ្រោះថ្នាក់ចរាចរណ៍។ ប៉ុន្តែនៅពេលប៉ូលិសសួរយើងពីអ្វីដែលបានកើតឡើង យើងប្រហែលជានិយាយបែបនេះវិញថា «វាបានកើតឡើងលឿនពេក ខ្ញុំពិបាកចាំថា ម៉ូតូបុកឡាន ឬក៏ឡានបុកម៉ូតូ»។ ប៉ុន្តែនៅពេលដែលព្រះយេស៊ូវបានយាងមក ទ្រង់មិនបានបង្ហាញអង្គទ្រង់តែមួយភ្លែតៗបែបនោះឡើយ។ ទ្រង់បានចំណាយពេលពី៣ទៅ៤ឆ្នាំ ជាមួយសាក្សីដែលបានឃើញផ្ទាល់ភ្នែក ពីមួយម៉ោងទៅមួយម៉ោង ពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយយប់ទៅមួយយប់ នៃការដើរ ការនិយាយ ការបរិភោគ ការអធិស្ឋាន និងការស្តាប់។ ខ្ញុំគណនាថា ពួកសាវកម្នាក់ៗបានចំណាយពេល ១ ឬ ២ ម៉ឺនម៉ោង ធ្វើជាសាក្សីនៃព្រះយេស៊ូវគ្រីស្ទ។ បើយើងគុណចំនួននោះជាមួយនឹងសាវកទាំង១២នាក់នោះឃើញថា មានភ័ស្តុតាងបញ្ជាក់អំពីព្រះយេស៊ូវប្រហែល ១០ ឬ ២០ ម៉ឺនម៉ោងរួមគ្នា។ បើយើងបន្ថែមសាក្សីរាប់សិបនាក់ផ្សេងទៀត នៅក្នុងក្រុមដែលបានធ្វើដំណើរជាមួយគ្នា ចំនួនម៉ោងនឹងជិតកន្លះលានម៉ោងឯណោះ! គ្រីស្ទសាសនា គឺជាសាសនានៃប្រវត្តិសាស្ត្រដ៏ពិតពីព្រោះមានសាក្សីរាប់រយ រាប់ពាន់នាក់ដែលបានឃើញផ្ទាល់ភ្នែកក្នុងរយៈពេលជាច្រើនឆ្នាំ។

មិនតែប៉ុណ្ណោះ សាក្សីផ្ទាល់ភ្នែកទាំងនេះ មិនគ្រាន់តែឃើញព្រះយេស៊ូវពីចម្ងាយនោះទេ ពួកគេបានរស់នៅជាមួយទ្រង់ បានមើលទ្រង់យ៉ាងជិតស្និទ្ធ បានស្តាប់ទ្រង់ ហើយថែមទាំងបានប៉ះទ្រង់ដោយដៃគេផ្ទាល់ទៀត។ ពាក្យចុងក្រោយអំពីការប៉ះទ្រង់ដោយដៃរបស់ពួកគេ គឺជាការពិបាកទទួលយក សម្រាប់មនុស្សជាច្រើននៅសម័យលោកយ៉ូហាន។ ហេតុអ្វី? ពីព្រោះទស្សនវិជ្ជាដែលមានប្រជាប្រិយបំផុត

ក្នុងចំណោមសាសន៍ក្រេក និងរ៉ូមនៅសម័យបុរាណបានបង្រៀនថា វិញ្ញាណមនុស្ស គឺល្អ ហើយរូបកាយអាក្រក់។ ដូច្នេះនៅពេលដែលពួកគេបានឮថា ព្រះរាជបុត្រានៃព្រះដែលជាវិញ្ញាណសុទ្ធសាធនៅស្ថានសួគ៌ បានកើតជាមនុស្ស ហើយយករូបកាយជាមនុស្ស គេស្អប់ខ្ពើមណាស់ ហើយគេថា មិនអាចកើតមានទេ! ហើយនៅពេលគេឮថា ព្រះរាជបុត្រានៃព្រះ បានសុគតនៅលើឈើឆ្កាងដូចជាឧក្រិដ្ឋជន វាកាន់តែគួរឲ្យស្អប់ខ្ពើមថែមទៀត។ ហើយនៅពេលដែលពួកគេឮទៀតថា ព្រះយេស៊ូវ ក្រោយដែលទ្រង់ត្រូវបានដោះលែងពីគុកនៃរូបកាយរបស់ទ្រង់ នោះទ្រង់បានទទួលយករូបកាយនោះវិញ នៅពេលទ្រង់រស់ពីសុគត វាក្លាយជារឿងកំប្លែងសម្រាប់ពួកគេទៅវិញ។ ពួកគេមិនអាចជឿការនេះទេ ដំណឹងល្អបែបនោះជាការជំពប់ដួលយ៉ាងខ្លាំងសម្រាប់មនុស្សសម័យបុរាណ (សូមមើល ១កូរិនថូស ១:២២-២៥)។

នេះហើយជាមូលហេតុមួយដែលលោកយ៉ូហានត្រូវសរសេរសំបុត្រនេះឡើង។ នៅពេលយើងអានកណ្ឌយ៉ូហានខ្សែទី១ យើងឃើញថា មនុស្សខ្លះដែលអះអាងថា ជាគ្រូមកពីព្រះ បាននាំយកទស្សនវិជ្ជាក្រេកនេះ ចូលក្នុងគ្រីស្ទសាសនារបស់ពួកគេ។ ពួកគេបាននិយាយថា ព្រះយេស៊ូវមិនបានយាងមកក្នុងសាច់ឈាមទេ តែគ្រាន់តែ**ហាក់ដូចជា**ចូលមកក្នុងសាច់ឈាមប៉ុណ្ណោះ។ លោកយ៉ូហានបានបដិសេធការបង្រៀននេះយ៉ាងខ្លាំង ព្រោះគាត់ផ្ទាល់បាននៅជាមួយព្រះយេស៊ូវរាល់ថ្ងៃអស់រយៈពេល៣ឬ៤ឆ្នាំ។ គាត់ដឹងច្បាស់ដោយគ្មានសង្ស័យថា ព្រះយេស៊ូវជាមនុស្សពិតដែលមានសាច់ និងឈាមពិតប្រាកដ។ ពួកសាវកបានបរិភោគជាមួយនឹងទ្រង់ ដើរជាមួយនឹងទ្រង់ ហើយនិយាយជាមួយនឹងទ្រង់ផង។ លោកយ៉ូហានថែមទាំងបាន *«ផ្អែកលើព្រះឱរា»* ព្រះយេស៊ូវ នៅអាហារពេលល្ងាចចុងក្រោយថែមទៀតផង (យ៉ូហាន ២១:២០)។

*«ខាងឯព្រះបន្ទូលនៃជីវិត»* បន្ទាប់ពី ១ ឬ ២ម៉ឺនម៉ោងនៃការស្តាប់ និងមើលព្រះយេស៊ូវ លោកយ៉ូហាន និងសាវកផ្សេងទៀតបានជឿជាក់ថា ព្រះយេស៊ូវគឺជា *«ព្រះបន្ទូលនៃជីវិត»* ដែលព្រះបានបញ្ជូនមក។ ព្រះជាម្ចាស់ជាប្រភពជីវិតតែមួយគត់ មិនថាជីវិតខាងរូបកាយ ឬជីវិតខាងវិញ្ញាណនោះទេ។ បើព្រះយេស៊ូវពីស្រុកណាសារ៉ែតក៏ជា *«ព្រះបន្ទូលនៃជីវិត»* នោះទ្រង់ត្រូវតែជាព្រះមួយរយភាគរយ និងជាមនុស្សមួយរយភាគរយក្នុងបុគ្គលតែមួយ។

## *១យ៉ូហាន ១:២*

*ដ្បិតព្រះដ៏ជាជីវិតទ្រង់បានលេចមកហើយ យើងខ្ញុំបានឃើញទ្រង់ ហើយក៏ធ្វើជាទីបន្ទាល់ប្រាប់ដល់អ្នករាល់គ្នា ពីជីវិតនោះដ៏រស់នៅអស់កល្បជានិច្ច ដែលពីដើមស្ថិតនៅនឹងព្រះវរបិតា ហើយបានលេចមកឲ្យយើងខ្ញុំ។*

*«ឃើញ...ធ្វើជាទីបន្ទាល់...ប្រាប់...»* លោកយ៉ូហាន ប្រើភាសាតុលាការដ៏ឧឡារិកនៅក្នុងខនេះ។ គាត់ និងពួកសាវកផ្សេងទៀតគឺជាសាក្សីផ្លូវការ ដែលគួរឲ្យទុកចិត្តទាំងស្រុង។ ជាថ្មីម្តងទៀត ពាក្យ *«យើងខ្ញុំ»* រំឭកយើងថា នេះគឺជាសក្ខីភាពរបស់ពួកសាវកនៃព្រះយេស៊ូវ ដែលព្រះអង្គបានជ្រើសរើសជាស្មរបន្ទាល់ជាផ្លូវការ។

*«ជីវិតនោះដ៏រស់នៅអស់កល្បជានិច្ច...លេចមក»* ព្រះយេស៊ូវគ្រីស្ទបានយករូបកាយជាមនុស្សពិត ដើម្បីសង្គ្រោះយើងពីអំពើបាបរបស់យើង។

*«ប្រាប់ដល់អ្នករាល់គ្នា...»* ឃ្លានេះណែនាំពីហេតុការណ៍ថ្មីពីរនៃដំណឹងល្អ គឺពាក្យ *«ប្រាប់»* និងពាក្យ *«អ្នករាល់គ្នា»*៖

> ពាក្យ ***«ប្រាប់»*** បង្រៀនយើងថា អ្វីៗទាំងអស់ដែលពួកសាវកបានឃើញ និងឮក្នុងកំឡុង៣ឬ៤ឆ្នាំ ពួកគេបានបន្តប្រាប់ជាសេចក្តីប្រកាសជាសាធារណៈ និងជាផ្លូវការ។ សារនេះត្រូវបានគេហៅថា ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។ បើ

និយាយពេញលេញហៅថា គម្ពីរសញ្ញាថ្មី។ វាប្រៀបដូចជាសារជាផ្លូវការពីព្រះមហាក្សត្រ ដែលសរសេរដោយលេខាធិការរបស់ព្រះអង្គ ជាសារដែលយើងមិនត្រូវធ្វេសប្រហែសឡើយ!

ពាក្យ *«អ្នករាល់គ្នា»* បង្រៀនយើងថា វាជាព្រះហឫទ័យព្រះ ដើម្បីឲ្យសារដ៏សំខាន់អំពីព្រះយេស៊ូវនេះ ទៅបន្តប្រាប់ដល់មនុស្សឯទៀត ក្រៅពីពួកសាវក។ តាមពិតពាក្យ*«អ្នករាល់គ្នា»* ក៏រួមបញ្ចូលទាំងអ្នក និងខ្ញុំផងដែរ ២០០០ឆ្នាំក្រោយមក គឺយើងដែលបានឮដំណឹងល្អពីព្រះយេស៊ូវតាមរយៈសារជាលាយលក្ខណ៍អក្សរ ដែលគេហៅថាព្រះគម្ពីរបរិសុទ្ធ។

## *១យ៉ូហាន ១:៣*

*ដូច្នេះសេចក្តីដែលយើងខ្ញុំបានឃើញ ហើយឮ នោះយើងខ្ញុំប្រាប់មកអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាមានសេចក្តីប្រកបនឹងយើងខ្ញុំដែរ រីឯសេចក្តីប្រកបរបស់យើងខ្ញុំនោះ គឺប្រកបនឹងព្រះវរបិតា ហើយនិងព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រាទ្រង់។*

អ្វីទាំងអស់ដែលលោកយ៉ូហាន និងសាវកឯទៀតបានឃើញព្រះយេស៊ូវធ្វើ ហើយឮព្រះយេស៊ូវមានបន្ទូល ឥឡូវនេះពួកគេកំពុងប្រកាសប្រាប់ដល់អ្នកដទៃទៀត។ ហេតុអ្វី បានជាពួកគេត្រូវប្រាប់បន្ត? លោកយ៉ូហានបានផ្តល់មូលហេតុពីរយ៉ាង៖ ដើម្បីឲ្យអ្នកស្តាប់នឹងមាន**សេចក្តីប្រកប**ជាមួយព្រះ(ខ៣) ហើយមាន**អំណរ**អស់កល្បជានិច្ច(ខ៤)។ ឥឡូវយើងនឹងមើលមូលហេតុទាំងពីរនេះ៖

**ដើម្បីឲ្យយើងមានការប្រកបជាមួយព្រះ។** ពួកសាវកប្រាប់យើងអំពីព្រះយេស៊ូវ ដើម្បីឲ្យយើងដែលស្តាប់ និងជឿ អាចមានការប្រកបជាមួយពួកសាវក និងជាមួយព្រះដ៏ជាព្រះវរបិតា និងជាមួយព្រះយេស៊ូវគ្រីស្ទដ៏ជាព្រះរាជបុត្រាទ្រង់។ ការប្រកបជាមួយព្រះ គឺជាអំណោយដ៏អស្ចារ្យបំផុតក្នុងលោក។ វាមានន័យថា

ព្រះបានដកអំពើបាប និងការបះបោររបស់យើងដែលរារាំងយើងមិនឲ្យធ្វើជាកូនរបស់ព្រះអម្ចាស់ចេញ។ បើប្រើពាក្យនៃគម្ពីរសញ្ញាចាស់ គឺមានន័យថា ព្រះបានត្រឡប់ជាព្រះរបស់យើង ហើយយើងបានត្រឡប់ជារាស្ត្ររបស់ទ្រង់។

**ដើម្បីឲ្យយើងមានអំណរអស់កល្បជានិច្ច។** ពួកសាវកប្រាប់យើងអំពីព្រះយេស៊ូវ ដើម្បីឲ្យអំណររបស់យើងបានពោរពេញឡើង។ តើអ្នកចង់មានអំណរជារៀងរហូតទេ? អ្នកត្រូវតែជឿដំណឹងល្អដែលពួកសាវកបានប្រកាសប្រាប់អំពីព្រះយេស៊ូវគ្រីស្ទ ដែលព្រះបានបញ្ជូនមក។ អស់អ្នកដែលប្រែចិត្តហើយជឿដល់ព្រះយេស៊ូវ នឹងមិនត្រូវវិនាសឡើយ គឺមានជីវិតអស់កល្បជានិច្ច និងអំណរអស់កល្បជានិច្ច។ មានតែដំណឹងល្អពិតដែលនាំមកនូវអំណរអស់កល្បជានិច្ច។ ដំណឹងល្អក្លែងក្លាយរបស់គ្រូខុសឆ្គង នាំមកនូវភាពអាម៉ាស់ និងការដាក់ទោសអស់កល្បជានិច្ច។

## ធាតុចាំបាច់ទាំងប្រាំនៃដំណឹងល្អពិត

ចូរអាន ១យ៉ូហាន ១:៣ ម្តងទៀត ហើយសូមសម្គាល់ថា ខនេះមានធាតុចាំបាច់ប្រាំនៃដំណឹងល្អពិត។ បើយើងបដិសេធធាតុណាមួយក្នុងចំណោមប្រាំនេះ មានន័យថា យើងជឿដំណឹងល្អក្លែងក្លាយវិញ។ សូមសម្គាល់ធាតុចាំបាច់ទាំងប្រាំ នៅក្នុងការណែនាំរបស់លោកយ៉ូហាន ដែលខ្ញុំបានដាក់បន្ទាត់ពីក្រោម៖

*«ដូច្នេះសេចក្ដីដែល<u>យើងខ្ញុំ</u>បានឃើញ ហើយឮ នោះយើងខ្ញុំ<u>ប្រាប់</u>មក<u>អ្នករាល់គ្នា</u> ដើម្បីឲ្យអ្នករាល់គ្នាមានសេចក្ដីប្រកបនឹងយើងខ្ញុំដែរ រីឯសេចក្ដីប្រកបរបស់យើងខ្ញុំនោះ គឺប្រកបនឹង<u>ព្រះវរបិតា</u> ហើយនិង<u>ព្រះយេស៊ូវគ្រីស្ទ</u>ជាព្រះរាជបុត្រាទ្រង់»។*

តើអ្នកបានឃើញធាតុចាំបាច់ទាំងប្រាំទេ? **ព្រះជាម្ចាស់** (១) បានប្រទាន **ព្រះយេស៊ូវគ្រីស្ទ** (២) ដែលបានជ្រើស **ពួកសាវក** (៣) ឲ្យប្រកាស **ដំណឹងល្អ** (៤) ដល់**មនុស្សទាំងអស់** (៥)។ យើងអាចចំណាំធាតុទាំងប្រាំនេះ ដោយចង្អុលទៅ ម្រាមដៃខាងឆ្វេងរបស់យើង។ យើងនឹងចាប់ផ្ដើមនឹងមេដៃ (ព្រះជាម្ចាស់) រហូតដល់កូនដៃ (មនុស្ស) ហើយត្រឡប់ទៅព្រះវិញ។



ធាតុចាំបាច់ប្រាំនៅក្នុងដំណឹងល្អ

មុននឹងចាប់ផ្ដើមសូមសម្គាល់ពីការពិតដែលគួរឲ្យសោកស្ដាយមួយ គឺ**ព្រះ**(១) និង **មនុស្ស**(៥) ដាច់ចេញឆ្ងាយពីគ្នា ពីព្រោះយើងបានចូលរួមជាមួយអារក្សសាតាំងក្នុងការបះបោរទាស់នឹងព្រះជាម្ចាស់ ហើយបានស្រឡាញ់របស់ដែលព្រះអង្គបានបង្កើតជាជាងស្រឡាញ់អ្នកបង្កើត។ តើព្រះជាម្ចាស់បានធ្វើអ្វី ដើម្បីដោះស្រាយស្ថានភាពវេទនារបស់យើង? ចូរចង្អុលទៅម្រាមដៃរបស់អ្នកនៅពេលយើងប្រាប់ដំណឹងល្អជាមួយគ្នា៖

ដោយសារព្រះអង្គស្រឡាញ់យើង **ព្រះ** (១) ដែលជាពន្លឺ និងសេចក្ដីស្រឡាញ់ បានចាត់ **ព្រះយេស៊ូវគ្រីស្ទ** (២) ជាព្រះរាជបុត្រារបស់ទ្រង់ ដើម្បីធ្វើជាអ្នកសង្គ្រោះនៃពិភពលោក។ ព្រះយេស៊ូវបានជ្រើសរើស **សាវក១២នាក់** (៣) ឲ្យធ្វើជាសាក្សីជាផ្លូវការរបស់ទ្រង់។ ពួកសាវកទាំងនោះបានចំណាយពេលជាង៣ឆ្នាំជាមួយព្រះយេស៊ូវ ហើយអ្វីដែលពួកគេបានឃើញ និងឮ ពួកគេបាន **ប្រកាសប្រាប់**

**តាមរយៈដំណឹងល្អដែលនិយាយ និងសរសេរ** (៤) ដល់**មនុស្សទាំងអស់** (៥)។ (ឥឡូវយើងដើរបញ្រ្ចាសវិញ)។ **មនុស្សទាំងអស់** (៥) ដែលស្តាប់ និងជឿ ដល់ **ដំណឹងល្អ** (៤) ទទួលបានការប្រកបគ្នាជាមួយ **ពួកសាវក** (៣) និង **ព្រះយេស៊ូវគ្រីស្ទ** (២) និង**ព្រះវរបិតា** (១)។

ការប្រកបគ្នាយ៉ាងជិតស្និទ្ធនេះ ជាមួយព្រះជាម្ចាស់ និងព្រះគ្រីស្ទ និងពួកសាវក បាន បង្ហាញនៅក្នុងរូបភាពខាងស្តាំ ដែលម្រាមទាំងប្រាំរួមគ្នាតែមួយក្នុង សេចក្តី ស្រឡាញ់ និងការប្រកបគ្នា។ ដំណឹងល្អនៃការប្រកបជាមួយព្រះ តាមរយៈព្រះគ្រីស្ទ នាំមកនូវជីវិត និងអំណរអស់កល្បជានិច្ច។

**តើព្រះវិញ្ញាណបរិសុទ្ធនៅឯណានៅក្នុងជំហានទាំងប្រាំនេះ?**

ព្រះវិញ្ញាណបរិសុទ្ធមានសកម្មភាពនៅគ្រប់ជំហាន៖

- ជំហាន១៖ ព្រះវិញ្ញាណជាព្រះវិញ្ញាណរបស់**ព្រះជាម្ចាស់**។
- ជំហាន២៖ ព្រះវិញ្ញាណជាព្រះវិញ្ញាណដែលបានបំពេញ**ព្រះយេស៊ូវ**។ (*«ព្រះវិញ្ញាណព្រះអម្ចាស់សណ្ឋិតលើខ្ញុំ...»* លូកា ៤:១៨។ ព្រះវិញ្ញាណបរិសុទ្ធជា*«វិញ្ញាណនៃព្រះយេស៊ូវគ្រីស្ទ»* ភីលីព ១:១៩)។
- ជំហាន៣៖ ព្រះយេស៊ូវបានប្រទានព្រះវិញ្ញាណដល់**ពួកសាវក**។ (*«ទ្រង់ផ្លុំលើគេទាំងមានបន្ទូលថា ចូរទទួលព្រះវិញ្ញាណបរិសុទ្ធចុះ»* យ៉ូហាន ២០:២២)។
- ជំហាន៤៖ ព្រះវិញ្ញាណបរិសុទ្ធបានណែនាំអ្នកដែលផ្សាយ**ដំណឹងល្អ** និងសរសេរ**បទគម្ពីរ** (២ពេត្រុស ១:២១)។
- ជំហាន៥៖ ព្រះវិញ្ញាណបរិសុទ្ធបានបង្កើត និងបំពេញ**ពួកជំនុំ**របស់ទ្រង់ (កិច្ចការ ២)។

យើងត្រូវមានធាតុចាំបាច់ទាំងប្រាំនេះ ដើម្បីបានគ្រីស្ទសាសនាពិត។ ប៉ុន្តែពេលខ្លះ មនុស្សចង់បដិសេធធាតុមួយ ឬពីរនៃធាតុទាំងនេះ។ ឧទាហរណ៍៖

**ការបដិសេធរាស្ត្ររបស់ព្រះ** (ជំហាន៥)។ ខ្ញុំមានមិត្តម្នាក់ដែលបាននិយាយថា «ខ្ញុំធុញទ្រាន់នឹងក្រុមជំនុំ ដែលតែងតែធ្វើឲ្យខ្ញុំខកចិត្ត ខ្ញុំអត់ត្រូវការពួកជំនុំទេ។ ខ្ញុំមានព្រះគម្ពីរ ហើយខ្ញុំមានព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយខ្ញុំគ្រប់ពេល ដូច្នេះខ្ញុំនឹងឈប់ចូលរួមជាមួយរាស្ត្ររបស់ព្រះទៀត ហើយខ្ញុំនឹងគោរពថ្វាយបង្គំ និងដើរតាមព្រះដោយខ្លួនឯងវិញ»។ អ្នកនេះអះអាងថា គាត់ដើរតាមព្រះយេស៊ូវ ប៉ុន្តែគាត់បដិសេធ**រាស្ត្ររបស់ព្រះ**(៥) ដែលព្រះគ្រីស្ទបានប្រទានជីវិត ដើម្បីសង្គ្រោះនោះ។ ក៏ប៉ុន្តែ យើងមិនអាចស្រឡាញ់ព្រះដោយមិនស្រឡាញ់ក្រុមជំនុំរបស់ទ្រង់នោះឡើយ។

**ការបដិសេធដំណឹងល្អពីព្រះ (ឬបទគម្ពីរ)** (ជំហាន៤)។ គ្រីស្ទបរិស័ទខ្លះបដិសេធបទគម្ពីរដែលជាទីបន្ទាល់ និយាយ និងសរសេររបស់ពួកសាវក និងពួកហោរារបស់ព្រះគ្រីស្ទ។ ពួកគេនិយាយថា «ព្រះគម្ពីរមានកំហុស» ឬ «បទគម្ពីរគ្មានអំណាចទេ» ឬ «ព្រះវិញ្ញាណបរិសុទ្ធនិយាយមកខ្ញុំដោយផ្ទាល់ ដូច្នេះព្រះគម្ពីរមិនសំខាន់ប៉ុន្មានទេ» ឬ «មនុស្សដែលសរសេរព្រះគម្ពីរ គ្រាន់តែជាមនុស្ស តែខ្ញុំចង់ស្តាប់ព្រះផ្ទាល់វិញ»។ គំនិតទាំងអស់នេះ មិនមែនជាគ្រីស្ទសាសនាពិតទេ។ បើយើងពិតជាជឿដល់ព្រះយេស៊ូវ យើងនឹងនិយាយដូចទ្រង់ថា *«បទគម្ពីរមិនអាចលើកចោលបានទេ»* (យ៉ូហាន ១០:៣៥ RKOV)។

**ការបដិសេធពួកសាវក** (ជំហាន៣)។ មនុស្សខ្លះនិយាយថា «ខ្ញុំស្រឡាញ់ព្រះយេស៊ូវ ប៉ុន្តែខ្ញុំមិនសូវចូលចិត្ត**ពួកសាវក**របស់ទ្រង់ ជាពិសេសសាវកប៉ុលដែលបាននាំគោលលទ្ធិច្រើនចូលក្នុងជំនឿយើង»។ ប៉ុន្តែ បើយើងបដិសេធពួកសាវករបស់ព្រះគ្រីស្ទ យើងក៏បដិសេធព្រះគ្រីស្ទដែរ (លូកា ១០:១៦)។

**ការបដិសេធព្រះយេស៊ូវ** (ជំហាន២)។ ក្រុមខុសឆ្គងតែងតែផ្ដល់ព្រះយេស៊ូវខុសពីព្រះយេស៊ូវដែលពួកសាវកបានធ្វើបន្ទាល់។

**ការបដិសេធព្រះជាម្ចាស់** (ជំហាន១)។ អ្នកខ្លះនិយាយថា «ខ្ញុំចូលចិត្តព្រះយេស៊ូវ ព្រោះទ្រង់ស្រឡាញ់ និងមានព្រះទ័យសប្បុរស តែខ្ញុំមិនចូលចិត្ត**ព្រះជាម្ចាស់**នៅក្នុងគម្ពីរសញ្ញាចាស់ ដែលពេញដោយសេចក្ដីក្រោធ»។ ប៉ុន្តែព្រះយេស៊ូវមានបន្ទូលម្ដងហើយម្ដងទៀតថា យើងត្រូវតែទទួលយកទាំងព្រះវរបិតា និងព្រះរាជបុត្រា។

សូមកត់សំគាល់ថា ព្រះយេស៊ូវគ្រីស្ទផ្ទាល់បានលើកឡើងធាតុចាំបាច់ទាំង៥ដដែលនេះជាមួយនឹងការប្រកបជាមួយនឹងព្រះ នៅពេលទ្រង់បានអធិស្ឋានសម្រាប់ពួកសាវកនៅយប់ដែលគេចាប់ទ្រង់។ ទ្រង់មានបន្ទូលថា *«ទូលបង្គំមិនអធិស្ឋានឲ្យ**អ្នកទាំងនេះ** [ពួកសាវក] តែប៉ុណ្ណោះ គឺឲ្យដល់ទាំង**អ្នកណា** [មនុស្សយើង] ដែលនឹងជឿដល់**ទូលបង្គំ** [ព្រះយេស៊ូវ] ដោយសារ**ពាក្យរបស់គេ**ថែមទៀតដែរ [ដំណឹងល្អ និងបទគម្ពីរ] ដើម្បីឲ្យទាំងអស់បានរួមមកតែមួយ ឱ**ព្រះវរបិតា**អើយ ទ្រង់គង់ក្នុងទូលបង្គំហើយទូលបង្គំនៅក្នុងទ្រង់ដែរ គឺឲ្យអ្នកទាំងនោះបានរួមគ្នាតែមួយនៅក្នុងយើង ប្រយោជន៍ឲ្យលោកីយ៍បានជឿថា ទ្រង់ចាត់ឲ្យទូលបង្គំមកពិត»* (យ៉ូហាន ១៧:២០-២១)។

***១យ៉ូហាន ១:៤***

*យើងខ្ញុំក៏**សរសេរ**សេចក្ដីទាំងនេះផ្ញើមកអ្នករាល់គ្នា ដើម្បីឲ្យសេចក្ដី**អំណរ**របស់អ្នករាល់គ្នាបានពោរពេញឡើង។*

ចូរយើងគិតមួយភ្លែតអំពីពាក្យ *«សរសេរ»* និង *«សេចក្ដីអំណរ»*៖

*«យើងខ្ញុំក៏សរសេរសេចក្ដីទាំងនេះ...»* ព្រះវិញ្ញាណបរិសុទ្ធបានដឹកនាំលោកយ៉ូហាន និងអ្នកនិពន្ធបទគម្ពីរផ្សេងទៀត ឲ្យ**កត់ទុក**ព្រះរាជសារនេះ អំពីការប្រកបជាមួយនឹងព្រះជាម្ចាស់តាមរយៈព្រះគ្រីស្ទ ដែលនាំឲ្យយើងមានជីវិត និងអំណរអស់កល្បជានិច្ច។ នៅពេលពួកសាវកកត់ទុកដំណឹងល្អនេះ តើដំណឹងល្អទៅជាខ្សោយជាងព្រះបន្ទូលដើម ដែលចេញពីព្រះឱស្ឋរបស់ព្រះយេស៊ូវឬ? តើវាបានបាត់បង់នូវអំណាច និងកំឡាំងខ្លះនៅពេលដែលត្រូវបានសរសេរចុះឬ? អត់សោះ! ខ៤នេះបញ្ជាក់យ៉ាងច្បាស់ថា សូម្បីតែពាក្យសរសេរនៃគម្ពីរ នៅតែនាំយើងឲ្យមានជីវិតអស់កល្ប និងការប្រកបជាមួយព្រះ និងអំណរដ៏ពោរពេញ! ព្រះមានផែនការ ឲ្យព្រះបន្ទូលរបស់ទ្រង់ ត្រូវសរសេរទុកសំរាប់មនុស្សជំនាន់ក្រោយ។ តាមពិតព្រះយេស៊ូវផ្ទាល់ បានបង្គាប់លោកយ៉ូហាន ឲ្យសរសេរព្រះបន្ទូលទ្រង់នៅក្នុងកណ្ឌគម្ពីរវិវរណៈ។ ព្រះយេស៊ូវមានបន្ទូលថា *«ដូច្នេះចូរឲ្យឯង**កត់**អស់ទាំងសេចក្ដីដែលឯងបានឃើញ ព្រមទាំងសេចក្ដីដែលមានសព្វថ្ងៃនេះ និងសេចក្ដីទាំងប៉ុន្មានដែលត្រូវកើតមកតាមក្រោយទៀតផង»* (វិវរណៈ ១:១៩)។

*«ដើម្បីឲ្យ**សេចក្ដីអំណរ**របស់អ្នករាល់គ្នាបានពោរពេញឡើង»* ហេតុអ្វីបានជាព្រះសុខចិត្តទទួលការលំបាកទាំងអស់នេះ ដើម្បីជួយសង្គ្រោះយើង? ***«ដើម្បីឲ្យសេចក្ដីអំណរ**របស់អ្នករាល់គ្នាបានពោរពេញឡើង»*។ ព្រះស្រឡាញ់យើងខ្លាំងណាស់ បានជាទ្រង់ចាត់ព្រះរាជបុត្រាទ្រង់ឲ្យស្ដារទំនាក់ទំនងឡើងវិញ ដែលយើងធ្លាប់មានជាមួយនឹងព្រះនៅសួនច្បារអេដែន។ នៅពេលការប្រកបជាមួយព្រះអម្ចាស់ត្រូវបានស្ដារឡើងវិញ តាមរយៈព្រះគ្រីស្ទ នោះអំណររបស់យើងក៏ត្រូវបានស្ដារឡើងវិញដែរ។

បន្ទាប់ពីការណែនាំដ៏អស្ចារ្យនេះរបស់លោកយ៉ូហាន យើងគួរចង់ដឹងយ៉ាងខ្លាំងពីសំណួរមួយ។ ក្នុងប្រវត្តិសាស្ត្រទាំងមូល មានតែម្ដងគត់ដែលព្រះជាម្ចាស់បានកើត

ជាមនុស្ស ដើម្បីរស់នៅជាមួយយើង និងបើកសម្ដែងពីព្រះវរបិតាដល់យើង។ ដូច្នេះ យើងត្រូវតែសួរថា *តើព្រះយេស៊ូវបានសម្ដែងអ្វីខ្លះអំពីព្រះវរបិតា នៅពេលដែលទ្រង់យាងមក?* ចម្លើយនៃសំណួរនេះ គឺសាមញ្ញបំផុត តែខ្លឹម៖

## ព្រះជាពន្លឺ និងព្រះជាសេចក្ដីស្រឡាញ់

អ្វីៗដែលលោកយ៉ូហាន និងសាវកផ្សេងទៀតបានឃើញ ហើយឮពីព្រះយេស៊ូវ លោកយ៉ូហានបានសង្ខេបទៅជាប្រយោគខ្លីពីរ ដែលមានអំណាច គឺ **ព្រះជាពន្លឺ** (១:៥) និង **ព្រះជាសេចក្ដីស្រឡាញ់** (៤:៨)។

***១យ៉ូហាន ១:៥***

*នេះជាដំណឹងដែលយើងខ្ញុំបានឮពីទ្រង់ ហើយក៏ប្រាប់មកអ្នករាល់គ្នាគឺថា **ព្រះទ្រង់ជាពន្លឺភ្លឺ** គ្មានសេចក្ដីងងឹតណានៅក្នុងទ្រង់សោះ។*

***«ព្រះជាពន្លឺ»*** ដូចដែលយើងបានឃើញនៅលំនាំដើមហើយ ពាក្យពន្លឺក្នុងគម្ពីរ គឺជារូបភាពនៃសេចក្ដីពីរ គឺ**ភាពបរិសុទ្ធ** និង**ការពិត**។ ដូច្នេះ *«ព្រះជាពន្លឺ»* មានន័យថា ព្រះអម្ចាស់ជាព្រះដ៏**បរិសុទ្ធ** ដែលតែងតែមានបន្ទូលពី**សេចក្ដីពិត**ជានិច្ច។ ភ្លើងនៃភាពបរិសុទ្ធរបស់ព្រះដុតបំផ្លាញសេចក្ដីប៉ងប្រាថ្នាដែលមិនសក្តិសមរបស់យើង ហើយចង្កៀងនៃសេចក្ដីពិតរបស់ព្រះបំភ្លឺផ្លូវរបស់យើង។ លើសពីនេះ បើព្រះជាពន្លឺ (គឺបរិសុទ្ធ និងពិត) នោះអស់អ្នកណាដែលកើតមកពីព្រះ ក៏នឹងមានបំណងប្រាថ្នាចង់ធ្វើជាមនុស្សបរិសុទ្ធ ហើយជឿសេចក្ដីពិតដែរ។ ដូច្នេះ នៅកណ្ឌយ៉ូហានខ្សែទី១ «ចូរបរិសុទ្ធ» និង «ជឿការពិត» ទៅជាបញ្ញត្តិសំខាន់ដែលជួយយើងវិនិច្ឆ័យគ្រូក្លែងក្លាយ។ ឥឡូវនេះសូមយើងរំលងមួយភ្លែត ទៅ១យ៉ូហាន ៤:៧-៨ ម្ដង៖

***១យ៉ូហាន ៤:៧-៨***

*ពួកស្ងួនភ្ងាអើយ យើងត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដ្បិតសេចក្ដីស្រឡាញ់មកពីព្រះ ឯអស់អ្នកណាដែលមានសេចក្ដីស្រឡាញ់ នោះឈ្មោះថាមកពីព្រះ ហើយក៏ស្គាល់ទ្រង់ដែរ តែអ្នកណាដែលគ្មានសេចក្ដីស្រឡាញ់ នោះមិនស្គាល់ព្រះវិញ ពីព្រោះ**ព្រះទ្រង់ជាសេចក្ដីស្រឡាញ់**នោះឯង។*

***«ព្រះជាសេចក្ដីស្រឡាញ់»*** (១យ៉ូហាន ៤:៨) យើងអាចនឹងភ្ញាក់ផ្អើលដែលលោកយ៉ូហានមានប្រសាសន៍ថា *«ព្រះជាសេចក្ដីស្រឡាញ់»* ជំនួសឲ្យ «ព្រះ**មាន**សេចក្ដីស្រឡាញ់» ឬ «ព្រះ**បង្ហាញ**ពីសេចក្ដីស្រឡាញ់»។ លោកយ៉ូហានមានប្រសាសន៍ថា *«ព្រះជាសេចក្ដីស្រឡាញ់»* ដើម្បីឲ្យយើងយល់ថា សេចក្ដីស្រឡាញ់គឺជានិស្ស័យមួយរបស់ព្រះជាម្ចាស់។ សេចក្ដីស្រឡាញ់ដ៏ពោរពេញ មិនមែនជាផ្នែកមួយក្នុងនិស្ស័យរបស់មនុស្សយើងទេ។ មនុស្សយើងត្រូវរៀនឲ្យចេះស្រឡាញ់មនុស្សដែលពិបាកស្រឡាញ់។ យើងត្រូវតែបង្ខំខ្លួនឲ្យស្រឡាញ់សត្រូវរបស់យើង។ ប៉ុន្តែសេចក្ដីស្រឡាញ់ហូរចេញពីព្រះ ដូចជាទឹកហូរចេញពីប្រភពទឹក។

ចូរចាំថា ពាក្យ*«ព្រះជាពន្លឺ»* នាំមកនូវសេចក្ដីបង្គាប់ពីរ សម្រាប់កូនរបស់ទ្រង់ គឺ «ចូរបរិសុទ្ធ» និង «ជឿការពិត»។ ដូចគ្នាដែរ ពាក្យ*«ព្រះជាសេចក្ដីស្រឡាញ់»* ក៏នាំមកនូវសេចក្ដីបង្គាប់ពីរដែរ គឺ «ស្រឡាញ់ព្រះ» និង«ស្រឡាញ់គ្នា»។ អ្នកនឹងឃើញថា សេចក្ដីបង្គាប់ទាំងពីរនេះ គឺជាបញ្ញត្តិដ៏ធំបំផុតពីរនៃសេចក្ដីជំនឿរបស់យើង ដែលសេចក្ដីបង្គាប់ផ្សេងៗទៀតអាស្រ័យលើ (ម៉ាកុស ១២:២៨-៣១)។

សង្ខេបមក៖

បើព្រះជា**ពន្លឺ** មនុស្សដែលកើតមកពីព្រះ នឹងបាន**បរិសុទ្ធ** ហើយ**ជឿការពិត**។ ហើយ...
បើព្រះជា**សេចក្ដីស្រឡាញ់** មនុស្សដែលកើតមកពីព្រះ នឹង**ស្រឡាញ់ព្រះ** និង**ស្រឡាញ់គ្នា**។

គ្រីស្ទបរិស័ទត្រូវតែអបអរសាទរចំពោះលក្ខណៈទាំងពីរ អំពីព្រះ គឺ *«ព្រះជាពន្លឺ»* និង *«ព្រះជាសេចក្ដីស្រឡាញ់»*។ យើងដែលកើតមកមានចិត្តតឹងតែង និងទៀងទាត់ ងាយស្រួលទទួលការពិតថា *«ព្រះជាពន្លឺ»*។ តែពេលខ្លះមនុស្សដែលមានចិត្ត តឹងតែង ភ្លេចបង្ហាញចិត្តស្លូត និងសប្បុរសដល់អ្នកឯទៀត។ ដូចគ្នា យើងដែលមាន ចិត្តឆាប់ក្ដួលអាណិត ប្រហែលជាងាយស្រួលទទួលពាក្យថា *«ព្រះជាសេចក្ដី ស្រឡាញ់»*។ ប៉ុន្តែមនុស្សដែលមានចិត្តក្ដួលអាណិត ពេលខ្លះពិបាកការពារភាព បរិសុទ្ធ និងសេចក្ដីពិតវិញ។ ប៉ុន្តែគ្រីស្ទបរិស័ទគួរទទួលការពិតទាំងពីរអំពីព្រះអង្គ ដោយមានចិត្តត្រេកអរ។ ហេតុនេះហើយបានលោកយ៉ូហានត្បាញ *«ព្រះជាពន្លឺ»* និង *«ព្រះជាសេចក្ដីស្រឡាញ់»* ជាមួយគ្នា កុំឲ្យយើងញែកចេញពីគ្នាឡើយ ក្រែងលោយើងបង្កើតព្រះក្លែងក្លាយ ឬដំណឹងល្អក្លែងក្លាយ។

នៅពេលលោកយ៉ូហាន ត្បាញការទាំងអស់នេះជាមួយគ្នា ប្រហែលយើងពិបាក ឃើញពីដំណើរនៃគំនិតរបស់លោកយ៉ូហាន ពីចំណុចមួយទៅមួយទៀត (ដូចដែល យើងធ្លាប់ឃើញក្នុងសំបុត្ររបស់សាវកប៉ុល)។ មុនដំបូងសំណេររបស់លោក យ៉ូហាន ហាក់ដូចជារញ៉េរញ៉ៃ។ ប៉ុន្តែនៅទីបញ្ចប់យើងនឹងឃើញថា លោកយ៉ូហាន បានត្បាញសំណាញ់សុវត្ថិភាពដ៏រឹងមាំមួយ ដែលមិនអនុញ្ញាតឲ្យយើងជ្រើសរើស *«ព្រះជាពន្លឺ»* ជំនួស *«ព្រះជាសេចក្ដីស្រឡាញ់»* ឬជ្រើសរើស *«ព្រះជាសេចក្ដី ស្រឡាញ់»* ជំនួស *«ព្រះជាពន្លឺ»*។

# ការសាកល្បងប្រាំយ៉ាង ដើម្បីវិនិច្ឆ័យអំពីគ្រូក្លែងក្លាយ និងគោលជំនឿក្លែងក្លាយ

## ១យ៉ូហាន ១:៦ - ២:១១

លោកយ៉ូហានបានចាក់គ្រឹះនៃសេចក្តីពិតអំពីដំណឹងល្អ នៅ១យ៉ូហាន ១:១-៤ ហើយបានឲ្យសេចក្តីប្រកាសខាងទេវសាស្ត្រទីមួយអំពីព្រះ នៅ១យ៉ូហាន ១:៥ (*«ព្រះជាពន្លឺ»*)។ ឥឡូវគាត់ឲ្យការវិនិច្ឆ័យប្រាំយ៉ាង ដើម្បីជួយឲ្យយើងស្គាល់គ្រូខុសឆ្គង និងគ្រូត្រឹមត្រូវ។ ការវិនិច្ឆ័យទាំងប្រាំនេះ ចាប់ផ្តើមដោយពាក្យ *«បើយើងនិយាយថា»* ឬ *«អ្នកណានិយាយថា»*។

ពាក្យ «វិនិច្ឆ័យ» (ឬធ្វើរោគវិនិច្ឆ័យ) ជាភាសាពេទ្យ ដែលគ្រូពេទ្យប្រើនៅពេលពួកគេត្រូវកំណត់ពីជំងឺ។ ពេទ្យធ្វើរោគវិនិច្ឆ័យដើម្បីដឹងថា ជំងឺមួយជាមហារីក ឬក៏មិនមែន កូវីដឬក៏មិនមែន ទឹកនោមផ្អែមឬក៏មិនមែន។ នៅពេលពួកគេធ្វើរោគវិនិច្ឆ័យ គេតែងតែប្រើពាក្យ«បើសិន»។ ឧទាហរណ៍ «**បើសិន** ស្នាមមានរូបរាងបែបនេះ វាមុខជាមហារីក តែបើសិនស្នាមមានរូបរាងបែបនេះវិញ វាមុខជាមិនមែនមហារីកទេ»។

ស្រដៀងគ្នាដែរ លោកយ៉ូហានបានសរសេរសំបុត្រទាំងនេះ ដើម្បីឲ្យយើងចេះវិនិច្ឆ័យរវាងគ្រូខុសឆ្គង និងគ្រូត្រឹមត្រូវ រវាងគោលលទ្ធិខុសឆ្គង និងគោលលទ្ធិត្រឹមត្រូវ។ នេះជាមូលហេតុដែលពាក្យ **បើ** ត្រូវបានប្រើ ២៤ដង ក្នុង ១០៥ខ នៃយ៉ូហានខ្សែទី១ (ជាកម្រិតច្រើនជាងកណ្ឌគម្ពីរឯទៀតក្នុងគម្ពីរសញ្ញាថ្មី)។ ទន្ទឹម

នឹងពាក្យ **បើ** លោកយ៉ូហានប្រើពាក្យស្រដៀង ដូចជា «អ្នកណាដែល...» «គឺយ៉ាងនេះឯងដែលយើងដឹងថា...» ។ល។ ដើម្បីជួយយើងវិនិច្ឆ័យចំពោះគ្រូខុសឆ្គង និងការបង្រៀនខុសឆ្គង (សូមមើលឧបសម្ព័ន្ធ៥៖ ពាក្យវិនិច្ឆ័យក្នុងកណ្ឌ១យ៉ូហាន)។

ការវិនិច្ឆ័យទាំងប្រាំនេះនៅដើមកណ្ឌ១យ៉ូហាន បង្ហាញថា គោលបំណងធំជាងគេរបស់លោកយ៉ូហានក្នុងសំបុត្រនេះ គឺព្រមានអំពីគ្រូខុសឆ្គង និងការបង្រៀនខុសឆ្គង ហើយជួយឲ្យយើងស្គាល់គ្រូនេះ។ លោក យ៉ូហានបានសម្តែងគោលបំណងនេះនៅ១យ៉ូហាន ២:១៨-២០៖

*«ក្មេងរាល់គ្នាអើយនេះជាពេលម៉ោងក្រោយបង្អស់ហើយ សព្វថ្ងៃនេះកើតមានពួកទទឹងនឹងព្រះគ្រីស្ទជា**ច្រើន** ដូចជាអ្នករាល់គ្នាបានឮហើយថា **អាទទឹងនឹងព្រះគ្រីស្ទត្រូវមក** ហេតុនោះបានជាយើងដឹងថា នេះជាពេលម៉ោងក្រោយបង្អស់។ ១៩ **គេបានចេញពីពួកយើងទៅ** តែមិនមែនជាពួកយើងទេ។ ដ្បិតបើគេជាពួកយើងមែន នោះនឹងបាននៅជាប់ជាមួយនឹងយើងហើយ។ តែដែលគេបានចេញទៅនោះដើម្បីនឹងសម្តែងពីគេថា គ្រប់គ្នាមិនមែនជាពួកយើងទេ។ ២០ រីឯអ្នករាល់គ្នាបានព្រះដ៏បរិសុទ្ធចាក់លាបឲ្យហើយក៏ចេះគ្រប់ទាំងអស់ផង»*។

លោកយ៉ូហានក៏សម្តែងទៀតថា ក្រុមខុសឆ្គងនេះនៅតែព្យាយាមមានឥទ្ធិពលលើក្រុមជំនុំ សូម្បីតែបន្ទាប់ពីពួកគេបានចាកចេញក៏ដោយ៖ *«ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នាពីដំណើរនៃពួកអ្នកដែល**នាំអ្នករាល់គ្នាឲ្យវង្វេង**»* (១យ៉ូហាន ២:២៦)។

យើងឃើញពីការនេះថា គោលបំណងនៃកណ្ឌគម្ពីរយ៉ូហានខ្សែទី១ គឺស្រដៀងនឹងកណ្ឌគម្ពីរពេត្រុសខ្សែទី២ និងកណ្ឌគម្ពីរយូដាស ដែលមានគោលបំណងការពារគ្រីស្ទបរិស័ទពីគ្រូខុសឆ្គង។ ក្រោយព្រះយេស៊ូវរស់ពីសុគតឡើងវិញ ទ្រង់មានការសន្ទនាសំខាន់ជាមួយនឹងសាវកពេត្រុស។ សាវកយ៉ូហានក៏បានស្តាប់ការសន្ទនានោះ

ហើយបានឮព្រះយេស៊ូវបង្គាប់លោកពេត្រុសឲ្យធ្វើការងារពីរ៖ *«ចូរឲ្យចំណីដល់កូនចៀមខ្ញុំស៊ីផង»* និង *«ចូរឃ្វាល [ការពារ] ហ្វូងចៀមរបស់ខ្ញុំចុះ»* (យ៉ូហាន ២១:១៥-១៦)។ នេះជាសេចក្តីដែលលោកពេត្រុស និងលោកយ៉ូហានបានធ្វើនៅក្នុងការសរសេរបទគម្ពីររបស់ពួកគាត់។ សាវកពេត្រុសបាន**ផ្តល់ចំណី**ដល់ហ្វូងចៀមរាប់សិបជំនាន់ តាមរយៈកណ្ឌគម្ពីរពេត្រុសខ្សែទី១ ហើយបន្ទាប់មកគាត់បាន**ការពារ**ហ្វូងចៀមរាប់សិបជំនាន់ តាមរយៈកណ្ឌគម្ពីរពេត្រុសខ្សែទី២ ឲ្យរួចពីឆ្កែចចក។ ស្រដៀងគ្នានេះដែរ លោកយ៉ូហានបាន**ផ្តល់ចំណី**ដល់ចៀមរាប់សិបជំនាន់របស់ព្រះគ្រីស្ទ តាមរយៈដំណឹងល្អរបស់លោកយ៉ូហាន ហើយគាត់ក៏បាន**ការពារ**ហ្វូងចៀមរាប់សិបជំនាន់តាមរយៈកណ្ឌគម្ពីរយ៉ូហានខ្សែទី១ ទី២ និងទី៣។ ការផ្តល់ចំណី និងការការពារតែងតែជាការងាររបស់អ្នកគង្វាល។

ទន្ទឹមនឹងការជួយដល់ពួកគ្រីស្ទបរិស័ទ ឲ្យចេះធ្វើការវិនិច្ឆ័យលើការបង្រៀនខុសឆ្គង លោកយ៉ូហានក៏បានបន្ថែមពាក្យជាច្រើននៃការធានា និងការលួងលោមដល់អ្នកជឿស្មោះត្រង់ ដែលអស់កម្លាំងបន្ទាប់ពីតយុទ្ធនឹងគ្រូខុសឆ្គង។ គ្រូបង្រៀនខុសឆ្គង តែងតែញាក់គ្រីស្ទបរិស័ទពិត ហើយធ្វើឲ្យគេសង្ស័យក្នុងចិត្តអំពីសេចក្តីសង្គ្រោះ។ ហេតុដូច្នេះហើយកណ្ឌគម្ពីរយ៉ូហានខ្សែទី១ ពេញដោយពាក្យធានា ដែលកម្សាន្តចិត្តអ្នកដែលបានតយុទ្ធនឹងគ្រូខុសឆ្គងទាំងនេះ។




**ឧទាហរណ៍៖** យុទ្ធសាស្ត្ររបស់ក្រុមខុសឆ្គងពីកូរ៉េដែលមានឈ្មោះថា បេសកកម្មដំណឹងល្អ (Good News Mission) ដែលមានលោក ប៉ាក អុក ស៊ូ ជានាយក គឺសួរសំណួរដែលមានគោលបំណងធ្វើឲ្យគ្រីស្ទបរិស័ទមានការសង្ស័យអំពីសេចក្តីសង្គ្រោះរបស់ពួកគាត់។ ពួកគេសួរថា «តើអ្នកដឹងថ្ងៃខែឆ្នាំដែលអ្នកបានកើតជាថ្មីទេ?»។ បើអ្នកឆ្លើយថា អ្នកមិនដឹងទេ

> នោះពួកគេនឹងនិយាយថា អ្នកមិនមែនជាគ្រីស្ទបរិស័ទទេ ហើយត្រូវការសេចក្តីសង្គ្រោះ។ គេក៏ប្រាប់អ្នកទៀតថា អ្នកត្រូវចាកចេញពីក្រុមជំនុំរបស់អ្នក ហើយចូលរួមក្នុងក្រុមជំនុំរបស់គេវិញ! (សូមមើលអត្ថបទអំពីបេសកកម្មដំណឹងល្អនៅផ្នែកទី២នៃសៀវភៅនេះ)។

ឥឡូវយើងនឹងមើលប្រយោគវិនិច្ឆ័យទី១ ដែលចាប់ផ្តើមនឹងពាក្យ «បើសិន»។

## ការវិនិច្ឆ័យទី១

***១យ៉ូហាន ១:៦-៧***

*បើសិនជាយើងរាល់គ្នាថា យើងមានសេចក្តីប្រកបនឹងទ្រង់ តែដើរក្នុងសេចក្តីងងឹតវិញ នោះឈ្មោះថា យើងកុហកហើយមិនប្រព្រឹត្តតាមសេចក្តីពិតទេ។ [7] តែបើយើងរាល់គ្នាដើរក្នុងពន្លឺវិញ ដូចជាទ្រង់ក៏គង់ក្នុងពន្លឺដែរ នោះយើងមានសេចក្តីប្រកបនឹងគ្នាទៅវិញ ទៅមក ហើយព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃទ្រង់ ក៏សំអាតយើងរាល់គ្នាពីគ្រប់អំពើបាបទាំងអស់។*

**ការវិនិច្ឆ័យទី១៖ បើអ្នកណានិយាយថា «ខ្ញុំមានសេចក្តីប្រកបជាមួយព្រះ» តែដើរក្នុងភាពងងឹតនៃព្រះក្លែងក្លាយ នោះគាត់កុហកហើយ។ គ្រូពិតទទួលយកពន្លឺនៃទីបន្ទាល់របស់ពួកសាវកអំពីព្រះគ្រីស្ទពិត។**

ពាក្យគន្លឹះក្នុងការស្វែងយល់អំពីការសាកល្បងដំបូងនៃការបង្រៀនខុសឆ្គងគឺ *«សេចក្តីប្រកប»*។ តើអ្នកចាំ ១យ៉ូហាន ១:៣ ទេ ដែលប្រាប់យើងពីអ្វីដែលនាំឲ្យមានសេចក្តីប្រកបជាមួយព្រះ? គឺការជឿដំណឹងល្អអំពីព្រះគ្រីស្ទពិត ដែលព្រះបានចាត់មក ហើយស្មរបន្ទាល់បានឃើញ ៖ *«ដូច្នេះសេចក្តីដែលយើងខ្ញុំបានឃើញ ហើយឮ នោះយើងខ្ញុំប្រាប់មកអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាមានសេចក្តីប្រកបនឹង*

*យើងខ្ញុំដែរ រីឯសេចក្ដីប្រកបរបស់យើងខ្ញុំនោះ គឺប្រកបនឹងព្រះវរបិតា ហើយនិងព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រាទ្រង់»។*

គ្រូខុសឆ្គងបានផ្ដល់ព្រះគ្រីស្ទផ្សេង ខុសពីព្រះគ្រីស្ទនៃស្មរបន្ទាល់។ និយាយម្យ៉ាងទៀត ពួកគេបដិសេធពន្លឺនៃការពិត ហើយកំពុងដើរក្នុងភាពងងឹត គឺភាពងងឹតនៃព្រះគ្រីស្ទក្លែងក្លាយ។ ដូច្នេះលោកយ៉ូហានបានមានប្រសាសន៍ថា ប្រសិនបើគ្រូទាំងនោះអះអាងថា ពួកគេមានសេចក្ដីប្រកបជាមួយព្រះ ប៉ុន្តែពួកគេមិនព្រមទទួលព្រះគ្រីស្ទពិតនៃពួកសាវក នោះគ្រូនោះកំពុងកុហក។ វិធីតែមួយគត់ដើម្បីមានការប្រកបគ្នាជាមួយនឹងព្រះ គឺទទួលយកព្រះរាជបុត្រានៃព្រះ ហើយចុះចូលនឹងពួកសាវក និងទីបន្ទាល់ផ្ទាល់ភ្នែករបស់ពួកគេ អំពីព្រះរាជបុត្រា។

> **ឧទាហរណ៍៖** គ្រូខុសឆ្គង អាន់ សាំងហុង ពីកូរេ មិនមែនជាព្រះគ្រីស្ទពិត ដែលនាំមកនូវការប្រកបជាមួយព្រះជាម្ចាស់ទេ។ គាត់ជាភាពងងឹតវិញ។ ដូចគ្នាដែរ ព្រះគ្រីស្ទក្លែងក្លាយឈ្មោះ អាប៉ូឡូ គីបូឡូយ សាន់ ម៉ុង មូន និង «គ្រីស្ទ» នៃក្រុមស្មរបន្ទាល់ព្រះយេហូវ៉ា គឺជាភាពងងឹតដែរ ហើយមិនអាចនាំយើងឲ្យមានសេចក្ដីប្រកបជាមួយព្រះបានឡើយ។ (សូមមើលផ្នែកទី២នៃសៀវភៅនេះ)។

សូមចាំថា សាក្សីដែលបានឃើញផ្ទាល់ភ្នែកបានរស់នៅជាមួយព្រះយេស៊ូវ ទាំងយប់ទាំងថ្ងៃ អស់រយៈពេល៣ឬ៤ឆ្នាំ។ ពួកគេជាសាក្សីដែលគួរឲ្យទុកចិត្ត។ អ្នកណាដែលបដិសេធសក្ខីភាពរបស់ពួកគេ អំពីព្រះយេស៊ូវ គឺគេកំពុងដើរក្នុងភាពងងឹត។ ការដើរក្នុងពន្លឺមានន័យថា ការទទួលយកព្រះគ្រីស្ទពិត ដែលពួកសាវកដើមបានធ្វើទីបន្ទាល់អំពី ហើយបដិសេធអាក្លែងក្លាយ។

*«...យើងមាន**សេចក្ដីប្រកប**នឹងគ្នាទៅវិញ ទៅមក ហើយព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃទ្រង់ ក៏**សំអាតយើង**រាល់គ្នាពីគ្រប់អំពើបាបទាំង*

*អស់»។* បើយើងដើរក្នុងពន្លឺនៃព្រះគ្រីស្ទពិត (មិនមែនភាពងងឹតនៃព្រះគ្រីស្ទក្លែងក្លាយ) លោកយ៉ូហាន សន្យានឹងយើងនៅខ៧ថា យើងនឹងទទួលបានលទ្ធផលដ៏សំខាន់ពីរគឺ៖

១. យើងនឹងមានសេចក្តីប្រកបជាមួយព្រះជាម្ចាស់ ព្រះគ្រីស្ទ និងពួកសាវក (ព្រះគ្រីស្ទក្លែងក្លាយ មិនអាចនាំឲ្យយើងប្រកបជាមួយព្រះបានឡើយ)។

២. ព្រះលោហិតព្រះយេស៊ូវ នឹងសម្អាតយើងពីគ្រប់អំពើបាបទាំងអស់ (ព្រះគ្រីស្ទក្លែងក្លាយមិនអាចសម្អាតយើងពីអំពើបាបទេ)។

នៅក្នុងខ៦ និងខ៧ លោកយ៉ូហាន ភ្ជាប់ការកើតពីព្រះ (*«សេចក្តីប្រកបជាមួយនឹងទ្រង់»*) ជាមួយនឹងការជឿសេចក្តីពិតអំពីព្រះគ្រីស្ទ (*«ដើរក្នុងពន្លឺ»*) ដូចនៅក្នុងរូបនេះ៖




*បើសិនជាយើងរាល់គ្នាថា **យើងមានសេចក្តីប្រកបនឹងទ្រង់ តែដើរក្នុងសេចក្តីងងឹតវិញ** នោះឈ្មោះថា យើងកុហក។ (១យ៉ូហាន ១:៦)*

ឥឡូវយើងមកដល់ការវិនិច្ឆ័យគ្រូខុសឆ្គងទី២របស់លោកយ៉ូហាន។

# ការវិនិច្ឆ័យទី២

*១យ៉ូហាន ១:៨-៩*
*បើសិនជាយើងថា យើងគ្មានបាបសោះនោះឈ្មោះថា យើងបញ្ឆោតដល់ខ្លួន ហើយសេចក្តីពិតមិនស្ថិតនៅក្នុងយើងទេ។ ៩ បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ហើយនឹងសំអាតយើងពីគ្រប់អំពើទុច្ចរិតទាំងអស់ផង។*

**ការវិនិច្ឆ័យទី២៖ បើអ្នកណានិយាយថា «ខ្ញុំគ្មានបាបទេ» ជំនួសឲ្យការលន់តួបាបប្រចាំថ្ងៃរបស់គេចំពោះព្រះជានិច្ច នោះគាត់បញ្ឆោតខ្លួនឯង ហើយគ្មានសេចក្តីពិតនៅក្នុងទេ។**

អារក្សសាតាំងដឹកនាំក្រុមខុសឆ្គងជាច្រើន ឲ្យបង្រៀនមិនត្រឹមត្រូវពីអំពើបាបនៅក្នុងជីវិតរបស់គ្រីស្ទបរិស័ទ។ នៅសម័យលោកយ៉ូហាន គ្រូខុសឆ្គងបានបង្រៀនថា វិញ្ញាណល្អ ប៉ុន្តែរូបកាយអាក្រក់។ គ្រូខ្លះដែលចង់ដោះសាអំពើបាបរបស់ខ្លួន អាចនិយាយថា «វិញ្ញាណរបស់ខ្ញុំគ្មានបាបទេ ពីព្រោះព្រះគ្រីស្ទបានសម្អាតខ្ញុំហើយ។ មានតែរូបកាយខ្ញុំប៉ុណ្ណោះ ដែលកំពុងប្រព្រឹត្តអំពើបាបនេះ មិនមែនខ្ញុំទេ»។

សព្វថ្ងៃនេះក្រុមក្លែងក្លាយនៅអាស៊ីខ្លះ ចូលចិត្តបង្រៀនថា គ្រីស្ទបរិស័ទពិតប្រាកដលែងមានបាបនៅក្នុងជីវិតទៀតហើយ។

> **ឧទាហរណ៍៖** ក្រុមខុសឆ្គងខ្លះហាមមិនឲ្យសមាជិករបស់ខ្លួនសារភាពលន់តួអំពើបាបរបស់ពួកគេចំពោះព្រះឡើយ។ ពួកគេនិយាយថា «ព្រះបានអត់ទោសអំពើបាបរបស់អ្នកនៅក្នុងព្រះគ្រីស្ទហើយ។ បើអ្នកសារភាពអំពើបាបរបស់អ្នកទៀត មានន័យថា អ្នកមិនជឿថា ព្រះអម្ចាស់បានអត់ទោសឲ្យអ្នកហើយនោះទេ»។ ក្រុមខុសឆ្គងដែលមានឈ្មោះថា បេសកកម្មដំណឹងល្អ (ដែលមានឈ្មោះមួយទៀតថា CLF–Christian

> Leaders Forum សន្និសីទអ្នកដឹកនាំសាសនាគ្រីស្ទ) បង្រៀនថា បើអ្នកនិយាយថា អ្នកនៅតែមានបាប អ្នកមិនមែនជាគ្រីស្ទបរិស័ទទេ។
>
> គ្រូខុសឆ្គងឯទៀត ដូច អាប៉ូឡូ គីបូឡូយ និយាយថា គេលែងប្រព្រឹត្តអំពើបាបរាល់ថ្ងៃទៀតហើយ! គេអះអាងថា ខ្លួនល្អឥតខ្ចោះហើយ។ ប៉ុន្តែគ្មានមនុស្សណាម្នាក់នៅលើផែនដី ដែលគ្មានបាបសោះឡើយ ពីព្រោះគ្មានអ្នកណាម្នាក់នៅលើផែនដីនេះ ដែលអាចគោរពបទបញ្ញត្តិដ៏ខ្ពង់ខ្ពស់បំផុតគ្រប់ពេលបានទេ គឺត្រូវស្រឡាញ់ព្រះឲ្យអស់ពីចិត្ត អស់ពីកម្លាំង និងអស់ពីគំនិត។

សូមអានខ៩ម្តងទៀត ដើម្បីរៀនការពិតពីអ្វីដែលគ្រីស្ទបរិស័ទត្រូវធ្វើ នៅពេលពួកគេធ្វើបាបរាល់ថ្ងៃ ៖ *«បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ហើយនិងសំអាតយើងពីគ្រប់អំពើទុច្ចរិតទាំងអស់ផង»។*

ការសន្យានេះជាអំណោយធំមួយរបស់ព្រះ ដល់កូនរបស់ទ្រង់ ហើយជាខគន្លឹះមួយ ដើម្បីជួយឲ្យគ្រីស្ទបរិស័ទរស់នៅដោយជោគជ័យ។ ព្រះវរបិតារបស់យើង កំពុងហៅកូនរបស់ទ្រង់ ឲ្យចូលមករង្វង់ព្រះហស្តរបស់ទ្រង់ ហើយលន់តួបាបរាល់ថ្ងៃ។

ពាក្យ «លន់តួ» (ឬសារភាព) ត្រូវបានប្រើ៣កន្លែងទៀតនៅក្នុងគម្ពីរសញ្ញាថ្មី៖

> **ម៉ាថាយ ៣:៦៖** បណ្តាជនបានលន់តួបាបរបស់ខ្លួន ហើយទទួលបុណ្យជ្រមុជទឹកដោយលោកយ៉ូហាន។
>
> **យ៉ាកុប ៥:១៦៖** លោកយ៉ាកុបបង្គាប់ឲ្យគ្រីស្ទបរិស័ទដែលឈឺលន់តួបាបរបស់គេចំពោះព្រះ។
>
> **កិច្ចការ ១៩:១៨-១៩៖** គ្រីស្ទបរិស័ទថ្មីបានលន់តួអំពើអាក្រក់របស់ខ្លួន ហើយយកសៀវភៅមន្តអាគមរបស់គេដុតចោល។

## ស្មោះត្រង់ និងសុចរិត

សូមកត់សម្គាល់ថា នៅពេលដែលលោកយ៉ូហាន នាំឲ្យយើងលន់តួបាប គាត់មិនបានមានប្រសាសន៍ថា ចូរលន់តួបាបពីព្រោះ «ព្រះអម្ចាស់មានព្រះហឫទ័យ **សប្បុរស** និង**មេត្តាករុណា**»នោះទេ។ តែគាត់និយាយថា ចូរលន់តួបាបពីព្រោះ *«ព្រះមានព្រះហឫទ័យ**ស្មោះត្រង់** ហើយ**សុចរិត**»*។ ហេតុអ្វីបានជាលោកយ៉ូហានបានជ្រើសរើសពាក្យ**ស្មោះត្រង់** ហើយ**សុចរិត** ជំនួសពាក្យ**សប្បុរស**និង**មេត្តាករុណា**? ហាក់ដូចជាជម្រើសនេះខុសហើយ។ ឧបមាថា បើអ្នកពិតជាមានពិរុទ្ធពីបទឧក្រិដ្ឋ ហើយរង់ចាំការជំនុំជម្រះ តើអ្នកចង់បាន ចៅក្រមដែលជាចៅក្រមស្មោះត្រង់ និងយុត្តិធម៌ជាងគេនៅស្រុកនោះ ឬចង់បានចៅក្រមដែលមានចិត្តសប្បុរស និងមេត្តាករុណាជាងគេ? បាទ អ្នកចង់បានចៅក្រមសប្បុរស។

ប៉ុន្តែលោកយ៉ូហាន ជឿថា កានិយាយថា *«ព្រះស្មោះត្រង់ និងសុចរិត»* គឺកាន់តែលើកទឹកចិត្តយើងជាង។ ហេតុអ្វី? ចម្លើយត្រូវបានរកឃើញនៅពីរខបន្ទាប់ទៀត នៅក្នុងគម្ពីរ ១យ៉ូហាន ២:១-២៖ *«តែបើសិនជាអ្នកណាភ្លាត់ធ្វើបាបវិញ នោះយើងមានព្រះដ៏ជាជំនួយមួយអង្គហើយ ដែលទ្រង់គង់នៅចំពោះព្រះវរបិតា គឺជាព្រះយេស៊ូវគ្រីស្ទជាព្រះដ៏សុចរិតដែលទ្រង់ជា**ដង្វាយធួននឹងបាប**យើងរាល់គ្នា...»*។ ពាក្យ *«ដង្វាយធួននឹងបាប»* គឺជាយញ្ញបូជាជំនួសមនុស្សមានបាប ដែលបង្វែរសេចក្តីក្រោធរបស់ព្រះ ចេញពីមនុស្សមានបាប ហើយដាក់លើយញ្ញបូជាវិញ (សូមអាន ១យ៉ូហាន ៤:១០) ដែរ។ ព្រះយេស៊ូវគឺជា ដង្វាយធួននឹងបាបនោះ។ បើព្រះយេស៊ូវបានបង់ថ្លៃលោះសម្រាប់អំពើបាបរបស់យើងទាំងស្រុងហើយ យើងអាចប្រាកដថា ព្រះ***ត្រូវ***អត់ទោសឲ្យយើង នៅពេលណាយើងលន់តួបាបប្រចាំថ្ងៃចំពោះទ្រង់។ តាមពិតបើព្រះមិនអត់ទោសឲ្យយើងទេ ក្រោយពីព្រះយេស៊ូវបានចេញសងថ្លៃទោសអស់ហើយ នោះព្រះ**មិន**ស្មោះត្រង់ និង**មិន**សុចរិតទេ ពីព្រោះទ្រង់បានឲ្យ

យើងសងអ្វីដែលព្រះយេស៊ូវបានបង់រួចហើយ។ ព្រះជាម្ចាស់មិនអាចធ្វើបែបមិនសុចរិតនោះទេ។ (សូមចាំគម្ពីររ៉ូម ៣:២១-២៦ ដែលពន្យល់ពីរបៀបដែលព្រះអាចរាប់មនុស្សមានបាបថាសុចរិត តែទ្រង់នៅតែសុចរិតផងដែរ)។

សូមចាំថា ព្រះយេស៊ូវផ្ទាល់បានបង្រៀនយើងឲ្យលន់តួបាបដល់ព្រះវរបិតារៀងរាល់ថ្ងៃ។ សូមស្ដាប់ពាក្យអធិស្ឋានដែលទ្រង់បានបង្រៀនដល់សិស្ស៖ *«សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ សូមអត់ទោសសេចក្តីកំហុសរបស់យើងខ្ញុំ ដូចជាយើងខ្ញុំបានអត់ទោស ដល់អស់អ្នកដែលធ្វើខុសនឹងយើងខ្ញុំដែរ»* (ម៉ាថាយ ៦:១១-១២)។

អភ័យឯកសិទ្ធិនៃការលន់តួបាបរបស់យើងចំពោះព្រះវរបិតារៀងរាល់ថ្ងៃ គឺជាអំណោយដ៏ធំពីព្រះ។ គ្រូណាដែលព្យាយាមយកអំណោយនេះចេញពីយើង មិនមែនជួយយើងទេ គឺធ្វើបាបយើងវិញ។ គោលបំណងនៃការលន់តួបាបរាល់ថ្ងៃ មិនមែនដើម្បីទទួល ការផ្សះផ្សាជាមួយព្រះអង្គម្តងហើយម្តងទៀតទេ (ការផ្សះផ្សាបានកើតឡើងតែម្តងជាសម្រេច) តែដើម្បីរក្សានូវទំនាក់ទំនងជិតស្និទ្ធដែលយើងមានហើយជាមួយព្រះវរបិតារបស់យើង តាមរយៈព្រះលោហិតរបស់ព្រះយេស៊ូវគ្រីស្ទ។ គោលបំណងគឺដើម្បីលួងលោមយើង មិនមែនសង្គ្រោះយើងទេ។ មានតែជង្វាយធួននឹងបាបរបស់ព្រះគ្រីស្ទប៉ុណ្ណោះ ដែលអាចផ្សះផ្សាយើងជាមួយនឹងព្រះបាន។

ការនេះនាំយើងមកដល់ការវិនិច្ឆ័យទី៣ របស់លោកយ៉ូហាន ចំពោះគ្រូក្លែងក្លាយទាំងនៅជំនាន់គាត់ និងជំនាន់យើង។

## ការវិនិច្ឆ័យទី៣

***១យ៉ូហាន ១:១០***

*បើយើងថា យើង**មិនបាន**ធ្វើបាបទេ នោះឈ្មោះថា យើងធ្វើឲ្យទ្រង់ទៅជាអ្នកកុហក វិញ ហើយព្រះបន្ទូលទ្រង់មិននៅក្នុងយើងទេ។*

**ការវិនិច្ឆ័យទី៣៖ បើអ្នកណាការពារបាបរបស់ខ្លួនថា «ខ្ញុំមិនបានធ្វើបាបទេ» ជំនួសឲ្យការលន់តួបាបរបស់ខ្លួន ហើយពឹងផ្អែកលើដង្វាយធួននឹងបាបរបស់ព្រះគ្រីស្ទ នោះគាត់ធ្វើឲ្យព្រះទៅជាអ្នកកុហក។**

> [ សូមកត់សម្គាល់ថា គម្ពីរ KOV បានបន្ថែមពាក្យ «មិនដែល» និង «សោះ» *(បើយើងថា យើង**មិនដែល**ធ្វើបាប**សោះ**...)* តែក្នុងភាសាក្រេក ខនេះ បកប្រែថា «បើយើងថា យើង**មិនបាន**ធ្វើបាបទេ...» តែប៉ុណ្ណោះ។ ]

*«បើយើងថា យើងមិនបានធ្វើបាបទេ...»* មុនដំបូង ហាក់ដូចជាឃ្លានេះក្នុងខ១០ និយាយដូចគ្នាទៅនឹងឃ្លាដំបូងក្នុងខ៨ដែលថា *«បើសិនជាយើងថា យើងគ្មានបាបសោះ...»*។ និយាយអ៊ីចឹង គួរឲ្យស្តាយដែលគម្ពីរ KSV បកប្រែឃ្លាទាំងពីរនោះដូចតែគ្នា។ ប៉ុន្តែ ក្នុងភាសាក្រេក ឃ្លាទាំងពីនោះខុសគ្នា ហើយភាពខុសគ្នានោះគឺសំខាន់ ណាស់។ សូមសម្គាល់៖

> ខ ៨៖ *«បើយើងថា **យើងគ្មានបាប**...»*
>
> ខ ១០៖ *«បើយើងថា **យើងមិនបានធ្វើបាប**...»*

តើការអួតថា «យើង**មិនបានធ្វើបាប**» ឬ «ខ្ញុំ**មិនបានធ្វើបាប**» មានន័យថាម៉េច? នៅក្នុងព្រះគម្ពីរ ឃ្លាផ្ទុយដែលថា«ខ្ញុំបានធ្វើបាប» ឬ «យើងបានធ្វើបាប» គឺជារបៀបធម្មតានៃការលន់តួបាបចំពោះព្រះ។ ចំនួន១៧ដងនៅក្នុងព្រះគម្ពីរ មនុស្សម្នាក់បាន

លន់តួបាបរបស់ខ្លួនដោយនិយាយថា «ខ្ញុំបានធ្វើបាបហើយ»។ ចំនួន២០ដងទៀត ជនជាតិអ៊ីស្រាអែលបានលន់តួថា «យើងបានធ្វើបាបហើយ»។ ក្នុង៣៧ករណីទាំងអស់នេះ បុគ្គល ឬក្រុមដែលលន់តួថា «ខ្ញុំបានធ្វើបាប» ឬ «យើងបានធ្វើបាប» កំពុងសំដៅទៅអំពើបាបជាក់លាក់ដែលគេបានធ្វើ ហើយឥឡូវបានលន់តួ។

ប៉ុន្តែ៣ដងនៅក្នុងគម្ពីរ មនុស្សរឹងទទឹងបានដោះសាខ្លួនដោយប្រើពាក្យដដែលនេះ ក្នុង ១យ៉ូហាន ១:១០ ថា «យើង**មិនបាន**ធ្វើបាបទេ»។ ឧទាហរណ៍ក្នុងគម្ពីរ យេរេមា ២:៣៥ ព្រះបានប្រាប់អ៊ីស្រាអែលថា ពួកគេបានធ្វើបាបទាស់នឹងទ្រង់។ ទ្រង់ថែមទាំងឲ្យឧទាហរណ៍ជាក់លាក់នៃអំពើបាបរបស់ពួកគេ ដូចជាការកៀបសង្កត់អ្នកក្រ។ តើពួកគេបានលន់តួថា «យើងបានធ្វើបាបហើយ»ទេ? ទេ ពួកគេបានដោះសាខ្លួនដោយនិយាយថា «យើង**មិនបាន**ធ្វើបាបទេ» ដូចនៅក្នុង១យ៉ូហាន ១:១០។ ការការពារអំពើបាបជំនួសការលន់តួនេះ គឺជាកំហុសដែលលោកយ៉ូហានបានព្រមាននៅក្នុង១យ៉ូហាន ១:១០។ ព្រះអម្ចាស់មិនចង់ឲ្យយើងការពារខ្លួននៅពេលយើងធ្វើបាប ឬនិយាយថា អ្វីដែលយើងបានធ្វើ ឬអ្នកផ្សេងបានធ្វើមិនមែនជាអំពើបាបនោះទេ នៅពេលទ្រង់ថា ពិតជាបាប។ ការការពារអំពើបាបរបស់យើងមិនមែនជាដំណោះស្រាយនៃអំពើបាបទេ។ ដំណោះស្រាយតែមួយគត់ នៅពេលគ្រីស្ទបរិស័ទធ្វើបាបរាល់ថ្ងៃ គឺស្តាប់តាមព្រះបន្ទូលរបស់ព្រះនៅ១យ៉ូហាន ១:៩ ឲ្យលន់តួបាប ហើយជឿដល់ការសន្យាដែលថា ព្រះមានហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ដោយសារព្រះលោហិតរបស់ព្រះយេស៊ូវ។

*«…យើងធ្វើឲ្យទ្រង់ទៅជាអ្នកកុហកវិញ ហើយព្រះបន្ទូលទ្រង់មិននៅក្នុងយើងទេ»*
បើព្រះបានប្រាប់យើងក្នុងព្រះបន្ទូលថា យើងពិតជាបានធ្វើអំពើបាបមួយ តែយើង

ឆ្លើយដោយនិយាយថា «ទេ យើង**មិនបាន**ធ្វើបាបទេ» យើងកំពុងហៅព្រះថា ជាអ្នកកុហក។

**ឧទាហរណ៍៖** ជាញឹកញាប់គ្រូខុសឆ្គងនិយាយថា អ្វីដែលព្រះហៅថា ជាបាប គឺវាមិនមែនជាបាបទេ។ ឧទាហរណ៍គ្រូគ្រីស្ទបរិស័ទខ្លះនឹងនិយាយទៅកាន់អ្នកដែលបានពន្លូតកូនថា «អ្នក**មិនបាន**ធ្វើបាបទេ ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងការសម្រេចចិត្តរបស់អ្នកហើយ»។ ពួកគេកំពុងហៅព្រះអង្គថា ជាអ្នកកុហកហើយ ព្រោះព្រះអង្គមានបន្ទូលថា ឃាតកម្មទាំងអស់ជាបាប។

**ឧទាហរណ៍៖** គ្រូក្នុងនិកាយសាវកថ្មីនិយាយទៅកាន់មនុស្សស្រឡាញ់ភេទដូចគ្នាថា «អ្នក**មិនបាន**ធ្វើបាបទេ» ពួកគេបង្រៀនថា ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងទំនាក់ទំនងភេទដូចគ្នា។ នៅពេលពួកគេបង្រៀនបែបនេះ គេកំពុងនិយាយថា ព្រះជាអ្នកកុហក ព្រោះព្រះមានបន្ទូលយ៉ាងច្បាស់នៅក្នុងព្រះគម្ពីរថា ការយកភេទដូចគ្នា គឺជាអំពើបាប (រ៉ូម ១:២៦-២៧, ១កូរិនថូស ៦:៩-១១ KSV, ១ធីម៉ូថេ ១:១០)។ គ្រីស្ទបរិស័ទពិតយល់ស្របនឹងការសម្ដែងរបស់ទ្រង់នៅក្នុងព្រះគម្ពីរ អំពីអ្វីដែលជាអំពើបាប សូម្បីតែលោកិយមានគំនិតផ្សេង។ (សូមអានអត្ថបទអំពីនិកាយសាវកថ្មីនៅក្នុងផ្នែកទី ២ នៃសៀវភៅនេះ)

ប៉ុន្តែវាមិនមែនគ្រាន់តែជាគ្រូក្លែងក្លាយដែលនិយាយថា «យើង**មិនបាន**ធ្វើបាបទេ» ពេលខ្លះសមាជិកក្រុមជំនុំក៏និយាយអ៊ីចឹងដែរ។ ឧទាហរណ៍នៅពេលគ្រីស្ទបរិស័ទម្នាក់ កែតម្រង់គ្រីស្ទបរិស័ទម្នាក់ទៀត ពីការនិយាយដើមគេ អ្នកនោះច្រើនតែដោះសាខ្លួនដោយនិយាយថា «ខ្ញុំ**មិនបាន**ធ្វើបាបទេ ខ្ញុំមិនបាននិយាយដើមគេទេ ខ្ញុំគ្រាន់តែសូមសំណូមពរអធិស្ឋានតែប៉ុណ្ណោះ» ឬថា «ខ្ញុំ**មិនបាន**និយាយដើមទេ ខ្ញុំគ្រាន់តែសុំយោបល់ប៉ុណ្ណោះ» ពេលខ្លះយើងកែតម្រង់គ្រីស្ទបរិស័ទចំពោះអំពើអសីលធម៌ខាងផ្លូវភេទ ហើយពួកគេនិយាយថា «យើង**មិនបាន**ធ្វើបាបទេ ពីព្រោះយើងស្រឡាញ់គ្នា»។

នៅពេលដែលគ្រីស្ទបរិស័ទពិតធ្វើបាប គាត់មិននិយាយថា «ខ្ញុំមិនបានធ្វើបាបទេ» ប៉ុន្តែ គាត់លន់តួបាបភ្លាមវិញ ដោយនិយាយថា «ខ្ញុំបានធ្វើបាបមែន» ហើយទុកចិត្តដល់ការសុគត និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ សំរាប់ការអត់ទោសបាប។ គ្មានអំពើបាបណាដែលអាក្រក់ រហូតដល់ព្រះលោហិតរបស់ព្រះគ្រីស្ទមិនអាចគ្របបាំងបាននោះឡើយ។ ចូររត់ទៅឯរង្វង់ព្រះហស្តព្រះវរបិតារបស់អ្នកភ្លាម។

សូមសារឡើងវិញការវិនិច្ឆ័យបីដំបូង៖

១. បើអ្នកនិយាយថា «ខ្ញុំមានសេចក្តីប្រកបជាមួយព្រះ» ប៉ុន្តែដើរក្នុងភាពងងឹតនៃព្រះគ្រីស្ទក្លែងក្លាយវិញ ធ្វើឲ្យ**អ្នក**ជាមនុស្សកុហក (១:៦)។

២. បើអ្នកនិយាយថា «ខ្ញុំគ្មានបាបសោះ» គឺ**កុហកខ្លួនឯង**ហើយ (១:៨)។

៣. បើអ្នកនិយាយថា «ខ្ញុំមិនបានធ្វើបាបទេ» នៅពេលដែលព្រះមានបន្ទូលថាអ្នកពិតជាបានធ្វើបាប នោះធ្វើឲ្យ**ព្រះជាអ្នកកុហក** (១:១០)។

ឥឡូវចូរឲ្យយើងរៀនអំពីមូលហេតុដែលព្រះស្មោះត្រង់ និងសុចរិតក្នុងការអត់ទោសបាបរបស់យើង៖

***១យ៉ូហាន ២:១-២***

*កូនតូចៗរាល់គ្នាអើយដែលខ្ញុំសរសេរសេចក្តីទាំងនេះផ្ញើមកនោះ ដើម្បីកុំឲ្យអ្នករាល់គ្នាធ្វើបាបទៀត។ តែបើសិនជាអ្នកណាភ្លាត់ធ្វើបាបវិញ នោះយើងមានព្រះដ៏ជាជំនួយមួយអង្គហើយ ដែលទ្រង់គង់នៅចំពោះព្រះវរបិតា គឺជាព្រះយេស៊ូវគ្រីស្ទជាព្រះដ៏សុចរិត។ ២ ដែលទ្រង់ជាដង្វាយធួននឹងបាបយើងរាល់គ្នា មិនត្រឹមតែបាបរបស់យើងរាល់គ្នាតែប៉ុណ្ណោះ គឺ និងបាបរបស់លោកីយ៍ទាំងមូលដែរ។*

តើធ្វើម៉េចឲ្យយើងដឹងប្រាកដថា ព្រះនឹងអត់ទោសបាបឲ្យយើង នៅពេលយើងលន់តួបាបរាល់ថ្ងៃ? ចម្លើយគឺនៅ ១យ៉ូហាន ២:១-២ ដែលមានបន្ទូលថា *«...តែបើសិនជាអ្នកណាភ្លាត់ធ្វើបាបវិញ នោះយើងមានព្រះដ៏ជាជំនួយមួយអង្គហើយ ដែលទ្រង់គង់នៅចំពោះព្រះវរបិតា គឺជាព្រះយេស៊ូវគ្រីស្ទជាព្រះដ៏សុចរិត។ ២ ដែលទ្រង់ជា**ដង្វាយធួននឹងបាប**យើងរាល់គ្នា មិនត្រឹមតែបាបរបស់យើងរាល់គ្នាតែប៉ុណ្ណោះ គឺ និងបាបរបស់លោកីយ៍ទាំងមូលដែរ»*។ ដំណោះស្រាយតែមួយសំរាប់អំពើបាបដែលយើងប្រព្រឹត្តរាល់ថ្ងៃ គឺជឿទុកចិត្តរាល់ថ្ងៃលើព្រះគ្រីស្ទដែលជា**ដង្វាយធួននឹងបាប**។ ព្រះគ្រីស្ទហើយ គឺជាព្រះដ៏ជាជំនួយ(មេធាវី)នៅចំពោះបល្ល័ង្កនៃព្រះ។ ព្រះវរបិតាមិនអាចបែរចេញពី អ្នកណាដែលព្រះយេស៊ូវបានសង្គ្រោះនោះឡើយ ព្រោះទ្រង់ស្មោះត្រង់ និង សុចរិត។

*«ខ្ញុំសរសេរសេចក្ដីទាំងនេះផ្ញើមកនោះ ដើម្បីកុំឲ្យអ្នករាល់គ្នាធ្វើបាបទៀត»*។ លោកយ៉ូហាន ស្រឡាញ់យើងខ្លាំងណាស់។ គាត់ឃើញថា អំពើបាបកំពុងលួចអំណររបស់យើងហើយ ព្រោះវាប៉ះពាល់ដល់ទំនាក់ទំនងរបស់យើងជាមួយព្រះ។ លោកយ៉ូហាន ចង់ឲ្យយើងសប្បាយចិត្តទាំងស្រុង ដូច្នេះគាត់សរសេរសំបុត្រនេះ *«ដើម្បីកុំឲ្យ[យើង]ធ្វើបាបទៀត»*។ គ្រីស្ទបរិស័ទ គឺជាមនុស្សដែលមិនចង់ធ្វើបាប ព្រោះបាបធ្វើឲ្យព្រះអាប់ឱនកិត្តិយស ហើយធ្វើឲ្យយើងបាត់អំណរ។

*«ខ្ញុំ**សរសេរ**សេចក្ដីទាំងនេះផ្ញើមកនោះ ដើម្បីកុំឲ្យអ្នករាល់គ្នាធ្វើបាបទៀត ...»* សូមកត់សម្គាល់ម្ដងទៀតថា គឺជាព្រះបន្ទូល**សរសេរ**របស់ព្រះអង្គ ដែលជួយយើងឲ្យយកជ័យជំនះលើអំពើបាប។ កុំឲ្យគិតថា អ្នកអាចឈ្នះលើអំពើបាបនោះឡើយ បើអ្នកធ្វេសប្រហែសនឹងព្រះបន្ទូល។ ខ្ញុំធ្លាប់សួរគ្រីស្ទបរិស័ទជាច្រើនពីការអានព្រះគម្ពីរប្រចាំថ្ងៃ ជាធម្មតាគេឆ្លើយដូចនេះ «អូលោក ខ្ញុំរវល់ណាស់!» បន្ទាប់មកខ្ញុំសួរពួកគេអំពីការលេងទូរស័ព្ទរាល់ថ្ងៃ។ គេឱនក្បាល ហើយឆ្លើយថា «បាទរាល់ថ្ងៃ»។ ព្រះ

បន្ទូលព្រះអង្គជួយឲ្យយើងឈ្នះលើបាប។ កុំធ្វេសប្រហែសឡើយ ចូរអានព្រះបន្ទូលរាល់ថ្ងៃ។

សូមសរុបសេចក្តីអំពីទំនាក់ទំនងរវាងគ្រីស្ទបរិស័ទ និងអំពើបាបៈ

- **គ្រីស្ទបរិស័ទពិត**និយាយថា «គោលដៅរបស់ខ្ញុំ គឺមិនធ្វើបាបឡើយ» (២:១)។ ប៉ុន្តែនៅពេលគាត់ធ្វើបាប គ្រីស្ទបរិស័ទដ៏ពិតក៏និយាយភ្លាមថា «ខ្ញុំបានធ្វើបាបហើយ» ហើយគាត់លន់តួបាបគាត់ចំពោះព្រះភ្លាម (១:៩)។ គាត់ទទួលបានការអត់ទោសពីព្រះភ្លាម តាមរយៈព្រះលោហិតរបស់ព្រះគ្រីស្ទ (២:២)។
- ប៉ុន្តែ**គ្រីស្ទបរិស័ទក្លែងក្លាយ**និយាយថា «ខ្ញុំអត់មានបាបទេ» (១:៨)។ ហើយនៅពេលគាត់ធ្វើបាបគាត់ក៏និយាយថា «ខ្ញុំមិនបានធ្វើបាបទេ» (១:១០)។

ឥឡូវនេះយើងដល់ការវិនិច្ឆ័យទី៤របស់លោកយ៉ូហាន ចំពោះគ្រូក្លែងក្លាយ។

## ការវិនិច្ឆ័យទី៤

*១យ៉ូហាន ២:៣-៤*

*យើងរាល់គ្នាដឹងថា យើងស្គាល់ទ្រង់ដោយសារសេចក្តីនេះ គឺដោយយើងកាន់តាមបញ្ញត្តរបស់ទ្រង់ [៤] អ្នកណាដែលថា "ខ្ញុំស្គាល់ទ្រង់" តែមិនកាន់តាមបញ្ញត្តរបស់ទ្រង់ទេ អ្នកនោះឈ្មោះថា ជាអ្នកកុហកហើយសេចក្តីពិតមិននៅក្នុងអ្នកនោះឡើយ។*

**ការវិនិច្ឆ័យទី៤៖ បើអ្នកណានិយាយថា «ខ្ញុំស្គាល់ព្រះ» តែមិនកាន់តាមបទបញ្ញត្តិរបស់ទ្រង់ នោះគាត់ជាអ្នកកុហក។ គ្រីស្ទបរិស័ទពិតដេញតាមភាពបរិសុទ្ធជានិច្ច។**

ការអះអាងថា *«ខ្ញុំស្គាល់ព្រះ»* គឺជារឿងដូចគ្នានឹងការអះអាងថា *«ខ្ញុំកើតពីព្រះ»* ដែរ។ អ្នកណាអះអាងថា ខ្លួនមានព្រះជាព្រះវរបិតា នឹងយកចិត្តទុកដាក់ចំពោះការ

ធ្វើតាមបញ្ញត្តិរបស់ព្រះវរបិតាដែរ។ នៅខនេះលោកយ៉ូហានបានចងភ្ជាប់ការកើតពីព្រះ ជាមួយនឹងការរស់នៅរបៀបបរិសុទ្ធ ដូចនៅក្នុងរូបនេះ។




*«អ្នកណាពោលថា ខ្ញុំស្គាល់ទ្រង់ តែមិនកាន់តាមបញ្ញត្តរបស់ព្រះអង្គ អ្នកនោះនិយាយកុហកហើយ»។ (១យ៉ូហាន ២:៤)*

យើងហៅការនេះថា «ការសាកល្បងនៃសីលធម៌» សំរាប់គ្រូបង្រៀន។ សូមចាំថា ព្រះគម្ពីរបានប្រាប់យើងឲ្យសាកល្បងទាំង**ជីវិត** និង**គោលជំនឿ**របស់គ្រូទាំងអស់នោះ។ សូម្បីតែគ្មានគ្រូបង្រៀនដែលល្អឥតខ្ចោះដូចព្រះយេស៊ូវ គ្រូបង្រៀនពិតនឹងមានទាំង កេរ្តិ៍ឈ្មោះល្អ និងគោលជំនឿល្អ ដូចសាវកប៉ុលបានទូន្មានដល់ធីម៉ូថេ នៅ ១ធីម៉ូថេ ៤:១៦ *«ចូរប្រុងប្រយ័ត្ននឹង**ខ្លួនអ្នក** ហើយនឹង**សេចក្ដីបង្រៀន**»*។

## កេរ្តិ៍ឈ្មោះល្អ និងគោលជំនឿល្អ

### ការសាកល្បងខាងសីលធម៌ចំពោះគ្រូបង្រៀន

គ្រូក្លែងក្លាយច្រើនតែបំពានច្បាប់របស់ព្រះ។ ពួកគេត្រូវបានទាក់ទាញជាពិសេសទៅនឹងអំពើបាបនៃការលោភលន់ ដែលជាការថ្វាយបង្គំរូបព្រះក្នុងចិត្ត (កូល៉ុស ៣:៥; ២ពេត្រុស ២:៣; យូដាសខ ១១) និងបាបនៃអំពើអសីលធម៌ខាងផ្លូវភេទ (២ពេត្រុស ២:១០,១៤)។ ទាំងលោកយូដាស និងលោកពេត្រុសក៏និយាយពីអំពើបាបនៃអំនួតដែរ។

## ការសាកល្បងខាងគោលជំនឿចំពោះគ្រូបង្រៀន




គ្រូក្លែងក្លាយក៏បង្រៀនខុសពីព្រះបន្ទូលរបស់ព្រះ។ ពួកគេមិនទទួលយកគោលលទ្ធិរបស់ព្រះគ្រីស្ទ និងសាវកទ្រង់ ដែលមាននៅក្នុងព្រះគម្ពីរទេ។ ធម្មតាពួកគេផ្តល់ឲ្យយើងនូវព្រះគ្រីស្ទ ខុសពីព្រះគ្រីស្ទដែលពួកសាវកបានប្រកាសប្រាប់យើងនៅក្នុងព្រះគម្ពីរ។ គ្រូខុសឆ្គងក៏តែងតែបង្អាប់ព្រះបន្ទូលរបស់ព្រះអង្គ ហើយលើកដំកើងពាក្យសំដីរបស់គ្រូនោះវិញ។ នៅផ្នែកទីពីរនៃសៀវភៅនេះ យើងនឹងរៀនអំពីគោលលទ្ធិជាច្រើន ដែលគ្រូខុសឆ្គងបង្វែរ និងបដិសេធ។ គ្រូពិតនឹងមានទាំងកេរ្តិ៍ឈ្មោះល្អ និងគោលជំនឿល្អ។

### *១យ៉ូហាន ២:៥-៦*

*...តែអ្នកណាដែលកាន់តាមព្រះបន្ទូលទ្រង់វិញ នោះប្រាកដជាសេចក្ដីស្រឡាញ់នៃព្រះបានពេញខ្នាតនៅក្នុងអ្នកនោះហើយ គឺដោយសេចក្ដីនោះឯងដែលយើងដឹងថាយើងនៅក្នុងទ្រង់។ ៦ អ្នកណាដែលថាខ្លួននៅក្នុងទ្រង់ នោះត្រូវតែប្រព្រឹត្តដូចជាទ្រង់ដែរ។*

*«សេចក្តីស្រឡាញ់នៃព្រះ»* អាចមានន័យថា សេចក្តីស្រឡាញ់នៃព្រះអម្ចាស់ចំពោះយើង ឬសេចក្តីស្រឡាញ់របស់យើងចំពោះព្រះ ឬសេចក្តីស្រឡាញ់ដែលព្រះឲ្យយើងសម្រាប់អ្នកឯទៀត។ អត្ថន័យនៅទីនេះ គឺប្រហែលជា «សេចក្តីស្រឡាញ់របស់យើងចំពោះព្រះបានពេញខ្នាត» ពីព្រោះ ៥:៣ មានបន្ទូលថា *«ដ្បិតនេះហើយជាសេចក្ដីស្រឡាញ់ដល់ព្រះ គឺឲ្យយើងកាន់តាមអស់ទាំងបញ្ញត្តិរបស់ទ្រង់»*។ ដូច្នេះអត្ថន័យ ១យ៉ូហាន ២:៥ គឺថា «សេចក្តីស្រឡាញ់របស់យើងចំពោះព្រះ បានពេញខ្នាត នៅពេលយើងកាន់តាមបញ្ញត្តិទ្រង់» ដូចក្នុងរូបនេះ។




*«តែអ្នកណាដែល**កាន់តាមព្រះបន្ទូល**ទ្រង់វិញ នោះប្រាកដជាសេចក្ដីស្រឡាញ់នៃព្រះបានពេញខ្នាតនៅក្នុងអ្នកនោះហើយ»។ (១យ៉ូហាន ២:៥)*

ការអះអាងថា «ខ្លួននៅក្នុងព្រះគ្រីស្ទ» និង«ខ្លួននៅជាប់នឹងព្រះគ្រីស្ទ» គឺដូចគ្នានឹងការអះអាងថា «បានកើតពីព្រះ»ដែរ។ «គ្រីស្ទបរិស័ទ» មានន័យថា អ្នកដែលជឿហើយដើរតាមព្រះគ្រីស្ទ។ ព្រះគ្រីស្ទបានរស់នៅក្នុងជីវិតនៃ ភាពបរិសុទ្ធ សេចក្ដីពិត និងសេចក្ដីស្រឡាញ់ ដូច្នេះការដើរតាមព្រះគ្រីស្ទមានន័យថា យើងក៏រស់នៅក្នុងជីវិតនៃភាពបរិសុទ្ធ សេចក្ដីពិត និងសេចក្ដីស្រឡាញ់ដែរ។ ហើយពេលណាយើងមិនបានរស់នៅក្នុងជីវិតបែបនេះ យើងលន់តួបាបចំពោះព្រះភ្លាម។

ដើម្បីរៀបចំយើងសម្រាប់ការវិនិច្ឆ័យទី៥ អំពីសេចក្ដីស្រឡាញ់ លោកយ៉ូហានរំឭកយើងអំពីបញ្ញត្តិរបស់ព្រះឲ្យចេះស្រឡាញ់ព្រះ និងអ្នកដទៃ។ ដោយសារព្រះជាសេចក្ដីស្រឡាញ់ អ្នកណាកើតពីព្រះ នឹងស្រឡាញ់ព្រះ និងស្រឡាញ់អ្នកដទៃទៀត។ ការស្រឡាញ់គ្នាទៅវិញទៅមក ដូចព្រះគ្រីស្ទបានស្រឡាញ់យើង គឺជា «បញ្ញត្តថ្មី» របស់ព្រះយេស៊ូវ។

## *១យ៉ូហាន ២:៧-៨*

*ពួកស្ងួនភ្ងាអើយ សេចក្ដីដែលខ្ញុំសរសេរផ្ញើមកអ្នករាល់គ្នានោះ មិនមែនជាបញ្ញត្តថ្មីទេ គឺជាបញ្ញត្តចាស់ដដែល ដែលអ្នករាល់គ្នាមានតាំងពីដើមមក។ ឯបញ្ញត្តចាស់នោះ គឺជាព្រះបន្ទូលដែលអ្នករាល់គ្នាបានឮហើយ។ ៨ ខ្ញុំក៏សរសេរបញ្ញត្ត១ថ្មីទៀតផ្ញើមកអ្នករាល់គ្នា ជាសេចក្ដីពិតដែលនៅក្នុងទ្រង់ ហើយក្នុងអ្នករាល់គ្នាដែរ ដ្បិតសេចក្ដីងងឹតកំពុងតែបាត់ទៅ ហើយពន្លឺដ៏ពិតបានភ្លឺឡើង។*

លោកយ៉ូហានបានសរសេរសំបុត្រនេះ ជាច្រើនឆ្នាំបន្ទាប់ពីព្រះគ្រីស្ទបានយាងឡើងទៅស្ថានសួគ៌វិញ។ ពេលព្រះយេស៊ូវគង់នៅផែនដីនៅឡើយ ព្រះអង្គបានប្រទាន *«បញ្ញត្តថ្មី»*ដល់សិស្សទ្រង់ នៅយ៉ូហាន ១៣:៣៤ ថា៖ *«ខ្ញុំឲ្យបញ្ញត្តថ្មីដល់អ្នករាល់គ្នា គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ គឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក»*។ គម្ពីរសញ្ញាចាស់បានបង្គាប់រាស្ត្ររបស់អង្គហើយថា «ត្រូវស្រឡាញ់ព្រះ» និង «ត្រូវស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង»។ ដូច្នេះនៅពេលព្រះយេស៊ូវបង្គាប់សិស្សឲ្យ *«ស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់ដល់អ្នករាល់គ្នា»* នោះគឺជាបញ្ញត្តិចាស់ផង ហើយជាបញ្ញត្តថ្មីផង។ *«ស្រឡាញ់គ្នា»* ជាបញ្ញត្តិចាស់ ប៉ុន្តែ ***«ស្រឡាញ់គ្នាដូចខ្ញុំបានស្រឡាញ់ដល់អ្នករាល់គ្នា»*** គឺជាកម្រិតថ្មីដែលខ្ពស់ជាងបញ្ញត្តិចាស់។ *«ស្រឡាញ់គ្នាទៅវិញទៅមក»* គឺជាខ្លឹមសារចម្បងមួយរបស់ព្រះគ្រីស្ទ និងពួកសាវករបស់ទ្រង់៖

*«ស្រឡាញ់គ្នា»* (យ៉ូហាន ១៣:៣៤)
*«ស្រឡាញ់ដល់គ្នា»* (យ៉ូហាន ១៣:៣៥)
*«ស្រឡាញ់ដល់គ្នា»* (យ៉ូហាន ១៥:១២)
*«ស្រឡាញ់គ្នា»* (យ៉ូហាន ១៥:១៧)
*«ស្រឡាញ់ជាបងជាប្អូន»* (រ៉ូម ១២:១០)
*«សេចក្តីស្រឡាញ់...ដល់គ្នា»* (១ថែស្សា ៣:១២)
*«ស្រឡាញ់គ្នា»* (១ពេត្រុស ១:២២)
*«ស្រឡាញ់គ្នា»* (១យ៉ូហាន ៣:១១)
*«ស្រឡាញ់គ្នា»* (១យ៉ូហាន ៣:២៣)
*«ស្រឡាញ់គ្នា»* (១យ៉ូហាន ៤:៧)
*«ស្រឡាញ់គ្នា»* (១យ៉ូហាន ៤:១១)
*«ស្រឡាញ់គ្នា»* (១យ៉ូហាន ៤:១២)
*«ស្រឡាញ់ដល់គ្នាទៅវិញទៅមក»* (២យ៉ូហាន ៥)

តើលោកយ៉ូហានគិតថា គ្រីស្ទបរិស័ទដែលទទួលសំបុត្រនេះ មិនស្រឡាញ់គ្នាទេឬ? ទេ ផ្ទុយទៅវិញ គាត់ច្បាស់ណាស់ថា បញ្ញត្តថ្មីនេះដែលជា *«សេចក្តីពិតក្នុង [ព្រះយេស៊ូវ]»* ក៏ជាសេចក្តីពិតចំពោះ *«អ្នករាល់គ្នា»* ដែរ។ តាមពិតរបៀបមួយដែលពួកគេដឹងថា *«សេចក្តីងងឹតកំពុងតែបាត់ទៅហើយពន្លឺដ៏ពិតបានភ្លឺឡើង»* គឺថា

ពួកគេស្រឡាញ់គ្នាទៅវិញទៅមក។ ហើយវិធីមួយដែលគេអាចដឹងថា គ្រូមួយជាគ្រូក្លែងក្លាយ គឺគាត់មិនស្រឡាញ់គ្នា ដូចជាព្រះយេស៊ូវបានស្រឡាញ់យើង។

ឥឡូវនេះយើងនឹងសិក្សាការវិនិច្ឆ័យទី៥ អំពីគ្រូក្លែងក្លាយ (ឬគ្រីស្ទបរិស័ទក្លែងក្លាយ) ដែលជាការសាកល្បងនៃសេចក្តីស្រឡាញ់។

## ការវិនិច្ឆ័យទី៥

***១យ៉ូហាន ២:៩-១១***

*អ្នកណាដែលថាខ្លួននៅក្នុងពន្លឺ តែស្អប់ដល់បងប្អូននោះឈ្មោះថា នៅក្នុងសេចក្តីងងឹតដរាបដល់សព្វថ្ងៃនេះ។*
*[10] ឯអ្នកណាដែលស្រឡាញ់ដល់បងប្អូនខ្លួននោះតែងនៅក្នុងពន្លឺវិញ ហើយនៅក្នុងអ្នកនោះគ្មានហេតុណានឹងបង្អាក់បង្អន់ចិត្តគេឡើយ។*
*[11] តែអ្នកណាដែលស្អប់ដល់បងប្អូននោះឈ្មោះថា នៅក្នុងសេចក្តីងងឹតវិញ ក៏ដើរក្នុងសេចក្តីងងឹតហើយមិនដឹងជាខ្លួនទៅឯណាផងពីព្រោះសេចក្តីងងឹតនោះបានបំបាំងភ្នែកហើយ។*

**ការវិនិច្ឆ័យទី៥៖ បើអ្នកណានិយាយថា «ខ្ញុំដើរក្នុងពន្លឺនៃសេចក្តីពិត» ប៉ុន្តែស្អប់បងប្អូនគាត់ នោះគាត់នៅក្នុងភាពងងឹតនៅឡើយ គ្រូបង្រៀនពិត ទាំងជឿការពិតអំពីព្រះយេស៊ូវផង ហើយស្រឡាញ់អ្នកដទៃផង។**

*«អ្នកណានិយាយថា ខ្លួននៅក្នុងពន្លឺ...»* អ្នកនេះអះអាងថា គាត់«ដើរក្នុងពន្លឺ» (គឺជឿការពិត) តែគាត់បដិសេធបញ្ញត្តិថា «ចូរស្រឡាញ់គ្នា»។ លោកយ៉ូហាន មិនអនុញ្ញាតឲ្យអ្នកនេះជ្រើសរើសរវាងគោលជំនឿ និង សេចក្តីស្រឡាញ់ទេ។ គោលជំនឿ និងសេចក្តីស្រឡាញ់ត្រូវតែផ្សារភ្ជាប់គ្នាជានិច្ចនៅក្នុងគ្រីស្ទសាសនាពិត។ បើគ្រូបង្រៀនអះអាងថា ខ្លួនបង្រៀនសេចក្តីពិត ប៉ុន្តែគាត់កាច និងមិន

សប្បុរស ចំពោះអ្នកដែលនៅក្រោមគាត់ នោះគាត់នៅតែស្ថិតក្នុងសេចក្ដីងងឹត ពីព្រោះ *«អ្នកណាស្អប់បងប្អូនខ្លួន អ្នកនោះស្ថិតនៅក្នុងសេចក្ដីងងឹត ហើយដើរក្នុងសេចក្ដីងងឹត ហើយមិនដឹងជា ខ្លួនទៅទីណាទេ ពីព្រោះសេចក្ដីងងឹតបានបំបាំងភ្នែកគាត់ហើយ»*។

នៅខប្រាំបួនលោកយ៉ូហានផ្សារភ្ជាប់ ការពិត និងសេចក្ដីស្រឡាញ់ដូចនៅក្នុងរូបនេះ។




*«អ្នកណានិយាយថា* ***ខ្លួននៅក្នុងពន្លឺតែស្អប់បងប្អូនវិញ*** *អ្នកនោះស្ថិតនៅក្នុងសេចក្ដីងងឹតនៅឡើយ»។ (១យ៉ូហាន ២:៩)*

( សូមកត់សម្គាល់ថា ការវិនិច្ឆ័យទី៥ ត្រូវបានលើកឡើងម្ដងទៀតនៅក្នុង ១យ៉ូហាន៤:២០ )។

# ការប្រឆាំងនឹងគ្រូក្លែងក្លាយជាបញ្ហាបែបគ្រួសារ

## ១យ៉ូហាន ២:១២-១៤

បីខបន្ទាប់ ក្នុងកណ្ឌយ៉ូហានខ្សែទី១ ធ្វើឲ្យយើងឆ្ងល់ណាស់។ លោកយ៉ូហានទើបបានចំណាយ២១ខដំបូង នៃកណ្ឌគម្ពីរយ៉ូហានខ្សែទី១ ដើម្បីព្រមានដល់ពួកគ្រីស្ទបរិស័ទអំពីការបង្រៀនខុសឆ្គង ហើយផ្តល់ឲ្យយើងនូវវិធី៥យ៉ាង ដើម្បីធ្វើការវិនិច្ឆ័យការបង្រៀនខុសឆ្គង។ តែភ្លាមៗនោះ គាត់សរសេរបទចំរៀងនៃក្តីស្រឡាញ់មួយ អំពីសមាជិកក្រុមជំនុំនោះ! សូមអានបទចំរៀងនៃក្តីស្រឡាញ់ដ៏ពីរោះនេះ៖

***១យ៉ូហាន ២:១២-១៤***

*១២ កូនតូចៗរាល់គ្នាអើយ! ខ្ញុំសរសេរផ្ញើមកអ្នករាល់គ្នា*
*ពីព្រោះទ្រង់បានអត់ទោសបាបរបស់អ្នករាល់គ្នាហើយ ដោយយល់ដល់ព្រះនាមទ្រង់*
*១៣ ឪពុករាល់គ្នាអើយ ខ្ញុំសរសេរផ្ញើមកអ្នករាល់គ្នា*
*ពីព្រោះបានស្គាល់ព្រះដែលទ្រង់គង់នៅតាំងពីដើមរៀងមក។*
*កំឡោះរាល់គ្នាអើយ ខ្ញុំសរសេរផ្ញើមកអ្នករាល់គ្នា*
*ពីព្រោះបានឈ្នះមេកំណាចហើយ។*

*ក្មេងរាល់គ្នាអើយ ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា*
*ពីព្រោះបានស្គាល់ព្រះវរបិតា។*
*១៤ ឪពុករាល់គ្នាអើយ ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា*
*ពីព្រោះបានស្គាល់ព្រះដែលគង់នៅតាំងពីដើមរៀងមក។*
*កំឡោះរាល់គ្នាអើយ ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា*
*ពីព្រោះមានកម្លាំង ហើយព្រះបន្ទូលក៏ស្ថិតនៅក្នុងអ្នករាល់គ្នា*
*អ្នករាល់គ្នាបានឈ្នះមេកំណាចហើយ។*

ហេតុអ្វីជាលោកយ៉ូហានសរសេរបទចំរៀងនៃក្តីស្រឡាញ់អំពីគ្រីស្ទបរិស័ទទាំងនេះ នៅក្នុងសំបុត្រអំពីគ្រូក្លែងក្លាយទៅវិញ ? មានមូលហេតុ៣៖

**១. លោក យ៉ូហានបានសរសេរបទចម្រៀងនេះ ដើម្បីអបអរជ័យជំនះដ៏អស្ចារ្យលើគ្រូខុសឆ្គង**

លោក យ៉ូហានបានសរសេរបទចម្រៀងនៃសេចក្តីស្រឡាញ់នេះ ពីព្រោះគ្រីស្ទបរិស័ទទាំងនេះ បានជំទាស់ និងបណ្តេញគ្រូក្លែងក្លាយដោយជោគជ័យ! ការតយុទ្ធនេះពិបាកមែនទែន ឥឡូវជាពេលដែលត្រូវអបអរសាទរចំពោះជ័យជំនះនេះ! ជាញឹកញាប់ណាស់ ក្នុងប្រវត្តិសាស្ត្រក្រុមជំនុំ គឺជាគ្រូខុសឆ្គង និងអ្នកដើរតាមពួកគេទេ ដែលបណ្តេញអ្នកជឿពិតវិញ។ រឿងនេះច្រើនតែកើតឡើង ពីព្រោះអ្នកជឿពិតប្រាកដ រង់ចាំយូរពេកមុនពេលពួកគេសំរេចចិត្តជំទាស់នឹងការបង្រៀនខុសឆ្គង។

ពីរដងបទចម្រៀងនេះសរសើរសមាជិកក្រុមជំនុំ ពីព្រោះពួកគេបានយក*«ឈ្នះលើមេកំណាចហើយ»*។ (សូមអានផងដែរនៅ១យ៉ូហាន ៤:៤; ៥:៤,៥ និង វិវរណៈ ២:៧,១១,១៧,២៦; ៣:៥,១២,២១ ដែលយើងឃើញពាក្យឈ្នះ និងជ័យជំនះ)។ កុំនឹកស្មានថា គ្រូក្លែងក្លាយបានចាកចេញដោយស្ម័គ្រចិត្តនោះឡើយ (២:១៩)។ គ្រូក្លែងក្លាយមិនដែលចាកចេញដោយស្ម័គ្រចិត្តនោះទេ។ ពិតជាមានការប្រយុទ្ធខ្លាំងខាងព្រលឹងវិញ្ញាណ ហើយគ្រូក្លែងក្លាយបានចាញ់សង្គ្រាម ហាលេលូយ៉ា ! ឪពុកម្តាយ កំលោះក្រមុំ ដ៏ខ្លាំងនិងស្មោះត្រង់បានយកឈ្នះលើគ្រូខុសឆ្គង ពីព្រោះពួកគេ *«ស្គាល់ព្រះដែលទ្រង់គង់នៅតាំងពីដើមរៀងមក»* ហើយនិង *«ព្រះបន្ទូលនៃព្រះស្ថិតនៅក្នុង[ពួកគេ]»* (១យ៉ូហាន ២:១៣-១៤)។

វាហាក់ដូចជាលោកយ៉ូហាន ផ្តល់ការសរសើរភាគច្រើនចំពោះជ័យជំនះនេះ ដល់អ្នកដឹកនាំវ័យក្មេងនៃក្រុមជំនុំ។ គាត់មានប្រសាសន៍ពីរដងថា អ្នកដឹកនាំវ័យក្មេងនេះ *«បានឈ្នះមេកំណាចហើយ»*។ គាត់ក៏មានប្រសាសន៍ផងដែរថា អ្នកដឹកនាំវ័យក្មេង

ទាំងនេះខ្លាំង ហើយ *«ព្រះបន្ទូលព្រះស្ថិតនៅជាប់នឹង[ពួកគេ]»*។ សូមសរសើរតម្កើងព្រះចំពោះអ្នកដឹកនាំវ័យក្មេងក្នុងក្រុមជំនុំយើង ដែលស្រឡាញ់កូនចៀមយ៉ាងខ្លាំង គឺគេមិនទុកឲ្យចចកបំផ្លាញឡើយ!

## ២. លោក យ៉ូហានបានសរសេរបទចម្រៀងនេះ ដើម្បីបង្ហាញថា ការជំទាស់នឹងគ្រូខុសឆ្គង គឺជាបញ្ហាបែបគ្រួសារ

សូមសម្គាល់ពី ទំនាក់ទំនងបែបគ្រួសារក្នុងបទចម្រៀងនេះ។ បើក្រុមជំនុំពិតជាគ្រួសារ ហើយបើយើងពិតជាស្រឡាញ់គ្នាដូចជាសមាជិកគ្រួសារ ដូច្នេះសមាជិកគ្រួសារទាំងអស់នឹងរួមគ្នាដើម្បីបញ្ឈប់ឥទ្ធិពលនៃគ្រូក្លែងក្លាយដែលជាឆ្កែចចកពាក់រោមចៀម។

## ៣. លោក យ៉ូហានបានសរសេរបទចម្រៀងនេះ ដើម្បីបញ្ជាក់ថា យើងត្រូវស្គាល់ព្រះជាម្ចាស់ និងព្រះបន្ទូលរបស់ទ្រង់ ដើម្បីស្គាល់ព្រះក្លែងក្លាយ

បីដងក្នុងបទចម្រៀងនេះគាត់ថា *«ព្រោះបានស្គាល់ព្រះ»*។ ហើយម្តង គាត់និយាយថា *«ព្រះបន្ទូលក៏ស្ថិតនៅក្នុងអ្នករាល់គ្នា»*។ ហើយប្រាំមួយដងគាត់ថា *«ខ្ញុំសរសេរផ្ញើមកអ្នករាល់គ្នា»*។ ដើម្បីស្គាល់ព្រះក្លែងក្លាយ យើងត្រូវស្គាល់ព្រះពិតប្រាកដ តាមរយៈដំណឹងល្អនៃព្រះគ្រីស្ទនៅក្នុងព្រះគម្ពីរ។

## ក្រុមជំនុំ ជាក្រុមគ្រួសារ

ដូចខ្ញុំនិយាយអម្បាញ់មិញ បទចម្រៀងរបស់លោកយ៉ូហាន រំឭកយើងថា ក្រុមជំនុំជាក្រុមគ្រួសារ។ បទនោះនិយាយពីអ្នកក្មេងៗក្នុងជំនឿ ពួកកំឡោះក្នុងជំនឿ (ប្រាកដជារួមទាំងយុវនារីផង) និងឪពុកនៅក្នុងជំនឿ (ប្រាកដជារួមទាំងម្តាយផង)។ លោកយ៉ូហាន ចង់ឲ្យយើងយល់ថា *ការជំទាស់ទៅនឹងការបង្រៀនខុសឆ្គង គឺជាបញ្ហាបែបគ្រួសារ ជាបញ្ហានៃសេចក្តីស្រឡាញ់ និងភក្តីភាពក្នុងគ្រួសារ*។ ការបង្រៀនខុសឆ្គង បានធ្វើឲ្យសេចក្តីសង្គ្រោះនៃគ្រួសារជំនុំ អាចធ្លាក់ក្នុងហានិភ័យ។

លោកយ៉ូហានស្គាល់ និងស្រឡាញ់សមាជិកក្រុមជំនុំទាំងអស់នេះ ដូចស្រឡាញ់ក្រុមគ្រួសារខ្លួនឯង។

គ្រីស្ទបរិស័ទខ្លះមិនចូលចិត្តការប្រឆាំងនឹងការបង្រៀនខុសឆ្គងឡើយ។ ពួកគេចង់ធ្វើរបៀបស្លូតចំពោះមនុស្សទាំងអស់ រួមទាំងគ្រូក្លែងក្លាយផង។ ពិតមែនមនុស្សខ្លះដែលចូលចិត្តជំទាស់នឹងការបង្រៀនខុសឆ្គង ហាក់ដូចជាខឹងរហូត ជំនួសឲ្យការពេញដោយសេចក្ដីស្រឡាញ់ និងភាពអាណិតអាសូរ ហើយគ្រីស្ទបរិស័ទមិនចង់ក្លាយជាមនុស្សបែបនោះទេ។ ប៉ុន្តែលោកយ៉ូហាន ចង់ឲ្យយើងដឹងថា ការជំទាស់ទៅនឹងសាសនាខុសឆ្គង គឺជាបញ្ហាសេចក្ដីស្រឡាញ់ក្នុងគ្រួសារ។ បងប្អូន ឪពុកម្ដាយ និងកូនក្នុងព្រលឹងវិញ្ញាណខ្លះនឹងបែរចេញពីព្រះអង្គ ដោយសារការបង្រៀនខុសឆ្គង គឺជាមនុស្សដែលយើងស្គាល់ និងស្រឡាញ់។ បើយើងពិតជាស្រឡាញ់អ្នកណា យើងនឹងចង់ការពារអ្នកនោះពីថ្នាំពុល។

កុំខ្មាសអៀននឹងការជំទាស់ទៅនឹងសាសនាខុសឆ្គងឡើយ។ តាមបណ្ដាញសង្គមមានពេញដោយ ឪពុកម្ដាយជាច្រើនព្រមានមិត្តភក្តិអំពីអាហារ ឬថ្នាំ ឬវ៉ាក់សាំងដែលអាចប៉ះពាល់ដល់សុខភាពកូនៗរបស់គេ។ យើងយល់ពីការព្រួយបារម្ភនេះ ពីព្រោះយើងស្រឡាញ់សមាជិកគ្រួសារយើង ហើយចង់ការពារពួកគេពីម្ហូប ឬថ្នាំមិនល្អ។ តើយើងគួរតែការពារសមាជិកគ្រួសារយើងលើសអម្បាលម៉ានទៅទៀត នៅពេលជីវិតអស់កល្បរបស់គេស្ថិតនៅលើហានិភ័យ។

> **ឧទាហរណ៍៖** កាលពីឆ្នាំមុនសមាជិកក្រុមជំនុំខ្ញុំម្នាក់ បានទុកសៀវភៅនៅផ្ទះខ្ញុំសម្រាប់ឲ្យសមាជិកគ្រួសារខ្ញុំអាន។ គាត់បាននិយាយថា សៀវភៅនោះនឹងពន្យល់ពីជំនឿថ្មីខ្លះរបស់គាត់ គឺជំនឿដែលក្រុមជំនុំរបស់យើងចាត់ទុកថា ជាគោលជំនឿខុសឆ្គង។ នៅពេលខ្ញុំក្រឡេកមើលសៀវភៅនោះ ខ្ញុំឃើញថា វាសរសេរដោយគ្រូខុសឆ្គងដ៏ល្បីល្បាញម្នាក់។ ដូច្នេះដោយខ្ញុំ

ស្រឡាញ់មិត្ត ដែលបាននាំគោលជំនឿខុសឆ្គងចូលក្នុងផ្ទះខ្ញុំ ហើយដោយខ្ញុំស្រឡាញ់សមាជិកគ្រួសារខ្ញុំ នោះខ្ញុំបានកែតម្រង់គាត់ក្នុងសេចក្ដីស្រឡាញ់ ហើយហាមគាត់ កុំឲ្យគាត់នាំគោលជំនឿខុសឆ្គងចូលក្នុងផ្ទះខ្ញុំទៀត ព្រោះជាថ្នាំពុល។

ក្រោយមកខ្ញុំចាប់ផ្ដើមសង្ស័យថា ប្រតិកម្មរបស់ខ្ញុំនោះខ្លាំងពេក។ ខ្ញុំដឹងថាសមាជិកគ្រួសាររបស់ខ្ញុំ គឺជាគ្រីស្ទបរិស័ទដ៏រឹងមាំ។ ពួកគេប្រាកដជានឹងឃើញកំហុសនៅក្នុងសៀវភៅ ហើយបដិសេធវា (ហើយពួកគេបានបដិសេធមែន)។ ប៉ុន្តែអ្នកនិពន្ធសៀវភៅនោះ គឺជាអ្នកនិពន្ធដ៏ពូកែម្នាក់ ដែលអាចធ្វើឲ្យការកុហករបស់សាតាំង ហាក់ដូចជាពិត ហើយគួរឲ្យទទួលយកបាន។ សូមចាំថា ទោះបីអ័ដាម និងអេវ៉ាមានប្រាជ្ញាខ្ពស់ ហើយមិនទាន់មាននិស្ស័យបាបនៅឡើយ ក៏ពួកគេចាញ់នឹងការភូតកុហកដ៏ឆ្លាតរបស់សាតាំងដែរ។ ការការពារកូនខាងវិញ្ញាណ ពីការបង្រៀនខុសឆ្គង គឺជាបញ្ហាបែបគ្រួសារ។ បើយើងស្រឡាញ់ក្មេងៗ បងប្អូន ឪពុកម្ដាយខាងវិញ្ញាណ នៅក្នុងក្រុមជំនុំយើង យើងនឹងការពារពួកគេពីថ្នាំពុលខាងវិញ្ញាណ។ យើងត្រូវតែមានចិត្តហ្មត់ចត់ ចំពោះមនុស្សដែលនាំការបង្រៀនខុសឆ្គងចូលមកក្នុងជីវិតយើង ទោះជាពួកគេជាមិត្តភក្តិ ឬសាច់ញាតិយើងក៏ដោយ។

សូមកត់សម្គាល់ថា លោកយ៉ូហាន ប្រើពាក្យគ្រួសារច្រើននៅកណ្ឌយ៉ូហានខ្សែទី១។ លោកប្រើពាក្យ«បងប្អូន» ១៤ដង។ លោកហៅពួកគ្រីស្ទបរិស័ទថា «កូន» ឬ «ក្មេង» ១៣ដង (រួមទាំង «កូនតូចៗ» ៧ដង) ហើយលោកប្រើពាក្យ «ឪពុក(ម្ដាយ)» ២ដង។ លោកយ៉ូហានមានប្រសាសន៍៩ដងអំពីការកើតក្នុងគ្រួសារនៃព្រះ ហើយលោកមានប្រសាសន៍១៣ដងថា ព្រះជា «ព្រះវរបិតានៃយើង»។ គ្រីស្ទសាសនាពិតគឺជាសាសនានៃទំនាក់ទំនងបែបគ្រួសារ។ (សូមមើល ឧបសម្ពន្ធ៤ អំពីទំនាក់ទំនងគ្រួសារនៅយ៉ូហានខ្សែទី១)

# ការអាក្រក់ខាងលោកិយ
# និងការអាក្រក់ខាងអាទទឹងនឹងព្រះគ្រីស្ទ

## ១យ៉ូហាន ២:១៥-១៩

បន្ទាប់ពីបទចំរៀងដ៏ពីរោះនេះ អំពីក្រុមគ្រួសារក្រុមជំនុំ លោកយ៉ូហានបានព្រមានពួកគេ អំពីការអាក្រក់ទូទៅពីរប្រភេទក្នុងផែនដីនេះ ដែលអាចជះឥទ្ធិពលដល់ក្រុមជំនុំ៖

**១. ការអាក្រក់ខាងលោកិយ** (**ខាងសីលធម៌**) ១យ៉ូហាន ២:១៥-១៧
**២. ការអាក្រក់ខាងអាទទឹងនឹងព្រះគ្រីស្ទ** (**ខាងគោលជំនឿ ឬទស្សនវិជ្ជា**)
១យ៉ូហាន ២:១៨-១៩

ការអាក្រក់ទាំងពីរយ៉ាង អាចបំផ្លាញមនុស្ស ហើយទាញពួកគេចេញពីព្រះ និងពីគ្រួសារទ្រង់។

### ការអាក្រក់ខាងលោកិយ (ខាងសីលធម៌)

***១យ៉ូហាន ២:១៥-១៧***

*កុំឲ្យស្រឡាញ់លោកីយ៍ឬរបស់អ្វីនៅក្នុងលោកីយ៍នេះឲ្យសោះ បើអ្នកណាស្រឡាញ់លោកីយ៍អ្នកនោះគ្មានសេចក្តីស្រឡាញ់របស់ព្រះវរបិតានៅក្នុងខ្លួនឡើយ។ ១៦ ដ្បិតអស់ទាំងសេចក្តីដែលនៅក្នុងលោកីយ៍នេះ គឺជាសេចក្តីប៉ងប្រាថ្នារបស់សាច់ឈាម និងសេចក្តីប៉ងប្រាថ្នារបស់ភ្នែក ហើយសេចក្តីអំនួតរបស់ជីវិត នោះមិនកើតមកពីព្រះវរបិតាទេ គឺមកតែពីលោកីយ៍នេះវិញ។ ១៧ ឯលោកីយ៍នេះ និងសេចក្តីប៉ងប្រាថ្នា*

*របស់វា នោះកំពុងកន្លងទៅ តែអ្នកណាដែលធ្វើតាមព្រះហឫទ័យព្រះ នោះនឹងនៅជាប់អស់កល្បជានិច្ចវិញ។*

ជាថ្មីម្តងទៀតលោកយ៉ូហានមានប្រសាសន៍ថា អ្នកដែលពិតជាស្រឡាញ់ព្រះ ត្រូវតែរស់នៅក្នុងជីវិតដ៏បរិសុទ្ធ ដូចដែលរូបនេះបង្ហាញ។




*«បើអ្នកណាស្រឡាញ់លោកីយ៍អ្នកនោះគ្មានសេចក្តីស្រឡាញ់របស់ព្រះវរបិតានៅក្នុងខ្លួនឡើយ»។ (១យ៉ូហាន ២:១៥)*

មុខជាគ្រូក្លែងក្លាយមួយចំនួនដែលបានចាកចេញពីក្រុមជំនុំ បានបង្ហាញថា ខ្លួនគេនៅក្រៅក្រុមគ្រួសាររបស់ព្រះ ដោយសេចក្តីស្រឡាញ់របស់គេចំពោះលោកិយ គឺពួកគេបានស្រឡាញ់ *«សេចក្តីប៉ងប្រាថ្នារបស់សាច់ឈាម និងសេចក្តីប៉ងប្រាថ្នារបស់ភ្នែក ហើយសេចក្តីអំនួតរបស់ជីវិត»*។ ព្រះជាពន្លឺ(ភាពបរិសុទ្ធ) ហើយអ្នកដែលកើតពីព្រះពិតប្រាកដ នឹងយកចិត្តទុកដាក់តាមបញ្ញត្តិសីលធម៌របស់ព្រះ។ តែសូម្បីតែគ្រីស្ទបរិស័ទស្មោះត្រង់នៅជាប់ក្នុងក្រុមជំនុំ ក៏ត្រូវការការព្រមាននេះដែរ អំពីការស្រឡាញ់លោកិយ។

តើលោកយ៉ូហានចង់មានន័យយ៉ាងដូចម្តេច នៅពេលគាត់និយាយថា *«កុំស្រឡាញ់លោកិយ»*? គាត់មិនចង់មានន័យថា យើងមិនត្រូវស្រឡាញ់ភពផែនដីនោះទេ។ ផែនដីគឺជាអំណោយរបស់ព្រះដែលទ្រង់ហៅថា *«ល្អប្រពៃ»* (លោកុប្បត្តិ ១:៣១) ហើយយើងគួរតែបង្ហាញការដឹងគុណ ចំពោះព្រះជាម្ចាស់ សម្រាប់អំណោយនេះ ដោយការថែទាំវា។ (ប៉ុន្តែសូមប្រយ័ត្ន កុំឲ្យយើងស្រឡាញ់ភពផែនដីជាងព្រះនោះ

ឡើយ!) លោកយ៉ូហានក៏មិនមែនមានន័យថា យើងមិនត្រូវស្រឡាញ់**មនុស្ស**នៅលើពិភពលោកដែរ។ ព្រះជាម្ចាស់បានបង្គាប់ឲ្យយើងស្រឡាញ់អ្នកជិតខាងរបស់យើង ហើយនោះរួមទាំងមនុស្សទាំងអស់នៅក្នុងពិភពលោកនេះដែរ សូម្បីតែសត្រូវរបស់យើងក៏ដោយ។ (ប៉ុន្តែសូមប្រយ័ត្ន កុំឲ្យយើងស្រឡាញ់បុគ្គលពិសេសម្នាក់ជាងព្រះនោះឡើយ!)។

នៅក្នុងខទាំងនេះពាក្យថា លោកិយសំដៅទៅ គ្រប់ទាំងការបះបោររបស់មនុស្សជាតិ និងពួកអារក្សទាស់នឹង ព្រះអាទិករ និងផែនការបរិសុទ្ធរបស់ទ្រង់ រួមទាំង ការដាក់អាទិភាពលើអ្វីដែលខុសនឹងព្រះជាម្ចាស់ និងអាទិភាពរបស់ទ្រង់។ គឺជាអ្វីៗដែលមនុស្ស និងអារក្សបានលើកដំកើងឡើងឲ្យស្មើនឹងព្រះ។

គ្រីស្ទបរិស័ទជាច្រើនដែលបានចាកចេញពីជំនឿលើព្រះយេស៊ូវ មិនចេញដោយសារការអាក្រក់ខាងគោលជំនឿទេ តែការអាក្រក់ខាងសីលធម៌វិញ។ ពួកគេធ្លាក់ចូលទៅក្នុងអំពើបាបធម្មតា ដែលបានបំផ្លាញជនជាតិអ៊ីស្រាអែលនៅទីរហោស្ថាន (១កូរិនថូស ១០:៦-១០) ហើយដែលបានបណ្តាលឲ្យយូដាស និងដេម៉ាស បោះបង់ចោលជំនឿ គឺអំពើបាបធម្មតា ដូចជាអំពើអសីលធម៌ខាងផ្លូវភេទ ការលោភលន់ អំនួត និង អំពើមន្តអាគម។ លោកយ៉ូហាន សង្ខេបអំពើការអាក្រក់របស់លោកីយ៍ ដោយការពិពណ៌នាដ៏ល្បីថា *«សេចក្តីប៉ងប្រាថ្នារបស់សាច់ឈាម និងសេចក្តីប៉ងប្រាថ្នារបស់ភ្នែក ហើយសេចក្តីអំនួតរបស់ជីវិត»*។

វាមិនសូវពិបាកយល់ពីអត្ថន័យ សេចក្តីប៉ងប្រាថ្នារបស់សាច់ឈាម និងសេចក្តីប៉ងប្រាថ្នារបស់ភ្នែក ប៉ុន្តែ តើអំនួតរបស់ជីវិត មានន័យយ៉ាងម៉េច? គន្លឹះដើម្បីយល់ឃ្លានេះ គឺពាក្យ«អំនួត»។ អំនួត តែងតែជាអំពើបាបនៃការប្រៀបធៀប ដូចអំពើបាបភ្លោះរបស់វា គឺការច្រណែន។ អំនួត និងការច្រណែននឹងកើតឡើង តែនៅពេលដែលអាចមានការប្រៀបធៀប និងការខុសគ្នារវាងមនុស្សពីរនាក់។ ប្រសិនបើមិន

មានភាពខុសគ្នារវាងមនុស្សពីរនាក់ទេ ពិបាកមានចិត្តអំនួតណាស់។ ឧទាហរណ៍ បើមនុស្សគ្រប់គ្នានៅលើពិភពលោកមានរថយន្ត ឬម៉ូតូតែមួយប្រភេទ និងមួយសេរីដូចគ្នា នោះគ្មានអ្នកណាអាចអួតអំពីឡាន ឬម៉ូតូរបស់ខ្លួនទេ។ ឬបើមនុស្សគ្រប់គ្នាមានភាពវាងវៃកម្រិតដូចៗគ្នា នោះគ្មានអ្នកណាម្នាក់ នឹងមានអំនួតអំពីភាពវៃឆ្លាតរបស់ខ្លួននោះឡើយ។ បាបឯទៀតដូចជាសេចក្ដីប៉ងប្រាថ្នាខាងសាច់ឈាម និងខាងភ្នែក អាចមាននៅក្នុងចិត្តអ្នក ដោយមិនបាច់ប្រៀបធៀបខ្លួនអ្នកជាមួយអ្នកដទៃទេ។ ប៉ុន្តែបាបនៃអំនួតរបស់ជីវិត ត្រូវតែមានការប្រៀបធៀប។ ទុក្ខវេទនាជាច្រើនកើតមានចំពោះមនុស្ស តាមរយៈអំនួត និងការច្រណែន ហើយនិងការប្រៀបធៀបរហូត។

**ក្រុមខុសឆ្គង និងបាបខាងលោកីយ៍។** ក្រុមខុសឆ្គងខ្លះល្បួងមនុស្សឲ្យចូលរួមជាមួយគេដោយប្រើ«អំនួតនៃជីវិត»។ ក្រុមខុសឆ្គងមួយពីប្រទេសកូរ៉េដែលគេហៅថា បេសកកម្មដំណឹងល្អ/សន្និសីទថ្នាក់ដឹកនាំជាតិ/ការប្រកបយុវជនអន្តរជាតិ (Good News Mission / Christian Leaders Forum / International Youth Fellowship) បានអញ្ជើញគ្រូគង្វាល និងអ្នកដឹកនាំយុវជនឲ្យចូលរួមជាមួយក្រុម មេដឹកនាំអន្តរជាតិ ព្រមទាំងចេញថ្លៃសំបុត្រយន្តហោះ និងថ្លៃសណ្ឋាគារ ដើម្បីធ្វើដំណើរទៅសន្និសីទអ្នកដឹកនាំនៅជុំវិញពិភពលោក «បើអ្នកចូលរួមជាមួយក្រុមរបស់យើង អ្នកនឹងក្លាយជាមេដឹកនាំសំខាន់ម្នាក់»។ នេះគឺជាអំនួតនៃជីវិត គឺជាបាបខាងលោកីយ៍។

ក្រុមខុសឆ្គងឈ្មោះ ក្រុមជំនុំព្រះដ៏មានគ្រប់ព្រះចេស្ដា ដែលមានព្រះគ្រីស្ទក្លែងក្លាយស្រី ពីស្រុកចិន ប្រើ Messenger និង ទូរស័ព្ទ ដើម្បីទាក់ទងនឹងមនុស្សថ្មី។ ធម្មតា គេប្រើមនុស្សស្រីទាក់ទងទៅមនុស្សប្រុស ហើយប្រុសទាក់ទងទៅមនុស្សស្រី។ ការនេះទាក់ទាញមនុស្សដោយប៉ងប្រាថ្នាខាងសាច់ឈាម។

ក្រុមខុសឆ្គងខ្លះទៀត បានចាប់ផ្តើមដោយ *«ប៉ងប្រាថ្នាខាងសាច់ឈាម»*។ ក្រុមខុសឆ្គងដែលគេហៅថា មរមន (ពួកបរិសុទ្ធថ្ងៃចុងក្រោយ) ត្រូវបានបង្កើតដោយលោកយ៉ូសែប ស្មីត ដែលមានប្រពន្ធជាង៤០នាក់ ហើយលោកព្រិកហាំ យ៉ង់ ដែលមានប្រពន្ធ៥៥នាក់! នេះគឺជាសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាមសុទ្ធសាធ។ (សូមអានអំពីក្រុមខុសឆ្គងនៅផ្នែកទី២)។

*«លោកីយ៍នេះ និងសេចក្តីប៉ងប្រាថ្នារបស់វា នោះកំពុងកន្លងទៅ តែអ្នកណាដែលធ្វើតាមព្រះហឫទ័យព្រះ នោះនឹងនៅជាប់អស់កល្បជានិច្ចវិញ»*។ ព្រះជាម្ចាស់បានបង្កើតមនុស្សមក ដើម្បីស្រឡាញ់ និងថ្វាយបង្គំតែអ្វីដែលស្ថិតស្ថេរអស់កល្បជានិច្ច។ លោកិយនេះ *«កំពុងកន្លងទៅ»*។ ការស្រឡាញ់លោកិយ ប្រៀបដូចជាការចងទូករបស់អ្នកជាប់នឹងកប៉ាល់ទីតានិច។ បន្តិចទៀតអ្នកនឹងបាត់បង់ទាំងអស់។

អំពើអាក្រក់ខាងលោកីយ៍ (ខាងសីលធម៌) បានបំផ្លាញមនុស្សរាប់ពាន់លាននាក់ ហើយបានបញ្ជូនពួកគេទៅស្ថាននរក តាំងពីពេលសាតាំងល្បួងអ័ដាម និងអេវ៉ាឲ្យប្រគល់ខ្លួនទៅសេចក្តីប៉ងប្រាថ្នារបស់សាច់ឈាម សេចក្តីប៉ងប្រាថ្នារបស់ភ្នែក និងអំនួតរបស់ជីវិត។ ដំណឹងល្អគឺថា អ័ដាមទីពីរ ព្រះអម្ចាស់យេស៊ូវគ្រីស្ទ អត់បានចាញ់ការល្បួងរបស់សាតាំង ខាងប៉ងប្រាថ្នារបស់សាច់ឈាម សេចក្តីប៉ងប្រាថ្នារបស់ភ្នែក និងអំនួតរបស់ជីវិតឡើយ (ម៉ាថាយ ៤:១-១០)។ អស់អ្នកណាដែលកែប្រែចិត្ត ហើយជឿលើព្រះយេស៊ូវ នោះព្រះលោហិតរបស់ទ្រង់នៅលើឈើឆ្កាងបានសងលោះ បាបដ៏អាក្រក់ទាំងអស់ខាងសេចក្តីប៉ងប្រាថ្នារបស់សាច់ឈាម សេចក្តីប៉ងប្រាថ្នារបស់ភ្នែក និងអំនួតរបស់ជីវិតហើយ។ មនុស្សរាប់រយលាននាក់ដែលជាទាសករខាងលោកិយ បានទទួលការអត់ទោស និងសេរីភាពពីព្រះយេស៊ូវគ្រីស្ទ។

បន្ទាប់មកលោកយ៉ូហានព្រមានយើងអំពីការអាក្រក់ម្យ៉ាងទៀត គឺការអាក្រក់ខាងអាទទឹងនឹងព្រះគ្រីស្ទ ដែលទាក់ទាញគំនិតយើង ច្រើនជាងរូបកាយយើង។

## ការអាក្រក់ខាងអាទទឹងព្រះគ្រីស្ទ (ខាងគោលជំនឿ ឬ ទស្សនវិជ្ជា)

*១យ៉ូហាន ២:១៨*

*ក្មេងរាល់គ្នាអើយនេះជាពេលម៉ោងក្រោយបង្អស់ ហើយសព្វថ្ងៃនេះកើតមានពួកទទឹងនឹងព្រះគ្រីស្ទ [អង់ទីគ្រីស្ទ] ជាច្រើន ដូចជាអ្នករាល់គ្នាបានឮហើយថា អាទទឹងនឹងព្រះគ្រីស្ទត្រូវមក ហេតុនោះបានជាយើងដឹងថា នេះជាពេលម៉ោងក្រោយបង្អស់។*

ពិតមែនការអាក្រក់ខាង **លោកិយ(ខាងសីលធម៌)** គ្រោះថ្នាក់ណាស់ តែមានគ្រោះថ្នាក់ដ៏ធំមួយទៀត គឺ**ការអាក្រក់ខាងអាទទឹងនឹងព្រះគ្រីស្ទ(ខាងគោលជំនឿ ឬ ទស្សនវិជ្ជា)** ដែលលោកយ៉ូហាន ហៅថា *«វិញ្ញាណអាទទឹងព្រះគ្រីស្ទ»* (ឬ អង់ទីគ្រីស្ទ) នៅ១យ៉ូហាន ៤:៣។ (លោកប៉ុលហៅការអាក្រក់ប្រភេទនេះថា *«ពាក្យបរមត្ថ»* និង *«ទស្សនវិជ្ជា»* នៅក្នុងកូល៉ុស ២:៨ ហើយ *«សេចក្ដីបង្រៀនរបស់ពួកអារក្ស»* នៅ ១ធីម៉ូថេ ៤:១)។

ការអាក្រក់ខាងលោកិយ(ខាងសីលធម៌) ទាក់ទាញសាច់ឈាមរបស់យើង តែការអាក្រក់ខាងអាទទឹងនឹងព្រះគ្រីស្ទ ទាក់ទាញ**គំនិត**យើង។ ការអាក្រក់ខាងលោកិយគ្មានប្រព័ន្ធណា ឬចក្ខុវិស័យណា ដែលឡើងខ្ពស់ជាងចំណង់ខាងសាច់ឈាមទេ។ ការអាក្រក់ខាងលោកិយ គឺជា «អ្វីដែលខ្ញុំចង់បានឥឡូវនេះ ឬយប់នេះ» តែប៉ុណ្ណោះ។ តែការអាក្រក់ខាងអាទទឹងនឹងព្រះគ្រីស្ទ បង្កើតប្រព័ន្ធនៃទស្សនវិជ្ជា ឬសាសនាទាំងមូល ជំនួសព្រះគ្រីស្ទ ដែលផ្ដល់នូវ «អ្វីដែលស័ក្តិសមនឹងរស់នៅដើម្បី និងស័ក្តិសមនឹងស្លាប់ដើម្បី»។ សម័យជំងឺកូវីដនេះ ហើយស្គាល់ពាក្យក្រេក អង់ទីក្នុងពាក្យ អង់ទីគ័រ ដែលប្រឆាំងនឹង វីរុស និងមេរោគ។ (នៅក្នុងភាសាក្រេក ពាក្យ «ទទឹងនឹងព្រះគ្រីស្ទ» គឺ «អង់ទីគ្រីស្ទ»។ «អង់ទី» ជាពាក្យក្រេក ដែលមានន័យថា «ប្រឆាំង» ឬ «ជំនួស»)។

## ឧទាហរណ៍នៃទស្សនវិជ្ជា «ទទឹងនឹងព្រះគ្រីស្ទ»

នៅសតវត្សទីមួយ ឥទ្ធិពលពី**សាសនាយូដា** (Judaism) បានដាក់សម្ពាធយ៉ាងខ្លាំងលើសហគមន៍គ្រីស្ទបរិស័ទឲ្យរក្សាច្បាប់ និងទំនៀមទម្លាប់សាសនាយូដា ដើម្បីឲ្យព្រះជាម្ចាស់ទទួល។ សាវកប៉ុលបានសរសេរគម្ពីរកាឡាទី និងកូល៉ុស ដើម្បីការពារដំណឹងល្អបរិសុទ្ធពីឥទ្ធិពលនេះ។ នៅសតវត្សទី២ **លទ្ធិណូស្ទិក** (Gnosticism) បានទាញគ្រីស្ទបរិស័ទជាច្រើនចេញពីព្រះគ្រីស្ទពិត។ (សំបុត្ររបស់យ៉ូហានមើលទៅតយុទ្ធនឹងទម្រង់ដំបូងនៃលទ្ធិណូស្ទិកដែលបដិសេធថា ព្រះគ្រីស្ទបានយាងមកខាងសាច់ឈាម)។ ក្រោយលទ្ធិណូស្ទិក មានគ្រូគង្វាលម្នាក់ឈ្មោះ **អារីយូស** ដែលបាននាំគ្រីស្ទបរិស័ទរាប់ពាន់នាក់ចាកចេញពីការពិត ដោយបង្រៀនថា ព្រះរាជបុត្រានៃព្រះជារបស់បង្កើត (ស្រដៀងនឹងលទ្ធិនៃក្រុមស្មរបន្ទាល់ព្រះយេហូវ៉ាសព្វថ្ងៃនេះ)។ ក្រោយមកសាសនា**ឥស្លាម** បានកើតឡើងប្រហែលឆ្នាំ ៦១០ នៃគ.ស. ហើយបានអះអាងថា ជាការបំពេញឲ្យពេញលេញនៃការបង្រៀនរបស់ព្រះគ្រីស្ទ និងពួកហោរា។ ពួកមូស្លីមបានបដិសេធថា ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ ហើយបានសុគតនៅលើឈើឆ្កាង។ នៅសម័យ រេនេណេសង់ (Renaissance) (គ.ស ១៤០០ - ១៦០០) **លទ្ធិមនុស្សនិយម** (Humanism) បានអះអាងថា មនុស្ស និងវិចារណញ្ញាណរបស់គេ គឺជាក្តីសង្ឃឹមតែមួយគត់របស់មនុស្សជាតិ។ **លទ្ធិអាទិទេពនិយម** ត្រូវបានចាប់ផ្តើមពេញនិយមក្នុងចំណោមគ្រីស្ទបរិស័ទនៅសតវត្សរ៍ទី១៨។ លទ្ធិនោះអះអាងថា ព្រះដែលជាអ្នកបង្កើតមិនដែលធ្វើអន្តរាគមន៍ក្នុងកិច្ចការរបស់មនុស្សទេ ហើយព្រះយេស៊ូវគ្រាន់តែជាមនុស្សល្អម្នាក់។ **លទ្ធិវិវត្តន៍ លទ្ធិកុម្មុយនីស្ត** និង**លទ្ធិវត្ថុនិយម** (Materialism) បានកើតឡើងនៅសតវត្សរ៍ទី១៩ ហើយអះអាងថា គ្មានព្រះទេ មានតែរបស់ដែលមាននៅ។ សាសនា **មរមន** និង**ស្មរបន្ទាល់ព្រះយេហូវ៉ា** ក៏បានកើតឡើងនៅសតវត្សរ៍ទី១៩ ដែរ ហើយបានផ្តល់នូវព្រះយេស៊ូវក្លែងក្លាយដល់ពិភពលោក។ នៅ

សតវត្សរ៍ទី២០ មានទស្សនវិជ្ជា និងសាសនាអង់ទីគ្រីស្ទជាច្រើនបានកើតឡើងជាថ្មី។ អារក្សសាតាំងនឹងបន្តធ្វើសាសនា និងទស្សនវិជ្ជាក្លែងក្លាយនៅគ្រប់សតវត្សរ៍រហូតដល់ព្រះគ្រីស្ទយាងត្រឡប់មកវិញ។ (សូមមើលផ្នែកទី២ ដែលរៀបរាប់សាសនាអង់ទីគ្រីស្ទខ្លះៗសព្វថ្ងៃនេះ)។

ទស្សនវិជ្ជាទទឹងនឹងព្រះគ្រីស្ទ (អង់ទីគ្រីស្ទ)ទាំងនេះ ច្រើនតែធ្វើជាសត្រូវទាស់នឹងដំណឹងល្អ ខ្លាំងជាងការល្បួងខាងសីលធម៌ ព្រោះវាមិនគ្រាន់តែផ្តល់ការសប្បាយមួយយប់ទេ ប៉ុន្តែផ្តល់មួយជីវិតនៃ «ការសក្តិសមរស់ដើម្បី និងស្លាប់ដើម្បី»។ វាផ្តល់នូវសេចក្តីសង្គ្រោះដោយគ្មានព្រះគ្រីស្ទ។ និយាយម៉្យាងទៀត លទ្ធិទាំងនេះ គឺជាលទ្ធិអង់ទីគ្រីស្ទ (ជំនួសព្រះគ្រីស្ទ)។

នៅសតវត្សរ៍ទី២០ ការអាក្រក់ខាងសីលធម៌ បាននាំឲ្យមនុស្សរាប់លាននាក់ស្លាប់ ប៉ុន្តែការអាក្រក់ខាងទស្សនវិជ្ជាក៏បាននាំឲ្យមនុស្សរាប់រយលាននាក់ស្លាប់ដែរ។ ប្រទេសកុម្មុយនីស្តដែលបដិសេធសាសនា ត្រូវទទួលខុសត្រូវចំពោះការស្លាប់របស់មនុស្សជាង១០០លាននាក់ តាមរយៈឃាតកម្ម អំណត់ និងសង្គ្រាម រួមទាំង២លាននាក់នៅកម្ពុជា ២០លាននាក់នៅសូវៀត និង៦០លាននាក់នៅក្នុងប្រទេសចិន។ លទ្ធិដែលជឿថា គ្មានព្រះ (អទេវនិយម) (Atheism) អះអាងថា ទារកដែលមិនទាន់កើត មិនមែនជាមនុស្សទេ ហើយលទ្ធផលនៃគំនិតអង់ទីគ្រីស្ទនោះ គឺការស្លាប់ទារកជាង ១៥០០លាននាក់ (១,៥០០,០០០,០០០) ដែលត្រូវបានគេសម្លាប់តាមការរំលូត តាំងពីឆ្នាំ១៩៨០មក! ព្រះគ្រីស្ទសន្យានឹងប្រទានជីវិត ប៉ុន្តែទស្សនវិជ្ជាអង់ទីគ្រីស្ទនេះ នាំមកនូវសេចក្តីស្លាប់ ការបំផ្លាញ ហើយនៅទីបំផុតស្ថាននរក។

នៅពេលដែលលោកយ៉ូហានមានប្រសាសន៍ថា *«ក្មេងរាល់គ្នាអើយ... អាទទឹងនឹងព្រះគ្រីស្ទត្រូវមក»* គាត់និយាយដោយភាពបន្ទាន់។ គាត់មិនត្រឹមតែផ្តល់ព័ត៌មានដូចជា «ក្មេងៗ មីងនឹងមកថ្ងៃនេះ» ប៉ុន្តែគាត់និយាយខ្លាំងជាងនេះ ដូចជា «កូនអើយ

ចោរមកហើយ មើលវានៅក្នុងផ្ទះហើយ»។ ព័ត៌មានអំពីការមកដល់របស់អាទទឹង នឹងព្រះគ្រីស្ទ មិនមែនជាព័ត៌មានថ្មីទាំងស្រុង ចំពោះសមាជិកក្រុមជំនុំរបស់លោក យ៉ូហានទេ។ ពួកគេបានឮពីព្រះយេស៊ូវ និងពួកសាវកផ្សេងទៀតថា គ្រូទទឹងនឹង ព្រះគ្រីស្ទត្រូវមក (ម៉ាថាយ ៧:១៥-២០; ២៤:២៣-២៧; កិច្ចការ ២០:២៨-៣២; ២ថែស្សាឡូនីច ២:១-១២; ២ពេត្រុស និងយូដាស)។ ឪពុកល្អតែងតែព្រមាន កូនៗរបស់ពួកគេ អំពីគ្រោះថ្នាក់។ គ្រូគង្វាលល្អៗក៏តែងតែព្រមានហ្វូងចៀម អំពីឆ្កែ ចចក មុនវាមកដល់ មិនមែនក្រោយទេ។

*«...អ្នករាល់គ្នាបានឮហើយថា អាទទឹងនឹងព្រះគ្រីស្ទត្រូវមក...»* លោកគ្រូ កូលិន គ្រូស (Colin Kruse) បាននិយាយថា «គ្រូ មូលតុន និង មិលលីហ្គែន (Moulton and Milligan) លើកឧទាហរណ៍ ដើម្បីបង្ហាញថា ពាក្យក្រេក អង់ទី ដែលភ្ជាប់នឹង នាម ឬឋានៈរបស់បុគ្គលម្នាក់ អាចមានន័យថា (១) ការអះអាងថា ជាមនុស្សម្នាក់នោះ ឬ(២) ការជំទាស់នឹង ការស្មើនឹង ឬការជំនួសមនុស្សនោះ។ ព្រះយេស៊ូវបាន បង្រៀនថា ព្រះគ្រីស្ទក្លែងក្លាយផ្សេងៗនឹងលេចមកនៅថ្ងៃចុងក្រោយ (ម៉ាថាយ ២៤:២៤ ម៉ាកុស ១៣:២២)។ ជាក់ស្តែងមានភាពខុសគ្នាតែតិចតួច រវាង ព្រះគ្រីស្ទក្លែងក្លាយ និងអង់ទីគ្រីស្ទមួយ ដ្បិតទាំងពីរប្រឆាំងនឹងព្រះគ្រីស្ទពិត។ ដូច្នេះនៅពេលអ្នកនិពន្ធនិយាយថា អ្នកអានរបស់គាត់បានឮថា អង់ទីគ្រីស្ទត្រូវមក គាត់កំពុងសំដៅទៅលើសារដែលពួកគេបានឮពីដំបូង (នៅពេលដែលពួកគេត្រូវ បានណែនាំក្នុងជំនឿដំបូង) ដែលរួមបញ្ចូលទាំងការបង្រៀនអំពីការមកដល់នៃ អង់ទីគ្រីស្ទ» (Kruse, ទំព័រ ៩៨)។

តារាងនេះពីលោកបណ្ឌិត Colin Kruse បង្ហាញថា ព្រះគ្រីស្ទ និងពួកសាវកបាន ព្រមានអំពី មេទទឹងច្បាប់ (អង់ទីគ្រីស្ទ) និងគោលជំនឿអង់ទីគ្រីស្ទ តាំងពីដើមដំបូង

នៃជំនឿគ្រីស្ទសាសនា គឺជា *«សេចក្ដីដែលអ្នករាល់គ្នាបានឮពីដើមមក»* (១យ៉ូហាន ២:២៤)។

| ម៉ាថាយ ២៤/ម៉ាកុស ១៣ | ២ថែស្សាឡូនីច ២ | យ៉ូហានខ្សែទី១ និង ទី២ | វិវរណៈ ១២-១៣ |
|---|---|---|---|
| ព្រះគ្រីស្ទក្លែង/ហោរាក្លែង នឹងមក (ម៉ាថាយ ២៤:៤-៥, ១១,២៤; ម៉ាកុស ១៣:២២) | មនុស្សទទឹងច្បាប់នឹងលេចមក (២:៣) | អាទទឹងនឹងព្រះគ្រីស្ទ (អង់ទីគ្រីស្ទ) នឹងមក (១យ៉ូហាន ២:១៨) | លោកយ៉ូហានឃើញសត្វសាហាវ១ ឡើងចេញពីសមុទ្រ (១៣:១) |
| | វាទាស់ទទឹងហើយលើកខ្លួនឡើងខ្ពស់លើសជាងអស់ទាំងអ្វីដែលហៅថាព្រះ (២:៤) | | សត្វសាហាវនោះពោលពាក្យប្រមាថដល់ព្រះ (១៣:៥-៦) |
| សេចក្ដីបង្ខូចបំផ្លាញ វាឈរនៅក្នុងទីបរិសុទ្ធ (ម៉ាថាយ ២៤:១៥-១៦; ម៉ាកុស ១៣:១៤) | វាអង្គុយនៅក្នុងព្រះវិហារ ទាំងសម្ដែងខ្លួនថាជាព្រះ (២:៤) | | ពួកមនុស្សត្រូវបានបង្ខំឲ្យថ្វាយបង្គំដល់រូបសត្វសាហាវនោះ (១៣:៤) |
| ខ្ញុំបានប្រាប់អ្នករាល់គ្នាជាមុន (ម៉ាថាយ ២៤:២៥; ម៉ាកុស ១៣:២៣) | នៅពេលដែលខ្ញុំនៅជាមួយ ខ្ញុំបានប្រាប់អ្នកអំពីការនេះ (២:៥) | ដូចដែលអ្នកបានឮថា អាទទឹងនឹងព្រះគ្រីស្ទត្រូវមក (១យ៉ូហាន ២:១៨) | លោកយ៉ូហានជំរាបអ្នកអានរបស់គាត់ពីអ្វីដែលនឹងមក (ខផ្សេងៗ) |
| | អ្នករាល់គ្នាស្គាល់សេចក្ដីដែលឃាត់វា (២:៦) ប្រយោជន៍ឲ្យវាបានលេចមកតែក្នុងពេលវេលារបស់វាប៉ុណ្ណោះ (២:៦) | | |
| | សេចក្ដីអាថ៌កំបាំងរបស់ការទទឹងច្បាប់កំពុងតែបណ្ដាលឡើង (២:៧) | ឥឡូវនេះមានពួកទទឹងនឹងព្រះគ្រីស្ទជាច្រើនបានមកហើយ (១យ៉ូហាន ២:១៨) | |
| | អាទទឹងច្បាប់ នឹងត្រូវបំផ្លាញពេលព្រះយេស៊ូវលេចមក (២:៨) | | |
| ព្រះគ្រីស្ទក្លែង/ហោរាក្លែងនឹងបង្ហាញទីសម្គាល់យ៉ាងធំ ហើយអស្ចារ្យ (ម៉ាថាយ ២៤:២៤; ម៉ាកុស ១៣:២២) | អាទទឹងច្បាប់នោះនឹងមកទាំងធ្វើការយ៉ាងធំហើយអស្ចារ្យ (២:៩) | | សត្វសាហាវ១ទៀតដែលចេញពីដីមក វាធ្វើការអស្ចារ្យដើម្បីបញ្ឆោតពួកមនុស្សនៅផែនដី (១៣:១១-១៤) |

១យ៉ូហាន ២:១៨

| ម៉ាថាយ ២៤/ម៉ាកុស ១៣ | ២ថែស្សាឡូនីច ២ | យ៉ូហានខ្សែទី១ និង ទី២ | វិវរណៈ ១២-១៣ |
|---|---|---|---|
| គេនឹងនាំមនុស្សជាច្រើនឲ្យក្បត់ព្រះ ទាំងអ្នករើសតាំងផងបើអាចធ្វើបាន (ម៉ាថាយ ២៤:៤,១១, ២៤; ម៉ាកុស ១៣:២២) | វាឆបោកអស់អ្នកណាដែលត្រូវវិនាស (២:១០) | ខ្ញុំសរសេរពីដំណើរនៃពួកអ្នកដែលនាំអ្នករាល់គ្នាឲ្យវង្វេង (១យ៉ូហាន ២:២៦) អ្នកប្រវ័ញ្ចបញ្ឆោតជាច្រើនបានមកក្នុងលោកីយ៍ហើយ (២យ៉ូហាន ៧) | សត្វសាហាវដែលចេញពីសមុទ្រមក វាច្បាំងនឹងពួកបរិសុទ្ធ (១៣:៧) |
| គេនិយាយថា មើលព្រះគ្រីស្ទគង់នៅទីនេះ...(ម៉ាថាយ ២៤:២៦; ម៉ាកុស ១៣:២១) | | | |
| | | ពួកទទឹងនឹងព្រះគ្រីស្ទគឺអស់អ្នកដែលមិនព្រមទទួលស្គាល់ថា ព្រះយេស៊ូវ ជាព្រះគ្រីស្ទ (១យ៉ូហាន ២:២២; ២យ៉ូហាន ៧) | |
| | | ពួកទទឹងនឹងព្រះគ្រីស្ទគឺអស់អ្នកដែលចេញពីយើងទៅ (១យ៉ូហាន ២:១៨-១៩; ២យ៉ូហាន ៧) | |

(តារាងពី Kruse ទំព័រ ១០០)

សូម្បីតែពួកអង់ទីគ្រីស្ទ(អាទទឹងនឹងព្រះគ្រីស្ទ) លេចឡើងក្នុងគ្រប់សតវត្ស ដើម្បីប្រឆាំងនឹងព្រះគ្រីស្ទពិត សាវកប៉ុលបង្រៀនអំពីមេអង់ទីគ្រីស្ទចុងក្រោយបង្អស់ ដែលនឹងមកមុនព្រះគ្រីស្ទយាងមកបន្តិច។ វានឹងទទួលបានអំណាចទូទាំងពិភពលោក ហើយប្រឆាំងនឹងជំនឿពិតយ៉ាងខ្លាំង ដែលយើងនឹងហៅថា មេអង់ទីគ្រីស្ទ ឬអាទទឹងច្បាប់(តួបាប)៖

> *«កុំឲ្យអ្នកណាបញ្ឆោតអ្នករាល់គ្នាជាយ៉ាងណាដែរ ថ្ងៃនោះ[ថ្ងៃយាងត្រឡប់មកវិញ របស់ព្រះគ្រីស្ទ] មិនមកឡើយ ទាល់តែមានសេចក្ដីក្បត់សាសនាមកជាមុន ហើយមនុស្សដែលជាតួបាបនោះ បានលេចមក គឺជាមនុស្សដែលត្រូវហិនវិនាស [៤] ដែលទាស់ទទឹងហើយលើកខ្លួនឡើងខ្ពស់លើសអស់ទាំងអ្វី*

*ដែលហៅថាព្រះ ឬរបស់អ្វីដែលគេគោរពប្រតិបត្តិផង ដល់ម៉្លេះបានជាវានឹងអង្គុយនៅដូចជាព្រះក្នុងវិហារនៃព្រះ ទាំងសម្តែងខ្លួនថា ជាព្រះផង ⁵ តើអ្នករាល់គ្នាមិននឹកចាំទេឬអីថា ក្នុងគ្រាដែលខ្ញុំនៅជាមួយនោះខ្ញុំបានប្រាប់អ្នករាល់គ្នាពីសេចក្តីទាំងនេះដែរ»* (២ថែស្សាឡូនីច ២:៣-៥)។

គ្រប់មនុស្សអង់ទីគ្រីស្ទ ឬលទ្ធិអង់ទីគ្រីស្ទ នឹងមាន «វិញ្ញាណអង់ទីគ្រីស្ទ (វិញ្ញាណទទឹងនឹងព្រះគ្រីស្ទ)» (១យ៉ូហាន ៤:៣) ដូចគ្នា ហើយនឹងផ្តល់នូវព្រះគ្រីស្ទក្លែងក្លាយ ឬផ្លូវសង្គ្រោះក្លែងក្លាយ។ ពួកគេនឹងអះអាងថា ទស្សនវិជ្ជារបស់ពួកគេ «សក្តិសមនឹងរស់ដើម្បី និងស្លាប់ដើម្បី»។ សាតាំងគឺជាគំនិតឆ្លាត ហើយខូច ដែលនៅពីក្រោយទស្សនវិជ្ជា និងចលនារបស់អង់ទីគ្រីស្ទទាំងអស់ តាំងពីសម័យព្រះគ្រីស្ទរហូតដល់ឥឡូវនេះ។

ពាក្យ«អង់ទីគ្រីស្ទ» (អាទទឹងនឹងព្រះគ្រីស្ទ) មិនមានន័យថា ទស្សនវិជ្ជា ឬសាសនាថ្មីនោះ មិនដែលប្រើព្រះនាមព្រះគ្រីស្ទនោះឡើយ។ តាមពិតគ្រូខុសឆ្គងនៅសម័យលោកយ៉ូហាន បានប្រើព្រះនាមរបស់ព្រះគ្រីស្ទជាញឹកញាប់ ប៉ុន្តែវាគឺជាព្រះគ្រីស្ទក្លែងក្លាយ គឺព្រះគ្រីស្ទដែលមិនបានយាងមកក្នុងសាច់ឈាម មិនបានសុគតនៅលើឈើឆ្កាង ហើយមិនបានរស់ពីសុគតឡើងវិញទេ។

*«ក្មេងរាល់គ្នាអើយ នេះជាពេលម៉ោងក្រោយបង្អស់...»* លោកយ៉ូហានកំពុងនិយាយអំពីគ្រាចុងក្រោយដែលចាប់ផ្តើមពីការសុគត និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទហើយនឹងបញ្ចប់ដោយការយាងមកជាលើកទីពីររបស់ទ្រង់ (កិច្ចការ ២:១៧; ២ធីម៉ូថេ ៣:១; យ៉ាកុប ៥:៣; ២ពេត្រុស ៣:៣)។ ក្នុងកំឡុងពេលទាំងមូលនេះ (អស់រយៈពេល ២០០០ឆ្នាំហើយ)! វិញ្ញាណ និងការបង្រៀនរបស់អង់ទីគ្រីស្ទ នឹងកើតឡើងម្តងហើយម្តងទៀត ក្នុងទម្រង់ផ្សេងៗគ្នាជាច្រើន នៅគ្រប់ជំនាន់។ «ឪពុកម្តាយ»ដ៏ឈ្លាសវៃនៃក្រុមជំនុំ នឹងយល់ថា តើចលនា និងក្រុមខុសឆ្គងអ្វីខ្លះ

កំពុងព្យាយាមជំនួសព្រះយេស៊ូវគ្រីស្ទ ហើយពួកគេនឹងព្រមាន «កូនៗ» របស់ពួកគេ អំពីពួកនោះ។

## *១យ៉ូហាន ២:១៩*

*គេបានចេញពីពួកយើងទៅ តែមិនមែនជាពួកយើងទេ ដ្បិតបើគេជាពួកយើងមែន នោះនឹងបាននៅជាប់ជាមួយនឹងយើងហើយ តែដែលគេបានចេញទៅនោះ ដើម្បីនឹងសម្ដែងពីគេថា គ្រប់គ្នាមិនមែនជាពួកយើងទេ។*

*«គេបានចេញពីពួកយើងទៅ...»* ពាក្យនេះសំដៅទៅពួកអង់ទីគ្រីស្ទ។ តើអ្នកមានការភ្ញាក់ផ្អើលទេ ដែលគ្រូអង់ទីគ្រីស្ទ គឺជាសមាជិកក្នុងក្រុមជំនុំនេះ ព្រមទាំងធ្វើជាអ្នកដឹកនាំផង? ជាធម្មតាយើងគិតថា ពួកអង់ទីគ្រីស្ទ គឺជាមនុស្សអាក្រក់ក្រៃលែង ដែលគ្មានក្រុមជំនុំណាអនុញ្ញាតឲ្យពួកគេនៅបាន។ ប៉ុន្តែតាមពិតពួកគេឆ្លាត និងពូកែបោកបញ្ឆោតណាស់។ ពួកគេក្លែងខ្លួនជា«ពន្លឺ» និងជាមនុស្សដែល«ដើរក្នុងពន្លឺ» ដូចជាសាតាំងដែល *«ក្លែងខ្លួនធ្វើជាទេវតានៃពន្លឺ»* ដែរ (២កូរិនថូស ១១:១៤)។ លោកយូដាសដែលជាប្អូនរបស់ព្រះយេស៊ូវ ក៏បានព្រមានអំពីគ្រូខុសឆ្គង ដែលលួចចូលក្នុងក្រុមជំនុំ ដើម្បីនាំមនុស្សឲ្យវង្វេង៖ *«ដ្បិតមានមនុស្សខ្លះបានលួចចូល គឺជាពួកអ្នកដែលមានទោសកត់ទុក តាំងពីដើមមក ជាមនុស្សទមិលល្មើស ដែលបំផ្លាស់ព្រះគុណរបស់ព្រះនៃយើងរាល់គ្នា ឲ្យទៅជាសេចក្ដីអាសអាភាស ហើយគេមិនព្រមទទួលព្រះអម្ចាស់យេស៊ូវនៃយើង ដែលទ្រង់ជាម្ចាស់តែ១ផងទេ»* (យូដាស ៤)។ ឧបាយកលរបស់ក្រុមខុសឆ្គងខ្លះ គឺចូលរួមក្នុងការថ្វាយបង្គំរបស់គ្រីស្ទបរិស័ទ ហើយក្រោយការថ្វាយបង្គំ ធ្វើជាមិត្តភក្ដិជាមួយនឹងសមាជិកក្រុមជំនុំ ព្រមទាំងសុំលេខទូរស័ព្ទដើម្បី«សិក្សាគម្ពីរ» ជាមួយគ្នា។ (សូមមើលផ្នែកទី២នៃសៀវភៅនេះ)។

ដូចដែលយើងបាននិយាយនៅលំនាំដើម ១យ៉ូហាន ២:១៩ គឺជាគន្លឹះក្នុងការស្វែងយល់ពីស្ថានភាព ដែលបណ្ដាលឲ្យលោកយ៉ូហានសរសេរសំបុត្រនេះ។ ថ្មីៗនេះក្រុមជំនុំរបស់លោកយ៉ូហានបានរងទុក្ខនៅក្រោម គ្រូក្លែងក្លាយទាំងនេះដែលលោកយ៉ូហានកំពុងពិពណ៌នា។ អរគុណព្រះអង្គ ដែលចុងក្រោយ សមាជិកក្រុមជំនុំបានបណ្ដេញគ្រូខុសឆ្គងឲ្យចេញពីក្រុមជំនុំ ប៉ុន្តែគ្រូខុសឆ្គងច្បាស់ជាបានយកសមាជិកក្រុមជំនុំជាច្រើនទៅជាមួយពួកគេដែរ គឺជាមនុស្សដែលត្រូវបានបោកបញ្ឆោតដោយការកុហករបស់គ្រូខុសឆ្គង។

## គ្រូខុសឆ្គងត្រូវចេញពីក្រុមជំនុំ មិនមែនអ្នកជឿពិតទេ

ជាញឹកញាប់ណាស់ ដែលអ្នកជឿពិតប្រាកដរង់ចាំយូរពេក មុនពួកគេសម្រេចចិត្តចាត់វិធានការទាស់នឹងគ្រូខុសឆ្គង តែពេលនោះវាហួសពេលទៅហើយ។ គ្រូខុសឆ្គងនោះមានឥទ្ធិពលច្រើនពេក ក្នុងក្រុមជំនុំហើយ។ មិនយូរមិនឆាប់ មានសមាជិកដែលជឿការកុហករបស់គ្រូខុសឆ្គងច្រើនជាង អ្នកស្មោះត្រង់នឹងសេចក្ដីពិត។ នៅពេលនោះគ្រូខុសឆ្គង និងពួកវាបណ្ដេញអ្នកជឿពិតចេញពីក្រុមជំនុំវិញ ថែមទាំងចោទប្រកាន់ពួកគេថា បំផ្លាញការរួបរួមគ្នា។ បើអ្នកជឿពិតមិនបានរង់ចាំយូរពេកក្នុងការកែគ្រូខុសឆ្គង នោះនឹងមានលទ្ធផលល្អប្រសើរជាង។ គឺជាគ្រូខុសឆ្គងដែលបំផ្លាញការរួបរួមគ្នា ដោយការបង្រៀនខុសឆ្គងរបស់ពួកគេ។ គឺពួកគេដែលគួរចាកចេញវិញ។

មាននិកាយជាច្រើននៅទូទាំងពិភពលោកដែលធ្លាប់ជឿព្រះគម្ពីរ និងផ្សាយដំណឹងល្អយ៉ាងច្បាស់។ ប៉ុន្តែ ឥឡូវនេះនិកាយទាំងនោះ និងសាលារបស់ពួកគេបង្រៀនថា ព្រះគម្ពីរមិនគួរឲ្យទុកចិត្ត ហើយព្រះយេស៊ូវមិនបានរស់ឡើងវិញទេ។ ពួកគេនិយាយថា ព្រះសព្វព្រះហឫទ័យចំពោះការយក និងការរៀបការភេទដូចគ្នា។ នៅពេលដែលគ្រីស្ទបរិស័ទពិត នៅក្នុងនិកាយទាំងនោះ ក្រោកឡើង

ប្រឆាំងនឹងការបង្រៀនខុសឆ្គងនេះ និកាយចោទប្រកាន់ពួកគេថា បំផ្លាញការរួបរួមគ្នា ហើយនិកាយបណ្ដេញអ្នកជឿពិតទាំងនេះចេញ។ ហេតុអ្វីបានជាគ្រូខុសឆ្គងមិនចាកចេញពីនិកាយទាំងនេះវិញ? ព្រោះវាយឺតពេលហើយ។ ពេលវេលាដើម្បីដាក់វិន័យដល់គ្រូខុសឆ្គងទាំងនោះ គឺ៥០ ឬ១០០ឆ្នាំមុន។ បើអ្នកមានចម្ការដែលមានដើមឈើដែលកំពុងបំពុលដី ពេលវេលាដើម្បីកម្ចាត់វា គឺនៅពេលដែលវានៅតូចនៅឡើយ ដែលងាយស្រួលដកចេញ។ ៥០ឆ្នាំក្រោយ វានឹងធំពេក ហើយឫសបានបំពុលចម្ការទាំងមូលរួចទៅហើយ។ (សូមមើលអត្ថបទ «គ្រីស្ទសាសនាសេរីនិយម» នៅផ្នែកទី២)។

សូម្បីតែនៅអាស៊ីនេះសាស្ត្រាចារ្យសាលាព្រះគម្ពីរខ្លះ និងអ្នកដឹកនាំនិកាយខ្លះចាប់ផ្ដើម ធ្វើឲ្យមនុស្សសង្ស័យពីសេចក្ដីពិតនៃព្រះ។ ជំហានដំបូងរបស់គេ គឺបង្រៀនសិស្សថា ព្រះគម្ពីរមានកំហុស ឬបង្រៀនថា មានវិធីជាច្រើន ដើម្បីឡើងស្ថានសួគ៌តាមរយៈសាសនាដទៃទៀត។ នៅក្នុងក្រុមជំនុំខ្លះ អ្នកដឹកនាំបង្រៀនសមាជិកថា ព្រះសព្វព្រះហឫទ័យនឹងទំនាក់ទំនង និងការរៀបការភេទដូចគ្នា ឬថាការរំលូតកូនជាការត្រឹមត្រូវក្នុងករណីខ្លះ។ បើសមាជិកក្រុមជំនុំម្នាក់ត្អូញត្អែរអំពីការបង្រៀនថ្មីនេះ គាត់ត្រូវនិកាយចោទប្រកាន់ថា គាត់កំពុងបំផ្លាញការរួបរួមគ្នា។ តែតាមពិត អ្នកដែលកំពុងណែនាំគោលលទ្ធិថ្មីទៅវិញទេ ដែលបំផ្លាញការរួបរួមគ្នានោះ។ កុំភ្លេចឲ្យសោះ៖ **គឺគ្រូក្លែងក្លាយ ដែលបំផ្លាញការរួបរួមគ្នារបស់ក្រុមជំនុំដោយគោលជំនឿថ្មី មិនមែនគ្រីស្ទបរិស័ទដែលចង់ការពារគោលជំនឿ *«ដែលបានទទួល១ដងជាសំរេច»*** (យូដាស ៣) **ពីព្រះគ្រីស្ទ និងសាវករបស់ទ្រង់នោះឡើយ។**

# ព្រះវិញ្ញាណបរិសុទ្ធជួយឲ្យយើង
# យកឈ្នះលើការបង្រៀនខុសឆ្គង

## ១យ៉ូហាន ២:២០-២៣

### *១យ៉ូហាន ២:២០*

*រីឯអ្នករាល់គ្នាបានព្រះដ៏បរិសុទ្ធចាក់លាបឲ្យហើយ ក៏ចេះគ្រប់ទាំងអស់ផង។*

នៅចំកណ្ដាលនៃការព្រមានដ៏តឹងរ៉ឹងរបស់លោកយ៉ូហាន អំពីវិញ្ញាណនិងគោលលទ្ធិនៃអង់ទីគ្រីស្ទ គាត់ចាប់ផ្ដើមនិយាយអំពីការចាក់ប្រេងតាំងនៃព្រះវិញ្ញាណបរិសុទ្ធ។ នេះអាចធ្វើឲ្យគ្រីស្ទបរិស័ទខ្លះ មានការភ្ញាក់ផ្អើល ព្រោះគេគិតថា ការងារនៃព្រះវិញ្ញាណបរិសុទ្ធ មិនសូវស្រុបនឹងការងារប្រឆាំងនឹងគ្រូក្លែងក្លាយទេ។ តែតាមពិតការពេញដោយព្រះវិញ្ញាណបរិសុទ្ធ គឺជាផ្នែកដ៏ចាំបាច់មួយ នៃការប្រឆាំងនឹងគោលជំនឿអង់ទីគ្រីស្ទ និងការពារការរួបរួមគ្នា។ មានតែវិញ្ញាណនៃសេចក្ដីពិត និងភាពបរិសុទ្ធប៉ុណ្ណោះ ដែលអាចយកឈ្នះលើវិញ្ញាណនៃអង់ទីគ្រីស្ទ និងគំនិតលោកីយ៍បាន។ មិនមែនតែលោកយ៉ូហានទេ ដែលបាននិយាយអំពីការងារព្រះវិញ្ញាណបរិសុទ្ធ ក្នុងការការពារគោលជំនឿពិត សូមស្ដាប់សាវកប៉ុល៖ *«ចូរនឹកចាំពីអស់ទាំងពាក្យត្រឹមត្រូវ ដែលអ្នកបានឮពីខ្ញុំ ទុកជាគំរូពីសេចក្ដីជំនឿ និងសេចក្ដីស្រឡាញ់ ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ ចូរ**រក្សា**បញ្ញើល្អដែលផ្ញើទុកនឹងអ្នក ដោយសារ**ព្រះវិញ្ញាណបរិសុទ្ធ** ដែលសណ្ឋិតនៅក្នុងយើង»* (២ធីម៉ូថេ ១:១៣-១៤)។ (សម្រាប់ឃ្លា *«វិញ្ញាណនៃសេចក្ដីពិត»* សូមមើលយ៉ូហាន ១៤:១៧;

១៥:២៦; ១៦:១៣; ១យ៉ូហាន ៤:៦ សម្រាប់ *«វិញ្ញាណនៃសេចក្ដីខុសឆ្គង»* សូមមើល១យ៉ូហាន ៤:៦; សម្រាប់ *«វិញ្ញាណនៃភាពបរិសុទ្ធ»* សូមមើលរ៉ូម ១:៤)។

មើលទៅគ្រូក្លែងក្លាយនៅសម័យលោកយ៉ូហានបានអះអាងថា មានតែពួកគេដែលមានព្រះវិញ្ញាណបរិសុទ្ធ និងចំណេះដឹងពិសេស ហើយសមាជិកក្រុមជំនុំគួរតែស្ដាប់ពួកគេ។ តាមពិត គ្រូក្លែងក្លាយទាំងអស់ព្យាយាមធ្វើឲ្យគ្រីស្ទបរិស័ទមានការសង្ស័យលើសមត្ថភាពផ្ទាល់ខ្លួន ដើម្បីយល់ពីសេចក្ដីពិត។ គ្រូនោះនិយាយថា «ទុកចិត្តយើង កុំទុកចិត្តលើខ្លួនឯងអី»។ ប៉ុន្ដែលោកយ៉ូហានមានប្រសាសន៍នៅ ២:២០ ថា តាមពិត គឺសមាជិកក្រុមជំនុំស្មោះត្រង់ ដែលមានព្រះវិញ្ញាណបរិសុទ្ធ និងចំណេះដឹង៖ *«**អ្នករាល់គ្នា**បានព្រះដ៏បរិសុទ្ធចាក់លាបឲ្យហើយ **ក៏ចេះគ្រប់ទាំងអស់**ផង»*។ អស់អ្នកដែលជឿលើសារដែលពួកគេបាន *«ឮតាំងពីដើមមក»* ជាអ្នកដែលបានយកឈ្នះលើមេកំណាច (១យ៉ូហាន ២:១៤)។ អ្នកដែលមានសារថ្មី គឺជាគ្រូក្លែងក្លាយ។

យើងត្រូវតែបដិសេធគ្រូដែលប្រាប់យើងថា មានតែពួកគេដែលអាចផ្ដល់ឲ្យយើងនូវចំណេះដឹងថ្មី ពិសេស និងអាថ៌កំបាំង។ គ្រូក្លែងក្លាយនៅក្នុងក្រុមជំនុំកូល៉ុសក៏បានសន្យាឲ្យ «ចំណេះដឹងពិសេស និងអាថ៌កំបាំង»។ សាវកប៉ុលបានឆ្លើយទៅពួកគេបែបដូច្នេះថា៖ *«គឺជាព្រះគ្រីស្ទ ដែលមានគ្រប់ទាំងផលថ្លៃវិសេសនៃប្រាជ្ញា និងសេចក្ដីចេះដឹងលាក់ទុកក្នុងទ្រង់»* (កូល៉ុស ២:៣)។ បើយើងមានព្រះគ្រីស្ទ យើងមិនត្រូវការអាថ៌កំបាំងរបស់គ្រូពិសេសទេ ពីព្រោះគ្មានអាថ៌កំបាំងណាអស្ចារ្យជាងព្រះយេស៊ូវទេ។ លោកយ៉ូហាន និងសាវកផ្សេងទៀតបានចំណាយពេល ១ ឬ ២ម៉ឺនម៉ោងជាមួយព្រះយេស៊ូវ ហើយអ្វីដែលពួកគេបានឃើញ និងឮ ពួកគេបានប្រកាសជាសាធារណៈដល់មនុស្សទាំងអស់ មិនមែនជាការសម្ងាត់ទេ។

ពួកគេក៏បានកត់ទុកដើម្បីឲ្យអ្នករាល់គ្នាអាចដឹង! យើងទាំងអស់គ្នាអាចចូលទៅកាន់ព្រះគ្រីស្ទតាមរយៈព្រះវិញ្ញាណបរិសុទ្ធ និងព្រះគម្ពីរបរិសុទ្ធ។ ចូរប្រយ័ត្ននឹងអ្នកដែលប្រាប់អ្នកថា ពួកគេមានអាថ៌កំបាំងពិសេស អំពីព្រះ ឬរឿងថ្មីៗដែលគ្រីស្ទបរិស័ទជំនាន់មុនមិនដឹង ឬខគម្ពីរថ្មី ដែលទើបបានរកឃើញ ឬព្រះគ្រីស្ទថ្មីសម្រាប់ជំនាន់យើង។ ទេ! អ្នកមានព្រះគ្រីស្ទពិតរួចហើយ។ អ្នកមានព្រះវិញ្ញាណបរិសុទ្ធរួចហើយ។ អ្នកមានព្រះគម្ពីរបរិសុទ្ធរួចហើយ។ អ្នកមានចំណេះដឹងរួចហើយ។ មិនមានអ្វីទៀតទេ។ មិនមែនមានអាថ៌កំបាំងទៀតទេ។ គ្រីស្ទសាសនាពិត ជាជំនឿសាធារណៈទាំងស្រុង ហើយងាយយល់។

តើអ្នកឃើញទេថា សាវកយ៉ូហាន និងសាវកឯទៀត កំពុងផ្តួលរំលំការយល់ច្រឡំអំពីការជំទាស់នឹងជំនឿខុសឆ្គង។ នេះគឺជាការយល់ច្រឡំ៤យ៉ាង អំពីការប្រឆាំងនឹងក្រុមខុសឆ្គង៖

១) អ្នកខ្លះច្រឡំថា «ការប្រឆាំងនឹងគោលជំនឿខុសឆ្គង គឺជាការដែលមនុស្សកាចធ្វើតែប៉ុណ្ណោះ»។ ប៉ុន្តែលោកយ៉ូហានមានប្រសាសន៍ថា ការប្រឆាំងនឹងគោលជំនឿខុសឆ្គង គឺជា**បញ្ហាបែបគ្រួសារ**មួយ ដែលឪពុកម្តាយខាងវិញ្ញាណការពារកូនតូចៗនៅក្នុងក្រុមជំនុំ។ វាជាទង្វើនៃសេចក្តីស្រឡាញ់ មិនមែនជាទង្វើនៃកំហឹងនោះ។

២) អ្នកខ្លះច្រឡំថា «ការប្រឆាំងនឹងគោលជំនឿខុសឆ្គង បំផ្លាញការរួបរួមគ្នា»។ ប៉ុន្តែពួកសាវកមានប្រសាសន៍ថា ការប្រឆាំងនឹងគោលជំនឿខុសឆ្គង គឺ**ការពារ**ការរួបរួមគ្នាវិញ។ គឺការបង្រៀនខុសឆ្គងដែលបំផ្លាញការរួបរួម (អេភេសូ ៤:១៤-១៦)។

៣) អ្នកខ្លះប្រទាំថា «ខ្ញុំមិនចាប់អារម្មណ៍នឹងការប្រឆាំងនឹងគោលជំនឿខុសឆ្គងទេ។ ខ្ញុំចាប់អារម្មណ៍នឹងសេចក្តីស្រឡាញ់វិញ» ប៉ុន្តែលោកយ៉ូហានបានបញ្ជាក់យ៉ាងច្បាស់ថា ក្រុមជំនុំជំទាស់នឹងក្រុមខុសឆ្គង ពីព្រោះពួកគេ**ស្រឡាញ់សមាជិកក្រុមជំនុំ**។ (សូមចាំថា លោកយ៉ូហាន ល្បីល្បាញដោយសារគាត់ជា «សាវកនៃសេចក្តីស្រឡាញ់»)។

៤) អ្នកខ្លះប្រទាំថា «ខ្ញុំមិនចាប់អារម្មណ៍នឹងការប្រឆាំងនឹងគោលជំនឿខុសឆ្គងទេ។ ខ្ញុំចាប់អារម្មណ៍នឹងព្រះវិញ្ញាណបរិសុទ្ធវិញ»។ ប៉ុន្តែលោកយ៉ូហាន បានបញ្ជាក់យ៉ាងច្បាស់ថា ការការពារអ្នកជឿវ័យក្មេងនៅក្នុងក្រុមជំនុំ ពីការបង្រៀនខុសឆ្គង គឺជាការងារ**ព្រះវិញ្ញាណបរិសុទ្ធ**។ ទ្រង់ជា *«វិញ្ញាណនៃសេចក្តីពិត»*។

## *១យ៉ូហាន ២:២១-២៣*

*ខ្ញុំសរសេរផ្ញើមក មិនមែនដោយព្រោះអ្នករាល់គ្នាមិនស្គាល់សេចក្តីពិតទេ គឺដោយព្រោះបានស្គាល់ ហើយក៏ដឹងថា គ្មានសេចក្តីភូតភរណាកើតពីសេចក្តីពិតនោះឡើយ*
*[២២] តើអ្នកណាជាអ្នកកុហក បើមិនមែនជាអ្នកដែលប្រកែកថា ព្រះយេស៊ូវមិនមែនជាព្រះគ្រីស្ទនោះទេ អ្នកណាដែលមិនព្រមទទួលស្គាល់ទាំងព្រះវរបិតា និងព្រះរាជបុត្រាផង អ្នកនោះហើយជាអ្នកទទឹងនឹងព្រះគ្រីស្ទ*
*[២៣] ឯអស់អ្នកណាដែលមិនព្រមទទួលស្គាល់ព្រះរាជបុត្រា នោះក៏គ្មានព្រះវរបិតាដែរ តែអ្នកណាដែលព្រមទទួលស្គាល់ព្រះរាជបុត្រា នោះក៏មានទាំងព្រះវរបិតាផង។*

មានការបង្រៀន និងការភូតកុហកនៃអង់ទីគ្រីស្ទ ជាច្រើនមុខ ច្រើនយ៉ាង។ នៅសម័យលោកយ៉ូហាន អ្នកប្រឆាំងនឹងព្រះគ្រីស្ទខ្លះ កំពុងតែបង្រៀនការកុហកថា ព្រះយេស៊ូវគ្រាន់តែជាមនុស្សធម្មតា ដែលក្រោយមកបានក្លាយជា«ព្រះគ្រីស្ទ» នៅពេលគាត់បានទទួល«វិញ្ញាណនៃព្រះគ្រីស្ទ» ពីស្ថានសួគ៌ នៅពេលជ្រមុជទឹក។

លោកយ៉ូហានបានហៅពួកគេថា ជាអ្នកកុហក៖ *«តើអ្នកណាជាអ្នកកុហក បើមិនមែនជាអ្នកដែលប្រកែកថា ព្រះយេស៊ូវមិនមែនជាព្រះគ្រីស្ទនោះទេ»*។ លោកយ៉ូហានមានប្រសាសន៍ថា សមាជិកក្រុមជំនុំដឹងរួចហើយថា នេះគឺជាការកុហក៖ *«ខ្ញុំសរសេរផ្ញើមក មិនមែនដោយព្រោះអ្នករាល់គ្នាមិនស្គាល់សេចក្តីពិតទេ គឺដោយព្រោះបានស្គាល់»*។




*បើអ្នកមិនជឿការពិតអំពីព្រះរាជបុត្រា អ្នកមិនមែនមកពីព្រះវរបិតាទេ។ ពីព្រោះ «អ្នកណាដែលបដិសេធព្រះរាជបុត្រា នោះគ្មានព្រះវរបិតាទេ»។ (១យ៉ូហាន ២:២៣)*

# ចូរនៅជាប់នឹងដំណឹងល្អដើម
# ហើយកុំស្វែងរកអ្វីដែលថ្មី

## ១យ៉ូហាន ២:២៤-២៨

*១យ៉ូហាន ២:២៤-២៦*

*ដូច្នេះចូរឲ្យសេចក្តីដែលអ្នករាល់គ្នាបានឮពីដើមមក បាននៅជាប់ក្នុងខ្លួនចុះ បើសិនជាសេចក្តីដែលឮតាំងពីដើមមកបាននៅជាប់ក្នុងអ្នករាល់គ្នាមែន នោះអ្នករាល់គ្នានឹងនៅជាប់ក្នុងព្រះរាជបុត្រា ហើយក្នុងព្រះវរបិតាដែរ [២៥] នេះហើយជាសេចក្តីដែលទ្រង់បានសន្យានឹងយើងរាល់គ្នា គឺជាជីវិតដ៏នៅអស់កល្បជានិច្ច [២៦] ខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា ពីដំណើរនៃពួកអ្នកដែលនាំអ្នករាល់គ្នាឲ្យវង្វេង។*

ក្រុមហ៊ុនដែលលក់របស់របរបានដឹងថា មនុស្សទាំងអស់ចូលចិត្តរបស់ថ្មីដែលពួកគេមិនដែលឃើញពីមុន។ នេះជាមូលហេតុដែលពាក្យ«ថ្មី» ដាក់ជាអក្សរធំៗលើកញ្ចប់ផលិតផលរបស់ពួកគេ។ ដូចគ្នាដែរ សាតាំងក៏តែងតែល្បួងយើងជាមួយអ្វីដែលថ្មី។ ប៉ុន្តែលោកយ៉ូហានប្រាប់យើងឲ្យនៅជាប់នឹងដំណឹងល្អដើម។ នៅក្នុងខទាំងប្រាំចាប់ពី ២:២៤ដល់២:២៨ ពាក្យថា «នៅជាប់» មាន៦ដង។ យើងមិនត្រូវរកមើលអ្វីដែលថ្មីនោះទេ តែត្រូវនៅជាប់ជាមួយដំណឹងល្អដើមពីពួកសាវកដើម។ នៅក្នុងប្រវត្តិសាស្ត្រនៃក្រុមជំនុំ មនុស្សជាច្រើនមិនបាននៅជាប់នឹងជំនឿទេ តែបានទៅរកគោលជំនឿថ្មីវិញ។ តើអ្នក និងខ្ញុំអាច *«នៅជាប់នឹងព្រះរាជបុត្រា ហើយនិងព្រះវរបិតា»* បានយ៉ាងដូចម្តេច? គឺដោយនៅជាប់នឹង *«សេចក្តីដែល[យើង]បានឮតាំងពីដើមមក»* (២:២៤) ដូចបង្ហាញនៅរូបនេះ។




*«បើសិនជាសេចក្តីដែលឮតាំងពីដើមមក បាននៅជាប់ក្នុងអ្នករាល់គ្នាមែន នោះអ្នករាល់គ្នានឹងនៅជាប់ក្នុងព្រះរាជបុត្រា ហើយក្នុងព្រះវរបិតាដែរ»។ (១យ៉ូហាន ២:២៤)*

ដំណឹងល្អ (គឺ*«សេចក្តីដែលអ្នកបានឮតាំងពីដើមមក»*) មិនគ្រាន់តែសម្រាប់ការ**ក្លាយជា**គ្រីស្ទបរិស័ទប៉ុណ្ណោះទេ គឺសម្រាប់ការ**នៅជាប់**ជាគ្រីស្ទបរិស័ទដែរ។ គ្រូខុសឆ្គងនៅទីក្រុងកូល៉ុសបាននិយាយដូចនេះថា «ដំណឹងល្អអំពីព្រះយេស៊ូវ គឺល្អសំរាប់គ្រីស្ទសាសនាបឋមសិក្សា ប៉ុន្តែបើអ្នកចង់ឈានដល់កំរិតខ្ពស់ យើងនឹងបង្រៀនអាថ៌កំបាំងថ្មីមួយចំនួនដល់អ្នក» (កូល៉ុស ២:៤,៨,១៦,១៨)។ ស្រដៀងនេះដែរ គ្រូក្លែងក្លាយនៅស្រុកកាឡាទីក៏បាននិយាយថា ដំណឹងល្អអំពីព្រះយេស៊ូវ គឺល្អសំរាប់គ្រីស្ទសាសនាបឋមសិក្សា ប៉ុន្តែបើមនុស្សចង់ខ្ពស់ជាងនេះពួកគេត្រូវបន្ថែមការកាត់ស្បែក ហើយចូលសាសន៍យូដា។ លោកប៉ុលបានមានប្រសាសន៍ថា គ្រូទាំងនេះស្ថិតនៅក្រោមបណ្តាសារបស់ព្រះ ពីព្រោះពួកគេបានបង្រៀនដំណឹងល្អផ្សេងទៀត។ លោកប៉ុលបានប្រាប់ពួកគ្រីស្ទបរិស័ទនៅក្រុងកាឡាទីឲ្យនៅជាប់នឹងដំណឹងល្អដើម មិនមែនដំណឹងល្អថ្មីទេ។ គាត់ថែមទាំងបានមានប្រសាសន៍ទៀតថា បើ**គាត់ផ្ទាល់** (ឬទេវតាពីស្ថានសួគ៌!) នាំដំណឹងល្អថ្មីមក គឺពួកគេត្រូវតែបដិសេធ (កាឡាទី ១:៦-៩)។ លោកយ៉ូហានបានមានប្រសាសន៍ថា មានតែអ្នកដែលនៅជាប់ក្នុងដំណឹងល្អដែលពួកគេបានជឿពីដំបូងនោះទេ ដែលនឹងទទួលបានជីវិតអស់កល្បជានិច្ច (សូមមើល កូល៉ុស ១:២៣ ២ធីម៉ូថេ ៣:១៤; យូដាស ៣)។

**«គម្ពីរថ្មី»**៖ ក្រុមខុសឆ្គងដែលហៅថា ពួកជំនុំនៃព្រះដ៏មានគ្រប់ព្រះចេស្តា (ផ្លែកបន្ទោរពីទិសខាងកើត) បង្រៀនថា ព្រះគម្ពីរប៊ីបគឺសម្រាប់ជំនាន់មុន

ប៉ុន្តែគ្មានប្រយោជន៍សម្រាប់សព្វថ្ងៃនេះទេ។ ពួកគេថា តាំងពីឆ្នាំ១៩៧៣ ពេលដែលស្រីចិនឈ្មោះ យ៉ាង ស៊ីងប៊ិន (Yang Xiangbin) បានកើតមក(ដែលគេហៅថា «ព្រះដ៏មានគ្រប់ព្រះចេស្ដា») យើងមាន «គម្ពីរថ្មី» ដែលមានពាក្យសំដីរបស់ យ៉ាង ស៊ីងប៊ិន ជំនួសព្រះគម្ពីរប៊ីប។ ពួកគេក៏បោះពុម្ពពាក្យ «ព្រះគម្ពីរបរិសុទ្ធ(Holy Bible)» លើគម្របនៃគម្ពីរក្លែងក្លាយនេះ ដើម្បីបោកបញ្ឆោតមនុស្ស។ មានព្រះគម្ពីរបរិសុទ្ធតែមួយ គឺលោកុប្បត្តិដល់វិវរណៈ។ គម្ពីរឯទៀតគឺសុទ្ធតែក្លែងក្លាយ។ (សូមមើលអត្ថបទពីក្រុមខុសឆ្គងនេះ នៅផ្នែកទី២)។

អារក្សសាតាំង ច្រើនតែនាំក្រុមខុសឆ្គងឲ្យធ្វើ«ព្រះគម្ពីរថ្មី» ដោយមាន «ការពិតថ្មី»។ បន្ទាប់ពីលោកយ៉ូហានបានស្លាប់ ក្រុមខុសឆ្គងនៅសម័យគាត់ បានធ្វើដំណឹងល្អថ្មី និង សំបុត្រគម្ពីរថ្មី ដែលក្លែងក្លាយ។ ក្រោយមកលោកមហាម៉ាត់បានសរសេរ សៀវភៅថ្មី ដែលហៅថា កូរ៉ាន។ នៅសតវត្សទី១៩ ពួកមរមនបានធ្វើគម្ពីរថ្មី ដែលពួកគេបានអះអាងថា ស្មើនឹងព្រះគម្ពីរបរិសុទ្ធ ឬល្អជាងទៀត។ «បទគម្ពីរ» ទាំងអស់នេះ និយាយខុសពីព្រះគម្ពីរបរិសុទ្ធ។ សៀវភៅទាំងនោះគឺជា «អង់ទីគម្ពីរ» ពីព្រោះ វាជាគម្ពីរក្លែងក្លាយជំនួសគម្ពីរត្រឹមត្រូវ។

សូម្បីតែសព្វថ្ងៃនេះក្ដីគ្រូបង្រៀនម្នាក់នៅអាស៊ីអាគ្នេយ៍បង្ហោះ វីដេអូអំពី «កណ្ឌគម្ពីរបាត់បង់» ដែលសម័យនេះបានរកឃើញវិញ។ គ្មានកណ្ឌគម្ពីរបាត់បង់ទេ ព្រះជាម្ចាស់មិនអាចបាត់បង់ព្រះបន្ទូលរបស់ទ្រង់ទេ។ គ្រូដែលបង្រៀនអំពីកណ្ឌគម្ពីរបាត់បង់ គឺជាគ្រូបង្រៀនខុសឆ្គងហើយ។

## *១យ៉ូហាន ២:២៧*

*រីឯដំណើរដែលទ្រង់ចាក់លាបឲ្យនោះ ក៏**នៅជាប់**នឹងអ្នករាល់គ្នាពិត ហើយអ្នករាល់គ្នាមិនត្រូវការឲ្យអ្នកណាបង្រៀនពីការអ្វីទេ ប៉ុន្តែដូចជាដំណើរចាក់លាបនោះ បានបង្រៀនពីគ្រប់ការទាំងអស់ ហើយមិនមែនជាសេចក្ដីកំភូតទេ គឺជាសេចក្ដីពិត*

*វិញ នោះត្រូវឲ្យអ្នករាល់គ្នា**នៅជាប់**ក្នុងទ្រង់ចុះ តាមដែលដំណើរនោះបាន បង្រៀនមក។*

ជាថ្មីម្តងទៀតលោកយ៉ូហាន រំឭកសមាជិកក្រុមជំនុំដ៏ស្មោះត្រង់ថា គឺ**ពួកគេ**ដែលជាអ្នកទទួលការចាក់ប្រេងលាបពីព្រះវិញ្ញាណបរិសុទ្ធ មិនមែនជាគ្រូខុសឆ្គងដែលទើបនឹងបានចាកចេញនោះទេ។ នេះជាមូលហេតុដែលគាត់មានប្រសាសន៍ថា *«អ្នករាល់គ្នាមិនត្រូវការឲ្យអ្នកណាបង្រៀនពីការអ្វីទេ»*។ គាត់មិនមែនមានន័យថា គ្រីស្ទបរិស័ទមិនត្រូវការគ្រូបង្រៀននោះឡើយ មើលលោកយ៉ូហានផ្ទាល់ កំពុងបង្រៀនពួកគេតាមរយៈសំបុត្រនេះ។ គាត់មានន័យថា «រីឯគ្រូក្លែងក្លាយទាំងនេះដែលទើបបានចាកចេញទៅ អ្នករាល់មិនត្រូវការឲ្យពួកគេបង្រៀនអ្នករាល់គ្នាពីអ្វីទេ ពីព្រោះអ្នករាល់គ្នាមានព្រះវិញ្ញាណបរិសុទ្ធ ហើយអ្នករាល់មានសេចក្តីបង្រៀនដែលអ្នករាល់គ្នាបានឮតាំងពីដើមរៀងមក»។ ដូច្នេះយើងមិនត្រូវឲ្យក្រុមខុសឆ្គងចូលមកក្នុងផ្ទះ និងក្រុមជំនុំរបស់យើង ដើម្បីបង្រៀនយើងទេ ហើយយើងមិនគួរស្តាប់ការបង្រៀនរបស់ពួកគេតាមទូរស័ព្ទដែរ! យើងមិនត្រូវការការបង្រៀនថ្មីរបស់គេទេ ពីព្រោះដំណឹងល្អរបស់ព្រះ និងសេចក្តីពិតរបស់ព្រះ និងព្រះវិញ្ញាណរបស់ព្រះបានស្ថិតនៅក្នុងខ្លួនយើងរួចហើយ។

នៅខ២៤មិញ លោកយ៉ូហានបានផ្តល់ការសន្យាដ៏មានតម្លៃមួយដល់យើងថា *«បើសេចក្តីដែលអ្នករាល់គ្នាបានឮពីដើមមក បាននៅជាប់ក្នុងអ្នករាល់គ្នាមែន នោះអ្នករាល់គ្នានឹងនៅជាប់ក្នុងព្រះយេស៊ូវ ហើយក្នុងព្រះវរបិតាដែរ»*។ ឥឡូវនេះនៅក្នុងខ ២៧ និង ២៨ ការសន្យានោះ ក្លាយជាបទបញ្ជាដែលយើងត្រូវធ្វើតាមវិញ ៖ *«ចូរនៅជាប់ក្នុងទ្រង់ចុះ»* ! យើងត្រូវតែព្យាយាមនៅជាប់នឹងដំណឹងល្អដើម រហូតដល់យើងស្លាប់។ ការនេះតម្រូវឲ្យមានការខិតខំប្រឹងប្រែងប្រចាំថ្ងៃ។ វាមិនមែនជាអ្វីដែលនឹងកើតឡើងដោយស្វ័យប្រវត្តិ ឬក៏ដោយគ្មានការគ្រប់គ្រង និងប្រៀនប្រដៅខ្លួនឯងនោះ

ទេ។ ហេតុនេះហើយបានជាលោកយ៉ូហាន បង្គាប់យើងពីរដងឲ្យ *«នៅជាប់ក្នុងព្រះ»!*។ យើងត្រូវតែខិតខំដើម្បីនៅជាប់ក្នុង*«អ្វីដែលយើងបានឮតាំងពីដើមរៀងមក»* ហើយមិនស្វែងរកអ្វីដែលថ្មីទេ។

## ***១យ៉ូហាន ២:២៨***

*ហើយ ឥឡូវនេះពួកកូនតូចៗអើយ ចូរ**នៅជាប់**ក្នុងទ្រង់ចុះ ដើម្បីកាលណាទ្រង់លេចមក នោះយើងខ្ញុំនឹងមានចិត្តក្លាហានឥតត្រូវការនឹងខ្មាសនៅចំពោះទ្រង់ ក្នុងកាលដែលទ្រង់យាងមកនោះឡើយ ។*

*«ចូរនៅជាប់ក្នុងទ្រង់»* ចូរនៅជាប់ក្នុងសេចក្ដីពិត! ចូរនៅជាប់ក្នុងក្រុមគ្រួសាររបស់ព្រះ! កុំបោះបង់ចោលព្រះយេស៊ូវ ដូចយូដាសបានធ្វើឡើយ! កុំបោះបង់ចោលព្រះគ្រីស្ទដ៏ពិត ដូចជាគ្រូក្លែងក្លាយនៅក្រុមជំនុំរបស់លោកយ៉ូហានទើបនឹងធ្វើ។ ព្រះអម្ចាស់យេស៊ូវផ្ទាល់បានដាស់តឿនសេចក្ដីដដែលនេះ ដល់ពួកសិស្សនៅយប់ចុងក្រោយរបស់ទ្រង់ម្ដងហើយម្ដងទៀត ពីព្រោះទ្រង់ជ្រាបថា ឆាប់ៗនេះ យូដាសនឹងក្បត់ទ្រង់ ពេត្រុសនឹងបដិសេធទ្រង់ ហើយសិស្សឯទៀតនឹងបោះបង់ទ្រង់ចោល។ ដូច្នេះទ្រង់បានបង្គាប់ដល់ពួកសាវកថា*«ចូរនៅជាប់នឹងខ្ញុំ»* (យ៉ូហាន ១៥:៤)។ *«គ្មានសេចក្ដីសង្គ្រោះដោយសារអ្នកណាទៀតសោះ»* (កិច្ចការ ៤:១២)។ ការបដិសេធព្រះយេស៊ូវ គឺបដិសេធផ្លូវតែមួយគត់នៃសេចក្ដីសង្គ្រោះ។ ជម្រើស គឺស្ថានសួគ៌ ឬស្ថាននរក។ អ្នកនឹងអរសប្បាយនៅពេលដែលទ្រង់យាងមកដល់ ឬអៀនខ្មាសវិញ។ អ្នកនឹងទទួលបានជីវិតអស់កល្ប ឬស្ថាននរកអស់កល្បជានិច្ច។ អ្នកត្រូវតែ**នៅជាប់**នឹងព្រះ និងព្រះរាជបុត្រានៃទ្រង់ គឺព្រះយេស៊ូវគ្រីស្ទដោយ**នៅជាប់**ក្នុងដំណឹងល្អដើម ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។

# កើតពីព្រះ

## គន្លឹះនៃការអនុវត្តន៍នៅកណ្ឌយ៉ូហានខ្សែទី១

## ១យ៉ូហាន ២:២៩ – ៣:៣

ព្រះយេស៊ូវបានយាងពីស្ថានសួគ៌មក ដើម្បីសំដែងដល់យើងស្គាល់តាមរយៈជីវិត និងការបង្រៀនរបស់ទ្រង់ថា ព្រះជាពន្លឺ និងព្រះជាសេចក្តីស្រឡាញ់។ ប៉ុន្តែយើងជាមនុស្សមានបាប តាំងពីកើតមក យើងមិនមែនជាពន្លឺ និងសេចក្តីស្រឡាញ់ទេ។ តើយើងមានសង្ឃឹមអ្វីដើម្បីក្លាយជាពន្លឺ និងសេចក្តីស្រឡាញ់ដូចព្រះបាន? តើធ្វើដូចម្តេចឲ្យយើង (១)មានភាពបរិសុទ្ធ (២)ជឿសេចក្តីពិត (៣)ស្រឡាញ់ព្រះ និង (៤)ស្រឡាញ់អ្នកដទៃ បើយើងកើតមកមានចិត្តអាក្រក់បែបនេះនោះ? យើងគ្មានសង្ឃឹមទេ លើកលែងតែយើងបាន**កើតជាថ្មី**ដោយព្រះវិញ្ញាណរបស់ព្រះ។ មានតែអស់អ្នកដែលកើតពីព្រះប៉ុណ្ណោះ ដែលអាចក្លាយជាពន្លឺ និងជាសេចក្តីស្រឡាញ់ដូចព្រះបាន។ មូលហេតុដែលគ្រូក្លែងក្លាយបានចាកចេញពីដំណឹងល្អពិត និងក្រុមជំនុំពិត មកពីពួកគេមិនបានកើតពីព្រះទេ។

***១យ៉ូហាន ២:២៩***

*បើអ្នករាល់គ្នាដឹងថា ទ្រង់សុចរិតនោះត្រូវតែយល់ឃើញថា អស់អ្នកណាដែលប្រព្រឹត្តតាមសេចក្តីសុចរិត នោះគេបាន**កើតពីទ្រង់**មកដែរ។*

នៅក្នុងខនេះ លោកយ៉ូហានចងភ្ជាប់ភាពបរិសុទ្ធ ជាមួយនឹងការកើតពីព្រះ ដូចក្នុងរូបនេះ។




*«អស់អ្នកណាដែលប្រព្រឹត្ត**តាមសេចក្ដីសុចរិត***
*នោះគេបាន**កើតពីទ្រង់**មកដែរ»។ (១យ៉ូហាន ២:២៩)*

ខ២៩នៃជំពូក២ គឺជាលើកដំបូង ដែលឃ្លា *«កើតពីព្រះ»* មានក្នុងកណ្ឌគម្ពីរយ៉ូហានខ្សែទី១។ បន្ទាប់ពីការលើកឡើងលើកទីមួយនេះ វាលេចឡើង៨ដងទៀត! ឃ្លាស្រដៀងគ្នាថា «មកពីព្រះ» បានលេចឡើង៨ដង ទាំងអស់នៅក្នុងជំពូក៤ និង៥ ហើយ *«កូនរបស់ព្រះ»* លេចឡើង៤ដង។ សរុបទៅសេចក្ដីអំពីការកើតជាថ្មីលេចឡើងជាង ២០ដង ចាប់ពី១យ៉ូហាន ២:២៩ ដល់ចុងបញ្ចប់នៃកណ្ឌគម្ពីរ (ជាង ២០ដង ក្នុង៦៨ខ!)។ ការកើតពីព្រះ ក្លាយជាប្រធានបទសំខាន់មួយ ក្នុង១យ៉ូហាន ជំពូក៣ ៤ និង៥។

តើយើងអាចកើតពីព្រះបានយ៉ាងដូចម្ដេច? ព្រះយេស៊ូវបានមានបន្ទូលប្រាប់លោកនីកូដេមថា ព្រះវិញ្ញាណបរិសុទ្ធធ្វើឲ្យយើងកើតពីព្រះ នៅពេលដែលយើងមានជំនឿលើព្រះយេស៊ូវ៖

*«បើមិនបានកើតជាថ្មី នោះគ្មានអ្នកណាអាចនឹងឃើញនគរព្រះបានទេ... ប្រាកដមែនខ្ញុំប្រាប់អ្នកជាប្រាកដថា បើមិនបានកើតអំពីទឹកហើយអំពីព្រះវិញ្ញាណនោះ គ្មានអ្នកណាអាចនឹងចូលទៅក្នុងនគរព្រះបានទេ។ របស់អ្វីដែលកើតពីសាច់នោះជាសាច់ទេ ហើយដែលកើតពីព្រះវិញ្ញាណនោះជាវិញ្ញាណវិញ ... ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រា*

*នោះមិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ»* (យ៉ូហាន ៣:៣, ៥, ៦, ១៦)។

នៅក្នុងវគ្គនេះ ព្រះយេស៊ូវកំពុងរំឭកលោកនីកូដេមអំពីការសន្យានៅគម្ពីរអេសេគាល ៣៦:២៥-២៧ ថា ថ្ងៃណាមួយ ព្រះនឹងជំរះចិត្តរបស់យើងឲ្យបានស្អាត ជាមួយនឹងទឹក ហើយដាក់ចិត្តថ្មី នៅក្នុងខ្លួនយើងដែរ។ សូមស្តាប់សេចក្តីសន្យាពីព្រះ អំពីការកើតជាថ្មីនៅគម្ពីរអេសេគាលៈ

*«នោះអញនឹងប្រោះទឹកស្អាតទៅលើឯងរាល់គ្នា ដូច្នេះ ឯងនឹងបានស្អាត អញនឹងជំរះឯងរាល់គ្នាឲ្យស្អាត ពីគ្រប់ទាំងសេចក្តីស្មោកគ្រោក ហើយពីអស់ទាំងរូបព្រះរបស់ឯងផង [២៦] អញនឹងឲ្យឯងមានចិត្តថ្មី ហើយនឹងដាក់វិញ្ញាណថ្មីនៅក្នុងឯងដែរ អញនឹងដកចិត្តដែលរឹងដូចថ្ម ពីរូបសាច់ឯងចេញ រួចនឹងឲ្យមានចិត្តជាសាច់វិញ [២៧] អញនឹងដាក់វិញ្ញាណរបស់អញនៅក្នុងឯងរាល់គ្នា ហើយបណ្តាលឲ្យឯងរាល់គ្នាដើរតាមក្រឹត្យក្រម ហើយរក្សាបញ្ញត្តច្បាប់របស់អញ ព្រមទាំងប្រព្រឹត្តតាមផង»* (អេសេគាល ៣៦:២៥-២៧)។

ការកើតជាថ្មីដោយព្រះវិញ្ញាណបរិសុទ្ធតាមរយៈជំនឿលើព្រះយេស៊ូវគ្រីស្ទ គឺជាការសំខាន់បំផុត ដែលអាចកើតឡើងក្នុងជីវិតរបស់អ្នក។ អ្នកអាចទទួលបុណ្យជ្រមុជទឹក១០០ដង ចូលរួមពិធីលៀងព្រះអម្ចាស់១០០០ដង ហើយទៅចូលរួមនៅព្រះវិហារ១០,០០០ដង ប៉ុន្តែបើអ្នកមិនបានកើតជាថ្មីទេ អ្នក *«មិនអាចនឹងឃើញនគរព្រះបានទេ»* (យ៉ូហាន ៣:៣) ហើយអ្នកនឹងមិនអាចក្លាយជាមនុស្សនៃពន្លឺ និងសេចក្តីស្រឡាញ់ដូចព្រះបានឡើយ។ លោកយ៉ូហានបានប្រាប់យើងនៅក្នុងដំណឹងល្អនៃយ៉ូហានជំពូក១ថា *«ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាចឲ្យបានត្រឡប់ជា**កូនព្រះ** គឺជា*

*កូនដែលមិនបានកើតមកពីឈាម ឬតាមប្រាថ្នាខាងរូបសាច់ ឬតាមចំណង់នៃមនុស្សឡើយ គឺកើតមកអំពីព្រះវិញ»* (យ៉ូហាន ១:១២,១៣)។ គ្រូខុសឆ្គង គឺជាអ្នកកាន់សាសនា ប៉ុន្តែពួកគេមិនដែលកើតមកពីព្រះទេ (ពួកគេមិនមែន *«មកពីព្រះ»* ទេ)។ បើពួកគេបានកើតពីព្រះមែន ពួកគេនឹងនៅជាប់ក្នុងសេចក្តីពិតរបស់ព្រះ និង សេចក្តីស្រឡាញ់របស់ព្រះ និង ក្រុមជំនុំរបស់ព្រះ។ អ្នកក៏អាចកើតពីព្រះឥឡូវនេះដែរ ដោយជឿលើព្រះយេស៊ូវ ហើយអំពាវនាវសូមព្រះអង្គសង្គ្រោះអ្នក។

តាមពិតលោកយ៉ូហាន ប្រើពាក្យផ្សេងៗជាច្រើន នៅសំបុត្រនេះ ដើម្បីពិពណ៌នាអំពីការកើតពីព្រះ៖

- យើងមានព្រះជា«ព្រះវរបិតា» នៃយើង ១:២,៣; ២:១,១៣,១៥,១៦,២២,២៣,២៤; ៣:៣
- យើងមាន«ព្រះវិញ្ញាណ» ២:២០,២៧; ៣:២៤; ៤:២,៦,១៣; ៥:៦,៨
- យើងមាន«ជីវិត» ១:១,២; ២:១៧,២៥; ៣:១៤,១៥; ៥:១១,១២,១៣,២០
- យើងមាន«ព្រះរាជបុត្រា» និង«សេចក្តីសង្គ្រោះ» ដូចដែលបានពិពណ៌នាដោយពាក្យទាំងនេះ៖

-ព្រះលោហិតរបស់ព្រះយេស៊ូវ ១:៧

-ការអត់ទោសបាប ១:៩; ២:១២

-ព្រះដ៏ជាជំនួយ ២:១ ដង្វាយធួននឹងបាប ២:២; ៤:១០

-សេចក្តីស្រឡាញ់របស់ព្រះចំពោះយើង ៣:១

-កូនព្រះ ៣:៣

-អំពើបាបបានដកចេញ ៣:៥

-បានរាប់ជាសុចរិត ៣:៧

-ការស្គាល់ព្រះ ៤:៦

នៅជំពូកបីលោកយ៉ូហានបន្តបង្រៀនអំពីការកើតពីព្រះ។

### *១យ៉ូហាន ៣:១ក*

*មើលសេចក្ដីស្រឡាញ់យ៉ាងណាហ្ន៎ ដែលព្រះវរបិតាបានផ្ដល់មកយើងរាល់គ្នា ឲ្យយើងបានហៅជាកូនរបស់ព្រះដូច្នេះ។ ហើយយើងក៏បានដូច្នេះដែរ។*

ដូចដែលខ្ញុំបាននិយាយហើយ ការកើតពីព្រះគឺជាគន្លឹះនៃការអនុវត្តន៍នៃកណ្ឌគម្ពីរយ៉ូហានខ្សែទី១។ កូនតែងតែស្រដៀងទៅនឹងឪពុកម្ដាយរបស់គេ ព្រោះគេបានកើតពីឪពុកម្ដាយ។ ដូចគ្នានេះដែរ បើព្រះជាពន្លឺ និងសេចក្ដីស្រឡាញ់ នោះអស់អ្នកណាដែលកើតពីព្រះ នឹងជាពន្លឺ និងសេចក្ដីស្រឡាញ់ដែរ។ ការកើតជាថ្មីជាកូនរបស់ព្រះតាមរយៈព្រះវិញ្ញាណបរិសុទ្ធ គឺជា*«ការចាក់ប្រេងលាប»* ដែលលោកយ៉ូហានបានលើកឡើងនៅក្នុង ២:២៧ ហើយដែលព្រះយេស៊ូវបានប្រាប់លោកនីកូដេមនៅក្នុងយ៉ូហាន ៣ ហើយដែលហោរាអេសេគាល និងយេរេមាបានទាយដល់អ៊ីស្រាអែលនៅគម្ពីរអេសេគាល ៣៦:២៥-២៧ និងគម្ពីរយេរេមា ៣១:៣៣។

តាម១យ៉ូហាន ៣:១ ហេតុអ្វីបានជាព្រះសំរេចព្រះទ័យធ្វើឲ្យយើងក្លាយជាកូនរបស់ទ្រង់? គឺសេចក្ដីស្រឡាញ់សុទ្ធសាធ។ *«មើល**សេចក្ដីស្រឡាញ់**យ៉ាងណាហ្ន៎ ដែលព្រះវរបិតាបានផ្ដល់មកយើងរាល់គ្នា ឲ្យយើងបានហៅជាកូនរបស់ព្រះ»* (១យ៉ូហាន ៣:១)។ *«ដ្បិតព្រះទ្រង់**ស្រឡាញ់**មនុស្សលោកដល់ម្ល៉េះ»* (យ៉ូហាន ៣:១៦)។ *«យើងស្រឡាញ់ទ្រង់ពីព្រោះ**ទ្រង់បានស្រឡាញ់**យើងជាមុន»* (១យ៉ូហាន ៤:១៩)។

### *១យ៉ូហាន ៣:១ខ*

*គឺដោយហេតុនោះបានជាលោកីយ៍មិនស្គាល់យើងទេ ពីព្រោះមិនស្គាល់ទ្រង់ដែរ។*

នៅក្នុងវប្បធម៌អាស៊ីយើង ទំនាក់ទំនងគ្រួសាររបស់យើងមានសារៈសំខាន់ណាស់។ ក្រុមជំនុំក៏ដូចគ្នាដែរ បើគ្រូក្លែងក្លាយមិនទទួលស្គាល់យើងជាកូនព្រះទេ នោះគឺ

ដោយសារតែពួកគេមិនមែនជាកូនព្រះ។ ប្រសិនបើពួកគេគិតទាបចំពោះព្រះ ពួកគេក៏នឹងគិតទាបចំពោះកូនៗរបស់ព្រះដែរ។ បើពួកគេស្អប់ព្រះ ពួកគេក៏នឹងស្អប់កូនៗរបស់ទ្រង់ផង។ សូមកុំមានការភ្ញាក់ផ្អើលបើលោកីយ៍ស្អប់អ្នក។ ពីព្រោះពួកគេមានឪពុកផ្សេង។




*«អ្នកណាស្គាល់ និងស្រឡាញ់ព្រះអ្នកនោះនឹងស្គាល់ ហើយស្រឡាញ់កូនៗរបស់ទ្រង់ផង»។ (១យ៉ូហាន ៣:១៥)*

ព្រះយេស៊ូវក៏បានមានព្រះបន្ទូលទៅកាន់អ្នកដឹកនាំសាសនាយូដាថា ពួកគេមានឪពុកផ្សេងពីទ្រង់៖

> *«អ្នករាល់គ្នាមានអារក្សសាតាំងជាឪពុក ហើយអ្នករាល់គ្នាចូលចិត្តធ្វើតាមតណ្ហាដែលគាប់ចិត្តដល់ឪពុករបស់អ្នក វាជាអ្នកសម្លាប់គេតាំងពីដើមមក វាមិនបាននៅជាប់ក្នុងសេចក្ដីពិត ព្រោះគ្មានសេចក្ដីពិតនៅក្នុងវាទេ កាលណាវាពោលពាក្យភូតភរនោះដុះចេញអំពីចិត្តវាមក ដ្បិតវាជាអ្នកកំភូតហើយជាឪពុកនៃសេចក្ដីនោះឯង [៤៥] ដោយព្រោះតែខ្ញុំនិយាយសេចក្ដីពិតបានជាអ្នករាល់គ្នាមិនជឿខ្ញុំ [៤៦] តើមានពួកអ្នករាល់គ្នាណាមួយចាប់ប្រកាន់ខ្ញុំពីអំពើបាបបានឬទេ តែបើខ្ញុំនិយាយសេចក្ដីពិតវិញ ហេតុអ្វីបានជាមិនជឿដល់ខ្ញុំសោះ [៤៧] អ្នកណាដែលកើតអំពីព្រះនោះក៏ស្ដាប់តាមព្រះបន្ទូលនៃព្រះដែរឯអ្នករាល់គ្នាមិនបានកើតមកពីព្រះទេបានជាមិនស្ដាប់តាមដូច្នេះ»* (យ៉ូហាន ៨:៤៤-៤៧)។

### *១យ៉ូហាន ៣:២ក*

*ពួកស្ងួនភ្ងាអើយ **ឥឡូវនេះ**យើងរាល់គ្នាជាកូនព្រះហើយ តែដែលយើងរាល់គ្នា**នឹង
បាន**ទៅជាយ៉ាងណាទៀតនោះ មិនទាន់សម្ដែងមកនៅឡើយ។*

### «ហើយ» និង «នឹងបាន»

ចូរកត់សំគាល់ពាក្យ «ហើយ» និង «នឹងបាន»។ យើងរាល់គ្នាជាកូនព្រះ**ហើយ**! នៅក្នុងសាសនាទាំងអស់ អ្នកកាន់សាសនានោះមិនអាចដឹងប្រាកដថា គេមានសេចក្ដីសង្គ្រោះ**ហើយ**នោះទេ។ គេត្រូវរង់ចាំដល់ថ្ងៃជំនុំជម្រះ នៅពេលអំពើបាបនិងអំពើល្អរបស់គេត្រូវថ្លឹងគ្នា។ ប៉ុន្តែនៅក្នុងគ្រីស្ទសាសនា*«យើងរាល់គ្នាជាកូនព្រះហើយ»* ហើយការពិតនេះ**ឥឡូវ** មានន័យថា នឹងមានការដែលយើង *«នឹងបាន»* ដែលយើងនឹងទទួលនៅថ្ងៃអនាគត ទោះបីជាវាមិនទាន់មកដល់ក៏ដោយ *(«តែដែលយើងរាល់គ្នានឹងបានទៅជាយ៉ាងណាទៀតនោះ មិនទាន់សម្ដែងមកនៅឡើយ »)*។ សូមស្ដាប់លោកយ៉ូហានទាយអំពីអនាគតរបស់យើង៖

### *១យ៉ូហាន ៣:២ខ*

*ប៉ុន្តែយើងដឹងថា កាលណាទ្រង់លេចមក នោះយើងនឹងបានដូចជាទ្រង់ ដ្បិតដែលទ្រង់យ៉ាងណា នោះយើងនឹងឃើញទ្រង់យ៉ាងនោះឯង។*

សិរីល្អរបស់ព្រះខ្លាំងណាស់។ អ្នកណាឃើញព្រះគ្រីស្ទ នៅក្នុងសិរីរុងរឿងរបស់ទ្រង់ នឹងទទួលការដេញឲ្យបរិសុទ្ធទាំងស្រុងដូចមាស ហើយក្លាយជាមានលក្ខណៈដូចព្រះអង្គ ឬក៏ត្រូវទទួលការបំផ្លាញ គឺបណ្ដេញចេញឆ្ងាយពីព្រះភ័ក្ត្ររបស់ទ្រង់អស់កល្បជានិច្ច។ ក្ដីសង្ឃឹមដ៏មុតមាំថា នៅថ្ងៃមួយយើងនឹងបានបរិសុទ្ធដូចព្រះយេស៊ូវ ជំរុញយើងឲ្យចង់ក្លាយជាមនុស្សបរិសុទ្ធឥឡូវនេះ ដូចក្នុងខបន្ទាប់នេះ។

***១យ៉ូហាន ៣:៣***

*អស់អ្នកណាដែលមានសេចក្តីសង្ឃឹមយ៉ាងនេះដល់ទ្រង់ នោះក៏តែងជំរះសំអាតចិត្តខ្លួនឲ្យដូចទ្រង់ដែលស្អាតដែរ។*

ខនេះរំឭកយើងពីកណ្ឌគម្ពីរយ៉ូហានខ្សែទី១ជំពូក១ ដែលបានប្រាប់យើងថា គ្រីស្ទបរិស័ទមិនត្រូវនិយាយថា *«ខ្ញុំគ្មានបាបសោះ»*។ មនុស្សដែលគ្មានបាបសោះមិនត្រូវការ *«ជំរះសំអាតចិត្តខ្លួន»* នោះទេ ព្រោះគាត់បរិសុទ្ធហើយ។ តែគ្រីស្ទបរិស័ទទាំងអស់នៅតែប្រព្រឹត្តបាបរាល់ថ្ងៃ បានជាគេត្រូវ *«ជំរះសំអាតចិត្តខ្លួន»* ដោយជំនួយពីព្រះវិញ្ញាណ និងអំណាចនៃព្រះបន្ទូល។

**អស់អ្នកដែលកើតពីព្រះនឹងមានភ័ស្តុតាងបី (ហើយគ្រូខុសឆ្គងនឹងខ្វះភ័ស្តុតាងទាំងនេះ)**

បន្ទាប់ពីលោកយ៉ូហាន ប្រាប់យើងពីគោលការណ៍សំខាន់នៃការកើតពីព្រះ គាត់ក៏បង្ហាញយើងថា ការកើតពីព្រះនឹងមានភ័ស្តុតាងបីនេះ...

១. អស់អ្នកដែលកើតពីព្រះនឹង**បរិសុទ្ធ** (៣:៤-១០)
២. អស់អ្នកដែលកើតពីព្រះនឹង**ស្រឡាញ់គ្នា** (៣:១១-២៤)
៣. អស់អ្នកដែលកើតពីព្រះនឹង**ជឿសេចក្តីពិត** (៤:១-៦)

យើងស្គាល់ចំណុចទាំងបីនេះ ជាបញ្ញត្ត៣ក្នុងបញ្ញត្តបួន ដែលចេញពីសេចក្តីពិតថា ព្រះជាពន្លឺ ហើយព្រះជាសេចក្តីស្រឡាញ់៖




ឥឡូវចូរយើងមើលភ័ស្តុតាងទាំងបីនេះម្តងមួយ។

# ភ័ស្តុតាងទី១៖
# អស់អ្នកណាដែលកើតពីព្រះនឹងត្រូវបរិសុទ្ធ

## ១យ៉ូហាន ៣:៤-១០

### *១យ៉ូហាន ៣:៤*

*ឯអស់អ្នកណាដែលប្រព្រឹត្តអំពើបាបវិញ នោះក៏ឈ្មោះថា ប្រព្រឹត្តរំលងក្រិត្យវិន័យដែរ ដ្បិតអំពើបាបជាការរំលងក្រិត្យវិន័យហើយ។*

លោកយ៉ូហានមានប្រសាសន៍ពីអំពើបាបនៅគ្រប់ជំពូក ប៉ុន្តែនេះជាលើកទីមួយហើយដែលគាត់ផ្តល់និយមន័យនៃអំពើបាប៖ *«អំពើបាបជាការរំលងក្រិត្យវិន័យ»*។ អាចនិយាយបានម៉្យាងទៀតថា អំពើបាបគឺជាការជិះជាន់ក្រឹត្យវិន័យល្អរបស់ព្រះ។ តើក្រឹត្យវិន័យរបស់ព្រះជាអ្វី? ព្រះយេស៊ូវបានសង្ខេបគម្ពីរសញ្ញាចាស់ទាំងមូល ជាក្រឹត្យវិន័យតែពីរ គឺស្រឡាញ់ព្រះអស់ពីចិត្ត ហើយស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង។ ដូច្នេះការ *«រំលងក្រិត្យវិន័យ»* មានន័យថា រស់នៅដោយជីវិតដែលជាន់ឈ្លីនូវបញ្ញត្តដ៏ធំទាំងពីរនេះ។ អំពើបាបជាប្រភេទជីវិតដែល...

> ...ស្រឡាញ់**របស់**ដែលព្រះបង្កើត ជាជាងព្រះ និង
> ...ស្រឡាញ់**ខ្លួនឯង**ជាងអ្នកដទៃ។

តើធ្វើដូចម្តេច ទើបយើងដឹងថា យើងកើតពីព្រះ? យើងនឹងធ្វើតាមក្រឹត្យវិន័យរបស់ព្រះ។ ឬនិយាយម៉្យាងទៀត យើងនឹងស្រឡាញ់ព្រះ ហើយស្រឡាញ់អ្នកដទៃ។ តើ

ធ្វើដូចម្ដេច ទើបយើងដឹងថា យើងមិនបានកើតពីព្រះ? គឺយើងនឹងស្រឡាញ់របស់ដែលព្រះបានបង្កើត ជាជាងព្រះ ហើយយើងស្រឡាញ់ខ្លួនឯងជាងអ្នកដទៃ។

## *១យ៉ូហាន ៣:៥*

*អ្នករាល់គ្នាដឹងហើយថា ទ្រង់បានលេចមកដើម្បីនឹងដោះបាបយើងចេញ ហើយក៏នៅក្នុងទ្រង់នោះគ្មានបាបសោះ។*

ហេតុអ្វីបានជាព្រះយេស៊ូវបានយាងមក? គឺ *«...ដើម្បីដោះបាបយើងចេញ»* តើព្រះស្ដាប់ព្រះទ័យ ដោយគ្រាន់តែសង្គ្រោះយើងពី**ទោស**នៃអំពើបាបនៅស្ថាននរកឬ? ទេ មិនមែនទេ ទ្រង់ក៏ចង់សង្គ្រោះយើងពី**អំណាច**នៃអំពើបាបនៅជីវិតនេះដែរ។ ទ្រង់មិនចង់ឲ្យយើងបន្តទម្លាប់ចាស់របស់យើង គឺស្រឡាញ់របស់ដែលព្រះបង្កើត ជាជាងព្រះ និងស្រឡាញ់ខ្លួនឯង ជាជាងអ្នកដទៃនោះ។ ព្រះជាម្ចាស់ស្អប់អំពើបាប ទ្រង់ដឹងថាអំពើបាបលួចអំណររបស់យើង ហើយរារាំងការលូតលាស់របស់យើង។

*«...នៅក្នុងទ្រង់នោះគ្មានបាបសោះ»* ព្រះយេស៊ូវមិនដែលមានបាបឡើយ។ ទ្រង់តែងតែស្រឡាញ់ព្រះវរបិតាច្រើនជាងស្រឡាញ់របស់ដែលព្រះអង្គបង្កើត ហើយទ្រង់តែងតែស្រឡាញ់អ្នកដទៃ ច្រើនជាងទ្រង់ស្រឡាញ់អង្គទ្រង់ផ្ទាល់។ ទ្រង់ជាគំរូនៃយើង។ ប៉ុន្តែទ្រង់មិនគ្រាន់តែជាគំរូឲ្យយើងត្រាប់តាមប៉ុណ្ណោះទេ ទ្រង់ក៏ជាអង្គសង្គ្រោះរបស់យើងផងដែរ សម្រាប់ឲ្យយើងជឿទុកចិត្ត។ ទ្រង់បានសុគតនៅលើឈើឆ្កាងដើម្បីបាបយើង ដើម្បីឲ្យយើងកើតជាថ្មីដោយព្រះវិញ្ញាណបរិសុទ្ធ និងរស់នៅក្នុងជីវិតដ៏បរិសុទ្ធ។ ព្រះយេស៊ូវ *«បានលេចមកដើម្បីនឹងដកបាបចេញ»* ទាំង**ទោស**នៃអំពើបាប និង**អំណាច**នៃអំពើបាប។

### *១យ៉ូហាន ៣:៦*

*អស់អ្នកដែលនៅជាប់ក្នុងព្រះអង្គ អ្នកនោះមិនធ្វើបាបទេ តែអ្នកដែលធ្វើបាប មិនបានឃើញព្រះអង្គឡើយ គឺមិនបានស្គាល់ព្រះអង្គផង (ព្រះគម្ពីរ RKOV)*

[ ខ៦យើងយោងតាមគម្ពីរ RKOV វិញ ពីព្រោះខនេះក្នុង KOV បកប្រែខ្លាំងពេកថា *«...មិន**ដែល**ធ្វើបាប»* ភាសាដើមអត់មានពាក្យ«ដែល» ទេ។ ]




*«អស់អ្នកដែល**នៅជាប់**ក្នុងព្រះអង្គ អ្នកនោះ **មិនធ្វើបាប**ទេ»។ (១យ៉ូហាន ៣:៦ RKOV)*

*«អស់អ្នកដែលនៅជាប់ក្នុងព្រះអង្គ អ្នកនោះមិនធ្វើបាបទេ»* ខ៦នេះមិននិយាយថា គ្រីស្ទបរិស័ទមិនដែលធ្វើបាបនោះទេ។ (បើមិនដូច្នោះទេ ហេតុអ្វីបានជាព្រះយេស៊ូវប្រាប់យើងឲ្យលន់តួបាបចំពោះព្រះរៀងរាល់ថ្ងៃ?) ខនេះសំដៅទៅទម្លាប់ និងកេរ្តិ៍ឈ្មោះប្រចាំថ្ងៃនៃគ្រីស្ទបរិស័ទ។ គ្រីស្ទបរិស័ទមិនរស់នៅជីវិតបែបអំពើបាបទេ។ តើនៅភូមិរបស់អ្នក អ្នកមានកេរ្តិ៍ឈ្មោះដូចម្តេច? តើអ្នកបង្កើតសន្តិភាព ឬបង្កឲ្យមានបញ្ហា? តើអ្នកនិយាយរបៀបសប្បុរស ដែលលើកទឹកចិត្ត ឬជាពាក្យជេរប្រមាថ និងនិយាយដើមគេ។ តើអ្នកកំណាញ់ ឬសប្បុរស? តើអ្នកប្រើទូរស័ព្ទដើម្បីលើកទឹកចិត្តមនុស្ស ឬមើលរឿងអាសអាភាស និងខ្សែភាពយន្តលោកីយ៍? តើអ្នកអត់ទោសឲ្យអ្នកដទៃ ឬចងគំនុំ? *«អស់អ្នកដែលនៅជាប់ក្នុងព្រះអង្គ អ្នកនោះមិនធ្វើបាបទេ»*។

មនុស្សជាច្រើនមិននៅជាប់ក្នុងព្រះគ្រីស្ទទេ។ ដូចជាគ្រាប់ពូជនៅលើដីថ្ម (ម៉ាថាយ ១៣:២០) ពួកគេជឿមួយរយៈខ្លី បន្ទាប់មកចាកចេញទៅ ដូចលោកយូដាសបានចាកចេញ។ ប៉ុន្តែអ្នកដែលនៅជាប់ក្នុងព្រះគ្រីស្ទ នឹងរស់នៅតាមរបៀបមួយដែល

បង្ហាញភ័ស្តុតាងនៃជីវិតបរិសុទ្ធ។ លោកយ៉ូហាន កំពុងរំឭកអ្នកស្តាប់ថា គ្រូក្លែងក្លាយមិននៅជាប់ក្នុងព្រះគ្រីស្ទទេ។ ពួកគេស្រឡាញ់ការកុហករបស់គេច្រើនជាងព្រះ និងសេចក្តីពិត។ លោកយ៉ូហានក៏ចង់ឲ្យគ្រីស្ទបរិស័ទដែលនៅជាប់នឹងទ្រង់ សំឡឹងមើលជីវិតផ្ទាល់ខ្លួនដែរ ដើម្បីសួរថា តើជីវិតរបស់ពួកគេមានភ័ស្តុតាងនៃភាពបរិសុទ្ធ ឬភ័ស្តុតាងនៃការរំលងក្រឹត្យវិន័យ?

## *១យ៉ូហាន ៣:៧*

*កូនតូចៗរាល់គ្នាអើយ! ចូរកុំឲ្យអ្នកណានាំអ្នករាល់គ្នាឲ្យវង្វេងឡើយ អ្នកណាដែលប្រព្រឹត្តសេចក្តីសុចរិតនោះឈ្មោះថា សុចរិតហើយ ដូចជាទ្រង់ក៏សុចរិតដែរ។*

ខនេះមានការសាកល្បងដ៏សាមញ្ញ ដែលជួយយើងវិនិច្ឆ័យរវាង គ្រូក្លែងក្លាយ និងគ្រូពិត។ តើពួកគេ ប្រព្រឹត្តសេចក្តីសុចរិតឬ? ពិតមែនគ្មានគ្រូណាដែលបរិសុទ្ធទាំងស្រុងទេ ព្រោះព្រះយេស៊ូវមិនទាន់យាងមកវិញ (១យ៉ូហាន ៣:២ខ)។ ប៉ុន្តែមនុស្សដែលបានកើតពីព្រះ មានទម្លាប់រស់នៅរបៀបសុចរិត។ តើអ្វីជាទម្លាប់នៃជីវិតរបស់អ្នក? តើអ្វីជាកេរ្តិ៍ឈ្មោះរបស់អ្នកនៅក្នុងភូមិ?




*«អ្នកណាដែលប្រព្រឹត្តសេចក្តីសុចរិត នោះឈ្មោះថា សុចរិត»។ (១យ៉ូហាន ៣:៧)*

*«ចូរកុំឲ្យអ្នកណានាំអ្នករាល់គ្នាឲ្យវង្វេងឡើយ»*។ មើលទៅគ្រូក្លែងក្លាយដែលទើបតែចាកចេញបានព្យាយាមបំភាន់សមាជិកក្រុមជំនុំ អំពីអំពើបាប។ ពួកគេបានការពារអំពើបាបរបស់ខ្លួនដោយនិយាយថា *«យើងមិនបានធ្វើបាប»* (១:១០)។ ឬពួកគេខ្លះបានបដិសេធមិនទទួលស្គាល់ថា ពួកគេមានបាបក្នុងជីវិតឡើយ ដោយថា៖

*«យើងគ្មានបាបសោះ»* (១:៨)។ ប្រហែលជាពួកគេបាននិយាយថា «កុំចោទប្រកាន់ខ្ញុំពីបាបខ្ញុំ ខ្ញុំសុចរិតក្នុងព្រះគ្រីស្ទ ទោះបីការប្រព្រឹត្តរបស់ខ្ញុំយ៉ាងណាក៏ដោយ»។ មួយទៀត ប្រហែលពួកគេថា «ពិតមែន ខ្ញុំបានប្រព្រឹត្តបាបនោះមែន ប៉ុន្តែបាបខ្ញុំនាំឲ្យព្រះទទួលការសរសើរកាន់តែច្រើន សម្រាប់ព្រះគុណ ដ៏ធំរបស់ទ្រង់» (សូមមើល រ៉ូម ៦:១)។ ឬប្រហែលពួកគេនិយាយថា «គឺរូបកាយខ្ញុំដែលបានធ្វើបាបនោះ មិនមែនព្រលឹងខ្ញុំទេ»។ មានវិធីជាច្រើនដែលគ្រូក្លែងក្លាយអាចបញ្ឆោតគ្រីស្ទបរិស័ទ ដើម្បីការពារអំពើបាបរបស់ពួកគេ។

## *១យ៉ូហាន ៣:៨ក*

*តែអ្នកណាដែលប្រព្រឹត្តអំពើបាបវិញ នោះគឺមកពីអារក្សទេ ពីព្រោះអារក្សបានធ្វើបាបចាប់តាំងពីដើមរៀងមក។*

*«...គឺមកពីអារក្សទេ»* តាមខនេះ តើអ្នកណាជាឪពុកខាងវិញ្ញាណរបស់មនុស្សដែលមានទម្លាប់នៃអំពើបាប ជំនួសទម្លាប់នៃភាពបរិសុទ្ធ? *«អ្នកណាដែលប្រព្រឹត្តអំពើបាបវិញ នោះគឺមកពីអារក្សទេ ពីព្រោះអារក្សបានធ្វើបាបចាប់តាំងពីដើមរៀងមក»*។ ព្រះយេស៊ូវមានបន្ទូលស្រដៀងគ្នា ទៅកាន់ពួកមេដឹកនាំសាសនាថា៖ *«អ្នករាល់គ្នាមានឪពុកជាអារក្ស»* (យ៉ូហាន ៨:៤៤)។ ពួកគេគ្មានទម្លាប់នៃសេចក្ដីសុចរិតឡើយ។ ពួកគេមិនបានកើតមកពីព្រះទេ។




*«អ្នកណាដែលប្រព្រឹត្ត**អំពើបាប** នោះគឺមក**ពីអារក្ស**ទេ»។ (១យ៉ូហាន ៣:៨ក)*

## *១យ៉ូហាន ៣:៨ខ*

*ដោយហេតុនោះបានជាព្រះរាជបុត្រានៃព្រះបានលេចមក គឺដើម្បីនឹងបំផ្លាញការរបស់អារក្សចេញ។*

នេះជាលើកទីពីរហើយ ដែលលោកយ៉ូហានបានប្រាប់យើង ពីមូលហេតុដែលព្រះយេស៊ូវយាងមកពីស្ថានសួគ៌៖

ទ្រង់បានលេចមកដើម្បីនឹង *«ដកបាបចេញ»* (១យ៉ូហាន ៣:៥)

ទ្រង់បានលេចមកដើម្បីនឹង *«បំផ្លាញការរបស់អារក្ស»* (១យ៉ូហាន ៣:៨ខ)

អំពើបាប និងសាតាំង គឺជាសត្រូវរបស់ព្រះ និងរបស់យើង។ ព្រះយេស៊ូវបានយាងមកដើម្បីបំផ្លាញសត្រូវទាំងពីរនេះ ហើយទ្រង់នឹងទទួលបានជ័យជំនះជាមិនខាន។ បើយើងអះអាងថា កើតពីព្រះ ប៉ុន្តែយើងធ្វើសន្ធិសញ្ញាសម្ងាត់ជាមួយសត្រូវរបស់ព្រះ (គឺបាប និងសាតាំង) នោះយើងបញ្ឆោតខ្លួនយើងហើយ។

ព្រះយេស៊ូវបានលេចមកដើម្បី *«បំផ្លាញការរបស់អារក្ស»*។ ការនេះគួរលើកទឹកចិត្តដល់យើង ពីព្រោះអ្វីក៏ដោយដែលព្រះអម្ចាស់យេស៊ូវមានព្រះរាជបំណងនឹងធ្វើ ទ្រង់នឹងធ្វើដោយជោគជ័យទាំងស្រុង។ បើទ្រង់យាងមកដើម្បីបំផ្លាញអារក្សសាតាំង នោះអារក្សសាតាំងនឹងត្រូវបំផ្លាញជាមិនខាន។ ព្រះគ្រីស្ទបានឈ្នះសាតាំងតាមរយៈការសុគត និងការរស់ឡើងវិញរបស់ទ្រង់ហើយ ហើយឥឡូវនេះទ្រង់កំពុងតែបំផ្លាញកិច្ចការរបស់សាតាំង ពាសពេញពិភពលោក តាមរយៈដំណឹងល្អ ហើយកំពុងតាំងបល្ល័ង្ករបស់ទ្រង់នៅលើនគរហិនហោចរបស់សាតាំង។ ទ្រង់កំពុងរំដោះអ្នកទោសពីសាតាំង និងដោះលែងពួកគេឲ្យមានសេរីភាព ហើយចូលរួមខាងសេចក្តីសុចរិតវិញ។ ការបំផ្លាញចុងក្រោយដល់សាតាំង នឹងកើតឡើងនៅពេលព្រះយេស៊ូវយាងមកលើកទីពីរ។ បើព្រះយេស៊ូវស្អប់កិច្ចការរបស់អារក្សខ្លាំងណាស់ ហេតុអ្វីបានជាអ្នក និងខ្ញុំចង់ធ្វើសន្តិភាពជាមួយបាបទៀត? ដោយមានជំនួយពីព្រះវិញ្ញាណ

បរិសុទ្ធនៅក្នុងយើង យើងត្រូវតែសម្លាប់អ្វីដែលនៅសេសសល់នៃអំពើបាបនៅក្នុងជីវិតរបស់យើង (រ៉ូម ៨:១៣-១៤)។ ហើយរស់នៅតាមទម្លាប់នៃអំពើល្អ និងសេចក្ដីស្រឡាញ់។

### *១យ៉ូហាន ៣:៩*

*អស់អ្នកដែលកើតពីព្រះ មិនប្រព្រឹត្តអំពើបាបទេ ដ្បិតពូជរបស់ព្រះស្ថិតនៅជាប់ក្នុងអ្នកនោះ ហើយអ្នកនោះពុំអាចធ្វើបាបបានឡើយ ព្រោះគេបានកើតពីព្រះ។ (RKOV)*

លោកយ៉ូហានមានប្រសាសន៍ឡើងវិញ នូវគោលការណ៍សំខាន់នេះ៖ ភ័ស្ដុតាងមួយដែលបញ្ជាក់ថា មនុស្សកើតពីព្រះ គឺថា គាត់មានទម្លាប់នៃភាពបរិសុទ្ធ ជំនួសឲ្យទម្លាប់នៃអំពើបាប។ តាមពិតគាត់មិនអាច *«ប្រព្រឹត្តអំពើបាប»* ជាទម្លាប់រស់នៅជាប្រចាំបានទេ ពីព្រោះជាពូជខាងវិញ្ញាណនៃព្រះ ស្ថិតនៅក្នុងចិត្តគាត់ដោយសារព្រះវិញ្ញាណ! នៅពេលគាត់បានធ្វើបាប គាត់សារភាពកំហុសនៅចំពោះព្រះភ្លាម ហើយទទួលបានការអត់ទោសភ្លាមដែរ។




*«អស់អ្នកដែល**កើតពីព្រះ** មិនប្រព្រឹត្ត**អំពើបាប**ទេ ដ្បិតពូជរបស់ព្រះស្ថិតនៅជាប់ក្នុងអ្នកនោះ ហើយអ្នកនោះពុំអាចធ្វើបាបបានឡើយ ព្រោះគេបានកើតពីព្រះ»។ (១យ៉ូហាន ៣:៩)*

ឃ្លាទាំងប្រាំក្នុង១យ៉ូហាន ៣:៩ បង្កើតបានជារូបភាព ដែលមានតុល្យភាព ដោយឃ្លាទីមួយជាគូរនឹងទី៥ ហើយឃ្លាទី២ជាគូរនឹងឃ្លាទី៤ ហើយគន្លឹះនៅកណ្ដាល៖

ក. អស់អ្នកដែល**កើតពីព្រះ**

ខ. មិនប្រព្រឹត្ត**អំពើបាប**ទេ

គ. ដ្បិត**ពូជរបស់ព្រះ**ស្ថិតនៅជាប់ក្នុងអ្នកនោះ

ខ. អ្នកនោះពុំអាចធ្វើ**បាប**បានឡើយ

ក. ព្រោះគេបាន**កើតពីព្រះ**។ (Kruse ទំព័រ ១២៥)

***១យ៉ូហាន ៣:១០***

*គឺយ៉ាងនោះហើយដែលនឹងសម្គាល់ថា ជាពួកកូនព្រះ ឬពួកកូនអារក្សទៅបាន ឯអ្នកណាដែលមិនប្រព្រឹត្តសេចក្ដីសុចរិត ហើយមិនស្រឡាញ់ដល់បងប្អូននោះ មិនមែនមកពីព្រះទេ។*

នៅក្នុងប្រយោគមួយនេះលោកយ៉ូហាន វេញបញ្ចូលគ្នានូវការសាកល្បងពីររបស់គ្រូបង្រៀន ដូចក្នុងរូបពីរនេះ៖




*«អ្នកណាដែលមិនប្រព្រឹត្តសេចក្ដីសុចរិត...នោះមិនមែនមក**ពីព្រះ**ទេ»។ (១យ៉ូហាន ៣:១០ខ)*




*«ឯអ្នកណា...ដែលមិន**ស្រឡាញ់បងប្អូនខ្លួន***
*នោះមិនមែន**មកពីព្រះ**ទេ»។ (១យ៉ូហាន ៣:១០គ)*

ខ១០ជាលើកទីបីហើយ ដែលលោកយ៉ូហានមានប្រសាសន៍ អំពីភ័ស្តុតាងនៃភាពបរិសុទ្ធ៖ «អ្នកណាដែលកើតពីព្រះនឹងមានជីវិតបរិសុទ្ធ»។ គ្រីស្ទបរិស័ទពិតមានទម្លាប់នៃភាពបរិសុទ្ធ មិនមែនទម្លាប់នៃអំពើបាបទេ។ នេះជាភ័ស្តុតាងទីមួយរបស់លោកយ៉ូហាន ដែលយើងកើតពីព្រះ។

ឃ្លាចុងបញ្ចប់នៃខ១០ នាំមកនូវភ័ស្តុតាងទីពីរនៃការកើតពីព្រះ៖ «អស់អ្នកណាដែលកើតពីព្រះ នឹងស្រឡាញ់អ្នកដទៃ»។ ក្នុងជប់បួនខបន្ទាប់ទៀត លោកយ៉ូហាននឹងពន្យល់ពីរឿងជាច្រើនអំពីសេចក្តីស្រឡាញ់ និងការស្តាប់។

# ភ័ស្តុតាងទី២៖
# អស់អ្នកណាដែលកើតពីព្រះ នឹងស្រឡាញ់អ្នកដទៃ
## ១យ៉ូហាន ៣:១១-២៤

***១យ៉ូហាន ៣:១១***

*ដ្បិតនេះឯងជាសេចក្តីដែលអ្នករាល់គ្នាបានឮពីដើមរៀងមកគឺថា ត្រូវឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមក។*

*«...បានឮពីដើមរៀងមក»* ពីរដងហើយដែលលោកយ៉ូហានបានព្រមានអ្នកស្តាប់របស់គាត់ កុំឲ្យស្វែងរកគោលជំនឿថ្មីឡើយ។ ផ្ទុយទៅវិញពួកគេត្រូវតែ...

១. នៅជាប់នឹង *«បទបញ្ញត្តដែលអ្នកមាន**តាំងពីដើមរៀងមក**»* គឺឲ្យស្រឡាញ់គ្នាទៅវិញទៅមក (១យ៉ូហាន ២:៧)។

២. នៅជាប់នឹង *«អ្វីដែលអ្នកបានឮ**តាំងពីដើមរៀងមក**»* ដែលជាដំណឹងល្អពិត អំពី ព្រះយេស៊ូវដែលបានយាងមកក្នុងសាច់ឈាម (១យ៉ូហាន ២:២៤)។

ឥឡូវនេះ គាត់បន្ថែមមួយទៀត ដែលតាមពិតដូចគ្នានឹងទីមួយខាងលើ៖

៣. នៅជាប់នឹង *«សេចក្តីដែលអ្នករាល់គ្នាបានឮ**តាំងពីដើមរៀងមក** គឺថា ត្រូវឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមក»* (១យ៉ូហាន ៣:១១)។

នេះមានន័យថា តាំងពីដំបូងដល់ចប់នៃព័ន្ធកិច្ចរបស់ព្រះយេស៊ូវជាមួយពួកសិស្ស ប្រធានបទសំខាន់មួយរបស់ទ្រង់ គឺកូនៗក្នុងព្រះរាជ្យរបស់ព្រះ ត្រូវស្រឡាញ់គ្នាទៅវិញទៅមក។ *«គេនឹងដឹងថា អ្នករាល់គ្នាជាសិស្សរបស់ខ្ញុំ ដោយសារសេចក្តីនេះឯង គឺដោយអ្នករាល់គ្នាមានសេចក្តីស្រឡាញ់ដល់គ្នាទៅវិញទៅមក»* (យ៉ូហាន ១៣:៣៥)។

## *១យ៉ូហាន ៣:១២*

*មិនមែនដូចជាកាអ៊ីនដែលកើតពីមេកំណាចមក ហើយបានសម្លាប់ប្អូនខ្លួននោះឡើយ ចុះតើហេតុអ្វីបានជាសម្លាប់ប្អូន គឺពីព្រោះតែការរបស់គាត់សុទ្ធតែអាក្រក់ ហើយការរបស់ប្អូនសុទ្ធតែល្អវិញ។*

ពេលយើងបង្រៀន ជាការល្អដែលយើងត្រូវឲ្យឧទាហរណ៍ល្អសម្រាប់អ្នកស្តាប់ធ្វើតាម។ ប៉ុន្តែវាក៏ជាការល្អដែរ ដែលពេលខ្លះ យើងឲ្យឧទាហរណ៍អាក្រក់ដើម្បីឲ្យគេចៀសវាង។ នៅខនេះលោកយ៉ូហានក៏បានផ្តល់គំរូអាក្រក់អំពីកាអ៊ីនដែលស្អប់ប្អូនរបស់គាត់ រហូតដល់បានសម្លាប់ប្អូននោះទៅ។ កាអ៊ីនបានធ្វើដូច្នេះ ពីព្រោះគាត់មិនមែនកើតពីព្រះទេ។ នោះហើយជាមូលហេតុដែល *«ការរបស់គាត់សុទ្ធតែអាក្រក់ ហើយការរបស់ប្អូនសុទ្ធតែល្អវិញ»*។ តែអេបិលបានកើតពីព្រះ។ គាត់មានឪពុកខាងវិញ្ញាណខុសគ្នា ដូច្នេះការប្រព្រឹត្តរបស់គាត់ គឺសុចរិត ហើយកេរ្តិ៍ឈ្មោះល្អរបស់គាត់នៅតែនិយាយដល់យើងរហូតដល់សព្វថ្ងៃនេះ (ហេព្រើរ ១១:៤)។

*«កាអ៊ីនដែលកើតពីមេកំណាច»* មានន័យថា សាតាំងជាឪពុក ឬជាម្ចាស់**ខាងវិញ្ញាណ**របស់កាអ៊ីន ដូចដែលយើងមានព្រះជាឪពុកខាងវិញ្ញាណរបស់យើងដែរ (ចូរប្រៀបធៀប ៣:១០ «ពួកកូនអារក្ស»)។ លោកប៉ុលក៏មានប្រសាសន៍ប្រាប់យើងនៅក្នុងគម្ពីរទីតុស ៣:៣ថា មុនយើងកើតជាថ្មី ជាកូនព្រះ *«យើងរស់នៅដោយទុច្ចរិត និងច្រណែនដោយការស្អប់ និងស្អប់គ្នាទៅវិញទៅមក»*។

**ប្រយ័ត្ន៖** គ្រូក្លែងក្លាយដ៏មានប្រជាប្រិយម្នាក់នៅអាមេរិកឈ្មោះ វីល្លៀម ប្រាណហាំ (William Branham) (១៩០៩-១៩៦៦) បានបង្រៀនថា អេវ៉ាបានរួមភេទជាមួយអារក្សសាតាំង ហើយបានបង្កើតកាអ៊ីន។ ការបង្រៀនខុសឆ្គងនេះ ដែលមកដល់អាស៊ីជំនាន់មុន មិនមាននៅក្នុងព្រះគម្ពីរទេ។ លោកប្រាណហាំ បានអះអាងថា គាត់បានទទួលការបង្រៀននេះ ដោយផ្ទាល់ពីព្រះ ប៉ុន្តែតាមពិត គ្រូក្លែងក្លាយឈ្មោះ វ៉ាឡិនទីនុស (Valentinus ១០០-១៦០) បានបង្កើតការបង្រៀនខុសឆ្គងនេះនៅសតវត្សទី២ ក្រោយសាវកយ៉ូហានស្លាប់មិនយូរប៉ុន្មាន។ លោកប្រាណហាំ ក៏បានបដិសេធគោលលទ្ធិនៃព្រះត្រៃឯកដែរ។ សព្វថ្ងៃគ្រូចម្រុងចម្រើនខ្លះ ដែលផ្សាយតាមទូរទស្សន៍ និយាយថា លោកប្រាណហាំ គឺបានជះឥទ្ធិពលយ៉ាងខ្លាំងក្នុងជីវិតរបស់ពួកគេ។ ហើយក្រុមខុសឆ្គងខ្លះ នៅតែបន្តការបង្រៀនកុហកនេះអំពីសាតាំង និងអេវ៉ា ដូចជាក្រុម សាន់ ម៉ុង មូន ជាដើម។ (សូមមើលផ្នែកទី២ នៃសៀវភៅនេះ)។

## ***១យ៉ូហាន ៣:១៣***

*បងប្អូនអើយបើលោកីយ៍ស្អប់អ្នករាល់គ្នា នោះកុំឲ្យឆ្ងល់ឡើយ។*

ទំនាក់ទំនងរវាងកាអ៊ីនដែលមិនជឿ និងអេបិលដែលជឿ គឺជានិមិត្តរូបនៃទំនាក់ទំនងរវាងលោកិយ និងយើង។ ព្រះយេស៊ូវបានមានបន្ទូលប្រាប់សិស្សទ្រង់ដូចគ្នានេះថា៖

> *«បើសិនជាលោកីយ៍ស្អប់អ្នករាល់គ្នា នោះអ្នករាល់គ្នាដឹងហើយថា គេបានស្អប់ខ្ញុំជាមុន។ ១៩ បើអ្នករាល់គ្នាជារបស់ផងលោកីយ៍ នោះលោកីយ៍នឹងស្រឡាញ់អ្នករាល់គ្នា តែដោយព្រោះខ្ញុំបានរើសចេញពីលោកីយ៍មក ហើយអ្នករាល់គ្នាមិនមែនជារបស់ផងលោកីយ៍ទៀត នោះបានជាលោកីយ៍ស្អប់អ្នករាល់គ្នាវិញ ២០ ចូរនឹកចាំពីពាក្យដែលខ្ញុំបានប្រាប់រួចហើយថា <បាវមិនមែនធំជាងចៅហ្វាយទេ> បើគេបានបៀតបៀនដល់ខ្ញុំ នោះគេនឹងបៀតបៀនដល់អ្នករាល់គ្នា ហើយ*

*បើគេកាន់តាមពាក្យខ្ញុំ នោះគេនឹងកាន់តាមពាក្យរបស់អ្នករាល់គ្នាដែរ» (យ៉ូហាន ១៥:១៨-២០)។*

### *១ យ៉ូហាន ៣:១៤*

*យើងរាល់គ្នាដឹងថា យើងបានកន្លងផុតពីសេចក្តីស្លាប់ទៅដល់ជីវិតហើយ ពីព្រោះយើងស្រឡាញ់ដល់ពួកបងប្អូន ឯអ្នកណាដែលមិនស្រឡាញ់បងប្អូន អ្នកនោះជាអ្នកនៅជាប់ក្នុងសេចក្តីស្លាប់នៅឡើយ។*




*«យើងរាល់គ្នាដឹងថា យើងបាន**កន្លងផុតពីសេចក្តីស្លាប់ ទៅដល់ជីវិត** ពីព្រោះយើង**ស្រឡាញ់ដល់ពួកបងប្អូន**»។ (១យ៉ូហាន ៣:១៤)*

កណ្ឌគម្ពីរយ៉ូហានខ្សែទី១មានពេញដោយការសាកល្បង ឬការវិនិច្ឆ័យ ដូចខនេះ ដើម្បីឲ្យយើងអាចសាកល្បងខ្លួនឯង និងសាកល្បងគ្រូក្លែងក្លាយ។ វិធីមួយដែលយើងដឹងថា *«យើងបានកន្លងផុតពីសេចក្តីស្លាប់ទៅដល់ជីវិត»* (កើតពីព្រះ) គឺយើង *«ស្រឡាញ់ដល់ពួកបងប្អូន»*។ គ្រូក្លែងក្លាយមិនចេះ *«ស្រឡាញ់ដល់ពួកបងប្អូន»* នោះមានន័យថា គាត់ស្ថិតក្នុងសេចក្តីស្លាប់ខាងវិញ្ញាណហើយ។

ធ្វើដូចម្តេចយើងអាច *«កន្លងផុតពីសេចក្តីស្លាប់ទៅឯជីវិត»*? ព្រះយេស៊ូវផ្ទាល់បានមានបន្ទូលប្រាប់យើងក្នុងយ៉ូហាន ៥:២៤-២៥ ថា *«ប្រាកដមែនខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលស្តាប់ពាក្យខ្ញុំ ហើយជឿដល់ព្រះអង្គដែលចាត់ឲ្យខ្ញុំមក អ្នកនោះមានជីវិតមិនដែលត្រូវជំនុំជំរះឡើយ គឺបានកន្លងហួសពីសេចក្តីស្លាប់ទៅដល់ជីវិតវិញ ប្រាកដមែនខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា នឹងមានពេលវេលាមក ក៏*

*មកដល់ហើយ ដែលមនុស្សស្លាប់នឹងឮសម្លេងព្រះរាជបុត្រានៃព្រះ ហើយអស់អ្នកណាដែលឮនឹងបានរស់វិញ»*។ មានតែព្រះទេ ដែលមានអំណាចនាំជីវិតចេញពីសេចក្តីស្លាប់ និងពន្លឺចេញពីភាពងងឹត និងចិត្តនៃសេចក្តីស្រឡាញ់ចេញពីចិត្តស្អប់។

***១យ៉ូហាន ៣:១៥***

*អ្នកណាដែលមានចិត្តស្អប់ដល់បងប្អូននោះឈ្មោះថា ជាអ្នកសម្លាប់គេហើយ អ្នករាល់គ្នាដឹងហើយថា គ្មានអ្នកសម្លាប់គេណាមួយដែលមានជីវិតដ៏រស់អស់កល្បជានិច្ចនៅក្នុងខ្លួនឡើយ។*




*«គ្មានអ្នកសម្លាប់គេណាមួយ ដែលមានជីវិតដ៏រស់អស់កល្បជានិច្ចនៅក្នុងខ្លួនឡើយ»។ (១យ៉ូហាន ៣:១៥)*

ដោយឮនឹងត្រចៀកផ្ទាល់របស់គាត់ លោកយ៉ូហានបានស្តាប់ព្រះអម្ចាស់យេស៊ូវពន្យល់ថា ការស្អប់ និងឃាតកម្មគឺជាអំពើបាបប្រភេទដូចគ្នា។ ព្រះយេស៊ូវមិនបានមានបន្ទូលថា ការស្អប់ និងឃាតកម្ម គឺជាបាបដូចគ្នាទាំងស្រុងនោះទេ ប៉ុន្តែថា ព្រះទ្រង់ទតមើលចិត្តរបស់យើង ហើយឃើញការស្អប់ដែលនៅទីនោះ ហើយចាត់ទុកវាជាឃាតកម្ម។ សូមស្តាប់ព្រះយេស៊ូវៈ *«អ្នករាល់គ្នាបានឮសេចក្តីដែលសម្តែងដល់មនុស្សពីបុរាណថា <កុំឲ្យសម្លាប់មនុស្សឲ្យសោះ បើអ្នកណាសម្លាប់មនុស្ស នោះក្រែងត្រូវជាប់ជំនុំជំរះហើយ> តែខ្ញុំប្រាប់អ្នករាល់គ្នាវិញថា សូម្បីតែអ្នកណាខឹងនឹងបងប្អូននោះក្រែងត្រូវជាប់ជំនុំជំរះដែរ ហើយអ្នកណាដែលស្តីឲ្យបងប្អូនថា អាចោលម្សៀត នោះក្រែងពួកក្រុមជំនុំធ្វើទោស តែចំណែកអ្នកណាដែលថា អាឆ្កួតនោះក្រែងធ្លាក់ទៅក្នុងភ្លើងនរក»* (ម៉ាថាយ ៥:២១-២២)។

ការស្អប់ ការច្រណែន និងការសងសឹក មាននៅក្នុងចិត្តមនុស្សតាំងពីកំណើត។ ជាច្រើនដង អ្នក និងខ្ញុំបានឃើញពាក្យ និងសកម្មភាពអាក្រក់ ដែលកុមារតូចៗធ្វើចំពោះគ្នាទៅវិញទៅមក។ ការនេះបង្ហាញយើងថា ការស្អប់ និងការសងសឹក គឺជានិស្ស័យមួយនៃចិត្តរបស់មនុស្សតាំងពីកំណើត។ មានតែការសុគតរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាងប៉ុណ្ណោះ ដែលអាចសង្គ្រោះយើងពីអំពើបាបនៃការស្អប់ និងឃាតកម្មបាន។ មានតែជំនឿលើព្រះយេស៊ូវប៉ុណ្ណោះ ដែលអាចផ្តល់ឲ្យយើងនូវចិត្តថ្មី ដែលមិនស្អប់គ្នាទៅវិញទៅមក។

ប៉ុន្តែ តើសេចក្តីស្រឡាញ់ជាអ្វី? តើការស្អប់ជាអ្វី? ដើម្បីឆ្លើយ លោកយ៉ូហានផ្តល់ឧទាហរណ៍មួយនៃសេចក្តីស្រឡាញ់ និងឧទាហរណ៍មួយនៃការស្អប់។ សូមស្តាប់៖

***១យ៉ូហាន ៣:១៦-១៨***

*ដោយសារសេចក្តីនេះ យើងរាល់គ្នាបានស្គាល់សេចក្តីស្រឡាញ់គឺដោយទ្រង់បាន*
*ស៊ូប្តូរព្រះជន្មទ្រង់ជំនួសយើង ដូច្នេះគួរឲ្យយើងប្តូរជីវិតយើងជំនួសបងប្អូនដែរ។*
*១៧ បើអ្នកណាមានភោគសម្បត្តិរបស់លោកីយ៍ ហើយឃើញបងប្អូនណាដែលខ្វះខាត*
*តែមិនចេះអាណិតមេត្តាសោះ នោះធ្វើដូចម្តេចឲ្យសេចក្តីស្រឡាញ់នៃព្រះបានស្ថិត*
*នៅក្នុងអ្នកនោះបាន ១៨ ពួកកូនតូចៗអើយ យើងមិនត្រូវស្រឡាញ់ដោយពាក្យសំដីឬ*
*ដោយបបូរមាត់ប៉ុណ្ណោះឡើយ គឺដោយការប្រព្រឹត្ត និងសេចក្តីពិតវិញ។*

មុននឹងយើងមើលឧទាហរណ៍របស់លោកយ៉ូហានអំពីសេចក្តីស្រឡាញ់ និងការស្អប់ សូមកត់សម្គាល់ថា នៅក្នុងខនេះគាត់បង្រៀនថា អ្នកណាដែលស្រឡាញ់ព្រះ ក៏នឹងស្រឡាញ់អ្នកដទៃដែរ ដូចក្នុងរូបនេះ។




*«បើអ្នកណាមានភោគសម្បត្តិរបស់លោកីយ៍ ហើយឃើញបងប្អូនណាដែលខ្វះខាត **តែមិនចេះអាណិតមេត្តាសោះ** នោះធ្វើដូចម្ដេចឲ្យ**សេចក្ដីស្រឡាញ់នៃព្រះ**បានស្ថិតនៅក្នុងអ្នកនោះបាន?»។ (១យ៉ូហាន ៣:១៧)*

**តើធ្វើដូចម្ដេចឲ្យយើងដឹងថា សេចក្ដីស្រឡាញ់គឺជាអ្វី**? *«យើងរាល់គ្នាបានស្គាល់សេចក្ដីស្រឡាញ់គឺដោយទ្រង់បានស៊ូប្ដូរព្រះជន្មទ្រង់ជំនួសយើង»* (៣:១៦) សូមក្រឡេកមើលគំរូរបស់ព្រះយេស៊ូវដែលជា *«អ្នកគង្វាលល្អ[ដែល]លះបង់ជីវិតដើម្បីចៀម»* (យ៉ូហាន ១០:១១,១៥)។ ទ្រង់បានចាត់ទុកយើងថា សំខាន់ជាងអង្គទ្រង់ដូច្នេះ*«យើងគួរតែលះបង់ជីវិតដើម្បីបងប្អូន»*។ នៅលើលោកនេះមិនមានសាសនាធំណាផ្សេងទៀត ដែលព្រះរបស់ពួកគេលះបង់ជីវិតសម្រាប់អ្នកដើរតាមនោះឡើយ។ ខ្លឹមសារនៃគ្រីស្ទសាសនា គឺជាសេចក្ដីស្រឡាញ់ ដែលលះបង់ប្រយោជន៍ផ្ទាល់ខ្លួន។

**តើធ្វើដូចម្ដេចឲ្យយើងដឹងថា ការស្អប់គឺជាអ្វី**? សូមអាន ៣:១៧ ចូរក្រឡេកមើលមនុស្សម្នាក់ ដែលមើលឃើញពីតម្រូវការរបស់មនុស្សនៅជុំវិញ ហើយគាត់មានលទ្ធភាពជួយ ប៉ុន្តែគាត់ *«បិទចិត្ត»* (ភាសាក្រេក) ទាស់នឹងមនុស្សទាំងនោះ។ នោះគឺជាការស្អប់ខ្ពើម។ ចិត្តដែលគួរតែមានសេចក្ដីសប្បុរស និងមេត្តាករុណាចំពោះពួកក្រីក្រ ទៅជាកំណាញ់វិញ។ ចិត្តដែលបិទនោះ និយាយថា «ទេខ្ញុំត្រូវការប្រាក់នោះ ច្រើនជាងគាត់ទៅទៀត។ ខ្ញុំក៏មិនមែនជាអ្នកមានដែរ។ តើគ្រួសារខ្ញុំនឹងរស់នៅដូចម្ដេច បើខ្ញុំឲ្យលុយ និងទ្រព្យរបស់យើងទៅឲ្យគេ? កូនៗរបស់ខ្ញុំក៏ត្រូវការលុយនោះសំរាប់បង់ថ្លៃសាលាដែរ»។ល។

ចិត្តកំណាញ់របស់យើងនេះដែលថា «កុំជួយគេ» គឺជាចិត្តដែលព្រះបានហាមដល់ជនជាតិអ៊ីស្រាអែល នៅក្នុងគម្ពីរចោទិយកថា ១៥:៧-១០

*«តែបើសិនជាមានអ្នកទាល់ក្រណានៅជាមួយនឹងឯង ដែលជាបងប្អូនឯង ...មិនត្រូវឲ្យឯង**តាំងចិត្តរឹង** ឬ**ក្តាប់ដៃ**នឹងបងប្អូនជាអ្នកក្រនោះឡើយ។ ... [8] គឺត្រូវឲ្យ**លាដៃ**ដល់គេវិញជាកុំខាន ហើយឲ្យគេខ្ចីតាមចិត្តឲ្យល្មមដល់គ្រាទាល់ក្រនោះចុះ [9] ចូរប្រយ័ត្ន កុំឲ្យមានចិត្តអាក្រក់ក្នុងចិត្តឯងដោយនឹកថា "ឆ្នាំទី៧ ជាឆ្នាំដែលត្រូវលើកលែង[បំណុល] នោះជិតដល់ហើយ" ហើយឯងគន់មើលបងប្អូនអ្នកក្រនោះ ដោយព្រងើយកន្តើយវិញ ឥតមានឲ្យអ្វីដល់គេសោះ ក្រែងគេប្តឹងដល់ព្រះយេហូវ៉ាពីឯង នោះនឹងបានរាប់ជាបាបដល់ឯង [10] ត្រូវឲ្យឯងចែកដល់គេជាកុំខានដោយមាន**ចិត្តឥតស្តាយ**ផង ដ្បិតបើប្រព្រឹត្តយ៉ាងដូច្នេះ នោះព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់នឹងប្រទានពរដល់ឯងក្នុងគ្រប់ទាំងការរបស់ឯង ហើយក្នុងអស់ទាំងការអ្វីដែលឯងដាក់ដៃធ្វើផង»។*

វគ្គនេះពីគម្ពីរចោទិយកថា អំពីការ**មិនបិទចិត្ត**របស់យើងទៅកាន់ជនក្រីក្រ អាចជួយយើងឲ្យយល់ខបន្ទាប់ទាំងបីដែលពិបាកបកស្រាយ។

***១យ៉ូហាន ៣:១៩-២០***

*គឺយ៉ាងនោះឯងដែលយើងនឹងដឹងថា យើងកើតមកពីសេចក្តីពិត ហើយយើងនឹងបាន**កំឡាចិត្ត**នៅចំពោះទ្រង់ផង [20] ដ្បិតបើសិនជាចិត្តយើង**ចោទប្រកាន់**ខ្លួន នោះព្រះទ្រង់ធំជាងចិត្តយើងទៅទៀត ហើយក៏ជ្រាបគ្រប់ទាំងអស់ផង។*

ខទាំងនេះប្រហែលជាខគម្ពីរដែលពិបាកបកស្រាយជាងគេនៅក្នុងកណ្ឌគម្ពីរយ៉ូហានខ្សែទី១ ជាពិសេសពាក្យ **កំឡាចិត្ត** និង **ចោទប្រកាន់**។ មុននឹងបកស្រាយយើងត្រូវឆ្លើយសំណួរពីរសិនៈ

**សំណួរទី១៖ តើយើងត្រូវបញ្ចុះបញ្ចូលចិត្តដែលសង្ស័យរបស់យើង ឬ បញ្ចុះបញ្ចូលចិត្តដែលកំណាញ់របស់យើង?**

*«...យើងនឹង**បានកំឡាចិត្ត**នៅចំពោះទ្រង់»*។ ពាក្យភាសាក្រេក ដែលបកប្រែថា *«កំឡា»* តែងតែត្រូវបានបកប្រែថា «បញ្ចុះបញ្ចូល» នៅក្នុងគម្ពីរសញ្ញាថ្មី (៥២ ដង)។ ប៉ុន្តែហេតុអ្វីបានជាលោកយ៉ូហានមានប្រសាសន៍និយាយថា យើងត្រូវបញ្ចុះបញ្ចូលចិត្តរបស់យើង? អាចមានចម្លើយពីរយ៉ាង៖

១. យើងត្រូវបញ្ចុះបញ្ចូល**ចិត្តសង្ស័យ**របស់យើងថា យើងពិតជាកូនរបស់ព្រះអង្គ ពីព្រោះយើងមានភ័ស្តុតាងនៃសេចក្តីស្រឡាញ់ចំពោះអ្នកក្រ។

...ឬ...

២. តើយើងត្រូវបញ្ចុះបញ្ចូល**ចិត្តកំណាញ់**របស់យើង ឲ្យបើកចំហវិញ ហើយជួយអ្នកក្រដោយឥតស្តាយ។

**សំណួរទី២៖ តើចិត្តយើងចោទប្រកាន់ខ្លួនអំពីអ្វី?**

បញ្ហាមួយទៀត គឺលោកយ៉ូហាន មិនប្រាប់យើងថា ចិត្តយើង*«ចោទប្រកាន់ខ្លួន»* ដោយហេតុអ្វីនោះទេ។ មានជម្រើសពីរ៖

១. ផ្នែក**សប្បុរស**នៃចិត្តកំពុងចោទប្រកាន់ខ្លួន ព្រោះយើងធ្វេសប្រហែសចំពោះ ពួកអ្នកក្រីក្រ។ ឬ...

២. ផ្នែក**កំណាញ់**ដែលនៅសេសសល់ពីចិត្តចាស់របស់យើង កំពុងចោទប្រកាន់ខ្លួន ពីព្រោះយើងជួយពួកក្រីក្រច្រើនពេក នៅពេលដែលគ្រួសាររបស់យើងត្រូវការលុយនោះដែរ។

ពិបាកដឹងថា អត្ថន័យមួយណាត្រឹមត្រូវ។ យើងទាំងអស់គ្នាធ្លាប់មានចិត្ត បន្ទោសខ្លួន ក្នុងករណីទាំងពីរនេះដែរ។

សរុបសេចក្ដីមក អាចមានការបកស្រាយធំពីរនៃ ១យ៉ូហាន ៣:១៩-២០៖

**ការបកស្រាយទី១៖ ខ្ញុំត្រូវបញ្ចុះបញ្ចូលចិត្តសង្ស័យរបស់ខ្លួនថា ខ្ញុំពិតជាកូនព្រះ។**

ការបកស្រាយទី១ និយាយបែបនេះ «**ចិត្ត**ខ្ញុំ ងាយនឹងមានការសង្ស័យ និង**ការថ្កោលទោស**ខ្លួនឯង អំពីការដែលខ្ញុំពិតជាកូនព្រះឬអត់។ ប៉ុន្តែនៅពេលដែលការថ្កោលទោសនេះកើតឡើង ខ្ញុំអាច**បញ្ចុះបញ្ចូល** (កំឡាចិត្ត)ខ្លួនឯងថា ខ្ញុំពិតជាកូនរបស់ព្រះ ពីព្រោះខ្ញុំមានភស្តុតាងនៃសេចក្ដីស្រឡាញ់ចំពោះពួកអ្នកក្រីក្រ។ ព្រះ**ធំជាង**ចិត្តសង្ស័យរបស់ខ្ញុំ ហើយដោយសារទ្រង់**ជ្រាបអ្វីៗទាំងអស់** រួមទាំងការសប្បុរសដែលខ្ញុំបានធ្វើដោយសម្ងាត់ផង ទ្រង់នឹងស្ពាងចិត្តខ្ញុំនៅទីបញ្ចប់»។

**ការបកស្រាយទី២៖ ខ្ញុំត្រូវបញ្ចុះបញ្ចូលចិត្តកំណាញ់របស់ខ្លួន ឲ្យសប្បុរសវិញ។**

ការបកស្រាយទី២និយាយបែបនេះ «**ចិត្ត**ខ្ញុំ នៅតែមានការកំណាញ់នៅសេសសល់ពីជីវិតចាស់របស់ខ្ញុំ។ ចិត្តដ៏កំណាញ់នេះ **ចោទប្រកាន់**ខ្ញុំគ្រប់ពេល ដែលខ្ញុំចង់លះបង់ទ្រព្យសម្បត្តិសម្រាប់អ្នកក្រីក្រ។ វាចោទថា <ហេតុអ្វីបានជាអ្នកផ្ដល់ប្រាក់នេះដល់អ្នកក្រ? គ្រួសាររបស់អ្នកត្រូវការប្រាក់នេះ ដូចមនុស្សទាំងនោះដែរ។ ត្រូវគិតពីកូនៗរបស់អ្នកដែរ។ បើអ្នកជួយជនក្រីក្រ គ្រួសារអ្នកត្រូវខ្វះខាតវិញ ។ល។> តែពីព្រោះខ្ញុំដឹងថា ព្រះ**ធំជាង**ចិត្តកំណាញ់របស់ខ្ញុំ ហើយថា ព្រះជាម្ចាស់ទតឃើញ និង**ជ្រាបគ្រប់ការទាំងអស់** រួមទាំងចិត្តកំណាញ់ខ្ញុំចំពោះអ្នកក្រផង ខ្ញុំត្រូវបញ្ចុះបញ្ចូលនិងបង្ខំចិត្តកំណាញ់របស់ខ្ញុំ ឲ្យធ្វើតាមបញ្ញត្តិរបស់ទ្រង់ទាក់ទងនឹងជនក្រីក្រ»។

វាជាការពិបាកក្នុងការជ្រើសរើសរវាងការបកស្រាយទាំងពីរនេះ។

*«ហើយទ្រង់ជ្រាបគ្រប់ទាំងអស់»*។ ឃ្លានេះនាំមកនូវការភ័យខ្លាចផង និងការលើកទឹកចិត្តផង។ វានាំមកនូវការភ័យខ្លាច ពីព្រោះព្រះទតឃើញរាល់ពេលដែល

យើងមានចិត្តកំណាញ់ចំពោះមនុស្សក្រីក្រ។ ទ្រង់ឃើញថា យើងមានលទ្ធភាពដើម្បីជួយ ប៉ុន្តែយើងមិនជួយទេ។ ប៉ុន្តែខនេះក៏អាចលើកទឹកចិត្ត ឲ្យយើងមានចិត្តសប្បុរសផងដែរ។ ដោយសារព្រះជ្រាបគ្រប់ការទាំងអស់ ទ្រង់ក៏ជ្រាបសេចក្តីត្រូវការរបស់យើងច្បាស់ជាងយើង។ ទ្រង់នឹងមិនឲ្យយើងឃ្លាន ឬខ្វះខាតឡើយ។ ទ្រង់នឹងមើលថែយើង ពេលណាយើងប្រើធនធានរបស់យើង ដើម្បីជួយជនក្រីក្រ។ ទ្រង់នឹងផ្គត់ផ្គង់យើង នូវអ្វីដែលយើងត្រូវការ ហើយលើសពីនោះទៀត! ទ្រង់នឹងមិនទតរំលង ឬភ្លេចអំពើសប្បុរសរបស់គ្រីស្ទបរិស័ទនោះឡើយ (ហេព្រើរ ៦:១០)។ ពិតមែនទ្រង់ជ្រាបអ្វីៗទាំងអស់។

## *១យ៉ូហាន ៣:២១-២២*

*ពួកស្ងួនភ្ងាអើយ បើចិត្តយើងមិនចោទប្រកាន់ចំពោះខ្លួនទេ នោះយើងមានសេចក្តីក្លាហាននៅចំពោះព្រះ ²² ហើយទោះបើយើងសូមអ្វីពីទ្រង់ក៏ដោយ គង់តែនឹងបានសម្រេច ពីព្រោះយើងកាន់តាមបញ្ញត្តទ្រង់ ហើយក៏ប្រព្រឹត្តការដែលគាប់ព្រះហឫទ័យដល់ទ្រង់ដែរ។*

*«យើងសូមអ្វីពីទ្រង់ក៏ដោយ គង់តែនឹងបានសម្រេច...»* សេចក្តីសន្យានេះ មិនមែនជាការសន្យាទូទៅ ដែលទ្រង់នឹងឲ្យអ្វីៗទាំងអស់ដែលយើងសូមនោះទេ។ ព្រះបានប្រទានសេចក្តីសន្យានេះ ដើម្បីលើកទឹកចិត្តយើងឲ្យប្រើប្រាស់ធនធានរបស់យើង ដើម្បីជួយជនក្រីក្រ។ នេះជាសេចក្តីសន្យាជាក់លាក់ពីព្រះ ពេលណាយើងខ្លាចថា ការជួយពួកអ្នកក្រីក្រនឹងធ្វើឲ្យយើងខ្វះខាតវិញ។ សេចក្តីសន្យានេះនាំឲ្យយើងអធិស្ឋានបែបនេះ៖ «ឱ ព្រះអង្គអើយ យើងទើបនឹងឲ្យអង្ករសេសសល់របស់យើងទាំងអស់ ដល់ស្ត្រីមេម៉ាយនេះ យើងដឹងថា ព្រះសព្វហឫទ័យចំពោះការនេះ។ យើងដឹងថា ទ្រង់ទតឃើញការទាំងអស់ ព្រមទាំងសេចក្តីត្រូវរបស់យើង។ យើងជឿលើ

សេចក្តីសន្យារបស់ទ្រង់ដែលថា យើងសូមអ្វីពីទ្រង់ក៏ដោយគង់តែនឹងបានសម្រេច។ អរគុណព្រះអង្គដែលទ្រង់ថែរក្សាយើង ហើយមិនឲ្យយើងអត់ឃ្លាន»។

## *១យ៉ូហាន ៣:២៣-២៤*

*ឯបញ្ញត្តទ្រង់នោះគឺថា ត្រូវឲ្យយើងជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រា នៃទ្រង់ ហើយត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចជាទ្រង់បានបង្គាប់មកហើយ*
*២៤ អ្នកណាដែលកាន់តាមបញ្ញត្តទ្រង់ នោះឈ្មោះថា នៅជាប់ក្នុងទ្រង់ ហើយទ្រង់ក៏គង់នៅក្នុងអ្នកនោះដែរ យើងដឹងថា ទ្រង់គង់នៅក្នុងយើងដោយសារព្រះវិញ្ញាណ ដែលទ្រង់ប្រទានមក។*

នៅក្នុងខទាំងនេះលោកយ៉ូហាន បានភ្ជាប់ទំនាក់ទំនងម្តងទៀត រវាងការជឿលើព្រះរាជបុត្រា និងការស្រឡាញ់គ្នាទៅវិញទៅមក ដូចនៅក្នុងរូបនេះ។




*«ឯបញ្ញត្តិទ្រង់នោះគឺថា ត្រូវឲ្យយើង**ជឿ**ដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃទ្រង់ ហើយត្រូវ**ស្រឡាញ់**គ្នាទៅវិញទៅមក»។ (១យ៉ូហាន ៣:២៣)*

*«... ជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃទ្រង់ ហើយត្រូវស្រឡាញ់គ្នាទៅវិញទៅមក»* នៅក្នុងខ២៣នេះ លោកយ៉ូហាន រំឭកយើងអំពីបញ្ញត្តពីរដែលជាគន្លឹះនៃជំនឿ៖

១) ជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ។
២) ស្រឡាញ់គ្នាទៅវិញទៅមក។

ជំនឿរបស់យើងគឺជាជំនឿដ៏សាមញ្ញណាស់។ គ្មានច្បាប់ ១០,០០០ប្រការ ដែលយើងត្រូវគោរពតាមនោះទេ។ នៅពេលដែលយើងរក្សាច្បាប់ល្អរបស់ទ្រង់ ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ហើយដោយដឹងគុណដល់ព្រះជាម្ចាស់ វាជាភ័ស្តុតាងដែលបង្ហាញថា ព្រះនៅជាប់នឹងយើង ហើយយើងនៅជាប់នឹងព្រះ។

លោកយ៉ូហាន ក៏រំឭកសមាជិកក្រុមជំនុំដ៏ស្មោះត្រង់ម្តងទៀត អំពីរបៀបដែលពួកគេអាចស្គាល់គ្រូបង្រៀនពិត៖ *«អ្នកណាដែលកាន់តាមបញ្ញត្តទ្រង់ នោះឈ្មោះថា នៅជាប់ក្នុងទ្រង់ ហើយទ្រង់ក៏គង់នៅក្នុងអ្នកនោះដែរ»* ដូចនៅក្នុងរូបនេះ។




*«អ្នកណាដែល**កាន់តាមបញ្ញត្តទ្រង់** នោះឈ្មោះថា **នៅជាប់ក្នុងព្រះ**»។ (១យ៉ូហាន ៣:២៤ក)*

*«យើងដឹងថា ទ្រង់គង់នៅក្នុងយើងដោយសារព្រះវិញ្ញាណដែលទ្រង់ប្រទានមក»* មានភ័ស្តុតាងមួយទៀត ដែលយើងកើតពីព្រះ គឺអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ដែលគង់នៅក្នុងយើង។ ជាការសំខាន់ណាស់ដែល លោកយ៉ូហាន លើកយកអំណោយជាព្រះវិញ្ញាណបរិសុទ្ធនៅត្រង់នេះ ពីព្រោះនៅក្នុងខបន្ទាប់ គាត់នឹងណែនាំអំពីបញ្ហាវិញ្ញាណក្លែងក្លាយ។ ដូចដែលមានព្រះគ្រីស្ទពិត និងអង់ទីគ្រីស្ទ គឺក៏មានព្រះវិញ្ញាណពិត និងអង់ទីវិញ្ញាណ។ មិនត្រឹមតែប៉ុណ្ណឹង យើងនឹងរៀនថា មានហោរាពិត ហើយអង់ទីហោរាដែរ។ អ្វីដែលមានតម្លៃ អ្វីដែលជាការពិត សាតាំងចង់ក្លែងបន្លំទាំងអស់។

ដល់ត្រឹមនេះ លោកយ៉ូហានបានបង្រៀនយើងថា អស់អ្នកដែលកើតពីព្រះ ...

១) នឹងត្រូវបរិសុទ្ធ (១យ៉ូហាន ៣:៤-១០)

២) នឹងស្រឡាញ់អ្នកដទៃ (១យ៉ូហាន ៣:១១-២៤)

ឥឡូវនេះយើងមកដល់ភ័ស្តុតាងទីបី។ អស់អ្នកណាដែលកើតពីព្រះ...

៣) **នឹងជឿ ហើយបង្រៀនសេចក្តីពិត** (ជាពិសេសសេចក្តីពិតអំពីព្រះយេស៊ូវគ្រីស្ទ) (១យ៉ូហាន ៤:១-៦)។

# ភ័ស្តុតាងទី៣៖
# អស់អ្នកណាដែលកើតពីព្រះនឹងជឿសេចក្តីពិត
## ១យ៉ូហាន ៤:១-៦

***១យ៉ូហាន ៤:១***

*ពួកស្ងួនភ្ងាអើយ កុំឲ្យជឿគ្រប់ទាំងវិញ្ញាណឡើយ ចូរល្បងវិញ្ញាណទាំងអស់វិញ ដើម្បីឲ្យបានដឹងជាមកពីព្រះ ឬមិនមែន ដ្បិតមានហោរាក្លែងក្លាយជាច្រើនកើតក្នុងលោកីយនេះហើយ។*

លោកយ៉ូហាន ចាប់ផ្តើមវគ្គថ្មីនេះអំពីការជឿ និងបង្រៀនសេចក្តីពិតដោយពាក្យ *«ពួកស្ងួនភ្ងា»*។ ការនេះរំឭកយើងម្តងទៀតថា ការដែលជំរុញយើងឲ្យជំទាស់ទៅនឹងការបង្រៀនខុសឆ្គង និងគ្រូខុសឆ្គង គឺជាសេចក្តីស្រឡាញ់។ ជីវិតដ៏នៅអស់កល្បជានិច្ច និងភាពលូតលាស់របស់មនុស្សលោក អាចកើតមានតាមរយៈសេចក្តីពិតរបស់ព្រះប៉ុណ្ណោះ មិនមែនពីការកុហករបស់សាតាំងទេ។ *«យើងខ្ញុំក៏សរសេរសេចក្តីទាំងនេះផ្ញើមកអ្នករាល់គ្នា ដើម្បីឲ្យសេចក្តីអំណររបស់អ្នករាល់គ្នាបានពោរពេញឡើង»* (១:៤)។ យើងត្រូវតែព្រមានដល់បងប្អូនស្ងួនភ្ងារបស់យើងអំពីអ្វីដែលនឹងលួចអំណររបស់ពួកគេ។

មានបទបញ្ញត្តិអវិជ្ជមានមួយ និង វិជ្ជមានមួយនៅក្នុង ១យ៉ូហាន ៤:១ ៖

១. បញ្ញត្តិអវិជ្ជមាន៖ *«កុំឲ្យជឿគ្រប់ទាំងវិញ្ញាណ»* ពាក្យ «វិញ្ញាណ» ក្នុងខនេះរំឭកយើងថា នៅពីក្រោយគ្រូក្លែងក្លាយទាំងអស់ មានវិញ្ញាណអាក្រក់ដែលកំពុង

ដឹកនាំគេ។ លោកយ៉ូហានព្រមានយើងអំពីការឆាប់ទទួលយកការបង្រៀនថ្មី។ ជាពិសេសគ្រីស្ទបរិស័ទថ្មីឆាប់ជឿគ្រូក្លែងក្លាយ ពីព្រោះគ្រូក្លែងក្លាយប្រើពាក្យដូចគ្នានឹងយើង និងព្រះគម្ពីរដូចគ្នានឹងយើងដែរ។

២. បញ្ញត្តិវិជ្ជមាន៖ *«ចូរល្បងវិញ្ញាណទាំងអស់វិញ ដើម្បីឲ្យបានដឹងជាមកពីព្រះ...»* គោលបំណងសំខាន់របស់លោកយ៉ូហាន នៅក្នុងសំបុត្រនេះ គឺដើម្បីជួយយើងឲ្យដឹងពីរបៀប «សាកល្បងវិញ្ញាណ ដើម្បីដឹងថា តើពួកគេមកពីព្រះ ឬមិនមែន»។ អ៊ីចឹង លោកយ៉ូហាន បានផ្ដល់ឲ្យយើងនូវ ការវិនិច្ឆ័យ៦០ករណីជាង ដើម្បីជួយយើងឲ្យសាកល្បងគ្រប់ទាំងវិញ្ញាណ។ (សូមមើល ឧបសម្ពន្ធ៥ សម្រាប់ខវិនិច្ឆ័យទាំងអស់នៅយ៉ូហានខ្សែទី១)។

ហេតុអ្វីបានជាយើងត្រូវសាកល្បងគ្រប់ទាំងវិញ្ញាណ?

*«...ចូរល្បង**វិញ្ញាណ**ទាំងអស់វិញ...ដ្បិតមាន**ហោរាក្លែងក្លាយ**ជាច្រើនកើតមកក្នុងលោកីយនេះហើយ»* នៅខនេះយ៉ូហានបង្ហាញទំនាក់ទំនងយ៉ាងច្បាស់ រវាងវិញ្ញាណអាក្រក់ និងហោរាក្លែងក្លាយ។ ព្រះយេស៊ូវ និងពួកសាវកបានបង្រៀនយើងថា ប្រាកដជានឹងមានហោរាក្លែងក្លាយ និងសេចក្តីបង្រៀនខុសឆ្គងជាច្រើនប្រភេទ ដែលនឹងកើតឡើង ពីព្រោះសាតាំងដែលជាវិញ្ញាណកុហក នៅពីក្រោយសេចក្ដីបង្រៀនខុសឆ្គងទាំងអស់ គឺវារវល់ណាស់ក្នុងការក្លែងបន្លំ។ សូមចងចាំថា មនុស្សធ្វើរបស់ក្លែងក្លាយ តែរបស់ណាដែលមានតម្លៃប៉ុណ្ណោះ។ ព្រះយេស៊ូវ និងដំណឹងល្អអំពីទ្រង់ គឺជារបស់មានតម្លៃបំផុតនៅលើពិភពលោក។ ដូច្នេះយើងដឹងថា សាតាំងនឹងធ្វើព្រះគ្រីស្ទក្លែងក្លាយ (**អង់ទីគ្រីស្ទ**) ដំណឹងល្អក្លែងក្លាយ ហើយនិងហោរាក្លែងក្លាយ។

ភ្លាមៗនោះលោកយ៉ូហានផ្ដល់ឲ្យយើងនូវការវិនិច្ឆ័យពីរយ៉ាង ដើម្បីសាកល្បងគ្រូក្លែងក្លាយ និងវិញ្ញាណដែលនៅពីក្រោយ៖

១) ការសាកល្បងនៃការបង្រៀនត្រឹមត្រូវអំពីព្រះយេស៊ូវគ្រីស្ទ (៤:២-៤)

២) ការសាកល្បងនៃការចុះចូលចំពោះពួកសាវកដើម (៤:៥-៦)។

*១យ៉ូហាន ៤:២-៣*

*យើងនឹងសម្គាល់ព្រះវិញ្ញាណនៃព្រះបាន ដូច្នេះគឺអស់ទាំងវិញ្ញាណណាដែលថ្លែងប្រាប់ថា ព្រះយេស៊ូវគ្រីស្ទបានមកក្នុងសាច់ឈាម គឺវិញ្ញាណនោះហើយដែលមកពីព្រះ* ³ *តែវិញ្ញាណដែលមិនព្រមថា ព្រះយេស៊ូវគ្រីស្ទបានមកក្នុងសាច់ឈាមទេ នោះមិនមែនមកពីព្រះឡើយ គឺជាវិញ្ញាណរបស់អាទទឹងនឹងព្រះគ្រីស្ទវិញ ដែលអ្នករាល់គ្នាបានឮនិយាយថា ត្រូវមក តែឥឡូវនេះក៏នៅក្នុងលោកីយហើយ។*

## ១. ការសាកល្បងនៃការបង្រៀនត្រឹមត្រូវអំពីព្រះយេស៊ូវគ្រីស្ទ

ដូចដែលយើងបានរៀនរួចមកហើយ ទស្សនវិជ្ជាដ៏មានប្រជាប្រិយនៅក្នុង ២០០ឆ្នាំដំបូងនៃក្រុមជំនុំ បានបង្រៀនថា រូបកាយរបស់មនុស្សគឺអាក្រក់ ប៉ុន្តែវិញ្ញាណ និងចិត្តគំនិតរបស់មនុស្សគឺល្អ។ ទស្សនៈនេះមិនអាចជាការពិតទេ ពីព្រោះព្រះជាម្ចាស់ផ្ទាល់ជាអ្នកដែលបានបង្កើតរូបកាយរបស់មនុស្សមក។ ក៏ប៉ុន្តែទស្សនៈនេះមានឥទ្ធិពលលើគ្រីស្ទសាសនាខ្លាំងណាស់ រហូតដល់មានគ្រូខ្លះ បានចាប់ផ្ដើមបង្រៀនថា ព្រះរាជបុត្រានៃព្រះ មិនអាចទទួលរូបកាយពិតឡើយ។

ការបង្រៀនខុសឆ្គងនេះមានពីរទម្រង់៖

១. អ្នកខ្លះបាននិយាយថា ព្រះយេស៊ូវមិនដែលមានរូបកាយពិតឡើយ។ គេថា ទ្រង់ជាវិញ្ញាណបរិសុទ្ធពីស្ថានសួគ៌ជានិច្ច ដែលគ្រាន់តែ**ហាក់ដូចជា**មានរូបកាយនៅលើផែនដីនេះ តែទ្រង់គ្រាន់តែបន្លំមនុស្ស។

២. អ្នកផ្សេងទៀតនិយាយថា មនុស្សឈ្មោះយេស៊ូវបានកើតមកជាមនុស្សធម្មតា ដែលមានរូបកាយធម្មតា ប៉ុន្តែនៅពេលដែលទ្រង់បានទទួលពិធីជ្រមុជទឹក ព្រះវិញ្ញាណរបស់ព្រះគ្រីស្ទ បានចុះមកពីស្ថានសួគ៌ ហើយចូលមកក្នុងគាត់ បណ្តោះអាសន្ន ដែលធ្វើឲ្យមនុស្សឈ្មោះ«យេស៊ូវ»ក្លាយជា«ព្រះគ្រីស្ទ» អស់រយៈពេលប្រហែល៣ឆ្នាំ។ បន្ទាប់មក មុនពេលដែលព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាងបន្តិច ព្រះវិញ្ញាណនៃព្រះគ្រីស្ទ បានចាកចេញពីគាត់ ហើយលោកយេស៊ូវនោះបានស្លាប់ជាមនុស្សធម្មតា ព្រោះព្រះមិនអាចស្លាប់បានឡើយ។

នេះជាការបង្រៀនបែបអង់ទីគ្រីស្ទ ហើយវាជាការបង្រៀនខុសឆ្គងដែលជោគជ័យជាងគេ ក្នុងអំឡុង២០០ឆ្នាំដំបូងនៃក្រុមជំនុំ ដែលបាននាំមនុស្សរាប់ពាន់នាក់ឲ្យបែរចេញពីព្រះ។ ចូរប្រុងប្រយ័ត្ន! កុំអនុញ្ញាតឲ្យទស្សនៈប្រជាប្រិយរបស់លោកិយ ចូលមកក្នុងក្រុមជំនុំ ហើយមានឥទ្ធិពលលើគោលជំនឿយើង។

លោកយ៉ូហានបានហៅការបង្រៀននេះថា *«អាទទឹងនឹងព្រះគ្រីស្ទ» (អង់ទីគ្រីស្ទ)* ពីព្រោះវាផ្តល់នូវព្រះគ្រីស្ទផ្សេង ពីព្រះគ្រីស្ទដែលពួកសាវកបានធ្វើបន្ទាល់អស់រយៈពេលជាង៣ឆ្នាំ។ វិញ្ញាណនៃអាទទឹងនឹងព្រះគ្រីស្ទ ដឹកនាំមនុស្សឲ្យបង្រៀនជំទាស់ទៅនឹងការបើកសម្តែងរបស់ព្រះគ្រីស្ទ ដែលពួកសាវកបានបង្រៀន។

ចូរចងចាំជានិច្ចថា មានតែព្រះគ្រីស្ទដែលបាន*«មកក្នុងសាច់ឈាម»* ដែលអាចសុគតនៅលើឈើឆ្កាងដើម្បីសង្គ្រោះយើង។ នៅក្នុងគម្ពីរលោកុប្បត្តិ ៣:១៥ ព្រះបានប្រាប់អ័ដាម និងអេវ៉ាថា អ្នកដែលនឹងកិនក្បាលសាតាំង គឺជា*«ពូជ»*របស់ស្ត្រី គឺជាមនុស្សពិតប្រាកដ។ ព្រះក៏បានប្រាប់អ័ប្រាហាំ និងដាវីឌដែរថា *«ពូជ»*របស់គេនឹងធ្វើជាអ្នកសង្គ្រោះ។ ព្រះក៏បានប្រាប់អេសាយថា *«នាងព្រហ្មចារីនឹងមានគភ៌ បង្កើតបានបុត្រាមួយ»* ហើយព្រះនាមរបស់បុត្រនោះ គឺអេម៉ាញូអែលដែលប្រែថា

*«ព្រះអង្គដែលគង់នៅជាមួយនឹងយើងខ្ញុំ»* (អេសាយ ៧:១៤)។ ទំនាយទាំងអស់នេះអាចបំពេញបាន តែតាមរយៈមនុស្សពិតប្រាកដ។




*«គឺអស់ទាំងវិញ្ញាណណាដែល**ថ្លែងប្រាប់ថា ព្រះយេស៊ូវគ្រីស្ទបានមកក្នុងសាច់ឈាម** គឺវិញ្ញាណនោះហើយ ដែល**មកពីព្រះ**»។ (១យ៉ូហាន ៤:២)*

## *១យ៉ូហាន ៤:៤*

*ពួកកូនតូចៗអើយ អ្នករាល់គ្នាមកពីព្រះ ហើយក៏ឈ្នះវិញ្ញាណទាំងនោះដែរ ពីព្រោះព្រះដែលគង់ក្នុងអ្នករាល់គ្នា នោះទ្រង់ធំជាងអានោះដែលនៅក្នុងលោកីយ៍ផង។*

ចូរកត់សម្គាល់ពាក្យ*«មកពីព្រះ»* *«មិនមែនមកពីព្រះទេ»* និង*«មកពីលោកីយ៍»* នៅក្នុងខ៤-៦។ លោកយ៉ូហានប្រាប់អ្នកអានថា ពួកគេហើយ *«មកពីព្រះ»*។ ពួកគេបានកើតពីព្រះ ហើយមានព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះគង់នៅក្នុងពួកគេ។ ព្រះវិញ្ញាណបរិសុទ្ធដែលគង់នៅក្នុងពួកគេ គឺធំជាងសាតាំងដែលនៅក្នុងលោកីយ៍នេះ។ នេះគឺជាហេតុផលតែមួយគត់ ដែលយើងអាចយកឈ្នះលើគ្រូក្លែងក្លាយបាន។ កុំឲ្យទុកចិត្តលើកម្លាំង ឬប្រាជ្ញាផ្ទាល់ខ្លួន ដើម្បីយកឈ្នះលើគ្រូក្លែងក្លាយ និងព្រះគ្រីស្ទក្លែងក្លាយឡើយ។

ឥឡូវលោកយ៉ូហាន ផ្ដល់របៀបទីពីរ ដើម្បីឲ្យយើងសាកល្បងវិញ្ញាណ៖ តើគ្រូបង្រៀននោះចុះចូលដោយបន្ទាបខ្លួនចំពោះពួកសាវករបស់ព្រះគ្រីស្ទឬ? សូមស្ដាប់៖

*១យ៉ូហាន ៤:៥-៦*

*ពួកនោះមកពីលោកីយទេ ដោយហេតុនោះបានជាគេនិយាយតាមភាពលោកីយ ហើយលោកីយក៏ស្ដាប់គេដែរ [6] ឯយើងរាល់គ្នាជាអ្នកមកពីព្រះវិញ ហើយអ្នកណាដែលស្គាល់ព្រះ នោះក៏ស្ដាប់យើងខ្ញុំ តែអ្នកណាដែលមិនមកពីព្រះទេ នោះមិនព្រមស្ដាប់យើងខ្ញុំឡើយ គឺយ៉ាងនោះឯងដែលយើងនឹងស្គាល់វិញ្ញាណនៃសេចក្ដីពិត និងវិញ្ញាណនៃសេចក្ដីខុសឆ្គងទៅបាន។*

## ២. ការសាកល្បងនៃការចុះចូលចំពោះពួកសាវក

*«អ្នកណាដែលស្គាល់ព្រះនោះក៏ស្ដាប់យើងខ្ញុំ»* ពាក្យ *«យើងខ្ញុំ»* សំដៅទៅពួកសាក្សីផ្ទាល់ភ្នែក គឺពួកសាវកដើម។ តើគ្រូក្លែងក្លាយទាំងនេះ បានស្ដាប់ពួកសាវកដែរឬទេ? អត់ទេ។ ពួកគេមានចិត្តក្រអឺតក្រទម និងបះបោរ។ ពួកគេថែមទាំងអះអាងថា ចេះជាងលោកយ៉ូហាន ដែលត្រូវបានរើសតាំងដោយព្រះយេស៊ូវ ដើម្បីធ្វើជាសាវកជាផ្លូវការម្នាក់! សាវកប៉ុលក៏ជួបប្រទះសត្រូវបែបនេះដែរ ដែលហៅខ្លួនឯងថា *«មហាសាវក»* ហើយបានអះអាងថា ខ្លួនមានសិទ្ធិអំណាចច្រើនជាងសាវកដែលព្រះយេស៊ូវបានរើសតាំងទៅទៀត (២កូរិនថូស ១១:៥,១១ KSV)។ គ្រូក្លែងក្លាយច្រើនតែមានចិត្តច្រឡោងខាម និងមិនចេះអៀនខ្មាស។ ចូរកត់សម្គាល់ភាពផ្ទុយគ្នា៖

| | | | | |
|---|---|---|---|---|
| **ពួកគេ (ពួកគ្រូក្លែងក្លាយ)** | មកពី លោកីយ៍ | ពួកគេនិយាយ តាមភាពលោកីយ៍ | ពួកគេមិនស្ដាប់ យើង (ពួកសាវក) ទេ | លោកីយ៍ស្ដាប់ ពួកគេ |
| **យើង (ពួកសាវក)** | មកពីព្រះ | យើងនិយាយពីព្រះ | | អ្នកណាដែលស្គាល់ ព្រះក៏ស្ដាប់តាមយើង |

### តើអ្នកណាជាសាវកដើម

ការចុះចូលចំពោះពួកសាវកមានន័យថា ចុះចូលចំពោះពួកសាវក**ដើម** និងសេចក្ដីបង្រៀនដើមរបស់ពួកគេ។ វាមិនមានន័យថា ចុះចូលចំពោះអ្នកណាដែលហៅខ្លួនឯងថា ជាសាវកនោះឡើយ។ សព្វថ្ងៃនេះមនុស្សជាច្រើន ហៅខ្លួនឯងថា ជា

សាវក។ ពាក្យ «សាវក» បកប្រែពីពាក្យក្រេកថា អាប៉ូស្តូឡូស (apostolos) ដែលគ្រាន់តែមានន័យថា តំណាង ឬប្រតិភូ។ ប្រសិនបើមនុស្សម្នាក់អះអាងថា ជាតំណាងផ្លូវការរបស់នាយករដ្ឋមន្ត្រី ប៉ុន្តែនាយករដ្ឋមន្ត្រីមិនដែលតែងតាំងគាត់ អ្នកនោះអាចមានទោសពីបទឆបោក។

ដូចគ្នាដែរ ប្រសិនបើមនុស្សម្នាក់ប្រាប់អ្នកថា «ខ្ញុំជាតំណាង(សាវក) នៃព្រះយេស៊ូវ» នោះគឺជាការអះអាងដ៏ធ្ងន់ណាស់។ អ្នកត្រូវសួរគាត់យ៉ាងលំអិតដូចជា «តើនៅពេលណាដែលព្រះគ្រីស្ទផ្ទាល់បានយាងមកតែងតាំងអ្នក ហើយតើមានសាក្សីប៉ុន្មាននាក់បានឃើញ និងឮព្រះគ្រីស្ទធ្វើការនោះ?» សាវករបស់ព្រះគ្រីស្ទគឺជាអ្នកតំណាងផ្លូវការរបស់ព្រះគ្រីស្ទ ដែលព្រះគ្រីស្ទបានតែងតាំងដោយផ្ទាល់នៅចំពោះមុខសាក្សីជាច្រើន។

មនុស្សម្នាក់មិនអាចយកឋានៈជាសាវករបស់ព្រះគ្រីស្ទ ដោយខ្លួនឯងបានឡើយ ហើយក៏មិនអាចទទួលឋានៈនោះពីមនុស្សណាទៀតដែរ។ មានតែព្រះគ្រីស្ទទេ ដែលមានសិទ្ធិជ្រើសរើសដោយផ្ទាល់ អ្នកណាធ្វើជាអ្នកតំណាងផ្លូវការរបស់ទ្រង់។ នោះហើយជាមូលហេតុ ដែលព្រះគ្រីស្ទក្រោយពីរស់ឡើងវិញ បានបង្ហាញខ្លួនដោយផ្ទាល់ ចំពោះលោក ប៉ុល និងលោក យ៉ាកុប ដើម្បីតែងតាំងពួកគាត់ជាសាវក។

សាវកដែលស្លាប់ចុងក្រោយគេ គឺសាវកយ៉ូហាន។ នៅពេលលោកស្លាប់ គ្មានអ្នកដឹកនាំក្រុមជំនុំជំនាន់បន្ទាប់ណាម្នាក់ ហ៊ានតាំងខ្លួនឯងជាសាវករបស់ព្រះគ្រីស្ទឡើយ សូម្បីតែលោក ធីម៉ូថេ ទីតុស ឬប៉ូលីកាប (Polycarp) ជាសិស្សរបស់លោកយ៉ូហាន។ ផ្ទុយទៅវិញ អ្នកដឹកនាំក្រុមជំនុំទាំងអស់បានទទួលស្គាល់ថា សម័យរបស់ពួកសាវកបានបញ្ចប់ត្រឹមលោក យ៉ូហានហើយ។ ពួកសាវកផ្ទាល់មិនបានតែងតាំងសាវកជំនាន់ថ្មី ឲ្យជំនួសពួកគេឡើយ។ ទាំងព្រះអម្ចាស់ក៏មិនដែលបានផ្ដល់របៀបនៅក្នុងព្រះគម្ពីរ ដើម្បីឲ្យក្រុមជំនុំជ្រើសរើសសាវកផ្លូវការថ្មីឡើយ។ ព្រះ

អង្គបានប្រាប់យើងពីរបៀបជ្រើសរើសគ្រូគង្វាលថ្មី សម្រាប់ក្រុមជំនុំរបស់យើង (១ធីម៉ូថេ ៣:១-៧ ទីតុស ១:៥-៩) និងអ្នកជំនួយ (១ធីម៉ូថេ ៣:៨-១៣) តែមិនមែនសាវកទេ។ ពួកសាវក គឺជាគ្រឹះនៃក្រុមជំនុំ (អេភេសូរ ២:២០)។ ក្រុមជំនុំត្រូវការគ្រឹះតែមួយប៉ុណ្ណោះ មិនមែនគ្រឹះថ្មីមួយសម្រាប់ជំនាន់នីមួយៗនោះទេ។ (*ការអត្ថាធិប្បាយកណ្ឌគម្ពីររ៉ូម,* J.D. Crowley, 2014)

សម្គាល់៖ ពាក្យក្រេក អាប៉ូស្តូឡូស (apostolos) ត្រូវបានបន្តប្រើនៅក្រុមជំនុំដើមដែលមានអត្ថន័យធម្មតាថា ប្រតិភូ ឬអ្នកតំណាងដូចជាក្នុងករណី បេសកជន ឬប្រតិភូ ត្រូវបានបញ្ជូនចេញទៅ ក្នុងនាមក្រុមជំនុំរបស់ពួកគេដែលបានចាត់ទៅ។ (២កូរិនថូស ៨:២៣ ភីលីព ២:២៥; កិច្ចការ ១៤:១៤; រ៉ូម ១៦:៧)។

# ព្រះជាសេចក្ដីស្រឡាញ់

## ១យ៉ូហាន ៤:៧-២១

ចូរចងចាំថា លោកយ៉ូហាន និងពួកសាវកឯទៀតបានចំណាយពេល ១ ឬ ២ម៉ឺនម៉ោង ដើម្បីស្ដាប់ និងមើលព្រះយេស៊ូវដែលជាព្រះរាជបុត្រាដ៏អស់កល្បរបស់ព្រះដែលគង់នៅ*«តាំងពីដើមមក»*។ អ្វីៗដែលពួកគេបានឃើញ និងឮ ពីព្រះយេស៊ូវ លោកយ៉ូហាន សង្ខេបជាការប្រកាសដ៏ធំពីរ គឺ **ព្រះជាពន្លឺ** (១:៥) ហើយ **ព្រះជាសេចក្ដីស្រឡាញ់** (៤:៨)។ ចេញពីលក្ខណៈទាំងពីររបស់ព្រះ យើងអាចចំរាញ់ចេញជាការល្បងលធំបួន របស់គ្រូពិត និងគ្រូក្លែងក្លាយ។

បើព្រះជា**ពន្លឺ** នោះអ្នកណាដែលកើតពីព្រះ នឹង**ត្រូវបានបរិសុទ្ធ** និង**ជឿការពិត**។ បើព្រះជា**សេចក្ដីស្រឡាញ់** នោះអ្នកណាដែលកើតពីព្រះ នឹង**ស្រឡាញ់ព្រះ** និង**ស្រឡាញ់គ្នា**។




ការល្បងលទាំងបួននេះ គឺជាចំណុចចងសំណាញ់សុវត្ថិភាពរបស់លោកយ៉ូហាន ប្រឆាំងនឹងការបង្រៀនខុសឆ្គង។

និយាយជាទូទៅ ៣ជំពូកដំបូងនៃកណ្ឌគម្ពីរនេះ បានសង្កត់ធ្ងន់លើ *«ព្រះជាពន្លឺ»* ទោះបីជាមានបទបញ្ញត្តិជាច្រើន អំពីការត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដែលបានត្បាញចូលក្នុងជំពូកនោះក៏ដោយ។ ប៉ុន្តែ ចាប់ផ្តើមនៅ ១យ៉ូហាន ៤:៧ លោកយ៉ូហាន សង្កត់ធ្ងន់លើ *«ព្រះជាសេចក្តីស្រឡាញ់»*។ តែសូម្បីតែក្នុងផ្នែកនេះ អំពី *«ព្រះជាសេចក្តីស្រឡាញ់»* យើងនឹងឃើញប្រយោគជាច្រើន អំពីភាពបរិសុទ្ធ និងសេចក្តីពិតខាងគោលលទ្ធិ ដែលត្រូវត្បាញចូលក្នុងបញ្ញត្តិអំពីសេចក្តីស្រឡាញ់នេះដែរ។

លោកយ៉ូហានមិនអនុញ្ញាតសេចក្តីពិតណាមួយញែកពីសេចក្តីពិតឯទៀតទេ។ គាត់បន្តត្បាញសេចក្តីទាំងអស់នោះ ដើម្បីបង្កើតជាសំណាញ់សុវត្ថិភាពដ៏រឹងមាំមួយ ដែលចងភ្ជាប់នឹង៤ជ្រុង គឺ ចូរបរិសុទ្ធ ជឿការពិត ស្រឡាញ់ព្រះ និងស្រឡាញ់គ្នា។ នេះគឺជាសំណាញ់សុវត្ថិភាព ដែលនឹងការពារយើងពីការបោកបញ្ឆោតពីក្រុមខុសឆ្គង។

***១យ៉ូហាន ៤:៧-៨***

*ពួកស្ងួនភ្ងាអើយយើងត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដ្បិតសេចក្តីស្រឡាញ់មកពីព្រះ ឯអស់អ្នកណាដែលមានសេចក្តីស្រឡាញ់ នោះឈ្មោះថា មកពីព្រះហើយក៏ស្គាល់ទ្រង់ដែរ [៨] តែអ្នកណាដែលគ្មានសេចក្តីស្រឡាញ់ នោះមិនស្គាល់ព្រះវិញ ពីព្រោះព្រះទ្រង់ជាសេចក្តីស្រឡាញ់នោះឯង។*

ក្នុងខទាំងនេះលោកយ៉ូហានបង្គាប់ឲ្យយើងស្រឡាញ់គ្នា ហើយក្រោយមកគាត់ផ្តល់ឲ្យយើងនូវការវិនិច្ឆ័យមួយទៀត ដើម្បីរកមើលថា តើអ្នកណាជាគ្រូពិត ហើយអ្នកណាជាគ្រីស្ទបរិស័ទពិត៖ គឺជាការសាកល្បងនៃសេចក្តីស្រឡាញ់។ គាត់ផ្តល់ឲ្យយើងនូវការសាកល្បងជាវិជ្ជមានថា *«អស់អ្នកណាដែលមានសេចក្តីស្រឡាញ់ នោះកើតពីព្រះ ហើយក៏ស្គាល់ទ្រង់ផង»* និងការសាកល្បងជាអវិជ្ជមានថា *«អស់អ្នកណា*

*ដែលគ្មានសេចក្តីស្រឡាញ់ នោះមិនស្គាល់ព្រះឡើយ»*។ ទីបំផុតគាត់ឲ្យមូលដ្ឋានជាទេវសាស្រ្តសម្រាប់ការសាកល្បងនេះ៖ *«ពីព្រោះព្រះជាសេចក្តីស្រឡាញ់»*។

តាមពិត លោកយ៉ូហានបានឲ្យយើងនូវការសាកល្បងនេះរួចហើយនៅក្នុង ១យ៉ូហាន ២:៩៖ *«អ្នកណាដែលថា ខ្លួននៅក្នុងពន្លឺតែស្អប់ដល់បងប្អូននោះ ឈ្មោះថា នៅក្នុងសេចក្តីងងឹតដរាបដល់សព្វថ្ងៃនេះ»*។

ហើយគាត់ក៏បានឲ្យការសាកល្បងនេះ នៅក្នុង ១យ៉ូហាន ៣:១៤ដែរ៖ *«យើងរាល់គ្នាដឹងថា យើងបានកន្លងផុតពីសេចក្តីស្លាប់ទៅដល់ជីវិតហើយ ពីព្រោះយើងស្រឡាញ់ដល់ពួកបងប្អូន»*។

*«ព្រះជាសេចក្តីស្រឡាញ់»*។ ព្រះផ្ទាល់ជានិយមន័យនៃសេចក្តីស្រឡាញ់។ សូម្បីតែមុនពេលដែលទ្រង់បានបង្កើតមនុស្ស ឬទេវតាមួយក៏ដោយ ជាការពិតហើយថា *«ព្រះជាសេចក្តីស្រឡាញ់»* ពីព្រោះព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធបានស្រឡាញ់គ្នាទៅវិញទៅមក ដោយអំណរ និងសេចក្តីស្រឡាញ់ដ៏ល្អឥតខ្ចោះតាំងពីអស់កល្បជានិច្ច។ ព្រះមិនបានបង្កើតមនុស្ស និងទេវតា ដោយព្រោះទ្រង់ឯកោ ហើយគ្មានអ្នកណា ដែលព្រះអង្គអាចស្រឡាញ់នោះឡើយ។ អង្គនៃព្រះត្រៃឯក បានស្រឡាញ់គ្នាទៅវិញទៅមក តាំងពីអស់កល្បរៀងមក។ ព្រះជាសេចក្តីស្រឡាញ់។

ចូរកត់សំគាល់ថា លោកយ៉ូហាន មិនបានមានប្រសាសន៍ថា «សេចក្តីស្រឡាញ់ គឺជាព្រះ» នោះឡើយ។ នៅពេលមនុស្សនិយាយទៅកាន់មនុស្សអសីលធម៌ថា «អ្នកមិនចាំបាច់ប្រែចិត្តទេ ពីព្រោះព្រះជាសេចក្តីស្រឡាញ់» តាមពិតអ្វីដែលពួកគេកំពុងនិយាយ គឺ «សេចក្តីស្រឡាញ់ គឺជាព្រះ»។ ពួកគេកំពុងនិយាយថា និយមន័យរបស់ខ្លួន អំពីសេចក្តីស្រឡាញ់កំណត់ថា ព្រះជាអ្វី។ ប៉ុន្តែលោកយ៉ូហាន មានប្រសាសន៍ថា

ព្រះផ្ទាល់ ជាអ្នកសម្រេចចិត្តថា អ្វីជាសេចក្តីស្រឡាញ់ ហើយអ្វីជាសេចក្តីពិត ហើយអ្វីជាព្រះ។ តើព្រះឲ្យអត្ថន័យយ៉ាងម៉េច អំពីសេចក្តីស្រឡាញ់ សូមស្តាប់៖

*១យ៉ូហាន ៤:៩-១០*

*សេចក្តីស្រឡាញ់របស់ព្រះបានសំដែងមកឲ្យយើងខ្ញុំស្គាល់ ដោយទ្រង់ចាត់ព្រះរាជបុត្រាទ្រង់តែ១ឲ្យមកក្នុងលោកីយ ដើម្បីឲ្យយើងរាល់គ្នាបានរស់ដោយសារទ្រង់ [១០] នេះហើយជាសេចក្តីស្រឡាញ់ មិនមែនយើងបានស្រឡាញ់ព្រះនោះទេ គឺទ្រង់បានស្រឡាញ់យើងទេតើ ហើយបានចាត់ព្រះរាជបុត្រាទ្រង់ឲ្យមកទុកជាដង្វាយឲ្យធួននឹងបាបយើងរាល់គ្នាផង។*

សេចក្តីស្រឡាញ់របស់ព្រះ ជាសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅ និងបរិសុទ្ធ។ គឺជាសេចក្តីស្រឡាញ់ ដែលលះបង់ និងសង្គ្រោះ។ សេចក្តីស្រឡាញ់របស់ព្រះបានឃើញថា យើងជាទាសករ នៃអំពើបាប សាតាំង និងសេចក្តីស្លាប់ ហើយទ្រង់ មិនអនុញ្ញាតឲ្យយើង បន្តនៅជាប់ក្នុងទាសភាពនោះទេ តែរំដោះយើងវិញ។ ការនិយាយថា «ព្រះជាសេចក្តីស្រឡាញ់មិនមែនមានន័យថា ព្រះជាព្រះស្រួលដែលយល់ព្រមនឹងអ្វីដែលយើងចង់ធ្វើនោះទេ។ ផ្ទុយទៅវិញ វាមានន័យថា ព្រះស្រឡាញ់ដល់អ្នកមានបាបដល់ម្ល៉េះ ដោយទ្រង់បានចាត់ព្រះរាជបុត្រាទ្រង់ឲ្យធ្វើជាយញ្ញបូជាដែលបង្វែរសេចក្តីក្រោធរបស់ព្រះចេញពីយើង ហើយដាក់លើព្រះគ្រីស្ទវិញ។ វាជាសេចក្តីស្រឡាញ់ដែលមិនគ្រាន់តែបង្ហាញ សេចក្តីមេត្តាករុណាដល់អ្នកមានបាប តែក៏បង្ហាញកិត្តិយសដល់ព្រះដោយបំពេញគ្រប់ទាំងសេចក្តីទាមទារនៃក្រឹត្យវិន័យរបស់ទ្រង់ តាមរយៈជីវិត និងសេចក្តីសុគតរបស់ព្រះយេស៊ូវ។

**ឧទាហរណ៍៖** ពេលខ្លះឪពុកម្តាយនឹងមើលរំលងអំពើបាបនៅក្នុងកូនរបស់ពួកគេ ហើយនិយាយថា «ខ្ញុំមើលរំលងការអាក្រក់ទាំងនេះ ពីព្រោះខ្ញុំស្រលាញ់កូនពេក តែតាមពិតការខកខានមិនបានកែអំពើបាបនៅក្នុងកូន

អ្នក គឺស្អប់កូនទៅវិញទេ (សុភាសិត ១៣:២៤) ព្រោះបាបនោះនឹងលួចអំណរពីកូន ហើយបំផ្លាញកូន ហើយនិងបញ្ជូនគេទៅស្ថាននរកទៀតផង។ ឪពុកម្តាយដែលស្រឡាញ់កូនខ្លួន នឹងមិនធ្វើពើចំពោះបាបរបស់កូនគាត់ទេ ប៉ុន្តែគាត់នឹងកែតម្រង់ ផ្តល់គំរូល្អដល់គេ ហើយអធិស្ឋានរាល់ថ្ងៃ សូមឲ្យព្រះសង្គ្រោះគេពីបាប។ ដូចគ្នានេះដែរ បើព្រះស្រឡាញ់យើង ទ្រង់ចង់ជួយយើងឲ្យរួចផុតពីអំពើបាប មិនមែនឲ្យយើងនៅតែបន្តនោះទេ។ ព្រះជាសេចក្តីស្រឡាញ់។

*«...ទ្រង់បានស្រឡាញ់យើងទេតើ ហើយបានចាត់ព្រះរាជបុត្រាទ្រង់ឲ្យមកទុកជាដង្វាយឲ្យធួននឹងបាបយើងរាល់គ្នាផង»*។ រីឯពាក្យ *«ធួននឹងអំពើបាប»* សូមមើលការអធិប្បាយនៅ ១យ៉ូហាន ២:២។ គ្រូខុសឆ្គងជាច្រើនបដិសេធសេចក្តីពិតនេះ ដែលថា ព្រះរាជបុត្រារបស់ព្រះ បានសងលោះថ្លៃបាបទាំងអស់ជំនួសយើង។ ក្រុមខុសឆ្គងភាគច្រើនបង្រៀនថា ការសុគតរបស់ព្រះគ្រីស្ទមិនគ្រប់គ្រាន់ទេ ហើយយើងក៏ត្រូវជឿទុកចិត្តលើអំពើល្អរបស់ខ្លួន ដើម្បីបានសង្គ្រោះផងដែរ។ គ្រីស្ទសាសនាសេរីនិយម (Liberal) បង្រៀនថា ព្រះយេស៊ូវមិនមែនជាដង្វាយធួននឹងអំពើបាបរបស់យើងទេ តែទ្រង់បានសុគតគ្រាន់តែជាគំរូនៃសេចក្តីស្រឡាញ់តែប៉ុណ្ណោះ ដើម្បីបង្ហាញពីសេចក្តីស្រឡាញ់របស់ព្រះចំពោះយើង។ (សូមមើល«គ្រីស្ទសាសនាសេរីនិយម»នៅផ្នែកទី២)។

## *១យ៉ូហាន ៤:១១*

*ពួកស្ងួនភ្ងាអើយបើព្រះបានស្រឡាញ់យើងរាល់គ្នាជាខ្លាំងទាំងម្ល៉េះ នោះត្រូវឲ្យយើងស្រឡាញ់គ្នាទៅវិញទៅមកដែរ។*

*«បើព្រះបានស្រឡាញ់យើងរាល់គ្នា**ជាខ្លាំងទាំងម្ល៉េះ**...»* សូមសម្គាល់ពាក្យ «ទាំងម្ល៉េះ»។ ក្នុងភាសាក្រេក ពាក្យនោះសំដៅទៅលក្ខណៈនៃសេចក្តីស្រឡាញ់របស់

ព្រះ។ និយាយម៉្យាងទៀតថា បើព្រះស្រឡាញ់យើង**បែបនោះ** ដោយចាត់ព្រះរាជបុត្រាទ្រង់មកដោះស្រាយបញ្ហាបាបរបស់យើង នោះយើងក៏គួរស្រឡាញ់គ្នាទៅវិញទៅមក តាមបែបលះបង់ប្រយោជន៍ផ្ទាល់ខ្លួននោះដែរ។ ព្រះមិនគ្រាន់តែស្រឡាញ់យើងតាមរបៀបទូទៅទេ។ ទ្រង់ស្រឡាញ់យើងតាមរបៀបមួយជាក់លាក់ដែលបានដោះស្រាយទាសភាពនៃអំពើបាបរបស់យើង។ ទ្រង់ស្រឡាញ់យើងតាមរបៀបដែលនាំឲ្យយើងមានភាពបរិសុទ្ធ និងអំណរ។ ដូច្នេះយើងគួរតែស្រឡាញ់គ្នាទៅវិញទៅមកបែបនោះដែរ តាមរបៀបលើកទឹកចិត្តពួកគេ ឲ្យបែរចេញពីអំពើបាប ហើយបែរទៅរកព្រះវិញ។

***១យ៉ូហាន ៤:១២***

*គ្មានអ្នកណាដែលឃើញព្រះឡើយ តែបើយើងស្រឡាញ់គ្នាទៅវិញទៅមក នោះព្រះទ្រង់គង់នៅក្នុងយើង ហើយសេចក្ដីស្រឡាញ់របស់ទ្រង់បានពេញខ្នាតក្នុងយើងដែរ។*

នេះគឺជាការវិនិច្ឆ័យមួយទៀត។ ដោយសារយើងមិនអាចមើលឃើញព្រះ ធ្វើដូចម្ដេចឲ្យយើងដឹងថា ទ្រង់គង់នៅក្នុងយើង? *«... បើយើងស្រឡាញ់គ្នាទៅវិញទៅមក នោះព្រះទ្រង់គង់នៅក្នុងយើង»* យើងអាចប្រើការសាកល្បងនេះចំពោះគ្រូក្លែងក្លាយដែរ។ គ្រូក្លែងក្លាយតែងតែអះអាងថា ខ្លួនមានទំនាក់ទំនងពិសេសជាមួយព្រះ។ ប៉ុន្តែ ពួកគេមិនបានស្រឡាញ់អ្នកដទៃ ដោយសេចក្ដីស្រឡាញ់បរិសុទ្ធទេ។




*«បើយើង**ស្រឡាញ់គ្នា**ទៅវិញទៅមក*
*នោះព្រះទ្រង់គង់នៅក្នុងយើង»។ (១យ៉ូហាន ៤:១២)*

## *១យ៉ូហាន ៤:១៣*

*គឺយ៉ាងនោះឯងដែលយើងដឹងថា យើងនៅជាប់ក្នុងទ្រង់ ហើយទ្រង់ក៏គង់នៅក្នុងយើង ពីព្រោះទ្រង់បានប្រទានព្រះវិញ្ញាណទ្រង់មកយើងរាល់គ្នា។*

តើយើងដឹងយ៉ាងដូចម្ដេចថា យើងជាកូនព្រះ ហើយព្រះគង់នៅក្នុងយើង? ពីព្រោះព្រះបានប្រទានព្រះវិញ្ញាណបរិសុទ្ធមកយើង។ អំណោយនេះគឺជា ការចាក់ប្រេងលាប ដែលលោកយ៉ូហានបានប្រាប់យើង នៅ១យ៉ូហាន ២:២០។ សូមសម្គាល់ទៀតថា ព្រះវិញ្ញាណបរិសុទ្ធជាគន្លឹះនៃការរស់នៅប្រកបដោយភាពបរិសុទ្ធ សេចក្ដីពិត ការស្រឡាញ់ព្រះ និងការស្រឡាញ់អ្នកដទៃ៖

១. **ត្រូវបរិសុទ្ធ**! ព្រះវិញ្ញាណត្រូវបានគេហៅថា ព្រះវិញ្ញាណ**បរិសុទ្ធ** (យ៉ូហាន ១:៣៣)

២. **ជឿការពិត**! ព្រះវិញ្ញាណបរិសុទ្ធបានផ្ដល់ឲ្យយើងនូវព្រះបន្ទូល**ដ៏ពិត** (២ពេត្រុស ១:២១)

៣. **ស្រឡាញ់ព្រះ**! ព្រះវិញ្ញាណបរិសុទ្ធដឹកនាំយើងឲ្យ**ស្រឡាញ់ព្រះ** ដោយហៅទ្រង់ថា អ័ប្បា (រ៉ូម ៨:១៥)។

៤. **ស្រឡាញ់គ្នា**! ផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធ គឺដំបូង **សេចក្ដីស្រឡាញ់** (កាឡាទី ៥:២២; កូល៉ុស ១:៨)។

តើអ្នកបានកត់សម្គាល់ទេថា ឥឡូវនេះលោកយ៉ូហាន បានផ្ដល់ឲ្យយើងនូវរបៀបច្បាស់លាស់ពីរយ៉ាង ដើម្បីដឹងថា ព្រះស្រឡាញ់យើង?

១. យើងដឹងថាព្រះស្រឡាញ់យើង ពីព្រោះទ្រង់បានប្រទានអំណោយទាននៃព្រះយេស៊ូវដែលបានសុគតជំនួសបាបយើង (១យ៉ូហាន ៤:៩-១០)

២. យើងដឹងថាព្រះស្រឡាញ់យើង ពីព្រោះទ្រង់បានប្រទានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដល់យើង (១យ៉ូហាន ៤:១៣; រ៉ូម ៥:៥)

នៅពេលយើងស្រឡាញ់អ្នកណាម្នាក់យ៉ាងខ្លាំង យើងចូលចិត្តឲ្យអំណោយដល់គេ។ តើព្រះអាចប្រទានអំណោយដ៏ថ្លៃថ្លាអ្វីជាងព្រះរាជបុត្រានៃទ្រង់ និងព្រះវិញ្ញាណទ្រង់! ព្រះស្រឡាញ់យើងដល់ម្ល៉េះ!

### *១យ៉ូហាន ៤:១៤*

*ហើយយើងបានឃើញក៏ធ្វើបន្ទាល់ថា ព្រះវរបិតាបានចាត់ព្រះរាជបុត្រាមកធ្វើជាព្រះអង្គសង្គ្រោះនៃមនុស្សលោក។*

សូមកត់សម្គាល់ពីភាសាតុលាការក៏ឧឡារិក ដែលលោកយ៉ូហានប្រើម្ដងទៀត៖ *«យើងបាន**ឃើញ**ក៏**ធ្វើបន្ទាល់**...»* គាត់បាននិយាយស្រដៀងគ្នានៅ ១យ៉ូហាន ១:៣ ថា៖ *«ដូច្នេះសេចក្ដីដែលយើងខ្ញុំបាន**ឃើញ** ហើយ**ឮ** នោះយើងខ្ញុំ**ប្រាប់**មកអ្នករាល់គ្នា»*។ នេះជារបៀបនិយាយ ដែលសាក្សីផ្ទាល់ភ្នែកតែងតែប្រើ។

ចូរកត់សម្គាល់ទៀតថា លោកយ៉ូហានលើកឡើងពីអង្គទាំងបីនៃព្រះត្រៃឯក នៅក្នុង ៤:១៣-១៤ (និងកន្លែងជាច្រើនទៀតនៅក្នុងកណ្ឌគម្ពីរយ៉ូហានខ្សែទី១)។ គ្រូពិតតែងតែបង្រៀន និងជឿត្រឹមត្រូវអំពីព្រះត្រៃឯក។ គ្រូខុសឆ្គងស្ទើរតែទាំងអស់បង្រៀនខុស ឬបំភាន់អត្ថន័យអំពីព្រះត្រៃឯក។ ក្រុមខុសឆ្គងមរមន អះអាងថា ជឿ

លើព្រះត្រៃឯក តែតាមពិតពួកគេជឿលើ ព្រះបីដោយឡែកពីគ្នា ហើយព្រះរាប់ពាន់អង្គទៀត! ( សូមមើល «សាសនាមរមន» នៅផ្នែកទី២ )

### *១យ៉ូហាន ៤:១៥*

*អ្នកណាដែលយល់ព្រមថា ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ អ្នកនោះឈ្មោះថាមានព្រះគង់នៅក្នុងខ្លួនពិត ហើយខ្លួនក៏នៅក្នុងព្រះដែរ។*




*«អ្នកណាដែល**យល់ព្រមថា ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ** អ្នកនោះឈ្មោះថា មាន**ព្រះគង់នៅក្នុងខ្លួន**»។ ( ១យ៉ូហាន ៤:១៥ )*

ជាថ្មីម្តងទៀតលោកយ៉ូហាន រំឭកយើងថា គ្រូពិតបង្រៀនយ៉ាងត្រឹមត្រូវអំពីព្រះយេស៊ូវគ្រីស្ទ។ ពួកគេចុះចូលចំពោះទីបន្ទាល់ផ្ទាល់ភ្នែកនៃពួកសាវកដែលបង្រៀនថា ព្រះយេស៊ូវគឺជាព្រះមែស៊ី និងជាព្រះរាជបុត្រាតែមួយរបស់ព្រះ។ គ្រូក្លែងក្លាយ និងពួកអង់ទីគ្រីស្ទជាច្រើននាក់អះអាងថា ពួកគេជាព្រះបុត្រារបស់ព្រះដែរ។ ជាធម្មតាពួកគេនិយាយថា ព្រះយេស៊ូវជាព្រះគ្រីស្ទសម្រាប់តែសម័យកាលមុន ប៉ុន្តែមានព្រះគ្រីស្ទថ្មីសម្រាប់សម័យកាលនេះ។ នេះគឺជាការកុហក។ ម្តងហើយម្តងទៀត ព្រះគម្ពីរហៅព្រះយេស៊ូវ ថាជាព្រះរាជបុត្រាតែមួយរបស់ព្រះ ( យ៉ូហាន ១:១៤; ១:១៨; ៣:១៦; ៣:១៨; ១យ៉ូហាន ៤:៩ )។ ព្រះយេស៊ូវមិនគ្រាន់តែជាព្រះគ្រីស្ទសម្រាប់សម័យកាលតែមួយទេ ប៉ុន្តែជាព្រះអាទិករនៃសាកលលោកទាំងមូល ហើយជាម្ចាស់នៃសម័យកាលទាំងអស់។

**ឧទាហរណ៍** អាប៉ូឡូ គីបូឡូយ (Apollo Quiboloy) នៃប្រទេសហ្វីលីពីនអះអាងថា ជា «ព្រះបុត្រាតែងតាំងនៃព្រះ» និងជា «ម្ចាស់នៃ

ចក្រវាល»។ នេះមិនមែនជាការពិតទេ។ គាត់មានអាយុ៧០ឆ្នាំហើយ (កើតក្នុងឆ្នាំ១៩៥០) ហើយមិនយូរមិនឆាប់គាត់នឹងត្រូវស្លាប់ដែ។ នៅពេលដែលគាត់ស្លាប់ គាត់នឹងមិនរស់ឡើងវិញ ដូចព្រះរាជបុត្រាពិតនៃព្រះ គឺព្រះយេស៊ូវគ្រីស្ទទេ។ (សូមមើល «អាប៉ូឡូ គីបូឡូយ» នៅផ្នែកទី២)

នៅទូទាំងប្រវត្តិសាស្រ្តគ្រូក្លែងក្លាយរាប់រយនាក់បានអះអាងថា ជាព្រះយេស៊ូវ ឬព្រះរាជបុត្រានៃព្រះ។ នៅក្រោមជា៤អ្នកដែលបានអះអាងថាជាព្រះយេស៊ូវ ។ សូមកត់សម្គាល់ថា ពួកគេទាំងអស់បានស្លាប់ហើយ ហើយពួកគេទាំងអស់ មិនបានរស់ពីស្លាប់ឡើងវិញឡើយ ៖

- បាហាអ៊ូឡាស នៅស្រុកពើស៊ី (ឥឡូវអ៊ីរ៉ង់) (១៨១៧-១៨៩២ ស្លាប់ដោយគ្រុនក្តៅ)
- សាន់ ម៉ុង មូន ពីប្រទេសកូរ៉េ (ឆ្នាំ១៩២០-២០១២ ស្លាប់ដោយរលាកសួត)
- អារីហ្វីនមហាម៉េត ពីប្រទេសម៉ាឡេស៊ី (១៩៤៣-២០១៦)
- មីតស៊ូអូ ម៉ាតាយូស៊ី ពីប្រទេសជប៉ុន (១៩៤៤-២០១៨ ស្លាប់ដោយជំងឺ)

## *១យ៉ូហាន ៤:១៦ក*

*យើងរាល់គ្នាបានស្គាល់ ហើយក៏ជឿចំពោះសេចក្តីស្រឡាញ់ដែលព្រះទ្រង់មានដល់យើង។*

តើយើងដឹងថា ព្រះស្រឡាញ់យើងដោយរបៀបណា? តើដោយព្រោះយើងមានអារម្មណ៍កក់ក្តៅក្នុងចិត្តឬ? តើដោយសារតែរឿងល្អៗកំពុងកើតឡើងចំពោះយើងឬ? តើមកពីយើងដឹងច្បាស់ពីថ្ងៃខែនិងឆ្នាំដែលយើងបានកើតជាថ្មីឬ? ទេ។ អារម្មណ៍រីករាយ វាជួនមានជួនអត់។ សុខភាព និងទ្រព្យសម្បត្តិវាឡើងចុះៗ។ តើធ្វើដូចម្តេចឲ្យយើងអាចដឹងប្រាកដថា ព្រះស្រឡាញ់យើង? ចម្លើយគឺនៅ ៤:៩ និង

៤:១៤ ៖ យើងដឹងថា ព្រះស្រឡាញ់យើងពីព្រោះព្រះប្រទានព្រះរាជបុត្រាទ្រង់តែមួយឲ្យមកសុគតជំនួសយើង។ មានតែពេលដែលយើងជឿលើព្រះរាជបុត្រាពិតពីព្រះ គឺព្រះយេស៊ូវគ្រីស្ទ ដែលយើងអាចទទួលបាននូវបទពិសោធន៍នៃសេចក្តីស្រឡាញ់ដែលព្រះមានចំពោះយើង ហើយនៅជាប់ក្នុងសេចក្តីស្រឡាញ់នោះ។ ព្រះគ្រីស្ទក្លែងក្លាយ គឺគ្រាន់តែជាមនុស្សធម្មតាប៉ុណ្ណោះ។ ពួកគេគ្មានអំណាចផ្សះផ្សាយើងជាមួយព្រះទេ។ ពួកគេគ្មានអំណាចដើម្បី *«ចាក់សេចក្តីស្រឡាញ់របស់ព្រះមកក្នុងចិត្តយើង តាមរយៈព្រះវិញ្ញាណបរិសុទ្ធ»* ទេ (រ៉ូម ៥:៥)។ ហើយពួកគេមិនអាចផ្តល់ឲ្យយើងនូវការធានានៃសេចក្តីសង្គ្រោះបានឡើយ។ តាមពិតគ្រូក្លែងក្លាយចូលចិត្តដកការធានាសេចក្តីសង្គ្រោះចេញពីយើង ដើម្បីឲ្យពួកគេអាចញាក់យើងបានយ៉ាងងាយស្រួល ដោយសារការភ័យខ្លាច។

### *១យ៉ូហាន ៤:១៦ខ*

*ព្រះជាតួសេចក្តីស្រឡាញ់ ឯអ្នកណាដែលនៅជាប់ក្នុងសេចក្តីស្រឡាញ់នោះក៏បាននៅជាប់ក្នុងព្រះ ហើយព្រះទ្រង់គង់នៅក្នុងអ្នកនោះដែរ។*




*«អ្នកណាដែលនៅ**ជាប់ក្នុងសេចក្តីស្រឡាញ់** នោះក៏បាននៅជាប់ក្នុងព្រះហើយ**ព្រះទ្រង់គង់នៅក្នុងអ្នកនោះ**»។ (១យ៉ូហាន ៤:១៦ខ)*

*«ព្រះជាតួសេចក្តីស្រឡាញ់»* លោកយ៉ូហានមានប្រសាសន៍ម្តងទៀតថា ដោយសារព្រះជាសេចក្តីស្រឡាញ់ អស់អ្នកណាដែលពិតជាកើតពីព្រះ នឹងនៅជាប់ក្នុងសេចក្តីស្រឡាញ់របស់ព្រះ ហើយមានពេញដោយសេចក្តីស្រឡាញ់របស់ព្រះដែរ។ ព្រះគ្រីស្ទក្លែងក្លាយ ស្រឡាញ់តែខ្លួនឯងទេ។ ពួកគេចង់បានអំណាច កិត្តិនាម និង

ការគោរពបូជា។ ពួកគេភាគច្រើនរស់នៅដូចស្ដេច ហើយបើកបររថយន្តថ្លៃៗ និងមានអ្នកបម្រើ និងអង្គរក្សជាច្រើននាក់។ ពួកគេមិនដូចព្រះយេស៊ូវទេ ដែលបានរស់នៅដោយរបៀបសាមញ្ញ។

**ចូរប្រុងប្រយ័ត្ន**! យើងត្រូវតែបដិសេធគ្រូគ្រីស្ទបរិស័ទទាំងឡាយណាដែលបានក្លាយជាសេដ្ឋី ពីការថ្វាយដង្វាយរបស់ពួកគ្រីស្ទបរិស័ទធម្មតា។ អ្នកផ្សាយតាមទូរទស្សន៍ និងអ៊ិនធឺណិត ល្បីៗ មកពីអាមេរិក កូរ៉េ សិង្ហបុរី និងហ្វីលីពីន ប្រេស៊ីល និង អាហ្វ្រិក ស្ទើរតែទាំងអស់បានក្លាយជាសេដ្ឋី ពីការថ្វាយដង្វាយពីអ្នកស្ដាប់។ ពួកគេរស់នៅក្នុងផ្ទះដែលតម្លៃរាប់លានដុល្លារ បើកបររថយន្តដែលមានតម្លៃរាប់សែនដុល្លារ និងមានយន្តហោះផ្ទាល់ខ្លួនដែលមានតម្លៃរាប់សិបលានដុល្លារទៀតផង។ មុនពេលពួកគេចាប់ផ្ដើមផ្សព្វផ្សាយតាមទូរទស្សន៍ ពួកគេមិនមែនជាអ្នកមានទាល់តែសោះ។ តើពួកគេទទួលបានប្រាក់ទាំងអស់នេះមកពីណា? ភាគច្រើនមកពីដង្វាយ! ព្រះគម្ពីរប្រាប់ថា ពួកគេដូចជាហោរាបាឡាមដែលប្រើសាសនាដើម្បីក្លាយជាអ្នកមាន(២ពេត្រុស២:១៥)។ ព្រះយេស៊ូវជាគំរូនៃការដឹកនាំដ៏រាបទាបរបស់យើង៖

*ប៉ុន្តែព្រះយេស៊ូវបានហៅពួកគេមកមានបន្ទូលថា៖ «អ្នករាល់គ្នាដឹងថាពួកចៅហ្វាយនៃសាសន៍ដទៃ តែងគ្រប់គ្រងលើសាសន៍របស់ខ្លួន ហើយពួកអ្នកធំក៏មានអំណាចលើគេដែរ* ២៦ *ប៉ុន្តែមិនត្រូវឲ្យមានដូច្នោះក្នុងពួកអ្នករាល់គ្នាឡើយ គឺអ្នកណាក្នុងពួកអ្នករាល់គ្នាដែលចង់ធ្វើជាធំ នោះនឹងត្រូវធ្វើជាអ្នកបំរើដល់អ្នករាល់គ្នាវិញ។* ២៧ *ហើយអ្នកណាក្នុងពួកអ្នកដែលចង់បានជាលេខ១ នោះត្រូវធ្វើជាបាវដល់អ្នករាល់គ្នាវិញដែរ* ២៨ *ដូចជាកូនមនុស្សបានមកមិនមែនឲ្យគេបំរើលោកទេ គឺនឹងបំរើគេវិញ ហើយនឹងឲ្យជីវិតខ្លួនទុកជាថ្លៃលោះមនុស្សជាច្រើនផង»* (ម៉ាថាយ ២០:២៥-២៨)។ ព្រះយេស៊ូវយាងមកដើម្បីលះបង់ជីវិត មិនមែនប្រមូលលុយទេ (សូមមើលពី «គ្រួចម្រុងចម្រើន» នៅផ្នែកទី២)។

### *១យ៉ូហាន ៤:១៧-១៨*

*គឺយ៉ាងនោះហើយដែលសេចក្តីស្រឡាញ់បានពេញខ្នាតក្នុងយើង ដើម្បីឲ្យយើងមានសេចក្តីក្លាហាននៅថ្ងៃជំនុំជំរះ ដ្បិតដែលព្រះទ្រង់ជាយ៉ាងណា នោះយើងរាល់គ្នាក៏យ៉ាងនោះនៅក្នុងលោកីយនេះដែរ។ [១៨] គ្មានសេចក្តីភ័យខ្លាចណានៅក្នុងសេចក្តីស្រឡាញ់ឡើយ សេចក្តីស្រឡាញ់ដែលពេញខ្នាតនោះបណ្តេញសេចក្តីភ័យខ្លាចចេញ ពីព្រោះសេចក្តីភ័យខ្លាចតែងជាប់មានសេចក្តីវេទនាហើយអ្នកណាដែលមានសេចក្តីភ័យខ្លាច នោះមិនទាន់បានពេញខ្នាតខាងឯសេចក្តីស្រឡាញ់នៅឡើយទេ។*

*«...ដ្បិតដែលព្រះទ្រង់ជាយ៉ាងណា នោះយើងរាល់គ្នាក៏យ៉ាងនោះនៅក្នុងលោកីយនេះដែរ»*។ លោកយ៉ូហានបង្រៀនកូនៗរបស់ព្រះ នឹងបង្ហាញសេចក្តីស្រឡាញ់ ពីព្រោះព្រះបង្ហាញសេចក្តីស្រឡាញ់ដែរ។

*«សេចក្តីស្រឡាញ់ដែលពេញខ្នាត នោះបណ្តេញសេចក្តីភ័យខ្លាចចេញ...»* នៅពេលយើងស្រឡាញ់អ្នកដែលនៅជុំវិញយើង រួមទាំងខ្មាំងសត្រូវរបស់យើងផង នោះសេចក្តីស្រឡាញ់របស់យើងកាន់តែខ្លាំងឡើងៗ និងកាន់តែមានភាពពេញខ្នាតដូចសេចក្តីស្រឡាញ់ពេញខ្នាត ដែលយើងនឹងទទួល នៅពេលយើងឃើញព្រះយេស៊ូវផ្ទាល់។ នៅពេលសេចក្តីស្រឡាញ់របស់យើងកាន់តែពេញខ្នាតឡើង យើងកាន់តែជឿជាក់ថា យើងពិតជាកូនព្រះ។ *«យើងរាល់គ្នាដឹងថា យើងបានកន្លងផុតពីសេចក្តីស្លាប់ទៅដល់ជីវិតហើយ ពីព្រោះយើងស្រឡាញ់ដល់ពួកបងប្អូន»* (១យ៉ូហាន ៣:១៤)។

### *១យ៉ូហាន ៤:១៩*

*ឯយើងរាល់គ្នា យើងស្រឡាញ់ទ្រង់ ពីព្រោះទ្រង់បានស្រឡាញ់យើងជាមុន។*

នេះគឺជាគោលការណ៍សំខាន់បំផុតមួយនៅក្នុងកណ្ឌគម្ពីរយ៉ូហានខ្សែទី១។ គ្រប់ទាំងលក្ខណសម្បត្តិ និងបំណងប្រាថ្នាល្អរបស់គ្រីស្ទបរិស័ទមកពីព្រះជាម្ចាស់។ យើងមានលក្ខណៈសម្បត្តិនោះ តែដោយសារព្រះវរបិតារបស់យើងមានលក្ខណៈសម្បត្តិនោះជាមុន។ បើយើងកើតពីព្រះ យើងនឹងបង្ហាញលក្ខណៈរបស់ព្រះនៅក្នុងជីវិតយើងដែរ។

- មូលហេតុតែមួយគត់ ដែលយើងស្រឡាញ់ គឺដោយសារតែទ្រង់ស្រឡាញ់យើង**ជាមុន**។
- មូលហេតុតែមួយគត់ ដែលយើងនិយាយសេចក្តីពិតគឺ ដោយសារតែទ្រង់មានបន្ទូលសេចក្តីពិត**ជាមុន**។
- មូលហេតុតែមួយគត់ ដែលយើងបរិសុទ្ធ គឺដោយសារតែទ្រង់បរិសុទ្ធ**ជាមុន**។
- មូលហេតុតែមួយគត់ ដែលយើងអត់ធ្មត់ គឺដោយសារតែទ្រង់អត់ធ្មត់**ជាមុន**។
- មូលហេតុតែមួយគត់ ដែលយើងស្រឡាញ់សត្រូវរបស់យើង គឺដោយសារតែទ្រង់ស្រឡាញ់សត្រូវទ្រង់**ជាមុន។** *«ចូរស្រឡាញ់ដល់ខ្មាំងសត្រូវរបស់អ្នករាល់គ្នា ឲ្យប្រព្រឹត្តល្អនឹងគេ ហើយឲ្យគេខ្ចីដោយឥតសង្ឃឹមថា នឹងបានអ្វីមកវិញសោះ នោះអ្នករាល់គ្នានឹងបានរង្វាន់ជាយ៉ាងធំ ហើយនឹងធ្វើជាកូននៃព្រះដ៏ខ្ពស់បំផុត ដ្បិតទ្រង់តែងល្អដល់ទាំងមនុស្សអកត្តញ្ញូ និងមនុស្សអាក្រក់ដែរ។ [៣៦] ដូច្នេះចូរអ្នករាល់គ្នាមានចិត្តមេត្តាករុណាដូចជាព្រះវរបិតានៃអ្នកទ្រង់មានព្រះហឫទ័យមេត្តាករុណាដែរ»* (លូកា ៦:៣៥-៣៦)។

លោកយ៉ូហាន ប្រើការវែកញែកដូចគ្នានឹងព្រះយេស៊ូដែរ ដែលថា កូនគួរមានលក្ខណៈដូចឪពុករបស់គេ។ *«មានពរហើយ អស់អ្នកដែលផ្សះផ្សាគេ ដ្បិតអ្នកទាំងនោះនឹងបានហៅជាកូនរបស់ព្រះ»* (ម៉ាថាយ ៥:៩)។

## *១យ៉ូហាន ៤:២០-២១*

*បើអ្នកណាថា ខ្លួនស្រឡាញ់ព្រះតែស្អប់ដល់បងប្អូនវិញ អ្នកនោះជាអ្នកកុហក ដ្បិតអ្នកណាដែលមិនស្រឡាញ់បងប្អូនដែលបានមើលឃើញទៅហើយ នោះធ្វើដូចម្តេចឡើយ ឲ្យស្រឡាញ់ដល់ព្រះដែលមើលមិនឃើញទៅបាន ២១ មួយទៀតយើងបានទទួលបញ្ញត្តនេះពីព្រះមកថា អ្នកណាដែលស្រឡាញ់ដល់ព្រះ នោះត្រូវតែស្រឡាញ់ដល់បងប្អូនដែរ។*




*«បើអ្នកណាថា ខ្លួនស្រឡាញ់ព្រះ តែស្អប់ដល់បងប្អូនវិញ អ្នកនោះជាអ្នកកុហក... អ្នកណាដែល**ស្រឡាញ់ដល់ព្រះ** នោះត្រូវតែ**ស្រឡាញ់ដល់បងប្អូនដែរ**»។ (១យ៉ូហាន ៤:២០-២១)*

*«បើអ្នកណាថា ...»* ពាក្យទាំងនេះនៅក្នុងខ២០ស្តាប់ទៅស្រដៀងនឹងប្រយោគវិនិច្ឆ័យ៥យ៉ាង នៅដើមកណ្ឌគម្ពីរយ៉ូហានខ្សែទី១ ដែលបានចាប់ផ្តើមដោយពាក្យ *«បើយើងនិយាយថា...»* និង *«បើអ្នកណាថា...»*។ នៅ៤:២០នេះ ការវិនិច្ឆ័យគឺសេចក្តីស្រឡាញ់ម្តងទៀត។ បើអ្នកណាថា ខ្លួនស្រឡាញ់ព្រះតែស្អប់ដល់បងប្អូនវិញ អ្នកនោះនិយាយកុហកហើយ។ តើធ្វើដូចម្តេចឲ្យលោកយ៉ូហាន ដឹងថា អ្នកនោះកំពុងកុហក? *«... ដ្បិតអ្នកណាដែលមិនស្រឡាញ់បងប្អូនដែលបានមើលឃើញទៅហើយ នោះធ្វើដូចម្តេចឡើយ ឲ្យស្រឡាញ់ដល់ព្រះដែលមើលមិនឃើញទៅបាន»*។ វាជាការងាយស្រួលដែលអះអាងថា យើងស្រឡាញ់ព្រះ ព្រោះយើងមិនអាចមើលឃើញព្រះឡើយ! តែការស្រឡាញ់បងប្អូនក្នុងក្រុមជំនុំជាក់ស្តែង ដែលពិបាកស្រឡាញ់ ដែលមានវណ្ណៈខុសពីយើង ដែលធ្វើឲ្យយើងឈឺចិត្ត ដែលស្លៀកពាក់ខុសពីយើង ដែលសុំខ្ចីលុយ ស្រឡាញ់មនុស្សបែបនោះជាការពិបាកណាស់។ ហើយក៏

ជាការពិបាកសម្រាប់ពួកគេស្រឡាញ់យើងដែរ! រីឯអ្នកជិតខាងក៏ដូចគ្នាដែរ វាជាការងាយស្រួលដែលយើងអះអាងថា ស្រឡាញ់មនុស្សទាំងអស់ ប៉ុន្តែការស្រឡាញ់អ្នកជិតខាងជាក់ស្តែងពិបាកណាស់ មនុស្សដែល បង្ខិតរបង ឈ្លោះប្រកែកគ្នាខ្លាំងៗពេលយប់ សើចចំអកពីជំនឿរបស់យើងលើព្រះគ្រីស្ទ ឬលួចបន្លែពីសួនច្បាររបស់យើង ការស្រឡាញ់មនុស្សបែបនោះ ពិបាកណាស់។ ប៉ុន្តែនេះគឺជាការដែលព្រះហៅយើងឲ្យធ្វើ។ ហើយទ្រង់គឺជាគំរូរបស់យើង៖

> *«ប៉ុន្តែ ខ្ញុំប្រាប់ថា ត្រូវស្រឡាញ់ពួកខ្មាំងសត្រូវ ត្រូវឲ្យពរដល់អ្នកណាដែលប្រទេចផ្តាសា ត្រូវប្រព្រឹត្តល្អនឹងអ្នកណាដែលស្អប់អ្នករាល់គ្នា ហើយត្រូវអធិស្ឋាន ឲ្យអ្នកណាដែលធ្វើទុក្ខបៀតបៀនដល់អ្នករាល់គ្នាវិញ ⁴⁵ ដើម្បីឲ្យបានធ្វើជាកូនរបស់ព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌ ព្រោះទ្រង់ធ្វើឲ្យថ្ងៃរបស់ទ្រង់រះឡើង បំភ្លឺទាំងមនុស្សអាក្រក់ និងមនុស្សល្អ ហើយទ្រង់បង្អុរឲ្យភ្លៀងធ្លាក់មក លើទាំងមនុស្សសុចរិត និងមនុស្សទុច្ចរិតផង ៤៦ ដ្បិតបើអ្នករាល់គ្នាស្រឡាញ់តែអស់អ្នកណា ដែលស្រឡាញ់ដល់ខ្លួន នោះតើបានបំណាច់អ្វី ឯពួកអ្នកយកពន្ធ តើគេមិនប្រព្រឹត្តដូច្នេះដែរទេឬអី ៤៧ ហើយបើអ្នករាល់គ្នាគំនាប់តែបងប្អូនអ្នកប៉ុណ្ណោះ នោះតើបានធ្វើអ្វីប្លែកពីគេ ឯពួកសាសន៍ដទៃ តើមិនប្រព្រឹត្តដូចគ្នាទេឬអី ៤៨ ដូច្នេះ ចូរឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ដូចព្រះវរបិតានៃអ្នក ដែលគង់នៅស្ថានសួគ៌ ទ្រង់គ្រប់លក្ខណ៍ដែរ»* (ម៉ាថាយ ៥:៤៤-៤៨)។

*«ស្អប់ដល់បងប្អូន ...»* ការស្អប់ដល់សមាជិកគ្រួសារក្រុមជំនុំ ដែលព្រះគ្រីស្ទបានសុគតជំនួសហើយ គឺជាអំពើបាបដ៏អាក្រក់ជាងធម្មតា។ ព្រះគ្រីស្ទស្រឡាញ់សមាជិកក្រុមជំនុំរបស់អ្នក ហើយបានសុគតសំរាប់ពួកគាត់ផង។ តើអ្នកស្អប់អ្នកនោះវិញឬ?

# សេចក្ដីសន្និដ្ឋានៈ

# ចូរឲ្យបរិសុទ្ធ! ជឿការពិត! ស្រឡាញ់ព្រះ! ស្រឡាញ់គ្នា!

## ១យ៉ូហាន ៥:១-២១

នៅពេលយើងចូលមកដល់សេចក្ដីសន្និដ្ឋានរបស់លោកយ៉ូហាន យើងពិបាកនិយាយថា ខទាំងនេះសង្កត់ធ្ងន់ទៅលើ«ព្រះជាពន្លឺ» ឬ «ព្រះជាសេចក្ដីស្រឡាញ់» ពីព្រោះ លោកយ៉ូហាន បញ្ចប់លិខិតរបស់គាត់ ដោយត្បាញបញ្ចូលគ្នានូវគោលការណ៍ ទាំងអស់ ដែលគាត់បានណែនាំក្នុងជំពូកមុនៗ៖

**ព្រះជាពន្លឺ** ដូច្នេះអស់អ្នកណាដែលកើតពីព្រះ នឹងបាន**បរិសុទ្ធ** ហើយ**ជឿការពិត** ។

**ព្រះជាសេចក្ដីស្រឡាញ់** ដូច្នេះអស់អ្នកណាដែលកើតពីព្រះ នឹង**ស្រឡាញ់ព្រះ** ហើយ**ស្រឡាញ់គ្នា** ។

ជំពូក៥ហាក់ដូចជាកំនួចធំដែលស្រាយមិនបាន តែតាមពិតវាជារូបប៉ាក់ដ៏ស្អាតនៃ សេចក្ដីស្រឡាញ់ ដែលមិនអាចរសាត់បានឡើយ។

***១យ៉ូហាន ៥:១ក***

*អស់អ្នកណាដែលជឿថា ព្រះយេស៊ូវជាព្រះគ្រីស្ទ អ្នកនោះបានកើតពីព្រះមក...*

លោកយ៉ូហាន បន្តផ្ដល់នូវប្រយោគវិនិច្ឆ័យបន្ថែមទៀត ដែលជួយយើងកំណត់ថា តើ គ្រូពិត និងគ្រីស្ទបរិស័ទពិតជាអ្នកណា។ នៅក្នុងខនេះគាត់មានប្រសាសន៍ឡើងវិញ

ពីការដែលគាត់បានមានប្រសាសន៍រួចហើយនៅក្នុង ២:២២-២៣ថា គ្រូពិតជឿលើទីបន្ទាល់របស់ពួកសាវកដែលថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ(ព្រះមែស៊ី)តែមួយគត់។




*«អស់អ្នកណាដែល**ជឿ**ថា **ព្រះយេស៊ូវជាព្រះគ្រីស្ទ** អ្នកនោះបាន**កើតពីព្រះ**មក»។ (១យ៉ូហាន ៥:១ក)*

## *១យ៉ូហាន ៥:១ខ*

*...ហើយអស់ទាំងអ្នកណាដែលស្រឡាញ់ព្រះ ដ៏បង្កើតខ្លួនមកនោះ ក៏រមែងស្រឡាញ់ដល់អស់អ្នកឯទៀតដែលកើតពីទ្រង់មកដែរ។*

មនុស្សខ្លះនិយាយថា «ខ្ញុំស្រឡាញ់ព្រះ តែខ្ញុំមានការពិបាកក្នុងការស្រឡាញ់មនុស្សនៅក្នុងក្រុមជំនុំ»។ តែលោកយ៉ូហាន មិនអនុញ្ញាតឲ្យយើងបំបែកសេចក្ដីស្រឡាញ់ចំពោះព្រះ និងសេចក្ដីស្រឡាញ់ចំពោះអ្នកដទៃចេញពីគ្នាឡើយ។




*«អស់ទាំងអ្នកណាដែល**ស្រឡាញ់ព្រះ**ដ៏បង្កើតខ្លួនមកនោះ ក៏រមែង**ស្រឡាញ់ដល់អស់អ្នកឯទៀត**ដែលកើតពីទ្រង់មកដែរ»។ (១យ៉ូហាន ៥:១ខ)*

## *១យ៉ូហាន ៥:២*

*កាលណាយើងស្រឡាញ់ដល់ព្រះ ហើយកាន់តាមអស់ទាំងបញ្ញត្តរបស់ទ្រង់ នោះយើងដឹងថា យើងស្រឡាញ់ដល់ពួកកូនរបស់ព្រះដែរ។*

នៅខនេះលោកយ៉ូហាន ចងភ្ជាប់សេចក្ដីពិតបី «ស្រឡាញ់គ្នា» ជាមួយ«ស្រឡាញ់ព្រះ» និង «ចូរឲ្យបរិសុទ្ធ» ដូចនៅក្នុងរូបទាំងពីរនេះ៖




*«កាលណាយើង**ស្រឡាញ់ដល់ព្រះ**...នោះយើងដឹងថា យើង**ស្រឡាញ់ដល់ពួកកូនរបស់ព្រះ**ដែរ»។ (១យ៉ូហាន ៥:២ក)*




*«កាលណាយើង...**កាន់តាមអស់ទាំងបញ្ញត្ត**របស់ទ្រង់...នោះយើងដឹងថា យើង**ស្រឡាញ់ដល់ពួកកូនរបស់ព្រះ**ដែរ»។ (១យ៉ូហាន ៥:២ខ)*

លោកយ៉ូហាននិយាយថា បើយើងអះអាងថា យើងស្រឡាញ់រាស្ត្ររបស់ព្រះ ប៉ុន្តែមិនយកចិត្តទុកដាក់ធ្វើតាមបញ្ញត្តិព្រះ តាមពិតយើងមិនស្រឡាញ់រាស្ត្ររបស់ព្រះទេ! ជីវិតយើងជាគំរូអាក្រក់ដល់បងប្អូនរបស់យើង។ ប៉ុន្តែនៅពេលដែលយើងព្យាយាមរស់នៅក្នុងជីវិតដ៏បរិសុទ្ធនិងសេចក្ដីស្រឡាញ់ (ដោយពឹងផ្អែកលើព្រះវិញ្ញាណរបស់ព្រះ) ហើយលន់តួបាបភ្លាមនៅពេលយើងបរាជ័យដួល នោះជីវិតយើងនឹងធ្វើជាការលើកទឹកចិត្តដល់បងប្អូនរបស់យើង។

### *១យ៉ូហាន ៥:៣*

*ដ្បិតនេះហើយជាសេចក្ដីស្រឡាញ់ដល់ព្រះ គឺឲ្យយើងកាន់តាមអស់ទាំងបញ្ញត្តរបស់ទ្រង់ ឯបញ្ញត្តទ្រង់នោះ មិនមែនជាបន្ទុកដ៏ធ្ងន់ទេ។*

ជាថ្មីម្តងទៀតលោកយ៉ូហាន ត្បាញបញ្ចូលគ្នាបញ្ញត្តិអំពី«ស្រឡាញ់ព្រះ» និង«ចូរឲ្យបរិសុទ្ធ»។ មនុស្សខ្លះនិយាយថា «ខ្ញុំស្រឡាញ់ព្រះ ប៉ុន្តែបញ្ញត្តិរបស់ទ្រង់តឹងរ៉ឹងពេក» ព្រះមិនអនុញ្ញាតឲ្យយើងបំបែកសេចក្តីស្រឡាញ់ ចេញពីភាពបរិសុទ្ធបានឡើយ។ ដូចក្នុងរូបនេះ។




*«ដ្បិតនេះហើយជាសេចក្តីស្រឡាញ់ដល់ព្រះ*
*គឺឲ្យយើង**កាន់តាមបញ្ញត្តរបស់ទ្រង់**»។ (១យ៉ូហាន ៥:៣)*

*«ឯបញ្ញត្តទ្រង់មិនមែនជាបន្ទុកដ៏ធ្ងន់ទេ»* លោកយ៉ូហាន មិនបានមានប្រសាសន៍ថា ការធ្វើតាមបញ្ញត្តិរបស់ព្រះ ជាការងាយស្រួលនោះទេ។ តើវាងាយស្រួលយ៉ាងម៉េច ឲ្យស្រឡាញ់សត្រូវរបស់យើង និងឲ្យពរដល់អ្នកជេរយើង និងចែកទ្រព្យសម្បត្តិរបស់យើងដល់ពួកអ្នកក្រីក្រ? តើវាងាយស្រួលស្តាប់ព្រះយ៉ាងម៉េច បើ លោកិយ សាច់ឈាម និងអារក្សតែងតែល្បួងយើងមិនឲ្យយើងធ្វើតាមនោះ? លោកយ៉ូហានចង់មានន័យថា គោលបំណង និងលទ្ធផល នៃបញ្ញត្តិព្រះ គឺដកហូតបន្ទុករបស់យើង មិនមែនបន្ថែមទេ។ ព្រះយេស៊ូវមានបន្ទូលថា៖

> *«អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សំរាក ២៩ ចូរទទួលនឹមខ្ញុំ ហើយរៀននឹងខ្ញុំចុះ ដ្បិតខ្ញុំស្លូត ហើយមានចិត្តសុភាព នោះអ្នករាល់គ្នានឹងបានសេចក្តីសំរាកដល់ព្រលឹង ៣០ ពីព្រោះនឹមខ្ញុំងាយទេ ហើយបន្ទុកខ្ញុំក៏ស្រាល»* (ម៉ាថាយ ១១:២៨-៣០)។

គឺជាសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម សេចក្តីប៉ងប្រាថ្នាខាងភ្នែក ហើយអំនួតនៃជីវិត ដែលជាបន្ទុកធ្ងន់ ដែលធ្វើឲ្យមនុស្សលិចចូលក្នុងនរក។ គឺជាគ្រូបង្រៀនអង់ទីគ្រីស្ទ ដែលដាក់ថែមបន្ទុកលើមនុស្ស ដែលមនុស្សមិនអាចទ្រាំបាន។ អំពើបាបមិនមែនជាសេរីភាពទេ តែជាទាសភាពវិញ។ សេចក្តីសុចរិត គឺជាសេរីភាព។ ដូចសាវកប៉ុលមានប្រសាសន៍៖

> *«ដូច្នេះ ធ្វើដូចម្តេច តើគួរឲ្យយើងប្រព្រឹត្តអំពើបាប ដោយព្រោះនៅក្រោមព្រះគុណ មិននៅក្រោមក្រឹត្យវិន័យឬអី ទេ មិនគួរឡើយ [១៦] តើអ្នករាល់គ្នាដឹងទេឬអីថា អ្នករាល់គ្នាប្រគល់ខ្លួនទៅធ្វើជាបាវបំរើ និងស្តាប់តាមចៅហ្វាយណា នោះអ្នកជាបាវបំរើរបស់ចៅហ្វាយនោះឯងដែលអ្នកស្តាប់តាម ទោះជារបស់ផងអំពើបាប ឲ្យបានសេចក្តីស្លាប់ ឬជារបស់ផងសេចក្តីស្តាប់បង្គាប់ ឲ្យបានសុចរិតក្តី [១៧] ឯអ្នករាល់គ្នា ពីដើមជាបាវបំរើរបស់អំពើបាបមែន ប៉ុន្តែអរព្រះគុណដល់ព្រះអង្គ ឥឡូវនេះ បានស្តាប់ដោយស្ម័គ្រពីចិត្ត តាមក្បួននៃលទ្ធិ ដែលគេបានប្រគល់មកអ្នករាល់គ្នា [១៨] ហើយអ្នករាល់គ្នាបានត្រឡប់ជាបាវបំរើនៃសេចក្តីសុចរិតវិញ ដោយទ្រង់បានប្រោសឲ្យរួចពីអំពើបាបហើយ»* (រ៉ូម ៦:១៥-១៨)។

### *១យ៉ូហាន ៥:៤-៥*

*ពីព្រោះគ្រប់ទាំងអស់ដែលកើតពីព្រះមក នោះបានឈ្នះលោកីយហើយ ឯជ័យជំនះដែលឈ្នះលោកីយនោះ គឺជាសេចក្តីជំនឿរបស់យើង [៥] តើអ្នកណាជាអ្នកឈ្នះលោកីយ បើមិនមែនជាអ្នកដែលជឿថា ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ។*

សូមចាំថា នៅក្នុង១យ៉ូហាន ២:១៤ លោកយ៉ូហានបានប្រើពាក្យ«ឈ្នះ» នៅពេលគាត់បានអបអរសាទរជ័យជំនះរបស់សមាជិកក្រុមជំនុំលើគ្រូក្លែងក្លាយ៖ *«កំឡោះរាល់គ្នាអើយខ្ញុំបានសរសេរផ្ញើមកអ្នករាល់គ្នា ពីព្រោះមានកម្លាំង ហើយព្រះបន្ទូលក៏*

*ស្ថិតនៅក្នុងអ្នករាល់គ្នា អ្នករាល់គ្នាបានឈ្នះមេកំណាចហើយ... ពួកកូនតូចៗអើយ អ្នករាល់គ្នាមកពីព្រះ ហើយក៏ឈ្នះវិញ្ញាណទាំងនោះដែរ»* (២:១៤; ៤:៤)។

តើធ្វើដូចម្ដេចឲ្យអ្នក និងខ្ញុំ អាចយកឈ្នះលោកីយ៍ និងការបង្រៀនរបស់អាទទឹងនឹងព្រះគ្រីស្ទបាន? ចម្លើយនៅ ខ៤ និង៥ ពន្យល់ដល់យើង៖

១. យើងត្រូវកើតពីព្រះពិតប្រាកដ ពីព្រោះ *«អស់ដែលកើតពីព្រះមក នោះបានឈ្នះលោកីយហើយ»* (៥:៤ក)។
២. យើងត្រូវតែមានជំនឿលើព្រះជាម្ចាស់ ពីព្រោះ *«ឯជ័យជំនះដែលឈ្នះលោកីយនោះ គឺជាសេចក្ដីជំនឿរបស់យើង»* (៥:៤ខ)។
៣. យើងត្រូវមានជំនឿថា ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ ពីព្រោះ *«តើអ្នកណាជាអ្នកឈ្នះលោកីយ បើមិនមែនជាអ្នកដែលជឿថា ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ?»* (៥:៥)។

នោះជារបៀបដែលគ្រីស្ទបរិស័ទនៅសម័យលោកយ៉ូហានបានយកឈ្នះលើគ្រូក្លែងក្លាយ ដែលបានលួចចូលក្នុងក្រុមជំនុំរបស់ពួកគេ។

### *១យ៉ូហាន ៥:៦-៨*

*គឺព្រះយេស៊ូវគ្រីស្ទនេះហើយ ដែលយាងមកដោយទឹក ហើយ និងឈាមមិនមែនដោយទឹកតែប៉ុណ្ណោះ គឺទាំងទឹកទាំងឈាមផង គឺជាព្រះវិញ្ញាណដែលធ្វើបន្ទាល់ ដ្បិតព្រះវិញ្ញាណជាសេចក្ដីពិត ៧ មានសាក្សី៣អង្គដែលធ្វើបន្ទាល់នៅស្ថានសួគ៌ គឺជាព្រះវរបិតា១ ព្រះបន្ទូល១ និងព្រះវិញ្ញាណបរិសុទ្ធ១ តែទាំង៣អង្គនេះរួមមកតែ១ទេ ៨ ហើយមាន៣មុខទៀត ដែលធ្វើបន្ទាល់នៅផែនដីដែរ គឺជាព្រះវិញ្ញាណ១ ទឹក១ និងឈាម១ ទាំង៣នេះក៏ត្រូវគ្នាដែរ។*

ពិបាកដឹងប្រាកដអំពីអត្ថន័យរបស់លោកយ៉ូហាន ក្នុងឃ្លាដែរថា *«ទ្រង់បានយាងមកដោយ**ទឹក** និង**ឈាម**»*។ មានទស្សនៈជាច្រើន។ មានពេលមួយទៀតដែលលោកយ៉ូហាន បានប្រើពាក្យ *«ទឹក»* និង *«ឈាម»* និង *«ធ្វើបន្ទាល់»* គឺទីបន្ទាល់ផ្ទាល់ភ្នែករបស់យ៉ូហាននៅពេលគេឆ្កាងទ្រង់៖

> *តែកាលគេមកដល់ព្រះយេស៊ូវ ក៏ឃើញថា ទ្រង់សុគតផុតហើយ បានជាគេមិនបំបាក់ព្រះបាទទ្រង់ទេ* [៣៤] *ប៉ុន្តែទាហានម្នាក់យកលំពែងចាក់ត្រង់ចំហៀងទ្រង់ នោះក៏ចេញ**ឈាម**ហើយ និង**ទឹក**មក* [៣៥] *អ្នកដែលឃើញបាន**ធ្វើបន្ទាល់**ហើយ សេចក្តីបន្ទាល់របស់អ្នកនោះក៏ពិតប្រាកដ អ្នកនោះដឹងថា ខ្លួននិយាយដើម្បីឲ្យអ្នករាល់គ្នាបានជឿ* (យ៉ូហាន ១៩:៣៣-៣៥)។

សូមសម្គាល់ថា ក្នុងវគ្គទាំងពីរលោកយ៉ូហានមានប្រសាសន៍អំពីការធ្វើបន្ទាល់។ នៅក្នុងគម្ពីរយ៉ូហាន ១៩ លោកយ៉ូហាន ផ្ទាល់ជាសាក្សីដែល**ធ្វើបន្ទាល់**ថា គាត់បានឃើញ**ទឹក** និង**ឈាម**ចេញពីព្រះយេស៊ូវ។ ប៉ុន្តែនៅក្នុង១យ៉ូហាន ៥:៦-៧នេះ អ្នកធ្វើបន្ទាល់គឺជា**ព្រះវិញ្ញាណបរិសុទ្ធ** រួមជាមួយ**ទឹក** និង**ឈាម**។

ក៏មានព្រឹត្តិការណ៍មួយទៀតដែលលោកយ៉ូហាន ប្រើពាក្យតុលាការថា **«ធ្វើបន្ទាល់»** ហើយនោះគឺជាពិធីជ្រមុជទឹករបស់ព្រះយេស៊ូវ នៅក្នុង**ទឹក**។ នៅដំណឹងល្អយ៉ូហានជំពូក១ លោកយ៉ូហាន ប្រាប់យើងពីទីបន្ទាល់ដ៏ឧឡារិករបស់លោកយ៉ូហាន បាទីស្ទដែលធ្វើបន្ទាល់ហាក់ដូចនៅក្នុងបន្ទប់សវនាការដែរ៖

> *យ៉ូហាន ក៏**ធ្វើបន្ទាល់**ថា៖ «ខ្ញុំបានឃើញព្រះវិញ្ញាណយាងចុះពីលើមេឃ មានរូបដូចជាព្រាបមកសណ្ឋិតលើទ្រង់* [៣៣] *ខ្ញុំមិនបានស្គាល់ទ្រង់ទេ ប៉ុន្តែព្រះដែលចាត់ឲ្យខ្ញុំមកធ្វើបុណ្យជ្រមុជដោយ**ទឹក** ទ្រង់មានបន្ទូលមកខ្ញុំថា "ដែលឯងឃើញ**ព្រះវិញ្ញាណ**យាងចុះមកសណ្ឋិតលើអ្នកណា គឺអ្នកនោះហើយដែលធ្វើ*

*បុណ្យជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ" [៣៤] ខ្ញុំបានឃើញមែន ហើយក៏**ធ្វើបន្ទាល់**ពីព្រះអង្គនោះថា ទ្រង់ជាព្រះរាជបុត្រានៃព្រះពិតមែន»* (១យ៉ូហាន ១:៣២-៣៤)។

### មនុស្សពិតប្រាកដ និងព្រះពិតប្រាកដ

សរុបទៅ ទឹក និងឈាម រំឭកយើងពី**ភាពជាមនុស្សពិត**របស់ព្រះគ្រីស្ទនៅក្នុងកំណើត ពិធីជ្រមុជទឹក និងការឆ្កាងរបស់ទ្រង់ គឺជាភាពជាមនុស្សពិត ដែលគ្រូក្លែងក្លាយបានបដិសេធ។ ពាក្យថា «ទឹក» ក៏អាចរំឭកយើងអំពីការជ្រមុជទឹករបស់ទ្រង់ គឺពេលដែល**ភាពជាព្រះពិត**របស់ព្រះគ្រីស្ទ ត្រូវបានព្រះវរបិតាធ្វើបន្ទាល់ពីស្ថានសួគ៌៖ *«នេះជាកូនស្ងួនភ្ងារបស់អញជាទីពេញចិត្តអញណាស់»* ទន្ទឹមនឹងនោះ ព្រះវិញ្ញាណនៃព្រះក៏បានធ្វើបន្ទាល់ជាសាធារណៈដែរ ដែលចុះមកពីស្ថានសួគ៌សណ្ឋិតលើទ្រង់ (ម៉ាថាយ ៣:១៧)។ (ពេលខ្លះទឹកក៏ជា និមិត្តរូបនៃព្រះវិញ្ញាណបរិសុទ្ធដែរ ដូចនៅយ៉ូហាន ៣:៥; ៤:១៣-១៤; ៧:៣៧-៣៩ និង អេសេគាល ៣៦:២៥-២៦)។

សូមចងចាំថា គ្រូក្លែងក្លាយនៅក្នុង២០០ឆ្នាំដំបូងនៃក្រុមជំនុំ មិនចង់ជឿថា ព្រះរាជបុត្រានៃព្រះបានយករូបកាយជាមនុស្សពិតប្រាកដនោះទេ។ នោះជាការគួរស្អប់ខ្ពើមចំពោះពួកគេ ដោយសាររូបកាយមនុស្ស ពីការចាប់កំណើត ការកើត រហូតដល់ការស្លាប់ គឺពាក់ព័ន្ធនឹងការគួរស្អប់ខ្ពើមជាច្រើនយ៉ាង។ គ្រូក្លែងក្លាយមិនអាចជឿថា ព្រះសព្វព្រះហឫទ័យទទួលយកភាពជាមនុស្សដ៏គួរឲ្យស្អប់ខ្ពើម ដោយកើតជាមនុស្សពិតប្រាកដនោះទេ។ ប៉ុន្តែទ្រង់ពិតជាបានយកភាពជាមនុស្សពិតមែន ពីព្រោះទ្រង់ស្រឡាញ់យើង ហើយចង់សង្គ្រោះយើង។

[ ហេតុអ្វីបានជា១យ៉ូហាន ៥:៧ នៅក្នុងគម្ពីរKOVវែងជាងនៅក្នុងគម្ពីរKSV? ពីព្រោះឯកសារព្រះគម្ពីរបុរាណខ្លះ មានពាក្យទាំងនេះនៅក្នុងខ៧៖ *«មានសាក្សីពអង្គដែលធ្វើ*

*បន្ទាល់នៅស្ថានសួគ៌ គឺជាព្រះវរបិតា១ ព្រះបន្ទូល១ និងព្រះវិញ្ញាណបរិសុទ្ធ១ តែទាំង៣ អង្គនេះរួមមកតែ១ទេ»*។ ប៉ុន្តែឯកសារគម្ពីរបុរាណខ្លះទៀត មិនមានពាក្យទាំងនោះទេ។ គម្ពីរ KSV និង ព្រះគម្ពីរឯទៀត ដោះស្រាយបញ្ហានេះដោយបញ្ចូលពាក្យនេះនៅក្នុងលេខយោងវិញ។ សាត្រាក្រេកទាំង ៧ នេះរួមបញ្ចូលប្រយោគខាងលើនេះ ៖ #៦១ (សតវត្សទី ១៦), #៦២៩ (សតវត្សរ៍ទី ១៤), #៨៨ (សតវត្សទី ១២, ក្នុងរឹម), #៤២៩ (សតវត្សទី ១៤, ក្នុងរឹម), #៦៣៦ (សតវត្សទី ១៤), #៩១៨ (សតវត្សទី ១៦), #២២១ (សតវត្សទី ១០, ក្នុងរឹម)។ សាត្រាក្រេកទាំងដប់ពីរនេះមិនរាប់បញ្ចូលប្រយោគនេះ ៖ #០១ (សតវត្សទី ៤), B (សតវត្សទី ៤), A (សតវត្សទី ៥), #០៤៨ (សតវត្សទី ៥), #០២៩៦ (សតវត្សទី ៦), L (សតវត្សទី ៨), P (សតវត្សទី ៩), K (សតវត្សទី ៩), Ψ (សតវត្សទី ៩), #០៤៩ (សតវត្សទី ៩), #០៥៦ (សតវត្សទី ១០), #០១៤២ (សតវត្សទី ១០)]

## *១យ៉ូហាន ៥:៩-១០*

*បើសិនជាយើងបានទទួលសេចក្តីបន្ទាល់របស់មនុស្សទៅហើយ នោះសេចក្តីបន្ទាល់របស់ព្រះក៏ប្រសើរជាងទៅទៀត ដ្បិតសេចក្តីបន្ទាល់របស់ព្រះគឺជាសេចក្តីដែលទ្រង់ថ្លែងប្រាប់ពីព្រះរាជបុត្រានៃទ្រង់ [១០] អ្នកណាដែលជឿដល់ព្រះរាជបុត្រានៃព្រះនោះ មានសេចក្តីបន្ទាល់នៅក្នុងខ្លួនហើយ តែអ្នកណាដែលមិនជឿដល់ព្រះសោះនោះ ឈ្មោះថា បានធ្វើឲ្យទ្រង់ទៅជាអ្នកកុហកវិញ ពីព្រោះមិនបានជឿលើសេចក្តីបន្ទាល់ដែលទ្រង់បានធ្វើពីដំណើរព្រះរាជបុត្រានៃទ្រង់។*

ម្តងទៀត នៅពេលយើងឮពាក្យ**បន្ទាល់** គំនិតរបស់យើងត្រឡប់ទៅឯទីបន្ទាល់ជាសាធារណៈរបស់ព្រះ អំពីព្រះយេស៊ូវនៅពិធីជ្រមុជទឹករបស់ទ្រង់៖ *«នេះជាកូនស្ងួនភ្ងាអញ ជាទីពេញចិត្តអញណាស់»* (ម៉ាថាយ ៣:១៧)។ អ្នកណាដែលជឿលើទីបន្ទាល់អំពីព្រះយេស៊ូវនេះ ពីព្រះវរបិតា អ្នកនោះក៏*«មានសេចក្តីបន្ទាល់នៅក្នុងខ្លួនហើយ»*។ អ្នកណាដែលបដិសេធទីបន្ទាល់នោះ កំពុងនិយាយថា ព្រះជាអ្នកកុហកហើយ។ ក្រុមខុសឆ្គងទាំងអស់នៅលើពិភពលោកនេះបដិសេធនូវផ្នែកខ្លះនៃទីបន្ទាល់របស់ព្រះអំពីព្រះយេស៊ូវគ្រីស្ទ។ ឧទាហរណ៍៖

- លទ្ធិជីណូទិកនិយម នៅសតវត្សរ៍ទី១និងទី២ បានអះអាងថា ព្រះរាជបុត្រានៃព្រះមិនបានយាងមកខាងសាច់ឈាមទេ។
- លោក ម៉ាស៊ីយូន (Marcion) នៅសតវត្សរ៍ទី២ បាននិយាយថា ព្រះនៃគម្ពីរសញ្ញាចាស់ មិនមែនជាព្រះដែលបានបញ្ជូនព្រះយេស៊ូវមកផែនដីនេះនោះទេ។
- លោក អារីយូស ពីក្រុងអាឡិចសាន់ឌ្រា នៅសតវត្សទី៣ បានអះអាងថា ព្រះរាជបុត្រានៃព្រះ មិនគង់នៅអស់កល្បជានិច្ចទេ តែត្រូវបានបង្កើតដោយព្រះវរបិតា។ (ស្មរបន្ទាល់ព្រះយេហូវ៉ានៅសម័យនេះ ក៏បង្រៀនដូចគ្នានេះដែរ)។
- សាសនាឥស្លាមនៅសតវត្សទី៧បានអះអាងថា ព្រះយេស៊ូវមិនបានសុគតនៅលើឈើឆ្កាង សំរាប់អំពើបាបរបស់មនុស្សជាតិទេ ហើយក៏មិនមែនជាព្រះរាជបុត្រានៃព្រះដែរ។
- គ្រូខុសឆ្គងដែលប្រឆាំងនឹងលទ្ធិអំពីព្រះត្រៃឯក ដូចជាវីល្លៀម ប្រាណហាំ អាប៉ូឡូ គីបូឡុយ និងលី ម៉ាន់ហ៊ី បង្រៀនថា មានព្រះតែមួយ ប៉ុន្តែព្រះនោះបាន«ប្តូរម៉ូដ» របស់ទ្រង់ ពីសម័យកាលមួយទៅសម័យកាលមួយទៀត (ពីព្រះវរបិតា ដូរជាព្រះរាជបុត្រា ដូរជាព្រះវិញ្ញាណបរិសុទ្ធ)។ ប៉ុន្តែគោលលទ្ធិព្រះត្រៃឯកបង្រៀនថា ព្រះតែមួយតែងតែមានបីអង្គជានិច្ច។
- ក្រុមខុសឆ្គងអាន់ សាំងហុង និងក្រុមជំនុំព្រះដ៏មានគ្រប់ព្រះចេស្តា បង្រៀនថា ព្រះយេស៊ូវជាព្រះគ្រីស្ទ សម្រាប់តែសម័យកាលរបស់ទ្រង់តែប៉ុណ្ណោះទេ តែឥឡូវ មានព្រះគ្រីស្ទថ្មីសម្រាប់សម័យកាលយើង។

- សាសនាមរមនបង្រៀនថា ព្រះយេស៊ូវ គឺជាបងប្រុសរបស់សាតាំងខាងវិញ្ញាណ ហើយក្រោយមកទ្រង់បានកើតជាមនុស្សធម្មតានៅផែនដី ប៉ុន្តែចុងក្រោយក៏បានក្លាយជាព្រះមួយ។
- គ្រីស្ទសាសនាសេរីនិយមបង្រៀនថា ព្រះយេស៊ូវគ្រាន់តែជាមនុស្សល្អដែលបានផ្ដល់គំរូល្អដល់យើង ដើម្បីយើងត្រាប់តាម។ (សូមផ្នែកទី២ «សាសនាក្លែងក្លាយ»)

លោកយ៉ូហានបានបញ្ជាក់យ៉ាងច្បាស់ថា៖ *«អ្នកណាដែលមិនជឿដល់ព្រះ សោះ នោះឈ្មោះថា បានធ្វើឲ្យទ្រង់ទៅជាអ្នកកុហកវិញ ពីព្រោះមិនបានជឿលើសេចក្ដីបន្ទាល់ដែលទ្រង់បានធ្វើពីដំណើរព្រះរាជបុត្រានៃទ្រង់»* (១យ៉ូហាន ៥:១០)។

## *១យ៉ូហាន ៥:១១-១២*

*នេះហើយជាសេចក្ដីបន្ទាល់ នោះគឺថា ព្រះទ្រង់បានប្រទានជីវិតដ៏នៅអស់កល្បជានិច្ចមកយើងរាល់គ្នា ហើយជីវិតនោះ គឺនៅក្នុងព្រះរាជបុត្រានៃទ្រង់ ¹²ឯអ្នកណាដែលមានព្រះរាជបុត្រា នោះក៏មានជីវិតដែរ តែអ្នកណាដែលគ្មានព្រះរាជបុត្រានៃព្រះទេ នោះគ្មានជីវិតឡើយ។*

ការប្រកាសដ៏ឧឡារិកនេះ ជាកំពូលខ្ពស់ជាងគេនៅកណ្ដាលយ៉ូហានខ្សែទី១។ ទីបន្ទាល់របស់ព្រះវរបិតា និង ព្រះវិញ្ញាណបរិសុទ្ធ ថែមទាំងទីបន្ទាល់របស់យ៉ូហានបាប់ទីស្ទ និងរបស់សាវក និងសាក្សីផ្ទាល់ភ្នែកឯទៀត រួមគ្នាប្រកាសច្បាស់ថា *«ព្រះទ្រង់បានប្រទានជីវិតដ៏នៅអស់កល្បជានិច្ចមកយើងរាល់គ្នា ហើយជីវិតនោះ គឺនៅក្នុងព្រះរាជបុត្រានៃទ្រង់ ឯអ្នកណាដែលមានព្រះរាជបុត្រា នោះក៏មានជីវិតដែរ តែអ្នកណាដែលគ្មានព្រះរាជបុត្រានៃព្រះទេ នោះគ្មានជីវិតឡើយ»*។

### *១យ៉ូហាន ៥:១៣*

*ខ្ញុំបានសរសេរសេចក្ដីទាំងនេះ ផ្ញើមកអ្នករាល់គ្នាដែលជឿដល់ព្រះនាមព្រះរាជបុត្រា នៃព្រះ ដើម្បីឲ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ចហើយ។*

គោលបំណងមួយរបស់លោកយ៉ូហាន ក្នុងការសរសេរសំបុត្រនេះ គឺដើម្បីធានាដល់អ្នកជឿព្រះយេស៊ូវគ្រីស្ទថា ពួកគេពិតជាមានជីវិតអស់កល្បជានិច្ច ពីព្រោះពួកគេជឿព្រះយេស៊ូវដដែល ដែលព្រះជាម្ចាស់ និងពួកសាវក បានធ្វើបន្ទាល់អំពីទ្រង់។ គឺជាគ្រូក្លែងក្លាយដែលបដិសេធព្រះគ្រីស្ទនៃពួកសាវក ហេតុដូច្នេះគេក៏បដិសេធជីវិតអស់កល្បជានិច្ចដែរ។

*«ដើម្បីឲ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ចហើយ»* នៅសាសនាផ្សេង មនុស្សមិនអាចដឹងប្រាកដថា គាត់មានជីវិតអស់កល្បជានិច្ចនោះទេ ទាល់តែដល់ថ្ងៃជំនុំជម្រះ នៅពេលដែលអំពើល្អ និងអំពើបាបរបស់គាត់ត្រូវថ្លឹងគ្នា។ ប៉ុន្តែគ្រីស្ទបរិស័ទអាចមានការធានាសេចក្ដីសង្គ្រោះឥឡូវនេះ ព្រោះព្រះគ្រីស្ទបានទទួលទោសទាំងអស់របស់គាត់ដាក់លើអង្គទ្រង់នៅលើឈើឆ្កាងហើយ។

### *១យ៉ូហាន ៥:១៤-១៥*

*យើងក៏មានសេចក្ដីក្លាហានដល់ទ្រង់យ៉ាងដូច្នេះដែរ គឺថា បើយើងនឹងសូមអ្វីដែលត្រូវតាមព្រះហឫទ័យទ្រង់ នោះទ្រង់នឹងទទួលព្រម [១៥] បើយើងដឹងថា ទ្រង់ទទួលព្រមតាមយើងក្នុងការអ្វីដែលយើងសូម ដូច្នេះនោះយើងក៏ដឹងថា យើងបានអ្វីដែលយើងសូមពីទ្រង់ហើយដែរ។*

*«...សូមអ្វីដែលត្រូវតាមព្រះហឫទ័យទ្រង់...»* អ្នកអាចសួរថា «តើធ្វើយ៉ាងដូចម្ដេចដើម្បីឲ្យខ្ញុំស្គាល់ព្រះហឫទ័យរបស់ព្រះ ដើម្បីខ្ញុំអាចសូមតាមព្រះហឫទ័យនោះបាន?» ព្រះបានឲ្យព្រះគម្ពីរដល់យើង ដើម្បីយើងអាចស្គាល់បំណងហឫទ័យរបស់

ទ្រង់យ៉ាងច្បាស់ ហើយអធិស្ឋានតាមព្រះហឫទ័យនោះ។ ឧទាហរណ៍ នៅពេលយើងអធិស្ឋានសូមឲ្យអ្នកណាម្នាក់ជឿព្រះយេស៊ូវ យើងដឹងថា យើងកំពុងអធិស្ឋានតាមព្រះហឫទ័យព្រះ ហើយយើងអាចជឿជាក់ថា ព្រះបានស្តាប់យើង។ ប៉ុន្តែបើយើងសូមព្រះអនុញ្ញាតឲ្យយើងរៀបការជាមួយអ្នកមិនជឿ យើងដឹងថា យើងកំពុងអធិស្ឋានក្រៅបំណងព្រះហឫទ័យរបស់ព្រះហើយ ពីព្រោះព្រះបន្ទូលបានហាមពីការនេះ។

និយាយអំពីការអធិស្ឋាន តើលោកយ៉ូហានចង់ឲ្យយើងអធិស្ឋានសម្រាប់គ្រូក្លែងក្លាយឬទេ? ហើយតើគាត់ចង់ឲ្យយើងអធិស្ឋានសម្រាប់អ្នកដែលត្រូវបានគ្រូក្លែងក្លាយបញ្ឆោតឬទេ? នៅខបន្ទាប់លោកយ៉ូហាន ប្រាប់យើងពីរបៀបដែលត្រូវអធិស្ឋាន ក្នុងករណីទាំងពីរនេះ៖

### *១យ៉ូហាន ៥:១៦-១៧*

*បើអ្នកណាឃើញបងប្អូនកំពុងតែធ្វើបាប គឺជាបាបដែលមិនមានទោសដល់ស្លាប់ទេ នោះត្រូវសូមចុះ ទ្រង់នឹងប្រទានជីវិតមកដល់អស់អ្នកធ្វើបាបដែលមិនមែនមានទោសដល់ស្លាប់នោះជាពិត តែមានបាបម្យ៉ាងដែលមានទោសដល់ស្លាប់វិញ ឯបាបនោះខ្ញុំមិនថា ឲ្យសូមអង្វរឲ្យទេ [១៧] គ្រប់ទាំងអំពើទុច្ចរិតសុទ្ធតែបាបទាំងអស់ ហើយក៏មានបាបខ្លះ ដែលមិនមានទោសដល់ស្លាប់ដែរ។*

បើយើងគិតពីបរិបទនៃកណ្ឌគម្ពីរយ៉ូហានខ្សែទី១ បាបដែល *«មិនមានទោសដល់ស្លាប់»* ទំនងជាអំពើបាបរបស់សមាជិកដែលចាញ់ការបោកបញ្ឆោតគ្រូខុសឆ្គង។ យើងនៅតែមានសង្ឃឹមសម្រាប់ពួកគេថា ពួកគេនឹងដឹងខ្លួន ហើយកែប្រែចិត្ត។ យើងត្រូវអធិស្ឋានសម្រាប់ពួកគេ ឲ្យពួកគេត្រឡប់មករកព្រះអម្ចាស់ និងក្រុមជំនុំវិញ។ តាមពិតខ្ញុំបានស្គាល់ដោយផ្ទាល់នូវមនុស្សមួយចំនួនដែលត្រូវគ្រូខុសឆ្គងបោកបញ្ឆោត ប៉ុន្តែក្រោយមកបានបែរមករកសេចក្តីពិតវិញ។

ប៉ុន្តែនៅក្នុងបរិបទនៃកណ្ឌគម្ពីរយ៉ូហានខ្សែទី១ *«អំពើបាបដែលមានទោសដល់ស្លាប់»* ទំនងជាអំពើបាបរបស់គ្រូក្លែងក្លាយផ្ទាល់ ដែលបដិសេធការបង្រៀនពិតពីព្រះយេស៊ូវគ្រីស្ទ។ ពួកនេះជាមនុស្សដូចយូដាស ដែលមានវិញ្ញាណប្រឆាំងជំទាស់នឹងព្រះគ្រីស្ទ (អង់ទីគ្រីស្ទ)។ លោកយ៉ូហានមានប្រសាសន៍ថា គាត់មិនបង្គាប់យើងឲ្យអធិស្ឋានសំរាប់គ្រូក្លែងក្លាយទាំងនេះទេ។ សូមកត់សម្គាល់ថា អ្នកនិពន្ធគម្ពីរហេព្រើរនិយាយតាមបែបស្រដៀងគ្នានេះ៖

> *«ដ្បិតពួកអ្នកដែលបានភ្លឺម្តងទាំងភ្លក់អំណោយទាននៃស្ថានសួគ៌ ក៏បានចំណែកនៃព្រះវិញ្ញាណបរិសុទ្ធ ៥ហើយភ្លក់ព្រះបន្ទូលដ៏ល្អនៃព្រះ និងការឫទ្ធិបារមីរបស់បរលោកនាយ ៦ រួចធ្លាក់ទៅវិញ នោះគ្មានផ្លូវណានឹងនាំឲ្យគេប្រែចិត្តម្តងទៀតទេដោយព្រោះគេបានឆ្កាងព្រះរាជបុត្រានៃព្រះខាងឯខ្លួនគេរួចទៅហើយ ព្រមទាំងធ្វើឲ្យទ្រង់ហាលនៅកណ្តាលជំនុំផង ៧ ដ្បិតដីណាបានបៀមទឹកភ្លៀង ដែលធ្លាក់មកជាញយៗ រួចបង្កើតជាបន្លែមានប្រយោជន៍ដល់អ្នកដែលភ្ជួររាស់ នោះបានទទួលព្រះពរហើយពីព្រះ ៨ តែដីណាដែលបង្កើតសុទ្ធតែបន្លា និងអញ្ចាញវិញ ដីនោះត្រូវបោះបង់ចោលចេញ ក៏ជិតនឹងត្រូវបណ្តាសាហើយ លុះដល់ចុងបំផុតនឹងត្រូវដុតចោលផង ៩ ពួកស្ងួនភ្ងាអើយទោះបើយើងខ្ញុំនិយាយ ដូច្នេះក៏ដោយ គង់តែយើងខ្ញុំទុកចិត្តខាងឯអ្នករាល់គ្នាថា បានសេចក្តីប្រសើរជាង គឺជាសេចក្តីដែលត្រូវខាងសេចក្តីជួយសង្គ្រោះវិញ»* (ហេព្រើរ ៦:៤-៩)។

ខ្ញុំមិនបានស្គាល់ដោយផ្ទាល់នូវគ្រូក្លែងក្លាយណាដែលត្រឡប់មករកសេចក្តីពិតបន្ទាប់ពីពួកគេបាន *«ឆ្កាងព្រះរាជបុត្រានៃព្រះរួចទៅហើយ»* (ហេព្រើរ ៦:៦) ហើយបានបដិសេធព្រះគ្រីស្ទដូចយូដាស។ តើលោកយ៉ូហាន ហាមយើងមិនឲ្យអធិស្ឋានសំរាប់ពួកគេឬ? គាត់មិនហាមឃាត់ទេ តែគាត់ក៏មិនបង្គាប់ដែរ ដោយប្រើ

ពាក្យថា៖ *«មានអំពើបាបម៉្យាងដែលមានទោសដល់ស្លាប់ ឯបាបនោះ ខ្ញុំមិនថា ឲ្យសូមអង្វរឲ្យទេ»*។ (ប៉ុន្តែព្រះអាចធ្វើអ្វីដែលមិនអាចកើតមាន។ សូមអានអត្ថបទ «គ្រីស្ទសាសនាសេរីនិយម» នៅផ្នែកទី២ ដើម្បីអានរឿងមួយអំពីគ្រូខុសឆ្គងដែលបានក្លាយជាគ្រីស្ទបរិស័ទពិត។)

## ការបូកសរុបចុងក្រោយ

លោកយ៉ូហាន បញ្ចប់សំបុត្ររបស់គាត់ ដោយបូកសរុបចំណុចសំខាន់៣យ៉ាង ដែលចាប់ផ្តើមដោយពាក្យ *«យើងដឹងថា...»*

***១យ៉ូហាន ៥:១៨***

***យើងដឹងថា*** *អ្នកណាដែលកើតពីព្រះមក នោះមិនចេះធ្វើបាបទេ អ្នកនោះឯងជាអ្នករក្សាខ្លួនវិញ ហើយមេកំណាចនឹងពាល់អ្នកនោះមិនបានឡើយ។*

***១យ៉ូហាន ៥:១៩***

***យើងដឹងថា*** *យើងមកពីព្រះពិត តែលោកីយទាំងមូលដេកនៅក្នុងឱវាទនៃមេកំណាចវិញ។*

***១យ៉ូហាន ៥:២០***

***យើងក៏ដឹងថា*** *ព្រះរាជបុត្រានៃព្រះ បានយាងមកហើយក៏ បានប្រទានឲ្យយើងរាល់គ្នាមានប្រាជ្ញា ដើម្បីឲ្យបានស្គាល់ព្រះដ៏ពិតប្រាកដ យើងរាល់គ្នាជាអ្នកនៅក្នុងព្រះដ៏ពិតប្រាកដនោះ គឺក្នុងព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃទ្រង់ ព្រះអង្គនោះឯងជាព្រះពិតប្រាកដ ហើយជាជីវិតអស់កល្បជានិច្ចផង។*

លោកយ៉ូហានមានប្រសាសន៍ថា ព្រះដែលបានចាត់ព្រះរាជបុត្រាទ្រង់តែមួយឲ្យមកសុគត សម្រាប់អំពើបាបរបស់យើង គឺជា *«ព្រះ**ពិតប្រាកដ** ហើយជាជីវិតអស់កល្ប*

*ជានិច្ចផង»*។ ពាក្យ *«ព្រះពិតប្រាកដ»* ជួយយើងឲ្យយល់ពីឃ្លាចុងក្រោយ ដែលនិយាយពីរូបព្រះ ដែលជាការថ្វាយបង្គំព្រះក្លែងក្លាយ៖

***១យ៉ូហាន ៥:២១***

*កូនតូចៗរាល់គ្នាអើយ ចូរឲ្យអ្នករាល់គ្នារក្សាខ្លួនឲ្យផុតពីរូបព្រះចេញ។*

ដូចដែលយើងបាននិយាយនៅក្នុងសេចក្តីណែនាំខាងដើម វាហាក់ដូចជាចម្លែកសម្រាប់លោកយ៉ូហាន ដែលបញ្ចប់សំបុត្ររបស់គាត់ដោយពាក្យទាំងនេះ អំពីរូបព្រះ ដែលគាត់មិនដែលមានប្រសាសន៍ពីរូបព្រះម្តងណាសោះ នៅក្នុងសំបុត្រនេះ។ ប៉ុន្តែខ្ញុំគិតថា ឥឡូវនេះ យើងយល់ថា កណ្ឌគម្ពីរនេះទាំងមូលជាការព្រមានអំពីរូបព្រះ គឺព្រះក្លែងក្លាយដែលគ្រូក្លែងក្លាយបានបង្កើត។

សូមចាំថា គ្រូក្លែងក្លាយបានបដិសេធព្រះគ្រីស្ទនៃពួកសាវក និងពួកសាវកនៃព្រះគ្រីស្ទ។ ព្រះគ្រីស្ទក្លែងក្លាយដែលពួកគេប្រកាស មិនមែនជា*«ព្រះពិតប្រាកដ»* ទេ តែជារូបព្រះវិញ។ មួយទៀត អ្នកណាដែលបដិសេធព្រះគ្រីស្ទនៃពួកសាវក ក៏បដិសេធព្រះជាម្ចាស់របស់ពួកសាវកដែរ ( *«ឯអស់អ្នកណាដែលមិនព្រមទទួលស្គាល់ព្រះរាជបុត្រា នោះក៏គ្មានព្រះវរបិតាដែរ»* ២:២៣)។ ដូច្នេះគ្រូក្លែងក្លាយបានជឿលើព្រះយេស៊ូវក្លែងក្លាយ និងព្រះវរបិតាក្លែងក្លាយដែរ គឺរូបព្រះទាំងអស់!

ព្រះពិត គឺគង់នៅអស់កល្បជានិច្ច។ ទ្រង់គឺជាពន្លឺ និងសេចក្តីស្រឡាញ់។ ទ្រង់ជាព្រះវរបិតា ជាព្រះរាជបុត្រា និងជាព្រះវិញ្ញាណបរិសុទ្ធ។ ទ្រង់បានបញ្ជូនព្រះរាជបុត្រាតែមួយរបស់ទ្រង់មកកើតជាមនុស្សពិតប្រាកដ សុគតសម្រាប់អំពើបាបរបស់យើង ហើយរស់ឡើងវិញ។ ព្រះផ្សេងទៀត គឺជារូបព្រះ ជាព្រះក្លែងក្លាយ ហើយមិនស័ក្តិសមនឹងទទួលការថ្វាយបង្គំរបស់យើងឡើយ។ ព្រះបានបង្កើតមនុស្សយើង ឲ្យរស់នៅអស់កល្បជានិច្ច ហើយថ្វាយបង្គំអស់កល្បជានិច្ច។ មានតែព្រះដែលគង់នៅ

អស់កល្បទេ ដែលស័ក្តិសមនឹងការថ្វាយបង្គំអស់កល្បជានិច្ចរបស់យើង។ មានតែព្រះដែលគង់នៅអស់កល្បទេ ដែលអាចបំពេញបំណងប្រាថ្នាដ៏នៅអស់កល្បជានិច្ចនៃចិត្តយើង។

*កូនតូចៗរាល់គ្នាអើយ ចូរឲ្យអ្នករាល់គ្នារក្សាខ្លួនឲ្យផុតពីរូបព្រះចេញ។*

# កណ្ឌគម្ពីរយ៉ូហានខ្សែទី២ និងទី៣ និយាយអ្វីខ្លះពីគ្រូក្លែងក្លាយ

## យ៉ូហានខ្សែទី២

***២យ៉ូហាន ៩១-៣***

*សំបុត្រអ្នកចាស់ទុំផ្ញើមកលោកស្រីរើសតាំង និងកូនចៅរបស់លោកស្រីដែលខ្ញុំ
ស្រឡាញ់ពិតប្រាកដ មិនមែនតែខ្ញុំ១ គឺព្រមទាំងអស់អ្នកដែលស្គាល់សេចក្ដីពិតផង
ដែរ ២ ដោយព្រោះសេចក្ដីពិតដែលនៅក្នុងយើងរាល់គ្នា ហើយក៏នៅជាមួយនឹង
យើងជាដរាប ៣ សូមឲ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ និងសេចក្ដីមេត្តា
ករុណា ហើយ និងសេចក្ដីសុខសាន្តអំពីព្រះដ៏ជាព្រះវរបិតា ហើយអំពីព្រះអម្ចាស់
យេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះវរបិតា គឺដោយសេចក្ដីពិត និងសេចក្ដី
ស្រឡាញ់។*

*«...លោកស្រីរើសតាំង និងកូនចៅរបស់លោកស្រី»* នេះទំនងជានិយាយអំពីក្រុមជំនុំមួយ*(«លោកស្រីរើសតាំង»)* ហើយសមាជិកក្រុមជំនុំ *(«កូនចៅរបស់លោកស្រី»)*។ លោកយ៉ូហាន តែងតែមើលឃើញក្រុមជំនុំជាក្រុមគ្រួសារ។

លោកយ៉ូហានតែងតែឃើញក្រុមជំនុំជាក្រុមគ្រួសារមួយ។ *«ដែលខ្ញុំស្រឡាញ់ពិតប្រាកដ...ដោយសេចក្ដីពិត និងសេចក្ដីស្រឡាញ់»* សូមកត់សម្គាល់ម្ដងទៀតថា លោកយ៉ូហាន នឹងមិនអនុញ្ញាតឲ្យអ្នកណាបំបែកសេចក្ដីពិត និងសេចក្ដីស្រឡាញ់

ចេញពីគ្នាឡើយ។ ការទាំងពីរនោះ តែងដើរទន្ទឹមគ្នាក្នុងគ្រីស្ទសាសនាដ៏ពិត ដូចដែលយើងនឹងឃើញនៅក្នុងរូបនេះ។




*«ដែលខ្ញុំ**ស្រឡាញ់**ពិតប្រាកដ...គឺដោយ**សេចក្ដីពិត** និង**សេចក្ដីស្រឡាញ់**»។ (២យ៉ូហាន ៩១ និង៣)*

## *២យ៉ូហាន ៩៤*

*ខ្ញុំមានសេចក្ដីអំណរជាខ្លាំងណាស់ដោយបានឃើញកូនចៅខ្លះរបស់លោកស្រីដែលប្រព្រឹត្តតាមសេចក្ដីពិត ដូចជាព្រះវរបិតាបានបង្គាប់មកយើងរាល់គ្នា។*

«ចូរជឿការពិត» គឺជាខ្លឹមសារមួយ ក្នុងចំណោមខ្លឹមសារធំជាងគេទាំងបួននៃសំបុត្ររបស់លោកយ៉ូហាន។ បើព្រះជាពន្លឺ នោះអស់អ្នកណាដែលកើតពីព្រះ នឹងជឿសេចក្ដីពិត ហើយ *«ប្រព្រឹត្តតាមសេចក្ដីពិត»*។




*កូនពិតរបស់ព្រះនឹងប្រព្រឹត្តតាមសេចក្ដីពិត។ (២យ៉ូហាន ៩៤)*

## *២យ៉ូហាន ៩៥*

*ឥឡូវនេះ ខ្ញុំសូមអង្វរលោកស្រីថា យើងត្រូវស្រឡាញ់គ្នាទៅវិញទៅមក។ ខ្ញុំមិនសរសេរបទបញ្ជាថ្មីផ្ញើមកជូនទេ នេះគឺជាបទបញ្ជាដែលយើងបានទទួល តាំងពីដើមដំបូងមកម្ល៉េះ។ [KSV]*

រំពេចនោះបន្ទាប់ពីលើកសរសើរក្រុមជំនុំចំពោះការដើរតាមសេចក្តីពិត លោកយ៉ូហានបានបង្គាប់ពួកគេឲ្យស្រឡាញ់គ្នាទៅវិញទៅមក។

### *២យ៉ូហាន ៥៦*

*នេះហើយជាសេចក្តីស្រឡាញ់ គឺឲ្យយើងរាល់គ្នាប្រព្រឹត្តតាមបញ្ញត្តទ្រង់ ឯសេចក្តីបញ្ញត្តនោះ គឺដូចជាបានឮតាំងតែពីដើមរៀងមក ដើម្បីឲ្យបានប្រព្រឹត្តតាម។*

ដូចដែលគាត់ធ្វើរាល់ពេល លោកយ៉ូហាន ចងភ្ជាប់សេចក្តីស្រឡាញ់ និងសេចក្តីពិតនៅក្នុងខនេះ។




*«នេះហើយជាសេចក្តីស្រឡាញ់ គឺឲ្យយើងប្រព្រឹត្តតាមបញ្ញត្តទ្រង់»។ (២យ៉ូហាន ៥៦)*

### *២យ៉ូហាន ៥៧*

*ពីព្រោះមានអ្នកប្រវ័ញ្ចបញ្ឆោតជាច្រើន បានមកក្នុងលោកីយហើយ ឯពួកអ្នកដែលមិនព្រមទទួលថា ព្រះយេស៊ូវគ្រីស្ទបានមកក្នុងសាច់ឈាមទេ នោះហើយជាអ្នកប្រវ័ញ្ចបញ្ឆោត ហើយជាអ្នកទទឹងនឹងព្រះគ្រីស្ទផង។*

អ្នកបោកបញ្ឆោតនេះ មិនព្រមទទួលទីបន្ទាល់ផ្ទាល់ភ្នែករបស់សាវកនៃព្រះយេស៊ូវគ្រីស្ទ ដែលថា ទ្រង់មានរូបកាយជាមនុស្សពិត ទ្រង់ពិតជាបានសុគត ហើយពិតជាបានរស់ពីសុគតឡើងវិញឡើយ។ ផ្ទុយទៅវិញពួកគេបានបង្រៀនទស្សនវិជ្ជាពីសម័យនោះដែលថា រូបកាយតែងតែអាក្រក់។ ពួកគេថា បើរូបកាយតែងតែអាក្រក់ នោះព្រះគ្រីស្ទដ៏បរិសុទ្ធមិនអាចមានរូបកាយពិតប្រាកដបានទេ។ លោកយ៉ូហាន

ហៅលទ្ធិនេះថា «លទ្ធិទទឹងនឹងព្រះគ្រីស្ទ (អង់ទីគ្រីស្ទ)» នៅ ១យ៉ូហាន ២:២២ ពីព្រោះវាជាទស្សនវិជ្ជារបស់សាតាំង។

## *២យ៉ូហាន ៥៨*

*ត្រូវឲ្យអ្នករាល់គ្នាប្រយ័ត្នក្រែងបាត់ផល ការដែលបានធ្វើហើយនោះ គឺឲ្យបានទទួលរង្វាន់ដ៏ពេញលេញវិញ។*

លោកយ៉ូហាន រំឭកគ្រីស្ទបរិស័ទថា វាជាការងាយស្រួលនឹងត្រូវបានបោកបញ្ឆោតដោយអ្នកប្រវ័ញ្ចបញ្ឆោតដ៏ឆ្លាតវៃទាំងនេះ។ ដូច្នេះពួកគេត្រូវតែប្រុងប្រយ័ត្ន។ កុំគិតថា យើងអាចមិនចាញ់ការភូតភរបោកបញ្ឆោតរបស់សាតាំងឡើយ។

*«...ទទួលរង្វាន់ដ៏ពេញលេញ»* លោកយ៉ូហាន រំឭកយើងថា ព្រះបានរៀបចំរង្វាន់អស្ចារ្យដល់អស់អ្នកណាដែលបដិសេធគ្រូក្លែងក្លាយ និងការបង្រៀនក្លែងក្លាយ ហើយដេញតាម ភាពបរិសុទ្ធ ការពិត ការស្រឡាញ់ព្រះ និងការស្រឡាញ់មនុស្សឯទៀត។

## *២យ៉ូហាន ៥៩*

*អ្នកណាដែលប្រព្រឹត្តរំលង ហើយមិនកាន់ខ្ជាប់ក្នុងសេចក្តីបង្រៀនរបស់ព្រះគ្រីស្ទ អ្នកនោះគ្មានព្រះទេ តែអ្នកណាដែលកាន់ខ្ជាប់ក្នុងសេចក្តីបង្រៀនរបស់ព្រះគ្រីស្ទវិញ អ្នកនោះមានទាំងព្រះវរបិតា និងព្រះរាជបុត្រាផង។*

លោកយ៉ូហាន រំឭកយើងម្តងទៀតថា អស់អ្នកណាដែលរកគោលជំនឿថ្មី ហើយមិននៅជាប់នឹងសេចក្តីបង្រៀនដែលព្រះគ្រីស្ទ និងពួកសាវកបានបង្រៀនតាំងពីដំបូងមកនោះ មិនមែនកើតពីព្រះទេ។




*«អ្នកណាដែល...មិនកាន់ខ្ជាប់ក្នុងសេចក្ដីបង្រៀនរបស់ព្រះគ្រីស្ទ អ្នកនោះគ្មានព្រះទេ»។ (២យ៉ូហាន ៩)*

## *២យ៉ូហាន ៩ ១០-១១*

*បើអ្នកណាមកឯអ្នករាល់គ្នា តែមិនបង្រៀនចំពោះសេចក្ដីនេះ នោះកុំឲ្យទទួល*
*អ្នកនោះនៅក្នុងផ្ទះឡើយ ក៏កុំឲ្យទាំងជំរាបសួរដល់អ្នកនោះផង ១១ ដ្បិតបើអ្នកណា*
*ជំរាបសួរនោះ ក៏តែងមានសេចក្ដីប្រកបគ្នាក្នុងការអាក្រក់របស់អ្នកនោះដែរ។*

នេះហើយជាបញ្ញត្តិដែលមនុស្សទាំងអស់ មានសមត្ថភាពអាចធ្វើតាមបាន សូម្បីតែគ្រីស្ទបរិស័ទថ្មី ដែលមិនទាន់ស្គាល់ព្រះគម្ពីរច្រើនប៉ុន្មានទេ! លោកយ៉ូហាន ច្បាស់ណាស់ថា ថ្ងៃណាមួយគ្រូបង្រៀនក្លែងក្លាយ នឹងព្យាយាមចូលផ្ទះ(ឬទូរស័ព្ទ)របស់អ្នកជឿ ហើយបង្រៀនដំណឹងល្អផ្សេង ដើម្បីបញ្ឆោតពួកគេ។ ដូច្នេះលោកយ៉ូហាន ផ្ដល់ឲ្យក្រុមជំនុំនូវវិធីងាយស្រួល ដើម្បីការពារខ្លួនពីការភូតភររបស់គ្រូក្លែងក្លាយ៖ **កុំឲ្យទទួលអ្នកនោះនៅក្នុងផ្ទះឡើយ ក៏កុំឲ្យទាំងជំរាបសួរដល់អ្នកនោះផង**!

សព្វថ្ងៃនេះ មធ្យោបាយចម្បងដែលក្រុមខុសឆ្គងចូលក្នុងផ្ទះយើងគឺតាមទូរស័ព្ទ យូធូប ហ្វេសបុក មេសសិនចឺ តេឡេក្រាម ។ល។ ឧទាហរណ៍ ពួកគេស្វែងរកការបង្ហោះអំពីព្រះគ្រីស្ទនៅតាមហ្វេសបុក ហើយទាក់ទងនឹងអ្នកបង្ហោះនោះតាមមេសសិនចឺ ដើម្បីសុំលេខទូរស័ព្ទ។ ធម្មតាពួកគេ ឲ្យប្រុសទាក់ទងទៅស្រី ហើយស្រីទាក់ទងទៅប្រុស។ គ្រីស្ទបរិស័ទមិនត្រូវឲ្យលេខទូរស័ព្ទរបស់ខ្លួនដល់ពួកគេឡើយ។ នៅពេលពួកគេព្យាយាមតេយើង យើងត្រូវបិទទូរស័ព្ទ ឬ ប្លក់លេខរបស់គេចោល យើងត្រូវសួរគ្រូគង្វាលរបស់យើងអំពីអ្នកបង្រៀនតាម យូធូប ដើម្បីដឹងថា គ្រូ

នោះគួរទុកចិត្តឬអត់។ ព្រះជាម្ចាស់បង្គាប់យើងនៅ ២យ៉ូហាន ១០ កុំអនុញ្ញាតឲ្យគ្រូខុសឆ្គងនេះចូលក្នុងផ្ទះយើងឡើយ ទាំងតាមរយៈទ្វារផ្ទះ តាមទូរស័ព្ទ តាមវិទ្យុ និងទូរទស្សន៍។ ចំពោះយើងដែលរស់នៅក្នុងវប្បធម៌អាស៊ី ដែលមនុស្សទាំងអស់ចេះគួរសម សេចក្ដីបង្គាប់នេះ ស្ដាប់ទៅហាក់ដូចជាមិនគួរសមសោះ។ ប៉ុន្តែកុំភ្លេចថា គ្រូក្លែងក្លាយ គឺជាចចកពាក់រោមចៀម។ ទោះបីជាគាត់រាក់ទាក់ និងមានចិត្តចង់ជួយក៏ដោយ ការបង្រៀនរបស់គាត់ នឹងបំផ្លាញហ្វូងចៀម។ សូម្បីតែនិយាយថា «សូមព្រះប្រទានពរ» ក៏ធ្វើឲ្យយើងមានចំណែកក្នុងការអាក្រក់របស់គាត់ដែរ។

## *២យ៉ូហាន ខ១២-១៣*

*ខ្ញុំមានសេចក្ដីជាច្រើននឹងសរសេរផ្ញើមកអ្នករាល់គ្នា តែមិនចង់សរសេរនៅក្រដាសដោយទឹកខ្មៅនោះទេ ដ្បិតខ្ញុំសង្ឃឹមថា នឹងមកសួរអ្នករាល់គ្នា ហើយនឹងនិយាយផ្ទាល់មាត់វិញ ដើម្បីឲ្យសេចក្ដីអំណររបស់យើងរាល់គ្នា ចំរើនបានពោរពេញឡើង*
*១៣ ឯកូនចៅរបស់ប្អូនស្រីរើសតាំង របស់លោកស្រី ក៏សូមជំរាបសួរមកលោកស្រីដែរ។*

លោកយ៉ូហាន រំឮកក្រុមជំនុំនេះថា ពួកគេមិននៅឯកោទេ។ ព្រះជាម្ចាស់គង់នៅជាមួយពួកគេជានិច្ច ហើយក្រុមជំនុំឯទៀត («ប្អូនស្រីរើសតាំង») ក៏កំពុងឈរជាមួយពួកគេនៅក្នុងការប្រឆាំងនឹងការបង្រៀនក្លែងក្លាយ។ ក្រុមជំនុំពិតត្រូវចូលរួមគ្នា ក្នុងការប្រឆាំងទាស់នឹងសេចក្ដីបង្រៀនខុសឆ្គង។

# យ៉ូហានខ្សែទី៣

## *៣យ៉ូហាន ៩១*

*សំបុត្រអ្នកចាស់ទុំផ្ញើមកអ្នកកៃយុស ជាអ្នកស្ងួនភ្ញាដែលខ្ញុំស្រឡាញ់ពិតប្រាកដ។*

កៃយុស គឺជាអ្នកដឹកនាំម្នាក់ក្នុងចំណោមអ្នកដឹកនាំក្រុមជំនុំនេះ។ នៅខ ៩ យើងនឹងជួបអ្នកដឹកនាំម្នាក់ទៀត ឈ្មោះឌីអូត្រេព ដែលក្រអឺតក្រទម ហើយមិនចុះចូល នឹងអំណាចរបស់សាវកយ៉ូហានទេ។

## *៣យ៉ូហាន ៩២-៤*

*អ្នកស្ងួនភ្ញាអើយ ខ្ញុំប្រាថ្នាចង់ឲ្យអ្នកបានចំរើនឡើងគ្រប់ជំពូក ហើយឲ្យបានសុខសប្បាយខាងរូបសាច់ ដូចជាព្រលឹងអ្នកបានចំរើនឡើង [៣] ដ្បិតខ្ញុំបានអរជាខ្លាំងណាស់ ដោយមានបងប្អូនមកធ្វើបន្ទាល់ពីសេចក្តីពិត ដែលនៅក្នុងអ្នក ដូចជាអ្នកធ្លាប់ប្រព្រឹត្តតាមសេចក្តីពិតនោះ [៤] គ្មានសេចក្តីណាដែលនាំឲ្យខ្ញុំអរសប្បាយលើសជាងសេចក្តីនេះទេ គឺដែលឮនិយាយថា ពួកកូនខ្ញុំកំពុងតែប្រព្រឹត្តតាមសេចក្តីពិតនោះឯង។*

ការបង្រៀនអំពីសេចក្តីពិតរបស់ព្រះនៅក្នុងបទគម្ពីរ នាំមកនូវសុខភាពខាងវិញ្ញាណ។ លោកយ៉ូហាន តែងតែអធិស្ឋានឲ្យកៃយុស និងសមាជិកក្រុមជំនុំផ្សេងទៀត ហើយរីករាយណាស់ដែលបានឮថា ពួកគេកំពុងដើរតាមសេចក្តីពិតដែលពួកគេបានទទួលតាំងពីដើមមក។ លោកយ៉ូហាន ដឹងច្បាស់ថា កូនពិតរបស់ព្រះ នឹងដើរក្នុងសេចក្តីពិត។




*«គ្មានសេចក្ដីណាដែលនាំឲ្យខ្ញុំអរសប្បាយលើសជាងសេចក្ដីនេះទេ គឺដែលឮនិយាយថា ពួកកូនខ្ញុំកំពុងតែប្រព្រឹត្តតាមសេចក្ដីពិត»។ (៣យ៉ូហាន ៤)*

## *៣យ៉ូហាន ៥-៨*

*អ្នកស្ងួនភ្ងាអើយ ការអ្វីដែលអ្នកធ្វើសម្រាប់ពួកបងប្អូន និងពួកដទៃដែរនោះអ្នកក៏ធ្វើដោយស្មោះត្រង់គ្រប់ទាំងអស់ហើយ ⁶ គេក៏បានធ្វើបន្ទាល់ពីសេចក្ដីស្រឡាញ់របស់អ្នកនៅមុខពួកជំនុំផង បើអ្នកនឹងជួយតម្រង់អ្នកទាំងនោះ តាមបែបគួរនឹងព្រះ នោះបានល្អហើយ ⁷ ដ្បិតគេបានចេញដើរទៅដោយព្រោះព្រះនាមទ្រង់ ឥតមានទទួលអ្វីពីសាសន៍ដទៃឡើយ ⁸ ដូច្នេះយើងរាល់គ្នាត្រូវជួយទំនុកបំរុងដល់មនុស្សយ៉ាងនោះ ដើម្បីឲ្យយើងបានធ្វើការជាមួយនឹងគេក្នុងសេចក្ដីពិត។*

លោកយ៉ូហានបានបញ្ជូនបេសកជនមួយចំនួនទៅសួរសុខទុក្ខក្រុមជំនុំនេះ និងក្រុមជំនុំឯទៀត។ (ទំនងជាបេសកជននេះ បានយកសំបុត្រពីលោកយ៉ូហានទៅឲ្យពួកគេ)។ នៅពេលដែលបេសកជនស្មោះត្រង់ទាំងនេះបន្តដំណើររបស់ពួកគេ លោកយ៉ូហាន សង្ឃឹមថា ក្រុមជំនុំនេះ នឹងផ្តល់ជង្វាយដល់ពួកគេ ដើម្បីពួកគេអាចបញ្ចប់បេសកកម្មដោយជោគជ័យ។ ដូចជា វិនិយោគិនឆ្លាតតែងតែស្វែងរកឱកាសថ្មីៗ ដើម្បីវិនិយោគ នោះគ្រីស្ទបរិស័ទនិងក្រុមជំនុំដែលមានប្រាជ្ញា ក៏តែងតែស្វែងរកឱកាសគាំទ្រ អ្នកផ្សាយដំណឹងល្អស្មោះត្រង់។ ផលចំណេញនៃការវិនិយោគនោះនឹងមានទំហំធំ និងអស់កល្បជានិច្ច។

### *៣យ៉ូហាន ១៩-១០*

*ខ្ញុំបានផ្ញើសំបុត្រផ្ញើមកពួកជំនុំ ប៉ុន្តែអ្នកឌីអូត្រេព ដែលចូលចិត្តចង់ធ្វើធំក្នុងពួកនោះ គាត់មិនទទួលយើងទេ* [10] *ដូច្នេះ បើខ្ញុំមក ខ្ញុំនឹងនឹកចាំពីការដែលអ្នកនោះធ្វើ ដោយគាត់ពោលពាក្យអាក្រក់ និយាយដើមយើង ហើយមិនស្កប់ចិត្តនឹងសេចក្តីនោះតែប៉ុណ្ណោះ ថែមទាំងមិនព្រមទទួលពួកបងប្អូនទៀតផង ហើយបើមានអ្នកណាចង់ទទួលគេ នោះគាត់ក៏ហាមឃាត់មិនឲ្យទទួលវិញ ព្រមទាំងកាត់គេចេញពីក្រុមជំនុំផង។*

ឌីអូត្រេព មិនមែនជាគ្រូក្លែងក្លាយទេ តែជាអ្នកដឹកនាំគ្រីស្ទបរិស័ទ ដែលមិនស្តាប់បង្គាប់។ យើងមិនគួរទាក់ទងនឹងគ្រូក្លែងក្លាយទេ តែយើងត្រូវតែស្រឡាញ់ និងកែតម្រង់ព្រមទាំងទូន្មានគ្រីស្ទបរិស័ទដែលមិនស្តាប់បង្គាប់។ ពេលខ្លះអ្នកដឹកនាំដែលមិនស្តាប់បង្គាប់បែបនេះ នឹងមិនស្តាប់ការកែតម្រង់របស់ក្រុមជំនុំ ហើយនឹងពង្រឹងចិត្តរបស់ខ្លួន។ ពេលខ្លះគាត់អាចធ្វើជាអ្នកដឹកនាំក្រុមខុសឆ្គងវិញ។ ឌីអូត្រេព បានបង្ហាញការដឹកនាំខ្លាំងពេកហើយ ដោយបណ្តេញពួកគ្រីស្ទបរិស័ទល្អៗចេញពីក្រុមជំនុំ ដោយសារតែពួកគេមិនយល់ព្រមជាមួយគាត់។ គាត់ក៏មិនព្រមចុះចូលចំពោះសាវករបស់ព្រះគ្រីស្ទ។ បើ ឌីអូត្រេព មិនប្រែចិត្តទេ គាត់ប្រាកដជាក្លាយជាគ្រូក្លែងក្លាយហើយ។

### *៣យ៉ូហាន ១១១*

*អ្នកស្ងួនភ្ងាអើយ ចូរត្រាប់តាមសេចក្តីល្អ កុំឲ្យតាមសេចក្តីអាក្រក់ឲ្យសោះ អ្នកណាដែលប្រព្រឹត្តល្អ នោះមកពីព្រះ តែអ្នកណាដែលប្រព្រឹត្តអាក្រក់ នោះមិនបានឃើញព្រះឡើយ។*




*«អ្នកណាដែលប្រព្រឹត្តល្អ នោះមកពីព្រះ»។ (៣យ៉ូហាន ខ១១)*

## *៣យ៉ូហាន ខ១២*

*មនុស្សទាំងអស់ ព្រមទាំងសេចក្តីពិត ក៏ធ្វើបន្ទាល់យ៉ាងល្អពីអ្នកដេមេទ្រាស យើងខ្ញុំក៏ធ្វើបន្ទាល់ដែរ ហើយអ្នករាល់គ្នាដឹងថា សេចក្តីបន្ទាល់របស់យើងនោះពិតប្រាកដមែន។*

លោក ដេមេទ្រាស ជាសមាជិកម្នាក់ទៀត នៃក្រុមជំនុំនេះ (ឬប្រហែលជាគ្រូបង្រៀនដែលចង់មកសួរសុខទុក្ខ ឬចង់ផ្លាស់មករស់នៅទីនោះ)។ ត្រូវចាំថា គ្រូពិតប្រាកដមានទាំងគោលជំនឿល្អ និងមានកេរ្តិ៍ឈ្មោះល្អ។ ដេមេទ្រាសមានទាំងពីរ។ គាត់មិនត្រឹមតែមាន *«បន្ទាល់ល្អ»* (កេរ្តិ៍ឈ្មោះ) ប៉ុណ្ណោះទេ ប៉ុន្តែ *«សេចក្តីពិត»* ក៏ធ្វើបន្ទាល់ថា គាត់សមនឹងទទួលបានកិត្តិយស និងភាពជាអ្នកដឹកនាំ។ លោកយ៉ូហានបានមានប្រសាសន៍ប្រាប់យើងនៅខ១១ថា នេះជាមនុស្សដែលយើងគួរយកតម្រាប់តាម។

## *៣យ៉ូហាន ខ១៣-១៥*

*ខ្ញុំមានសេចក្តីជាច្រើននឹងសរសេរផ្ញើមក តែខ្ញុំមិនចង់សរសេរដោយស្លាបប្រកា និងទឹកខ្មៅទេ។ ¹⁴ ដោយខ្ញុំសង្ឃឹមថា នឹងមកសួរអ្នករាល់គ្នាយ៉ាងឆាប់ហើយនឹងនិយាយដោយផ្ទាល់មាត់វិញ ¹⁵ សូមឲ្យអ្នកបានប្រកបដោយសេចក្តីសុខ ពួកសម្លាញ់ខាងណោះ គេជំរាបសួរមកអ្នក សូមជំរាបសួរដល់ពួកសម្លាញ់ខាងណេះ តាមឈ្មោះគេរៀងខ្លួនផង។*

*«សូមឲ្យអ្នកបានប្រកបដោយសេចក្ដីសុខ»* ក្រុមជំនុំដែលអនុញ្ញាតឲ្យមានគ្រូខុសឆ្គងនៅ មិនដែលមានសេចក្ដីសុខសាន្តឡើយ។ សេចក្ដីសុខសាន្ត និងការរួបរួមគ្នា គឺជាលទ្ធផលនៃសេចក្ដីពិត និងសេចក្ដីស្រឡាញ់។

> *«ចូរបណ្ដេញមនុស្សដែលចំអកមើលងាយ នោះសេចក្ដីទាស់ទែងគ្នា នឹងបាត់ទៅ អើសេចក្ដីឈ្លោះប្រកែកនឹងសេចក្ដីត្មះតិះដៀលនឹងស្ងប់ទៅដែរ»* (សុភាសិត ២២៖១០)។

> *«ឯមនុស្សណាដែលបង្កើតបក្សពួក នោះត្រូវកាត់គេចោលចេញ ក្នុងពេលក្រោយដែលទូន្មានប្រដៅគេម្ដងពីរហើយ»* (ទីតុស ៣៖១០)។

សេចក្ដីអត្ថាធិប្បាយនៃកណ្ឌយ៉ូហានខ្សែទី១ ទី២ និងទី៣ ចប់តែប៉ុណ្ណេះ។

---

ដូចជាបុគ្គលិកធនាគារចំណាយពេលរាប់សិបម៉ោង ដើម្បីស្រាវជ្រាវ ពីក្រដាសប្រាក់ពិតប្រាកដ មុននឹងប៉ះក្រដាសប្រាក់ក្លែងក្លាយ យើងក៏បានចំណាយពេលរាប់សិបម៉ោង ក្នុងការស្រាវជ្រាវដំណឹងល្អពិត ហើយនិងព្រះគ្រីស្ទពិត ក្នុងសំបុត្ររបស់លោកយ៉ូហាន។

ឥឡូវយើងដល់ពេលសិក្សាដំណឹងល្អក្លែងក្លាយ គ្រូបង្រៀនក្លែងក្លាយ និងព្រះគ្រីស្ទក្លែងក្លាយ នៅផ្នែកទី២។

ផ្នែកទី២

# សាសនាក្លែងក្លាយ

## ក្រុមក្លែងក្លាយនៅអាស៊ី និងពិភពលោក

# ការប្រើការវិនិច្ឆ័យនៅសំបុត្រយ៉ូហាន និងបទគម្ពីរឯទៀត ដើម្បីស្គាល់គ្រូខុសឆ្គង និងការបង្រៀនខុសឆ្គង

សូមចាំថា នៅ១យ៉ូហាន ២:១៥-១៩ សាវកយ៉ូហានបានព្រមានយើង ពីសេចក្តីអាក្រក់ពីរប្រភេទ គឺសេចក្តីអាក្រក់ខាងលោកីយ៍ និងសេចក្តីអាក្រក់ខាងអាទទឹងនឹងព្រះគ្រីស្ទ (អង់ទីគ្រីស្ទ)។ ក្រុមខុសឆ្គងនីមួយៗដែលយើងនឹងសិក្សា គឺជាក្រុមខុសឆ្គងអង់ទីគ្រីស្ទ មានន័យថា គេផ្តល់ព្រះគ្រីស្ទក្លែងក្លាយ ជំនួសព្រះគ្រីស្ទពិត ហើយគ្រីស្ទសាសនាក្លែងក្លាយ ជំនួសគ្រីស្ទសាសនាពិត។ ក្រុមនេះក៏អះអាងថា គេផ្តល់ «ការដែលសក្តិសមរស់ដើម្បី និងស្លាប់ដើម្បី»។ នេះជាមូលហេតុដែលសមាជិកនៃក្រុមខុសឆ្គងទាំងនេះ ប្រគល់ខ្លួនគេ និងទ្រព្យសម្បត្តិរបស់គេទាំងស្រុងទៅគ្រូក្លែងក្លាយ ដូចដែលជាគ្រីស្ទបរិស័ទពិតប្រាកដ បានលះបង់ជីវិតរបស់គេទាំងស្រុងចំពោះព្រះដែរ។

## គ្រីស្ទសាសនាក្លែងក្លាយ

ប៉ុន្មានឆ្នាំមុន ខ្ញុំបានទៅសួរសុខទុក្ខមន្ត្រីជាន់ខ្ពស់នៅក្រសួងធម្មការ និងសាសនានៅភ្នំពេញ។ ខ្ញុំបានសួរគាត់ថា តើឯកឧត្តមធ្លាប់ឆ្ងល់ទេ ហេតុអ្វីបានជាក្រុមប្រឹក្សាគ្រីស្ទសាសនាទាំងអស់នៅកម្ពុជាបដិសេធក្រុមមរមន។ គាត់បាននិយាយថា គាត់ពិតជាឆ្ងល់អំពីរឿងនេះដោយសារពួកមរមន អះអាងថា គេជឿលើព្រះយេស៊ូវគ្រីស្ទដែរ។ ខ្ញុំបានពន្យល់ដោយប្រាប់រឿងមួយ៖

> **ឧបមាថា** មនុស្សម្នាក់មកជួបឯកឧត្តមនៅក្រសួង ដើម្បីសុំច្បាប់បង្កើតនិកាយព្រះពុទ្ធសាសនាថ្មីនៅប្រទេសកម្ពុជា។ ឯកឧត្តមបានសួរថា «សូម

> ប្រាប់ខ្ញុំអំពីនិកាយព្រះពុទ្ធសាសនារបស់អ្នក»។ បុរសនេះបានឆ្លើយថា «និកាយរបស់យើងជឿថា ព្រះពុទ្ធគឺជាបុរសជនជាតិអាហ្វ្រិកម្នាក់ ដែលរស់នៅក្នុងប្រទេសកេនញ៉ានៅសតវត្សរ៍ទី១៩។ ព្រះពុទ្ធយើងបានបង្រៀនថា ការសម្លាប់សត្វ និងបរិភោគសត្វជាការល្អ។ លោកក៏បានបង្រៀនផងដែរថា ការផឹកស្រា គឺជាផ្នែកមួយដ៏សំខាន់នៃការគោរពបូជាព្រះពុទ្ធសាសនា។ លោកក៏បង្រៀនទៀតថា ការចាប់បដិសន្ធិឡើងវិញមិនមែនជាការពិតទេ។ ដូច្នេះតើយើងអាចសុំច្បាប់បង្កើតនិកាយព្រះពុទ្ធសាសនានេះ នៅក្នុងប្រទេសកម្ពុជាបានទេ?»

តើមន្ត្រីនោះគួរឆ្លើយយ៉ាងម៉េចទៅបុរសនោះ? ប្រហែលគាត់នឹងឆ្លើយថា ព្រះពុទ្ធពិតប្រាកដមិនមែនជាជនជាតិអាហ្វ្រិកទេ ហើយព្រះពុទ្ធពិតប្រាកដ មិនបានបង្រៀនសេចក្ដីទាំងនេះអំពីការសម្លាប់សត្វ ការផឹកស្រា និងការចាប់បដិសន្ធិបែបនោះទេ។ ប្រហែលគាត់នឹងប្រាប់បុរសនោះទៀតថា និកាយរបស់គាត់មិនមែនជាពុទ្ធសាសនាទាល់តែសោះ សូម្បីតែគេប្រើឈ្មោះ«ព្រះពុទ្ធសាសនា»ក៏ដោយ។ គាត់មុខជានឹងប្រាប់បុរសនោះថា និកាយរបស់គាត់ជានិកាយក្លែងក្លាយហើយ!

គ្រីស្ទបរិស័ទយើងមានគំនិតដូចគ្នាអំពីក្រុមខុសឆ្គងទាំងអស់។ ក្រុមទាំងអស់នេះយកឈ្មោះ«គ្រីស្ទសាសនា» «ព្រះយេស៊ូវ» និង«ព្រះជាម្ចាស់» ។ល។ ហើយឲ្យអត្ថន័យដល់ពាក្យទាំងនោះខុសពីអត្ថន័យគ្រីស្ទសាសនាពិត។

នេះជាមូលហេតុដែលគ្រីស្ទបរិស័ទពិត បដិសេធក្រុមខុសឆ្គងទាំងអស់ ដែលបានមកដល់អាស៊ីអាគ្នេយ៍ ពីអាមេរិក អឺរ៉ុប អាស៊ី និងអាហ្វ្រិក។ នៅផ្នែកទី២នេះ យើងនឹងផ្ដល់អត្ថបទ អំពីក្រុមខុសឆ្គង១១ក្រុមនៅអាស៊ី និងតំបន់ឯទៀត។ សូម្បីតែយើងមិនពិភាក្សាអំពីក្រុមខុសឆ្គងមួយដែលអ្នកចាប់អារម្មណ៍ ឬបើមានក្រុមខុសឆ្គងថ្មីកើតឡើង អ្នកនៅតែអាចស្គាល់កំហុសឆ្គងរបស់ពួកគេ ហើយការពារក្រុមជំនុំ និងក្រុមគ្រួសាររបស់អ្នក ដោយប្រើគោលការណ៍ ដែលយើងបានរៀននៅក្នុងកណ្ឌគម្ពីរ

យ៉ូហានខ្សែទី១ និងបទគម្ពីរផ្សេងទៀត។ ប្រយោគវិនិច្ឆ័យរបស់សាវកយ៉ូហាននៅសតវត្សរ៍ទី១ នៅតែមានប្រយោជន៍រហូតមកដល់សព្វថ្ងៃនេះ ពីព្រោះសាតាំងតែងតែប្រើការកុហកដដែលៗ នៅគ្រប់សតវត្សរ៍។

## ការវិនិច្ឆ័យ១០

យើងនឹងប្រើការវិនិច្ឆ័យ១០ពីកណ្ឌគម្ពីរយ៉ូហានខ្សែទី១ និងបទគម្ពីរផ្សេងទៀត ដើម្បីល្បងលក្រុមខុសឆ្គងទាំងនេះ។ យើងនឹងមិនប្រើការវិនិច្ឆ័យទាំងអស់ ទៅលើក្រុមខុសឆ្គងទាំងអស់នោះទេ គឺប្រើតែការវិនិច្ឆ័យដែលចាំបាច់សម្រាប់ក្រុមខុសឆ្គងនីមួយៗតែប៉ុណ្ណោះ។

១. **ការវិនិច្ឆ័យនៃដំណឹងល្អ។** តើពួកគេជឿថា សេចក្ដីសង្គ្រោះកើតឡើងតាមរយៈតែការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ឬក៏ពួកគេផ្សាយដំណឹងល្អផ្សេងទៀត? ហើយអះអាងថា សេចក្ដីសង្គ្រោះមានតែតាមរយៈក្រុមរបស់ពួកគេ? (កាឡាទី ១:៦-៩; ២កូរិនថូស ១១:៤; ១យ៉ូហាន ១:២; ២:២៥; ៥:១១; ៥:១៣; ដំណឹងល្អយ៉ូហាន ៣:១៥-១៦; ៣:៣៦; ៥:២៤; ៦:៤០;១៧:៣; ២០:៣)

២. **ការវិនិច្ឆ័យនៃព្រះយេស៊ូវដ៏ពិត។** តើពួកគេទទួលយកព្រះយេស៊ូវដូចគ្នា ដែលព្រះជាម្ចាស់បានសម្ដែង និងពួកសាវកបានធ្វើជាសាក្សី ឬពួកគេដើរក្នុងសេចក្ដីងងឹត ដោយផ្ដល់ព្រះគ្រីស្ទផ្សេង (អង់ទីគ្រីស្ទ) ជំនួសឲ្យព្រះគ្រីស្ទពិត? តើព្រះគ្រីស្ទរបស់ពួកគេមានពង្សាវតារដែលបញ្ជាក់ថា គាត់ជាកូនចៅរបស់អ័ប្រាហាំ និងស្ដេចដាវីឌទេ? ពាក្យ «គ្រីស្ទ»មានន័យថា «ព្រះមែស៊ី» ហើយព្រះមែស៊ីពិតប្រាកដ ត្រូវតែជាកូនចៅរបស់អ័ប្រាហាំ និងស្ដេចដាវីឌ។ (១យ៉ូហាន ១:១-៧ និង ២:១៨-២៥ និង ៤:១-៣; ២កូរិនថូស ១១:៤)

៣. **ការវិនិច្ឆ័យនៃការរស់នៅរបៀបបរិសុទ្ធ។** តើពួកគេធ្វើតាមបញ្ញត្តិរបស់ព្រះ ដើម្បីរស់នៅក្នុងជីវិតដ៏បរិសុទ្ធ ឬគេមានចិត្តកាច ចិត្តលោភលន់ និងអសីលធម៌ខាងផ្លូវភេទ? (១យ៉ូហាន ២:៣-៦ និង ៣:៤-១០)

៤. **ការវិនិច្ឆ័យនៃសេចក្តីស្រឡាញ់។** តើពួកគេមានចិត្តស្រឡាញ់ដ៏រាបទាប ឬមានចិត្តធំ ហើយព្យាយាមត្រួតត្រា គំរាមកំហែង និងបំភិតបំភ័យសមាជិករបស់ពួកគេ? តើពួកគេរស់នៅដូចស្តេច និងមហាក្សត្រី នៅពេលដែលអ្នកដើរតាមពួកគេត្រូវបានបង្ខំឲ្យធ្វើការ ដោយទទួលបានប្រាក់ខែទាប? (១យ៉ូហាន ២:៧-១១ និង៣:១១-១៨ និង ៤:៧-១២; ២កូរិនថូស ១១:១៩-២១)

៥. **ការវិនិច្ឆ័យនៃព្រះបន្ទូល។** តើពួកគេទទួលយក និងគោរពដល់ព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី ឬពួកគេមើលងាយគម្ពីរ ឬក៏បន្ថែម«គម្ពីររបស់គេ» ជំនួសព្រះគម្ពីរប៊ីប? តើពួកគេនិយាយថា ព្រះរាជសារក្នុងព្រះគម្ពីរគ្មានអំណាច ឬមានកំហុស ឬមិនមែនសម្រាប់សម័យកាលយើងទេ? (១យ៉ូហាន១:៤; ២:១២-១៤; ៥:១៣ និងដំណឹងល្អយ៉ូហាន ១០:៣៥ និង ២០:៣១)

៦. **ការវិនិច្ឆ័យនៃព្រះត្រៃឯក។** តើពួកគេជឿលទ្ធិ ព្រះត្រៃឯក ដែលបានសម្តែងក្នុងព្រះគម្ពីរ និងពន្យល់នៅក្នុងគោលជំនឿផ្សេងៗនៃក្រុមជំនុំឬទេ (ដូចជាគោលជំនឿណៃសៀជាដើម)? (១យ៉ូហាន ៤:១៣-១៤; ម៉ាថាយ ២៨:១៩)

៧. **ការវិនិច្ឆ័យនៃដំណោះស្រាយអំពើបាបក្នុងជីវិតគ្រីស្ទបរិស័ទ។** តើពួកគេនិយាយថា គ្រីស្ទបរិស័ទគ្មានបាបទេ ដូច្នេះមិនចាំបាច់លន់តួអំពើបាប? (១យ៉ូហាន ១:៨-២:២; លូកា ១១:៤)

៨. **ការវិនិច្ឆ័យនៃទំនាយ។** តើគេធ្វើទំនាយខុសឬទេ? (ចោទិយកថា ១៨:២០-២២; ២ពេត្រុស ២:១-៣; ម៉ាកុស ១៣:២២; ម៉ាថាយ ៧:១៥, ២៤:១១ និង២៤)

៩. **ការវិនិច្ឆ័យនៃការបំបែកបំបាក់ក្រុមជំនុំ និងការអះអាងថា ពួកគេជាក្រុមត្រឹមត្រូវផ្តាច់មុខ។** តើពួកគេព្យាយាមបំបែកក្រុមជំនុំដែលមានស្រាប់ ដោយនិយាយថា ពួកគេជាក្រុមជំនុំពិតតែមួយ ហើយសេចក្តីសង្គ្រោះមានតែតាមរយៈពួកគេតែប៉ុណ្ណោះឬទេ? (ទីតុស៣:១០-១១)

១០. **ការវិនិច្ឆ័យនៃសមាមាត្រ។** តើពួកគេវាយតម្លៃខុស ដោយរាប់ការសំខាន់ទៅជាមិនសំខាន់វិញ ហើយរាប់ការដែលមិនសំខាន់ ឲ្យទៅជាសំខាន់បំផុតវិញ ដូចពួកផារីស៊ីបានធ្វើឬទេ? (ម៉ាថាយ ២៣:២៤)

## មិនមានគោលជំនឿខុសឆ្គងថ្មីទេ

អារក្សសាតាំងបានប្រើការកុហកទាំងអស់របស់វាហើយ ក្នុងអំឡុង៥០០ឆ្នាំដំបូងនៃក្រុមជំនុំ។ ក្រុមខុសឆ្គងដែលយើងគិតថាថ្មីនៅសតវត្សរ៍ទី២១ កំពុងបង្រៀនពាក្យកុហកដដែលៗ ដូចដែលអារក្សសាតាំងបានប្រើក្នុង៥សតវត្សរ៍ដំបូង។ (សាតាំងប្រៀបដូចជាជាង ដែលយកម៉ូតូចាស់ ទៅដាក់អំពូលថ្មី និងប្លាស្ទិកថ្មី ដើម្បីលក់ជាថ្មី)។

គ្រីស្ទបរិស័ទដែលមិនដឹងអ្វីទាំងអស់ អំពីប្រវត្តិសាស្ត្រនៃក្រុមជំនុំ នឹងមិនយល់ថា ក្រុមខុសឆ្គងបច្ចុប្បន្ននេះ កំពុងប្រើការកុហកដដែល ដែលសាតាំងបានប្រើ នៅសម័យកាលក្រុមជំនុំដើម។ ព្រះបានប្រទានដល់ពួកជំនុំដំបូង នូវអ្នកដឹកនាំជាច្រើន ដែលមានប្រាជ្ញាវាងវៃ ដែលបានច្បាំងឈ្នះដោយជោគជ័យ ទាស់នឹងគ្រប់ទាំងសេចក្តីកុហកទាំងនេះ។ ពួកគេបានឈ្នះសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះ និងអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។ យើងអាចពឹងផ្អែកលើប្រាជ្ញារបស់ពួកគេ។

> **ឧទាហរណ៍៖** នៅដើមសតវត្សរ៍ទី៤ ក្រុមជំនុំដំបូងបានប្រឆាំងទាស់នឹងគ្រូក្លែងក្លាយឈ្មោះអារីយូស ដែលបង្រៀនថា ព្រះរាជបុត្រានៃព្រះ ត្រូវបានបង្កើតឡើងដោយព្រះវរបិតា ហើយមិនគង់នៅអស់កល្បជានិច្ចទេ។ គ្រីស្ទបរិស័ទជាច្រើន បានចាញ់ការបោកបញ្ឆោតនេះ។ ប៉ុន្តែព្រះបាន

លើកអ្នកដឹកនាំដែលប្រកបដោយការឆ្លាតវៃមកពីព្រះ ដូចជាលោក អាថាណាស៊ីយូស ដើម្បីប្រឆាំងទាស់នឹងអារីយូស ដោយជោគជ័យ នៅក្រុមប្រឹក្សា ណៃសៀនៅ ឆ្នាំ៣២៥ នៃគ.ស។ ប៉ុន្តែការកុហករបស់អារីយូស មិនបានបាត់ទាំងស្រុងនោះទេ។ អារក្សសាតាំងបានប្រើពាក្យកុហករបស់អារីយូសម្តងហើយម្តងទៀត ក្នុងកំឡុងពេល១៧០០ឆ្នាំក្រោយមកទៀត ប៉ុន្តែនៅក្នុងទម្រង់ផ្សេងគ្នា និងតាមរយៈមនុស្សផ្សេងទៀត។ នៅសតវត្សរ៍ទី១៩ ការភូតភររបស់អារីយូសបានត្រឡប់មកវិញ តាមរយៈក្រុមខុសឆ្គង ឈ្មោះ ស្មរបន្ទាល់ព្រះយេហូវ៉ា ដែលនិយាយថា ព្រះយេស៊ូវមិនគង់នៅតាំងពីអស់កល្បជានិច្ចទេ។ ប៉ុន្តែយើងមិនត្រូវភ្លេចថា លោកអាថាណាស៊ូយូស និងអ្នកដឹកនាំឯទៀត បានតយុទ្ធដោយជោគជ័យចំពោះការកុហកទាំងនេះ! យើងមិនចាំបាច់តយុទ្ធនឹងការកុហកដដែលនេះហាក់ដូចជាលើកទី១នោះទេ។ យើងគ្រាន់តែត្រូវប្រឈមមុខសម្រាប់សេចក្តីពិតរបស់ព្រះជាមួយនឹងបងៗរបស់យើងនៅក្រុមជំនុំដំបូង ដែលបានតយុទ្ធ និងយកឈ្នះរួចហើយ កាលពីច្រើនឆ្នាំមុន។

## ឈ្មោះដូចគ្នា មនុស្សផ្សេងគ្នា

ពេលខ្លះមនុស្សនិយាយថា «នោះមិនមែនជាក្រុមខុសឆ្គងទេ ពួកគេជឿព្រះយេស៊ូវដូចយើងដែរ»។ ប៉ុន្តែកុំភ្លេចថា ក្រុមខុសឆ្គងប្រើឈ្មោះ និងពាក្យដូចគ្នានឹងយើងដែរ ប៉ុន្តែប្តូរអត្ថន័យនៃឈ្មោះ និងពាក្យទាំងនោះ។

**ឧបមាថា** អ្នកជួបមនុស្សម្នាក់ដែលនិយាយថា គាត់ស្គាល់ ចេ. ឌី. ក្រោលី ដែរ។ អ្នកសួរគាត់ថា «អូ! តើអ្នកស្គាល់ ចេ. ឌី.ដោយសារអ្វី?» គាត់ឆ្លើយថា «ពេលខ្ញុំរាននៅប្រទេសរុស្ស៊ី ខ្ញុំបានជួបគាត់នៅទីនោះ»។ អ្នកនិយាយថា «អូ ប៉ុន្តែ ចេ. ឌី. មិនដែលរស់នៅក្នុងប្រទេសរុស្ស៊ីទេ។ តើអ្នកប្រាកដទេថាពិតជា ចេ. ឌី. ក្រោលី ដូចគ្នាឬ? តើគាត់មើលទៅដូចអ្វី?» បុរសនោះឆ្លើយថា «គាត់ទាប ហើយទំពែក មានស្បែកខ្មៅ ហើយគាត់ធ្វើការជាវិស្វករ»។ អ្នកក៏ពន្យល់ថា «អូ នោះគឺជា ចេ. ឌី. ក្រោលី ផ្សេង។ ចេ. ឌី.

ក្រោលី ដែលខ្ញុំស្គាល់ គាត់មានមាឌខ្ពស់ មានសក់ពណ៌ត្នោត ហើយជាគ្រូបង្រៀនព្រះគម្ពីរ។ ពីរនាក់នោះមានឈ្មោះដូចគ្នា ប៉ុន្តែជាមនុស្សផ្សេងគ្នា»។

ដូចគ្នាដែរ យើងមិនត្រូវចាញ់បញ្ឆោតពីក្រុមខុសឆ្គង ដែលនិយាយអំពី «ព្រះ» និង«គ្រីស្ទ» និង«ដំណឹងល្អ» ទេ ប៉ុន្តែកំពុងនិយាយអំពីព្រះផ្សេង ព្រះគ្រីស្ទផ្សេង និងដំណឹងល្អផ្សេង។ យើងត្រូវតែនិយាយថា «សូមប្រាប់ខ្ញុំអំពីព្រះដែលអ្នកជឿ។ សូមប្រាប់ខ្ញុំអំពីព្រះគ្រីស្ទរបស់អ្នក។ សូមពន្យល់ប្រាប់ខ្ញុំពីដំណឹងល្អរបស់អ្នក»។ នេះជាមធ្យោបាយតែមួយគត់ ដែលយើងអាចដឹងថា ជាការពិត ឬក្លែងក្លាយនោះ។ យើងត្រូវហ៊ានសួរសំណួរដូចនេះ ម្តងហើយម្តងទៀត៖

«តើព្រះរាជបុត្រានៃព្រះមានដើមដំបូងទេ ឬទ្រង់គង់នៅតាំងពីអស់កល្បជានិច្ចមក?»

«តើព្រះគ្រីស្ទរបស់អ្នកបានរស់ពីស្លាប់ឡើងវិញទាំងរូបកាយទេ?»

«តើមានព្រះប៉ុន្មាន?»

«តើយើងត្រូវធ្វើអ្វីដើម្បីឲ្យបានសង្គ្រោះ?»

«តើក្រុមរបស់អ្នក គឺជាផ្លូវតែមួយទៅឋានសួគ៌ឬ?» ។ល។

## អ្នកណាដែលអះអាងថា ខ្លួនជាព្រះគ្រីស្ទ ត្រូវតែមានភ័ស្តុតាងបញ្ជាក់ថា គាត់គឺជាពូជពង្សរបស់ស្តេចដាវីឌ

ក្នុងភាសាហេព្រើរ ពាក្យ «មែស៊ី» សំដៅទៅស្តេចចាក់ប្រេងតាំងរបស់អ៊ីស្រាអែល ដែលនឹងមកសង្គ្រោះយើងពីអំពើបាប។ ក្នុងភាសាក្រេក ពាក្យ «មែស៊ី» បកប្រែថា «គ្រីស្ទ»។ អ្នកណាដែលអះអាងថា ខ្លួនជាព្រះគ្រីស្ទ ត្រូវតែផ្តល់ភ័ស្តុតាងតាមរយៈខ្សែស្រឡាយថា គាត់គឺជាពូជពង្សរបស់ អ័ប្រាហាំ និង ស្តេចដាវីឌ ដូចពង្សាវតារ

របស់ព្រះយេស៊ូវនៅក្នុងកណ្ឌគម្ពីរលូកា ៣:២៣-៣៨ (ហើយនិង នៅ ម៉ាថាយ ១:១-១៦)។

### មានតែព្រះយេស៊ូវគ្រីស្ទពីស្រុកណាសារ៉ែតទេ ដែលជាអ័ដាមទីពីរ និងអ័ដាមចុងក្រោយ

ព្រះជាម្ចាស់បានបង្កើតអ័ដាម ដើម្បីធ្វើជាតំណាងនៃមនុស្សជាតិទាំងអស់ ក្នុងការថែរក្សាពិភពលោក នៅក្រោមអំណាចល្អរបស់ព្រះជាម្ចាស់។ ប៉ុន្តែអ័ដាមមិនបានស្តាប់បង្គាប់ព្រះជាម្ចាស់ ដូច្នេះមនុស្សជាតិ បានធ្លាក់ក្រោមអំណាចរបស់សាតាំង អំពើបាប និងសេចក្តីស្លាប់។ តែព្រះបានសន្យាចំពោះអ័ដាម និងអេវ៉ាថា ទ្រង់នឹងបញ្ជូនពូជពង្សម្នាក់របស់ពួកគាត់ («ពូជនាង») មកបំផ្លាញសាតាំង ហើយនាំមនុស្សមកក្រោមអំណាចដ៏សប្បុរសរបស់ព្រះជាម្ចាស់វិញ (លោកុប្បត្តិ ៣:១៥)។

ប៉ុន្តែ ព្រះជាម្ចាស់មិនបានសន្យាថា នឹងបញ្ជូនអ្នកសង្គ្រោះមក**ជាច្រើន**នោះទេ គឺមានតែមួយប៉ុណ្ណោះ។ នោះហើយជាមូលហេតុដែល១កូរិនថូស ១៥:៤៧ ហៅព្រះយេស៊ូវគ្រីស្ទថា ជា *«បុរសទី២»* គឺមានន័យថា អ័ដាមទីពីរ ដែលនឹងយាងមកធ្វើជាតំណាងថ្មីរបស់មនុស្សលោក ហើយធ្វើអ្វីៗដែលអ័ដាមទី១បានបរាជ័យ។ មានអ្នកដឹកនាំសាសនាសំខាន់ៗជាច្រើននាក់ ដែលបានកើតមកក្នុងចន្លោះរាប់ពាន់ឆ្នាំរវាងអ័ដាមទីមួយ និងអ័ដាមទីពីរ (ព្រះគ្រីស្ទ) ដូចជា ម៉ូសេ ខុងជឺ និងព្រះពុទ្ធ ជាដើម។ ប៉ុន្តែ ឋានៈជា «អ័ដាមទីពីរ» បង្ហាញដល់យើងថា មនុស្សទាំងនោះមិនអាចធ្វើជាតំណាងមនុស្សលោក ដើម្បីផ្សះផ្សាព្រះ និងមនុស្សបានឡើយ គឺមានតែព្រះយេស៊ូវពីណាសារ៉ែតជាព្រះរាជបុត្រាតែមួយគត់របស់ព្រះប៉ុណ្ណោះ។

ចុះសម័យបន្ទាប់ពីព្រះយេស៊ូវយាងទៅស្ថានសួគ៌វិញ? តើមានអ័ដាមទី៣ ទី៤ ឬទី៥កើតឡើងទេ? គ្មានទេ។ អ្នកដឹកនាំសាសនាជាច្រើននាក់បានកើតមកបន្ទាប់ពីសម័យព្រះយេស៊ូវ ដូចជា មហាម៉ាត់ (Muhammad) បាហាអ៊ូឡា

(Bahá'u'lláh) អាន់ សាំងហុង (Ahn Sahng-Hong) អាប៉ូឡូ គីបូឡូយ (Apollo Quiboloy) សាន់ ម៉្យុង មូន (Sun Myung Moon) យ៉ាង ស៊ីងប៊ិន (Yang Xiangbin) លី ម៉ាន់ហ៊ី (Lee Man-hee) ជាដើម។ តើអ្នកណាក្នុងចំណោមពួកគេជា អ័ដាមទី៣ ទី៤ ឬទី៥? គ្មានទេ! ធ្វើម៉េចបានដឹង? ពីព្រោះ ១កូរិនថូស ១៥:៤៥ ហៅព្រះយេស៊ូវគ្រីស្ទថា ជា*«អ័ដាមក្រោយបង្អស់»*។ ឋានៈជា *«អ័ដាមក្រោយបង្អស់»* សម្តែងថា គ្មានអ្នកសង្គ្រោះក្រោយព្រះយេស៊ូវទេ។ យើងកំពុងរង់ចាំការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវពីណាសារ៉ែត មិនមែនអ្នកផ្សេងទៀយ។ (Ronald Yu, "Combating the Cult Almighty God Church," ChinaSource Quarterly, Spring 2015)។

## សៀវភៅនេះ គឺជាវ៉ាក់សាំង មិនមែនជាថ្នាំព្យាបាលទេ

យើងផ្តល់វ៉ាក់សាំងដល់អ្នកដែលមិនទាន់ឆ្លងជំងឺ ប៉ុន្តែយើងផ្តល់ថ្នាំព្យាបាលដល់អ្នកដែលបានឆ្លងជំងឺរួចហើយ។ គ្រីស្ទបរិស័ទភាគច្រើននៅក្នុងក្រុមជំនុំរបស់យើងមិនទាន់បានប៉ះពាល់ នឹងការបង្រៀនក្លែងក្លាយរបស់ក្រុមទាំងនេះនៅឡើយទេ។ អ្វីដែលពួកគេត្រូវការ គឺវ៉ាក់សាំង ដើម្បីការពារពួកគេ ក្នុងករណីដែលពួកគេត្រូវបានប៉ះពាល់គោលជំនឿខុសឆ្គង។ នោះហើយជាមូលហេតុដែលយើងមិនត្រឹមតែផ្តល់ព័ត៌មានអំពីគោលលទ្ធិចម្លែករបស់ក្រុមទាំងនេះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានអវិជ្ជមាន អំពីជីវិតដ៏គួរឲ្យខ្ពើមរបស់មេដឹកនាំក្រុមទាំងនេះ ដូចជាព័ត៌មានអំពីភរិយាទាំងប្រាំរបស់លោកសាន់ ម៉្យុង មូន ឬ ភរិយា៥០នាក់របស់ស្ថាបនិកសាសនាមរមន ឬការពិតដែលថា «គ្រីស្ទ» អាន់ សាំងហុង បានស្លាប់ដោយសារជំងឺដាច់សរសៃឈាមខួរក្បាល និងគាំងបេះដូងក្នុងឆ្នាំ ១៩៨៥! ព័ត៌មានអវិជ្ជមានប្រភេទនេះមានប្រយោជន៍ជាវ៉ាក់សាំងការពារគ្រីស្ទបរិស័ទ ពីការទាក់ទាញនៃក្រុមទាំងនេះ ប៉ុន្តែ

ព័ត៌មានអវិជ្ជមានមិនសូវមានប្រសិទ្ធភាពដើម្បីប្រើជា «ថ្នាំព្យាបាល» ដែលជួយសង្គ្រោះអ្នកដែលចាញ់បោកគេរួចទៅហើយនោះទេ។

បើដូចនេះ តើយើងគួរធ្វើអ្វីចំពោះអ្នកដែលបានចូលរួមក្រុមខុសឆ្គងហើយ គឺអ្នកដែល «ឈឺ» រួចហើយ? តើថ្នាំព្យាបាលដែលគេត្រូវការជាអ្វី? ថ្នាំព្យាបាល គឺការឮដំណឹងល្អពិតពីអ្នក ហើយនិងការអានព្រះគម្ពីរពិតជាមួយអ្នក ហើយជួបជាមួយព្រះយេស៊ូវពិត តាមពាក្យ និងសកម្មភាពនៃសេចក្ដីស្រឡាញ់របស់គ្រីស្ទបរិស័ទ។

## មុខពូថៅ 

អ្នកចាំថា នៅក្នុងសេចក្ដីណែនាំអំពីសៀវភៅនេះ យើងបានប្រៀបធៀបកលល្បិចនៃក្រុមខុសឆ្គងទៅនឹងមុខពូថៅ។ ផ្លែពូថៅមានមុខម្ខាងសម្រាប់ចូលឈើ ហើយខ្នងម្ខាងសម្រាប់ដំដែកគោល។ បើយើងពុះឈើដោយមុខពូថៅ វានឹងងាយចូល។ ប៉ុន្តែបើយើងពុះឈើដោយខ្នងពូថៅវិញ វានឹងមិនចូលសោះ។ មុខពូថៅតំណាងសេចក្ដីបង្រៀនស្រាលដែលក្រុមខុសឆ្គងចង់និយាយមុន ពីព្រោះសេចក្ដីទាំងនោះងាយចូលក្នុងចិត្តគំនិតយើងជាង។ ខ្នងពូថៅ តំណាងឲ្យគោលលទ្ធិអាក្រក់បំផុត គឺជាជំនឿដែលសមាជិកក្រុមខុសឆ្គងចង់លាក់សិន ពីព្រោះពួកគេដឹងថា គ្រីស្ទបរិស័ទនឹងបដិសេធសេចក្ដីនោះភ្លាម។ ប៉ុន្តែកុំភ្លេច បើមុខពូថៅ ចូលក្នុងឈើ ខ្នងពូថៅនឹងចូលមកតាមក្រោយភ្លាម ហើយបំបែកឈើជាពីរ! បើយើងទទួលយកការបង្រៀនតូចៗរបស់គ្រូក្លែងក្លាយ មិនយូរមិនឆាប់យើងក៏នឹងទទួលយកការបង្រៀនអាក្រក់ក្រៃលែងដែលនឹងបំបែកយើងពីសេចក្ដីពិត ហើយនឹងបញ្ជូនយើងទៅឋាននរកដែរ។

នៅចុងអត្ថបទក្រុមខុសឆ្គងនីមួយៗ ខ្ញុំនឹងបន្ថែមផ្នែកមួយថា «មុខពូថៅ» ដែលនឹងបង្ហាញពីសេចក្តីណា ដែលក្រុមខុសឆ្គងចង់បង្រៀនពីដំបូង(មុខពូថៅ)ព្រោះវាងាយចូល។ យើងក៏នឹងបង្ហាញពីគោលជំនឿដ៏ប្រមាថ ដែលគេចង់លាក់រហូតដល់ពេលក្រោយ(ខ្នងពូថៅ)។

ទីបញ្ចប់ សូមកុំភ្លេច ២យ៉ូហាន ១:១០-១១ ចែងថា ៖ *«បើអ្នកណាមកឯអ្នករាល់គ្នា តែមិនបង្រៀនចំពោះសេចក្តីនេះ នោះកុំឲ្យទទួលអ្នកនោះនៅក្នុងផ្ទះឡើយ កុំឲ្យទាំងជំរាបសួរដល់អ្នកនោះផង ដ្បិតបើអ្នកណាជំរាបសួរនោះក៏តែងមានសេចក្តីប្រកបគ្នាក្នុងការអាក្រក់របស់អ្នកនោះដែរ»*។

# អាន់ សាំងហុង និង ហ្សាង គីល ចា («ព្រះមាតា»)

**Ahn Sahng-Hong and Zahng Gil Jah (“God the Mother”)**

**សមាគមផ្សព្វផ្សាយពិភពលោកពួកជំនុំនៃព្រះ**

**World Mission Society Church of God**

**ប៊ុនដាង  កូរ៉េខាងត្បូង**

## ប្រវត្តិ

អាន់ សាំងហុង បានទទួលបុណ្យជ្រមុជទឹកពីក្រុមជំនុំ Seventh Day Adventist នៅឆ្នាំ១៩៥៤ ប៉ុន្តែក្រោយមកគាត់ត្រូវគេបណ្តេញចេញនៅឆ្នាំ១៩៦២ ហើយគាត់បានបង្កើតសាសនារបស់គាត់ផ្ទាល់វិញ។ កាលដែលគាត់នៅមានជីវិត អាន់ សាំងហុង (Ahn Sahng-Hong) មិនដែលអះអាងថា ខ្លួនជាព្រះគ្រីស្ទនោះទេ។ ហើយគាត់ក៏បានបដិសេធជាសាធារណៈនូវការបង្រៀនថា មាន «ព្រះមាតា»ដែរ។ ប៉ុន្តែ



ក្រោយគាត់ស្លាប់ដោយស្ទះសរសៃឈាម និងគាំងបេះដូង នៅឆ្នាំ១៩៨៥ ក្រុមខុសឆ្គងរបស់គាត់បានបែកជាពីរ។ ផ្នែកមួយដែលហៅថា «សមាគមផ្សព្វផ្សាយ

ពិភពលោកពួកជំនុំនៃព្រះ» បានអះអាងថា អាន់ សាំងហុង គឺជា«ព្រះវរបិតា» និងជាព្រះគ្រីស្ទសម្រាប់សម័យកាលរបស់យើង ហើយភរិយាខាងវិញ្ញាណរបស់គាត់ គឺ ហ្សាង គីល ចា (Zahng Gil Jah) ជា «ព្រះមាតា»។ នេះគឺជាពាក្យដែលដកស្រង់ពីលក្ខន្តិកៈជាផ្លូវការរបស់ពួកគេ៖ «យើងជឿលើសេចក្តីពិតថា យើងនឹងត្រូវបានសង្គ្រោះដោយព្រះបិតាខាងវិញ្ញាណនៃស្ថានសួគ៌ អាន់ សាំងហុង ដែលបានយាងមកពិភពលោក ដូចដែលបានសរសេរនៅក្នុងព្រះគម្ពីរ និងដោយជឿលើកូនក្រមុំរបស់ព្រះវរបិតាស្ថានសួគ៌ ហ្សាង គីល ចា»។

ក្រុមខុសឆ្គងរបស់ អាន់ សាំងហុង ប្រើពាក្យ «ព្រះ ព្រះយេស៊ូវ ព្រះគ្រីស្ទ សេចក្តីសង្គ្រោះ» ។ល។ ប៉ុន្តែមានអត្ថន័យខុសពីអត្ថន័យក្នុងព្រះគម្ពីរ។ ក្រុមប្រឹក្សាគ្រីស្ទបរិស័ទទាំងនេះនៅប្រទេសកូរ៉េខាងត្បូង បានចេញសេចក្តីថ្លែងការថា ក្រុម អាន់ សាំងហុង ជាក្រុមខុសឆ្គង៖ Christian Council of Korea (ឆ្នាំ ២០០០) Daejeon Christian Council (ឆ្នាំ ២០០៧) Presbyterian Church of Korea (PCK Tonghap) (ឆ្នាំ ២០០២) PCK Hapshin (ឆ្នាំ ២០០៣) និង PCK Hapdon (ឆ្នាំ ២០០៨)។ មិនតែប៉ុណ្ណោះ បេសកជនទាំងអស់ដែលមកពីប្រទេសកូរ៉េក៏បដិសេធក្រុមនេះ និងក្រុមក្លែងក្លាយផ្សេងៗទៀតដែលមកពីកូរ៉េដែរ។

## ជំនឿនៃបេសកកម្មពិភពលោកនៃព្រះ

**ពួកគេជឿថា អាន់ សាំងហុង គឺជាព្រះគ្រីស្ទ។** គេហទំព័រ អាន់ សាំងហុង និយាយថា «ព្រះគ្រីស្ទ អាន់ សាំងហុងបានមកដល់ផែនដីហើយ បានបង្កើតក្រុមជំនុំរបស់ព្រះ ហើយបានបង្រៀនយើងថា មនុស្សទាំងអស់ គឺជាទេវតា ដែលបានមកផែនដី បន្ទាប់ពីបានធ្វើបាបនៅស្ថានសួគ៌»។ ពួកគេជឿថា ព្រះយេហូវ៉ា ជាព្រះអង្គសង្គ្រោះសំរាប់សម័យកាលសញ្ញាចាស់ ព្រះយេស៊ូវជាព្រះអង្គសង្គ្រោះសំរាប់សម័យកាលគម្ពីរ

សញ្ញាថ្មី ហើយ «ព្រះគ្រីស្ទអាន់ សាំងហុង» ជាអ្នកសង្គ្រោះសំរាប់សម័យកាលបច្ចុប្បន្ន។

ប៉ុន្តែព្រះគម្ពីរមានបន្ទូលអំពីព្រះគ្រីស្ទថា *«ព្រះអង្គ**នោះ**ជាថ្ម ដែលលោករាល់គ្នា ជាជាងសង់ផ្ទះ បានមើលងាយ ប៉ុន្តែទ្រង់បានត្រឡប់ជាថ្មជ្រុងយ៉ាងឯកវិញ ហើយ**គ្មានសេចក្តីសង្គ្រោះ ដោយសារអ្នកណាទៀតសោះ** ដ្បិតនៅក្រោមមេឃគ្មាននាមឈ្មោះណាទៀត បានប្រទានមកមនុស្សលោក ឲ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ»* (កិច្ចការ ៤:១១-១២)។

ពាក្យ «គ្រីស្ទ» គឺជាភាសាក្រេក ដែលបកប្រែពាក្យហេព្រើរ(ជ្វីហ្វ)ថា «មែស៊ី»។ ក្នុងព្រះគម្ពីរងារ ព្រះមែស៊ី តែងតែសំដៅទៅលើស្តេចប្រទេសអ៊ីស្រាអែល។ ព្រះមែស៊ីពិត(គ្រីស្ទ) ត្រូវតែជាពូជពង្សរបស់ស្តេចដាវីឌ ហើយទ្រង់ត្រូវតែបង្ហាញភ័ស្តុតាងពីពង្សាវតារ ដូចព្រះគ្រីស្ទបានធ្វើនៅក្នុងលូកា ៣:២៣-២៨។ ព្រះមែស៊ី (ព្រះគ្រីស្ទ) ត្រូវតែជាជនជាតិយូដា។ វាមិនអាចទៅរួចទេ ដែលព្រះមែស៊ីជាជនជាតិអាមេរិក ចិន ហ្វីលីពីន អាហ្វ្រិក ឬក៏ កូរ៉េ! ដូច្នេះ «គ្រីស្ទ អាន់ សាំងហុង» គឺក្លែងក្លាយហើយ។

ក្រុម អាន់ សាំងហុង ភ្លេចថា ព្រះយេស៊ូវ មិនមែនជាអ្នកសង្គ្រោះសម្រាប់តែសម័យកាលរបស់ទ្រង់ប៉ុណ្ណោះទេ តែជាអ្នកបង្កើតសកលលោក (ចក្រវាល)ទាំងមូល ហើយជាម្ចាស់នៃសម័យកាលទាំងអស់៖ *«គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្តារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ»* (យ៉ូហាន ១:៣)។ *«ដ្បិតគឺទ្រង់ហើយដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបើជារាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ នោះសុទ្ធតែកើតមកដោយសារទ្រង់ ហើយសំរាប់ទ្រង់ទាំងអស់ផង»* (កូល៉ុស ១:១៦)។

**ពួកគេជឿថា ហ្សាង គីល ចា គឺជាព្រះមាតា។** ក្រុមខុសឆ្គង អាន់ សាំងហុង និយាយថា «សមាគមផ្សព្វផ្សាយពិភពលោកពួកជំនុំនៃព្រះ ជឿលើព្រះមាតា»។ ពួកគេក៏និយាយដែរថា «ដូចជាជីវិតខាងរូបកាយរបស់យើង គឺបានមកតាមរយៈម្ដាយខាងសាច់ឈាមរបស់យើង ឯជីវិតខាងវិញ្ញាណរបស់យើង ក៏ត្រូវបានមកតាមរយៈម្ដាយខាងវិញ្ញាណរបស់យើងដែរ។ ព្រះគម្ពីរធ្វើបន្ទាល់យ៉ាងច្បាស់ថា មានមាតាស្ថានសួគ៌របស់យើង ហើយថា មានតែមាតាស្ថានសួគ៌របស់យើងប៉ុណ្ណោះ ដែលអាចប្រទានជីវិតអស់កល្បជានិច្ចដល់យើងបាន»។ ឃ្លាយោងនេះកំពុងសំដៅទៅលើ«ភរិយា» របស់អាន់ សាំងហុង ដែលមានឈ្មោះថា សាង គីល ចា ដែលរស់នៅប្រទេសកូរ៉េ។ តែគាត់គឺជាមនុស្សធម្មតា មិនមែនជាព្រះទេ។ ព្រះគម្ពីរប៊ីបនិយាយអំពីព្រះដែលជាព្រះវរបិតា និងព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ហើយនិងព្រះវិញ្ញាណបរិសុទ្ធ។ ប៉ុន្តែបើអ្នកស្វែងរកក្នុងព្រះគម្ពីរសម្រាប់ពាក្យ «ព្រះមាតា» ឬ «មាតានៃស្ថានសួគ៌» នោះអ្នកនឹងមិនឃើញសោះ!។ ការជឿលើព្រះមាតា គឺជាការប្រមាថទាស់នឹងព្រះ។ សូម្បី អាន់ សាំងហុងផ្ទាល់ មុនស្លាប់ គាត់បានបដិសេធគំនិតដែលថា មានព្រះមាតា ឬថា ព្រះមានប្រពន្ធ។

**តើសាសនាអាន់ សាំងហុង បានបង្វែរបទគម្ពីរយ៉ាងណា ដើម្បីបង្ហាញថា មាន «ព្រះមាតា»**? ពួកគេធ្វើវាជាបីជំហាន។

១. សាសនា អាន់ សាំងហុង និយាយថា ដោយសារព្រះបានបង្កើតទាំងបុរស និងស្ត្រីនៅក្នុងរូបភាពរបស់ព្រះ (លោកុប្បត្តិ ១:២៧) នោះត្រូវតែមាន «ព្រះវរបិតា» សម្រាប់រូបរបស់អ័ដាម និង «ព្រះមាតា» សម្រាប់រូបរបស់អេវ៉ា។ បន្ទាប់មក ពួកគេនិយាយថា ព្រះមាតានោះជា ហ្សាង គីល ចា ។

ប៉ុន្តែក្នុងភាសាហេព្រើរលោកុប្បត្តិ ១:២៧ មានបន្ទូលថា *«ទ្រង់ក៏បង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ គឺបានបង្កើតគេឲ្យចំនឹងរូបអង្គទ្រង់នោះឯង ក៏បង្កើតគេឡើងជាប្រុស*

*ជាស្រី»*។ ពាក្យទាំងប្រាំមួយដែលខ្ញុំបានគូសបន្ទាប់ពីក្រោម នៅក្នុងភាសាហេព្រើរ គឺសំដៅទៅបុរស មិនមែនស្ត្រីទេ។ ពាក្យទាំងនេះសំដៅទៅលើព្រះតែមួយ មិនមែនព្រះជាបុរសមួយ និងព្រះជាស្ត្រីមួយនោះទេ។ មិនមាន «ព្រះមាតា»នៅក្នុងលោកុប្បត្តិ១ ហើយក៏គ្មាននៅកន្លែងផ្សេងទៀតនៅក្នុងព្រះគម្ពីរដែរ។

២. សាសនា អាន់ សាំងហុង និយាយថា នៅពេលដែលសាវកប៉ុល បានហៅទីក្រុងយេរូសាឡិមថា *«ម្តាយយើងទាំងអស់គ្នា»* នៅក្នុងកាឡាទី ៤:២៦ គាត់កំពុងសំដៅទៅលើ ហ្សាង គីល ចា គឺ «ព្រះមាតា»!

ប៉ុន្តែនៅពេលដែលអ្នកមើលកាឡាទី ៤:២១-៣១ នោះអ្នកឃើញថា សាវក ប៉ុល កំពុងប្រើម្តាយពីរនាក់ គឺហាការ និងសារ៉ា ដើម្បីតំណាងឲ្យសម្ពន្ធមេត្រីពីរ គឺសម្ពន្ធមេត្រីនៅភ្នំស៊ីណាយ និងសម្ពន្ធមេត្រីថ្មី។ សាវកប៉ុលបាននិយាយថា *«នោះជាសេចក្តីប្រៀបធៀប គឺស្ត្រីទាំង២នេះ ជាគំរូពីសេចក្តីសញ្ញា២ច្បាប់»* (ខ.២៤)។ នេះជាការប្រៀបធៀបរបស់សាវកប៉ុល៖

| **សម្ពន្ធមេត្រីចាស់** | **សម្ពន្ធមេត្រីថ្មី** |
|---|---|
| នាងហាការជាម្តាយ | នាងសារ៉ាជាម្តាយ |
| យេរូសាឡិមនៃទាសភាព | យេរូសាឡិមនៃសេរីភាព |
| បែបផែនដី | បែបស្ថានសួគ៌ |

ដូច្នេះ នាងហាការតំណាងឲ្យក្រុងយេរូសាឡិមដែលនៅក្រោមទាសភាព ហើយនាងសារ៉ាតំណាងឲ្យក្រុងយេរូសាឡិមដែលមានសេរីភាព។ មិនមានការនិយាយអំពី ហ្សាង គីល ចា សោះ!

៣. សាសនា អាន់ សាំងហុងចង្អុលទៅក្រុងយេរូសាឡិមថ្មី ក្នុងវិវរណៈ ដែលចុះមកពីស្ថានសួគ៌ ជា *«គាត់តែងដូចជាប្រពន្ធថ្មោងថ្មីតែងខ្លួនទទួលប្ដី»* (វិវរណៈ ២១:២)។ ពួកគេថា «ឃើញទេ! ហ្សាង គីល ចា  គឺជាប្រពន្ធរបស់ព្រះ! នាងគឺជា ព្រះមាតា»។

គ្រូក្លែងក្លាយតែងតែយកខគម្ពីរចេញពីបរិបទរបស់ខនោះ។  សូមមើល វិវរណៈ ២១:២ ម្ដងទៀត ប៉ុន្តែចាប់ផ្ដើមជាមួយខ ១ ដើម្បីឃើញបរិបទ៖ *«រួចខ្ញុំឃើញផ្ទៃមេឃថ្មី និងផែនដីថ្មី* ***ដ្បិតផ្ទៃមេឃមុន និងផែនដីមុនបានកន្លងបាត់ទៅហើយ ក៏គ្មានសមុទ្រទៀតឡើយ*** *២ ហើយយ៉ូហានខ្ញុំ ក៏ឃើញទីក្រុងដ៏បរិសុទ្ធ គឺជាក្រុងយេរូសាឡិមថ្មី ចុះពីស្ថានសួគ៌មកអំពីព្រះ គាត់តែងដូចជាប្រពន្ធថ្មោងថ្មីតែងខ្លួនទទួលប្ដី»*។  ច្បាស់ណាស់ ក្រុងយេរូសាឡិមថ្មីអាចចុះពីស្ថានសួគ៌បានលុះត្រាតែ *«ផ្ទៃមេឃមុន និងផែនដីមុនបានកន្លងបាត់ទៅហើយ ក៏គ្មានសមុទ្រទៀតឡើយ»*។  ឥឡូវយើងត្រូវសួរថា តើផ្ទៃមេឃមុន និងផែនដីមុនបានកន្លងបាត់ទៅហើយឬនៅ? ច្បាស់ជានៅ។  ហើយតើលែងមានសមុទ្រទៀតឬ? ទេនៅមាន! ដូច្នេះ ទីក្រុងយេរូសាឡិមថ្មីមិនទាន់ចុះមកពីស្ថានសួគ៌ទេ ហើយ ហ្សាង គីល ចា (Zahng Gil-Jah) ដែលកើតក្នុងឆ្នាំ ១៩៤៣ មិនមែនជាក្រុងយេរូសាឡិមថ្មីទេ។  ការបង្វែរបទគម្ពីរនេះ បង្ហាញយើងពីរបៀបដែលក្រុមក្លែងក្លាយប្រើព្រះគម្ពីរតាមរបៀបបោកបញ្ឆោត។

**ពួកគេជឿថា អាន់ សាំងហុង គឺជាព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធក្នុងបុគ្គលម្នាក់**។  នេះគឺជាការប្រមាថ។  ក្រុម អាន់ សាំងហុងបដិសេធគោលជំនឿនៃព្រះត្រៃឯក។

**ពួកគេជឿថា សេចក្ដីសង្គ្រោះបានមកដោយការរក្សាថ្ងៃឈប់សម្រាក និងការធ្វើបុណ្យរំលងរបស់ជនជាតិអ៊ីស្រាអែល**។  ក្រុមខុសឆ្គង អាន់ សាំងហុង បង្រៀនថា មនុស្សមិនអាចសង្គ្រោះទាល់តែរក្សាថ្ងៃសៅរ៍ ជាថ្ងៃឈប់សម្រាក និងរក្សាបុណ្យ

រំលងប្រចាំឆ្នាំ ដូចសាសន៍អ៊ីស្រាអែល។ តែនេះគឺជាការពឹងលើការធ្វើតាម ក្រឹត្យវិន័យ ដើម្បីឲ្យបានសង្គ្រោះ។ នៅក្នុងគម្ពីរកាឡាទី ១:៨-៩ លោកប៉ុលដាក់បណ្តាសា លើអស់អ្នកណាដែលបន្ថែមក្រឹត្យវិន័យសាសន៍យូដាទៅនឹងជំនឿលើព្រះគ្រីស្ទ៖ *«ប៉ុន្តែបើយើងខ្ញុំ ឬទេវតាពីស្ថានសួគ៌ នឹងប្រាប់ដំណឹងណាមកអ្នករាល់គ្នា ខុសពីដំណឹងល្អដែលយើងខ្ញុំបានប្រាប់ហើយ នោះឲ្យគេត្រូវបណ្តាសាចុះ ឯសេចក្តីដែលខ្ញុំទើបនឹងនិយាយអម្បាញ់មិញនេះ នោះខ្ញុំនិយាយម្តងទៀតថា បើអ្នកណាប្រាប់ដំណឹងណាខុសពីដំណឹងល្អដែលអ្នករាល់គ្នាបានទទួលហើយ នោះឲ្យគេត្រូវបណ្តាសាចុះ»* (កាឡាទី ១:៨-៩)។ លោកប៉ុលកំពុងសំដៅទៅលើគ្រូក្លែងក្លាយនៅក្រុមជំនុំកាឡាទី ដែលចង់បង្ខំគ្រីស្ទបរិស័ទនៅទីនោះឲ្យបន្ថែមការកាត់ស្បែកទៅនឹងជំនឿលើព្រះគ្រីស្ទ ដូចជា អាន់ សាំងហុង បង្ខំសមាជិកគាត់ឲ្យធ្វើបុណ្យរំលង និងរក្សាថ្ងៃសម្រាករបស់សាសន៍យូដា ដើម្បីបានសង្គ្រោះ។

## តើព្រះគម្ពីរមានបន្ទូលយ៉ាងដូចម្តេចអំពីថ្ងៃឈប់សម្រាក?

ទាក់ទងនឹងថ្ងៃឈប់សំរាក និងថ្វាយបង្គំ គម្ពីររ៉ូម ១៤:៥ មានបន្ទូលថា គ្រីស្ទបរិស័ទមានសេរីភាពជ្រើសរើសថ្ងៃណាដែលពិសេស ឬក៏គ្មានថ្ងៃពិសេសសោះ៖ *«ម្នាក់រាប់ថាថ្ងៃ១ល្អជាងថ្ងៃ១ ម្នាក់ទៀតរាប់ថា ថ្ងៃណាក៏ដូចជាថ្ងៃណា ត្រូវឲ្យគ្រប់គ្នាជឿពិតប្រាកដក្នុងចិត្តខ្លួន»*។ គម្ពីររ៉ូម ៦:១៤ ចែងថា គ្រីស្ទបរិស័ទមិននៅក្រោមក្រឹត្យវិន័យទៀតទេ។ ទោះបីជាគ្រីស្ទបរិស័ទ ស្រឡាញ់ក្រឹត្យវិន័យ ១០ប្រការ ពីព្រោះក្រឹត្យវិន័យបង្ហាញពីលក្ខណៈបរិសុទ្ធរបស់ព្រះអង្គ ក៏ដោយ ក៏កិច្ចព្រមព្រៀងថ្មី (សញ្ញាថ្មី)របស់ព្រះជាមួយគ្រីស្ទបរិស័ទ ផ្អែកលើព្រះលោហិតរបស់ព្រះគ្រីស្ទ មិនមែនច្បាប់របស់ជនជាតិយូដា នៅភ្នំស៊ីណាយនោះទេ។ លោកុប្បត្តិ តាមពិតក្នុងរាប់ពាន់ឆ្នាំតាំងពីអ័ដាមលោកុប្បត្តិ ១:១ រហូតដល់ភ្នំស៊ីណាយនៅ និក្ខមនំ ១៦:២៦ មិនមានបទបញ្ញត្តិណាទាក់ទងនឹងថ្ងៃទី៧ទាល់តែសោះ។ ការនេះបង្ហាញ

ថា ច្បាប់ឈប់សម្រាក បានចាប់ផ្ដើមនឹងកិច្ចព្រមព្រៀងរបស់ព្រះជាមួយអ៊ីស្រាអែល នៅលើភ្នំស៊ីណាយ ហើយសម្រាប់តែជនជាតិយូដាតែប៉ុណ្ណោះ។ ព្រះយេស៊ូវបាននាំយកសេចក្ដីសញ្ញាថ្មីជាង និងល្អជាង ដោយផ្អែកលើការសុគតរបស់ទ្រង់នៅលើភ្នំកាល់វ៉ារី ដែលជំនួសសេចក្ដីសញ្ញាមុន ដែលមានមូលដ្ឋានលើភ្នំស៊ីណាយ ៖ *«តែឥឡូវនេះវិញ ដែលទ្រង់[ព្រះគ្រីស្ទ]ជាអ្នកកណ្ដាលរបស់សេចក្ដីសញ្ញា១ដ៏ប្រសើរជាងប៉ុណ្ណា ដែលសេចក្ដីសញ្ញានោះបានតាំងឡើងលើពាក្យសន្យាប្រសើរជាងផងនោះទ្រង់ក៏បានទទួលការងារដ៏ប្រសើរជាងប៉ុណ្ណោះដែរ»* (ហេព្រើរ ៨:៦)។

នៅកិច្ចព្រមព្រៀងរបស់ព្រះជាមួយអ៊ីស្រាអែល ទ្រង់បានហាមពួកគេមិនឲ្យទាំងបង្កាត់ភ្លើងនៅថ្ងៃទី៧ (និក្ខមនំ ៣៥:៣) ហើយហាមមិនអនុញ្ញាតឲ្យអ្នកណាលក់ដូរ ឬធ្វើដំណើរចេញពីផ្ទះទេ (និក្ខមនំ ១៦:២៩)។ មិនតែប៉ុណ្ណោះអ្នកណាដែលរំលងច្បាប់នៃថ្ងៃឈប់សម្រាក ត្រូវគេប្រហារជីវិត (និក្ខមនំ ៣១:១៤)។ តើសមាជិកអាន់ សាំងហុងបានរក្សាច្បាប់ថ្ងៃទី៧ដោយរបៀបនេះដែរឬទេ?។

**តើព្រះគម្ពីរមានបន្ទូលយ៉ាងដូចម្ដេចអំពីបុណ្យរំលង?**

រីឯបុណ្យរំលង ព្រះបានបង្គាប់ដល់លោកម៉ូសេក្នុងនិក្ខមនំ១២ ថា *«មិនត្រូវឲ្យអ្នកប្រទេសក្រៅណាបរិភោគបុណ្យនេះ»* និង *«មិនត្រូវឲ្យមានអ្នកមិនកាត់ស្បែកណាបរិភោគបុណ្យនេះឡើយ»* (និក្ខមនំ ១២:៤៣-៤៨) បុណ្យរំលង គឺសំរាប់ជនជាតិអ៊ីស្រាអែលតែប៉ុណ្ណោះ។ វាមិនមែនសម្រាប់ជនជាតិ កូរ៉េ ឬជនជាតិអាមេរិកាំង ឬជនជាតិខ្មែរទេ។ តើសមាជិកនៃក្រុម អាន់ សាំងហុង សុខចិត្តទទួលការកាត់ស្បែកដើម្បីគេអាចរក្សាបុណ្យរំលងឬទេ? បើដូច្នេះមែនពួកគេក៏ត្រូវរក្សាច្បាប់ទាំង៦០០នៃច្បាប់របស់ព្រះក្នុងគម្ពីរសញ្ញាចាស់ដែរ ពីព្រោះសាវកប៉ុលមានប្រសាសន៍ថា *«ហើយខ្ញុំធ្វើបន្ទាល់ម្ដងទៀត ដល់អស់មនុស្សដែលកាត់ស្បែកហើយថា អ្នកនោះឯងជាអ្នកជំពាក់ក្រឹត្យវិន័យ នឹងត្រូវធ្វើតាមគ្រប់ជំពូក»* (កាឡាទី ៥:៣)។

**ក្រុមខុសឆ្គង អាន់ សាំងហុង ធ្លាក់ការសាកល្បងជាច្រើន៖**

**ពួកគេបរាជ័យការសាកល្បងនៃព្រះយេស៊ូវគ្រីស្ទ៖** ក្រុមខុសឆ្គង អាន់ សាំងហុង អះអាងថា អាន់ សាំងហុង គឺជាព្រះគ្រីស្ទដែលបានយាងត្រឡប់ពីស្ថានសួគ៌។ ប៉ុន្តែ អាន់ សាំងហុង គ្រាន់តែជាមនុស្សប៉ុណ្ណោះ។ យើងដឹងថា គាត់គ្រាន់តែជាមនុស្ស ព្រោះគាត់បានស្លាប់ដោយសារជំងឺដាច់សរសៃឈាមខួរក្បាល និងគាំងបេះដូង នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៨៥ **ហើយគាត់មិនបានរស់ពីស្លាប់ឡើងវិញទេ។** ព្រះគ្រីស្ទដ៏ពិត គឺព្រះយេស៊ូវ ជាអ្នកភូមិណាសារ៉ែត មិនបានសុគតដោយសារជំងឺណាទេ។ ទ្រង់បានសុគតនៅលើឈើឆ្កាងសំរាប់អំពើបាបរបស់យើង ហើយបីថ្ងៃក្រោយមក ទ្រង់មានព្រះជន្មរស់ពីសុគតឡើងវិញ ដូចដែលទ្រង់បានមានបន្ទូលទុកមុន! ព្រះគ្រីស្ទដែលបានសុគត ហើយនៅជាប់ក្នុងសេចក្តីស្លាប់ មិនអាចជួយយើងបានទេ។ ព្រះគ្រីស្ទដែលចាញ់អំពើបាប និងសេចក្តីស្លាប់ មិនអាចជួយយើងឲ្យយកឈ្នះលើអំពើបាប និងសេចក្តីស្លាប់បានទេ។

**ពួកគេបរាជ័យការសាកល្បងនៃការសង្គ្រោះ ដោយព្រះគុណតាមរយៈជំនឿលើព្រះគ្រីស្ទតែ១ប៉ុណ្ណោះ៖** គេហទំព័ររបស់ពួកគេនិយាយថា «សព្វថ្ងៃនេះសេចក្តីសង្គ្រោះត្រូវបានផ្តល់ឲ្យតែតាមរយៈឈ្មោះព្រះគ្រីស្ទអាន់ សាំងហុង តែប៉ុណ្ណោះ ហើយមានតែអស់អ្នកដែលជាសាក្សីរបស់ព្រះគ្រីស្ទ អាន់ សាំងហុង ហើយអធិស្ឋានក្នុងនាមគាត់ ទើបអាចចូលក្នុងនគរស្ថានសួគ៌បាន»។ ពួកគេក៏និយាយថា មនុស្សណាដែលធ្វើតាមថ្ងៃឈប់សម្រាក និងបុណ្យរំលងរបស់ជនជាតិយូដា នោះនឹងបានសង្គ្រោះ។ នេះគឺជាការប្រមាថព្រះ។ គ្មានអ្នកណាដែលពឹងលើការធ្វើតាមថ្ងៃឈប់សម្រាក និងបុណ្យរំលង ឬក្រឹត្យវិន័យឯទៀត នឹងបានសង្គ្រោះនោះទេ។ សូមស្តាប់សាវកប៉ុល៖

*នៃប៉ុលខ្ញុំប្រាប់អ្នករាល់គ្នាថា បើអ្នករាល់គ្នាទទួលកាត់ស្បែក នោះព្រះគ្រីស្ទ គ្មានប្រយោជន៍ដល់អ្នករាល់គ្នាសោះ ៣ ហើយខ្ញុំធ្វើបន្ទាល់ម្តងទៀតដល់អស់មនុស្សដែលកាត់ស្បែកហើយថា អ្នកនោះឯងជាអ្នកជំពាក់ក្រឹត្យវិន័យ និងត្រូវធ្វើតាមគ្រប់ជំពូក ៤ អ្នករាល់គ្នាណាដែលពឹងក្រឹត្យវិន័យឲ្យបានរាប់ជាសុចរិត នោះត្រូវកាត់ចេញពីព្រះគ្រីស្ទ អ្នកបានធ្លាក់ចេញពីព្រះគុណហើយ ៥ ដ្បិតយើងរាល់គ្នាអាងសេចក្តីជំនឿដើម្បីនឹងរង់ចាំដោយនូវព្រះវិញ្ញាណឲ្យបានសេចក្តីសុចរិត ដែលយើងសង្ឃឹមចង់បាននោះ ៦ ពីព្រោះក្នុងព្រះគ្រីស្ទយេស៊ូវ ដែលកាត់ស្បែក ឬមិនកាត់ នោះមិនជាប្រយោជន៍អ្វីទេ មានប្រយោជន៍តែសេចក្តីជំនឿ ដែលប្រព្រឹត្តដោយសេចក្តីស្រឡាញ់ប៉ុណ្ណោះ* (កាឡាទី ៥:២-៦)។

ក្តីសង្ឃឹមតែមួយគត់នៃការសង្គ្រោះរបស់យើង គឺការសុគត និងការមានព្រះជន្មរស់ឡើងវិញនៃព្រះគ្រីស្ទពិត គឺព្រះយេស៊ូវពីភូមិណាសារ៉ែត។

**ពួកគេបរាជ័យការសាកល្បងនៃព្រះត្រៃឯក៖** ក្រុមនេះបង្រៀនថា អាន់ សាំងហុង ជាព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធក្នុងបុគ្គលតែមួយ។ ថែមពីនោះទៀត នៅលើគេហទំព័រពួកគេនិយាយថា «មានតែព្រះវិញ្ញាណ និងកូនក្រមុំទេ គឺព្រះគ្រីស្ទយាងមកជាលើកទីពីរ អាន់ សាំងហុង និងម្តាយនៃយេរូសាឡិមថ្មី ដែលមានជីវិតអមតៈ ហើយមានតែពួកគេប៉ុណ្ណោះ ដែលមានជីវិត»។ នេះគឺជាការប្រមាថព្រះជាម្ចាស់ មានតែព្រះជាម្ចាស់ដែលមានជីវិត។ នៅក្នុងគម្ពីរយ៉ូហាន ៥:២៦ ព្រះយេស៊ូវគ្រីស្ទមានបន្ទូលថា៖ *«ពីព្រោះដែលព្រះវរបិតា មានជីវិតក្នុងព្រះអង្គទ្រង់យ៉ាងណា នោះទ្រង់ក៏បានប្រទានឲ្យព្រះរាជបុត្រា មានជីវិតក្នុងព្រះអង្គទ្រង់យ៉ាងនោះដែរ»*។ បើ អាន់ សាំងហុង មានជីវិតនៅក្នុងខ្លួនគាត់ ហេតុអ្វីបានជាគាត់ស្លាប់នៅឆ្នាំ១៩៨៥ ហើយមិនដែលរស់ឡើងវិញ? បើ ហ្សាង គីល ចា មានជីវិតនៅក្នុងគាត់ផ្ទាល់ ហេតុអ្វីគាត់មិនប្រោសឲ្យ អាន់ សាំងហុង រស់ឡើងវិញនៅឆ្នាំ១៩៨៥

នោះ? ហ្សាង គីល ចា មានអាយុជិត៨០ឆ្នាំហើយ។ តើគាត់នឹងមានជ័យជំនះលើសេចក្តីស្លាប់ ដូចព្រះយេស៊ូវពិតទេ? ទេ។ មនុស្ស២នាក់នេះ គ្មានជីវិតនៅក្នុងខ្លួនទេ។ ព្រោះពួកគេទាំងពីរនាក់ជាមនុស្សធម្មតាសុទ្ធសាធ។

**ពួកគេបរាជ័យការសាកល្បងនៃការធ្វើទំនាយខុស៖** នៅឆ្នាំ១៩៥៦ អាន់ សាំងហុង បានធ្វើទំនាយថា ព្រះគ្រីស្ទនឹងយាងត្រឡប់មកវិញក្នុងរយៈពេល១០ឆ្នាំខាងមុខ ប៉ុន្តែការនេះមិនបានកើតឡើងទេ។ ក្រោយមកទៀតក្រុមរបស់គាត់បានទាយថា ពិភពលោកនឹងត្រូវចប់ក្នុងឆ្នាំ១៩៨៨។ ពួកគេគឺជាហោរាក្លែងក្លាយ។ (សូមមើល ចោទិយកថា ១៨:២០-២២)។

## ក្រុម អាន់ សាំងហុង អះអាងថា គាត់ជាព្រះគ្រីស្ទដែលយាងត្រឡប់មកវិញ ប៉ុន្តែព្រឹត្តិការណ៍ណាខ្លះត្រូវកើតឡើង នៅពេលព្រះពិតយាងមកវិញ?

ព្រះគម្ពីរបាននិយាយច្បាស់ណាស់ អំពីព្រឹត្តិការណ៍ដែលត្រូវតែកើតឡើងនៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ។ យើងអាចប្រើប្រាស់បទទំនាយទាំងនេះ ដើម្បីល្បងមើល ថា អាន់ សាំងហុង ឬ ហ្សាង គីល ចា គឺជាព្រះគ្រីស្ទពិត ឬ ជាព្រះគ្រីស្ទក្លែងក្លាយ។

១. ពេលដែលព្រះគ្រីស្ទពិតប្រាកដយាងមកវិញ ទ្រង់នឹង *«សងសេចក្តីទុក្ខលំបាក»* ដល់ពួកអ្នកដែលធ្វើទុក្ខដល់គ្រីស្ទបរិស័ទ ហើយប្រទានការ *«សំរាក»* និងសេចក្តីសង្គ្រោះ ដល់ពួកអ្នកដែលត្រូវគេធ្វើទុក្ខ។ ទ្រង់នឹងមក *«ជាមួយនឹងពួកទេវតានៃព្រះចេស្តាទ្រង់ នៅក្នុងអណ្តាតភ្លើង ទាំងសងសឹកនឹងពួកអ្នកដែលមិនស្គាល់ព្រះ ហើយនិងពួកអ្នកដែលមិនស្តាប់តាមដំណឹងល្អ ពីព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើង»*។ (២ថែស្សាឡូនីច ១:៦-៨) **តើការនេះបានកើតឡើងទេនៅពេលដែល អាន់ សាំងហុង និង ហ្សាង គីល ចា មកនោះ?**

២. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងមិនយាងមកដោយស្ងាត់ៗទេ។ មនុស្សគ្រប់គ្នានៅលើពិភពលោកនឹងបានឃើញទ្រង់។ *«ព្រោះដំណើរដែលកូនមនុស្សមក នោះនឹងបានដូចជាផ្លេកបន្ទោរ ដែលភ្លឺផ្លេកៗ ពីទិសខាងកើតដល់ទិសខាងលិច*

*ដែរ»* និង *«គ្រប់ទាំងភ្នែកនឹងឃើញទ្រង់» «ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង»* (ម៉ាថាយ ២៤:២៧; វិវរណៈ ១:៧; ១ថែស្សាឡូនីច ៤:១៦) **តើការនេះបានកើតឡើងទេ នៅពេលដែល អាន់ សាំងហុង និង ហ្សាង គីល ចា មកនោះ?**

៣. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ នោះនៅលើមេឃនឹងត្រូវកក្រើករំពើក។ *«ស្រាប់តែថ្ងៃនឹងទៅជាងងឹត ខែនឹងលែងភ្លឺ អស់ទាំងផ្កាយនឹងធ្លាក់ចុះពីលើមេឃ ហើយអស់ទាំងអំណាចនៅលើមេឃនឹងត្រូវកក្រើករំពើក»* (ម៉ាថាយ ២៤:២៩)។ **តើការនេះបានកើតឡើងទេ នៅពេលដែល អាន់ សាំងហុង និង ហ្សាង គីល ចា មកនោះ?**

៤. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងយាងមកដោយអំណាច និងសិរីល្អ ហើយមនុស្សមានបាបទាំងអស់នៅលើផែនដីនឹងសោកសៅ។ *«នោះទីសំគាល់របស់កូនមនុស្សនឹងលេចមកនៅលើមេឃ គ្រប់ទាំងពូជមនុស្សនៅផែនដីនឹងគក់ទ្រូងយំ ក៏នឹងឃើញកូនមនុស្ស មកលើពពកនៅលើមេឃ មានទាំងព្រះចេស្តា និងសិរីល្អជាខ្លាំង»* (ម៉ាថាយ ២៤:៣០) **តើការនេះបានកើតឡើងទេ នៅពេលដែល អាន់ សាំងហុង និង ហ្សាង គីល ចា មកនោះ?**

៥. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ *«លោកនឹងចាត់ពួកទេវតារបស់លោក ឲ្យមកដោយសូរផ្លុំត្រែជាខ្លាំង ទេវតាទាំងនោះនឹងប្រមូលពួករើសតាំងរបស់លោកពីទិសទាំង៤ ចាប់តាំងពីជើងមេឃម្ខាង រហូតដល់ជើងមេឃម្ខាង»*។ (ម៉ាថាយ ២៤:៣១) **តើការនេះបានកើតឡើងទេ នៅពេលដែលអាន់ សាំងហុង និង ហ្សាង គីល ចា មកនោះ?**

៦. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងបំផ្លាញអាទទឹងនឹងព្រះគ្រីស្ទ (ជាមនុស្សដែលត្រូវហិនវិនាស) *«កុំឲ្យអ្នកណាបញ្ឆោតអ្នករាល់គ្នាជាយ៉ាងណាដែរ ដ្បិតថ្ងៃនោះមិនមកឡើយ ទាល់តែមានសេចក្តីក្បត់សាសនាមកជាមុន ហើយមនុស្សដែលជាតួបាបនោះបានលេចមក គឺជាមនុស្សដែលត្រូវហិនវិនាស ដែលទាស់ទទឹង ហើយលើកខ្លួនឡើង ខ្ពស់លើសជាងអស់ទាំងអ្វី ដែលហៅថាព្រះ ឬរបស់អ្វីដែលគេគោរពប្រតិបត្តិផង ដល់ម្ល៉េះបានជាវានឹងអង្គុយនៅ ដូចជាព្រះក្នុងវិហារនៃព្រះ ទាំងសំដែងខ្លួនថា*

*ជាព្រះផង...នោះទើបអាទទឹងច្បាប់នោះនឹងលេចមក ដែលព្រះអម្ចាស់យេស៊ូវនឹងបំផ្លាញ ដោយខ្យល់ពីព្រះឱស្ឋទ្រង់ ហើយធ្វើឲ្យវិនាស ដោយរស្មីពន្លឺពីដំណើរទ្រង់យាងមក»* (២ថែស្សាឡូនីច ២:៣-៤, ៨)។ **តើការនេះបានកើតឡើងទេ នៅពេលដែល អាន់ សាំងហុង និង ហ្សាង គីល ចា មកនោះ?**

៧. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងចាក់សេចក្តីក្រោធរបស់ទ្រង់ទៅលើអស់អ្នកមានបាបទាំងអស់គ្នា។ *«ដ្បិតអ្នករាល់គ្នាដឹងច្បាស់ហើយថា ថ្ងៃនៃព្រះអម្ចាស់នឹងមកដល់ ដូចជាចោរមកនៅពេលយប់។ ដ្បិតកាលណាគេកំពុងតែនិយាយថា មានសេចក្តីសុខសាន្ត មានសេចក្តីរៀបរយហើយ នោះលោតែមានសេចក្តីហិនវិនាសមកលើគេភ្លាម ដូចជាស្ត្រីមានគភ៌ឈឺនឹងសំរាល ហើយគេចមិនរួចឡើយ»* (១ថែស្សាឡូនីច ៥:២-៣)។ **តើការនេះបានកើតឡើងទេ នៅពេលដែលអាន់ សាំងហុង និង ហ្សាង គីល ចា មកនោះ?**

៨. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងកាត់ទោសគ្រប់គ្នាភ្លាមៗ។ *«តែកាលណាកូនមនុស្សនឹងមក ក្នុងសិរីល្អរបស់លោក មានទាំងពួកទេវតាបរិសុទ្ធទាំងអស់គ្នា មកជាមួយ នោះលោកនឹងឡើងគង់លើបល្ល័ង្ករុងរឿងឧត្តមរបស់លោក។ រួចគ្រប់ទាំងសាសន៍ នឹងត្រូវប្រមូលគ្នា នៅចំពោះលោក ហើយលោកនឹងញែកគេចេញពីគ្នា ដូចជាអ្នកគង្វាលដែលញែកចៀមចេញពីពពែដែរ»* (ម៉ាថាយ ២៥:៣១-៣២)។ **តើការនេះបានកើតឡើងទេ នៅពេលដែលអាន់ សាំងហុង និង ហ្សាង គីល ចា មកនោះ?**

៩. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មក ទ្រង់នឹងប្រោសរូបកាយអ្នកស្លាប់ទាំងអស់ដែលជាគ្រីស្ទបរិស័ទ។ *«ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង នោះពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់។ រួចយើងរាល់គ្នាដែលកំពុងតែរស់នៅ ក៏នឹងបានលើកឡើង ទៅក្នុងពពកជាមួយគ្នាទាំងអស់ ដើម្បីឲ្យបានជួបជុំនឹងព្រះអម្ចាស់នៅនាអាកាស យ៉ាងនោះ យើងនឹងនៅជាមួយនឹងព្រះអម្ចាស់ជាដរាបទៅ»* (១ថែស្សាឡូនីច ៤:១៦-១៧)។ **តើការនេះបានកើតឡើងទេ នៅពេលដែល អាន់ សាំងហុង និង ហ្សាង គីល ចា មកនោះ?**

១០. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មក ទ្រង់នឹងមិនកើតមកជាទារកតូចទេ ប៉ុន្តែទ្រង់នឹងយាងមកពីស្ថានសួគ៌ជាអ្នកចម្បាំងដ៏មានគ្រប់ព្រះចេស្ដា ដើម្បីវិនិច្ឆ័យជំនុំជម្រះផែនដី។ *«ខ្ញុំក៏ឃើញមេឃបើកចំហឡើង នោះឃើញមានសេះស១ និងព្រះអង្គដែលគង់លើវា ទ្រង់មានព្រះនាមថា «ស្មោះត្រង់ ហើយពិតប្រាកដ» ទ្រង់ជំនុំជំរះ ហើយច្បាំងដោយសុចរិត ១២ ព្រះនេត្រទ្រង់ដូចជាអណ្ដាតភ្លើង ហើយនៅលើព្រះសិរសា មានមកុដជាច្រើន ទ្រង់មានព្រះនាមកត់ទុក ដែលគ្មានអ្នកណាស្គាល់ឡើយ លើកតែអង្គទ្រង់ប៉ុណ្ណោះ ១៣ ទ្រង់ក៏ទ្រង់ព្រះពស្ត្រជ្រលក់ដោយឈាម ហើយព្រះនាមទ្រង់ហៅថា «ព្រះបន្ទូលនៃព្រះ» ១៤ អស់ទាំងពលបរិវារនៅស្ថានសួគ៌ ក៏ជិះសេះសដង្ហែទ្រង់ ទាំងស្លៀកពាក់សំពត់ទេស ហើយស្អាតផង ១៥ មានដាវយ៉ាងមុតចេញពីព្រះឱស្ឋទ្រង់ ដើម្បីនឹងកាប់អស់ទាំងសាសន៍ ហើយទ្រង់នឹងឃ្វាលគេ ដោយដំបងដែក ទ្រង់ក៏ជាន់ក្នុងធុងឃ្នាបនៃស្រាទំពាំងបាយជូរ ជាសេចក្ដីឃោរឃៅរបស់សេចក្ដីខ្ញាល់នៃព្រះដ៏មានព្រះចេស្ដាបំផុត ១៦ ទ្រង់មានព្រះនាមកត់នៅព្រះពស្ត្រ ហើយនៅព្រះឧរុទ្រង់ថា «ស្ដេចលើអស់ទាំងស្ដេច ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់»*។ (វិវរណៈ ១៩:១១-១៦)។ **តើការនេះបានកើតឡើងទេនៅពេលដែល អាន់ សាំងហុង និង ហ្សាង គីល ចា មកនោះ?**

**គ្មានព្រឹត្តិការណ៍ណាមួយសោះបានកើតឡើង ក្នុងចំណោមព្រឹត្តិការណ៍ទាំងនេះ នៅពេលដែល អាន់ សាំងហុង និង ហ្សាង គីល ចា មកនោះ។** អាន់ សាំងហុង និង ហ្សាង គីល ចា ជាព្រះគ្រីស្ទក្លែងក្លាយ។

## មុខពូថៅ



តើក្រុមនេះបានប្រើការបង្រៀនអ្វីធ្វើជាមុខពូថៅ ដើម្បីពុះគ្រីស្ទបរិស័ទចេញពីក្រុមជំនុំ អ្នកធ្វើការឲ្យ អាន់ សាំងហុង តែងតែចាប់ផ្ដើមដោយនិយាយអំពីថ្ងៃឈប់សម្រាកនៅថ្ងៃទី៧។ ពួកគេនឹងមិនអនុញ្ញាតឲ្យអ្នកសួរសំណួរអ្វីផ្សេងទៀតទេ ទាល់តែអ្នកយល់ព្រមជាមួយពួកគេជាមុនសិនអំពីថ្ងៃឈប់សម្រាកនៅថ្ងៃទី៧ ហើយ

យល់ព្រមទទួលបុណ្យជ្រមុជទឹកពីពួកគេដែរ។ តាមពិត ជាការងាយស្រួលចំពោះពួកគេ ដែលអាចរកខជាច្រើននៅក្នុងគម្ពីរសញ្ញាចាស់ ដែលបង្គាប់ឲ្យជនជាតិអ៊ីស្រាអែលឈប់សម្រាកនៅថ្ងៃទី៧ ពីព្រោះនេះពិតជាច្បាប់របស់ព្រះសម្រាប់អ៊ីស្រាអែល នៅក្នុងគម្ពីរសញ្ញាចាស់នៅលើភ្នំស៊ីណាយ។ ប៉ុន្តែនៅក្នុងគម្ពីរសញ្ញាថ្មីគ្មានសេចក្តីបង្គាប់ណាដែលយើងត្រូវឈប់សម្រាកនៅថ្ងៃទី៧នោះទេ។

តើអ្វីជាខ្ទងពូថៅ? តើគោលលទ្ធិប្រមាថអ្វីខ្លះដែលពួកគេនឹងលាក់ពីអ្នករហូតដល់ពេលក្រោយ? ជាធម្មតា ពួកគេលាក់បាំងការបង្រៀនរបស់ពួកគេ ដែលថា អាន់ សាំងហុង គឺជាព្រះគ្រីស្ទដែលយាងមកលើកទីពីរ ហើយ ហ្សាង គីល ចា គឺជា «ព្រះមាតា»។ ក៏ប៉ុន្តែ អាន់ សាំងហុង គ្រាន់តែជាមនុស្ស ហើយឥឡូវគាត់ស្លាប់ហើយ។ ប្រពន្ធរបស់គាត់គ្រាន់តែជាមនុស្សប៉ុណ្ណោះ គាត់ក៏ត្រូវស្លាប់ដែរ ហើយនឹងមិនរស់ពីស្លាប់ឡើងវិញទេ។ ប៉ុន្តែប្រសិនបើអ្នកបានទទួលយកការបង្រៀនខុសឆ្គងរបស់ពួកគេ អំពីថ្ងៃឈប់សម្រាក និងបុណ្យរំលងហើយ នោះមុខពូថៅបានចូលទៅក្នុងចិត្តរបស់អ្នករួចហើយ ហើយមិនយូរទេ ខ្ទងពូថៅនឹងចូលតាមក្រោយភ្លាមយ៉ាងងាយស្រួល ដោយបំបែកអ្នកចេញពីព្រះគ្រីស្ទពិត និងដំណឹងល្អពិត។

នៅពេលដែលអ្នកធ្វើការរបស់ អាន់ សាំងហុង ចង់និយាយអំពីថ្ងៃទី៧ អ្នកត្រូវតែទទូចឲ្យពួកគេនិយាយជាមុនអំពី «ព្រះគ្រីស្ទពិតជាអ្នកណា ហើយធ្វើម៉េចឲ្យយើងដឹង?» និង «ហេតុអ្វីបានជា អាន់ សាំងហុង មិនរស់ពីស្លាប់ឡើងវិញ បើគាត់ជាព្រះគ្រីស្ទ?» និង «តើអាន់ សាំងហុង អាចជួយយើងបានយ៉ាងម៉េច បើគាត់ស្លាប់បាត់ហើយ?» ហើយនិង «ហេតុអ្វីបានជាព្រះគម្ពីរមិនដែលចែងអំពីឈ្មោះ ព្រះមាតាសោះ?» បើពួកគេមិនព្រមនិយាយអំពីបញ្ហាដែលមានសារៈសំខាន់បំផុតទាំងនេះ អ្នកត្រូវតែបញ្ចប់ការសន្ទនាភ្លាមៗ។ ចូរចងចាំថា អ្នកជាមេគ្រួសារ។ បើពួកគេមិនអនុញ្ញាតឲ្យអ្នកនិយាយនៅក្នុងផ្ទះអ្នកទេ ពួកគេត្រូវតែចេញពីផ្ទះរបស់អ្នក។ អ្នក

ធ្វើការរបស់អាន់ សាំងហុង គឺជាឆ្កែចចកពាក់រោមចៀម មិនមែនជាអ្នកជឿពិតប្រាកដទេ។ យើងកុំព្រួយបារម្ភ ក្នុងការបង្អន់ចិត្តឆ្កែចចកឡើយ ព្រោះវាចង់បំផ្លាញកូនចៀមរបស់យើង។

វិធីមួយទៀតដែលក្រុមខុសឆ្គងអាន់ សាំងហុងចូលទៅគ្រីស្ទបរិស័ទ គឺតាមរយៈការងាររក្សាបរិស្ថាន កម្មវិធីបរិច្ចាគឈាម និងការជួយសង្គ្រោះពេលមានគ្រោះមហន្តរាយ។ ការទាំងនេះហាក់ដូចជាមានប្រយោជន៍ដល់សង្គមផង ប៉ុន្តែទាំងនេះគឺជាមធ្យោបាយរបស់ពួកគេ ដើម្បីជះឥទ្ធិពលដល់មនុស្សកាន់តែច្រើន។ ការនេះគ្រាន់តែជាមុខពួថៅប៉ុណ្ណោះ។

ទីបញ្ចប់សូមកុំភ្លេច២យ៉ូហាន ១:១០-១១៖ *«បើអ្នកណាមកឯអ្នករាល់គ្នាតែមិនបង្រៀនចំពោះសេចក្ដីនេះ នោះកុំឲ្យទទួលអ្នកនោះនៅក្នុងផ្ទះឡើយ កុំឲ្យទាំងជំរាបសួរដល់អ្នកនោះផង ដ្បិតបើអ្នកណាជំរាបសួរ នោះក៏តែងមានសេចក្ដីប្រកបគ្នាក្នុងការអាក្រក់របស់អ្នកនោះដែរ»*។



*នេះគឺជាផ្នូររបស់ អាន់ សាំងហុង នៅប្រទេសកូរ៉េ។ វាមិនមែនជាផ្នូរទទេដូចជាផ្នូររបស់ព្រះគ្រីស្ទពិតនោះឡើយ។*

*(រូបភាព និងឃ្លាដកស្រង់ ពីគេហទំព័រ ក្រុមជំនុំបេសកកម្មពិភពលោកនៃព្រះ https://wmscog.com )។*

## ធនធានគួរទុកចិត្តៈ

https://carm.org/world-mission-society-church-of-god/

# អាប៉ូឡូ គីបូឡូយ

**Apollo Quiboloy**

**«ព្រះរាជ្យនៃព្រះយេស៊ូវគ្រីស្ទ»**

**«ព្រះរាជបុត្រាតែងតាំងនៃព្រះ និងជាម្ចាស់នៃចក្រវាល»**

**ទីក្រុងដាវ៉ាវ ប្រទេសហ្វីលីពីន**

## ប្រវត្តិ

អាប៉ូឡូ គីបូឡូយ កើតនៅទីក្រុងដាវ៉ាវប្រទេសហ្វីលីពីន នៅថ្ងៃទី២៥ខែមេសាឆ្នាំ ១៩៥០។ ឪពុករបស់គាត់ជាសមាជិកនៃក្រុមជំនុំដ៏ល្អមួយ ប៉ុន្តែក្រោយមកបាន



ចាកចេញពីក្រុមជំនុំនោះ ដើម្បីចូលរួមជាមួយនិកាយមួយ ដែលបដិសេធព្រះត្រៃឯក គឺ United Pentecostal Church។ ក្រោយមកអាប៉ូឡូ គីបូឡូយ បានក្លាយជាគ្រូគង្វាលនៃក្រុមជំនុំមួយនៃនិកាយនោះដែរ។ បន្ទាប់មកគាត់បាន បង្កើតក្រុមជំនុំផ្ទាល់ខ្លួន ហើយអះអាងថា ខ្លួនជាព្រះរាជបុត្រានៃព្រះ។ ឥឡូវនេះ ក្រុមខុសឆ្គងរបស់គាត់មានសមាជិកជាងមួយលាននាក់ ដោយពួកគេចាត់ទុកគាត់ ជាម្ចាស់នៃចក្រវាល។ ខាងលើជាឡូហ្គោរបស់គាត់ ដែលហៅគាត់ថា ជាព្រះយេស៊ូវ

គ្រីស្ទ ហើយ«នាមដែលខ្ពស់លើសអស់ទាំងនាម» ជានាមដែលគាត់បានលួចយកពី ពី ភីលីព ២:៩ ដែលសំដៅទៅ ព្រះគ្រីស្ទពិត គឺព្រះយេស៊ូវពីស្រុកណាសារ៉ែត មិនមែន អាប៉ូឡូ គីបូឡូយទេ។

## អាប៉ូឡូ គីបូឡូយ អះអាងថា ខ្លួនជាព្រះរាជបុត្រានៃព្រះ

ឧបាយកលមួយដែល មេដឹកនាំក្រុមខុសឆ្គងជាច្រើនបានប្រើ គឺបង្រៀនថា ព្រះយេស៊ូវបានបរាជ័យ មិនបានបំពេញគោលដៅទាំងអស់ ដែលព្រះវរបិតាបានបញ្ជូនទ្រង់ឲ្យធ្វើឡើយ ដូច្នេះត្រូវតែមានព្រះគ្រីស្ទមួយទៀត ដើម្បីបញ្ចប់ការងារនោះ។ នេះក៏ជាការអះអាងរបស់អាប៉ូឡូ គីបូឡូយពីប្រទេសហ្វីលីពីនដែរ។ សូមស្តាប់សំដីផ្ទាល់របស់គាត់៖

> «នៅពេលដែលព្រះរាជបុត្រានៅក្នុងស្ថានភាពនៃសាសន៍យូដា គឺព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើង បានយាងមក ហើយបានបង់ថ្លៃលោះដោយទ្រង់សុគតនៅលើឈើឆ្កាង នោះសេចក្តីសង្គ្រោះមិនបានបញ្ចប់ត្រឹមនោះទេ។ ទ្រង់កំពុងរង់ចាំកូនចៅអ័ដាមទី១[គីបូឡូយ]កើតនៅក្នុងព្រះវិញ្ញាណរបស់ទ្រង់»។

គីប៉ូឡូយកំពុងសំដៅលើខ្លួនគាត់ថា ជាអ្នកដែលនឹងបញ្ចប់នូវអ្វីដែលព្រះយេស៊ូវមិនបានបញ្ចប់។ នេះគឺជាការប្រមាថទាស់នឹងព្រះយេស៊ូវគ្រីស្ទពិត។ ប៉ុន្តែការប្រមាថរបស់គីបូឡូយនៅមានទៀត៖

> «ខ្ញុំ [គីបូឡូយ] ជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត គ្មានអ្នកណាអាចទៅឯព្រះវរបិតាបានឡើយ លើកលែងតែដោយសារខ្ញុំ»។ គីប៉ូឡូយកំពុងយកព្រះបន្ទូលរបស់ព្រះយេស៊ូវនៅយ៉ូហាន ១៤:៦ ដើម្បីនិយាយអំពីខ្លួនគាត់! នេះគឺជាការប្រមាថទាស់នឹងព្រះយេស៊ូវគ្រីស្ទពិត។

«ខ្ញុំអាចបញ្ចប់ការងាររបស់ទ្រង់[ព្រះគ្រីស្ទ]បាន។ ខ្ញុំបានបំពេញផ្នែកខាងវិញ្ញាណនៃសេចក្តីសង្គ្រោះ ដែលមិនត្រូវបានបញ្ចប់ក្នុងសម័យយូដា និងសម័យនៃក្រុមជំនុំ។ ខ្ញុំជាការសម្រេចបំពេញរបស់ព្រះវរបិតា នៃកិច្ចការដែលទ្រង់បានធ្វើនៅលើឈើឆ្កាង»។ នេះគឺជាការប្រមាថទាស់នឹងព្រះយេស៊ូវគ្រីស្ទពិត។

«បើអ្នកចង់ឃើញព្រះវរបិតា សូមមើលមកខ្ញុំចុះ»។ នេះគឺជាការប្រមាថទាស់នឹងព្រះវរបិតា។

## អាប៉ូឡូ គីបូឡុយអះអាងថា ខ្លួនគ្មានបាបទេ

គាត់អះអាងថា ស្ថានភាពរបស់គាត់សព្វថ្ងៃនេះ គឺដូចគ្នានឹងអ័ដាមមុនពេលគាត់ធ្លាក់ក្នុងបាប គឺគ្មានបាបទេ។ ក៏ប៉ុន្តែ ទោះយ៉ាងណាក៏ដោយ *«គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង...ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ»* (រ៉ូម ៣:១០,២៣)។

## អាប៉ូឡូ គីប៉ូឡុយអះអាងថា ជាផ្លូវតែមួយគត់នៃការសង្គ្រោះ

គាត់ថា មនុស្សអាចទទួលការសង្គ្រោះបាន ទាល់តែគាត់ព្រមទទួលយក គីប៉ូឡុយជាព្រះរាជបុត្រានៃព្រះ។ គីប៉ូឡុយបានអះអាងថា ព្រះយេស៊ូវ គ្រាន់តែជាព្រះអង្គសង្គ្រោះ សំរាប់សាសន៍យូដាប៉ុណ្ណោះ តែគីប៉ូឡុយ គឺជាអ្នកសង្គ្រោះសំរាប់សាសន៍ដទៃ។ ប៉ុន្តែសាវកពេត្រុសមានប្រសាសន៍ថា៖

> *«ព្រះអង្គនោះ[ព្រះយេស៊ូវ]ជាថ្មដែលលោករាល់គ្នាជាជាងសង់ផ្ទះបានមើលងាយ ប៉ុន្តែទ្រង់បានត្រឡប់ជាថ្មជ្រុងយ៉ាងឯកវិញ ហើយ**គ្មានសេចក្តីសង្គ្រោះដោយសារអ្នកណាទៀតសោះ** ដ្បិតនៅក្រោមមេឃគ្មាននាមឈ្មោះណាទៀត បានប្រទានមកមនុស្សលោក ឲ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ»* (កិច្ចការ ៤:១១-១២)។

ពីរពាន់ឆ្នាំមុន អាប៉ូឡូ គីបូឡូយបានកើតមក សាវកប៉ុលបានបង្រៀនថា ព្រះយេស៊ូវ ដែលត្រូវគេឆ្កាង ជាសេចក្តីសង្គ្រោះនៃសាសន៍យូដា និងសាសន៍ដទៃផង៖ *«តែយើងខ្ញុំប្រកាសប្រាប់ពីព្រះគ្រីស្ទ ដែលទ្រង់ត្រូវឆ្កាងវិញ ជាហេតុនាំឲ្យរវាតចិត្តដល់សាសន៍យូដា និងជាសេចក្តីល្ងង់ល្ងើដល់សាសន៍ក្រេក[សាសន៍ដទៃ]*[២៤] *តែព្រះគ្រីស្ទទ្រង់ជាព្រះចេស្តា ហើយជាប្រាជ្ញារបស់ព្រះវិញ ដល់អស់អ្នកដែលទ្រង់ហៅ ទាំងសាសន៍យូដា ហើយនិងសាសន៍ក្រេកផង»* (១កូរិនថូស ២៣-២៤)។

ដូចអាន់ សាំងហុង ពីកូរ៉េ និង យ៉ាង ស៊ីងប៊ិន ពីចិន អាប៉ូឡូ គីបូឡូយ ក៏ចែកប្រវត្តិសាស្ត្រជាបីសម័យកាល៖

| | |
|---|---|
| **សម័យកាលសាសន៍យូដា** | អ័ដាមជាព្រះរាជបុត្រា**ដំបូង**នៃព្រះ ប៉ុន្តែគាត់បានបរាជ័យ។ |
| **សម័យកាលក្រុមជំនុំ** | ព្រះយេស៊ូវជាព្រះរាជបុត្រា**បង្កើត**នៃព្រះ ប៉ុន្តែទ្រង់បានបរាជ័យ មិនបានបំពេញសេចក្តីសង្គ្រោះរបស់យើងទាំងស្រុងទេ។ |
| **សម័យកាលបច្ចុប្បន្ន** | ឥឡូវព្រះជាម្ចាស់បានចូលមកក្នុងអាប៉ូឡូ គីបូឡូយ ដែលជាព្រះរាជបុត្រាតែងតាំងរបស់ព្រះ ដែលនឹងបំពេញសេចក្តីសង្គ្រោះរបស់យើងឲ្យបានសម្រេច។ |

តែអាប៉ូឡូ គីបូឡូយ ភ្លេចថា ព្រះយេស៊ូវ មិនមែនជាព្រះអង្គសង្គ្រោះសម្រាប់តែសម័យកាលមួយប៉ុណ្ណោះទេ តែជាអ្នកបង្កើតសកលលោក (ចក្រវាល)ទាំងមូល ហើយជាម្ចាស់នៃសម័យកាលទាំងអស់។ *«គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្តារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ»* (យ៉ូហាន ១:៣)។ *«ដ្បិតគឺទ្រង់ហើយដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបើជារាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាច*

*គ្រប់គ្រង ឬអំណាចណាក៏ដោយ នោះសុទ្ធតែកើតមកដោយសារទ្រង់ ហើយសំរាប់ទ្រង់ទាំងអស់ផង»* (កូល៉ុស ១:១៦)។

## អាប៉ូឡូ គីបូឡុយជឿថា សេចក្តីសង្គ្រោះមកតាមរយៈតែការកែប្រែចិត្តតែប៉ុណ្ណោះ

គីបូឡុយ អះអាងថា មនុស្សលោកទាំងអស់មានឆន្ទៈសេរី ដែលអាចសម្រេចចិត្តឈប់ធ្វើការអាក្រក់ ហើយចាប់ផ្តើមធ្វើការល្អ។ គាត់ថា «តាមរយៈការកែប្រែចិត្ត យើងអនុញ្ញាតឲ្យព្រះធ្វើការក្នុងយើង ក្នុងអំណាចរបស់ទ្រង់។ វិញ្ញាណនៃសាតាំង លូសេហ្វឺ ត្រូវបណ្តេញចេញ ហើយវិញ្ញាណថ្មីនឹងមកជំនួស» គីបូឡុយបដិសេធសេចក្តីសង្គ្រោះដោយព្រះគុណតាមរយៈជំនឿលើការសុគត និងការរស់ពីសុគតឡើងវិញរបស់ព្រះគ្រីស្ទ។ ជំនួសនោះគាត់បង្រៀន សេចក្តីសង្គ្រោះតាមតែការកែប្រែចិត្តប៉ុណ្ណោះ នេះជាដំណឹងល្អក្លែងក្លាយ។

## អាប៉ូឡូ គីបូឡុយបដិសេធព្រះត្រៃឯក

គាត់បដិសេធជាសាធារណៈ ចំពោះគោលលទ្ធិនៃព្រះត្រៃឯក និងគោលជំនឿណៃសៀ (Nicene Creed) ដោយហៅថា ជាការដែលសាតាំងបានបង្កើត។ ចំណុចតែមួយនេះធ្វើឲ្យគាត់ជាគ្រូក្លែងក្លាយ។

## សាតាំងបានបញ្ចូលពូជរបស់វា ចូលក្នុងនាងអេវ៉ា ហើយកាអ៊ីនជាលទ្ធផល

គ្រូបង្រៀនដែលបដិសេធព្រះត្រៃឯក ច្រើនតែបង្រៀនថា សាតាំងបានធ្វើឲ្យអេវ៉ាបង្កើតកាអ៊ីន។ (ការបង្រៀនខុសឆ្គងនេះ បានបង្កើតដោយគ្រូក្លែងក្លាយឈ្មោះវ៉ាលែន ទីនុស នៅសតវត្សទី២ ហើយបានលេចឡើងម្តងទៀតនៅសតវត្សទី២០ តាមរយៈគ្រូខុសឆ្គងជនជាតិអាមេរិកម្នាក់ឈ្មោះ វីល្លៀម ប្រាណហាំ (១៩០៩-១៩៦៥) ដែលបានបដិសេធព្រះត្រៃឯកផងដែរ។

## អាប៉ូឡូ គីបូឡយបានក្លាយជាសេដ្ឋីដោយសារសាសនា

គីបូឡយតែងតែទាមទារអ្នកស្តាប់គាត់តាមទូរទស្សន៍ ឲ្យផ្ញើប្រាក់ឲ្យគាត់ ហើយទាមទារឲ្យសមាជិកក្រុមរបស់គាត់ ឲ្យប្រាក់១០ភាគរយ នៃប្រាក់ចំណូលរបស់ពួកគេមកគាត់។ គីបូឡយបានក្លាយជាមហាសេដ្ឋីតាមរយៈសាសនា ដោយមានគេហដ្ឋានដ៏ស្តុកស្តម្ភជាច្រើន ឡានថ្លៃៗ និងយន្តហោះ។ តែគាត់នៅតែទាមទារប្រាក់ពីគេ។ ហេតុអ្វីបានជាអ្នកក្រ ត្រូវឲ្យប្រាក់ដល់អ្នកមាន? (សូមមើលសុភាសិត ២២:១៦ សម្រាប់ការព្រមានអំពីការផ្តល់ប្រាក់ដល់អ្នកមានដែលជិះជាន់អ្នកក្រ)។

## អាប៉ូឡូ គីបូឡយ អះអាងថា គាត់ជាព្រះគ្រីស្ទដែលយាងត្រឡប់មកវិញ ប៉ុន្តែព្រឹត្តិការណ៍ណាខ្លះត្រូវកើតឡើង នៅពេលព្រះគ្រីស្ទពិតយាងមកវិញ?

ព្រះគម្ពីរបាននិយាយច្បាស់ណាស់ អំពីព្រឹត្តិការណ៍ដែលត្រូវតែកើតឡើងនៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ។ យើងអាចប្រើប្រាស់បទទំនាយទាំងនេះ ដើម្បីល្បងមើលថា អាប៉ូឡូ គីបូឡយ គឺជាព្រះគ្រីស្ទពិត ឬជាព្រះគ្រីស្ទក្លែងក្លាយ។

១. ពេលដែលព្រះគ្រីស្ទពិតប្រាកដយាងមកវិញ ទ្រង់នឹង *«សងសេចក្តីទុក្ខលំបាក»* ដល់ពួកអ្នកដែលធ្វើទុក្ខដល់គ្រីស្ទបរិស័ទ ហើយប្រទានការ *«សំរាក»* និងសេចក្តីសង្គ្រោះ ដល់ពួកអ្នកដែលត្រូវគេធ្វើទុក្ខ។ ទ្រង់នឹងមក *«ជាមួយនឹងពួកទេវតានៃព្រះចេស្តាទ្រង់ នៅក្នុងអណ្តាតភ្លើង ទាំងសងសឹកនឹងពួកអ្នកដែលមិនស្គាល់ព្រះ ហើយនិងពួកអ្នកដែលមិនស្តាប់តាមដំណឹងល្អ ពីព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើង»*។ (២ថែស្សាឡូនីច ១:៦-៨) **តើការនេះបានកើតឡើងទេនៅពេលដែល អាប៉ូឡូ គីបូឡយ មកនោះ?**

២. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងមិនយាងមកដោយស្ងាត់ៗទេ។ មនុស្សគ្រប់គ្នានៅលើពិភពលោកនឹងបានឃើញទ្រង់។ *«ព្រោះដំណើរដែលកូនមនុស្សមក នោះនឹងបានដូចជាផ្លេកបន្ទោរ ដែលភ្លឺផ្លេកៗ ពីទិសខាងកើតដល់ទិសខាងលិចដែរ»* និង *«គ្រប់ទាំងភ្នែកនឹងឃើញទ្រង់»* *«ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌*

*មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង»* (ម៉ាថាយ ២៤:២៧; វិវរណៈ ១:៧; ១ថែស្សាឡូនីច ៤:១៦) **តើការនេះបានកើតឡើងទេ នៅពេលដែល អាប៉ូឡូ គីបូឡូយ មកនោះ?**

៣. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ នោះនៅលើមេឃនឹងត្រូវកក្រើករំពើក។ *«ស្រាប់តែថ្ងៃនឹងទៅជាងងឹត ខែនឹងលែងភ្លឺ អស់ទាំងផ្កាយនឹងធ្លាក់ចុះពីលើមេឃ ហើយអស់ទាំងអំណាចនៅលើមេឃនឹងត្រូវកក្រើករំពើក»* (ម៉ាថាយ ២៤:២៩)។ **តើការនេះបានកើតឡើងទេ នៅពេលដែល អាប៉ូឡូ គីបូឡូយ មកនោះ?**

៤. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងយាងមកដោយអំណាច និងសិរីល្អ ហើយមនុស្សមានបាបទាំងអស់នៅលើផែនដីនឹងសោកសៅ។ *«នោះទីសំគាល់របស់កូនមនុស្សនឹងលេចមកនៅលើមេឃ គ្រប់ទាំងពូជមនុស្សនៅផែនដីនឹងគក់ទ្រូងយំ ក៏នឹងឃើញកូនមនុស្ស មកលើពពកនៅលើមេឃ មានទាំងព្រះចេស្តា និងសិរីល្អជាខ្លាំង»* (ម៉ាថាយ ២៤:៣០) **តើការនេះបានកើតឡើងទេ នៅពេលដែល អាប៉ូឡូ គីបូឡូយ មកនោះ?**

៥. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ *«លោកនឹងចាត់ពួកទេវតារបស់លោក ឲ្យមកដោយសូរផ្លុំត្រែជាខ្លាំង ទេវតាទាំងនោះនឹងប្រមូលពួករើសតាំងរបស់លោកពីទិសទាំង៤ ចាប់តាំងពីជើងមេឃម្ខាង រហូតដល់ជើងមេឃម្ខាង»*។ (ម៉ាថាយ ២៤:៣១) **តើការនេះបានកើតឡើងទេ នៅពេលដែល អាប៉ូឡូ គីបូឡូយ មកនោះ?**

៦. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងបំផ្លាញអាទទឹងនឹងព្រះគ្រីស្ទ (ជាមនុស្សដែលត្រូវហិនវិនាស) *«កុំឲ្យអ្នកណាបញ្ឆោតអ្នករាល់គ្នាជាយ៉ាងណាដែរ ដ្បិតថ្ងៃនោះមិនមកឡើយ ទាល់តែមានសេចក្តីក្បត់សាសនាមកជាមុន ហើយមនុស្សដែលជាតួបាបនោះបានលេចមក គឺជាមនុស្សដែលត្រូវហិនវិនាស ដែលទាស់ទទឹង ហើយលើកខ្លួនឡើង ខ្ពស់លើសជាងអស់ទាំងអ្វី ដែលហៅថាព្រះ ឬរបស់អ្វីដែលគេគោរពប្រតិបត្តិផង ដល់ម្ល៉េះបានជាវានឹងអង្គុយនៅ ដូចជាព្រះក្នុងវិហារនៃព្រះ ទាំងសំដែងខ្លួនថាជាព្រះផង...នោះទើបអាទទឹងច្បាប់នោះនឹងលេចមក ដែលព្រះអម្ចាស់យេស៊ូវនឹងបំផ្លាញ*

*ដោយខ្យល់ពីព្រះឱស្ឋទ្រង់ ហើយធ្វើឲ្យវិនាស ដោយរស្មីពន្លឺពីដំណើរទ្រង់យាងមក»* (២ថែស្សាឡូនីច ២:៣-៤, ៨)។ **តើការនេះបានកើតឡើងទេ នៅពេលដែល អាប៉ូឡូ គីបូឡូយ មកនោះ**?

៧. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងចាក់សេចក្តីក្រោធរបស់ទ្រង់ទៅលើអស់អ្នកមានបាបទាំងអស់គ្នា។ *«ដ្បិតអ្នករាល់គ្នាដឹងច្បាស់ហើយថា ថ្ងៃនៃព្រះអម្ចាស់នឹងមកដល់ ដូចជាចោរមកនៅពេលយប់។ ដ្បិតកាលណាគេកំពុងតែនិយាយថា មានសេចក្តីសុខសាន្ត មានសេចក្តីរៀបរយហើយ នោះលោតែមានសេចក្តីហិនវិនាសមកលើគេភ្លាម ដូចជាស្ត្រីមានគភ៌ឈឺនឹងសំរាល ហើយគេចមិនរួចឡើយ»* (១ថែស្សាឡូនីច ៥:២-៣)។ **តើការនេះបានកើតឡើងទេ នៅពេលដែល អាប៉ូឡូ គីបូឡូយ មកនោះ**?

៨. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងកាត់ទោសគ្រប់គ្នាភ្លាមៗ។ *«តែកាលណាកូនមនុស្សនឹងមក ក្នុងសិរីល្អរបស់លោក មានទាំងពួកទេវតាបរិសុទ្ធទាំងអស់គ្នា មកជាមួយ នោះលោកនឹងឡើងគង់លើបល្ល័ង្ករុងរឿងឧត្តមរបស់លោក។ រួចគ្រប់ទាំងសាសន៍ នឹងត្រូវប្រមូលគ្នា នៅចំពោះលោក ហើយលោកនឹងញែកគេចេញពីគ្នា ដូចជាអ្នកគង្វាលដែលញែកចៀមចេញពីពពែដែរ»* (ម៉ាថាយ ២៥:៣១-៣២)។ **តើការនេះបានកើតឡើងទេ នៅពេលដែល អាប៉ូឡូ គីបូឡូយ មកនោះ**?

៩. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មក ទ្រង់នឹងប្រោសរូបកាយអ្នកស្លាប់ទាំងអស់ដែលជាគ្រីស្ទបរិស័ទ។ *«ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង នោះពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់។ រួចយើងរាល់គ្នាដែលកំពុងតែរស់នៅ ក៏នឹងបានលើកឡើង ទៅក្នុងពពកជាមួយគ្នាទាំងអស់ ដើម្បីឲ្យបានជួបជុំនឹងព្រះអម្ចាស់នៅនាអាកាស យ៉ាងនោះ យើងនឹងនៅជាមួយនឹងព្រះអម្ចាស់ជាដរាបទៅ»* (១ថែស្សាឡូនីច ៤:១៦-១៧)។ **តើការនេះបានកើតឡើងទេ នៅពេលដែល អាប៉ូឡូ គីបូឡូយ មកនោះ**?

១០. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មក ទ្រង់នឹងមិនកើតមកជាទារកតូចទេ ប៉ុន្តែទ្រង់នឹងយាងមកពីស្ថានសួគ៌ជាអ្នកចម្បាំងដ៏មានគ្រប់ព្រះចេស្តា ដើម្បីវិនិច្ឆ័យ

ជំនុំជម្រះផែនដី។ *«ខ្ញុំក៏ឃើញមេឃបើកចំហឡើង នោះឃើញមានសេះស១ និងព្រះអង្គដែលគង់លើវា ទ្រង់មានព្រះនាមថា «ស្មោះត្រង់ ហើយពិតប្រាកដ» ទ្រង់ជំនុំជំរះ ហើយច្បាំងដោយសុចរិត ១២ ព្រះនេត្រទ្រង់ដូចជាអណ្តាតភ្លើង ហើយនៅលើព្រះសិរសា មានមកុដជាច្រើន ទ្រង់មានព្រះនាមកត់ទុក ដែលគ្មានអ្នកណាស្គាល់ឡើយ លើកតែអង្គទ្រង់ប៉ុណ្ណោះ ១៣ ទ្រង់ក៏ទ្រង់ព្រះពស្ត្រជ្រលក់ដោយឈាម ហើយព្រះនាមទ្រង់ហៅថា «ព្រះបន្ទូលនៃព្រះ» ១៤ អស់ទាំងពលបរិវារនៅស្ថានសួគ៌ ក៏ជិះសេះសដង្ហែទ្រង់ ទាំងស្លៀកពាក់សំពត់ទេស ហើយស្អាតផង ១៥ មានដាវយ៉ាងមុតចេញពីព្រះឱសទ្រង់ ដើម្បីនឹងកាប់អស់ទាំងសាសន៍ ហើយទ្រង់នឹងឃ្វាលគេ ដោយដំបងដែក ទ្រង់ក៏ជាន់ក្នុងធុងឃ្នាបនៃស្រាទំពាំងបាយជូរ ជាសេចក្តីឃោរឃៅរបស់សេចក្តីខ្ញាល់នៃព្រះដ៏មានព្រះចេស្តាបំផុត ១៦ ទ្រង់មានព្រះនាមកត់នៅព្រះពស្ត្រ ហើយនៅព្រះឧរូទ្រង់ថា «ស្តេចលើអស់ទាំងស្តេច ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់»*។ (វិវរណៈ ១៩:១១-១៦)។ **តើការនេះបានកើតឡើងទេនៅពេលដែល អាប៉ូឡូ គីបូឡុយ មកនោះ?**

**គ្មានព្រឹត្តិការណ៍ណាមួយបានកើតឡើងសោះ ក្នុងចំណោមព្រឹត្តិការណ៍ទាំងនេះ នៅពេលដែល អាប៉ូឡូ គីបូឡុយ បានកើតនៅប្រទេសហ្វីលីពីន។** អាប៉ូឡូ គីបូឡុយ ជាព្រះគ្រីស្ទក្លែងក្លាយ។

## សេចក្តីសន្និដ្ឋាន

អាប៉ូឡូ គីបូឡុយមានអាយុ៧០ឆ្នាំហើយ។ គាត់មិនអាចរស់រហូតបានទេ តើគាត់នឹងរស់ឡើងវិញដូចជាព្រះយេស៊ូវបានរស់ពីសុគតឡើងវិញដែរឬទេ? ទេ ពីព្រោះគាត់មិនមែនជាព្រះរាជបុត្រាពិតទេ។ គាត់មិនមែនជាម្ចាស់ពិតនៃសកលលោកទេ គ្រាន់តែជាមនុស្សធម្មតាម្នាក់ប៉ុណ្ណោះ។ បើគាត់ជាម្ចាស់នៃសាកលលោក គាត់ក៏ជាម្ចាស់លើសេចក្តីស្លាប់ផងដែរ។

ប៉ុន្តែព្រះយេស៊ូវគ្រីស្ទពិតបានសុគតសម្រាប់បាបយើង និងមានព្រះជន្មរស់ឡើងវិញ ហើយរស់នៅអស់កល្បជានិច្ច។ បន្ថិចទៀតទ្រង់នឹងយាងត្រឡប់មកវិញ ដើម្បី

វិនិច្ឆ័យគ្រូក្លែងក្លាយទាំងអស់ ដូចជាអាប៉ូឡូ គីបូឡូយ និងអស់អ្នកដែលដើរតាមគាត់។

ជាចុងក្រោយសូមកុំភ្លេច២យ៉ូហាន ១:១០-១១ ៖ *«បើអ្នកណាមកឯអ្នករាល់គ្នា តែមិនបង្រៀនចំពោះសេចក្ដីនេះ នោះកុំឲ្យទទួលអ្នកនោះនៅក្នុងផ្ទះឡើយ កុំឲ្យទាំងជំរាបសួរដល់អ្នកនោះផង ដ្បិតបើអ្នកណាជំរាបសួរ នោះក៏តែងមានសេចក្ដីប្រកបគ្នាក្នុងការអាក្រក់របស់អ្នកនោះដែរ»*។

***ព័ត៌មានថ្មី*** *៖ នៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០២១ មេធាវីរដ្ឋាភិបាលអាមេរិក បានចោទប្រកាន់អាប៉ូឡូ គីបូឡូយនៅក្នុងតុលាការសហរដ្ឋអាមេរិក ពីបទជួញដូរមនុស្ស និងរួមភេទជាមួយអនីតិជន។ យើងចាំមើលដំណើរការកាត់ក្តីនោះ។*

( https://www.cnnphilippines.com/news/2021/11/19/Apollo-Quiboloy-sex-trafficking-church-United-States.html )

## ធនធានគួរទុកចិត្តៈ

https://carm.org/kingdom-of-jesus-christ/a-biblical-response-to-the-teachings-of-pastor-apollo-quiboloy-and-the-kingdom-of-jesus-christ/?highlight=Apollo%20Quiboloy

# លី ម៉ាន់ហ៊ី និង ព្រះវិហារស៊ីនឆន់ជី

**Lee Man-hee**

**ព្រះវិហារសាសនាគ្រីស្ទ ស៊ីនឆន់ជី (Shincheonji)**

**ដែហ្គូ ប្រទេស កូរ៉េ**

## ប្រវត្តិ

លី ម៉ាន់ហ៊ី កើតនៅឆ្នាំ១៩៣១នៅឆេនឌូប្រទេសកូរ៉េ។ គាត់បានបង្កើតក្រុមខុសឆ្គង ស៊ីនឆន់ជី ក្នុងឆ្នាំ១៩៨៤ ហើយគាត់បានហៅខ្លួនឯងថា ជា«គ្រូគង្វាលដែលព្រះបានសន្យា» ហើយជា ព្រះគ្រីស្ទដែលត្រូវយាងមកលើកទីពីរ។ គាត់អះអាងថា មានតែគាត់ទេ ទើបអាចយល់ព្រះគម្ពីរបានយ៉ាងត្រឹមត្រូវ។ គាត់សន្យានឹងយកមនុស្ស ១៤៤000នាក់ទៅស្ថានសួគ៌ជាមួយគាត់នៅថ្ងៃជំនុំជម្រះ។



ឈ្មោះស៊ីនឆន់ជី ជាភាសាកូរ៉េ ប្រែពីកណ្ឌគម្ពីរវិវរណៈ ២១:១ ប្រែថា «ផ្ទៃមេឃថ្មី និងផែនដីថ្មី»។ ឈ្មោះជាផ្លូវការនៃក្រុមនេះគឺ ស៊ីនឆន់ជី ក្រុមជំនុំនៃព្រះយេស៊ូវ វិហាររោងឧបោសថនៃសេចក្តីបន្ទាល់។

ដូចជាក្រុមខុសឆ្គងឯទៀតដែរ ស៊ីនឆន់ជី ចូលចិត្តបង្កើតអង្គការជាច្រើន ដែលពួកគេប្រើជាមធ្យោបាយ ដើម្បីបានសមាជិកថ្មី ដូចជា៖ សមាគមអ្នកស្ម័គ្រចិត្ត Mannam/សម្ព័ន្ធយុវជនអន្តរជាតិ Mannam (MIYC) ក្រុមយុវជនសន្តិភាពអន្តរជាតិ (IPYG) / វប្បធម៌សួគ៌ា សន្តិភាពពិភពលោក ការស្តារឡើងវិញនៃពន្លឺ(HWPL) ប៉ារ៉ាគ្រីស្តូ វិហាររោងឧបោសថនៃសេចក្តីបន្ទាល់(SCJ) ការសិក្សាព្រះគម្ពីរអន្តរជាតិស៊ីយ៉ូន។ [ Mannam Volunteer Association/Mannam International Youth Coalition (MIYC), International Peace Youth Group (IPYG), Heavenly Culture, World Peace, Restoration of Light (HWPL), Parachristo, Temple of the Tabernacle of the Testimony (SCJ), and Zion International Bible Study ]

## ជំនឿ

**ក្រុមស៊ីនឆន់ជីជឿថា ក្រុមស៊ីនឆន់ជី គឺជាផ្លូវតែមួយគត់ទៅឯព្រះ។** អ្នកសម្ភាសន៍ម្នាក់មកពីទស្សនាវដ្តីពិភពលោក *(The World)* បានសួរលី ម៉ាន់ហ៊ីថា៖ «ក្នុងអាយុកាល២០០០ឆ្នាំ នៃប្រវត្តិសាស្រ្តរបស់គ្រីស្ទបរិស័ទ តើស៊ីនឆន់ជី គឺជាផ្លូវពិតតែមួយគត់ទៅឯព្រះឬ?» លី ម៉ាន់ហ៊ី បានឆ្លើយថា «បាទ ត្រូវហើយ»។ (https://www.pri.org/stories/2017-07-11/apocalyptic-korean-christian-group-goes-different-names-critics-say-its-just-cult)

**ក្រុមស៊ីនឆន់ជីថា ព្រះយេស៊ូវបានយាងត្រឡប់មកវិញជា លី ម៉ាន់ហ៊ី**! លី ម៉ាន់ហ៊ីនិយាយថា ការយាងមកជាលើកទី២របស់ព្រះគ្រីស្ទ បានកើតឡើងនៅលើផែនដីរួចហើយ គឺវិញ្ញាណរបស់ព្រះគ្រីស្ទបានមកសណ្ឋិតលើរូបកាយរបស់ លី ម៉ាន់ហ៊ី (ហាន ២០១៣:១២៩-១៣២)។

**ក្រុមស៊ីនឆន់ជីលើសេចក្តីសង្គ្រោះ តាមរយៈការប្រព្រឹត្ត។** «លី ម៉ាន់ហ៊ី អះអាងថា សេចក្តីសង្គ្រោះត្រូវបានផ្តល់តាមរយៈបុណ្យចាំបាច់ពីរ គឺជំនឿ និងការប្រព្រឹត្ត។ ជំនួសឲ្យការជឿថា សេចក្តីសង្គ្រោះត្រូវបានតាមរយៈជំនឿតែប៉ុណ្ណោះ គាត់អះអាងថា សេចក្តីសង្គ្រោះបានតាមរយៈការធ្វើល្អ (ហាន ២០១៣:៤២៨)»។ (https://repository.up.ac.za/bitstream/handle/2263/53079/Kim_Shincheonji_2016.pdf?sequence=1&isAllowed=y)។

**ក្រុមស៊ីនឆន់ជីជឿថា លី ម៉ាន់ហ៊ីមិនចេះស្លាប់ទេ ហើយគាត់នឹងនាំមនុស្ស ១៤៤000នាក់ទៅស្ថានសួគ៌** ជាមួយគាត់នៅថ្ងៃជំនុំជម្រះ។ ក្រុមស៊ីនឆន់ជីបង្រៀនថា មនុស្ស១៤៤000នាក់ដែលបានរៀបរាប់នៅក្នុងកណ្ឌគម្ពីរវិវរណៈ ៧:៤ គឺជាសមាជិកនៃកុលសម្ព័ន្ធទាំង១២នៃស៊ីនឆន់ជី។

**ក្រុមស៊ីនឆន់ជីបដិសេធគោលលទ្ធិព្រះត្រៃឯក។**

**ក្រុមស៊ីនឆន់ជីអះអាងថា មនុស្សទាំងអស់ជាទេវតាដែលបានចុះមកផែនដី។**

**ក្រុមស៊ីនឆន់ជីជឿជាក់ថា មានតែ លី ម៉ាន់ហ៊ីតែម្នាក់ប៉ុណ្ណោះ ដែលមានសមត្ថភាពបកស្រាយព្រះបន្ទូលនៃព្រះយ៉ាងត្រឹមត្រូវ។**

លី ម៉ាន់ហ៊ី មានអាយុ៩0ឆ្នាំហើយ គាត់នឹងមិនរស់ពីស្លាប់ឡើងវិញ ដូចព្រះយេស៊ូវគ្រីស្ទពិតទេ។ គាត់នឹងមិននាំសមាជិក ១៤៤000 នាក់ទៅស្ថានសួគ៌ទេ។ មិនយូរមិនឆាប់មនុស្សទាំងអស់នឹងឃើញថា គាត់ជាមនុស្សធម្មតា ដែលគ្មានអំណាចលើអំពើបាប និងសេចក្តីស្លាប់ទេ។ មានតែព្រះគ្រីស្ទពិត ដែលព្រះគម្ពីរបានចែងតែប៉ុណ្ណោះ ដែលមានអំណាចលើអំពើបាប និងសេចក្តីស្លាប់។

ក្រុមប្រឹក្សា និងនិកាយប្រូតេស្តង់ទាំងអស់នៅប្រទេសកូរ៉េ បានរួមគ្នាចេញសេចក្តីថ្លែងការណ៍ព្រមានថា ស៊ីនឆន់ជីគឺជាក្រុមខុសឆ្គង ហើយលី ម៉ាន់ហ៊ីគឺជាគ្រូក្លែងក្លាយ។

## មធ្យោបាយក្រុមស៊ីនឆន់ជី គឺលួចក្រុមជំនុំ និងសមាជិកក្រុមជំនុំ

សូមចាំថា ក្រុមខុសឆ្គងតែងតែព្យាយាមលួចក្រុមជំនុំ និងសមាជិកក្រុមជំនុំ ពីព្រោះការនោះងាយស្រួលជាងការបង្កើតក្រុមជំនុំខ្លួនឯង។ «...នៅក្នុងវីដេអូ ពីសិក្ខាសាលាស៊ីនឆន់ជី ដែល កាសែតញូវយ៉កថែមស៍ (New York Times) បានឃើញ គ្រូបង្រៀនបាននិយាយថា របៀបចាស់នៃការបង្កើតក្រុមជំនុំ ហើយកសាងវា <ថ្លៃពេក ត្រូវការមនុស្សច្រើនពេក ហើយអស់រយៈពេលយូរពេក។ ការលេបក្រុមជំនុំដែលមានស្រាប់ហើយ ល្អជាង... តែកុំប្រាប់មធ្យោបាយនេះដល់អ្នកឯទៀត >» (https://www.culteducation.com/group/1331-shinchonji-church-founder-man-hee-lee-/35334-in-bad-faith.html)

## លី ម៉ាន់ហ៊ី អះអាងថា គាត់ជាព្រះគ្រីស្ទដែលយាងត្រឡប់មកវិញ ប៉ុន្តែព្រឹត្តិការណ៍ណាខ្លះត្រូវកើតឡើង នៅពេលព្រះពិតយាងមកវិញ?

ព្រះគម្ពីរបាននិយាយច្បាស់ណាស់ អំពីព្រឹត្តិការណ៍ដែលត្រូវតែកើតឡើងនៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ។ យើងអាចប្រើប្រាស់បទទំនាយទាំងនេះ ដើម្បីល្បងមើល ថា លី ម៉ាន់ហ៊ី គឺជាព្រះគ្រីស្ទពិត ឬជាព្រះគ្រីស្ទក្លែងក្លាយ។

១. ពេលដែលព្រះគ្រីស្ទពិតប្រាកដយាងមកវិញ ទ្រង់នឹង *«សងសេចក្តីទុក្ខលំបាក»* ដល់ពួកអ្នកដែលធ្វើទុក្ខដល់គ្រីស្ទបរិស័ទ ហើយប្រទានការ *«សំរាក»* និងសេចក្តីសង្គ្រោះ ដល់ពួកអ្នកដែលត្រូវគេធ្វើទុក្ខ។ ទ្រង់នឹងមក *«ជាមួយនឹងពួកទេវតានៃព្រះចេស្តាទ្រង់ នៅក្នុងអណ្តាតភ្លើង ទាំងសងសឹកនឹងពួកអ្នកដែលមិនស្គាល់ព្រះ ហើយនិងពួកអ្នកដែលមិនស្តាប់*

*តាមដំណឹងល្អ ពីព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើង»*។ (២ថែស្សាឡូនីច ១:៦-៨) **តើការនេះបានកើតឡើងទេនៅពេលដែល លី ម៉ាន់ហ៊ី មកនោះ?**

២. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងមិនយាងមកដោយស្ងាត់ៗទេ។ មនុស្សគ្រប់គ្នានៅលើពិភពលោកនឹងបានឃើញទ្រង់។ *«ព្រោះដំណើរដែលកូនមនុស្សមក នោះនឹងបានដូចជាផ្លេកបន្ទោរ ដែលភ្លឺផ្លេកៗ ពីទិសខាងកើតដល់ទិសខាងលិចដែរ»* និង *«គ្រប់ទាំងភ្នែកនឹងឃើញទ្រង់» «ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង»* (ម៉ាថាយ ២៤:២៧; វិវរណៈ ១:៧; ១ថែស្សាឡូនីច ៤:១៦) **តើការនេះបានកើតឡើងទេនៅពេលដែល លី ម៉ាន់ហ៊ី មកនោះ?**

៣. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ នោះនៅលើមេឃនឹងត្រូវកក្រើករំពើក។ *«ស្រាប់តែថ្ងៃនឹងទៅជាងងឹត ខែនឹងលែងភ្លឺ អស់ទាំងផ្កាយនឹងធ្លាក់ចុះពីលើមេឃ ហើយអស់ទាំងអំណាចនៅលើមេឃនឹងត្រូវកក្រើករំពើក»* (ម៉ាថាយ ២៤:២៩)។ **តើការនេះបានកើតឡើងទេ នៅពេលដែល លី ម៉ាន់ហ៊ី មកនោះ?**

៤. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងយាងមកដោយអំណាច និងសិរីល្អ ហើយមនុស្សមានបាបទាំងអស់នៅលើផែនដីនឹងសោកសៅ។ *«នោះទីសំគាល់របស់កូនមនុស្សនឹងលេចមកនៅលើមេឃ គ្រប់ទាំងពូជមនុស្សនៅផែនដីនឹងគក់ទ្រូងយំ ក៏នឹងឃើញកូនមនុស្ស មកលើពពកនៅលើមេឃ មានទាំងព្រះចេស្តា និងសិរីល្អជាខ្លាំង»* (ម៉ាថាយ ២៤:៣០) **តើការនេះបានកើតឡើងទេ នៅពេលដែល លី ម៉ាន់ហ៊ី មកនោះ?**

៥. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ *«លោកនឹងចាត់ពួកទេវតារបស់លោក ឲ្យមកដោយសូរផ្លុំត្រែជាខ្លាំង ទេវតាទាំងនោះនឹងប្រមូលពួករើសតាំងរបស់លោកពីទិសទាំង៤ ចាប់តាំងពីជើងមេឃម្ខាង រហូតដល់ជើងមេឃម្ខាង»*។ (ម៉ាថាយ ២៤:៣១) **តើការនេះបានកើតឡើងទេ នៅពេលដែល លី ម៉ាន់ហ៊ី មកនោះ?**

៦. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងបំផ្លាញអាទទឹងនឹងព្រះគ្រីស្ទ (ជាមនុស្សដែលត្រូវហិនវិនាស) *«កុំឲ្យអ្នកណាបញ្ឆោតអ្នករាល់គ្នាជាយ៉ាងណា*

*ដែរ ដ្បិតថ្ងៃនោះមិនមកឡើយ ទាល់តែមានសេចក្ដីក្បត់សាសនាមកជាមុន ហើយមនុស្ស ដែលជាតួបាបនោះបានលេចមក គឺជាមនុស្សដែលត្រូវហិនវិនាស ដែលទាស់ទទឹង ហើយ លើកខ្លួនឡើង ខ្ពស់លើសជាងអស់ទាំងអ្វី ដែលហៅថាព្រះ ឬរបស់អ្វីដែលគេគោរព ប្រតិបត្តិផង ដល់ម្ល៉េះបានជាវានឹងអង្គុយនៅ ដូចជាព្រះក្នុងវិហារនៃព្រះ ទាំងសំដែងខ្លួនថា ជាព្រះផង...នោះទើបអាទទឹងច្បាប់នោះនឹងលេចមក ដែលព្រះអម្ចាស់យេស៊ូវនឹងបំផ្លាញ ដោយខ្យល់ពីព្រះឱស្ឋទ្រង់ ហើយធ្វើឲ្យវិនាស ដោយរស្មីពន្លឺពីដំណើរទ្រង់យាងមក»* (២ថែស្សាឡូនីច ២:៣-៤, ៨)។ **តើការនេះបានកើតឡើងទេ នៅពេលដែល លី ម៉ាន់ហ៊ី មកនោះ**?

៧. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងចាក់សេចក្ដីក្រោធរបស់ ទ្រង់ទៅលើអស់អ្នកមានបាបទាំងអស់គ្នា។ *«ដ្បិតអ្នករាល់គ្នាដឹងច្បាស់ហើយថា ថ្ងៃនៃ ព្រះអម្ចាស់នឹងមកដល់ ដូចជាចោរមកនៅពេលយប់។ ដ្បិតកាលណាគេកំពុងតែនិយាយថា មានសេចក្ដីសុខសាន្ត មានសេចក្ដីរៀបរយហើយ នោះលោតែមានសេចក្ដីហិនវិនាសមក លើគេភ្លាម ដូចជាស្ត្រីមានគភ៌ឈឺនឹងសំរាល ហើយគេចមិនរួចឡើយ»* (១ថែស្សាឡូនីច ៥:២-៣)។ **តើការនេះបានកើតឡើងទេ នៅពេលដែល លី ម៉ាន់ហ៊ី មកនោះ**?

៨. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងកាត់ទោសគ្រប់គ្នាភ្លាមៗ។ *«តែកាលណាកូនមនុស្សនឹងមក ក្នុងសិរីល្អរបស់លោក មានទាំងពួកទេវតាបរិសុទ្ធទាំង អស់គ្នា មកជាមួយ នោះលោកនឹងឡើងគង់លើបល្ល័ង្ករុងរឿងឧត្តមរបស់លោក។ រួចគ្រប់ ទាំងសាសន៍ នឹងត្រូវប្រមូលគ្នា នៅចំពោះលោក ហើយលោកនឹងញែកគេចេញពីគ្នា ដូចជា អ្នកគង្វាលដែលញែកចៀមចេញពីពពែដែរ»* (ម៉ាថាយ ២៥:៣១-៣២)។ **តើការនេះបាន កើតឡើងទេ នៅពេលដែល លី ម៉ាន់ហ៊ី មកនោះ**?

៩. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មក ទ្រង់នឹងប្រោសរូបកាយអ្នកស្លាប់ទាំង អស់ដែលជាគ្រីស្ទបរិស័ទ។ *«ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយ ស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង នោះពួកស្លាប់ ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់។ រួចយើងរាល់គ្នាដែលកំពុងតែរស់នៅ ក៏នឹង បានលើកឡើង ទៅក្នុងពពកជាមួយគ្នាទាំងអស់ ដើម្បីឲ្យបានជួបជុំនឹងព្រះអម្ចាស់នៅនា*

*អាកាស យ៉ាងនោះ យើងនឹងនៅជាមួយនឹងព្រះអម្ចាស់ជាដរាបទៅ»* (១ថែស្សាឡូនីច ៤:១៦-១៧)។ **តើការនេះបានកើតឡើងទេ នៅពេលដែល លី ម៉ាន់ហ៊ី មកនោះ?**

១០. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មក ទ្រង់នឹងមិនកើតមកជាទារកតូចទេ ប៉ុន្តែទ្រង់នឹងយាងមកពីស្ថានសួគ៌ជាអ្នកចម្បាំងដ៏មានគ្រប់ព្រះចេស្តា ដើម្បីវិនិច្ឆ័យជំនុំជម្រះផែនដី។ *«ខ្ញុំក៏ឃើញមេឃបើកចំហឡើង នោះឃើញមានសេះស១ និងព្រះអង្គដែលគង់លើវា ទ្រង់មានព្រះនាមថា «ស្មោះត្រង់ ហើយពិតប្រាកដ» ទ្រង់ជំនុំជំរះ ហើយច្បាំងដោយសុចរិត ១២ ព្រះនេត្រទ្រង់ដូចជាអណ្តាតភ្លើង ហើយនៅលើព្រះសិរសា មានមកុដជាច្រើន ទ្រង់មានព្រះនាមកត់ទុក ដែលគ្មានអ្នកណាស្គាល់ឡើយ លើកតែអង្គទ្រង់ប៉ុណ្ណោះ ១៣ ទ្រង់ក៏ទ្រង់ព្រះពស្ត្រជ្រលក់ដោយឈាម ហើយព្រះនាមទ្រង់ហៅថា «ព្រះបន្ទូលនៃព្រះ» ១៤ អស់ទាំងពលបរិវារនៅស្ថានសួគ៌ ក៏ជិះសេះសដង្ហែទ្រង់ ទាំងស្លៀកពាក់សំពត់ទេស ហើយស្អាតផង ១៥ មានដាវយ៉ាងមុតចេញពីព្រះឱសទ្រង់ ដើម្បីនឹងកាប់អស់ទាំងសាសន៍ ហើយទ្រង់នឹងឃ្វាលគេ ដោយដំបងដែក ទ្រង់ក៏ជាន់ក្នុងធុងឃ្នាបនៃស្រាទំពាំងបាយជូរ ជាសេចក្តីឃោរឃៅរបស់សេចក្តីខ្ញាល់នៃព្រះដ៏មានព្រះចេស្តាបំផុត ១៦ ទ្រង់មានព្រះនាមកត់នៅព្រះពស្ត្រ ហើយនៅព្រះឱរូទ្រង់ថា «ស្តេចលើអស់ទាំងស្តេច ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់»*។ (វិវរណៈ ១៩:១១-១៦)។ **តើការនេះបានកើតឡើងទេនៅពេលដែល លី ម៉ាន់ហ៊ី មកនោះ?**

**គ្មានព្រឹត្តិការណ៍ណាមួយបានកើតឡើងសោះ ក្នុងចំណោមព្រឹត្តិការណ៍ទាំងនេះ នៅពេលដែល លី ម៉ាន់ហ៊ី មកនោះ។** លី ម៉ាន់ហ៊ី ជាព្រះគ្រីស្ទក្លែងក្លាយ។



## មុខពូថៅ

តើអ្វីខ្លះជាមុខពូថៅ ដែលក្រុមស៊ីនឆន់ជីប្រើ ដើម្បីចូលក្នុងក្រុមជំនុំ ហើយបំបែកវា? ពួកគេប្រើពាក្យសំដីគ្រីស្ទសាសនា ដែលគ្រីស្ទបរិស័ទទាំងអស់ស្គាល់។ ដើម្បីរក

មនុស្សថ្មី សមាជិកស៊ីនឆន់ជីនឹងទៅជួបមនុស្សនៅទីក្រុង ហើយអញ្ជើញឲ្យគេចូលរួមសាលារៀនភាសាអន្តរជាតិ ដោយឥតគិតថ្លៃ។ ឬសមាជិកស៊ីនឆន់ជីចូលរួមការថ្វាយបង្គំនៅព្រះវិហារគ្រីស្ទបរិស័ទ ហើយបន្ទាប់ពីកម្មវិធីថ្វាយបង្គំ គេក៏អញ្ជើញគ្រីស្ទបរិស័ទចូលរួម «ការសិក្សាព្រះគម្ពីរ»។ មុនដំបូង «ការសិក្សាព្រះគម្ពីរ»នេះ គឺរៀនពីគោលលទ្ធិគ្រឹះ នៃគ្រីស្ទសាសនា ប៉ុន្តែមិនយូរមិនឆាប់ គេផ្តោតសំខាន់លើមេដឹកនាំសាសនានៃក្រុមខុសឆ្គងនេះ គឺលី ម៉ាន់ហ៊ី។ ត្រង់ចំណុចនេះ ក្រុមខុសឆ្គងប្រាប់អ្នកដើរតាមថ្មីថា ក្រុមជំនុំទាំងអស់ សុទ្ធតែមកពីអារក្សសាតាំង ហើយពួកគេត្រូវតែកាត់ផ្តាច់រាល់ទំនាក់ទំនងជាមួយមនុស្សខាងក្រៅស៊ីនឆន់ជី។ ក្រុមស៊ីនឆន់ជីក៏បើកសកលវិទ្យាល័យធំមួយ ហើយប្រើសាលានោះ ដើម្បីបានសមាជិកថ្មី។

ជាចុងក្រោយកុំភ្លេច ២យ៉ូហាន ១:១០-១១ ៖ «បើអ្នកណាមកឯអ្នករាល់គ្នា តែមិនបង្រៀនចំពោះសេចក្តីនេះ នោះកុំឲ្យទទួលអ្នកនោះនៅក្នុងផ្ទះឡើយ កុំឲ្យទាំងជំរាបសួរដល់អ្នកនោះផង ដ្បិតបើអ្នកណាជំរាបសួរ នោះក៏តែងមានសេចក្តីប្រកបគ្នាក្នុងការអាក្រក់របស់អ្នកនោះដែរ»។



*នៅខែមករាឆ្នាំ ២០២១ លី ម៉ាន់ហ៊ីត្រូវបានប្រកាសថាមានពិរុទ្ធភាពនៅតុលាការស្រុកស៊ូវ៉ុន ប្រទេសកូរ៉េ ពីបទចោទប្រកាន់ថាបានកិបកេងលុយព្រះវិហារជាង ៥ លានដុល្លារ។ នៅក្នុងរូបភាពនេះគាត់ត្រូវបានដោះលែងឲ្យនៅក្រៅឃុំ។*

( https://www.koreatimes.co.kr/www/nation/2021/12/251_319746.html )

## ធនធានគួរទុកចិត្តៈ

*https://www.apologeticsindex.org/14298-shincheonji-cult-of-christianity*

# សាន់ ម៉ុង មូន

## Sun Myung Moon

## ព្រះវិហារបង្រួបបង្រួម Unification Church

## សហព័ន្ធគ្រួសារដើម្បីសន្តិភាព និងការបង្រួបបង្រួមពិភពលោក (FFWPU)

## (សមាគមព្រះវិញ្ញាណបរិសុទ្ធសម្រាប់ការបង្រួបបង្រួមគ្រីស្ទសាសនាពិភពលោក)

## សេអ៊ូល ប្រទេសកូរ៉េ

## ប្រវត្តិ

សាន់ ម៉ុង មូន (Sun Myung Moon ត្រកូលគឺ Moon) កើតនៅទីក្រុង ជុងជូ (Chongju) ខេត្ត ព្យុងកាន (Pyongan) ប្រទេសកូរ៉េ (បច្ចុប្បន្នកូរ៉េខាងជើង) នៅថ្ងៃទី ៦ ខែមករា ឆ្នាំ១៩២០។ លោក មូន អះអាងថា នៅពេលគាត់មានអាយុ ១៦ឆ្នាំ ព្រះយេស៊ូវបានលេចមកជួបនឹងគាត់ ហើយប្រាប់គាត់ថា ព្រះយេស៊ូវបានបរាជ័យក្នុងបេសកកម្មរបស់ទ្រង់កាលពី ២០០០ ឆ្នាំមុន ពីព្រោះទ្រង់បានសុគតដោយមិនបានរៀបការ និងបង្កើតគ្រួសារល្អឥតខ្ចោះមួយ ដែលគ្មានបាប។ ដូច្នេះ លោក មូន ត្រូវតែជាព្រះមែស៊ីថ្មី ដើម្បីធ្វើអ្វីដែលព្រះយេស៊ូវ បានបរាជ័យ។ ដូច្នេះ លោក មូន បានបង្កើតសាសនាថ្មីដែលហៅ Unification Church។

លោក មូន បានរៀបការជាមួយប្រពន្ធដំបូងរបស់គាត់ឈ្មោះ ឆយ ស៊ីន-គីល (Choi Seon-gil) នៅថ្ងៃទី ១ ខែមីនា ឆ្នាំ ១៩៤៥។ ក្រោយនាងបានលែងលះជាមួយគាត់ដោយនិយាយថា «ប្ដីរបស់ខ្ញុំមានទំនាក់ទំនងម្ដងហើយម្ដងទៀត ដោយបោកស្រីទាំងនោះ។ ខ្ញុំបានគិតថា ខ្ញុំមិនអាចទ្រាំទ្រជីវិតបែបនោះទៀតទេ ដូច្នេះ នេះ

ជាហេតុផលនៃការលែងលះរបស់ខ្ញុំ»។ (បទសម្ភាសន៍ដោយ ប៉ាក ជុង-ហ្វា នៅទីក្រុងសេអ៊ូល ខែសីហា ១៩៩២)។

ខណៈពេលដែលគាត់នៅតែរៀបការជាមួយ ឆយ ស៊ីន-គីល លោក មូន បានយកប្រពន្ធមិនស្របច្បាប់ពីរនាក់នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០។ នៅខែមេសា ឆ្នាំ១៩៦០ គាត់បានរៀបការជាមួយ ហាន ហាក់ ចា (Han Hak Ja) អាយុ ១៧ ឆ្នាំ។ ហើយពួកគេមានកូន១៤នាក់។

ទោះបីជាលោក មូន អះអាងថា ជាព្រះគ្រីស្ទក៏ដោយ គាត់បានស្លាប់នៅថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ២០១២ **ហើយមិនបានរស់ឡើងវិញទេ**។ បន្ទាប់ពីលោក មូន ស្លាប់ទៅ ប្រពន្ធរបស់គាត់ឈ្មោះ ហាន ហាក់ ចា បានក្លាយជាអគ្គនាយកតែមួយគត់ នៃក្រុម Unification Church។ គាត់ក៏អះអាងថា ខ្លួនជាព្រះមែស៊ីដែរ ប៉ុន្តែយើងដឹងថា គាត់ក៏នឹងមិនរស់ពីស្លាប់ឡើងវិញដែរ។ មានតែព្រះយេស៊ូវគ្រីស្ទដែលជាព្រះមែស៊ីពិតប៉ុណ្ណោះ ដែលបានបង្ហាញព្រះចេស្តារបស់ទ្រង់លើសេចក្តីស្លាប់ តាមរយៈការរស់ឡើងវិញរបស់ទ្រង់។

## ជំនឿ

**លោកមូនបានបង្រៀនថា បាបដើមនៅចម្ការអេដែន គឺជាការរួមភេទរវាងសាតាំង និងអេវ៉ា។** ដោយសារបាបនេះស្បូននិងឈាមរបស់អេវ៉ា មានពេញដោយអំពើបាប ហើយពូជពង្សទាំងអស់របស់នាង ត្រូវកើតមកដោយមានបាបដែរ។ គាត់ក៏បង្រៀនថា ដំណោះស្រាយតែមួយគត់ ដើម្បីសម្អាតបាបដើមនេះ គឺស្រីៗត្រូវតែមានទំនាក់ទំនងផ្លូវភេទជាមួយបុរស ឥតខ្ចោះ («អ័ដាមពិត») ដើម្បីឲ្យឈាម និងស្បូនរបស់ពួកនាង អាចត្រូវបានសម្អាតពីអំពើបាបដើមរបស់អេវ៉ា។ លោកមូនបានហៅការនេះថា ពិធីលាងសម្អាតឈាម (ពិធី ពីការីអឹម)។ លោកមូន បានអះអាងថា គាត់ហើយជាបុរសល្អឥតខ្ចោះ ដែលអាចបន្សុទ្ធស្បូនស្រីៗតាមរយៈការរួមភេទ។ នេះគឺ

ជាការប្រមាថ និងអសីលធម៌បំផុត។ ពិធីលាងសម្អាតឈាម (បន្សុទ្ធស្បូន) ត្រូវបានអនុវត្តតាំងពីដំបូងនៃសាសនានេះ ក្នុងឆ្នាំ ១៩៤៥ រហូតដល់ឆ្នាំ ១៩៦២។ នៅឆ្នាំ ១៩៦២ ពិធីទំពាំងបាយជូរបរិសុទ្ធ និងពិធីបីថ្ងៃ បានជំនួសពិធីសម្អាតឈាម។ (*Change of Blood Lineage through Ritual Sex in the Unification Church*, Kirsti L. Nevalainen, 2010)

**លោកមូនក៏បានបង្រៀនផងដែរថា ព្រះយេស៊ូវគ្រីស្ទត្រូវរៀបការ និងមានកូន** ដើម្បីឲ្យទ្រង់អាចចូលរួមក្នុងការជួយស្ត្រី «សម្អាតស្បូនរបស់ពួកគេ» និងបង្កើតសាសន៍ថ្មីដែលគ្មានបាបសោះ។ ប៉ុន្តែព្រះយេស៊ូវបានបដិសេធមិនបានជួយតាមរបៀបនោះទេ ដូច្នេះទ្រង់បានសុគតដោយបរាជ័យ។ លោកមូនបានអះអាងថា ខ្លួនគាត់ត្រូវបានបញ្ជូនមកឲ្យធ្វើអ្វីដែលព្រះយេស៊ូវមិនបានធ្វើ។ នេះគឺជាការប្រមាថដល់ព្រះយេស៊ូវ។

**លោក មូន បានអះអាងថា ជាព្រះមែស៊ី ដែលគ្មានបាប** ដែលព្រះបានបញ្ជូនមកដើម្បីជួយសង្គ្រោះមនុស្សជាតិ។

**លោក មូន បានបង្រៀនថា មនុស្សមានបាបអាចគាប់ព្រះហឫទ័យដល់ព្រះដោយការសងដល់ព្រះ។** «ដើម្បីចាប់ផ្តើមដំណើរការឆ្ពោះទៅរកភាពល្អឥតខ្ចោះឡើងវិញ ព្រះជាម្ចាស់បានបញ្ជូនព្រះមែស៊ីផ្សេងៗមកផែនដី ដែលអាចស្តាស្ថានភាពនៃទំនាក់ទំនងរវាងមនុស្សជាតិជាមួយនឹងព្រះជាម្ចាស់។ តែមុនការនេះអាចកើតឡើងបាន មនុស្សត្រូវតែប្រព្រឹត្តអំពើល្អ **ដើម្បីលុបបំបាត់ចោលនូវឥទ្ធិពលអាក្រក់នៃអំពើបាប**។ ក្រុមនេះហៅការនេះថា «សំណង»។ (Daske, D. and Ashcraft, W. 2005, *New Religious Movements*, New York:New York University Press, p. 142.)

ការបង្រៀននេះអំពីការសង «សំណង» គឺស្រដៀងនឹងគោលលទ្ធិនៃការទទួលទណ្ឌកម្មសម្រាប់អំពើបាបរបស់អ្នកនៅក្នុងព្រះពុទ្ធសាសនា («ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់») ហើយផ្ទុយពីសេចក្ដីសង្គ្រោះដោយសារព្រះគុណ តាមរយៈជំនឿលើការសុគត និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ។

## ភរិយាទីមួយរបស់លោក សាន់ ម៉ុង មូន បានធ្វើបន្ទាល់អំពីអំពើអសីលធម៌របស់លោក មូន

លោក ផាក ចុង ហ្វា (Pak Chung-hwa) ដែលជាសមាជិកម្នាក់ក្នុងចំណោមសមាជិកស្ថាបនិកទាំងប្រាំមួយនាក់ នៃក្រុម សាន់ ម៉ុង មូន បានសម្ភាសភរិយាទី១របស់លោក មូន គឺលោកស្រី ឆយ ស៊ីន គីល ដែលបាននិយាយថា «ស្រីៗដែលមានទំនាក់ទំនងផ្លូវភេទជាមួយ សាន់ ម៉ុង មូន នឹងជ្រើសរើសបុរសម្នាក់ទៀត និងមានទំនាក់ទំនងផ្លូវភេទជាមួយបុរសនោះ។ បន្ទាប់មកបុរសនោះ នឹងមានទំនាក់ទំនងជាមួយនារីម្នាក់ទៀត ហើយនារីនោះមានទំនាក់ទំនងផ្លូវភេទជាមួយបុរសម្នាក់ទៀត។ ហើយវាបន្តដូច្នេះរហូតទៅ។ និយាយម៉្យាងទៀត សកម្មភាពនេះ ត្រូវអនុវត្តបន្តគ្នា ដូចរត់បណ្ដាក់»។ (ពីទស្សនាវដ្ដីជប៉ុន 週刊ポスト *Shūkan Post* “Weekly Post” October 8, 1993)។



*នៅរូបនេះពីឆ្នាំ១៩៩២ លោក ផាក ជុង ហ្វា កំពុងសម្ភាសន៍ភរិយាទីមួយរបស់លោកមូន ឆយ ស៊ីន គីល អំពីអំពើអសីលធម៌របស់លោកមូនជាមួយស្រីៗ។*

## ប្រពន្ធទាំងប្រាំរបស់ សាន់ ម៉្យុង មូន

| ឈ្មោះ | ឆ្នាំរៀបការ | រៀបរាប់ |
|---|---|---|
| **ឆយ ស៊ឺន គីល** Choi Seon Gil | ២៨/៤/៤៥ រៀបការស្របច្បាប់ | លែងលះគ្នានៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៥៧ ដោយសារអំពើផិតក្បត់ច្រើនដងរបស់លោក មូន |
| គីម ចុង ហ្វា Kim Chong-hwa | ១៩៤៦-៤៨ យកគ្នាអត់ស្របច្បាប់ | ខណៈពេលដែលមិនទាន់បានលែងលះពីប្រពន្ធដើមរបស់ខ្លួន លោកមូនបានរួមរស់ដោយខុសច្បាប់ជាមួយនឹងនាង គីម ចុង ហ្វា (Kim Chong-hwa) នៅពេលនាងនៅតែជាប្រពន្ធស្របច្បាប់របស់លោក ចុង ម៉្យុង ស៊ីអុន (Chong Myung-seon)។ (ប្ដីរបស់នាងកំពុងរស់នៅក្នុងផ្ទះតែមួយ ជាមួយនឹងប្រពន្ធគាត់ និងលោកមូន!) ទាំងនាង និងលោកមូនត្រូវបានចាប់ខ្លួន និងដាក់ពន្ធនាគារពីបទ ពហុពន្ធភាព នៅថ្ងៃទី ២២/២/៤៨។ |
| **គីម ម៉្យុង ហ៊ី** Kim Myung-hee | ១៩៥៤ អាយុ ២៣ឆ្នាំ យកគ្នាអត់ស្របច្បាប់ | បន្ទាប់ពីលោក មូនបានធ្វើឲ្យនាង ម៉្យុង ហ៊ី (Myung-hee) មានផ្ទៃពោះ នោះគាត់បានបញ្ជូននាងទៅលាក់ខ្លួននៅប្រទេសជប៉ុន ជាជនភៀសខ្លួនគ្មានឯកសារ។ កូនប្រុសរបស់ពួកគេឈ្មោះ មូន ហ៊ី ជីន (Moon Hee-jin) បានកើតនៅប្រទេសជប៉ុននៅថ្ងៃទី ១៧/៧/៥៥។ |
| **ហាន់ ហាក់ ចា** Han Hak Ja | មេសា ១៩៦០ រៀបការស្របច្បាប់ | លោក មូន និង ហាន់ ហាក់ ចា មានកូន ១៤ នាក់។ បន្ទាប់ពីលោកមូនស្លាប់ក្នុងឆ្នាំ ២០១២ ហាន់ ហាក់ ចា បានក្លាយជាអគ្គនាយកនៃក្រុម Unification Church ឋានៈដែលគាត់នៅមានរហូតមកដល់សព្វថ្ងៃ។ |
| **ឆយ ស៊ូន ហ្វា** Choi Soon-hwa ដែលគេហៅថា អានី “Annie” | ១៩៦៤ រៀបការដោយសម្ងាត់ទៅទីក្រុងសេអ៊ូល | ទំនាក់ទំនងផ្លូវភេទរបស់លោកមូនជាមួយ«អានី» បានចាប់ផ្ដើមនៅឆ្នាំ ១៩៥៣ ពេលនាងនៅជានិស្សិត។ ផែនការរបស់លោកមូន គឺរៀបការទាំងអានី និងបងស្រីរបស់នាងគឺ ស៊ូន ហ្ស៊ីល (Soon Shil) តាមគំរូយ៉ាកុបដែលបានរៀបការជាមួយលេអា និងរ៉ាជែល។ នាង ស៊ូន ហ្ស៊ីល បានផ្ដាច់ពាក្យនៅឆ្នាំ ១៩៥៩ នៅពេលដែលនាងបានដឹងពីអំពើអសីលធម៌របស់លោកមូន។ ក្រោយនោះបន្តិចលោកមូនបានរៀបការជាមួយ ហាន់ ហាក់ ចា ក្នុងឆ្នាំ ១៩៦០។ នៅទីបំផុតលោកមូន បានរៀបការជាមួយអានី ដោយលួចលាក់នៅឆ្នាំ ១៩៦៤ (ខណៈពេលដែលគាត់នៅតែជាប្ដីរបស់ ហាន់ ហាក់ ចា! ហើយបានកូនប្រុសសម្ងាត់ម្នាក់ ឈ្មោះ សាមផាក (Sam PARK) ដែលបាននិយាយបរិហារទាស់នឹងលោកមូន។ វីឌីអូនេះជាទីបន្ទាល់របស់ Sam PARK ៖ https://www.youtube.com/watch?v=xPwJYC9h93M&t=50s |

## រឿងរ៉ាវដ៏ក្រៀមក្រំនៃកូនៗរបស់ សាន់ ម៉្យុង មូន និង ហាន ហាក់ ចា

លោក មូន និងភរិយាសង្ឃឹមថា អាចបង្កើតគ្រួសារគំរូដែលពួកគេហៅថា «គ្រួសារពិត»។ ប៉ុន្តែ នៅពេលដែលយើងក្រឡេកមើលជីវិតកូនៗ របស់ពួកគេខ្លះ យើងឃើញថា លោកមូន មិនអាចសម្អាតបាបដើម ចេញពីស្បូនភរិយារបស់គាត់គឺ ហាន់ ហាក់ ចា បានឡើយ! កូនខ្លះរបស់ពួកគេបានធំឡើង ដោយរស់នៅក្នុងជីវិតដែលមានបាប និងសោកនាដកម្ម។

- កូនប្រុសច្បងរបស់ពួកគេឈ្មោះ ស្ទេវ មូន (Steve Moon) ហ្យ ជិន មូន (Hyo Jin Moon) គឺជាអ្នកញៀនថ្នាំ ដែលបានស្លាប់ដោយសារគាំងបេះដូង នៅអាយុ ៤៥ ឆ្នាំ។ ប្រពន្ធរបស់គាត់ឈ្មោះ ណានស៊ូក ហុង (Nansook Hong) បានចោទប្រកាន់គាត់ពីបទអំពើហិង្សាលើរាងកាយនៅក្នុងសៀវភៅរបស់គាត់។ (Nansook Hong, *In the Shadow of the Moons,* Little/Brown, 1998)

- កូនប្រុសម្នាក់ទៀតឈ្មោះ យ៉ាំង ជីន មូន (Young Jin Moon) បានធ្វើអត្តឃាតខ្លួនឯងនៅថ្ងៃទី ២៧ ខែតុលា ឆ្នាំ១៩៩៩ ។

- កូនស្រីរបស់ពួកគេឈ្មោះ អ៊ិន ជីន មូន (In Jin Moon) បានលែងលះប្តី និងរៀបការជាមួយគូស្នេហ៍របស់នាង។

- នៅឆ្នាំ ២០១៥ កូនប្រុសរបស់ពួកគេឈ្មោះ ហ្យុង ជីន មូន (Hyung Jin Moon) បានហៅម្តាយរបស់គាត់ឈ្មោះ ហាន់ ហាក់ ចា ថា «ស្រីសំផឹងនៃបាប៊ីឡូន» (សំដៅទៅលើមនុស្សអាក្រក់នៅក្នុងវិវរណៈ ១៧:១ )។ បងប្រុសរបស់គាត់ គឺ លោក កូក ជីន មូន (Kook Jin Moon) ចាស្ទីន (Justin) បានបំបែកខ្លួន ពីម្តាយរបស់ពួកគេ ដើម្បីបង្កើតក្រុមខុសឆ្គង

> របស់ខ្លួនផ្ទាល់។ រហូតដល់ឥឡូវពួកគេនិយាយការពារជាសាធារណៈ ចំពោះអាពាហ៍ពិពាហ៍សម្ងាត់របស់ឪពុកពួកគេ ជាមួយនឹងក្រុមស្ត្រី ៦ នាក់ ដែលលោកមូនហៅថា«ម៉ារាទាំង៦» ។

ប្រសិនបើ «គ្រួសារពិត» ដែលមកពី «ឪពុកពិត» និង «ម្ដាយពិត» មានបញ្ហាធ្ងន់ធ្ងរជាច្រើន តើធ្វើដូចម្ដេចឲ្យ សាន់ ម៉្យុង មូន នឹងនាំមកនូវសេចក្ដីសង្គ្រោះ និងការស្ដារឡើងវិញនៅលើផែនដីនេះបាន? លោកមូន គឺជាព្រះគ្រីស្ទក្លែងក្លាយ គឺ «អង់ទីគ្រីស្ទ» (១យ៉ូហាន ២:១៨-១៩ អាទទឹងព្រះគ្រីស្ទ)។

មានតែព្រះមែស៊ីដ៏ពិត គឺព្រះយេស៊ូវពីណាសារ៉ែតប៉ុណ្ណោះ ដែលបានដោះស្រាយបញ្ហាបាបរួចហើយ។ ទ្រង់បានធ្វើដូច្នេះ តាមរបៀបបរិសុទ្ធ នៅពេលដែលទ្រង់បានសុគតនៅលើឈើឆ្កាងសម្រាប់យើង ដោយសេចក្ដីស្រឡាញ់ មិនមែនតាមរបៀបមិនបរិសុទ្ធ គឺការប្រព្រឹត្តអំពើអសីលធម៌ខាងផ្លូវភេទដូចជា សាន់ ម៉្យុង មូន បានធ្វើនោះទេ។



*ក្រុមស្ថាបនិកនៃ Unification Church នៅឆ្នាំ១៩៥៤។ លោក មូន អង្គុយខាងមុខ ហើយលោក ផាក ជុង ហ្វា ឈរនៅពីក្រោយខាងឆ្វេង។*

**សរុបមក លោក សាន់ ម៉ុង មូន បានបរាជ័យការវិនិច្ឆ័យជាច្រើនពីកណ្ឌគម្ពីរ ១យ៉ូហាន និងបទគម្ពីរផ្សេងៗទៀត**

- **លោក មូន បរាជ័យការវិនិច្ឆ័យអំពីព្រះគ្រីស្ទពិត។** លោកមូនបានបង្រៀនថា ព្រះយេស៊ូវមិនបានកើតពីស្ត្រីព្រហ្មចារីទេ ហើយទ្រង់បានបរាជ័យក្នុងបេសកកម្មរបស់ទ្រង់ ដើម្បីបន្សុទ្ធអំពើបាបដើមរបស់អេវ៉ា។ នោះហើយជាមូលហេតុដែលព្រះត្រូវបញ្ជូនព្រះគ្រីស្ទមួយទៀតឈ្មោះ សាន់ ម៉ុង មូន។ នេះជាការប្រមាថដ៏ធ្ងន់ដល់ព្រះយេស៊ូវ!

- **លោក មូន បរាជ័យការវិនិច្ឆ័យអំពីសេចក្តីស្រឡាញ់។** លោកមូន បានប្រព្រឹត្តចំពោះស្ត្រីតាមរបៀបដ៏គួរឲ្យអាម៉ាស់ និងអាក្រក់បំផុត។ មិនតែប៉ុណ្ណោះ នៅពេលដែលខ្លួនគាត់ផ្ទាល់ បានរស់នៅដូចជាស្តេច អ្នកដើរតាមគាត់រាប់ពាន់នាក់ បានលាឈប់ពីការងារ ដើម្បីដើររកលុយឲ្យគាត់។ អ្នកដើរតាមគាត់ជាច្រើនបានលក់ផ្ទះ និងដីរបស់គេ ដើម្បីថ្វាយតង្វាយដល់លោកមូន។ លោកមូន និងក្រុមគ្រួសារបានក្លាយជាមហាសេដ្ឋី មកពីសាសនាក្លែងក្លាយនេះ។

- **លោក មូន បរាជ័យការវិនិច្ឆ័យអំពីសេចក្តីសង្គ្រោះ ដោយព្រះគុណតាមរយៈជំនឿ។** លោកមូនបានបង្រៀនថា យើងត្រូវតែបង់ប្រាក់សម្រាប់អំពើបាបរបស់យើងផ្ទាល់ តាមរយៈសំណង។ ពាក្យ សំណង សំដៅទៅការរងទុក្ខវេទនា ឬការបង់ប្រាក់ជាដង្វាយ ដើម្បីសងសម្រាប់អំពើបាបពីមុន។

- **លោក មូន បរាជ័យការវិនិច្ឆ័យអំពីភាពបរិសុទ្ធ។** លោកមូនគឺជាមនុស្សមានបាប ដែលឆ្លៀតឱកាសធ្វើបាបស្រីៗ ដោយប្រព្រឹត្តអំពើផិតក្បត់ និងសហាយស្មន់។

## សាន់ ម៉្យុង មូន អះអាងថា គាត់ជាព្រះគ្រីស្ទដែលយាងត្រឡប់មកវិញ ប៉ុន្តែ ព្រឹត្តិការណ៍ណាខ្លះត្រូវកើតឡើង នៅពេលព្រះពិតយាងមកវិញ

ព្រះគម្ពីរបាននិយាយច្បាស់ណាស់ អំពីព្រឹត្តិការណ៍ដែលត្រូវតែកើតឡើងនៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ។ យើងអាចប្រើប្រាស់បទទំនាយទាំងនេះ ដើម្បីល្បងមើល ថា សាន់ ម៉្យុង មូន គឺជាព្រះគ្រីស្ទពិត ឬជាព្រះគ្រីស្ទក្លែងក្លាយ។

១. ពេលដែលព្រះគ្រីស្ទពិតប្រាកដយាងមកវិញ ទ្រង់នឹង *«សងសេចក្ដីទុក្ខលំបាក»* ដល់ពួកអ្នកដែលធ្វើទុក្ខដល់គ្រីស្ទបរិស័ទ ហើយប្រទានការ *«សំរាក»* និងសេចក្ដីសង្គ្រោះ ដល់ពួកអ្នកដែលត្រូវគេធ្វើទុក្ខ។ ទ្រង់នឹងមក *«ជាមួយនឹងពួកទេវតានៃព្រះចេស្ដាទ្រង់ នៅក្នុងអណ្ដាតភ្លើង ទាំងសងសឹកនឹងពួកអ្នកដែលមិនស្គាល់ព្រះ ហើយនិងពួកអ្នកដែលមិនស្ដាប់តាមដំណឹងល្អ ពីព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើង»*។ (២ថែស្សាឡូនីច ១:៦-៨) **តើការនេះបានកើតឡើងទេនៅពេលដែល សាន់ ម៉្យុង មូន មកនោះ?**

២. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងមិនយាងមកដោយស្ងាត់ៗទេ។ មនុស្សគ្រប់គ្នានៅលើពិភពលោកនឹងបានឃើញទ្រង់។ *«ព្រោះដំណើរដែលកូនមនុស្សមក នោះនឹងបានដូចជាផ្លេកបន្ទោរ ដែលភ្លឺផ្លេកៗ ពីទិសខាងកើតដល់ទិសខាងលិចដែរ»* និង *«គ្រប់ទាំងភ្នែកនឹងឃើញទ្រង់»* *«ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង»* (ម៉ាថាយ ២៤:២៧; វិវរណៈ ១:៧; ១ថែស្សាឡូនីច ៤:១៦) **តើការនេះបានកើតឡើងទេនៅពេលដែល សាន់ ម៉្យុង មូន មកនោះ?**

៣. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ នោះនៅលើមេឃនឹងត្រូវកក្រើករំពើក។ *«ស្រាប់តែថ្ងៃនឹងទៅជាងងឹត ខែនឹងលែងភ្លឺ អស់ទាំងផ្កាយនឹងធ្លាក់ចុះពីលើមេឃ ហើយអស់ទាំងអំណាចនៅលើមេឃនឹងត្រូវកក្រើករំពើក»* (ម៉ាថាយ ២៤:២៩)។ **តើការនេះបានកើតឡើងទេ នៅពេលដែល សាន់ ម៉្យុង មូន មកនោះ?**

៤. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងយាងមកដោយអំណាច និងសិរីល្អ ហើយមនុស្សមានបាបទាំងអស់នៅលើផែនដីនឹងសោកសៅ។ *«នោះទីសំគាល់របស់កូនមនុស្សនឹងលេចមកនៅលើមេឃ គ្រប់ទាំងពូជមនុស្សនៅផែនដីនឹងគក់ទ្រូងយំ ក៏នឹងឃើញកូនមនុស្ស មកលើពពកនៅលើមេឃ មានទាំងព្រះចេស្តា និងសិរីល្អជាខ្លាំង»* (ម៉ាថាយ ២៤:៣០) **តើការនេះបានកើតឡើងទេ នៅពេលដែល សាន់ ម៉ឹង មូន មកនោះ**?

៥. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ *«លោកនឹងចាត់ពួកទេវតារបស់លោក ឲ្យមកដោយសូរផ្លុំត្រែជាខ្លាំង ទេវតាទាំងនោះនឹងប្រមូលពួករើសតាំងរបស់លោកពីទិសទាំង៤ ចាប់តាំងពីជើងមេឃម្ខាង រហូតដល់ជើងមេឃម្ខាង»*។ (ម៉ាថាយ ២៤:៣១) **តើការនេះបានកើតឡើងទេ នៅពេលដែល សាន់ ម៉ឹង មូន មកនោះ**?

៦. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងបំផ្លាញអាទទឹងនឹងព្រះគ្រីស្ទ (ជាមនុស្សដែលត្រូវហិនវិនាស) *«កុំឲ្យអ្នកណាបញ្ឆោតអ្នករាល់គ្នាជាយ៉ាងណាដែរ ដ្បិតថ្ងៃនោះមិនមកឡើយ ទាល់តែមានសេចក្តីក្បត់សាសនាមកជាមុន ហើយមនុស្សដែលជាតួបាបនោះបានលេចមក គឺជាមនុស្សដែលត្រូវហិនវិនាស ដែលទាស់ទទឹង ហើយលើកខ្លួនឡើង ខ្ពស់លើសជាងអស់ទាំងអ្វី ដែលហៅថាព្រះ ឬរបស់អ្វីដែលគេគោរពប្រតិបត្តិផង ដល់ម្ល៉េះបានជាវានឹងអង្គុយនៅ ដូចជាព្រះក្នុងវិហារនៃព្រះ ទាំងសំដែងខ្លួនថាជាព្រះផង...នោះទើបអាទទឹងច្បាប់នោះនឹងលេចមក ដែលព្រះអម្ចាស់យេស៊ូវនឹងបំផ្លាញដោយខ្យល់ពីព្រះឱស្ឋទ្រង់ ហើយធ្វើឲ្យវិនាស ដោយរស្មីពន្លឺពីដំណើរទ្រង់យាងមក»* (២ថែស្សាឡូនីច ២:៣-៤, ៨)។ **តើការនេះបានកើតឡើងទេ នៅពេលដែល សាន់ ម៉ឹង មូន មកនោះ**?

៧. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងចាក់សេចក្តីក្រោធរបស់ទ្រង់ទៅលើអស់អ្នកមានបាបទាំងអស់គ្នា។ *«ដ្បិតអ្នករាល់គ្នាដឹងច្បាស់ហើយថា ថ្ងៃនៃព្រះអម្ចាស់នឹងមកដល់ ដូចជាចោរមកនៅពេលយប់។ ដ្បិតកាលណាគេកំពុងតែនិយាយថា មានសេចក្តីសុខសាន្ត មានសេចក្តីរៀបរយហើយ នោះលោតែមានសេចក្តីហិនវិនាសមក*

*លើគេភ្លាម ដូចជាស្ត្រីមានគភ៌ឈឺនឹងសំរាល ហើយគេចមិនរួចឡើយ»* (១ថែស្សាឡូនីច ៥:២-៣)។ **តើការនេះបានកើតឡើងទេ នៅពេលដែល សាន់ ម៉ុង មូន មកនោះ?**

៨. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងកាត់ទោសគ្រប់គ្នាភ្លាមៗ។ *«តែកាលណាកូនមនុស្សនឹងមក ក្នុងសិរីល្អរបស់លោក មានទាំងពួកទេវតាបរិសុទ្ធទាំងអស់គ្នា មកជាមួយ នោះលោកនឹងឡើងគង់លើបល្ល័ង្ករុងរឿងឧត្តមរបស់លោក។ រួចគ្រប់ទាំងសាសន៍ នឹងត្រូវប្រមូលគ្នា នៅចំពោះលោក ហើយលោកនឹងញែកគេចេញពីគ្នា ដូចជាអ្នកគង្វាលដែលញែកចៀមចេញពីពពែដែរ»* (ម៉ាថាយ ២៥:៣១-៣២)។ **តើការនេះបានកើតឡើងទេ នៅពេលដែល សាន់ ម៉ុង មូន មកនោះ?**

៩. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មក ទ្រង់នឹងប្រោសរូបកាយអ្នកស្លាប់ទាំងអស់ដែលជាគ្រីស្ទបរិស័ទ។ *«ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង នោះពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់។ រួចយើងរាល់គ្នាដែលកំពុងតែរស់នៅ ក៏នឹងបានលើកឡើង ទៅក្នុងពពកជាមួយគ្នាទាំងអស់ ដើម្បីឲ្យបានជួបជុំនឹងព្រះអម្ចាស់នៅនាអាកាស យ៉ាងនោះ យើងនឹងនៅជាមួយនឹងព្រះអម្ចាស់ជាដរាបទៅ»* (១ថែស្សាឡូនីច ៤:១៦-១៧)។ **តើការនេះបានកើតឡើងទេ នៅពេលដែល សាន់ ម៉ុង មូន មកនោះ?**

១០. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មក ទ្រង់នឹងមិនកើតមកជាទារកតូចទេ ប៉ុន្តែទ្រង់នឹងយាងមកពីស្ថានសួគ៌ជាអ្នកចម្បាំងដ៏មានគ្រប់ព្រះចេស្តា ដើម្បីវិនិច្ឆ័យជំនុំជម្រះផែនដី។ *«ខ្ញុំក៏ឃើញមេឃបើកចំហឡើង នោះឃើញមានសេះស១ និងព្រះអង្គដែលគង់លើវា ទ្រង់មានព្រះនាមថា «ស្មោះត្រង់ ហើយពិតប្រាកដ» ទ្រង់ជំនុំជំរះ ហើយច្បាំងដោយសុចរិត [១២] ព្រះនេត្រទ្រង់ដូចជាអណ្តាតភ្លើង ហើយនៅលើព្រះសិរសា មានមកុដជាច្រើន ទ្រង់មានព្រះនាមកត់ទុក ដែលគ្មានអ្នកណាស្គាល់ឡើយ លើកតែអង្គទ្រង់ប៉ុណ្ណោះ [១៣] ទ្រង់ក៏ទ្រង់ព្រះពស្ត្រជ្រលក់ដោយឈាម ហើយព្រះនាមទ្រង់ហៅថា «ព្រះបន្ទូលនៃព្រះ» [១៤] អស់ទាំងពលបរិវារនៅស្ថានសួគ៌ ក៏ជិះសេះសដង្ហែទ្រង់ ទាំងស្លៀកពាក់សំពត់ទេស ហើយស្អាតផង [១៥] មានដាវយ៉ាងមុតចេញពីព្រះឱសទ្រង់ ដើម្បីនឹងកាប់អស់ទាំងសាសន៍ ហើយទ្រង់នឹងឃ្វាលគេ ដោយដំបងដែក ទ្រង់ក៏ជាន់ក្នុងធុងឃ្នាបនៃ*

*ស្រាទំពាំងបាយជូរ ជាសេចក្ដីឃោរឃៅរបស់សេចក្ដីខ្ញាល់នៃព្រះដ៏មានព្រះចេស្ដាបំផុត ១៦ ទ្រង់មានព្រះនាមកត់នៅព្រះពស្ត្រ ហើយនៅព្រះឧរូទ្រង់ថា «ស្ដេចលើអស់ទាំងស្ដេច ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់»។* (វិវរណៈ ១៩:១១-១៦)។ **តើការនេះបានកើតឡើងទេនៅពេលដែល សាន់ ម៉ុង មូន មកនោះ?**

**គ្មានព្រឹត្តិការណ៍ណាមួយបានកើតឡើងសោះ ក្នុងចំណោមព្រឹត្តិការណ៍ទាំងនេះ នៅពេលដែល សាន់ ម៉ុង មូន មកនោះ។** សាន់ ម៉ុង មូន ជាព្រះគ្រីស្ទក្លែងក្លាយ។



## មុខពូថៅ

តើការបង្រៀនអ្វីដែលជា«មុខពូថៅ» របស់ក្រុម សាន់ ម៉ុង មូន ដែលងាយស្រួលបំបែកក្រុមជំនុំពីសេចក្ដីពិត? ពួកគេអញ្ជើញមេដឹកនាំក្រុមជំនុំនិងមន្ត្រីរដ្ឋាភិបាល ដើម្បីចូលរួមក្នុងអង្គប្រជុំដ៏ធំអំពី «សន្តិភាពពិភពលោក» ដែលលោកស្រី ហាន់ ហាក់ ចា ជាវាគ្មិនសំខាន់បំផុត។

សមាជិកនៃក្រុមខុសឆ្គងនេះ នឹងព្យាយាមទាក់ទាញអ្នកជឿលើគ្រីស្ទសាសនាពិត ដោយនិយាយអំពីការសង្កត់ធ្ងន់របស់ក្រុមគេ លើគុណតម្លៃគ្រួសារ សន្តិភាពពិភពលោក និងអាពាហ៍ពិពាហ៍ស្មោះត្រង់។

តើអ្វីទៅជា«ខ្នងពូថៅ»? តើជំនឿណាខ្លះដែលគេចង់លាក់ពីយើង? ក្រុមនេះចង់លាក់បាំងជីវិតអសីលធម៌របស់លោកមូន ការអះអាងរបស់គាត់ថា ជាព្រះមែស៊ី និងការបង្រៀនរបស់គាត់ថា យើងត្រូវសងបាបខ្លួនឯង ដោយការសងបំណុល។

សូមចងចាំម្ដងទៀតថា សាន់ ម៉ុង មូន បានស្លាប់នៅឆ្នាំ ២០១២ ហើយមិនបានរស់ឡើងវិញទេ (ខាងក្រោមមានរូបភាពផ្នូររបស់គាត់)។ សេចក្ដីស្លាប់បានយកឈ្នះ

គាត់ទាំងស្រុង។ មនុស្សដែលចាញ់បាប និងសេចក្ដីស្លាប់ មិនអាចជួយអ្នក និងខ្ញុំឲ្យយកឈ្នះសេចក្ដីស្លាប់បានទេ។ លោកមូន គឺជាព្រះគ្រីស្ទក្លែងក្លាយ។

ជាចុងក្រោយសូមកុំភ្លេច ២យ៉ូហាន ១:១០-១១ ៖ *«បើអ្នកណាមកឯអ្នករាល់គ្នា តែមិនបង្រៀនចំពោះសេចក្ដីនេះ នោះកុំឲ្យទទួលអ្នកនោះនៅក្នុងផ្ទះឡើយ កុំឲ្យទាំងជំរាបសួរដល់អ្នកនោះផង ដ្បិតបើអ្នកណាជំរាបសួរ នោះក៏តែងមានសេចក្ដីប្រកបគ្នាក្នុងការអាក្រក់របស់អ្នកនោះដែរ»។*



*ផ្នូររបស់ សាន់ ម្យ៉ុង មូន។ ប្រពន្ធគាត់ ហាន ហាក់ ចា អាយុជិត ៨០ ឆ្នាំហើយ។ គាត់ហៅខ្លួនឯងថាជា "ព្រះ" ប៉ុន្តែគាត់ក៏នឹងមិនរស់ពីស្លាប់ឡើងវិញដែរ។*

# ពួកជំនុំនៃព្រះដ៏មានគ្រប់ព្រះចេស្ដា

**Church of Almighty God**

**អ្នកស្រី យ៉ាង ស៊ីងប៊ិន (Yang Xiangbin)**

**ផ្លេកបន្ទោរទិសខាងកើត Eastern Lightning**

**ពីប្រទេសចិន**

## ប្រវត្តិ

ក្រុមនេះបានចាប់ផ្ដើមនៅឆ្នាំ ១៩៩១ នៅប្រទេសចិន។ សេចក្ដីបង្រៀនចំបងរបស់ពួកគេគឺថា ព្រះយេស៊ូវបានយាងត្រឡប់មកវិញជាស្ត្រីជនជាតិចិន! ពួកគេថែមទាំងថ្វាយបង្គំនាងថាជា«ព្រះដ៏មានព្រះចេស្ដា» ក្រុមនេះមិនបានបញ្ជាក់ជាសាធារណៈថាស្ត្រីនេះជានរណាទេ ប៉ុន្តែ ឈ្មោះរបស់គាត់គឺ យ៉ាង ស៊ីងប៊ិន (Yang Xiangbin) ហើយនាងកើតនៅឆ្នាំ ១៩៧៣ នៅប្រទេសចិន។ ក្រោយដែលគាត់ប្រលងធ្លាក់មធ្យមសិក្សាទុតិយភូមិនៅស្រុកចិន គាត់ចាប់ផ្ដើមធ្វើទំនាយដល់ក្រុមមួយដែលស្ដាប់គាត់។ នៅឆ្នាំ ១៩៩១ បុរសម្នាក់ឈ្មោះ ចាវ វ៉ៃសាន (Zhao Weishan) ដែលជាសមាជិកក្រុមខុសឆ្គងមួយទៀត បានជួបនាង ហើយក៏បានក្លាយជាមេដឹកនាំក្រុមគាត់។ ដោយសារក្រុមនេះបង្កមានបញ្ហាជាច្រើន



រដ្ឋាភិបាលចិនបានប្រកាសថា ពួកគេជាក្រុមខុសច្បាប់ ដែលធ្វើឲ្យពួកគេត្រូវលាក់ខ្លួន។ នៅឆ្នាំ ២០០០ យ៉ាង ស៊ីងប៊ិន និង ចាវ វៃសាន ត្រូវបានអនុញ្ញាតឲ្យចូលទឹកដីសហរដ្ឋអាមេរិក។ ពួកគេបានទៅរស់នៅទីក្រុងញូវយ៉ក ជាកន្លែងដែលពួកគេកំពុងដឹកនាំក្រុមខុសឆ្គងនេះ។ ប៉ុន្តែ នាង យ៉ាង ស៊ីងប៊ិននៅតែលាក់ខ្លួន ហើយមិនបង្ហាញខ្លួនជាសាធារណៈឡើយ។ ប្រហែលជានាងនៅតែព្រួយបារម្ភអំពីអ្វីដែលរដ្ឋាភិបាលចិននឹងធ្វើដល់ «ព្រះដ៏មានគ្រប់ព្រះចេស្ដា»។

សមាជិកនៃក្រុមនេះ គឺច្រឡោងខាមណាស់។ ពួកគេធ្វើជាមិត្តភក្តិជាមួយមនុស្សក្នុងគោលបំណង ដើម្បីហៅពួកគេឲ្យចូលសិក្សា«ព្រះគម្ពីរ»។ ប៉ុន្តែដល់កន្លែងគេរៀនពីសៀវភៅ របស់យ៉ាង ស៊ីងប៊ិន។ ជាធម្មតាយុវនារីក្នុងក្រុមនេះ ទាក់ទងនឹងមនុស្សប្រុស ហើយមនុស្សប្រុសទាក់ទងនឹងមនុស្សស្រីវិញ។ នៅប្រទេសចិន ក្រុមខុសឆ្គងនេះ ទាក់ទាញស្រីៗ ជាពិសេសស្ត្រីមេផ្ទះដែលឯកោ ដែលស្វាមីទៅធ្វើការនៅទីក្រុងមួយផ្សេងទៀត។ មនុស្សបានធ្វើទីបន្ទាល់ថា បើស្វាមីមិនព្រមចូលរួមក្រុមនេះដែរ ក្រុមនេះបបួលភរិយាឲ្យលែងលះប្ដីរបស់គាត់។ **ដោយសារអាកប្បកិរិយាច្រឡោងខាមរបស់ក្រុមនេះ និងការប្រើប្រាស់ សៀវភៅ វីដេអូ និងអ៊ីនធឺណិតយ៉ាងឆ្លាតវៃ ខ្ញុំចាត់ទុកក្រុមនេះថាជាក្រុមដ៏គ្រោះថ្នាក់បំផុតនៅកម្ពុជា។**

## ជំនឿរបស់ក្រុមនៃព្រះដ៏មានគ្រប់ព្រះចេស្ដា (ផ្នែកបន្ទោរទិសកើត)

**ក្រុមនេះជឿថា យ៉ាង ស៊ីងប៊ិន គឺជាព្រះដ៏មានគ្រប់ព្រះចេស្ដា។** ក្រុមផ្នែកបន្ទោរទិសកើតនេះជឿថា «ព្រះដ៏មានគ្រប់ព្រះចេស្ដា» បានមកផែនដីហើយ គឺនៅពេលដែលអ្នកស្រី យ៉ាង ស៊ីងប៊ិន បានកើតក្នុងឆ្នាំ ១៩៧៣ ដើម្បីនាំមកនូវសម័យកាលទីបី នៃមនុស្សជាតិ គឺ«សម័យកាលនៃនគរ»។ សម័យកាលដំបូងគឺ «សម័យកាលនៃក្រិត្យវិន័យ» (សម័យនៃគម្ពីរសញ្ញាចាស់) ហើយសម័យកាលទី២ គឺ «សម័យកាលនៃព្រះគុណ» ដែលបានចាប់ផ្ដើមជាមួយនឹងកំណើតរបស់ព្រះគ្រីស្ទ។ សម័យកាលទី

៣ បានចាប់ផ្តើមក្នុងឆ្នាំ ១៩៧៣ ដោយកំណើតលោកស្រី យ៉ាង ស៊ីងប៊ិន។ ការបែងចែកប្រវត្តិសាស្រ្តទៅជាសម័យកាលទាំងបី គឺជាការដែលក្រុមខុសឆ្គងជាច្រើនបានបង្រៀន។ ហើយស្ថាបនិកនៃក្រុមខុសឆ្គង គឺតែងតែអះអាងថា ខ្លួនជា «ព្រះគ្រីស្ទ» នៃសម័យកាលទីបី!

ប៉ុន្តែក្រុម «ព្រះដ៏មានគ្រប់ព្រះចេស្តា» បានភ្លេចថា ព្រះយេស៊ូវមិនមែនគ្រាន់តែជាព្រះអង្គសង្គ្រោះនៃសម័យកាលរបស់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ក៏ជាអ្នកបង្កើតសកលលោកទាំងមូលផងដែរ។ *«គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្តារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ»* (យ៉ូហាន ១:៣)។ *«ដ្បិតគឺទ្រង់ហើយ ដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបើជារាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ នោះសុទ្ធតែកើតមកដោយសារទ្រង់ ហើយសំរាប់ទ្រង់ទាំងអស់ផង»* (កូល៉ុស ១:១៦)។ ដូច្នេះព្រះយេស៊ូវ ជាអ្នកបង្កើតរបស់សព្វសារពើ ទាំង យ៉ាង ស៊ីងប៊ិន និង ចាវ វៃសាន ដែលគ្រាន់តែជាមនុស្សប៉ុណ្ណោះ។ ព្រះយេស៊ូវក៏ជា អាលផា និងអូមេកា គឺជាមុនគេ ហើយក្រោយគេ ជាដើម ហើយជាចុង (វិវរណៈ ២២:១៣)។

**ក្រុមនេះបដិសេធគោលជំនឿព្រះត្រៃឯក។**

**ក្រុមនេះបង្រៀនថា ព្រះយេស៊ូវមិនអាចជម្រះមនុស្សពីអំណាចនៃអំពើបាបឡើយ។**

ក៏ដូចជាក្រុមខុសឆ្គងដទៃទៀតដែរ ក្រុមនេះអះអាងថា ព្រះយេស៊ូវមិនបានជោគជ័យទាំងស្រុងក្នុងបេសកកម្មរបស់ព្រះអង្គ ដើម្បីលោះមនុស្សជាតិទេ។ ពួកគេនិយាយថា ទ្រង់បានបង់ថ្លៃសម្រាប់អំពើបាបរបស់មនុស្សជាតិ ប៉ុន្តែបានបរាជ័យក្នុងការ

ដោះស្រាយបញ្ហានៃនិស្ស័យបាបដែលនៅសេសសល់។ ដូច្នេះ ត្រូវការព្រះគ្រីស្ទមួយទៀត គឺ យ៉ាង ស៊ីងប៊ិន។ នៅក្នុង វីដេអូ យូធូប ក្រុមនេះនិយាយថា «ព្រះដ៏គ្រប់ព្រះចេស្ដា គឺជាព្រះអម្ចាស់យេស៊ូវដែលបានយាងត្រឡប់មកវិញ... ពាក្យសំដីរបស់ព្រះដ៏មានគ្រប់ព្រះចេស្ដា មានសេចក្ដីពិតទាំងអស់ ដើម្បីជម្រះ និងសង្គ្រោះមនុស្សលោក» ពួកគេកំពុងនិយាយអំពី យ៉ាង ស៊ីងប៊ិន។ នេះគឺជាការប្រមាថខ្លាំងណាស់ដល់ព្រះយេស៊ូវ។ យ៉ាង ស៊ីងប៊ិន គឺជា អង់ទីគ្រីស្ទមួយ។

## ក្រុមនេះជឿថា ព្រះយេស៊ូវមិនបានរស់ពីសុគតឡើងវិញទេ។

ការនេះមានន័យថា ក្រុមនេះគ្មានសង្ឃឹមថា នឹងទទួលបានជ័យជំនះលើសេចក្ដីស្លាប់ទេ ពីព្រោះមានតែព្រះគ្រីស្ទដែលបានឈ្នះសេចក្ដីស្លាប់ ដែលអាចជួយយើងឲ្យឈ្នះសេចក្ដីស្លាប់បាន។ នៅពេលដែល យ៉ាង ស៊ីងប៊ិន ស្លាប់ ប្រាកដណាស់ គាត់នឹងមិនអាចរស់ឡើងវិញទេ ពីព្រោះគាត់មិនមែនជាព្រះគ្រីស្ទពិត។

## ក្រុមនេះជឿថា ព្រះគម្ពីរបរិសុទ្ធ គឺសម្រាប់សម័យកាលមុន ហើយគ្មានប្រយោជន៍សម្រាប់សម័យកាលនេះទេ។




ពួកគេបង្រៀនថា ជំនួសព្រះគម្ពីរបរិសុទ្ធ ឥឡូវយើងមានពាក្យថ្មីរបស់ «ព្រះដ៏មានគ្រប់ព្រះចេស្ដា ( យ៉ាង ស៊ីងប៊ិន )» សម្រាប់សម័យកាលនេះ។ ពួកគេបានបោះពុម្ពសៀវភៅជាច្រើន ដែលមានពាក្យរបស់ យ៉ាង ស៊ីងប៊ិន ដូចជាសៀវភៅដែលមានឈ្មោះថា *ព្រះបន្ទូលបានលេចមកជាសាច់ឈាម (រូបភាពខាងស្ដាំ)*។ ក្រុមខុសឆ្គងនេះសង្កត់ធ្ងន់ទៅលើការប្រជុំគ្នា ដើម្បីអានពាក្យរបស់«ព្រះដ៏មានគ្រប់ព្រះចេស្ដា»ជាមួយគ្នា។ ពួកគេហៅការប្រជុំនោះថា «ការ

សិក្សាព្រះគម្ពីរ» ប៉ុន្តែនៅពេលពួកគេជួបជុំគ្នា ពួកគេមិនសិក្សាព្រះគម្ពីរប៊ីបទាល់តែសោះ ប៉ុន្តែជានិមិត្ត និងពាក្យសំដីរបស់ព្រះគ្រីស្ទក្លែងក្លាយ យ៉ាង ស៊ីងប៊ិន នេះវិញ។

សូមកត់សម្គាល់នៅក្នុងរូបភាពនេះថា ក្រុមនេះបានបោះពុម្ពពាក្យ «ព្រះគម្ពីរបរិសុទ្ធ» (Holy Bible) នៅលើគម្របសៀវភៅរបស់ យ៉ាង ស៊ីងប៊ិន។ នេះគឺជាការបោកប្រាស់សុទ្ធសាធ។ ចំណងជើង «ព្រះគម្ពីរបរិសុទ្ធ» តែងតែសំដៅទៅ ព្រះគម្ពីរបរិសុទ្ធដើមដែលមាន ៦៦កណ្ឌពីលោកុប្បត្តិរហូតដល់វិវរណៈ។ ប៉ុន្តែសៀវភៅនេះគ្មានអ្វីក្រៅពីសំដីរបស់ស្ត្រីជនជាតិចិនម្នាក់ ដែលកំពុងលាក់ខ្លួននៅក្រុងញូវយ៉កដែលអះអាងថា ខ្លួននាងគឺជា «ព្រះដ៏មានគ្រប់ចេស្តា»ប៉ុណ្ណោះ។ សៀវភៅនេះជាគម្ពីរក្លែងក្លាយ។ ចូរប្រយ័ត្ននឹងក្រុមភូតភរអាក្រក់នេះ។ ប្រសិនបើអ្នកឃើញមនុស្សដែលមានសៀវភៅនេះ ពួកគេគឺជាឆ្កែចចកដែលពាក់រោមចៀម ហើយសៀវភៅដែលពួកគេសិក្សា គឺពោរពេញទៅដោយការកុហក។

## ឈ្មោះក្រុមនេះគួរអោយអស់សំណើចណាស់

ឈ្មោះមួយរបស់គេគឺ «ផ្លេកបន្ទោរទិសខាងកើត» ដោយដកស្រង់ចេញពី ម៉ាថាយ ២៤:២៧ ដែលព្រះយេស៊ូវប្រកាសថា ការយាងមកលើកទីពីររបស់ទ្រង់ គឺមកជាសាធារណៈ ដែលមនុស្សទាំងអស់ក្នុងពិភពលោកនឹងឃើញ៖ *«ព្រោះដំណើរដែលកូនមនុស្សមក នោះនឹងបានដូចជាផ្លេកបន្ទោរ ដែលភ្លឺផ្លេកៗ ពីទិសខាងកើតដល់ទិសខាងលិចដែរ»* ហើយ *«គ្រប់ទាំងភ្នែកនឹងឃើញទ្រង់»* (វិវរណៈ ១:៧)។ ប៉ុន្តែគ្រីស្ទក្លែងក្លាយនៃក្រុមនេះ មិនបានមកផែនដីជាសាធារណៈដូចជាផ្លេកបន្ទោរដែលបំភ្លឺពេញផ្ទៃមេឃ ដើម្បីឲ្យមនុស្សទាំងអស់ឃើញនោះទេ។ ផ្ទុយទៅវិញ នាងបានមកដោយសម្ងាត់ ហើយបានលាក់ខ្លួនអស់រយៈពេលជាច្រើនឆ្នាំ! ប៉ុន្តែនៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងមកវិញ ទ្រង់នឹងមិនមកដោយសម្ងាត់ទេ។ សូមស្តាប់ពីការនេះ៖

*«គ្រានោះ បើមានអ្នកណាប្រាប់អ្នករាល់គ្នាថា មើល ព្រះគ្រីស្ទគង់នៅទីនេះ ឬនៅទីនោះ នោះកុំឲ្យជឿគេឡើយ។ ដ្បិតនឹងមានព្រះគ្រីស្ទក្លែង ហើយហោរាក្លែងកើតឡើង គេនឹងធ្វើទីសំគាល់យ៉ាងធំ ហើយនិងការអស្ចារ្យ ដើម្បីនឹងនាំទាំងពួកអ្នករើសតាំងឲ្យវង្វេងផង បើសិនជាបាន។ មើល! ខ្ញុំបានប្រាប់អ្នករាល់គ្នាជាមុន។ ដូច្នេះ បើគេប្រាប់អ្នករាល់គ្នាថា មើល ទ្រង់គង់នៅទីរហោស្ថាន នោះកុំឲ្យចេញទៅឡើយ ឬថា មើល ទ្រង់គង់នៅ**ក្នុងបន្ទប់** នោះក៏កុំឲ្យជឿឲ្យសោះ។ ព្រោះដំណើរដែលកូនមនុស្សមក នោះនឹងបានដូចជាផ្លេកបន្ទោរ ដែលភ្លឺផ្លេកៗ ពីទិសខាងកើតដល់ទិសខាងលិចដែរ»* (ម៉ាថាយ ២៤:២៣-២៧)។

រយៈពេល ៣០ឆ្នាំមកហើយ «គ្រីស្ទ» របស់ក្រុមក្លែងក្លាយនេះ បានលាក់ខ្លួននៅក្នុង *«ក្នុងបន្ទប់»* (ខ២៦) នៅប្រទេសចិន ហើយឥឡូវនៅ *«ក្នុងបន្ទប់»* កន្លែងណាមួយនៅទីក្រុងញូវយ៉ក។ ប៉ុន្តែនៅពេលដែលព្រះយេស៊ូវយាងមក *«គ្រប់ទាំងភ្នែកនឹងឃើញទ្រង់»* (វិវរណៈ ១:៧) ។

## យ៉ាង ស៊ីងប៊ិន អះអាងថា គាត់ជាព្រះគ្រីស្ទដែលយាងត្រឡប់មកវិញ ប៉ុន្តែព្រឹត្តិការណ៍ណាខ្លះត្រូវកើតឡើង នៅពេលព្រះគ្រីស្ទពិតយាងមកវិញ?

ព្រះគម្ពីរបាននិយាយច្បាស់ណាស់ អំពីព្រឹត្តិការណ៍ដែលត្រូវតែកើតឡើងនៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ។ យើងអាចប្រើប្រាស់បទទំនាយទាំងនេះ ដើម្បីល្បងមើល យ៉ាង ស៊ីងប៊ិន គឺជាព្រះគ្រីស្ទពិត ឬជាព្រះគ្រីស្ទក្លែងក្លាយ។

១. ពេលដែលព្រះគ្រីស្ទពិតប្រាកដយាងមកវិញ ទ្រង់នឹង *«សងសេចក្តីទុក្ខលំបាក»* ដល់ពួកអ្នកដែលធ្វើទុក្ខដល់គ្រីស្ទបរិស័ទ ហើយប្រទានការ *«សំរាក»* និងសេចក្ដីសង្គ្រោះ ដល់ពួកអ្នកដែលត្រូវគេធ្វើទុក្ខ។ ទ្រង់នឹងមក *«ជាមួយនឹងពួកទេវតានៃព្រះចេស្ដាទ្រង់ នៅក្នុង*

*អណ្ដាតភ្លើង ទាំងសងសឹកនឹងពួកអ្នកដែលមិនស្គាល់ព្រះ ហើយនិងពួកអ្នកដែលមិនស្ដាប់តាមដំណឹងល្អ ពីព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើង»*។ (២ថែស្សាឡូនីច ១:៦-៨) **តើការនេះបានកើតឡើងទេនៅពេលដែល យ៉ាង ស៊ុងប៊ិន មកនោះ?**

២. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងមិនយាងមកដោយស្ងាត់ៗទេ។ មនុស្សគ្រប់គ្នានៅលើពិភពលោកនឹងបានឃើញទ្រង់។ *«ព្រោះដំណើរដែលកូនមនុស្សមក នោះនឹងបានដូចជាផ្លេកបន្ទោរ ដែលភ្លឺផ្លេកៗ ពីទិសខាងកើតដល់ទិសខាងលិចដែរ»* និង *«គ្រប់ទាំងភ្នែកនឹងឃើញទ្រង់» «ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង»* (ម៉ាថាយ ២៤:២៧; វិវរណៈ ១:៧; ១ថែស្សាឡូនីច ៤:១៦) **តើការនេះបានកើតឡើងទេនៅពេលដែល យ៉ាង ស៊ុងប៊ិន មកនោះ?**

៣. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ នោះនៅលើមេឃនឹងត្រូវកក្រើករំពើក។ *«ស្រាប់តែថ្ងៃនឹងទៅជាងងឹត ខែនឹងលែងភ្លឺ អស់ទាំងផ្កាយនឹងធ្លាក់ចុះពីលើមេឃ ហើយអស់ទាំងអំណាចនៅលើមេឃនឹងត្រូវកក្រើករំពើក»* (ម៉ាថាយ ២៤:២៩)។ **តើការនេះបានកើតឡើងទេ នៅពេលដែល យ៉ាង ស៊ុងប៊ិន មកនោះ?**

៤. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងយាងមកដោយអំណាច និងសិរីល្អ ហើយមនុស្សមានបាបទាំងអស់នៅលើផែនដីនឹងសោកសៅ។ *«នោះទីសំគាល់របស់កូនមនុស្សនឹងលេចមកនៅលើមេឃ គ្រប់ទាំងពូជមនុស្សនៅផែនដីនឹងគក់ទ្រូងយំ ក៏នឹងឃើញកូនមនុស្ស មកលើពពកនៅលើមេឃ មានទាំងព្រះចេស្ដា និងសិរីល្អជាខ្លាំង»* (ម៉ាថាយ ២៤:៣០) **តើការនេះបានកើតឡើងទេ នៅពេលដែល យ៉ាង ស៊ុងប៊ិន មកនោះ?**

៥. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ *«លោកនឹងចាត់ពួកទេវតារបស់លោក ឲ្យមកដោយសូរផ្លុំត្រែជាខ្លាំង ទេវតាទាំងនោះនឹងប្រមូលពួករើសតាំងរបស់លោកពីទិសទាំង៤ ចាប់តាំងពីជើងមេឃម្ខាង រហូតដល់ជើងមេឃម្ខាង»*។ (ម៉ាថាយ ២៤:៣១) **តើការនេះបានកើតឡើងទេ នៅពេលដែល យ៉ាង ស៊ីងប៊ិន មកនោះ?**

៦. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងបំផ្លាញអាទទឹងនឹងព្រះគ្រីស្ទ (ជាមនុស្សដែលត្រូវហិនវិនាស) *«កុំឲ្យអ្នកណាបញ្ឆោតអ្នករាល់គ្នាជាយ៉ាងណាដែរ ដ្បិតថ្ងៃនោះមិនមកឡើយ ទាល់តែមានសេចក្ដីក្បត់សាសនាមកជាមុន ហើយមនុស្សដែលជាតួបាបនោះបានលេចមក គឺជាមនុស្សដែលត្រូវហិនវិនាស ដែលទាស់ទទឹង ហើយលើកខ្លួនឡើង ខ្ពស់លើសជាងអស់ទាំងអ្វី ដែលហៅថាព្រះ ឬរបស់អ្វីដែលគេគោរពប្រតិបត្តិផង ដល់ម្ល៉េះបានជាវានឹងអង្គុយនៅ ដូចជាព្រះក្នុងវិហារនៃព្រះ ទាំងសំដែងខ្លួនថាជាព្រះផង...នោះទើបអាទទឹងច្បាប់នោះនឹងលេចមក ដែលព្រះអម្ចាស់យេស៊ូវនឹងបំផ្លាញដោយខ្យល់ពីព្រះឱស្ឋទ្រង់ ហើយធ្វើឲ្យវិនាស ដោយរស្មីពន្លឺពីដំណើរទ្រង់យាងមក»* (២ថែស្សាឡូនីច ២:៣-៤, ៨)។ **តើការនេះបានកើតឡើងទេ នៅពេលដែល យ៉ាង ស៊ុងប៊ិន មកនោះ**?

៧. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងចាក់សេចក្ដីក្រោធរបស់ទ្រង់ទៅលើអស់អ្នកមានបាបទាំងអស់គ្នា។ *«ដ្បិតអ្នករាល់គ្នាដឹងច្បាស់ហើយថា ថ្ងៃនៃព្រះអម្ចាស់នឹងមកដល់ ដូចជាចោរមកនៅពេលយប់។ ដ្បិតកាលណាគេកំពុងតែនិយាយថាមានសេចក្ដីសុខសាន្ត មានសេចក្ដីរៀបរយហើយ នោះលោតែមានសេចក្ដីហិនវិនាសមកលើគេភ្លាម ដូចជាស្ត្រីមានគភ៌ឈឺនឹងសំរាល ហើយគេចមិនរួចឡើយ»* (១ថែស្សាឡូនីច ៥:២-៣)។ **តើការនេះបានកើតឡើងទេ នៅពេលដែល យ៉ាង ស៊ុងប៊ិន មកនោះ**?

៨. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងកាត់ទោសគ្រប់គ្នាភ្លាមៗ។ *«តែកាលណាកូនមនុស្សនឹងមក ក្នុងសិរីល្អរបស់លោក មានទាំងពួកទេវតាបរិសុទ្ធទាំងអស់គ្នា មកជាមួយ នោះលោកនឹងឡើងគង់លើបល្ល័ង្ករុងរឿងឧត្ដមរបស់លោក។ រួចគ្រប់ទាំងសាសន៍ នឹងត្រូវប្រមូលគ្នា នៅចំពោះលោក ហើយលោកនឹងញែកគេចេញពីគ្នា ដូចជាអ្នកគង្វាលដែលញែកចៀមចេញពីពពែដែរ»* (ម៉ាថាយ ២៥:៣១-៣២)។ **តើការនេះបានកើតឡើងទេ នៅពេលដែល យ៉ាង ស៊ុងប៊ិន មកនោះ**?

៩. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មក ទ្រង់នឹងប្រោសរូបកាយអ្នកស្លាប់ទាំងអស់ដែលជាគ្រីស្ទបរិស័ទ។ *«ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង នោះពួកស្លាប់*

*ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់។ រួចយើងរាល់គ្នាដែលកំពុងតែរស់នៅ ក៏នឹងបានលើកឡើង ទៅក្នុងពពកជាមួយគ្នាទាំងអស់ ដើម្បីឲ្យបានជួបជុំនឹងព្រះអម្ចាស់នៅនាអាកាស យ៉ាងនោះ យើងនឹងនៅជាមួយនឹងព្រះអម្ចាស់ជាដរាបទៅ»* (១ថែស្សាឡូនីច ៤:១៦-១៧)។ **តើការនេះបានកើតឡើងទេ នៅពេលដែល យ៉ាង ស៊ីងប៊ិន មកនោះ?**

១០. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មក ទ្រង់នឹងមិនកើតមកជាទារកតូចទេ ប៉ុន្តែទ្រង់នឹងយាងមកពីស្ថានសួគ៌ជាអ្នកចម្បាំងដ៏មានគ្រប់ព្រះចេស្ដា ដើម្បីវិនិច្ឆ័យជំនុំជម្រះផែនដី។ *«ខ្ញុំក៏ឃើញមេឃបើកចំហឡើង នោះឃើញមានសេះស១ និងព្រះអង្គដែលគង់លើវា ទ្រង់មានព្រះនាមថា «ស្មោះត្រង់ ហើយពិតប្រាកដ» ទ្រង់ជំនុំជំរះ ហើយច្បាំងដោយសុចរិត [12] ព្រះនេត្រទ្រង់ដូចជាអណ្តាតភ្លើង ហើយនៅលើព្រះសិរសា មានមកុដជាច្រើន ទ្រង់មានព្រះនាមកត់ទុក ដែលគ្មានអ្នកណាស្គាល់ឡើយ លើកតែអង្គទ្រង់ប៉ុណ្ណោះ [13] ទ្រង់ក៏ទ្រង់ព្រះពស្ត្រជ្រលក់ដោយឈាម ហើយព្រះនាមទ្រង់ហៅថា «ព្រះបន្ទូលនៃព្រះ» [14] អស់ទាំងពលបរិវារនៅស្ថានសួគ៌ ក៏ជិះសេះសដង្ហែទ្រង់ ទាំងស្លៀកពាក់សំពត់ទេស ហើយស្អាតផង [15] មានដាវយ៉ាងមុតចេញពីព្រះឱសទ្រង់ ដើម្បីនឹងកាប់អស់ទាំងសាសន៍ ហើយទ្រង់នឹងឃ្វាលគេ ដោយដំបងដែក ទ្រង់ក៏ជាន់ក្នុងធុងឃ្នាបនៃស្រាទំពាំងបាយជូរ ជាសេចក្តីឃោរឃៅរបស់សេចក្តីខ្ញាល់នៃព្រះដ៏មានព្រះចេស្តាបំផុត [16] ទ្រង់មានព្រះនាមកត់នៅព្រះពស្ត្រ ហើយនៅព្រះឧរូទ្រង់ថា «ស្តេចលើអស់ទាំងស្តេច ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់»*។ (វិវរណៈ ១៩:១១-១៦)។ **តើការនេះបានកើតឡើងទេនៅពេលដែល យ៉ាង ស៊ីងប៊ិន មកនោះ?**

**គ្មានព្រឹត្តិការណ៍ណាមួយសោះបានកើតឡើង ក្នុងចំណោមព្រឹត្តិការណ៍ទាំងនេះ នៅពេលដែល យ៉ាង ស៊ីងប៊ិន មកនោះ។** យ៉ាង ស៊ីងប៊ិន ជាព្រះគ្រីស្ទក្លែងក្លាយ។ គាត់មិនមែនជា «ព្រះដ៏មានគ្រប់ព្រះចេស្ដា»នោះទេ។ អស់រយៈពេលជាច្រើនឆ្នាំនាងបានលាក់ខ្លួនពីរដ្ឋាភិបាលចិន។ ប៉ុន្តែនៅពេលព្រះគ្រីស្ទពិតយាងមក ទ្រង់មិនខ្លាចអ្នកណាទេ ពីព្រោះទ្រង់ជាព្រះដ៏មានគ្រប់ព្រះចេស្ដាពិតប្រាកដ គឺជាស្តេចលើអស់ទាំងស្តេច ជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់!



## មុខពូថៅ

តើអ្វីជាមុខពូថៅ ដែលក្រុមនេះប្រើ សម្រាប់ពុះគ្រីស្ទបរិស័ទចេញពីក្រុមជំនុំ និងព្រះរបស់គេ? ឧបាយកលចម្បងរបស់ក្រុមនេះគឺ ហ្វេសបុក និងទូរស័ព្ទ។ ពួកគេបង្ហោះវីដេអូតាម ហ្វេសបុក និង យូធូប អំពីព្រឹត្តិការ និងមហន្តរាយនៃថ្ងៃចុងក្រោយដើម្បីបំភ័យអ្នកមើល។ នៅពេលគ្រីស្ទបរិស័ទម្នាក់ចុចឡៃ លើការបង្ហោះនោះ ក្រុមនេះទាក់ទងនឹងគេភ្លាមតាមមេសសិនចឺដើម្បីសុំលេខទូរស័ព្ទ។ នៅពេលពួកបានលេខទូរស័ព្ទពួកគេតែអ្នកនោះរហូត ដើម្បីបបួលពួកគេចូលរួម«រៀនព្រះគម្ពីរ»ជាមួយពួកគេតាមទូរស័ព្ទ ឬ Zoom។ គ្រីស្ទបរិស័ទទាំងអស់ចាប់អារម្មណ៍ នឹងការសិក្សាព្រះគម្ពីរ ដូច្នេះនៅពេលក្រុមនេះ អញ្ជើញគេឲ្យចូល«សិក្សាព្រះគម្ពីរ» នោះគេចាប់អារម្មណ៍ណាស់។ ប៉ុន្តែនៅពេលគ្រីស្ទបរិស័ទចូលរួម ពួកគេឃើញថាក្រុមនេះមិនបានសិក្សាព្រះគម្ពីរបរិសុទ្ធទាល់តែសោះ គ្រាន់តែជាពាក្យសំដីរបស់ស្ត្រីដែលហៅខ្លួនថា «ព្រះដ៏មានគ្រប់ចេស្ដា»។

## ការច្រៀងចំរៀងថ្វាយបង្គំព្រះគ្រីស្ទក្លែងក្លាយ

គ្រីស្ទបរិស័ទក៏ចូលចិត្តច្រៀងចម្រៀងសរសើរព្រះណាស់។ អ្នកដើរតាម យ៉ាង ស៊ីងប៊ិន បានសរសេរបទចម្រៀងជាច្រើន មិនមែនសរសើរព្រះជាម្ចាស់ពិតទេ តែសរសើរព្រះក្លែងក្លាយយ៉ាង ស៊ីងប៊ិន ដែលគេហៅថា «ព្រះដ៏មានគ្រប់ព្រះចេស្ដា» វិញ។ ពួកគេបានបកប្រែបទចម្រៀងនោះជាច្រើនភាសា ហើយបង្ហោះលើប្រព័ន្ធអ៊ីនធឺណិត។ ក៏ប៉ុន្តែ បទចម្រៀងរបស់ពួកគេ មានការបោកបញ្ឆោត ឧទាហរណ៍ បទចម្រៀងរបស់ពួកគេជាភាសាអង់គ្លេស មិនប្រើពាក្យសព្វនាមស្រី «She» និង «Her» សំដៅលើ យ៉ាង ស៊ីងប៊ិនទេ ប៉ុន្តែប្រើសព្វនាមបុរស «He» និង «Him»

ហាក់ដូចជា យ៉ាង ស៊ីងប៊ិនជាមនុស្សប្រុស។ ហើយការបង្រៀននៅយូធូប ក៏សំដៅទៅ យ៉ាង ស៊ីងប៊ិន ដោយប្រើ «He» និង «Him» ដែរ។ នេះគឺជាការបោកបញ្ឆោតខ្លាំងណាស់។ ក្រុមនេះដឹងថា មនុស្សភាគច្រើនមិនចង់គិតពីព្រះយេស៊ូវគ្រីស្ទជាស្រ្តីទេ ពីព្រោះព្រះគ្រីស្ទពិត ត្រូវតែជាបុរសម្នាក់ ដែលជាកូនចៅរបស់ស្តេចដាវីឌ។

វិធីមួយទៀតដែលពួកគេទាក់ទាញសមាជិកថ្មី គឺតាមរយៈគេហទំព័ររបស់គេឈ្មោះថា «kingdomsalvation» និង «godfootsteps» ដែលមានអត្ថបទ និងវីដេអូដែលត្រូវបានបកប្រែទៅភាសាជាច្រើននៅក្នុងពិភពលោក។ ពួកគេបានបង្ហោះវីដេអូរាប់រយ ដែលមានចម្រៀង មានសេចក្តីអធិប្បាយ ទីបន្ទាល់ និងខ្សែភាពយន្តដើម្បីសរសើរស្រ្តីនេះ ដែលពួកគេហៅថា «ព្រះដ៏មានគ្រប់ព្រះចេស្តា»។ កុំមើលវីដេអូ យូធូប ណាមួយរបស់ពួកគេ ឬមើលគេហទំព័ររបស់ពួកគេនោះឡើយ។ ប្រសិនបើអ្នកឃើញរូបសញ្ញាសំគាល់ នេះ អ្នកត្រូវដឹងថា វាជាក្រុមអង់ទីគ្រីស្ទះ

មិនយូរមិនឆាប់ព្រះគ្រីស្ទក្លែងក្លាយនេះ ដែលមកពីប្រទេសចិន នឹងត្រូវចាស់ទៅ (ឥឡូវគាត់មានអាយុ ៥០ ឆ្នាំហើយ)។ ទោះបីជានាងហៅខ្លួនឯងថា «មានគ្រប់ចេស្តា» ក៏ដោយ ក៏នាងមិនអាចយកឈ្នះសេចក្តីស្លាប់បានដែរ ពីព្រោះនាងគ្រាន់តែជាមនុស្សធម្មតាប៉ុណ្ណោះ មិនមែនជាព្រះគ្រីស្ទទេ។ ប៉ុន្តែនៅពេលដែលព្រះគ្រីស្ទដ៏ពិតបានសុគត នោះទ្រង់បានរស់ឡើងវិញ នៅបីថ្ងៃក្រោយមក ដូចដែលព្រះគម្ពីរបានចែងទុក។ សេចក្តីស្លាប់មិនអាចមានជ័យជំនះលើព្រះយេស៊ូវគ្រីស្ទបានទេ

ពីព្រោះទ្រង់ជាព្រះដ៏មានគ្រប់ព្រះចេស្ដាពិត! ហើយនៅពេលដែលព្រះគ្រីស្ទពិតប្រាកដត្រឡប់មកផែនដីវិញ ទ្រង់នឹងមិនលាក់ខ្លួននៅក្នុងបន្ទប់ ដូច យ៉ាង ស៊ីងប៊ិនទេ! អត់ទេ *«គ្រប់ទាំងភ្នែកនឹងបានឃើញទ្រង់»* (វិវរណៈ ១:៧)

ក្រុមប្រឹក្សាគ្រីស្ទបរិស័ទទាំងអស់នៅក្នុងប្រទេសចិន ចាត់ទុកពួកជំនុំនៃព្រះដ៏មានគ្រប់ព្រះចេស្ដា (Eastern Lightning) ថាជា ក្រុមខុសឆ្គងដ៏គ្រោះថ្នាក់។ សូមនៅឲ្យឆ្ងាយពីពួកគេ ហើយកុំមើលវីដេអូរបស់ពួកគេ ឬនិយាយជាមួយពួកគេតាមទូរស័ព្ទ។ ពួកគេជាឆ្កែចចកពាក់រោមចៀម។

ក្រុមនេះប្រើឈ្មោះច្រើន៖ The Church of the Almighty God, The Congregation, Eastern Lightning, New Power Lord's Church, Church of the Gospel's Kingdom

ចុងក្រោយ សូមកុំភ្លេច ២យ៉ូហាន ១:១០-១១ *«បើអ្នកណាមកឯអ្នករាល់គ្នា តែមិនបង្រៀនចំពោះសេចក្ដីនេះ នោះកុំឲ្យទទួលអ្នកនោះ នៅក្នុងផ្ទះឡើយ កុំឲ្យទាំងជំរាបសួរដល់អ្នកនោះផង ដ្បិតបើអ្នកណាជំរាបសួរ នោះក៏តែងមានសេចក្ដីប្រកបគ្នា ក្នុងការអាក្រក់របស់អ្នកនោះដែរ»*។ (កុំភ្លេចថា ការហាមមិនអនុញ្ញាតឲ្យគេចូលផ្ទះនេះ ក៏និយាយរួមទាំងការចូលតាមទូរស័ព្ទរបស់ខ្លួនដែរ)។


ព្រះបន្ទូលលេចមកជាសាច់ឈាម


ការជំនុំជម្រះ ចាប់ផ្ដើមពីដំណាក់របស់ព្រះជាម្ចាស់


ព្រះបន្ទូលប្រចាំថ្ងៃរបស់ព្រះជាម្ចាស់


សម្រង់ព្រះបន្ទូលនៃព្រះដ៏មានគ្រប់ព្រះចេស្ដា


ព្រះជាម្ចាស់បានយាងមក ទ្រង់គឺជាស្ដេច

*សៀវភៅទាំងនេះមិនមែនជាព្រះគម្ពីរទេ។ វាជាគម្ពីរក្លែងក្លាយ ដែលជាពាក្យរបស់ស្ត្រីជនជាតិចិនម្នាក់ដែលអះអាងថានាងជាព្រះ។ ចូរនៅឲ្យឆ្ងាយពីសៀវភៅទាំងនេះ។*

*ក្រុមនេះចំណាយប្រាក់រាប់លានដុល្លារដើម្បីផលិតភាពយន្ត និងវីដេអូចម្រៀងជាច្រើនភាសា។ នៅពេលដែលខ្សែភាពយន្ត និងវីដេអូចម្រៀងនិយាយអំពី «ព្រះ» «ព្រះអម្ចាស់» «ព្រះដ៏មានគ្រប់ព្រះចេស្ដា» ឬ «ព្រះគ្រីស្ទ» ពួកគេកំពុងនិយាយអំពីស្ត្រីជនជាតិចិនម្នាក់ដែលកំពុងលាក់ខ្លួននៅទីក្រុងញូវយ៉ក មិនមែនអំពីព្រះពិតនោះទេ។ បើអ្នក «ចូលចិត្ត» ឬ «ចែករំលែក» វីដេអូទាំងនេះ អ្នកកំពុងជួយព្រះគ្រីស្ទក្លែងក្លាយ។*




## ធនធានគួរឲ្យទុកចិត្ត

https://www.chinasource.org/resource-library/articles/brief-look-at-some-of-eastern-lightnings-false-teachings/

https://www.chinasource.org/resource-library/articles/a-field-study-of-the-church-of-almighty-god-cult/

https://www.chinasource.org/resource-library/articles/combating-the-cult-almighty-god-church/

https://www.cnn.com/2014/06/06/world/asia/china-eastern-lightning-killing/index.html

# ស្មរបន្ទាល់ព្រះយេហូវ៉ា

## Jehovah's Witnesses and Watchtower Bible and Tract Society

### ទីក្រុងញូវយ៉ក

ក្រុមស្មរបន្ទាល់ព្រះយេហូវ៉ាប្រើពាក្យថា «ព្រះជាម្ចាស់ ព្រះរាជបុត្រានៃព្រះ ព្រះយេស៊ូវ ព្រះវិញ្ញាណបរិសុទ្ធ សេចក្តីសង្គ្រោះ និងការរស់ឡើងវិញ ។ល។ » ដូចគ្រីស្ទបរិស័ទដែរ ប៉ុន្តែពួកគេឲ្យអត្ថន័យខុសពីអត្ថន័យក្នុងគម្ពីរ។

## ប្រវត្តិ



ឆាល្ស ថេហ្ស រើសិល (Charles Taze Russell) (រូបភាពខាងស្តាំ) បានបង្កើតក្រុមខុសឆ្គងនេះនៅឆ្នាំ ១៨៧០។ ដូចគ្រូខុសឆ្គងអារីយូស នៅសតវត្សទី៤ លោករើសិល បានបដិសេធភាពជាព្រះរបស់ព្រះគ្រីស្ទ និងព្រះត្រៃឯកដែរ។ គាត់ក៏បង្រៀនថា រូបកាយរបស់ព្រះយេស៊ូវ មិនបានរស់ពីស្លាប់ឡើងវិញទេ ហើយមិនជឿថា មានស្ថាននរកទេ។ គាត់បានបង្រៀនថា ទីបញ្ចប់នៃសាកលលោកនឹងមកនៅសម័យគាត់ ហើយថា សង្គ្រាមអើម៉ាគេដូន (វិវរណៈ ១៦:១៦) ត្រូវតែកើតឡើងនៅក្នុងជំនាន់ដែលបានរស់នៅក្នុងកំឡុងឆ្នាំ១៩១៤។ ទំនាយនេះ និងទំនាយជាច្រើនទៀតបានបរាជ័យ ដូច្នេះលោករើសិលជាហោរាក្លែងក្លាយ។

## ជំនឿ

**ក្រុមនេះជឿថា ព្រះយេស៊ូវ គឺជាទេវតាដែលព្រះវរបិតាបានបង្កើតពីសូន្យមក។** ក្រុមស្មរបន្ទាល់ព្រះយេហូវ៉ាបង្រៀនថា ព្រះជាម្ចាស់គង់នៅតាំងពីអស់កល្បជានិច្ច តែព្រះយេស៊ូវគ្រីស្ទមិនគង់នៅតាំងពីអស់កល្បជានិច្ចទេ ទ្រង់មានដើមដំបូងវិញ។ គេជឿថា ព្រះជាម្ចាស់បានបង្កើតព្រះរាជបុត្រានៃទ្រង់ មុនអ្វីៗទាំងអស់។ បន្ទាប់មកព្រះរាជបុត្រានៃព្រះ បានបង្កើតអ្វីៗផ្សេងទៀត។ ដូច្នេះព្រះរាជបុត្រានៃព្រះ ជារបស់ដែលត្រូវបានបង្កើតឡើង ហើយមិនមែនគង់នៅតាំងពីអស់កល្បជានិច្ចនោះទេ។ អ្នកអាចចាំបានថា គ្រូក្លែងក្លាយអារីយូសក៏បានបង្រៀនសេចក្ដីដូចគ្នានៅសតវត្សរ៍ទី៣និងទី៤។ នៅឆ្នាំ៣២៥នៃគ.ស មានសន្និបាតគ្រូគង្វាលពីទូទាំងពិភពលោក នៅទីក្រុង ណៃសៀ (Nicea) ដើម្បីប្រឆាំង និងកាត់ទោសអារីយូស និងការបង្រៀនរបស់គាត់។ តែបច្ចុប្បន្ននេះ ការកុហករបស់អារីយូស បានមកវិញហើយ តាមរយៈក្រុមស្មរបន្ទាល់ព្រះយេហូវ៉ា។

ក៏ប៉ុន្ដែ គោលជំនឿអំពីភាពជាព្រះរបស់ព្រះគ្រីស្ទ គឺចែងយ៉ាងច្បាស់នៅក្នុងគម្ពីរយ៉ូហាន ១:១ ដែលប្រកាសថា «ព្រះបន្ទូល» (ព្រះរាជបុត្ររបស់ព្រះ) គឺជាព្រះពិតប្រាកដតាំងពីអស់កល្បរៀងមក៖ *«កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ»*។ តើស្មរបន្ទាល់ព្រះយេហូវ៉ាឆ្លើយយ៉ាងណាចំពោះខនេះ? ឆ្លើយអត់បានទេ ដូច្នេះពួកគេបានបកប្រែគម្ពីរផ្ទាល់របស់គេដែលហៅថា *New World Translation (ពិភពថ្មី)* ដែលនិយាយខុសពីព្រះគម្ពីរ។ សូមស្ដាប់របៀបដែលគេបានបកប្រែគម្ពីរយ៉ូហាន ១:១ «នៅដើមដំបូង មានលោកដែលហៅថាបណ្ដាំ ហើយលោកដែលហៅថាបណ្ដាំបាននៅជាមួយនឹងព្រះ ហើយលោកដែលហៅថាបណ្ដាំជា**ព្រះមួយ**»! បើព្រះយេស៊ូវមិនមានភាពជាព្រះ មានន័យដូចម្ដេចដែលថា ទ្រង់ជាព្រះមួយ? តើមានព្រះប៉ុន្មាន?

**ក្រុមនេះជឿថា សេចក្ដីសង្គ្រោះកើតឡើងតាមរយៈទេវតាមីកែល។** ក្រុមស្មរ បន្ទាល់ព្រះយេហូវ៉ាជឿថា ព្រះរាជបុត្រានៃព្រះ ដែលព្រះជាម្ចាស់បានបង្កើតពីសូន្យមក គឺជាមហាទេវតាមីកែល! ដោយសារអ័ដាម អេវ៉ាបានធ្វើបាបទាស់នឹងព្រះ ទ្រង់បានប្រាប់ទេវតាមីកែល (ព្រះរាជបុត្រានៃព្រះ) ឲ្យមកផែនដី ហើយកើតជាមនុស្សដែលមានឈ្មោះថា យេស៊ូវ ដើម្បីនាំសេចក្ដីសង្គ្រោះដល់ពិភពលោក។ គេជឿថា យេស៊ូវនេះបានស្លាប់នៅលើបង្គោលមួយ មិនមែនជាឈើឆ្កាងទេ ហើយគាត់មិនបានស្លាប់សម្រាប់អំពើបាបនៃពិភពលោកទាំងមូលទេ គឺគាត់បានបង់ថ្លៃលោះមនុស្សតែម្នាក់ឈ្មោះអ័ដាម ដែលជាអ្នកតំណាងរបស់យើង។ និយាយម្យ៉ាងទៀត គឺមនុស្សម្នាក់ (យេស៊ូវ)បានស្លាប់ជំនួសមនុស្សម្នាក់(អ័ដាម)។ នៅដំណឹងល្អពិត ព្រះរាជបុត្រាបានសុគតជំនួសមនុស្សលោក។

**ក្រុមនេះជឿថា ព្រះយេស៊ូវមិនបានរស់ឡើងវិញទេ។** ពួកគេបង្រៀនថា ក្រោយយេស៊ូវរបស់គេបានស្លាប់ រូបកាយរបស់គាត់មិនបានរស់ពីស្លាប់ឡើងវិញទេ។ លោកយេស៊ូវគ្រាន់តែក្រោកឡើងជាវិញ្ញាណ ដែលមើលមិនឃើញ ប៉ុន្តែរូបកាយគាត់នៅតែស្លាប់ក្នុងផ្នូរ។ បើអ៊ីចឹង ហេតុអ្វីបានជាផ្នូរនៅទទេ? ក្រុមស្មរបន្ទាល់ព្រះយេហូវ៉ាមិនដឹងទេ។ ពួកគេសង្ស័យថា ប្រហែលព្រះបានធ្វើឲ្យរូបកាយរបស់យេស៊ូវរលាយបាត់សូន្យទៅវិញ។ ឬប្រហែលព្រះយកសពលោកយេស៊ូវមកលាក់នៅកន្លែងផ្សេង!! ពួកគេបង្រៀនថា នៅពេលយេស៊ូវបានលេចឲ្យពួកសិស្សឃើញអស់រយៈពេល៤០ថ្ងៃ បន្ទាប់ពីគាត់រស់ឡើងវិញនោះ គាត់គ្រាន់តែប្រើរូបកាយបណ្ដោះអាសន្នមួយ ដើម្បីឲ្យសិស្សគិតថា គាត់បានរស់ឡើងវិញជាសាច់ឈាមមែន! នេះជាមូលហេតុដែលពួកសិស្សអាចពាល់គាត់បាន និងជាហេតុដែលគាត់អាចបរិភោគអាហារបាន។ បើនេះជាការពិត ទាំងព្រះវរបិតា និងព្រះរាជបុត្រា បានចូលរួមក្នុងការបោកបញ្ឆោតដ៏ធំមួយ ដើម្បីធ្វើល្បិចដល់ពួកសិស្សរាប់រយនាក់។ មិន

តែប៉ុណ្ណោះ ទេវតាបរិសុទ្ធក៏ពាក់ព័ន្ធនឹងការបោកបញ្ឆោតដែរ ព្រោះពួកគេបានបើកផ្នូរដើម្បីបង្ហាញថា រូបកាយរបស់យេស៊ូវបានរស់ឡើងវិញ។ បើមានតែវិញ្ញាណលោកយេស៊ូវដែលបានរស់ឡើងវិញ មិនបាច់បង្ហាញផ្នូរទទេដល់ពួកសិស្សទេ។

ក៏ប៉ុន្តែសូមស្តាប់ព្រះបន្ទូលរបស់ព្រះយេស៊ូវ៖ *«ព្រះយេស៊ូវទ្រង់ឆ្លើយទៅគេថា ចូរបំផ្លាញ**ព្រះវិហារនេះ**ចុះ រួចក្នុងរវាង៣ថ្ងៃខ្ញុំនឹងសង់ឡើងវិញ.... ប៉ុន្តែគឺទ្រង់មានព្រះបន្ទូលពីព្រះវិហារដែលជា**រូបអង្គ**ទ្រង់ទេ»* (យ៉ូហាន ២:១៩,២១)។ ក្រុមស្មរបន្ទាល់ព្រះយេហូវ៉ាមិនជឿខនេះទេ។ ថែមពីលើនេះ ក្រោយពីព្រះយេស៊ូវរស់ឡើងវិញ នោះទ្រង់បានបញ្ជាក់ថា ទ្រង់បានរស់ឡើងវិញទាំងមានរូបកាយខាងសាច់ឈាម៖ *«ទ្រង់មានព្រះបន្ទូលទៅគេថា ហេតុអ្វីបានជាវិលវល់ហើយសង្ស័យក្នុងចិត្តដូច្នេះ ចូរមើលមកដៃនិងជើងខ្ញុំឲ្យបានដឹងថា នេះគឺខ្ញុំពិតមែន ចូរពាល់ខ្ញុំមើល **ដ្បិតខ្មោចគ្មានសាច់ ឬឆ្អឹងដូចជាឃើញខ្ញុំនេះទេ**»* (លូកា ២៤:៣៨-៣៩)។ តើព្រះយេស៊ូវកុហកដល់ពួកសិស្សនៅក្នុងខនេះ ឬរូបកាយទ្រង់បានរស់ពីសុគតឡើងវិញពិតមែន?

ស្មរបន្ទាល់ព្រះយេហូវ៉ាការពារជំនឿរបស់គេ ដោយឆ្លើយថា ព្រះយេស៊ូវអាចលេចមក ហើយក្រោយមកបាត់វិញ។ ពួកគេសួរថា «ធ្វើដូចម្តេចឲ្យរូបកាយអាចធ្វើអ៊ីចឹងបាន?» សាវកប៉ុល នឹងឆ្លើយពួកគេ ដូចដែលគាត់បានឆ្លើយនឹងគ្រូខុសឆ្គងនៅសម័យគាត់ ដែលបានបដិសេធការរស់ឡើងវិញដែរថា *«ឱមនុស្សកំឡៅអើយ»* (១កូរិនថូស ១៥:៣៦)។ នៅវគ្គនោះសាវកប៉ុលក៏បង្រៀនតទៅទៀតថា រូបកាយដែលរស់ឡើងវិញ ខុសគ្នាឆ្ងាយពីរូបកាយមុនរស់ឡើងវិញ សូម្បីតែរូបកាយនោះ ជារូបកាយដដែល។ រូបកាយចាស់ខ្សោយ តែរូបកាយថ្មីខ្លាំងពូកែ។ រូបកាយចាស់ គឺខាងផែនដីនេះ ឯរូបកាយថ្មីគឺខាងស្ថានសួគ៌ **ប៉ុន្តែជារូបកាយតែមួយដដែល** សូមស្តាប់សាវកប៉ុល៖

*«បងប្អូនអើយ សេចក្តីដែលខ្ញុំចង់និយាយនេះ គឺថា សាច់ឈាមពុំអាចនឹងគ្រងនគរព្រះជាមរដកបានឡើយ ហើយសេចក្តីពុករលួយក៏ពុំអាចនឹងគ្រងសេចក្តីដែលមិនចេះពុករលួយបានដែរ។ ៥១ នែ ខ្ញុំប្រាប់អ្នករាល់គ្នាពីសេចក្តីអាថ៌កំបាំង គឺថាយើងទាំងអស់គ្នានឹងមិនដេកលក់ទៅទេ ៥២ តែទាំងអស់គ្នានឹងបានផ្លាស់ប្រែទៅក្នុង១រំពេចវិញ គឺក្នុង១ប៉ប្រិចភ្នែកប៉ុណ្ណោះ ក្នុងកាលដែលឮសូរត្រែក្រោយបង្អស់ ដ្បិតត្រែនឹងឮឡើងមែន នោះពួកស្លាប់នឹងរស់ឡើងវិញមិនពុករលួយទៀតឡើយ រួចយើងរាល់គ្នានឹងបានផ្លាស់ប្រែទៅ ៥៣ ដ្បិតត្រូវតែរូបកាយដ៏ពុករលួយនេះ បានប្រដាប់ដោយសេចក្តីមិនពុករលួយវិញ ហើយរូបកាយដែលរមែងស្លាប់នេះ ត្រូវតែបានប្រដាប់ដោយសេចក្តីមិនចេះស្លាប់វិញដែរ»* (១កូរិនថូស ១៥:៥០-៥៣)។

សាវកប៉ុលពន្យល់ពីការរស់ឡើងវិញដោយរបៀបនេះ៖ ព្រះផ្លាស់ប្រែរូបកាយដែលស្លាប់ ទៅជារូបកាយដែលខ្លាំងពូកែ សិរីរុងរឿង ខាងវិញ្ញាណ និងមិនពុករលួយ។ សាវកប៉ុលហៅវាថា *«រូបកាយខាងវិញ្ញាណ»* (១កូរិនថូស ១៥:៤៤) ដើម្បីបង្ហាញភាពខុសគ្នាពីរូបកាយចាស់ដែលស្លាប់និងពុករលួយ។ ស្មរបន្ទាល់ព្រះយេហូវ៉ាមិនជឿថា ព្រះកាយរបស់ព្រះគ្រីស្ទបានរស់ឡើងវិញ ជារូបកាយបែបផ្សេងទេ។ គេជឿថារូបកាយរបស់លោកយេស៊ូវបានស្លាប់រហូត ហើយមានតែព្រលឹងរបស់គាត់ដែលរស់ឡើងវិញ។ បន្ទាប់មកព្រះជាម្ចាស់បានធ្វើឲ្យរូបកាយនោះបាត់បង់ទៅ។ ប៉ុន្តែការធ្វើឲ្យរូបកាយរលាយបាត់ទៅ មិនមែនជាអត្ថន័យនៃពាក្យ រស់ពីស្លាប់ឡើងវិញទេ។ នៅក្នុងគម្ពីរពាក្យក្រេក *អាណាស្តាស៊ីស* ដែលបកប្រែថា «រស់ពីស្លាប់ឡើងវិញ» មានន័យថា រូបកាយស្លាប់ ផ្លាស់ប្រែជា រូបកាយបែបផ្សេង ដែលអាចរស់នៅអស់កល្បជានិច្ច។ ស្មរបន្ទាល់ព្រះយេហូវ៉ា មិនជឿលើគោលជំនឿនេះទេ។

**ការព្យាករណ៍ខុសអំពីការយាងមកលើកទីពីររបស់ព្រះគ្រីស្ទ។** លោក រើសិល បានបង្រៀនថា ព្រះយេស៊ូវបានត្រឡប់មកវិញនៅឆ្នាំ១៨៧៤ហើយ ប៉ុន្តែតាមរបៀបអាថ៌កំបាំងដែលគ្មានអ្នកណាអាចមើលឃើញបានឡើយ។ បន្ទាប់មកគាត់បានទាយនៅឆ្នាំ១៨៨៩ថា «សមរភូមិនៃថ្ងៃដ៏អស្ចារ្យរបស់ព្រះដ៏មានគ្រប់ព្រះចេស្ដា...នឹងបញ្ចប់នៅឆ្នាំ១៩១៤ នៃគ.ស.ដោយការផ្តួលរំលំទាំងស្រុង នៃការគ្រប់គ្រងបច្ចុប្បន្នរបស់ផែនដី»។ ច្បាស់ណាស់ការនោះមិនបានកើតឡើងទេ។ នៅក្នុងឆ្នាំដដែលនោះគាត់ក៏បានព្យាករណ៍អំពីការនេះ៖ «ក្នុងរយៈពេល២៦ឆ្នាំ ខាងមុខនេះរដ្ឋាភិបាលទាំងអស់នឹងត្រូវដួលរលំ និងរំលាយចោល»។ ការនេះក៏អត់បានកើតឡើងដែរ។ គាត់ក៏បានព្យាករណ៍ទៀតថា ឆ្នាំ ១៩១៤ នឹងជា ...

- ចុងបញ្ចប់នៃសាសនាទាំងអស់
- ការបំផ្លាញរដ្ឋាភិបាលទាំងអស់
- ចុងបញ្ចប់នៃគ្រាវេទនាដ៏ធំ
- ចុងបញ្ចប់នៃសង្គ្រាមហាម៉ាគេដូន
- ពេលដែល លោក ឆាល្សថេហ្ស រើសិល និងអ្នកដើរតាមគាត់ នឹងត្រូវបានលើកឡើងទៅស្ថានសួគ៌
- ពេលដែលរាជាណាចក្ររបស់ព្រះយេស៊ូវ នឹងត្រូវបានស្ថាបនាជាសួនមនោរម្យនៅលើ ផែនដី
- ការចាប់ផ្តើមនៃការរស់ឡើងវិញនៅលើផែនដី

គ្មានទំនាយណាមួយ ក្នុងចំណោមទំនាយទាំងនេះបានកើតឡើងនោះទេ។ ក្រោយមកក្រុមរបស់គាត់បានទាយថា អ័ប្រាហាំ និងអ៊ីសាក នឹងរស់ឡើងវិញនៅឆ្នាំ១៩២៥។ ការព្យាករណ៍នេះបានបរាជ័យ។ បន្ទាប់មកពួកគេបានព្យាករណ៍ថារជ្ជកាល ១០០០ ឆ្នាំរបស់ព្រះគ្រីស្ទ នឹងចាប់ផ្តើមនៅឆ្នាំ ១៩៧៥។ ការព្យាករណ៍

នេះក៏បានបរាជ័យដែរ។ ហេតុអ្វីយើងគួរទុកចិត្តពួកគេ? ពួកគេគឺជាហោរាក្លែងក្លាយ។

**ពួកគេបដិសេធព្រះត្រៃឯក។** ស្មរបន្ទាល់ព្រះយេហូវ៉ាបង្រៀនថា ព្រះមិនមែនជាព្រះត្រៃឯកទេ ហើយព្រះយេស៊ូវក៏មិនមែនជាព្រះដែរ។ ពួកគេក៏បង្រៀនផងដែរថា ព្រះវិញ្ញាណបរិសុទ្ធមិនមែនជាអង្គដែលអាចគិត និយាយ និងស្តាប់នោះទេ តែគ្រាន់តែជាថាមពល ឥតមានឆន្ទៈ ដែលមកពីព្រះតែប៉ុណ្ណោះ ស្រដៀងនឹងថាមពលអគ្គីសនីដែលគ្មានឆន្ទៈដែរ។ ប៉ុន្តែនៅក្នុងព្រះគម្ពីរ ព្រះវិញ្ញាណបរិសុទ្ធអាចធ្វើជាសាក្សី (យ៉ូហាន ១៥:២៦) បង្រៀន (យ៉ូហាន ១៤:២៦; ១កូរិនថូស ២:១៣) សោកសៅ (អេភេសូរ ៤:៣០) និយាយ (កិច្ចការ ៨:២៩, ១៣:២) ខឹង (ហេព្រើរ ១០:២៩) ស្វែងរក (១កូរិនថូស ២:១០-១១) ហាមឃាត់ (កិច្ចការ ១៦:៦-៧); និងជួយ (រ៉ូម ៨:២៦-២៧) ។ល។ ថាមពលដែលគ្មានឆន្ទៈ មិនអាចធ្វើការទាំងអស់នេះបានឡើយ។

**សេចក្តីសង្គ្រោះអាចបានតាមតែក្រុមស្មរបន្ទាល់ព្រះយេហូវ៉ាតែប៉ុណ្ណោះ។** ស្មរបន្ទាល់ព្រះយេហូវ៉ាអះអាងថា ក្រុមសាសនាឯទៀតទាំងអស់គឺសុទ្ធតែខុស។ ដូច្នេះសេចក្តីសង្គ្រោះអាចកើតមានតែតាមរយៈសមាជិកភាព ក្នុងក្រុមស្មរបន្ទាល់ព្រះយេហូវ៉ាតែប៉ុណ្ណោះ។

**មុខពួចៅ** 

តើអ្វីជាមុខពួចៅសម្រាប់ក្រុមនេះ? ស្មរបន្ទាល់ព្រះយេហូវ៉ា ចង់ឲ្យមនុស្សគិតថា ពួកគេជាក្រុមជំនុំគ្រីស្ទបរិស័ទពិត ដូច្នេះពួកគេប្រើពាក្យដូចយើងថា

«ព្រះយេស៊ូវគ្រីស្ទ ព្រះវិញ្ញាណបរិសុទ្ធ សេចក្ដីសង្គ្រោះ ការរស់ឡើងវិញ»។ល។ ប៉ុន្តែពួកគេបំភាន់អត្ថន័យពាក្យទាំងនេះ តាមជំនឿគេ។ ពួកគេទៅផ្ទះគ្រីស្ទបរិស័ទ ហើយសួរថា តើអ្នកចង់រស់នៅលើផែនដីដ៏ល្អឥតខ្ចោះជារៀងរហូតដែរឬទេ។ ពួកគេកាន់ព្រះគម្ពីរនៅក្នុងដៃ ប៉ុន្តែខគម្ពីរដែលគេប្រើ គឺគេបំភាន់អត្ថន័យតាមជំនឿរបស់គេដែរ។

តើការបង្រៀនអ្វីខ្លះដែលពួកគេចង់លាក់បាំង(ខ្ទងពូថៅ)? នៅដំបូងពួកគេចង់លាក់ជំនឿរបស់គេថា ព្រះជាម្ចាស់បានបង្កើតព្រះរាជបុត្រាពីសូន្យមក ជាទេវតាមីកែល។ ពួកគេក៏ចង់លាក់បាំងជំនឿដែលថា រូបកាយរបស់ព្រះយេស៊ូវមិនបានរស់ពីសុគតឡើងវិញទេ។ ហើយពួកគេមិនដែលចង់និយាយអំពីការព្យាករណ៍បរាជ័យជាច្រើនរបស់ពួកគេឡើយ។

នៅពេលដែលស្មរបន្ទាល់ព្រះយេហូវ៉ា ចង់និយាយអំពីការដែលមិនសូវសំខាន់ យើងត្រូវតែសួរពួកគេម្តងហើយម្តងទៀត អំពីសំណួរសំខាន់ជាងគេដូចជា៖

«តើព្រះរាជបុត្រានៃព្រះជារបស់ដែលបង្កើតឬ (ឬសួរម្យ៉ាងទៀតថា តើទ្រង់មានដើមកំណើតទេ?)»

«តើព្រះយេស៊ូវគ្រីស្ទបានរស់ពីសុគតឡើងវិញទាំងរូបកាយដូចព្រះគម្ពីរបានចែងទេ?»

«តើព្រះយេស៊ូវរបស់អ្នកអាចជួយយើងឲ្យយកឈ្នះលើបាប និងសេចក្តីស្លាប់យ៉ាងម៉េចបាន បើគាត់មិនអាចឈ្នះលើសេចក្តីស្លាប់បានផងនោះ?»

«តើព្រះយេស៊ូវបានសុគតសម្រាប់អំពើបាបរបស់មនុស្សតែម្នាក់ ឬសម្រាប់អំពើបាបរបស់ពិភពលោក?»

«តើមានតែការសង្គ្រោះតាមរយៈស្មរបន្ទាល់ព្រះយេហូវ៉ាទេ?»

## វិធីដើម្បីលើកទឹកចិត្តស្មរបន្ទាល់ព្រះយេហូវ៉ាឲ្យជឿលើព្រះគ្រីស្ទដ៏ពិត

ខ្ញុំកំពុងពិភាក្សាគ្នាជាមួយពួកម៉ាកខ្ញុំ ដែលជាស្មរបន្ទាល់ព្រះយេហូវ៉ា ហើយយើងបានអានគម្ពីរយ៉ូហាន ៥:២២-២៣ ជាមួយគ្នា៖ *«ព្រះវរបិតាទ្រង់មិនជំនុំជំរះអ្នកណាទេ ទ្រង់បានប្រគល់គ្រប់ការជំនុំជំរះដល់ព្រះរាជបុត្រាវិញ* ***ដើម្បីឲ្យមនុស្សទាំងអស់បានគោរពប្រតិបត្តិដល់ព្រះរាជបុត្រា ដូចជាគោរពប្រតិបត្តិដល់ព្រះវរបិតាដែរ*** *អ្នកណាដែលមិនគោរពប្រតិបត្តិដល់ព្រះរាជបុត្រា នោះក៏មិនគោរពប្រតិបត្តិដល់ព្រះវរបិតាដែលចាត់ឲ្យទ្រង់មកដែរ»*។

បន្ទាប់មកខ្ញុំបានសួរសំណួរនេះដល់ពួកម៉ាកខ្ញុំថា «ពេលក្រុមជំនុំរបស់អ្នកប្រជុំដើម្បីថ្វាយបង្គំ តើពួកគេ<*គោរពប្រតិបត្តិដល់ព្រះរាជបុត្រា ដូចជាគោរពប្រតិបត្តិដល់ព្រះវរបិតា*> ដែរឬទេ?» មិត្តរបស់ខ្ញុំ បានគ្រវីក្បាល ហើយឆ្លើយថា ទេ។

នោះខ្ញុំបាននិយាយថា «ពេលអ្នកទៅថ្វាយបង្គំថ្ងៃអាទិត្យនេះ សូមសួរខ្លួនឯងថា ហេតុអ្វីបានជាក្រុមជំនុំខ្ញុំមិន *គោរពប្រតិបត្តិដល់ព្រះរាជបុត្រា ដូចជាគោរពប្រតិបត្តិដល់ព្រះវរបិតា?* ហេតុអ្វីបានជាក្រុមជំនុំខ្ញុំមិនច្រៀងសរសើរដល់ព្រះយេស៊ូវ ដូចយើងច្រៀងសរសើរដល់ព្រះវរបិតា? ហេតុអ្វីបានជាក្រុមជំនុំខ្ញុំ មិនស្រឡាញ់ព្រះយេស៊ូវអស់ពីចិត្ត ដូចយើងស្រឡាញ់ព្រះវរបិតា? ហេតុអ្វីបានជាក្រុមជំនុំខ្ញុំមិននិយាយអំពីព្រះយេស៊ូវ ដូចដែលសាវកប៉ុលនិយាយនៅ ភីលីព ៣:៧-១១៖ *<ដើម្បីឲ្យខ្ញុំបានស្គាល់ទ្រង់ និងព្រះចេស្តានៃដំណើរដែលទ្រង់រស់ឡើងវិញ ហើយនិងសេចក្តីប្រកបក្នុងការរងទុក្ខរបស់ទ្រង់ ព្រមទាំងត្រឡប់ទៅដូចជាទ្រង់ក្នុងសេចក្តីស្លាប់ផង>?»*។

បន្ទាប់មកខ្ញុំបាននិយាយដោយរបៀបកក់ក្តៅទៅមិត្តភក្តិខ្ញុំថា «ខ្ញុំសូមអញ្ជើញបងឲ្យមកលេងក្រុមជំនុំរបស់ខ្ញុំ ហើយបងនឹងឃើញថា ក្រុមជំនុំមួយដែលគោរពប្រតិបត្តិ

ដល់ព្រះរាជបុត្រា ដូចយើងគោរពប្រតិបត្តិដល់ព្រះវរបិតាដែរ ពីព្រោះនោះជាសញ្ញាសំគាល់នៃក្រុមជំនុំពិត»។

យោបល់មួយទៀត ដើម្បីនាំមិត្តភក្តិក្នុងស្មរបន្ទាល់ព្រះយេហូវ៉ាឲ្យស្គាល់ព្រះយេស៊ូវពិត គឺអានគម្ពីរហេព្រើរជំពូក១ជាមួយគ្នា។ ស្នាក់ការកណ្តាលរបស់ស្មរបន្ទាល់ព្រះយេហូវ៉ា ទទួលសំណួរពីសមាជិករបស់ពួកគេ អំពីហេព្រើរជំពូក១ ជាងវគ្គគម្ពីរឯទៀត។ ហេតុអ្វី? ពីព្រោះអ្នកនិពន្ធហេព្រើរជំពូក១ ដកស្រង់ខគម្ពីរសញ្ញាចាស់ជាច្រើន អំពីព្រះយេហូវ៉ា ដែលបានបំពេញក្នុងព្រះយេស៊ូវគ្រីស្ទ។ ឧទាហរណ៍ នៅហេព្រើរ ១:៨-៩ អ្នកនិពន្ធគម្ពីរហេព្រើរយោងខនេះ ពីទំនុកដំកើង ៤៥៖ *«តែខាងឯព្រះរាជបុត្រាវិញ នោះទ្រង់មានព្រះបន្ទូលថា <ឱ**ព្រះ**អើយ បល្ល័ង្កទ្រង់នៅជាប់អស់កល្បជានិច្ចរៀងរាបតទៅ ព្រះដំបងពេជ្ររបស់រាជ្យទ្រង់ នោះជាដំបងសុចរិត ទ្រង់បានស្រឡាញ់សេចក្តីសុចរិត ហើយស្អប់ការទទឹងច្បាប់ ហេតុនោះបានជាព្រះ គឺជាព្រះនៃទ្រង់បានចាក់ប្រេងថ្វាយទ្រង់ ជាប្រេងនៃសេចក្តីត្រេកអរសាទរលើសជាងពួកសម្លាញ់នៃទ្រង់>»*។ សូមសម្គាល់ថា ទំនុកដំកើង ៤៥:៦-៧នេះ មានបន្ទូលអំពីព្រះជាម្ចាស់៖ *«ឱព្រះ...»* ប៉ុន្តែអ្នកនិពន្ធគម្ពីរហេព្រើរ ប្រើខនោះដើម្បីនិយាយពីព្រះយេស៊ូវវិញ។ ព្រះយេស៊ូវជាព្រះ! មួយទៀតនៅហេព្រើរ ១:១០-១២ អ្នកនិពន្ធ យោងទំនុកដំកើង ១០២:២៥-២៧៖ *«ឱ**ព្រះអម្ចាស់**អើយកាលដើមដំបូងទ្រង់បានបង្កប់ឫសផែនដី ហើយផ្ទៃមេឃក៏ជាការដែលព្រះហស្តទ្រង់ធ្វើដែរ ឯរបស់ទាំងនោះនឹងសាបសូន្យទៅ តែទ្រង់នឹងគង់នៅជាប់ដដែល របស់ទាំងនោះនឹងចាស់ទៅដូចជាសំលៀកបំពាក់ ទ្រង់នឹងផ្លាលទៅដូចជាអាវ ហើយរបស់ទាំងនោះក៏នឹងប្រែក្លាយទៅ តែទ្រង់នៅតែដដែល ព្រះជន្មទ្រង់មិនចេះផុតឡើយ»*។ នៅគម្ពីរទំនុកដំកើង១០២:២៥-២៧ ពាក្យ «ព្រះអម្ចាស់» គឺ«យេហូវ៉ា» (យ៉ាវេ) ក្នុងភាសា

ហេព្រើរ តែអ្នកនិពន្ធគម្ពីរហេព្រើរនិយាយថា ខនោះ គឺអំពីព្រះយេស៊ូវវិញ! ដូច្នេះ ព្រះយេស៊ូវ គឺជាព្រះយេហូវ៉ា!

ហើយសូមកុំភ្លេច២យ៉ូហាន ១:១០-១១៖ *«បើអ្នកណាមកឯអ្នករាល់គ្នាហើយមិនបង្រៀនចំពោះសេចក្តីនេះ នោះកុំឲ្យទទួលអ្នកនោះនៅក្នុងផ្ទះឡើយ កុំឲ្យទាំងជំរាបសួរដល់អ្នកនោះផង ដ្បិតបើអ្នកណាជំរាបសួរនោះក៏តែងមានសេចក្តីប្រកបគ្នាក្នុងការអាក្រក់របស់អ្នកនោះដែរ»*។

**ធនធានគួរឲ្យទុកចិត្ត**

https://carm.org/?s=Jehovah%27s+witnesses

# សាសនាមរមន

## Mormonism

## សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

## Salt Lake City, Utah, USA

ពួកមរមនប្រើពាក្យដូចគ្នានឹងគ្រីស្ទសាសនាដែរ ដូចជា «ព្រះ ព្រះយេស៊ូវ សាតាំង សេចក្ដីសង្គ្រោះ ព្រះត្រៃឯក» ជាដើម។ ប៉ុន្តែអត្ថន័យដែលគេឲ្យពាក្យទាំងនោះ មានអត្ថន័យផ្សេងពីគ្រីស្ទសាសនាពិត។

### ប្រវត្តិ




យ៉ូសែប ស្មីតបានបង្កើតសាសនាថ្មី ឈ្មោះសាសនាមរមន នៅរដ្ឋញូវយ៉កប្រហែលឆ្នាំ១៨៣៨។ គាត់បានប្រកាសថា ព្រះបានប្រាប់គាត់ ឲ្យចាកចេញពីក្រុមជំនុំព្រះយេស៊ូវគ្រីស្ទ ព្រោះក្រុមជំនុំទាំងអស់ សុទ្ធតែអាក្រក់។ លោកស្មីតបាន និយាយថា ទេវតាដែលមកពីព្រះ បានប្រាប់គាត់ ពីកន្លែង ដែលសៀវភៅធ្វើពីមាសដែលគេកប់ទុក។ គាត់បាន និយាយថា គាត់បានរកឃើញសៀវភៅមាសនោះ ហើយ បកប្រែវាពី «ភាសាអេហ្ស៊ីប កំណែទម្រង់» (Reformed Egyptian) ដោយមានជំនួយពីព្រះ។ គាត់ហៅគម្ពីរនោះថា គម្ពីរមរមន តាមឈ្មោះមនុស្សម្នាក់ដែលគាត់ថា ជាអ្នក

សរសេរសៀវភៅមាសនោះ។ សៀវភៅនោះនិទានរឿងអំពីជនជាតិបុរាណមួយនៅអាមេរិកខាងជើង ដែលជាពូជជនជាតិអ៊ីស្រាអែល។ (អ្នកវិទ្យាសាស្ត្រ ថា គ្មានភ័ស្តុតាង អំពីភាសា ឬអក្សរដែលហៅថា «ភាសាអេហ្ស៊ីបកំណែទម្រង់» នោះទេ ហើយគ្មានភ័ស្តុតាងដែលថា មានជនជាតិដើមភាគតិចនៅអាមេរិក ជាពូជជនជាតិអ៊ីស្រាអែលនោះទេ)។ ក្រោយមកលោកស្មីត អះអាងថា គាត់បានប្រគល់សៀវភៅនោះ ទៅទេវតាវិញហើយ។ ដូច្នេះ គ្មានរបៀបណាដើម្បីដឹងប្រាកដថា លោកស្មិតនិយាយការពិត ឬដឹងប្រាកដថាការបកប្រែគម្ពីរមរមនត្រឹមត្រូវឬទេ។ យ៉ូសែប ស្មីតត្រូវបានចាប់ខ្លួនជាច្រើនដង ដោយសារការលួចបន្លំធនាគារ អំពើប្រាសចាកសីលធម៌ខាងផ្លូវភេទ និងការមានពហុពន្ធភាព។ (បើចង់ឃើញគ្រប់បញ្ជីចាប់ខ្លួនលោកស្មីត សូមមើលអត្ថបទ «យ៉ូសែប ស្មីត និង ប្រព័ន្ធយុត្តិធម៌» https://en.wikipedia.org/wiki/Joseph_Smith_and_the_criminal_justice_system)

## ជំនឿ

គោលជំនឿសាសនាមរមន គឺប្លែកមែនទែន ហើយខុសពីគ្រីស្ទសាសនាពិត។ វាជាសាសនាខុសគ្នាទាំងស្រុង។ ប៉ុន្តែដោយសារពួកគេប្រើឈ្មោះដូចគ្នានឹងជំនឿយើងដែរ គឺពាក្យ *«ព្រះ» «ព្រះយេស៊ូវ» «សាតាំង»* ។ល។ នោះមនុស្សគិតថា វាជាសាសនាគ្រីស្ទមួយដែរ។

**ពួកមរមនជឿថា មានព្រះរាប់ពាន់អង្គ ដែលរស់នៅលើភពផែនដីផ្ទាល់របស់ពួកគេ។** ពួកគេបង្រៀនថា «...ព្រះវរបិតាធ្លាប់ជាមនុស្សធម្មតានៅលើភពមួយផ្សេងទៀត ហើយគាតបានក្លាយជាព្រះ ដោយធ្វើតាមច្បាប់ និងក្រឹត្យវិន័យរបស់ព្រះ នៃភពនោះ ហើយ[បន្ទាប់មក]បានមកដល់ពិភពលោកនេះ ជាមួយប្រពន្ធគាត់ (នាងបានក្លាយជាព្រះដែរ)។ ហើយតាមរយៈទំនាក់ទំនងផ្លូវភេទ ពួកគេបង្កើតកូនខាងវិញ្ញាណរាប់ពាន់លាននាក់នៅស្ថានសួគ៌។ កូនខាងវិញ្ញាណទាំងនេះ រួមមានព្រះយេស៊ូវ អារក្ស

អ្នក និងខ្ញុំ សុទ្ធសឹងជាបងប្អូន ដែលកើតនៅក្នុងសម័យកាលមុន។ កូនខាងវិញ្ញាណទាំងនេះ ចុះមកចូលក្នុងរូបកាយទារកនៅពេលកើតមក។ ... លើសពីនេះទៀតពួកមរមនស្មោះត្រង់ ដែលបានបង់១០ភាគរយនៃប្រាក់ចំណូលរបស់ពួកគេដល់វិហារមរមន អាចក្លាយជាព្រះនៃភពផ្ទាល់ខ្លួនរបស់ពួកគេ ហើយបន្ទាប់មកអាចចាប់ផ្តើមដំណើរការទាំងនេះម្តងទៀត។ វាគឺជា ការប្រមាថដល់ព្រះ ដែលនិយាយថា ទ្រង់ធ្លាប់ជាមនុស្ស ហើយមានព្រះច្រើន។ (https://carm.org/mormonism/mormon-beliefs-are-they-christian/)

**ពួកមរមនបដិសេធព្រះត្រៃឯក។** ពួកមរមនចូលចិត្តនិយាយថា ពួកគេជឿលើព្រះត្រៃឯក ប៉ុន្តែតាមពិតពួកគេជឿលើព្រះ ៣ ដាច់ដោយឡែកពីគ្នា (និងព្រះរាប់ពាន់ទៀត!)។ ពួកគេមិនជឿលើព្រះតែមួយ ដែលជាព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធដ៏អស់កល្បជានិច្ចនោះទេ។ សាសនាមរមន គឺជាសាសនាពហុនិយម មិនមែនជាសាសនាគ្រីស្ទទេ។

**ពួកមរមនជឿថា ព្រះយេស៊ូវគ្រីស្ទ គឺជាមនុស្សធម្មតាដែលបានក្លាយជាព្រះ។** នៅក្នុងសាសនាមរមន ព្រះរាជបុត្រាមិនគង់នៅតាំងពីអស់កល្បជានិច្ចទេ។ វិញ្ញាណរបស់ទ្រង់បានកើតមកនៅពេលដែលព្រះវរបិតានៅស្ថានសួគ៌ និងមហេសីរបស់ទ្រង់ដែលជាព្រះដែរ បានរួមដំណេក(ទាំងពីរអង្គមានរូបកាយ ដូចអ្នក និងខ្ញុំ) ហើយបង្កើតវិញ្ញាណដែលយើងហៅថា ព្រះយេស៊ូវ។ ក្រោយមកពួកគេបានរួមភេទម្តងទៀត ហើយបានបង្កើតវិញ្ញាណដែលយើងហៅថា សាតាំង។ (ដូច្នេះ ព្រះយេស៊ូវ និងអារក្សសាតាំងជាបងប្អូនគ្នា)។ តាមរបៀបដូចគ្នា ព្រះ និងភរិយាច្រើនរបស់ទ្រង់បានរួមភេទ ដប់ពាន់លានដងទៀត (១០,000,000,000ដង!) ដើម្បីបង្កើតវិញ្ញាណសម្រាប់ដប់ពាន់លាននាក់ ដែលធ្លាប់បានរស់នៅលើភពនេះ! ពួកគេជឿថា ក្រោយមកវិញ្ញាណឈ្មោះព្រះយេស៊ូវ បានកើតជាមនុស្សធម្មតា ដូចអ្នកនិងខ្ញុំ គាត់

មិនមែនជាព្រះទេ តែដោយសារគាត់បានធ្វើតាមក្រឹត្យវិន័យ នោះព្រះវរបិតាបានលើកដំកើងគាត់ដល់ឋានៈជាព្រះមួយ។

**អ្នកដឹកនាំមរមនសំខាន់ៗបានបង្រៀនថា ព្រះវរបិតា បានរួមភេទជាមួយនឹងម៉ារា ដើម្បីបង្កើតរូបកាយរបស់ព្រះយេស៊ូវ។** ពួកគេបានបង្រៀនថា ព្រះវរបិតា (ដែលមានរូបកាយដូចយើង) បានចុះមកផែនដី ហើយធ្វើឲ្យម៉ារាមានផ្ទៃពោះ ដោយរួមភេទជាមួយនាង។ ពួកគេថា ទ្រង់បានធ្វើដូច្នេះ ដើម្បីរៀបចំរូបកាយដែលនឹងទទួលវិញ្ញាណឈ្មោះយេស៊ូវ។ (នេះគឺជាការប្រមាថដ៏អាក្រក់ចំពោះព្រះវរបិតា និងនាងព្រហ្មចារីម៉ារា!)។

សូមស្តាប់ពាក្យសំដីអាក្រក់របស់មេដឹកនាំមរមនផ្ទាល់អំពីរឿងនេះ៖ «ព្រះគ្រីស្ទត្រូវបានបង្កើត តាមរយៈ ព្រះវរបិតាដែលអមតៈ ដោយរបៀបដូចគ្នា ដែលមនុស្សធម្មតាត្រូវបានបង្កើតពីឪពុកធម្មតា» (គោលលទ្ធិ មរមន ១៩៦៦ ទំព័រ ៥៤៧)។ លោក ព្រីកហាំ យ៉ង់ ដែលជានាយកទីពីរនៃសាសនាមរមន បង្រៀនម្តងហើយម្តងទៀតថា ព្រះយេស៊ូវត្រូវចាប់ទំផ្ទៃ ពេលព្រះមានការរួមភេទធម្មតា រវាងព្រះវរបិតា និងនាងម៉ារា៖ «ព្រះវរបិតាចុះមកបង្កើតទ្រង់ ដោយរបៀបដែលមនុស្សធម្មតាធ្វើ...» (*The Complete Discourses of Brigham Young*, vol. 1, p. 321; February 16, 1849, Salt Lake City)។ ម្តងទៀត នេះគឺជាការប្រមាថដ៏អាក្រក់ចំពោះព្រះវរបិតា និងនាងព្រហ្មចារីម៉ារា!

សព្វថ្ងៃនេះពួកមរមន ទទូចថា ជំនឿនេះមិនមែនជាជំនឿផ្លូវការរបស់សាសនាមរមនទេ។ តែមានអ្នកដឹកនាំសំខាន់ៗយ៉ាងតិច៤នាក់ ដែលបានបង្រៀនថា ព្រះបានរួមភេទជាមួយនាងម៉ារា ដូចជា ព្រីកហាំ យ៉ង់ (Brigham Young) ហ៊ីបឺ ឃីមបិល (Heber Kimbal) អ័រសិន ប្រាត (Orson Pratt) ហើយ យ៉ូសែប អែហ្វ ស្មីត (Joseph F. Smith)។ ហើយក្រុមជំនុំមរមនមិនដែលបានបដិសេធ ការបង្រៀន

ប្រមាថនេះទេ។ ពួកមរមនមិនគួរឆ្ងល់ថា ហេតុអ្វីបានជាយើងអាក់អន់ចិត្តនឹងសាសនារបស់ពួកគេឡើយ។

**ពួកមរមនបន្ថែមគម្ពីរថ្មី។** ពួកមរមនអះអាងថា ពួកគេទទួលព្រះគម្ពីរប៊ីប («ឲ្យតែបានបកប្រែយ៉ាងត្រឹមត្រូវ»)។ ប៉ុន្តែពួកគេបន្ថែមបីសៀវភៅទៀត គឺ (១) *គម្ពីរមរមន* (២) *គោលលទ្ធិនិង សេចក្តីសញ្ញា* ហើយ (៣) *មុក្តាដ៏មានតម្លៃ*។ ពួកគេអះអាងថា យ៉ូសែប ស្មីតបានបកប្រែគម្ពីរមរមនពីសៀវភៅមាស ដែលគាត់បានរកឃើញកប់នៅញូវយ៉ក។ សៀវភៅទាំងនេះមានសារៈសំខាន់ចំពោះពួកគេជាងព្រះគម្ពីរ។

**ពួកមរមនបង្រៀនថា វា ជាការល្អដែលអ័ដាមមិនស្តាប់បង្គាប់ព្រះ** ពីព្រោះ នោះគឺជាផ្លូវតែមួយគត់ ដែលមនុស្សជាតិអាចត្រូវបានសង្គ្រោះ (២នីហ្វៃ Nephi ២:២២-២៥)។ នេះគឺជាការប្រមាថ។

**ពួកមរមនបង្រៀនថា ព្រះមានរូបកាយ មិនគ្រាន់តែជាវិញ្ញាណទេ។** គម្ពីរគេថា «ព្រះវរបិតាមានរូបកាយជាសាច់ និងឆ្អឹងដូចមនុស្សដែរ ...» (*គោលលទ្ធិ និង សេចក្តីសញ្ញា* ១៣០:២២)។ ប៉ុន្តែនេះគឺជាការប្រមាថ ព្រោះព្រះយេស៊ូវបានមានបន្ទូលនៅក្នុងយ៉ូហាន ៤:២៤ ថា *«ព្រះជាម្ចាស់ជាវិញ្ញាណ ហើយអស់អ្នកដែលថ្វាយបង្គំទ្រង់ ត្រូវតែថ្វាយបង្គំដោយវិញ្ញាណ និងសេចក្តីពិត»*។

**ពួកមរមនបង្រៀនថាមាន «ព្រះមាតា» ជាច្រើន។** (មើល *Articles of Faith, ប្រការនៃសេចក្តីជំនឿ* ដោយ James Talmage ទំព័រ ៤៤៣)។ ពួកគេជឿថា ព្រះវរបិតា និងព្រះមាតា ជាប្តីប្រពន្ធនឹងគ្នា ដែលបង្កើតកូនខាងវិញ្ញាណជាមួយគ្នា (*គោលលទ្ធិ មរមន* ទំព័រ ៥១៦)។ នេះគឺជាការប្រមាថប្រឆាំងនឹងព្រះពិត។ ព្រះគម្ពីរប៊ីប មិនដែលនិយាយអំពីព្រះមាតាទេ។

**ពួកមរមនបដិសេធ សេចក្តីសង្គ្រោះ ដោយព្រះគុណតាមរយៈសេចក្តីជំនឿតែប៉ុណ្ណោះ។** សូមស្តាប់ពាក្យរបស់ពួកគេផ្ទាល់៖

- «គោលលទ្ធិមួយដែលខុសឆ្គងបំផុត មានប្រភពពីអារក្សសាតាំង... គឺមនុស្សអាចបានសង្គ្រោះ ដោយព្រះគុណពីព្រះអង្គទទេ គឺថាមានតែជំនឿលើព្រះយេស៊ូវតែប៉ុណ្ណោះ ដើម្បីបានសេចក្តីសង្គ្រោះ» (*Miracle of Forgiveness* ដោយអគ្គនាយកមរមន Spencer W. Kimball ទំ. ២០៦)។
- យញ្ញបូជារបស់ព្រះយេស៊ូវមិនអាចសម្អាតយើងពីអំពើបាបមួយចំនួនបានទេ (ដូចជាឃាតកម្ម និងការផិតក្បត់ ម្តងហើយម្តងទៀត) (*Journal of Discourses* ភាគទី៣,១៨៥៦, ទំ.២៤៧)។
- អំពើល្អជាការចាំបាច់សម្រាប់សេចក្តីសង្គ្រោះ (*Articles of Faith* ទំ. ៩២)។
- គ្មានការសង្គ្រោះទេ សម្រាប់អ្នកដែលមិនទទួល យ៉ូសែប ស្មីតជាព្យាការីរបស់ព្រះ (*Doctrines of Salvation* ភាគទី១ ទំ.១៨៨)។
- «យើងដឹងថា ដោយសារព្រះគុណដែលយើងបានសង្គ្រោះ **ក្រោយពីយើងធ្វើអស់សមត្ថភាពយើង**» ( 2 Nephi 25:23)។

## សាសនាមរមន មិនមែនជាគ្រីស្ទសាសនាទេ។

ជំនឿទាំងនេះពិតជាចម្លែកណាស់ ដែលយើងមិនត្រូវហៅសាសនាមរមនថា ជាសាសនាគ្រីស្ទានទេ។ ពួកមរមនមានសិទ្ធិបង្កើតសាសនាថ្មី ដែលខុសប្លែកឆ្ងាយពីសាសនាព្រះគ្រីស្ទ ប៉ុន្តែគេមិនមានសិទ្ធិហៅថា គ្រីស្ទសាសនាទេ។ ហើយគេក៏គ្មានសិទ្ធិ លួចព្រះនាម និងឈ្មោះរបស់គ្រីស្ទសាសនាដូចជា *ព្រះវរបិតា ព្រះរាជបុត្រា ព្រះវិញ្ញាណបរិសុទ្ធ ព្រះយេស៊ូវគ្រីស្ទ ដំណឹងល្អ* ។ល។

## ស្ថាបនិកនៃសាសនាមរមន ក៏បានបរាជ័យចំពោះការសាកល្បងនៃសីលធម៌ និងភាពបរិសុទ្ធ

អស់រយៈពេល៤០ឆ្នាំដំបូងនៃសាសនាមរមន មេដឹកនាំបានបង្រៀនសមាជិកថា ការមានប្រពន្ធច្រើនជាគោលការណ៍សុចរិត និងចាំបាច់។

**ស្ថាបនិកសាសនាមរមន យ៉ូសែប ស្មីត បានយកប្រពន្ធយ៉ាងហោចណាស់២៧នាក់ និងអាចជាង៤០នាក់។** ប្រពន្ធគាត់ខ្លះនៅតែជាប្រពន្ធស្របច្បាប់នឹងប្ដីដើមនៅឡើយ នៅពេលពួកគេរៀបការជាមួយលោកស្មីត! នៅក្នុងគម្ពីរមរមន *Doctrine and Covenants* ផ្នែក១៣២ ព្យាការីសាសនាមរមនបានហៅការមានប្រពន្ធច្រើនថា ជា «គោលលទ្ធិដ៏បរិសុទ្ធ និងសំខាន់បំផុត ដែលធ្លាប់បានសម្ដែងដល់មនុស្សនៅលើផែនដី»។ គាត់ក៏បង្រៀនថា បុរសម្នាក់ត្រូវការភរិយាយ៉ាងហោចណាស់ក៏បីនាក់ដែរ ដើម្បីទទួលបាន «ការលើកតម្កើងពេញលេញ» ក្រោយស្លាប់។ គាត់បានថា ព្រះបានព្រមានរបៀបនេះ៖ «អស់អ្នកណាដែលក្រឹត្យវិន័យនេះបានសម្ដែងដល់ ពួកគេត្រូវតែគោរពប្រតិបត្តិ...ហើយបើមិនគោរពតាមកិច្ចព្រមព្រៀងនេះទេ អ្នកនោះនឹងត្រូវវិនាស។ ពីព្រោះគ្មានអ្នកណាអាចបដិសេធកិច្ចព្រមព្រៀងនេះ ហើយត្រូវបានអនុញ្ញាតឲ្យចូលក្នុងសិរីល្អរបស់ខ្ញុំឡើយ»។ និយាយម្យ៉ាងទៀត មនុស្សដែលបដិសេធគោលការណ៍មានប្រពន្ធច្រើននេះ មិនអាចទទួលសេចក្ដីសង្គ្រោះបានឡើយ។ (https://en.wikipedia.org/wiki/ListofJoseph Smith%27swives)

ភរិយាម្នាក់របស់យ៉ូសែប ស្មីតឈ្មោះ ហេឡែន ម៉ារ គឹមបល (Helen Mar Kimball) មានអាយុត្រឹម១៤ឆ្នាំប៉ុណ្ណោះ នៅពេលយ៉ូសែប ស្មីតបានរៀបការជាមួយនាង! ឪពុករបស់នាងបានសួរនាងថា សុខចិត្តធ្វើជាប្រពន្ធរបស់យ៉ូសែប ស្មីត ឬអត់? ហើយគាត់ព្រម។ ក្រោយមក នាងបានពន្យល់អំពីការសម្រេចរបស់នាងថា

«គាត់[យ៉ូសែប ស្មីត]បាននិយាយមកខ្ញុំថា <បើនាងនឹងបោះជំហាននេះ វាពិតជាធានាបាននូវសេចក្ដីសង្គ្រោះ និងការលើកតម្កើងដ៏អស់កល្បរបស់នាង ព្រមទាំងគ្រួសារនៃឪពុកនាង និងបងប្អូនទាំងអស់របស់នាងផង> ការសន្យានេះធំណាស់ដែលខ្ញុំសុខចិត្តលះបង់ខ្លួនឯង ដើម្បីទិញរង្វាន់ដ៏រុងរឿង»។ https://en.wikipedia.org/wiki/https://en.wikipedia.org/wiki/Mormonism_and_polygamy)

សូមកត់សម្គាល់ពីរបៀបដែលយ៉ូសែប ស្មីត បានប្រើអំណាច និងឥទ្ធិពលរបស់គាត់ ញាក់ក្មេងស្រីនេះឲ្យរៀបការជាមួយគាត់ ដោយសន្យាជួយសង្គ្រោះដល់ឪពុកម្ដាយ និងក្រុមគ្រួសាររបស់នាង។ នេះជាអំពើដ៏អាក្រក់បំផុត។

**អគ្គនាយកទី២នៃសាសនាមរមន ឈ្មោះព្រិកហាំ យ៉ង់ (Brigham Young) មានប្រពន្ធ ៥១នាក់**! (https://en.wikipedia.org/wiki/List_of_Brigham_Young%51s_wives)

នៅឆ្នាំ១៨៩០ តំបន់យូថាហ៍ ដែលប្រជាជនភាគច្រើនកាន់សាសនាមរមន គឺចង់ក្លាយជារដ្ឋមួយនៃសហរដ្ឋអាមេរិក ប៉ុន្តែរដ្ឋាភិបាលសហរដ្ឋអាមេរិក មិនអនុញ្ញាតឲ្យតំបន់យូថាហ៍ ចូលរួមទេ ទាល់តែពួកគេមានច្បាប់ហាមការមានប្រពន្ធច្រើន។ ស្រាប់តែ អ្នកដឹកនាំសាសនាមរមនបានទទួលការសម្ដែងពីព្រះថា ឥឡូវការមានប្រពន្ធច្រើនខុសពីច្បាប់មរមន!

លោកយ៉ូសែប ស្មីត និងព្រិកហាំ យ៉ង់ ជាស្ថាបនិកដ៏ធំពីររូបនៃសាសនាមរមន។ តើយើងអាចជឿទុកចិត្តលើបុរសទាំងនេះដូចម្ដេចបាន ដែលបានចូលរួមក្នុងការយកប្រពន្ធច្រើននេះ ព្រមទាំងបំផ្លាញ ក្រុមគ្រួសារដោយរៀបការជាមួយស្រីនៅមានប្ដីនៅ

ឡើយ? (សូមមើលបញ្ជីពេញលេញនៃភរិយារបស់ យ៉ូសែប ស្មីត និង ព្រិកហាំ យ៉ង់ នៅចុងបញ្ចប់នៃអត្ថបទនេះ)។



**មុខពូថៅ**

បើពួកមរមនមានគោលជំនឿប្រមាថព្រះអ៊ីចឹង តើធ្វើដូចម្ដេចឲ្យគេអាចមានសមាជិកថ្មីបាន? ពួកគេលាក់ជំនឿ និងប្រវត្តិសាស្ត្រអាក្រក់របស់ពួកគេ។

សព្វថ្ងៃនេះពួកមរមន មិនមែនជាអ្នកអួតខ្លួន និងមានប្រពន្ធច្រើនដូចយ៉ូសែប ស្មីត និងព្រិកហាំ យ៉ង់ទេ។ ពួកគេមានចិត្តល្អរាបសា និងគួរសម។ នៅពេលបេសកជនគេជិះកង់មួយគូៗ ពីផ្ទះមួយទៅផ្ទះមួយពួកគេចាប់ផ្ដើមការសន្ទនារបស់គេ ដោយនិយាយអំពីការដែលសាសនាគេ ផ្ដោតលើការមានក្រុមគ្រួសារដ៏រឹងមាំ។ នេះគឺជាការដែលធ្វើឲ្យគេចាប់អារម្មណ៍ ពីព្រោះមនុស្សភាគច្រើនចង់មានគ្រួសាររឹងមាំ និងសន្តិភាព។ ពួកមរមនក៏ចូលចិត្តប្រើឈ្មោះ «ព្រះ» និង«ព្រះយេស៊ូវគ្រីស្ទ» ដើម្បីឲ្យអ្នកស្ដាប់គិតថា សាសនាមរមនគ្រាន់តែជានិកាយមួយនៃគ្រីស្ទសាសនាប៉ុណ្ណោះ។ តែតាមពិតវាជាសាសនាខុសគ្នាទាំងស្រុង ដែលបានលួចយកឈ្មោះទាំងនេះ ចេញពីគ្រីស្ទសាសនាពិត។ ទាំងអស់នេះគឺជាមុខពូថៅដែលងាយស្រួលចូលទៅក្នុងឈើ។

តើខ្នងពូថៅជាអ្វីខ្លះ? តើជំនឿប្រមាថណាខ្លះ ដែលពួកមរមនចង់លាក់ពីយើង? ពួកគេចង់លាក់បាំងជំនឿដែលថា ព្រះធ្លាប់ជាមនុស្សធម្មតា ដែលបានក្លាយជាព្រះ ហើយថា ព្រះរាជបុត្រានៃព្រះ និងសាតាំង គឺជាបងប្អូននឹងគ្នា ហើយថា ព្រះយេស៊ូវគ្រាន់តែជាមនុស្សធម្មតាម្នាក់ ដែលក្រោយមកបានក្លាយជាព្រះដែរ ហើយថា ព្រះ

មានប្រពន្ធច្រើននៅស្ថានសួគ៌ ហើយថាស្ថាបនិកមរមន មានប្រពន្ធរហូតដល់៤០ ឬ ៥០នាក់ (ដែលអ្នកខ្លះនៅតែជាប្រពន្ធរបស់ប្តីដើម)។ បើសិនជាបេសកជនមរមន បានបង្រៀនរឿងប្រមាថទាំងនេះ នៅពេលដំបូង ស្ទើរតែគ្មានអ្នកណាម្នាក់ទទួលយក សាសនានេះទេ។

## របៀបលើកទឹកចិត្តពួកមរមនឲ្យជឿលើព្រះពិត

អ្នកប្រហែលជាមិនអាចបញ្ចុះបញ្ចូលពួកមរមនឲ្យងាកចេញពីសាសនារបស់គេ ដោយប្រាប់គាត់អំពីភរិយាទាំង៤០នាក់របស់យ៉ូសែប ស្មីតបានទេ។ ផ្លូវតែមួយ ដើម្បីនាំពួកមរមន ឲ្យជឿលើព្រះគ្រីស្ទពិត គឺពន្យល់ដំណឹងល្អពិតដល់ពួកគេ ហើយ លើកទឹកចិត្តឲ្យពួកគេអានព្រះគម្ពីរប៊ីបមួយចប់។ មានតែព្រះវិញ្ញាណបរិសុទ្ធដែល ធ្វើការតាមរយៈព្រះបន្ទូលនៃព្រះទេ ដែលអាចនាំពួកគេទៅកាន់សេចក្តីសង្គ្រោះ បាន។ ពួកមរមនភាគច្រើនមិនបានអានព្រះគម្ពីរច្រើនទេ ពីព្រោះក្រុមជំនុំរបស់គេ ធ្វើឲ្យគេសង្ស័យថា គម្ពីរមិនបានបកប្រែរបៀបត្រឹមត្រូវ។

បើពួកគេលើកឡើងពីបញ្ហាព្រះគម្ពីរបកប្រែត្រឹមត្រូវ អ្នកអាចសួរគេថា «តើគម្ពីរ មរមនបានបកប្រែត្រឹមត្រូវទេ? តាមពិតយើងមិនអាចដឹងទេ ពីព្រោះគ្មានឯកសារនៃ គម្ពីរមរមនជាភាសាដើមសោះឡើយ។ ផ្ទុយទៅវិញ ព្រះគម្ពីរប៊ីបយើងមានឯកសារ បុរាណលើសជាង៥០០០ច្បាប់ ជាភាសាហេព្រើរ និងក្រេក ហើយខ្លះចាស់ជាង ២០០០ឆ្នាំហើយ ដូច្នេះយើងអាចដឹងថា គម្ពីរប៊ីបបានបកប្រែត្រឹមត្រូវ ឬអត់។ ពេលអ្នកវិទ្យាសាស្ត្រសិក្សាឯកសារបុរាណទាំងអស់នេះ ឃើញថា ព្រះគម្ពីរប៊ីបបាន បកប្រែតាមរបៀបត្រឹមត្រូវ និងយកចិត្តទុកដាក់បំផុត។

ចូរលើកទឹកចិត្តពួកម៉ាកមរមនឲ្យគិតពិចារណាអំពី ភាពគួរឲ្យទុកចិត្ត នៃប្រវត្តិសាស្ត្រ នៅក្នុងព្រះគម្ពីរប៊ីប។ បុរាណវិទូនៅអ៊ីស្រាអែល និងតំបន់ជុំវិញបានរកឃើញ ទីក្រុង ភូមិ ភ្នំ និងទន្លេ រាប់រយ ដែលបានរៀបរាប់នៅក្នុងព្រះគម្ពីរ។ ដូចគ្នាដែរបុរាណវិទូក៏

បានរកឃើញភ័ស្តុតាងជាច្រើនអំពី ស្តេច និងមនុស្សឯទៀតរាប់សិប ដែលគម្ពីរបានរៀបរាប់។ **ផ្ទុយទៅវិញ បុរាណវិទូមិនបានរកឃើញ ទីតាំងបុរាណណាមួយ ដែលបានរៀបរាប់នៅក្នុងគម្ពីរមរមនឡើយ។** សូម្បីតែអ្នកវិទ្យាសាស្ត្រមរមនក៏បានទទួលស្គាល់ការនេះ៖ «តាមនរវិទ្យា ឈ្មោះ John Clark នៅសាកលវិទ្យាល័យ Brigham Young អ្នកបុរាណវិទ្យាស្ទើរតែទាំងអស់ នៅសាកលវិទ្យាល័យមរមននោះទទួលស្គាល់ថា ការរកឃើញរបស់បុរាណ ដែលទាក់ទងទៅព្រឹត្តិការណ៍នៅក្នុងគម្ពីរមរមន គឺអត់មានទេ»។ (https://www.bethinking.org/mormons/what-to-say-to-mormons/4-mormons-archaeology)

ជាចុងក្រោយកុំភ្លេច២យ៉ូហាន ១:១០-១១៖ *«បើអ្នកណាមកឯអ្នករាល់គ្នា តែមិនបង្រៀនចំពោះសេចក្តីនេះ នោះកុំឲ្យទទួលអ្នកនោះនៅក្នុងផ្ទះឡើយ កុំឲ្យទាំងជំរាបសួរដល់អ្នកនោះផង ដ្បិតបើអ្នកណាជំរាបសួរ នោះក៏តែងមានសេចក្តីប្រកបគ្នាក្នុងការអាក្រក់របស់អ្នកនោះដែរ»*។



***យ៉ូសែប ស្មីត*** *ស្ថាបនិកសាសនាមរមនបានរៀបការជាមួយប្រពន្ធជាង ២៧នាក់ក្នុងរយៈពេលតែ៣ឆ្នាំប៉ុណ្ណោះ! គាត់បានបង្រៀនថា មានព្រះជាច្រើនដែលមួយអង្គៗកាន់កាប់លើភពមួយដាច់ដោយឡែក។ គាត់ក៏បង្រៀនថា ព្រះទាំងអស់ធ្លាប់ជាមនុស្ស ដែលក្រោយមកបានក្លាយជាព្រះ ដោយសារជីវិតស្មោះត្រង់របស់ពួកគេ។*



***ព្រិកហាំ យ៉ង់*** *ជាអគ្គនាយកទីពីរនៃសាសនាមរមន មានប្រពន្ធយ៉ាងហោចណាស់ ៥១នាក់។ ប្រពន្ធមួយចំនួននៅតែជាប្រពន្ធរបស់ប្តីដើម នៅពេលដែលព្រិកហាំ យ៉ង់រៀបការជាមួយពួកគេ ដូច្នេះគាត់មានកំហុសក្នុងការបំផ្លាញក្រុមគ្រួសារទាំងនេះ។ ព្រិកហាំ យ៉ង់ នៅតែទទួលបានការគោរពខ្ពស់ជាងគេពីពួកមរមនទាំងអស់ ហើយសកលវិទ្យាល័យធំជាគេរបស់ពួកគេ បានដាក់ឈ្មោះតាមគាត់ដែរ។*

# ភរិយាជាច្រើនរបស់ស្ថាបនិកសាសនាមរមន

នៅទំព័របន្ទាប់មានបញ្ជីភរិយារាប់សិបនាក់របស់យ៉ូសែប ស្មីត និង ព្រិកហាំ យ៉ង់។ យើងក៏រាយបញ្ជីអាយុរបស់ប្រពន្ធនៅពេលរៀបការ និង ឆ្នាំនៃអាពាហ៍ពិពាហ៍របស់ពួកគេ។ សូមសម្គាល់ថា **ភរិយាប្រាំបួននាក់របស់លោកស្មីត នៅតែជាប្រពន្ធស្របច្បាប់របស់ប្តីដើម នៅពេលពួកគេរៀបការជាមួយលោកស្មីត**។ សូមកត់សម្គាល់ផងដែរថា នៅឆ្នាំ១៨៤២ លោកស្មីតបានរៀបការជាមួយស្រ្តី១៣នាក់ក្នុងមួយឆ្នាំ ហើយនៅឆ្នាំ១៨៤៣ គាត់បានរៀបការជាមួយនារី ២១នាក់ ក្នុងមួយឆ្នាំ គឺស្ទើរតែរៀបការថ្មី២ដងក្នុងមួយខែ! នេះគឺជាចរិតខូចរបស់បុរសដែលបានបង្កើតសាសនាមរមន។

អ្នកស្នងដំណែងលោកស្មីត គឺព្រិកហាំ យ៉ង់ រឹតតែអាក្រក់ជាងនេះទៅទៀត។ គាត់មានប្រពន្ធជាង៥០នាក់។ ប្រពន្ធគាត់ខ្លះ**នៅតែជាប្រពន្ធស្របច្បាប់ជាមួយប្តីដើម**! នេះមានន័យថា គាត់បានបំផ្លាញក្រុមគ្រួសារទាំងនោះ ដើម្បីបានប្រពន្ធថ្មី។ សូមកត់សម្គាល់ថា នៅឆ្នាំ១៨៤៦ ព្រិកហាំ យ៉ង់បានរៀបការជាមួយប្រពន្ធថ្មី ស្ទើរតែរាល់ពីរសប្តាហ៍ម្តង។ នេះគឺជាអាកប្បកិរិយាដែលខូចបំផុត។ នៅថ្ងៃទី២៨ខែមករាឆ្នាំ១៨៤៦ លោកយ៉ង់ បានរៀបការជាមួយនាង ចេមមីម៉ាអែនចែល (Jemima Angell) និង**ម្តាយរបស់នាងនៅថ្ងៃតែមួយ**! គឺអាក្រក់ក្រៃលែង គួរឲ្យខ្ពើមណាស់។ លោកយ៉ូសែប ស្មីត និងព្រិកហាំ យ៉ង់ មានប្រពន្ធដែលមានអាយុតែ ១៤,១៥ និង១៦ ឆ្នាំ។ សាសនាមរមនបង្រៀនថា ផ្លូវមួយដែលយើងសង្គ្រោះខ្លួនយើង គឺតាមរយៈអាពាហ៍ពិពាហ៍ និងការមានកូន ប៉ុន្តែបុរសអាក្រក់ទាំងពីរនាក់នេះ បានយកប្រពន្ធចេញពីអ្នកដទៃ។

ដើម្បីការពារលោកស្មីត និងលោកយ៉ង់ ពួកមរមនចូលចិត្តចង្អុលបង្ហាញពីស្តេចសាឡូម៉ូននៅក្នុងព្រះគម្ពីរដែលមានប្រពន្ធច្រើនណាស់។ ពិតមែន តែការនេះច្បាស់ជាប្រឆាំងទៅនឹងព្រះហឫទ័យរបស់ព្រះ ដូចមានចែងនៅក្នុងចោទិយកថា ១៧:១៤-២០។ មួយទៀតស្តេចសាឡូម៉ូនបានស្ថិតនៅក្រោមការជំនុំជម្រះរបស់ព្រះដោយសារបាបនេះ ប្រពន្ធជាច្រើនរបស់ស្តេចសាឡូម៉ូន ក៏បាននាំទ្រង់ចេញពីព្រះ។ ប៉ុន្តែសាឡូម៉ូនមិនដែលរៀបការជាមួយស្ត្រីដែលមានប្តីហើយ ដូចជាយ៉ូសែប ស្មីត និង ព្រិកហាំ យ៉ង់ទេ (សូមអាន ១ពង្សាវតារក្សត្រ ១១:៤)។

**JOSEPH SMITH'S WIVES**

| NAME and AGE | YEAR MARRIED |
|---|---|
| Loiusa Beaman 26 | 1841 |
| Zina Huntington 20** | 1841 |
| P. Huntington 31** | 1841 |
| Agnes Coolbrith 30** | 1842 |
| Lucinda Pendleton 40 | 1842 |
| Mary Rollins 23** | 1842 |
| Sylvia Sessions 23** | 1842 |
| Patty Bartlett 47** | 1842 |
| Sarah Kingsley 53** | 1842 |
| Elizabeth Davis 50 | 1842 |
| Marinda Johnson 26 | 1842 |
| Delcena Johnson 35 | 1842 |
| Eliza Snow 38 | 1842 |
| Sarah Rapson | 1842 |
| Sarah Ann Whitney 17 | 1842 |
| Martha McBride 37 | 1842 |
| Ruth Vose 35** | 1843 |
| Flora Woodworth 16 | 1843 |
| Emily Partridge 19 | 1843 |
| Eliza Partridge 22 | 1843 |
| Almera Johnson 29 | 1843 |
| Lucy Walker 17 | 1843 |
| Sarah Lawrence 16 | 1843 |
| Maria Lawrence 19 | 1843 |
| Helen Mar Kimball 14 | 1843 |
| Elvira Cowles 29** | 1843 |
| Rhoda Ricahrds 58 | 1843 |
| Hannah Ells 30 | 1843 |
| Mary Ann Frost 34 | 1843 |
| Olive Frost 27 | 1843 |
| Nancy Winchester 14 | 1843 |
| Desdemona Fullmer 33 | 1843 |
| Melissa Lott 19 | 1843 |
| Sarah Scott | 1843 |
| Phebe Watrous 38 | 1843 |
| Mary Huston | 1843 |
| Fanny Young 55 | 1843 |

**These women were still married to their husbands when they married Joseph Smith. This was against the law.

References: https://en.wikipedia.org/wiki/List_of_Joseph_Smith%27s_wives

**ស្រីទាំង៩នេះនៅតែជាប្រពន្ធរបស់ប្ដីដំបូងរបស់ពួកគេនៅពេលដែលលោក យ៉ង់ បានយកពួកគេធ្វើជាប្រពន្ធរបស់គាត់។ នេះគឺជាឧក្រិដ្ឋកម្ម។

**BRIGHAM YOUNG'S WIVES**

| NAME and AGE | YEAR MARRIED |
|---|---|
| Miriam Angeline Works 18 | 1824 |
| Mary Ann Angell 27 | 1834 |
| Lucy Ann Decker 20 | 1842 |
| Augusta Adams 40** | 1843 |
| Harriet Elizabeth Cook 19 | 1843 |
| Clarissa Decker 15 | 1844 |
| Emily Partridge 20 | 1844 |
| Clarissa Ross 30 | 1844 |
| Louisa Beaman 29 | 1844 |
| Eliza Snow 40 | 1844 |
| Elizabeth Fairchild 16 | 1844 |
| Clarissa Blake 48 | 1844 |
| Rebecca Holman 20 | 1844 |
| Diana Chase 17 | 1844 |
| Susanne Snively 29 | 1844 |
| Olive Grey Frost 28 | 1844 |
| Mary Ann Clark 28 | 1845 |
| Margaret Pierce 22 | 1845 |
| Mary Pierce 25 | 1845 |
| Emmeline Free 18 | 1845 |
| Mary E. Rollins 26 | 1845 |
| Margaret Alley 20 | 1846 |
| Olive Andrews 27 | 1846 |
| Emily Haws 22 | 1846 |
| Martha Bowker 23 | 1846 |
| Ellen Rockwood 16 | 1846 |
| Jemima Angell 41* (daughter of Phebe) | 1846 |
| Phebe Morton 59* (Young's Mother-in-law) | 1846 |
| Abigail Marks 69 (Young's Mother-in-law) | 1846 |
| Cynthia Porter 62 | 1846 |
| Mary Eliza Nelson 33 | 1846 |
| Rhoda Richards 61 | 1846 |
| Zina D. Huntington 25** | 1846 |
| Amy Cecilia Cooper 41 | 1846 |
| Mary Ellen de la Montaigne 42 | 1846 |
| Julia Foster 36 | 1846 |
| Abigail Harback 55 | 1846 |
| Mary Ann Turley 18 | 1846 |
| Naamah Carter 24 | 1846 |
| Nancy Cressy 65 | 1846 |
| Jane Terry 26 | 1846 |
| Lucy Bigelow 16 | 1847 |
| Mary Jane Begelow 19 | 1847 |
| Sarah Malin 43 | 1848 |
| Eliza Burgess 25 | 1848 |
| Mary Oldfield 59 | 1852 |
| Eliza Babcock 24 | 1853 |
| Catherine Reese 51 | 1855 |
| Harriet Barney 25 | 1856 |
| Amelia Folsom 24 | 1863 |
| Mary Van Cott 23 | 1868 |
| Ann Eliza Webb 24 | 1868 |
| Elizabeth Jones 55 | 1869 |
| Lydia Farnsworth 61** | 1870 |
| Hannah Tapfield 65 | 1872 |

*លោកយ៉ង់បានរៀបការជាមួយស្រីម្នាក់និងម្ដាយរបស់នាងនៅថ្ងៃតែមួយ។

**ស្រីទាំង៣នេះនៅតែជាប្រពន្ធរបស់ប្ដីដំបូងរបស់ពួកគេនៅពេលដែលលោក យ៉ង់ បានយកពួកគេធ្វើជាប្រពន្ធរបស់គាត់។ នេះគឺជាឧក្រិដ្ឋកម្ម។

References: https://en.wikipedia.org/wiki/List_of_Brigham_Young%27s_wives

# ប៉ាក អុក ស៊ូ និង ក្រុមបេសកកម្មដំណឹងល្អ

## Pak Ock Soo and Good News Mission

## ការជួបជុំប្រកបអ្នកដឹកនាំគ្រីស្ទបរិស័ទ Christian Leaders Fellowship

## ការជួបជុំយុវជនអន្តរជាតិ International Youth Fellowship

## សេអ៊ូល កូរ៉េខាងត្បូង

ក្រុមបេសកកម្មដំណឹងល្អ ហើយអ្នកដឹកនាំ លោក ប៉ាក អុក ស៊ូ ខុសពីក្រុមខុសឆ្គង ដែលយើងសិក្សាកន្លងមក ពីព្រោះក្រុមនេះកាន់តាមគោលជំនឿត្រឹមត្រូវជាច្រើនដែរ ទាំង ព្រះត្រៃឯក និង ការសុគត និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ សម្រាប់អំពើបាបរបស់យើង។ មនុស្សជាច្រើនដែលចូលក្រុមនេះ ជាគ្រីស្ទបរិស័ទពិតប្រាកដ។ ក៏ប៉ុន្តែក្រុមប្រឹក្សាគ្រីស្ទបរិស័ទទាំងអស់នៅប្រទេសកូរ៉េ បានរួមគ្នាប្រកាសសេចក្តីថ្លែងការថា ក្រុមបេសកកម្មដំណឹងល្អ គឺជាក្រុមខុសឆ្គងមួយ។ ដោយសារមូលហេតុ ៤ យ៉ាង៖

១) ពួកគេត្រួតត្រាសិទ្ធិលើសមាជិករបស់ពួកគេទាំងស្រុង
២) ពួកគេអះអាងថា ពួកគេ ជាក្រុមជំនុំពិតតែមួយគត់
៣) ពួកគេបានបន្ថែម គោលជំនឿច្របូកច្របល់អំពីអំពើបាប និងសេចក្តីសង្គ្រោះ
៤) ពួកគេព្យាយាមបំបែក ឬលួចក្រុមជំនុំផ្សេងៗទៀត

ការនេះរំលឹកយើងថា ក្រុមដែលមានគោលជំនឿត្រឹមត្រូវអាចក្លាយជាក្រុមខុសឆ្គង ដោយការលើកដំកើងអ្នកដឹកនាំរបស់គេ ដល់ឋានៈខ្ពស់ពេក។ ការត្រួតត្រាសមាជិក ការបង្កឲ្យមានការបាក់បែកគ្នាក្នុងក្រុមជំនុំឯទៀត ការលួចចៀមរបស់គេ ហើយការអះអាងថា ជាក្រុមជំនុំពិតតែមួយ។

## ប្រវត្តិ

នៅទសវត្សឆ្នាំ ១៩៦០ បុរសម្នាក់នៅប្រទេសកូរ៉េឈ្មោះ ប៉ាក អុក ស៊ូ (Park Ock Soo) បានទទួលការបណ្ដុះបណ្ដាលពីបេសកជនជនជាតិអាមេរិកម្នាក់ឈ្មោះ ឌិក យ៉ក (Dick York)។ ក្រោយមក លោក ប៉ាក អុក ស៊ូ បានបង្កើតនិកាយរបស់ខ្លួនឯង ដែលគេស្គាល់នៅប្រទេសកូរេថា «ក្រុមសេចក្ដីសង្គ្រោះ» ពីព្រោះមធ្យោបាយរបស់ពួកគេ គឺជ្រៀតចូលក្នុងក្រុមជំនុំ បញ្ចុះបញ្ចូលគ្រីស្ទបរិស័ទថា ពួកគេមិនទាន់បានសង្គ្រោះពិតទេ។ ជំរុញឲ្យគេទទួលសេចក្ដីសង្គ្រោះពិត ហើយចូលក្រុមជំនុំបេសកកម្មដំណឹងល្អរបស់ពួកគេវិញ។

ក្រោយមក លោក ខ្វោន ស៊ីនចាន់ (Kwon Shin-Chan) និងអ្នកស្នងតំណែងរបស់គាត់គឺ យូ ប្យុង-អឿន (Yoo Byung-eun) បានបែកពីបេសកកម្មដំណឹងល្អ ហើយបង្កើតក្រុមមួយឈ្មោះថា ពួកជំនុំដំណឹងល្អបាបទីស្ទកូរ៉េ។ ដែលមានសេចក្ដីបង្រៀនប្រហាក់ប្រហែលនឹង លោក ប៉ាក អុក ស៊ូដែរ។ នៅឆ្នាំ ១៩៨៣ លោក យូ ប្យុង-អឿន ត្រូវបានគេចោទប្រកាន់ពីបទបង្វែរមូលនិធិក្រុមជំនុំទៅសម្រាប់ជាការធ្វើជំនួញវិញ។ ពេលនោះលោក លី យ៉ូហាន (លី បុក-ជិល) បានយកសមាជិកប្រមាណជាង ៥០០០នាក់ ហើយបានបង្កើតក្រុមមួយទៀតដែលមានឈ្មោះថា បេសកកម្មព្រះបន្ទូលនៃជីវិត។ ក្រុមប្រឹក្សាគ្រីស្ទបរិស័ទទាំងអស់នៅប្រទេសកូរ៉េចាត់ទុកថា ក្រុម «និកាយសង្គ្រោះ» ទាំងនេះ គឺជាក្រុមខុសឆ្គង និងជាក្រុមបំបាក់បំបែក។

## ជំនឿ

ទោះបីបេសកកម្មដំណឹងល្អ មានគោលជំនឿល្អល្មមក្តី មានបញ្ហាធំៗ ៤៖

**ក្រុមនេះបង្រៀនថា សេចក្តីសង្គ្រោះមានតែតាមរយៈក្រុមជំនុំរបស់ពួកគេតែមួយប៉ុណ្ណោះ។** នៅពេលក្រុមណាមួយអះអាងថា មានតែក្រុមជំនុំរបស់ខ្លួនទេ ដែលពិតនោះយើងដឹងភ្លាមថា គឺជាក្រុមខុសឆ្គងហើយ។

**ក្រុមនេះបង្រៀនថា ការប្រែចិត្តពីអំពើបាបទាំងឡាយ និងការជឿទុកចិត្តលើព្រះគ្រីស្ទ មិនចាំបាច់សំរាប់ការសង្គ្រោះនោះទេ។** ពួកគេអះអាងថា ដើម្បីឲ្យបានសង្គ្រោះ គឺត្រូវការតែ **ការយល់**ថា ព្រះគ្រីស្ទបានដកយកអំពើបាបរបស់អ្នកនៅលើឈើឆ្កាងរួចហើយ។ ក៏ប៉ុន្តែ **ការយល់**ពីអ្វីដែលព្រះគ្រីស្ទបានធ្វើនៅលើឈើឆ្កាង មិនដូចគ្នានឹង**ការកែប្រែចិត្ត និង ការជឿទុកចិត្ត**លើការដែលព្រះគ្រីស្ទបានធ្វើនៅលើឈើឆ្កាងនោះទេ។ បាទ ការយល់អំពីដំណឹងល្អជាការសំខាន់មែន នៅក្នុងគ្រីស្ទសាសនាតែ *«បើឥតមានសេចក្តីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ»* (ហេព្រើរ ១១:៦)។ គ្មានសេចក្តីសង្គ្រោះឡើយ បើគ្មានការកែប្រែចិត្តពីអំពើបាប និងជំនឿលើព្រះគ្រីស្ទ។

**ក្រុមនេះបង្រៀនថា គ្រីស្ទបរិស័ទមិនត្រូវសារភាពលន់តួអំពើបាបទាំងឡាយរបស់ខ្លួនចំពោះព្រះឡើយ។** ពួកគេបង្រៀនថា ការសារភាពលន់តួអំពើបាប គឺជាភ័ស្តុតាងដែលបង្ហាញថា អ្នកនោះមិនបានជឿថា ព្រះយេស៊ូវបានដកអំពើបាបរបស់គាត់ចេញហើយនោះទេ។ ប្រសិនបើអ្នកព្ធនរណាបង្រៀនថា យើងមិនត្រូវសារភាពអំពើបាបរបស់យើងចំពោះព្រះ អ្នកដឹងភ្លាមថា គាត់កំពុងបង្រៀន ការខុសឆ្គងពីបេសកកម្មដំណឹងល្អ ឬជាក្រុមខុសឆ្គងស្រដៀងហើយ។

**ក្រុមនេះបង្រៀនថា លោកយ៉ូហានបាទីស្ទ បានដាក់អំពើបាបទាំងអស់របស់ពិភពលោកទៅលើអង្គព្រះយេស៊ូវ នៅពេលដែលទ្រង់ទទួលបុណ្យជ្រមុជទឹក។** ក៏

ប៉ុន្តែព្រះគម្ពីរប្រាប់ថា ព្រះយេស៊ូវបានផ្ទុកអំពើបាបរបស់យើងនៅក្នុងព្រះកាយរបស់ព្រះអង្គ**នៅលើឈើឆ្កាង** *«ទ្រង់បានផ្ទុកអំពើបាបរបស់យើងរាល់គ្នា នៅលើរូបអង្គទ្រង់ ជាប់លើឈើឆ្កាង...»* (១ពេត្រុស ២:២៤)។

## មធ្យោបាយ

មធ្យោបាយរបស់ «ក្រុមសេចក្តីសង្គ្រោះ» មកពីប្រទេសកូរ៉េ ព្យាយាមឲ្យគ្រីស្ទបរិស័ទសង្ស័យពីសេចក្តីសង្គ្រោះរបស់ខ្លួន។ ដំបូងពួកគេសួរថា **«តើអ្នកធ្លាប់បានសារភាពអំពើបាបរបស់អ្នកចំពោះព្រះដែរឬទេ?»** ប្រសិនបើអ្នកឆ្លើយថា ធ្លាប់។ នោះពួកគេនឹងនិយាយថា «បើអ៊ីចឹង អ្នកមិនមែនជាគ្រីស្ទបរិស័ទពិតទេ ពីព្រោះការដែលអ្នកសារភាពលន់តួអំពើបាបជាភ័ស្តុតាងថា អ្នកមិនជឿថា ព្រះយេស៊ូវបានដកអំពើបាបរបស់អ្នករួចហើយនោះទេ» តាមរបៀបនេះ ពួកគេ នាំឲ្យគ្រីស្ទបរិស័ទសង្ស័យ ពីសេចក្តីសង្គ្រោះ ហើយទាក់ទាញគ្រីស្ទបរិស័ទឲ្យចូលក្នុងក្រុមខុសឆ្គងរបស់ពួកគេ។ តាមពិតព្រះគម្ពីរបង្រៀនថា ការលន់តួបាបរាល់ថ្ងៃ ជាភ័ស្តុតាងមួយ ដែលយើងពិតជាកូនរបស់ព្រះ ពីព្រោះយើងធ្វើតាមព្រះយេស៊ូវ ដែលបានបង្រៀនសិស្សឲ្យលន់តួរាល់ថ្ងៃ (ម៉ាថាយ ៦:១១-១២; ១យ៉ូហាន ១:៩)។

ពេលខ្លះទៀត គេនឹងសួរទៅកាន់គ្រីស្ទបរិស័ទថា **«តើអ្នកជាអ្នកមានបាប ឬជាអ្នកសុចរិត?»** ពិតណាស់ សំណួរនេះ មិនងាយស្រួលឆ្លើយដោយពាក្យតែមួយមាត់នោះទេ។ យើងទាំងអស់គ្នាដែលជាគ្រីស្ទបរិស័ទដឹងហើយថា ព្រះបានរាប់យើងជាសុចរិតពេញលេញភ្លាម តាំងពីយើងបានជឿលើព្រះយេស៊ូវ ដោយសារព្រះលោហិតរបស់ទ្រង់។ ប៉ុន្តែយើងក៏ដឹងថា ចិត្តរបស់យើងមិនទាន់ល្អឥតខ្ចោះទេ ហើយយើងក៏ធ្វើបាបរាល់ថ្ងៃដែរ ជាពិសេសអំពើបាបដ៏ធំបំផុត គឺការមិនស្រឡាញ់ព្រះឲ្យអស់ពីចិត្ត អស់ពីព្រលឹង អស់ពីគំនិត និងអស់ពីកម្លាំង។ ដូច្នេះ តើយើងនឹងឆ្លើយតបយ៉ាងដូចម្តេច នៅពេលគេសួរយើងថា «តើអ្នកជាអ្នកមានបាប ឬជាអ្នកសុចរិត?»

ប្រសិនបើយើងឆ្លើយថា យើងនៅតែធ្វើបាបរាល់ថ្ងៃ នោះមនុស្សពីក្រុមបេសកកម្មដំណឹងល្អ នឹងនិយាយថា «យើញទេ អ្នកមិនទាន់ជាគ្រីស្ទបរិស័ទពិតទេ។ អ្នកត្រូវតែក្លាយជាគ្រីស្ទបរិស័ទពិត ហើយចូលក្រុមយើង»។ ច្បាស់ណាស់ ប៉ាក អុក ស៊ូ និងក្រុមរបស់គាត់ មិនយល់ពីភាពខុសគ្នារវាង ស្ថានភាពរបស់គ្រីស្ទបរិស័ទចំពោះព្រះ គឺជាមនុស្សសុចរិតទាំងស្រុង និងជីវិតប្រចាំថ្ងៃរបស់គ្រីស្ទបរិស័ទ ជាមនុស្សដែលនៅតែជំពប់ដួល ហើយត្រូវលន់តួបាបចំពោះព្រះវរបិតារបស់យើងរាល់ថ្ងៃនោះទេ។ ការលន់តួបាបប្រចាំថ្ងៃចំពោះ អ័ប្បា របស់យើង គឺជាអំណោយដ៏ធំបំផុតមួយ ដែលព្រះបានប្រទានមកយើង តែ ប៉ាក អុក ស៊ូ ចង់ដកយកអំណោយនេះចេញពីយើង។

មធ្យោបាយទីបី គឺគេសួរគ្រីស្ទបរិស័ទថា «**តើអ្នកកើតជាថ្មីនៅថ្ងៃខែឆ្នាំណា**?» ប្រសិនបើអ្នកមិនដឹង នោះគេនឹងប្រាប់អ្នកថា អ្នកមិនទាន់បានកើតជាថ្មីទេ។ ពួកគេនិយាយថា ប្រសិនបើអ្នកដឹងថ្ងៃខែឆ្នាំកំណើតខាងសាច់ឈាមរបស់អ្នក នោះអ្នកក៏ត្រូវដឹងពីថ្ងៃកំណើតខាងវិញ្ញាណរបស់អ្នកដែរ។ តាមរយៈរបៀបនេះ ពួកគេបង្កើតឲ្យមានការសង្ស័យនៅក្នុងចិត្តរបស់គ្រីស្ទបរិស័ទ។ តាមពិត គ្មានបទគម្ពីរណាដែលប្រាប់យើងថា យើងត្រូវតែដឹងពីថ្ងៃនៃការសង្គ្រោះរបស់យើង ដើម្បីឲ្យបានសេចក្តីសង្គ្រោះពិតប្រាកដនោះទេ។ ការនេះជាការបន្ថែមការប្រព្រឹត្តទៅក្នុងសេចក្តីសង្គ្រោះ។

## ក្រុមនេះបរាជ័យការសាកល្បងទាំងនេះ៖

- **ក្រុមនេះបរាជ័យសាកល្បងនៃសេចក្តីសង្គ្រោះដោយព្រះគុណ តាមរយៈជំនឿលើព្រះគ្រីស្ទតែប៉ុណ្ណោះ។** ក្រុមនៃពួកបេសកកម្មដំណឹងល្អទាំងអស់មកពីប្រទេសកូរ៉េ បានអះអាងថា សេចក្តីសង្គ្រោះអាចមានបានតែតាមរយៈក្រុមជំនុំរបស់ពួកគេតែមួយប៉ុណ្ណោះ ហើយក្រុមជំនុំផ្សេងៗទៀត គឺខុសទាំងអស់! ពួកគេក៏អះអាងថា ការកែប្រែចិត្តពីអំពើបាប និងការជឿទុកចិត្ត

លើព្រះគ្រីស្ទ មិនចាំបាច់មាន ដើម្បីបានសេចក្តីសង្គ្រោះទេ។ មានតែគ្រូខុសឆ្គងទេដែលបង្រៀនថា មិនបាច់កែប្រែចិត្តដើម្បីបានសង្គ្រោះ។ តើពួកសាវក និងព្រះយេស៊ូវបានបង្រៀនដូចម្តេចអំពីការកែប្រែចិត្ត? (លូកា ១៣:៣, ២៤:៤៦-៤៧; កិច្ចការ ២:៣៨, ១៧:៣០, ២០:២១; ១ថែស្សាឡូនិច ១:៩)

- **ក្រុមនេះបរាជ័យការសាកល្បងនៃភាពជាម្ចាស់នៃព្រះយេស៊ូវគ្រីស្ទ។** ព្រះយេស៊ូវគ្រីស្ទ ជាម្ចាស់ពិតរបស់គ្រីស្ទបរិស័ទទាំងអស់។ ប៉ុន្តែ ក្រុមនេះទាមទារឲ្យគ្រីស្ទបរិស័ទចុះចូលទាំងស្រុង ចំពោះគំនិត ប៉ាក អុក ស៊ូ និងអ្នកដឹកនាំដទៃទៀតរបស់ក្រុមនេះ។ គាត់ហាមមិនឲ្យសមាជិក ទុកចិត្តលើគំនិតរបស់ខ្លួនឡើយ ពីព្រោះគំនិតរបស់ខ្លួនមកពីសាតាំង ផ្ទុយទៅវិញ គាត់ប្រាប់សមាជិកឲ្យស្តាប់ គំនិត និងពាក្យសំដីរបស់អ្នកដឹកនាំបេសកកម្មដំណឹងល្អ។ ក៏ប៉ុន្តែ ហេតុអ្វីដែលយើងគួរជឿជាក់លើគំនិតរបស់ ប៉ាក អុក ស៊ូ?! ធ្វើដូចម្តេចឲ្យយើងដឹងថា គំនិតរបស់ ប៉ាក អុក ស៊ូ មកពីព្រះ មិនមែនមកពីសាតាំង? របៀបមួយដែលយើងអាចដឹងថា ក្រុមនេះគឺជាក្រុមខុសឆ្គង គឺថា អ្នកដឹកនាំរបស់គេ មានការត្រួតត្រាទាំងស្រុងលើសមាជិករបស់ពួកគេ។

- **ក្រុមនេះបរាជ័យការសាកល្បងនៃការបង្រៀនត្រឹមត្រូវ អំពីអំពើបាបនៅក្នុងជីវិតរបស់គ្រីស្ទបរិស័ទ។** លោក ប៉ាក អុក ស៊ូ និយាយថា យើងមិនគួរលន់តួសារភាពអំពើបាបទាំងឡាយរបស់យើងទេ ពីព្រោះតាមពិតយើងមានបាបតែមួយគត់។ គាត់ថា បាបតែមួយគត់របស់យើងគឺ បាបដើមដែលអ័ដាមបានប្រព្រឹត្ត ហើយព្រះបានអត់ទោសបាបមួយនោះរួចហើយតាមរយៈព្រះគ្រីស្ទ។ ដូច្នេះបើគ្រីស្ទបរិស័ទនៅតែលន់តួសារភាពបាប

ទាំងឡាយរបស់គាត់រាល់ថ្ងៃ នោះគាត់បង្ហាញភ័ស្តុតាងថា គាត់មិនជឿថា ព្រះបានដកបាបរបស់គាត់ចេញហើយទេ។

បើយើងសួរលោក ប៉ាក អំពីបាបទាំងឡាយដែលគ្រីស្ទបរិស័ទប្រព្រឹត្តរាល់ថ្ងៃ គាត់ឆ្លើយថា ការនោះមិនមែនជាបាបទេ គ្រាន់តែជាឧក្រិដ្ឋកម្មតែប៉ុណ្ណោះ។ គាត់ថា «ប្រហែលអ្នកបាន លួច កុហក និង សម្លាប់គេ ប៉ុន្តែ ការនោះ មិនមែនបាបទេ គ្រាន់តែជាឧក្រិដ្ឋកម្មប៉ុណ្ណោះ» (Pak Ock Soo, *The Secret of Forgiveness and Being Born Again*, p. 37)។ ថែមពីនេះទៀត លោក ប៉ាក ព្រមទាំងបានកែបទគម្ពីរឲ្យត្រូវនឹងការបង្រៀនថ្មីនេះរបស់គាត់។ នៅយ៉ូហាន ៨:១១ ព្រះយេស៊ូវបានប្រាប់ស្ត្រីសំផឹងថា *«ខ្ញុំក៏មិនកាត់ទោសនាងដែរ អញ្ជើញទៅចុះ តែ**កុំធ្វើបាបទៀតឡើយ**»*។ ប៉ុន្តែ ប៉ាក អុក ស៊ូ ប្តូរព្រះបន្ទូលរបស់ព្រះយេស៊ូវ ដោយនិយាយថា «ខ្ញុំក៏មិនកាត់ទោសនាងដែរ។ **នាងគ្មានបាបទេ**»។

បើគ្មានអំពើបាបក្នុងជីវិតប្រចាំថ្ងៃរបស់គ្រីស្ទបរិស័ទ ហេតុអ្វីបានជាព្រះយេស៊ូវបាននាំឲ្យសិស្សរបស់ទ្រង់ លន់តួសារភាពអំពើបាបរាល់តែថ្ងៃ ទ្រង់មានបន្ទូលថា *«**កាលណាអ្នករាល់គ្នាអធិស្ឋាន នោះត្រូវថា** ៖... សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការ មកជារាល់ថ្ងៃ សូមអត់ទោសបាប [ពហុវចនៈ] យើងខ្ញុំ ដ្បិតយើងខ្ញុំក៏អត់ទោស ដល់អស់អ្នកដែលធ្វើខុសនឹងយើងខ្ញុំដែរ »* (លូកា ១១:២-៤)។ ហើយនៅ១យ៉ូហាន ១:៩ សាវកយ៉ូហាននិយាយថា*«បើយើងលន់តួបាប [ពហុវចនៈ] វិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង...»*។ នៅ១យ៉ូហាន ១:៩ ការលន់តួសារភាពអំពើបាបទាំងឡាយរបស់យើង ជាភ័ស្តុតាងថា យើងជាគ្រីស្ទបរិស័ទពិត ប៉ុន្តែ ប៉ាក អុក ស៊ូ

បង្រៀនថា ការលន់តួបាប ជាភ័ស្តុតាងថា យើងអត់ទាន់បានទទួលសេចក្តីសង្គ្រោះទេ។ តើយើងត្រូវស្តាប់ព្រះយេស៊ូវ និងសាវករបស់ទ្រង់ ឬប៉ាក អុក ស៊ូ? ម្យ៉ាងទៀតនៅ ១យ៉ូហាន ១:៨ សាវកយ៉ូហានបង្រៀនថា *«បើសិនជាយើងថា យើងគ្មានបាបសោះ នោះឈ្មោះថាយើងបញ្ឆោតដល់ខ្លួន ហើយសេចក្តីពិតមិនស្ថិតនៅក្នុងយើងទេ»*។ តែ ប៉ាក អុក ស៊ូ ថាជាការត្រឹមត្រូវដែលថា «យើងគ្មានបាបសោះ»។ បើអ៊ីចឹង លោក ប៉ាក អុក ស៊ូ កំពុងបញ្ឆោតដល់ខ្លួន ហើយសេចក្តីពិតមិនស្ថិតនៅក្នុងគាត់ទេ។

- **ក្រុមនេះបរាជ័យការសាកល្បងនៃព្រះគម្ពីរ៖** ពេលខ្លះអ្នកដឹកនាំក្រុមបេសកកម្មដំណឹងល្អ ត្រូវបានគេចោទប្រកាន់ថា បានដាក់សម្ពាធទៅលើប្តី ឬប្រពន្ធដែលជឿ ឲ្យត្រូវតែលែងលះប្តី ឬ ប្រពន្ធដែលមិនជឿ ដើម្បីកុំឲ្យពួកគេ «ទឹមនឹមស្រៀក»។ នេះផ្ទុយពីសេចក្តីបង្រៀនច្បាស់លាស់របស់សាវកប៉ុលនៅក្នុង ១កូរិនថូស ៧:១២-១៤ ថា អ្នកជឿម្នាក់ៗ គួរតែនៅជាមួយប្តី ឬប្រពន្ធដែលមិនជឿ ប្រសិនបើគាត់ព្រមនៅជាមួយ។

លោក ឌីក យ៉ក ដែលគាត់បានចំណាយពេលយ៉ាងច្រើន ក្នុងការណែនាំលោក ប៉ាក អុក ស៊ូ នៅប្រទេសកូរ៉េ កាលពីទសវត្សរ៍ឆ្នាំ១៩៦០ បាននិយាយថ្មីៗនេះថា «សរុបទៅ បេសកកម្មដំណឹងល្អ គឺជាក្រុមខុសឆ្គង»។ គាត់បានប្រាប់ថា ប៉ាក អុក ស៊ូ បានតាំងខ្លួនជាសាវកសម្រាប់សម័យកាលនេះ ហើយគាត់មានសិទ្ធិអំណាចពេញលេញលើអស់អ្នកដែលនៅក្រោមបង្គាប់គាត់។ ក្រុមនេះក៏ជឿជាក់ថា ពួកគេគឺជាពួកជំនុំពិតតែមួយគត់។ លោក ឌីក យ៉ក មានប្រសាសន៍ថា «គោលលទ្ធិរបស់ពួកគេមានសេចក្តីពិតអំពីដំណឹងល្អច្រើនដែរ ដូច្នេះហើយក៏មានអ្នកជឿពិតខ្លះ ក្នុងចំណោមពួកគេ ប៉ុន្តែមានកំហុស និងបង្រៀនខុសឆ្គងជាច្រើនដែលបានលាយចូលដែរ»។ ថ្មីៗលោក ឌីក យ៉កបានធ្វើវីដេអូខ្លះ ដែលប្រាប់ពីសេចក្តីពិតអំពី ប៉ាក អុក ស៊ូ។ នេះ

គឺជាតំណភ្ជាប់ទៅវីដេអូទី១ ដែលមានចំណងជើងថា «ឌីក យ៉ក ចាប់ផ្ដើមណែនាំ ប៉ាក អុក ស៊ូ»៖ https://www.youtube.com/watch?v=Vvpg1u0ZhQc ។

## មុខពូថៅ 

តើអ្វីជាមុខពូថៅដែលអ្នកតាមលោកប៉ាក់ អុក ស៊ូ ប្រើដើម្បីពុះបំបែកពួកជំនុំរបស់ព្រះ? យើងបានមើលហើយអំពីមធ្យោបាយរបស់ក្រុមនេះ ដើម្បីបញ្ចូលគំនិតសង្ស័យនៅក្នុងចិត្តគំនិតរបស់គ្រីស្ទបរិស័ទទាក់ទងនឹងសេចក្ដីសង្គ្រោះ។

របៀបមួយទៀត ដែលបេសកកម្មដំណឹងល្អទាក់ទាញសមាជិកថ្មី គឺតាមរយៈអង្គការផ្សេងៗរបស់គេ ដូចជា ការជួបជុំប្រកបអ្នកដឹកនាំគ្រីស្ទបរិស័ទ (Christian Leaders Fellowship) និង ការជួបជុំយុវជនអន្តរជាតិ (International Youth Fellowship)។ ពួកគេទាក់ទាញចិត្តគ្រូគង្វាល និងយុវជន ដោយ *«អំនួតរបស់ជីវិត»* (១យ៉ូហាន ២:១៦) គឺប្រាប់គេថា គេជាអ្នកដឹកនាំសំខាន់ ព្រមទាំងចេញលុយចំណាយទាំងអស់ ដើម្បីចូលរួមមហាសន្និបាតអ្នកដឹកនាំ នៅទីក្រុងធំៗនៅផែនដីនេះ។ ប៉ុន្តែចូរទាយមើលថា តើអ្នកណាជាវាគ្មិនសំខាន់នៅសន្និបាតនោះ? បាទ ប៉ាក អុក ស៊ូ។

នៅក្នុងយុទ្ធសាស្រ្តទាំងអស់នេះ ពួកគេបានលាក់បាំង ការដែលអ្នកដឹកនាំបេសកកម្មដំណឹងល្អ នឹងត្រួតត្រាលើជីវិតរបស់សមាជិកទាំងស្រុង ហើយថែមទាំងអាចបង្ខំឲ្យពួកគេលែងលះប្ដី ឬប្រពន្ធរបស់ពួកគេផង ប្រសិនបើប្ដីឬប្រពន្ធនោះ មិនព្រមចូលជាសមាជិកដែរ។ ពួកគេក៏មិនប្រាប់អ្នកទេថា គ្រប់ក្រុមនិកាយ និងក្រុមប្រឹក្សានៅប្រទេសកូរ៉េខាងត្បូង បានប្រកាសថា ក្រុមបេសកកម្មដំណឹងល្អ គឺជាក្រុមខុសឆ្គង។



*ប៉ាក អុក ស៊ូ*

ក្រៅពីក្រុមបេសកកម្មដំណឹងល្អ មាន «ក្រុមសេចក្តីសង្គ្រោះ» ពីរទៀត មកពីប្រទេសកូរ៉េដែលស្រដៀងគ្នា។ សូមកត់សម្គាល់ថា ក្រុមជំនុំគ្រីស្ទសាសនាទាំងអស់នៅប្រទេសកូរ៉េ ចាត់ទុកក្រុមទាំងពីរនេះ ជាក្រុមខុសឆ្គងដែរ៖

- ពួកជំនុំដំណឹងល្អបាបទីស្ទកូរ៉េ (សព យូ ប្យុង-អឿន)
- ពួកជំនុំបេសកកម្មព្រះបន្ទូលនៃជីវិត ឬក្រុមជំនុំព្រះយេស៊ូវបាបទីស្ទ (លី យ៉ូ-ហាន)

«ក្រុមសេចក្តីសង្គ្រោះ» ទាំងអស់ ជារឿយៗហៅខ្លួនឯងថា «បាប់ទីស្ទ»។ ប៉ុន្តែក្រុមនិកាយបាបទីស្ទធំៗទាំងអស់នៅក្នុងប្រទេសកូរ៉េ បដិសេធពួកគេ ពីព្រោះពួកគេបំបាក់បំបែកក្រុមជំនុំ ហើយអះអាងថា ការសង្គ្រោះ គឺតាមរយៈតែក្រុមជំនុំរបស់ពួកគេតែប៉ុណ្ណោះ។

ចុងក្រោយសូមកុំភ្លេច ២យ៉ូហាន ១:១០-១១ *«បើអ្នកណាមកឯអ្នករាល់គ្នា តែមិនបង្រៀនចំពោះសេចក្តីនេះ នោះកុំឲ្យទទួលអ្នកនោះ នៅក្នុងផ្ទះឡើយ កុំឲ្យទាំងជំរាបសួរដល់អ្នកនោះផង ដ្បិតបើអ្នកណាជំរាបសួរ នោះក៏តែងមានសេចក្តីប្រកបគ្នា ក្នុងការអាក្រក់របស់អ្នកនោះដែរ»*។

**ធនធានគួរទុកចិត្ត៖** https://thecenters.org/searchgroups.aspx?groupid=212

# ដំណឹងល្អចម្រុងចម្រើន និង គ្រូចម្រុងចម្រើន

## Prosperity Gospel and Prosperity Preachers

ប្រហែល ៥០០ ឆ្នាំមុន គ្រូពួកជំនុំរ៉ូម៉ាំងកាតូលិកម្នាក់ ឈ្មោះ យ៉ូហាន តេតហ្សែល (Johannes Tetzel) ត្រូវបានចាត់បញ្ជូនដោយមេដឹកនាំនៃពួកជំនុំកាតូលិក ឲ្យទៅប្រទេសអាល្លឺម៉ង់ ដើម្បីរៃអង្គាសប្រាក់សម្រាប់ក្រុមជំនុំ ដោយលក់ ក្រដាសដែលគេហៅថា «ប័ណ្ណលើកលែងទោស(Indulgence)»។ ប័ណ្ណនោះបានសន្យាថានឹងរំដោះមនុស្សពីការរងទុក្ខនៅឋាន ធីហ្គាថ៏រី (Purgatory)។ លោកតេតហ្សែលបានធ្វើការសន្យាដ៏អស្ចារ្យដល់ពួកអាល្លឺម៉ង់ថា នៅពេលពួកគេបានទិញប័ណ្ណនេះនោះម្នាក់ដែលជាទីស្រឡាញ់របស់ពួកគេនឹងត្រូវបានដោះលែងពីសេចក្តីវេទនា នៅស្ថាន ធីហ្គាថ៏រី។ (តាមគោលជំនឿជំនុំកាតូលិក ស្ថាន «ធីហ្គាថ៏រី» គឺជាកន្លែងដាក់ទណ្ឌកម្មរវាងផែនដី និងស្ថានសួគ៌ ដែលគ្រីស្ទបរិស័ទត្រូវទៅបន្ទាប់ពីស្លាប់ ដើម្បីនឹងរងទុក្ខយ៉ាងធ្ងន់ធ្ងរ ចំពោះអំពើបាបរបស់ពួកគេរយៈពេលយូរឆ្នាំ ដើម្បីរៀបចំចូលទៅស្ថានសួគ៌)។

លោក តេតហ្សែល បាននិយាយបែបនេះដល់អ្នកភូមិក្រីក្រ៖ «តើអ្នកមិនស្រឡាញ់ដល់ឪពុកម្តាយដែលបានលាចាកលោកនេះទៅទេឬអី? ពួកគាត់កំពុងតែរងទុក្ខនៅស្ថានធីហ្គាថ៏រី ឥឡូវនេះ។ ប៉ុន្តែប្រសិន បើអ្នកថ្វាយដង្វាយដល់ក្រុមជំនុំវិញ នោះអ្នកអាចរំដោះពួកគាត់ពីការរងទុក្ខវេទនានោះបាន»។ ទាំងអស់នេះ គឺជាការកុហកដែលលោក តេតហ្សែលបានសន្យាចំពោះប្រជាជន ដើម្បីឲ្យគាត់អាចប្រមែប្រមូល

ប្រាក់សម្រាប់សម្តេចប៉ាប។ លោក តេតហ្សែល គឺជាអ្នកដែលលោកម៉ាទីន លូធើ បានប្រឆាំង នៅពេលដែលគាត់ដំដែកគោលបិទឯកសារ ៩៥ ចំណុច នៅទ្វារក្រុម ជំនុំ ក្នុងឆ្នាំ ១៥១៧។ (សូមមើលក្នុងអត្ថបទស្តីពីរ៉ូម៉ាំងកាតូលិកនៅក្នុង ឧបសម្ព័ន្ធទី១)។

សព្វថ្ងៃនេះយើងគ្មានលោក តេតហ្សែលទៀតទេ ដែលប្រើសាសនាដើម្បីរកលុយ។ ជំនួសគាត់យើងមានគ្រូផ្សព្វផ្សាយចម្រុងចម្រើន តាមទូរទស្សន៍ និងអ៊ីនធឺណិត។ មនុស្សដូច Joseph Prince, Joyce Meyer និង Joel Osteen ជាដើម បាន ក្លាយជាអ្នកមានស្តុកស្តម្ភ ដោយសារការសន្យាផ្សេងៗចំពោះអ្នកស្តាប់របស់គេ។ ស្រដៀងនឹងលោក តេតហ្សែល អ្នកផ្សព្វផ្សាយនេះសន្យា ពីទ្រព្យសម្បត្តិ និង សុខភាពល្អ ដល់គ្រីស្ទបរិស័ទដែលថ្វាយប្រាក់ដល់ពួកគេ។

## ប៉ុន្តែតើអ្វីជាគោលដៅចម្បងនៃជំនឿព្រះយេស៊ូវ ដើម្បីបានទ្រព្យសម្បត្តិ ឬដើម្បីបានព្រះ?

គោលដៅនៃជីវិតរបស់គ្រីស្ទបរិស័ទ គឺត្រូវស្គាល់ដល់ព្រះដែលទ្រង់ជាព្រះអាទិករ របស់យើង ស្រឡាញ់ទ្រង់ដ៏អស់កល្បជានិច្ច និងថ្វាយជីវិត និងទ្រព្យសម្បត្តិរបស់ យើង ដើម្បីផ្សព្វផ្សាយដំណឹងល្អរបស់ទ្រង់នៅលើផែនដី។ គ្រីស្ទបរិស័ទជឿថា ព្រះ មានតម្លៃខ្ពង់ខ្ពស់ជាងទ្រព្យសម្បត្តិឆ្ងាយណាស់។ គាត់ដឹងថា បើគ្មានព្រះទេ ក៏នឹង គ្មានទ្រព្យសម្បត្តិផងដែរ - គ្មានមាស គ្មានអាហារ គ្មានដី និងគ្មានសុខភាពទេ ដូច្នេះ វាជាការល្ងង់ខ្លៅណាស់ ក្នុងការស្រឡាញ់អ្វីៗទាំងអស់នេះ ច្រើនជាងយើង ស្រឡាញ់ព្រះ ដែលបានបង្កើតរបស់ទាំងនោះមក!

ការស្រឡាញ់អ្វីៗដែលជារបស់ព្រះ ច្រើនជាងស្រឡាញ់ព្រះ គឺដូចជាកូនប្រុសដែល និយាយទៅឪពុកគាត់ថា «លោកឪពុកមិនទាន់ស្លាប់ទេ តែខ្ញុំចង់បានកេរ្តិ៍មរតកឥឡូវ នេះ»។ អស់អ្នកដែលប្រើព្រះ និងសាសនា ដើម្បីបានទ្រព្យសម្បត្តិ និងសុខភាពល្អ

គឺប្រៀបដូចជាកូនអាក្រក់នោះដែរ។ ពួកគេគ្រាន់តែប្រើព្រះដើម្បីបានទ្រព្យសម្បត្តិ និងសុខភាពប៉ុណ្ណោះ។ ប៉ុន្តែព្រះជាអ្នកបង្កើតអ្វីៗទាំងអស់ ដែលគួរឲ្យយើងចង់បាន និងធ្វើឲ្យយើងស្កប់ចិត្ត។ ដូច្នេះ ព្រះអង្គផ្ទាល់ ត្រូវជាទីគាប់ចិត្ត និងជាទីពេញចិត្ត ជាងអ្វីៗ ដែលទ្រង់បានបង្កើតមក។ គោលដៅធំបំផុតរបស់គ្រីស្ទបរិស័ទ គឺមិនមែន ដើម្បីទទួលបានសុខភាព និងទ្រព្យសម្បត្តិនោះទេ ប៉ុន្តែដើម្បីបានព្រះ គឺស្គាល់ទ្រង់ និងស្រឡាញ់ទ្រង់ជាព្រះវរបិតារបស់យើង។ មនុស្សដែលមានព្រះ បូកនឹងរបស់ទាំងអស់ មិនមែនមានជាងមនុស្សដែលមានតែព្រះនោះទេ។ ឬនិយាយម្យ៉ាងទៀត៖

ព្រះ + គ្មានអ្វីសោះ = មានអ្វីៗទាំងអស់

និង

មានអ្វីៗទាំងអស់ – ព្រះ = គ្មានអ្វីសោះ

## ប្រសិនបើអ្នកត្រូវបាត់បង់អ្វីៗទាំងអស់ ដើម្បីទទួលបានព្រះ តើអ្នកសុខចិត្តធ្វើទេ?

នេះគឺជាជម្រើសដែលបុរសអ្នកមានម្នាក់នៅក្នុងព្រះគម្ពីរត្រូវធ្វើការសម្រេចចិត្ត។ បុរសនេះបានមករកព្រះយេស៊ូវ ហើយនិយាយថា *«តើត្រូវឲ្យខ្ញុំធ្វើការល្អអ្វី ឲ្យបានជីវិតរស់នៅអស់កល្បជានិច្ច?»* ព្រះយេស៊ូវអាចឃើញចិត្តរបស់បុរសនេះ ដោយទ្រង់ដឹងថា គាត់ស្រឡាញ់ទ្រព្យសម្បត្តិរបស់គាត់ច្រើនជាងស្រឡាញ់ព្រះ។ ព្រះយេស៊ូវចង់ឲ្យគាត់ប្រែចិត្តពីអំពើបាបនោះ ហើយទទួលការអត់ទោស ដូច្នេះទ្រង់ក៏បានសាកល្បងគាត់ដោយប្រើពាក្យបង្គាប់ខុសពីធម្មតាថា៖ *«ចូរអ្នកទៅលក់របស់ទ្រព្យខ្លួន ហើយចែកដល់ពួកអ្នកក្រីក្រទៅ នោះអ្នកនឹងបានទ្រព្យសម្បត្តិនៅឯស្ថានសួគ៌វិញ រួចឲ្យមកតាមខ្ញុំចុះ»* (ម៉ាថាយ ១៩:២១)។ តើបុរសម្នាក់នេះសម្រេចចិត្តធ្វើអ្វី? *«កាលមនុស្សកំឡោះបានឮព្រះបន្ទូលនោះហើយ នោះក៏ចេញទៅទាំងព្រួយ*

*ចិត្ត ព្រោះមានទ្រព្យសម្បត្តិជាច្រើន»* (ម៉ាថាយ ១៩:២២)។ ការនេះធ្វើឲ្យយើងសោកស្តាយខ្លាំង។ គាត់ចង់បានទ្រព្យសម្បត្តិជាជាងចង់បានព្រះ។

តាមពិតយើងម្នាក់ៗកំពុងតែប្រឈមមុខនឹងការសម្រេចចិត្តដូចគ្នា។ ព្រះយេស៊ូវបានមានបន្ទូលនៅក្នុងលូកា ១៦:១៣ ថា *«អ្នកមិនអាចបំរើព្រះផង និងបំរើប្រាក់ផងបានទេ»*។ យើងត្រូវតែសម្រេចចិត្ត។ បើយើងស្រឡាញ់ទ្រព្យសម្បត្តិ ឬសុខភាពច្រើនជាងស្រឡាញ់ព្រះ យើងមិនអាចមានព្រះបានទេ។ ហើយប្រសិនបើយើងស្លាប់ដោយគ្មានព្រះ យើងនឹងបាត់បង់អ្វីៗទាំងអស់។ គ្មាននរណានៅឯស្ថាននរកដែលជាសេដ្ឋីនោះទេ!

## ប្រសិនបើការលំបាកនាំអ្នកឲ្យកាន់តែជិតស្និទ្ធនឹងព្រះ តើអ្នកជ្រើសរើសយកការលំបាកនោះទេ?

ខ្ញុំមិននិយាយថា វាជាផែនការរបស់ព្រះសម្រាប់កូនរបស់ទ្រង់ឲ្យមានភាពក្រីក្រ និងជំងឺនោះទេ។ ប៉ុន្តែប្រសិនបើគ្រីស្ទបរិស័ទដឹងថា ភាពក្រីក្រ និងជំងឺ នឹងនាំគាត់ឲ្យកាន់តែជិតស្និទ្ធនឹងព្រះ នោះគាត់នឹងអរគុណចំពោះការលំបាកទាំងអស់នោះ។ តាមពិតយើងដឹងពីព្រះគម្ពីរថា ជារឿយៗព្រះប្រើទុក្ខលំបាក ដើម្បីនាំយើងឲ្យកាន់តែជិតស្និទ្ធនឹងទ្រង់ (២កូរិនថូស ១២:៩-១០ និង រ៉ូម ៥:៣-៤)។

ផ្ទុយទៅវិញគ្រូអធិប្បាយភាពចម្រុងចម្រើនប្រាប់យើងថា វាជាបំណងព្រះហឫទ័យរបស់ព្រះជានិច្ច ដើម្បីឲ្យយើងមានសុខភាពល្អ និងទ្រព្យសម្បត្តិជាបរិបូរណ៍។ ប៉ុន្តែតាមពិត ព្រះមានបំណងព្រះទ័យខ្ពស់ជាងនេះទៀតសម្រាប់យើង គឺដើម្បីឲ្យបានបរិសុទ្ធ និងពេញដោយអំណរដូចព្រះយេស៊ូវ។ ប្រសិនបើការរងទុក្ខលំបាកនាំឲ្យយើងស្គាល់ និងស្រឡាញ់ព្រះកាន់តែច្រើន នោះទ្រង់មិនស្រឡាញ់យើងទេ បើព្រះអង្គបញ្ចៀសការលំបាកនោះចេញពីជីវិតរបស់យើង។

## តើព្រះជាម្ចាស់កំណាញ់ឬ?

ប្រាកដជាអត់ ព្រះជាម្ចាស់ជាព្រះដ៏សប្បុរស និងសទ្ធា។ លើសពីការដែលយើងអាចយល់បាន។ យើងអាចដឹងការនេះ ដោយក្រឡេកមើលធម្មជាតិដែលទ្រង់បានបង្កើតមក។ ទ្រង់មិនបានបង្កើតដើមពោត ដែលមានគ្រាប់ពោតតែពីរបីឡនោះទេ ប៉ុន្តែមានមួយពាន់គ្រាប់នៅដើមមួយ! ដើមស្វាយមួយដើម នឹងមានផ្លែស្វាយរាប់រយផ្លែជារៀងរាល់ឆ្នាំ សម្រាប់រយៈពេល៤០ ឆ្នាំ!

អូ អស្ចារ្យណាស់ របៀបដែលព្រះស្រឡាញ់យើង ហើយចាក់បង្ហូរព្រះពរ នូវសុខភាព និងទ្រព្យធនដល់យើង! មិនត្រឹមតែប៉ុណ្ណោះ យើងធ្លាប់ឃើញថា នៅពិភពលោកទាំងមូល ដំណឹងល្អច្រើនតែនាំមកនូវភាពចម្រើន និងសុខភាពល្អដល់គ្រីស្ទបរិស័ទ ពីព្រោះព្រះអង្គប្រទានឲ្យប្រជារាស្ត្ររបស់ទ្រង់នូវចិត្តថ្មី ដែលពោរពេញទៅដោយភាពស្មោះត្រង់ ភាពឧស្សាហ៍ព្យាយាម ភាពសុចរិត សេចក្តីស្រឡាញ់ និងការគ្រប់គ្រងចិត្តខ្លួនឯង។

## តើព្រះបង្គាប់យើងឲ្យជួយអ្នកមាន ឬអ្នកក្រ?

គ្រូចម្រុងចម្រើន ជាអ្នកមានរស់នៅក្នុងវិមានដ៏ធំ ហើយមានយន្តហោះឯកជនផ្ទាល់ខ្លួនរបស់ពួកគេទៀត តែពួកគេទាមទារទស្សនិកជនដែលមើលទូរទស្សន៍ និងអ៊ីនធឺណិត របស់ពួកគេ ផ្ញើប្រាក់មកឲ្យពួកគេរហូត។ ប៉ុន្តែ តើព្រះយេស៊ូវបង្គាប់យើងឲ្យថ្វាយដង្វាយដល់អ្នកមាន ឬអ្នកក្រ? សូមស្តាប់៖ *«ប៉ុន្តែ កាលណាអ្នកធ្វើទាន នោះកុំឲ្យដៃឆ្វេងដឹងការដែលដៃស្តាំធ្វើឡើយ ដើម្បីឲ្យអំពើទានរបស់អ្នក បានស្ងាត់កំបាំង នោះព្រះវរបិតានៃអ្នក ដែលទ្រង់ទតឃើញក្នុងទីសំងាត់ ទ្រង់នឹងប្រទានរង្វាន់ដល់អ្នកនៅទីប្រចក្សច្បាស់»* (ម៉ាថាយ ៦:៣-៤)។

ព្រះយេស៊ូវចង់ឲ្យយើងឲ្យទានដល់អ្នកក្រ មិនមែនដល់អ្នកមាននោះទេ៖ *«ព្រះយេស៊ូវបានមានបន្ទូលទៅកាន់បុរសដែលបានអញ្ជើញទ្រង់ដែរថា៖ <កាល*

*ណាអ្នកជប់លៀងភ្ញៀវពេលថ្ងៃត្រង់ ឬពេលល្ងាច នោះកុំឲ្យអញ្ជើញពួកសំឡាញ់ បងប្អូនសាច់ញាតិ ឬ**អ្នកមាន** ដែលនៅជិតខាងឡើយ ក្រែងគេក៏អញ្ជើញអ្នកទៅសង ដូច្នោះវិញដែរ។ បើកាលណាអ្នករៀបជប់លៀងភ្ញៀវនោះ ចូរអញ្ជើញពួក**អ្នកក្រ អ្នកពិការ អ្នកខ្វើច និងអ្នកខ្វាក់**វិញ។ យ៉ាងនោះអ្នកនឹងបានពរពិត ដ្បិតមនុស្សទាំងនោះគ្មានអ្វីនឹងសងអ្នកវិញទេ លុះកាលណាពួកមនុស្សសុចរិតរស់ឡើងវិញ នោះអ្នកនឹងបានរង្វាន់ហើយ>»* (លូកា ១៤:១២-១៤)។

អ្នកនិពន្ធសុភាសិតព្រមានយើងពីការជួយអ្នកមាន៖ *«អ្នកដែលសង្កត់សង្កិនមនុស្សទាល់ក្រ ដើម្បីនឹងចំរើនទ្រព្យសម្បត្តិខ្លួនឡើង ហើយអ្នកណាដែលជូនជំនូនដល់អ្នកមាន នោះនឹងត្រឡប់ជាខ្វះខាតវិញ»* (សុភាសិត ២២:១៦)។ ខនេះរំឭកយើងពីគ្រូចម្រុងចម្រើន ដែលទាមទារដង្វាយពីអ្នកស្តាប់ដែលក្រីក្រ ហើយក៏រំឭកយើងអំពីពួកក្រីក្រ ដែលធ្វើដង្វាយដល់គ្រូចម្រុងចម្រើន ដោយសង្ឃឹមថា គេនឹងទទួលលុយវិញ មួយជាមួយរយដែរ។ ទាំងពីគឺប្រើសាសនាដើម្បីក្លាយទៅជាអ្នកមាន។

ច្បាស់ណាស់ ដែលព្រះចង់ឲ្យយើងជួយដល់អ្នកក្រីក្រ មិនមែនដល់គ្រូជាអ្នកមាន នៅតាមទូរទស្សន៍ទាំងនេះនោះទេ។ ឧទាហរណ៍ អ្នកស្រី ចយ ម៉ៃយើ ( Joyce Meyer) ស្នាក់នៅក្នុងបន្ទប់សណ្ឋាគារដែលមានតម្លៃជាង ១000 ដុល្លារក្នុងមួយយប់។ ផ្ទះរបស់គាត់មានតម្លៃ ២០លានដុល្លារ។ គាត់ធ្វើដំណើរពីទីក្រុងមួយទៅទីក្រុងមួយទៀត ដោយជិះយន្តហោះផ្ទាល់ខ្លួន ហើយគាត់ទទួលបានប្រាក់ខែជាង ១០ម៉ឺនដុល្លារជា**រៀងរាល់ខែ**! ប្រសិនបើគ្រូអធិប្បាយទាំងនេះ ជាអ្នកមានយ៉ាងខ្លាំង ហេតុអ្វីបានជាពួកគេនៅតែសុំលុយពីយើងទៀត? (www.msn.com/en-xl/news/other/joyce-meyer-net-worth-house-sources-of-income-2021/ar-BB1cxVMK)

## គ្រូចម្រុងចម្រើនល្បីៗ

នេះគឺជាបញ្ជីគ្រូចម្រុងចម្រើនល្បីៗនៅជុំវិញពិភពលោក។ ពួកគេរកលុយបានច្រើនណាស់ ដែលធ្វើឲ្យពួកគេ រស់នៅដូចជាស្ដេច និងមហាក្សត្រី។ បញ្ជីនេះមិនគ្រប់ទាំងអស់ទេ គឺនៅមានរាប់រយនាក់ទៀត (គ្រូនៅបញ្ជីនេះខ្លះជិតសេចក្ដីពិតជាងគ្រូឯទៀត ប៉ុន្តែពួកគេទាំងអស់បង្រៀនថា ជាព្រះហឫទ័យរបស់ព្រះអង្គ ដែលយើងត្រូវមានជីវភាពស្ដុកស្ដម្ភ និងសុខភាពល្អ ហើយថា យើងអាចក្លាយជាអ្នកមាន ដោយនិយាយពាក្យ ដែលបង្កើតឲ្យមានសុខភាពល្អ និងភាពចម្រុងចម្រើន)។

### សហរដ្ឋអាមេរិក

បិននី ហិន (Benny Hinn)
ចូល អូស្ទីន (Joel Osteen)
ចយ ម៉ាយើ (Joyce Meyer)
ធីឌី ចេក (TD Jakes)
ខេនណិត ខុបឡិន (Kenneth Copeland )
ផល្លា ហ្វៃត (Paula White)
ខេនណិត ហេហ្គិន (ខ្មោច) (Kenneth Hagin)
ក្រិហ្វឡូ ដុល្លា (Creflo Dollar)

### អាស៊ី

យ៉ូសែប ព្រិន (Joseph Prince)
កង ហ៊ី (Kong Hee)

### អាហ្វ្រិក

ធីប៊ី ចយស៊ូអា (ខ្មោច) (T.B. Joshua)
សែបភើត ប៊ូសស៊ីរី (Shepherd Bushiri)
គ្រីស អូយ៉ាឃីឡូមេ (Chris Oyakhilome)
រេ មីខលលី (Ray McCauley)
អ៊ូប៊ឺត អេងជែល (Uebert Angel)
អ៊ីអេ អាដេបូយេ (E.A. Adeboye)
អាយ៉ូ អូរិតសេចាហ្វរ (Ayo Oritsejafor)
ដាវីដ អូយ៉េដេបូ (David Oyedepo)
អាលហ្វ លូកោ (Alph Lukau)

### អាមេរិកខាងត្បូង

វ៉ាល់ឌីមីរ៉ូ សាន់ទីអាហ្គូ (Valdemiro Santiago)
អេឌៀ ម៉ាសេដូ (Edir Macedo)

ជាច្រើនឆ្នាំមុន នៅពេលដែលគ្រូអធិប្បាយទាំងនេះចាប់ផ្ដើមបង្រៀន ពួកគេមិនមែនជាអ្នកមានទេ។ ប៉ុន្តែឥឡូវនេះ ពួកគេបានក្លាយជាអ្នកមានយ៉ាងខ្លាំង ហើយរស់នៅដូចជាស្ដេច។ តើពួកគេក្លាយជាសេដ្ឋីដោយរបៀបណា? ការមានបានរបស់ពួកគេ

ភាគច្រើនមកតាមរយៈដង្វាយរបស់គ្រីស្ទបរិស័ទសាមញ្ញ។ ហើយឥឡូវនេះពួកគេចង់ឲ្យគ្រីស្ទបរិស័ទសាមញ្ញនេះ ថ្វាយដង្វាយដល់ពួកគេថែមទៀត។ សូមកុំធ្វើប្រាក់របស់លោកអ្នកទៅឲ្យពួកគេ ឬក៏ស្តាប់ពួកគេនោះឡើយ! មូលហេតុដែលពួកគេនៅតែជាអ្នកមាន គឺដោយសារតែមានមនុស្សល្ងង់នៅតែធ្វើប្រាក់ឲ្យទៅពួកគេ ដោយសង្ឃឹមថា នឹងទទួលបានព្រះពរ ពីព្រះជាម្ចាស់វិញ។ គ្រូអធិប្បាយទាំងនេះ មិនត្រូវការប្រាក់ដង្វាយរបស់យើងទេ។ ពួកគេគឺជាគ្រូក្លែងក្លាយ។ អស់អ្នកណាដែលប្រើសាសនាដើម្បីក្លាយជាអ្នកមាន គឺជាគ្រូក្លែងក្លាយ ទោះបីជាពួកគេបង្រៀនរឿងខ្លះដែលមានប្រយោជន៍ក៏ដោយ។

ប្រសិនបើការសន្យារបស់គ្រូចម្រុងចម្រើនទាំងនេះ ទាក់ទងនឹងលុយ ជាការពិតនោះពួកគេខ្លួនឯងនឹងមានលុយច្រើនហូរហៀរ រហូតពួកគេនឹងធ្វើលុយមកអ្នកស្តាប់វិញ! ភ័ស្តុតាងដែលថា អ្វីដែលពួកគេកំពុងបង្រៀនអំពីលុយមិនពិតនោះ គឺពួកគេនៅតែបន្តសុំលុយពីអ្នកដទៃទៀត! ហេតុអ្វីបានជាពួកគេនៅតែត្រូវការលុយពីគ្រប់គ្នាប្រសិនបើពួកគេមានទ្រព្យសម្បត្តិជាងមនុស្សគ្រប់គ្នាទៀតនោះ? ដោយសារតែពួកគេត្រូវការប្រាក់បន្ថែម ដើម្បីទ្រទ្រង់ជីវិតជាអ្នកមានរបស់ពួកគេ។

## តើយើងដឹងយ៉ាងដូចម្តេចថា នរណាម្នាក់គឺជាគ្រូក្លែងក្លាយនៃភាពចម្រុងចម្រើន?

- គាត់ចំណាយពេលច្រើននិយាយអំពីទ្រព្យសម្បត្តិ និងសុខភាព។
- គាត់មិនបានព្រមានមនុស្សអំពីគ្រោះថ្នាក់នៃការចង់ក្លាយជាអ្នកមាននោះទេ។
- គាត់បង្រៀនថា អ្នកអាចបង្កើតទ្រព្យសម្បត្តិ និងសុខភាពល្អ ដោយពាក្យសម្តីពិសេសរបស់អ្នក (ដូចព្រះ)។
- គាត់បានក្លាយជាសេដ្ឋី ពីដង្វាយរបស់គ្រីស្ទបរិស័ទសាមញ្ញ។

- គាត់មិនសូវមាន អ្នកទទួលខុសត្រូវលើគាត់នោះទេ។ ធម្មតាគ្មានក្រុមចាស់ទុំណាដែលហ៊ានកែតម្រូវគាត់ឡើយ។
- គាត់និយាយច្រើន អំពីខ្លួនគាត់ ហើយគាត់ជា «វីរបុរស» នៃរឿងផ្ទាល់ខ្លួនរបស់គាត់។
- បុគ្គលិកលក្ខណៈរបស់គាត់ គឺជាចំណុចសំខាន់ជាងគេ ដើម្បីអូសទាញអ្នកស្ដាប់ មិនមែនការបង្រៀនព្រះបន្ទូលរបស់ព្រះ ឬការផ្សាយដំណឹងល្អទេ។
- គាត់រស់នៅក្នុងជីវិតដ៏ប្រណិត និងថ្លៃថ្នូរ ដោយមានរថយន្តថ្លៃៗ ផ្ទះធំៗជាច្រើន ហើយយន្តហោះឯកជនផងដែរ។
- គាត់មិនបង្រៀនអំពីភាពចាំបាច់នៃការរងទុក្ខនៅក្នុងជីវិតជាគ្រីស្ទបរិស័ទទេ។
- គាត់និយាយថា ជំងឺ និងភាពក្រីក្រ កើតចេញពីការខ្វះជំនឿ ឬមកពីសាតាំង។
- គាត់អះអាងថា ព្រះមានបន្ទូលនឹងគាត់ផ្ទាល់។

ពួកគេខ្លះអះអាងថា គេមានអំណាចក្នុងការប្រោសឲ្យជា ប៉ុន្តែពួកគេមិនចូលមន្ទីរពេទ្យដើម្បីទៅប្រោសអ្នកជំងឺនៅទីនោះទេ។ ផ្ទុយទៅវិញ ពួកគេប្រើការសន្យាប្រោសឲ្យជា ដើម្បីទទួលបានដង្វាយបន្ថែមពីអស់អ្នកដែលស្ដាប់តាមគេ។

## ហេតុអ្វីបានជាគ្រូចម្រុងចម្រើនពេញនិយមម្ល៉េះ?

គ្រូចម្រុងចម្រើនមានប្រជាប្រិយណាស់ ព្រោះមនុស្សដែលស្ដាប់តាមពួកគេ ចង់ក្លាយជាអ្នកមាន និងចង់បានសុខភាពល្អដែរ។ គ្រូចម្រុងចម្រើនដឹងពីការនេះ ដូច្នេះពួកគេប្រើ**បំណងប្រាថ្នា**របស់អ្នកស្ដាប់ ដើម្បីកេងចំណេញលើពួកគេ។ ពួកគេសន្យា

ដល់អ្នកដើរតាមរបស់ពួកគេថា ពួកគេអាចនឹងក្លាយជាអ្នកមាន តាមរយៈសាសនាព្រះយេស៊ូវគ្រីស្ទ។

**តើព្រះទ្រង់មានបន្ទូលអ្វីខ្លះ អំពីអស់អ្នកដែលប្រើសាសនាដើម្បីទៅជាមាន?**
ព្រះគម្ពីរបានព្រមានយើងអំពីមនុស្សដែល *«រកចំណេញពីព្រះបន្ទូលរបស់ព្រះ»* គឺមនុស្សដែលក្លាយជាអ្នកមានពីជំនឿលើព្រះយេស៊ូវគ្រីស្ទ។ សាវកប៉ុលបាននិយាយថា *«ដ្បិតយើងមិនមែនរកចំណេញពីព្រះបន្ទូលរបស់ព្រះ ដូចមនុស្សជាច្រើននោះឡើយ តែក្នុងព្រះគ្រីស្ទ យើងនិយាយក្នុងនាមជាមនុស្សស្មោះត្រង់ ជាមនុស្សដែលព្រះបានចាត់ឲ្យមក នៅចំពោះព្រះអង្គ»* (២កូរិនថូស ២:១៧ RKOV)។

លោកប៉ុលក៏បានព្រមានយើងអំពីគ្រូក្លែងក្លាយទាំងនោះ ដែលប្រើរបៀបសាសនា ជាមធ្យោបាយដើម្បីទទួលបានផលប្រយោជន៍៖

> *«បើអ្នកណាបង្រៀនពីសេចក្តីអ្វីផ្សេងទៀត ហើយមិនយល់ព្រមតាមពាក្យសំដីដែលត្រឹមត្រូវ គឺជាព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង និងជាសេចក្តីបង្រៀនដែលត្រឹមត្រូវ តាមសេចក្តីគោរពប្រតិបត្តិដល់ព្រះទេ អ្នកនោះឈ្មោះថាមានចិត្តធំ ហើយមិនដឹងអ្វីសោះ គឺវក់តែនឹងជជែក ហើយដេញដោលពីន័យពាក្យ ដែលនាំឲ្យកើតសេចក្តីឈ្នានីស ឈ្លោះប្រកែក ជេរប្រមាថ និងសេចក្តីសង្ស័យដ៏អាក្រក់ប៉ុណ្ណោះ ជាសេចក្តីជំលោះឥតប្រយោជន៍របស់មនុស្សខូចគំនិត ហើយឥតស្គាល់សេចក្តីពិត* ***ដោយស្មានថា ការគោរពប្រតិបត្តិដល់ព្រះជាផ្លូវឲ្យបានកំរៃ»*** (១ធីម៉ូថេ ៦:៣-៥)។

សាវកពេត្រុសក៏ព្រមានយើងអំពីគ្រូក្លែងក្លាយដែលស្រឡាញ់ប្រាក់ដែរ៖ *«ពួកគេមានភ្នែកពោរពេញដោយអំពើផិតក្បត់ គេមិនចេះលែងធ្វើបាបឡើយ ក៏បិទនុយចាប់ព្រលឹងមនុស្សដែលមិនខ្ជាប់ខ្ជួន ហើយមានចិត្តធ្លាប់ខាងឯ**សេចក្តីលោភ*** គឺជា

*មនុស្សដែលត្រូវបណ្ដាសា គេបានបោះបង់ចោលផ្លូវទៀងត្រង់ ហើយវង្វេងទៅតាមផ្លូវរបស់ហោរាបាឡាមជាកូនបេអ៊រ ដែល**ស្រឡាញ់កំរៃនៃការទុច្ចរិត**»* (២ពេត្រុស ២:១៤-១៥)។

សូម្បីតែក្រុមជំនុំដើមដំបូងក៏មានច្បាប់ទាស់ប្រឆាំងនឹង គ្រូដើរអធិប្បាយដែលសុំលុយដែរ។ នៅក្នុងសៀវភៅតូចនៃច្បាប់ក្រុមជំនុំនៅសតវត្សរ៍ទី២ ដែលមានឈ្មោះថា «ឌាដាកកេ» (Didache) យើងអានឃើញថា «ប្រសិនបើគ្រូអធិប្បាយសុំលុយ គាត់គឺជា**ហោរាក្លែងក្លាយ**»។

## តើបំណងប្រាថ្នាចង់ក្លាយជាអ្នកមាន គឺជាគោលដៅល្អ ឬជាគោលដៅដែលបំផ្លាញជីវិតរបស់អ្នក?

គ្រូចម្រុងចម្រើនប្រាប់អ្នកថា ជាការល្អដែលយើងចង់ក្លាយជាអ្នកមានទ្រព្យធន។ ពួកគេថែមទាំងប្រាប់អ្នកថា អ្នកមានអំណាច បង្កើតទ្រព្យធនច្រើន ដោយការប្រើពាក្យសម្ដីរបស់អ្នក គឺ ដូចព្រះដែរ! នោះគឺជាការបង្រៀនខុសឆ្គង។ ព្រះគម្ពីរនិយាយផ្ទុយពីការនេះថា៖

> *«**រីឯពួកអ្នកដែលចង់ធ្វើជាអ្នកស្ដុកស្ដម្ភ នោះនឹងធ្លាក់ទៅក្នុងសេចក្ដីល្បួង** និងអន្ទាក់ ហើយក្នុងបំណងជាច្រើនដែលឆ្កួតផ្ដាស ហើយធ្វើទុក្ខដល់ខ្លួន ក៏ពន្លិចមនុស្សទៅក្នុងសេចក្ដីហិនវិនាស និងសេចក្ដីអន្តរធានវិញ។ ដ្បិតការដែលស្រឡាញ់ប្រាក់ នោះហើយជាមេឫសនៃសេចក្ដីអាក្រក់គ្រប់យ៉ាង ដែលអ្នកខ្លះបានឈោងតាម ហើយត្រូវវង្វេងលោមឲ្យឃ្លាតចេញពីសេចក្ដីជំនឿ ទាំងចាក់ទំលុះខ្លួនគេ ដោយសេចក្ដីព្រួយលំបាកជាច្រើន»* (១ធីម៉ូថេ ៦:៩-១០)។

ប្រហែលជាអ្នកគួរតែអានខគម្ពីរនេះម្តងទៀត ដោយយកចិត្តទុកដាក់បំផុត ប្រសិនបើ អ្នកកំពុងតែជាប់នៅក្នុងសេចក្តីល្បួងនៃការស្រឡាញ់ទ្រព្យធន។ ហេតុអ្វីបានជាគ្រូ ចម្រុងចម្រើនមិនបង្រៀនអំពីខទាំងនេះ?

សូមសម្គាល់ថា សាវកប៉ុលបង្រៀនថា *«ដ្បិតការដែលស្រឡាញ់ប្រាក់ នោះហើយជា* ***មេឫសនៃសេចក្តីអាក្រក់គ្រប់យ៉ាង***»។ ការស្រឡាញ់ប្រាក់ បង្កើតអំពើបាប ច្រើនមុខ ទៀត។ នេះជាមូលហេតុដែលគ្រូចម្រុងចម្រើនជាច្រើនបានធ្លាក់ក្នុងបាប សហាយស្មន់ និងគោលជំនឿខុសឆ្គង។ ការចង់ធ្វើជាអ្នកស្តុកស្តម្ភ មិនមែនជា គោលបំណងល្អ តែជាគោលបំណងដែលនាំឲ្យមានគ្រោះថ្នាក់វិញ។

ជំនួសឲ្យការដាក់គោលដៅក្លាយជាអ្នកមានស្តុកស្តម្ភ ព្រះអង្គទ្រង់ប្រាប់យើងឲ្យ មានគោលបំណងនៃការគោរពប្រតិបត្តិដល់ព្រះ ដែលមានទាំងចិត្តស្កប់ស្កល់វិញ៖ *«តែការគោរពប្រតិបត្តិដល់ព្រះ ដែលមានទាំងចិត្តស្កប់ស្កល់ផង នោះជាកំរៃ១យ៉ាង ធំមែន ដ្បិតយើងរាល់គ្នាមិនបានយកអ្វី ចូលមកក្នុងលោកីយ៍នេះទេ ហើយច្បាស់ជា យើងពុំអាចនឹងយកអ្វីចេញទៅវិញបានដែរ តែបើមានអាហារទទួលទាន និង សំលៀកបំពាក់ នោះក៏ល្មមឲ្យយើងបានស្កប់ចិត្តហើយ»* (១ធីម៉ូថេ ៦:៦-៨)។ គ្រូ ចម្រុងចម្រើនមិនបានព្រមានយើងអំពីគ្រោះថ្នាក់នៃភាពស្តុកស្តម្ភនោះទេ ហើយពួក គេក៏មិនអធិប្បាយអំពីខគម្ពីរដូចនេះទេ៖ *«ចូរឲ្យជីវិតអ្នករាល់គ្នាបានឥតលោភ ពីការ ស្រលាញ់ប្រាក់ ឲ្យជីវិតអ្នកបានស្កប់ចិត្តនឹងរបស់ដែលមានហើយប៉ុណ្ណោះចុះ ដ្បិត ទ្រង់មានព្រះបន្ទូលថា <អញនឹងមិនចាកចេញពីឯង ក៏មិនបោះបង់ចោលឯងឡើយ> បានជាយើងរាល់គ្នាអាចនឹងនិយាយដោយក្លាហានថា <ខ្ញុំមិនព្រមខ្លាចឡើយ ព្រោះ ព្រះអម្ចាស់ទ្រង់ជាជំនួយខ្ញុំ តើមនុស្សនឹងធ្វើដល់ខ្ញុំជាយ៉ាងណាបាន?>»* (ហេព្រើរ ១៣:៥-៦)។ ហេតុអ្វីបានជាពួកគេស្ងាត់ស្ងៀមមិននិយាយអំពីខគម្ពីរទាំងនេះ?

## តើភាពស្តុកស្តម្ភជាភ័ស្តុតាងនៃព្រះពររបស់ព្រះ ឬក៏ជាឧបសគ្គចំពោះសេចក្តីសង្គ្រោះរបស់យើង?

យើងទាំងអស់គ្នាបានស្គាល់មនុស្សអាក្រក់ដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភ។ ភាពស្តុកស្តម្ភមិនមែនជាសញ្ញានៃព្រះពររបស់ព្រះទេ។ តាមពិតព្រះយេស៊ូវបានមានបន្ទូលប្រាប់ពួកសាវកថា ភាពស្តុកស្តម្ភធ្វើឲ្យមនុស្សពិបាកទទួលបានជីវិតអស់កល្បជាង៖ *«ដែលមនុស្សអ្នកមានចូលទៅក្នុងនគរព្រះ នោះពិបាកណាស់...បើសត្វអូដ្ឋនឹងចូលតាមប្រហោងម្ជុល នោះងាយជាជាងមនុស្សអ្នកមានចូលទៅក្នុងនគរព្រះវិញ»*។ ពាក្យនោះធ្វើឲ្យពួកសាវកភ្ញាក់ផ្អើលយ៉ាងខ្លាំង ពួកគេស្មានថា ភាពស្តុកស្តម្ភជាសញ្ញានៃព្រះពរពីព្រះ។ ដូច្នេះ ពួកគេបានសួរថា *«តើអ្នកណាអាចនឹងបានសង្គ្រោះ ព្រះយេស៊ូវទ្រង់ទតទៅគេ មានព្រះបន្ទូលថា ការនោះមនុស្សលោកធ្វើពុំកើតទេ តែព្រះទ្រង់ធ្វើកើត ដ្បិតព្រះទ្រង់អាចនឹងធ្វើកើតទាំងអស់បាន»* (ម៉ាកុស ១០:២៣-២៧)។

## តើមួយណាចាំបាច់ជាងនៅក្នុងជីវិតគ្រីស្ទបរិស័ទ ភាពស្តុកស្តម្ភ ឬការរងទុក្ខ?

យើងអាចជាគ្រីស្ទបរិស័ទដោយគ្មានភាពស្តុកស្តម្ភ ប៉ុន្តែយើងមិនអាចជាគ្រីស្ទបរិស័ទដោយគ្មានការរងទុក្ខនោះឡើយ។ សូមស្តាប់សាវកប៉ុល៖ *«ព្រះវិញ្ញាណទ្រង់ក៏ធ្វើបន្ទាល់នឹងវិញ្ញាណយើងថា យើងជាកូនរបស់ព្រះ បើសិនណាជាកូនព្រះហើយ នោះយើងក៏បានគ្រងមរដកដែរ គឺជាអ្នកគ្រងមរដកនៃព្រះជាមួយនឹងព្រះគ្រីស្ទផង* ***ឲ្យតែយើងទទួលរងទុក្ខជាមួយនឹងទ្រង់ចុះ ដើម្បីឲ្យបានដំកើងឡើងជាមួយនឹងទ្រង់ដែរ»*** (រ៉ូម ៨:១៦-១៧)។ គាត់ក៏បានប្រាប់គ្រីស្ទបរិស័ទទាំងអស់ដែរថា *«ត្រូវតែទ្រាំរងទុក្ខវេទនាជាច្រើន ទើបនឹងចូលទៅក្នុងនគរព្រះបាន»* (កិច្ចការ ១៤:២២)។

សាវកពេត្រុសបានលើកឡើងនូវចំណុចដូចគ្នានេះថា៖ *«ដូច្នេះ ដែលព្រះគ្រីស្ទទ្រង់បានរងទុក្ខក្នុងសាច់ឈាមជំនួសយើងរួចហើយ នោះត្រូវឲ្យអ្នករាល់គ្នាមានគំនិត*

*ដូច្នោះដែរ ទុកជាគ្រឿងការពារខ្លួន ដ្បិតអ្នកណាដែលបានរងទុក្ខក្នុងសាច់ឈាម នោះបានឈប់ខាងឯអំពើបាបហើយ ២ដើម្បីកុំឲ្យបង់ពេលដែលសល់ និងរស់នៅខាងសាច់ឈាម តាមតែសេចក្ដីប៉ងប្រាថ្នារបស់មនុស្សទៀតឡើយ គឺតាមបំណងព្រះហឫទ័យនៃព្រះវិញ»* (១ពេត្រុស ៤:១-២)។ លោកប៉ុលក៏បាននិយាយអំពីទុក្ខវេទនាផ្ទាល់ខ្លួនរបស់គាត់ និងការល្បួងដោយទាញគាត់ឲ្យសម្លឹងមើលទៅកាន់សុភមង្គលដែលគ្រាន់តែជាបណ្ដោះអាសន្ន។ លោកនិយាយថា *«ដ្បិតសេចក្ដីទុក្ខលំបាកយ៉ាងស្រាលរបស់យើងខ្ញុំ ដែលនៅតែមួយភ្លែតនេះ នោះបង្កើតឲ្យយើងខ្ញុំមានសិរីល្អយ៉ាងធ្ងន់លើសលប់ដ៏នៅអស់កល្បជានិច្ចវិញ ដោយយើងខ្ញុំមិនរាប់អានរបស់ដែលមើលឃើញឡើយ គឺរាប់អានតែរបស់ដែលមើលមិនឃើញវិញ ដ្បិតរបស់ដែលមើលឃើញ នោះស្ថិតស្ថេរមិនយូរប៉ុន្មានទេ តែឯរបស់ដែលមើលមិនឃើញ នោះនៅស្ថិតស្ថេរអស់កល្បជានិច្ចវិញ»* (២កូរិនថូស ៤:១៧-១៨)។ លោកប៉ុលថែមទាំងត្រេកអរចំពោះការរងទុក្ខរបស់គាត់ ពីព្រោះគាត់ដឹងថា ការរងទុក្ខទាំងអស់នោះនឹងធ្វើឲ្យជំនឿរបស់គាត់កាន់តែរឹងមាំ៖ *«មិនតែប៉ុណ្ណោះសោត យើងនៅតែអួតក្នុងកាលដែលមានទុក្ខលំបាកដែរ ដោយដឹងថា សេចក្ដីទុក្ខលំបាកបង្កើតឲ្យមានសេចក្ដីទ្រាំទ្រ សេចក្ដីទ្រាំទ្របង្កើតឲ្យមានសេចក្ដីស៊ាំថ្នឹក សេចក្ដីស៊ាំថ្នឹកបង្កើតឲ្យមានសេចក្ដីសង្ឃឹម»* (រ៉ូម ៥:៣-៤)។ ហេតុអ្វីបានជាគ្រូបង្រៀនចម្រុងចម្រើនស្ងាត់ស្ងៀមចំពោះខទាំងអស់នេះ?

## តើព្រះយេស៊ូវបានបង្គាប់ឲ្យយើងស្វែងរកនគរព្រះ ឬក៏រកផលប្រយោជន៍ខាងទ្រព្យសម្បត្តិ?

សូមស្ដាប់ព្រះយេស៊ូវជាព្រះអម្ចាស់របស់យើង៖

> *«គ្មានបាវណាដែលបំរើចៅហ្វាយ២បានទេ ពីព្រោះបាវនោះនឹងស្អប់១ ស្រឡាញ់១ ឬនឹងកាន់ខាង១ ហើយមើលងាយ១ ដូច្នេះ អ្នករាល់គ្នាក៏បំរើព្រះផង ទ្រព្យសម្បត្តិផង**ពុំបាន**ដែរ»* (លូកា ១៦:១៣)។

*«ដោយហេតុនេះបានជាខ្ញុំប្រាប់អ្នករាល់គ្នាថា កុំឲ្យខ្វល់ខ្វាយនឹងជីវិតដែលនឹងបរិភោគអ្វី ឬនឹងរូបកាយ ដែលនឹងស្លៀកពាក់អ្វីនោះឡើយ ឯជីវិត តើមិនវិសេសជាងចំណីអាហារ ហើយរូបកាយ តើមិនវិសេសជាងសំលៀកបំពាក់ ទេឬអី ចូរពិចារណាពីសត្វស្លាបនៅលើអាកាស វាមិនសាបព្រោះ មិនច្រូតកាត់ ឬប្រមូលដាក់ក្នុងជង្រុកផង តែព្រះវរបិតានៃអ្នក ដែលគង់នៅស្ថានសួគ៌ ទ្រង់ចិញ្ចឹមវា ឯអ្នករាល់គ្នា តើគ្មានដំឡៃលើសជាងសត្វទាំងនោះទេឬអី ចុះនៅក្នុងពួកអ្នករាល់គ្នា តើមានអ្នកឯណាដែលអាចនឹងបន្ថែមកំពស់ខ្លួន១ហត្ថដោយសារសេចក្តីខ្វល់ខ្វាយបានឬទេ ហើយពីដំណើរសំលៀកបំពាក់ តើអ្នករាល់គ្នាខំខ្វល់ខ្វាយធ្វើអ្វី ចូររំពឹងគិតតែពីផ្កាឈូកនៅក្នុងបឹង ដែលវាដុះជាយ៉ាងដូចម្តេច គឺវាមិននឿយហត់នឹងធ្វើការ ឬស្រាវរវៃទេ តែខ្ញុំប្រាប់អ្នករាល់គ្នាថា សូម្បីតែហ្លួងសាឡូម៉ូន ក្នុងគ្រាដែលមានគ្រប់ទាំងសេចក្តីរុងរឿងរបស់ទ្រង់ នោះទ្រង់មិនបានតែងអង្គ ដូចជាផ្កា១នោះផង រីឯតិណជាតិ ដែលដុះនៅវាលក្នុងថ្ងៃនេះ ហើយថ្ងៃស្អែកត្រូវគេដុតនៅជើងក្រាន បើព្រះទ្រង់តុបតែងស្មៅយ៉ាងដូច្នោះ នោះឱមនុស្សមានជំនឿតិចអើយ តើទ្រង់មិនតុបតែងឲ្យអ្នករាល់គ្នាលើសជាងទៅទៀតទេឬអី ដូច្នេះ កុំឲ្យខ្វល់ខ្វាយថា តើត្រូវបរិភោគអ្វី ឬស្លៀកពាក់អ្វីនោះឡើយ ដ្បិតគឺជាសាសន៍ដទៃទេតើ ដែលខំស្វែងរករបស់ទាំងនោះវិញ ឯព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌ ទ្រង់ជ្រាបហើយ ថាអ្នករាល់គ្នាត្រូវការនឹងរបស់ទាំងនោះដែរ។ **ចូរស្វែងរកនគរ និងសេចក្តីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង»*** (ម៉ាថាយ ៦:២៥-៣៣)។

**តើអ្វីជាគោលដៅនៃដំណឹងល្អចម្រុងចម្រើន និងគោលដៅនៃដំណឹងល្អពិត?**
តើអ្វីជាគោលដៅជីវិតរបស់អស់អ្នកដែលប្រើសាសនាដើម្បីការមានបាន និងសុខភាព? គោលដៅជីវិតរបស់ពួកគេ គឺដើម្បីតែមានសុខភាពល្អ និងទ្រព្យសម្បត្តិដែលនៅក្នុងជីវិតនេះប៉ុណ្ណោះ។ ហើយអ្នកដែលស្តាប់គ្រូទាំងនោះ ក៏មានគោលដៅជីវិតដូចគ្នាដែរ។ ប៉ុន្តែតើគោលដៅជីវិតរបស់គ្រីស្ទបរិស័ទគឺជាអ្វី? គឺដើម្បីស្គាល់ដល់ព្រះ ដើរតាមព្រះយេស៊ូវគ្រីស្ទ និងចំណាយទាំងជីវិត និងធនធានរបស់យើង ដើម្បីនាំដំណឹងល្អដល់អ្នកដទៃ។ តើព្រះយេស៊ូវបានប្រទានគំរូអ្វីខ្លះដល់យើងដើម្បីដើរតាម? *«ដ្បិតអ្នករាល់គ្នាបានស្គាល់ព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាហើយ ថាទោះបើទ្រង់ជា**សេដ្ឋី**ក៏ដោយ គង់តែទ្រង់បានត្រឡប់ជា**ក្រ** ដោយព្រោះអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបាន**មានឡើង** ដោយសារសេចក្តីកម្ររបស់ទ្រង់»* (២កូរិនថូស ៨:៩)។

ព្រះយេស៊ូវបានលះបង់នូវភាពស្តុកស្តម្ភ និងសុវត្ថិភាពទាំងអស់របស់ទ្រង់ ដើម្បីយាងមកសង្គ្រោះយើង ពីអំពើបាប និងស្ថាននរក ដើម្បីឲ្យយើងបានក្លាយជាអ្នកមានជាមួយព្រះអស់កល្បជានិច្ច។ ហើយទ្រង់បានបង្គាប់ឲ្យយើងធ្វើតាមគំរូរបស់ទ្រង់៖ យើងក៏ត្រូវតែក្លាយជាអ្នកក្រដែរ ដើម្បីឲ្យអ្នកដទៃក្លាយជាអ្នកមានក្នុងព្រះយេស៊ូវគ្រីស្ទ។ យើងអាចធ្វើដូចនេះតាមវិធីពីរយ៉ាង ដោយការចែករំលែកនូវទ្រព្យសម្បត្តិរបស់យើង ដើម្បីជួយដល់អ្នកក្រីក្រ និងដោយការចែករំលែកទ្រព្យសម្បត្តិរបស់យើងដល់អ្នកផ្សាយដំណឹងល្អ ដែលក្រុមជំនុំបញ្ជូនឲ្យទៅផ្សាយដំណឹងល្អនៅកន្លែងដែលមិនទាន់ឮ។

សូមកត់សម្គាល់នូវភាពខុសគ្នាធំៗរវាងគោលដៅនៃដំណឹងល្អពិត និងដំណឹងល្អចម្រុងចម្រើន៖

**គោលដៅនៃដំណឹងល្អពិត (២កូរិនថូស ៨:៩)**

ព្រះយេស៊ូវជាសេដ្ឋី

ទ្រង់បានក្លាយជាអ្នកក្រសម្រាប់យើង ...

ដើម្បីឲ្យយើងនឹងក្លាយជាសេដ្ឋីក្នុងព្រះគ្រីស្ទ ...

ដើម្បីឲ្យយើងក្លាយជាអ្នកក្រសម្រាប់មនុស្សឯទៀត ...

ដើម្បីឲ្យគេក្លាយជាសេដ្ឋីក្នុងព្រះយេស៊ូវ ...

ដើម្បីឲ្យគេក៏ក្លាយជាអ្នកក្រសម្រាប់អ្នកផ្សេងទៀត ...

ដើម្បីអ្នកផ្សេងទៀតនោះនឹងក្លាយជាសេដ្ឋីក្នុងព្រះយេស៊ូវ ...

។ល។ រហូតដល់ព្រះយេស៊ូវយាងមក។

**គោលដៅនៃដំណឹងល្អចម្រុងចម្រើន**

ព្រះយេស៊ូវជាសេដ្ឋី

ទ្រង់បានក្លាយជាអ្នកក្រសម្រាប់យើង...

ដើម្បីឲ្យយើងក្លាយជាសេដ្ឋី។

ចប់។

តើគ្រូចម្រុងចម្រើនបានធ្វើតាមគំរូរបស់ព្រះគ្រីស្ទ ដោយបានក្លាយជាអ្នកក្រ ដើម្បីឲ្យអ្នកដទៃក្លាយជាអ្នកមានក្នុងព្រះយេស៊ូវដែរឬទេ? ទេ ផ្ទុយទៅវិញ។ គ្រូចម្រុងចម្រើនទាំងនោះបានក្លាយជាអ្នកមាន ដោយសុំឲ្យពួកអ្នកក្រផ្តល់ប្រាក់ឲ្យពួកគេ។ នេះគឺជា បទគម្ពីរ ២កូរិនថូស ៨:៩ ម្តងទៀត ប៉ុន្តែខ្ញុំបានប្តូរពាក្យដើម្បីពិពណ៌នាអំពីគ្រូចម្រុងចម្រើនវិញ៖ «ដ្បិតអ្នកដឹងពីសេចក្តីលោភលន់របស់ គ្រូចម្រុងចម្រើនហើយថា ទោះបីពីមុនពួកគេក្រក៏ដោយ ពេលនេះពួកគេបានក្លាយជាសេដ្ឋីតាមរយៈដង្វាយពីជនក្រីក្រ ដើម្បីឲ្យអ្នកក្រីក្រ នឹងកាន់តែក្រ»។ យើងត្រូវសួរសំណួរនេះម្តងទៀត៖ ហេតុអ្វីបានជាគ្រូចម្រុងចម្រើន ដែលជាអ្នកមាន នៅតែបន្តសុំលុយពីមនុស្សសាមញ្ញទៀត?

## មុខពូថៅ 

តើគ្រូចម្រុងចម្រើនប្រើអ្វីធ្វើជាមុខពូថៅ ដើម្បីពុះយើងចេញពីសេចក្តីពិត? ពួកគេប្រើសេចក្តីសន្យាអំពី សុខភាពល្អ ហើយនិងភាពចម្រុងចម្រើន។ ពួកគេដឹងថាមនុស្សជាច្រើនត្រូវបានល្បួងដោយបាបលោភលន់ និងចង់មានចង់បាន មិនថាអ្នកជឿ ឬអ្នកមិនជឿទេ។ មនុស្សជាច្រើនត្រូវបានសង្កត់ដោយបំណុល និងជំងឺ។ ដូច្នេះគ្រូទាំងនេះ ទាក់ទាញអ្នកស្តាប់ដោយការសន្យាអំពី ទ្រព្យសម្បត្តិ និងសុខភាព។ មួយទៀត ពួកគេចូលចិត្តធ្វើឲ្យមនុស្សចាប់អារម្មណ៍ជាមួយនឹងអំណាចរបស់ពួកគេ លើវិញ្ញាណផ្សេងៗ ដូចជាគ្រូមន្តអាគមជាដើម។ កុំមានការភ្ញាក់ផ្អើលបើគ្រូចម្រុងចម្រើនទាំងនេះ ពេលខ្លះបង្រៀននូវអ្វីដែលត្រឹមត្រូវ ហើយថែមទាំងមានប្រយោជន៍ទៀតនោះ។ ប្រសិនបើគ្រូក្លែងក្លាយបង្រៀនសុទ្ធតែខុសឆ្គង នោះគ្មាននរណាជឿពួកគេឡើយ។ គឺដោយសារតែការបង្រៀនខុសឆ្គងរបស់ពួកគេត្រូវបានលាយបញ្ចូលគ្នាជាមួយនឹងការបង្រៀនពិត ដែលធ្វើឲ្យគ្រីស្ទបរិស័ទវង្វេង។

ក្រោយដែលគ្រូចម្រុងចម្រើនបានចាប់អ្នកស្តាប់ហើយ ពួកគេបន្ថែមការបង្រៀនខុសឆ្គងទៀត។ គ្រូចម្រុងចម្រើនខ្លះ បដិសេធគោលជំនឿនៃព្រះត្រៃឯក។ ខ្លះបង្រៀនថា ព្រះយេស៊ូវមិនបានលោះបាបរបស់យើងទាំងស្រុងនៅលើឈើឆ្កាងទេ។ ហើយស្ទើរតែទាំងអស់បង្រៀនថា យើងអាចបង្កើតភាពចម្រុងចម្រើន និងសុខភាពល្អដោយពាក្យសំដីខ្លាំងពូកែរបស់យើង ពីព្រោះយើងជាព្រះតូច។

## គ្រូបង្រៀនដែលបញ្ឆោរ

នៅគម្ពីរអេសាយ ៣០:៩-១០ ហោរាអេសាយបានបន្ទោសអ៊ីស្រាអែល ព្រោះគេចង់បានហោរាដែលប្រើពាក្យបញ្ឆោរ ជំនួសការពិត៖ *«ដ្បិតជនជាតិនេះគេនឹង*

*ចចេស ជាពួកកូនចៅភូតកុហក គឺជាកូនចៅ ដែលមិនព្រមផ្ទង់ចិត្តស្ដាប់ក្រឹត្យវិន័យរបស់ព្រះយេហូវ៉ាទេ ១០ គេប្រាប់ដល់ពួកមើលឆុតថា កុំឲ្យមើលឡើយ ហើយដល់ពួកហោរាថា កុំឲ្យទាយពីសេចក្ដីទៀងត្រង់ ឲ្យយើងស្ដាប់ឲ្យសោះ គឺត្រូវនិយាយពីសេចក្ដី**ស្រួលបួលវិញ** ត្រូវទាយជាសេចក្ដីភូតភរចុះ»*។ គ្រូចម្រុងចម្រើនដឹងថា អ្នកស្ដាប់របស់គេចង់ស្ដាប់ពាក្យបញ្ឆោរដូចជា៖

«ព្រះពេញចិត្តនឹងអ្នក មិនមែនក្រោធទេ»

«ព្រះចង់ឲ្យអ្នកក្លាយជាសេដ្ឋី»

«អ្នកជាព្រះតូចមួយ»

«អ្នកមានអំណាចបង្កើតភាពចម្រុងចម្រើនដោយគ្រាន់តែនិយាយ»

«អ្នកមិនមែនជាអ្នកមានបាបទេ»

តែគ្រូពីព្រះជាម្ចាស់ បង្រៀនសេចក្ដីពិតរបស់ព្រះ ដែលមានទាំង សេចក្ដីស្រឡាញ់នៃព្រះ និងភាពបរិសុទ្ធនៃព្រះ ទាំងព្រះជាសេចក្ដីស្រឡាញ់ និងព្រះជាពន្លឺ។ គ្រូដែលបញ្ឆរអ្នក ដោយពាក្យសំដីផ្អែមៗ មិនស្រឡាញ់អ្នកទេ ពួកគេចង់គ្រប់គ្រងអ្នក និងប្រើអ្នកសម្រាប់ប្រយោជន៍របស់គេ។

ចូរឈប់ស្ដាប់គ្រូក្លែងក្លាយនៅលើទូរទស្សន៍ និងអ៊ីនធឺណិត។ ចូរចូលជាសមាជិកនៅក្នុងក្រុមជំនុំដែលបង្រៀនទាំងព្រះជាពន្លឺផង ទាំងព្រះជាសេចក្ដីស្រឡាញ់ផង ជាក្រុមជំនុំដែលព្រមានអ្នកអំពីគ្រោះថ្នាក់ នៃចិត្តលោភលន់ ជាក្រុមជំនុំដែលនិយាយថា «អ្នកមិនមែនជាព្រះទេ មានតែព្រះទេដែលជាព្រះ» ជាក្រុមជំនុំដែលស្រឡាញ់អ្នករហូតដល់កែអ្នកដោយសេចក្ដីស្រឡាញ់នៅពេលអ្នកវង្វេង ជាក្រុមជំនុំដែលបង្រៀនគ្រប់ទាំងសេចក្ដីពិតរបស់ព្រះអង្គ មិនមែនគ្រាន់តែផ្នែកស្រួលនោះទេ ជាក្រុមជំនុំដែលមានអ្នកដឹកនាំសុចរិត ស្រឡាញ់ និងជាគំរូដល់ហ្វូងចៀម។

តើលោកអ្នកបានឃើញថា ជីវិតរបស់ព្រះយេស៊ូវនៅក្នុងកណ្ឌម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាន គឺខុសគ្នាពីជីវិតរបស់គ្រូចម្រុងចម្រើនទាំងនោះទេ?! ត្រូវហើយ ព្រះយេស៊ូវបានប្រោសមនុស្សរាប់ពាន់នាក់ ដោយសេចក្តីស្រឡាញ់ ចំពោះពួកគេ ប៉ុន្តែទ្រង់មិនបានសង្កត់ធ្ងន់លើសុខភាព និងទ្រព្យសម្បត្តិនៅក្នុងសេចក្តីបង្រៀនរបស់ទ្រង់នោះឡើយ។ ផ្ទុយទៅវិញទ្រង់ បានព្រមានមនុស្សគ្រប់គ្នា អំពីគ្រោះថ្នាក់នៃការស្រឡាញ់លុយ និងទ្រព្យសម្បត្តិ ហើយទ្រង់ផ្ទាល់បានរស់នៅក្នុងជីវិតដ៏រាបទាប និងស្តាប់ស្គាល់។ ប្រសិនបើគ្រូអធិប្បាយមិនសង្កត់ធ្ងន់លើចំណុចដូចគ្នា នឹងការដែលព្រះយេស៊ូវ និងពួកសាវកបានសង្កត់ធ្ងន់ទេ នោះគាត់មុខជាគ្រូក្លែងក្លាយហើយ។ សូមកុំអនុញ្ញាតឲ្យគ្រូក្លែងក្លាយនេះចូលក្នុងផ្ទះតាមរយៈទូរស័ព្ទ ឬទូរទស្សន៍របស់អ្នកឡើយ។ សូមចាំពី ២យ៉ូហាន ខ ១០-១១។

---

## ពាក្យផ្ទាល់ខ្លួនរបស់គ្រូចម្រុងចម្រើន

សូមស្តាប់ពាក្យសម្តីផ្ទាល់របស់គ្រូចម្រុងចម្រើន ការឆ្លើយតបរបស់ខ្ញុំនៅក្នុងឃ្នាប[ ]។

**ចយ ម៉ៃយើ** (Joyce Meyer)

លោកស្រី ចយ ម៉ៃយើ បាននិយាយថា «ខ្ញុំមិនឈប់ធ្វើបាបទេ ទាល់តែខ្ញុំដឹង...ថា ខ្ញុំមិនមែនជាមនុស្សមានបាបទៀតទេ»។

> [ប៉ុន្តែសាវក យ៉ូហាននិយាយថា អស់អ្នកដែលនិយាយថា ខ្លួនគ្មានបាបសោះ នោះឈ្មោះថាបញ្ឆោតដល់ខ្លួន ហើយសេចក្តីពិតមិនស្ថិតនៅក្នុងពួកគេទេ (១យ៉ូហាន ១:៨)]។

នៅក្នុងសៀវភៅមួយរបស់គាត់ ចយ ម៉ៃយើ បានបង្រៀនថា ការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង មិនបានសងថ្លៃអំពើបាបរបស់យើងទាំងស្រុងនោះទេ ប៉ុន្តែបន្ទាប់ពីការសុគត ទ្រង់ត្រូវទៅស្ថាននរក ដើម្បីទទួលទារុណកម្ម ពីសាតាំង និងអារក្ស។ បន្ទាប់ពីនោះព្រះយេស៊ូវបានកើត

ជាថ្មី! គាត់បានសរសេរថា «ក្នុងអំឡុងពេលនោះទ្រង់ [ព្រះយេស៊ូវ] បានចូលស្ថាននរក ជាកន្លែងដែលអ្នក និងខ្ញុំសមនឹងទៅ (ស្របច្បាប់) ដោយសារអំពើបាបរបស់យើង...ទ្រង់បានបង់ថ្លៃលោះនៅទីនោះ... **ព្រះយេស៊ូវបានបង់ថ្លៃនៅលើឈើឆ្កាងផង និងនៅស្ថាននរកផង**... [បន្ទាប់មក] ទ្រង់ត្រូវបានប្រោសឲ្យរស់ពីសុគតឡើងវិញ ដែល**ជាមនុស្សដំបូងដែលបានកើតជាថ្មី**»។ ចយ ម៉ៃយើ ក៏បាននិយាយថា «អ្នកមិនអាចទៅស្ថានសួគ៌បានទេ លុះត្រាតែអ្នកជឿដោយអស់ពីចិត្តថា ព្រះយេស៊ូវ**បានទទួលទោសជំនួសអ្នកនៅស្ថាននរក**»។

[ប៉ុន្តែ១ពេត្រុស ២:២៤ និយាយថា *«ទ្រង់បានផ្ទុកអំពើបាបរបស់យើងរាល់គ្នា នៅលើរូបអង្គទ្រង់ ជាប់លើ**ឈើឆ្កាង**...»*។ មិនត្រឹមតែប៉ុណ្ណោះ នៅក្នុងលូកា ២៣:៤៣ ព្រះយេស៊ូវបានសន្យាជាមួយចោរនៅលើឈើឆ្កាងថា *«**ថ្ងៃនេះ** អ្នកនឹងនៅក្នុងស្ថានបរមសុខជាមួយនឹងខ្ញុំដែរ»* មិនមែន «ថ្ងៃនេះខ្ញុំនឹងទៅនរកបីថ្ងៃ ដើម្បីទទួលទារុណកម្ម អំពើបាបរបស់អ្នក» នោះទេ។]

ចយ ម៉ៃយើ បាននិយាយថា នៅពេលដែលព្រះយេស៊ូវបានយកអំពើបាបរបស់យើង នោះទ្រង់លែងជាព្រះរាជបុត្រានៃព្រះទៀត មួយរយៈនោះ៖ «ទ្រង់ [ព្រះយេស៊ូវ] អាចជួយខ្លួនឯងរហូតដល់ចំណុចដែលទ្រង់និយាយថា <ទូលបង្គំសូមថ្វាយវិញ្ញាណទូលបង្គំដល់ព្រះហស្តទ្រង់>។ នៅពេលនោះទ្រង់មិនអាចធ្វើអ្វីសម្រាប់ខ្លួនឯងបានទៀតទេ។ ទ្រង់បានក្លាយជាបាប ទ្រង់**លែងជាព្រះរាជបុត្រានៃព្រះហើយ**។ ទ្រង់ជាបាប»។

[ប៉ុន្តែវាមិនអាចទៅរួចទេ ដែលព្រះរាជបុត្រានៃព្រះ លែងជាព្រះរាជបុត្រានៃព្រះ សូម្បីតែមួយភ្លែត។ នេះគឺជាការប្រមាថ។]

ចយ ម៉ៃយើ បាននិយាយថា «**ពាក្យសម្ដីគឺជាធុងថាមពល**...ខ្ញុំកំពុងនិយាយអំពី<ការហៅអ្វីដែលមិនមាន ថាមាន> [រ៉ូម ៤:១៧] ហើយទាយអំពីឆ្អឹងស្ងួត ដែលងាប់នៅក្នុងជីវិតរបស់អ្នកថា <ឱឆ្អឹងស្ងួតអើយ ចូរស្ដាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់>។ ប្រហែលជាអ្នកត្រូវនិយាយទៅកាន់ [គណនីធនាគារ] របស់អ្នកថា <អូ គណនីចូរស្ដាប់ព្រះបន្ទូលរបស់ព្រះអម្ចាស់ ឯងនឹងមិននៅទទេរហូតឡើយ>»។

[ប៉ុន្តែនៅក្នុង រ៉ូម ៤:១៧ គឺព្រះផ្ទាល់ដែល *«ប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ ទាំងមានព្រះបន្ទូលពីរបស់ដែលគ្មាន ទុកដូចជាមាន»* មិនមែនយើងទេ។ មួយទៀត ប្រសិនបើយើង

អាចបញ្ជាឲ្យគណនីធនាគាររបស់យើងពេញបាន ហេតុអ្វី ចយ ម៉ៃយើ មិនបញ្ជាឲ្យគណនីធនាគារផ្ទាល់របស់គាត់ពេញ ដើម្បីគាត់អាចឈប់សុំឲ្យមនុស្សផ្ញើប្រាក់ទៅគាត់?]

ចយ ម៉ៃយើ បាននិយាយថា «ហេតុអ្វីបានជាមនុស្សប្រកែក... នៅពេលព្រះហៅមនុស្សរបស់ទ្រង់ថាជា **ព្រះតូច**?»

[គាត់កំពុងនិយាយអំពីសេចក្ដីបង្រៀនដែលគ្រូចម្រុងចម្រើនចូលចិត្តបង្រៀនថា ព្រះបានធ្វើឲ្យគ្រីស្ទបរិស័ទទៅជា «ព្រះតូច» ដែលមានអំណាចបង្កើតអ្វីៗតាមពាក្យរបស់យើង។ នេះគឺជាការប្រមាថ។]

ចយ ម៉ៃយើ បាននិយាយថា «ទាល់តែអ្នកអធិស្ឋាន ទើបព្រះអាចធ្វើការបាន»។

[ប៉ុន្តែព្រះជាម្ចាស់មានពេញដោយអំណាចព្រះចេស្ដា និងអធិបតេយ្យភាពបំផុត។ ទ្រង់អាចធ្វើអ្វីដែលទ្រង់ចង់ធ្វើ នៅពេលណាដែលទ្រង់ចង់ធ្វើ។ សូមស្ដាប់គម្ពីរដានីយ៉ែល ៤:៣៤-៣៥៖ *«...អំណាចគ្រប់គ្រងរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាប ហើយរាជ្យទ្រង់ក៏នៅអស់ទាំងដំណមនុស្សតរៀងទៅ ឯអស់ទាំងមនុស្សលោកក៏រាប់ទុកជាឥតការទទេ ទ្រង់ធ្វើតាមតែព្រះហឫទ័យក្នុងពួកពលបរិវារនៃស្ថានសួគ៌ ហើយនៅកណ្ដាលពួកមនុស្សលោកផង ឥតមានអ្នកណាអាចនឹងឃាត់ទប់ព្រះហស្តទ្រង់ ឬនឹងទូលសួរទ្រង់ថា <ទ្រង់ធ្វើអ្វីដូច្នេះបានឡើយ>»*]

**ចូល អូស្ទីន** (Joel Osteen)

លោក ចូល អូស្ទីន បាននិយាយថា «[ព្រះ] បានមានបន្ទូលថា <អ័ដាម អ្នកណាប្រាប់អ្នកថាអ្នកនៅអាក្រាត?> និយាយម្យ៉ាងទៀត តើអ្នកណាប្រាប់អ្នកថា មានអ្វីខុសនៅក្នុងអ្នក?...នោះគឺជាការកុហកមកពីសត្រូវ អ្នកត្រូវបដិសេធគំនិតទាំងនោះ ហើយស្វែងយល់ពីអ្វីដែលព្រះមានបន្ទូលអំពីអ្នក»។

[យោងតាម ចូល អូស្ទីន អ័ដាម និងអេវ៉ាគួរតែបដិសេធគំនិតដែលថា មានអ្វីខុសចំពោះពួកគាត់ បន្ទាប់ពីពួកគាត់បានធ្វើបាប។ ប៉ុន្តែការពិត គឺមានកំហុសធ្ងន់យ៉ាងខ្លាំងចំពោះពួកគាត់ គឺពួកគាត់បានចូលរួមជាមួយសាតាំងក្នុងការបះបោររបស់វា ហើយឥឡូវនេះពួកគាត់ត្រូវបានកាត់ផ្ដាច់ពីព្រះ ហើយបានបាត់បង់។]

លោក គ្រីស វ៉លលេក (Chris Wallace) នៃសារព័ត៌មាន Fox News បានសួរលោក ចូល អូស្ទីន ថា «តើពួកមរមនជា គ្រីស្ទបរិស័ទពិតឬ?» លោក អូស្ទីន បាននិយាយថា «ខ្ញុំគិតថា ពួកគេ គឺជាគ្រីស្ទបរិស័ទពិត»។ នៅកន្លែងផ្សេងទៀតគាត់បាននិយាយថា «សាសនាមរមន ខុសគ្នាបន្តិចបន្តួច ប៉ុន្តែខ្ញុំនៅតែឃើញថា ពួកគេគឺជាបងប្អូននៅក្នុងព្រះគ្រីស្ទ»។

> [សាសនាមរមន គឺជាសាសនាខុសគ្នាទាំងស្រុង ពីគ្រីស្ទសាសនាពិត។ សូមមើលអត្ថបទពីសាសនាមរមន]

នៅក្នុងបទសម្ភាសន៍មួយ គេសួរ ចូល អូស្ទីន ថា តើមនុស្សដែលស្រឡាញ់ភេទដូចគ្នា ហើយនៅតែបន្តប្រព្រឹត្តបាបនោះ ពួកគេនឹងត្រូវព្រះទទួលឲ្យចូលស្ថានសួគ៌ដែរឬទេ? គាត់ឆ្លើយថា «ខ្ញុំជឿថា ពួកគេនឹងបានចូល»។

> [ប៉ុន្តែតើសាវកប៉ុលបាននិយាយអ្វីខ្លះ នៅក្នុង១កូរិនថូស ៦:៩-១១ (KSV)? តើយើងគួរជឿចូល អូស្ទីន ឬជឿសាវកប៉ុល?]

ចូល អូស្ទីន បាននិយាយថា «នៅពេលអ្នកក្រីក្រ អត់ និងបានជោគជ័យ... វាមិននាំមកនូវកិត្តិយសដល់ព្រះទេ ... ចូរស្តាប់ នៅពេលអ្នកមើលទៅល្អ ស្លៀកពាក់ល្អ រស់នៅកន្លែងស្អាតពូកែក្នុងអាជីពរបស់អ្នក មានចិត្តសប្បុរសជាមួយអ្នកដទៃ នោះហើយនាំមកនូវស្នាមញញឹមដល់ព្រះភក្ត្ររបស់ព្រះ។ ទ្រង់រីករាយ ដើម្បីធ្វើឲ្យអ្នករីកចម្រើនឡើង...ព្រះយេស៊ូវបានយាងមក ដើម្បីយើងអាចរស់នៅក្នុងជីវិតបរិបូរណ៍។ យើងតំណាងឲ្យព្រះដ៏មានមហិទ្ធិឫទ្ធិនៅលើផែនដីនេះ។ យើងគួរតែធ្វើជាគំរូនៃសេចក្តីល្អរបស់ទ្រង់៖ មានពរខ្លាំង មានភាពរុងរឿងខ្លាំង មានចិត្តសប្បុរសខ្លាំង មានអំណរខ្លាំង **ដែលធ្វើឲ្យអ្នកផ្សេងទៀតចង់បានអ្វីដែលយើងមាន**...»។

> [ប៉ុន្តែព្រះគម្ពីរមិនដែលនិយាយថា យើងទាក់ទាញមនុស្សឲ្យមករកដំណឹងល្អ នៅពេលយើង «មើលទៅល្អ ស្លៀកពាក់ល្អ ហើយរស់នៅកន្លែងស្អាត»នោះទេ។ តែផ្ទុយទៅវិញ គឺនៅពេលដែលយើងរស់នៅក្នុងជីវិតដែលមានសេចក្តីស្រឡាញ់ ការលះបង់ និងការផ្សាយដំណឹងល្អ។ សូមស្តាប់សាវកប៉ុល៖ *«ដោយមានកេរ្តិ៍ឈ្មោះ ហើយត្រូវអាប់ឱន ដោយគេនិយាយអាក្រក់ ឬល្អក្តី ទុកដូចជាមនុស្សកំភូត តែពិតត្រង់ទេ ដូចជាគ្មានអ្នកណាស្គាល់យើងខ្ញុំ តែមនុស្សទាំងអស់បានស្គាល់វិញ ដូចជាហៀបនឹងស្លាប់ តែមើល យើងខ្ញុំរស់ទេ ដូចជាត្រូវវាយផ្ចាល តែមិនបានដល់ស្លាប់ទេ ដូចជាមានសេចក្តីព្រួយ តែចេះតែបាន*

*សប្បាយវិញ ដូចជាទ័លក្រ តែកំពុងតែចំរើនដល់មនុស្សជាច្រើន ដូចជាគ្មានអ្វីសោះ តែមានគ្រប់ទាំងអស់វិញ»* (២កូរិនថូស ៦:៨-១០)។ ភាពអំណរក្នុងការរងទុក្ខវេទនា គឺជាជីវិតដែលបានធ្វើឲ្យមនុស្សរាប់លាននាក់រកព្រះសម័យដំបូងនៃក្រុមជំនុំ។]

លោក ឡារី឵ ឃីង (Larry King) បានសួរលោក ចូល អូស្ទីន នៅក្នុងបទសម្ភាសន៍តាមទូរទស្សន៍ថា តើគាត់ប្រើពាក្យថា «មនុស្សមានបាប» នៅក្នុងការអធិប្បាយរបស់គាត់ទេ។ គាត់បាននិយាយថា «ខ្ញុំមិនប្រើវាទេ [ពាក្យថា មនុស្សមានបាប]។ ... ប៉ុន្តែមនុស្សភាគច្រើនដឹងរួចមកហើយថា ខ្លួនកំពុងធ្វើអ្វីខុស។ នៅពេលពួកគេមកក្រុមជំនុំ ខ្ញុំចង់ប្រាប់ពួកគេថា អ្នកអាចផ្លាស់ប្តូរបាន»។

[ប៉ុន្តែការប្រាប់នរណាម្នាក់ថា «អ្នកអាចផ្លាស់ប្តូរបាន» នោះមិនមែនជាដំណឹងល្អទេ។ វាជាដំណឹងអាក្រក់ ព្រោះយើងគ្មានសមត្ថភាពផ្លាស់ប្តូរទេ។ យើងត្រូវការចិត្តថ្មីតាមរយៈដំណឹងល្អ អំពីការសុគត និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ។ ហើយផ្នែកមួយនៃដំណឹងល្អ គឺជាដំណឹងអាក្រក់ ដែលយើងជាមនុស្សមានបាប។]

លោក ចូល អូស្ទីន បាននិយាយថា «ព្រះបានធ្វើអ្វីគ្រប់យ៉ាង ដែលទ្រង់នឹងធ្វើរួចទៅហើយ។ ឥឡូវនេះ បាល់ស្ថិតនៅខាងអ្នកហើយ។ ប្រសិនបើអ្នកចង់បានភាពជោគជ័យ ប្រសិនបើអ្នកចង់បានប្រាជ្ញា បើអ្នកចង់មានភាពចម្រុងចម្រើន និងមានសុខភាពល្អ អ្នកនឹងត្រូវធ្វើច្រើនជាងការគិត ហើយការជឿ។ អ្នកត្រូវតែប្រកាសពាក្យសម្តីដោយក្លាហាន នូវពាក្យនៃជំនឿ និងជ័យជំនះ លើខ្លួនអ្នក និងគ្រួសាររបស់អ្នក»។

[ដូចគ្រូចម្រុងចម្រើនទាំងអស់ដែរ ចូល អូស្ទីន បង្រៀនថា យើងអាចបង្កើតភាពចម្រុងចម្រើន និងសុខភាពល្អ ដោយការនិយាយពាក្យសំដីពិសេស ដូចជាព្រះបានបង្កើតសកលលោកដោយការមានបន្ទូលដែរ។]

## គ្រូចម្រុងចម្រើនផ្សេងៗ

«វាមិនមែនជា<ជំពូក និងខ> គ្រប់ពេលទេ។ អាម៉ែន? ចូរមើលរាងកាយរបស់អ្នក ហើយនិយាយថា <ខ្ញុំជឿថា ខ្ញុំមានរាងកាយមានសុខភាពល្អបំផុត អាយុ ៥០ឆ្នាំ> អ្នកអាចនិយាយដូច្នេះបាន! វាមិនមែនជា<ជំពូក និងខ> គ្រប់ពេលទេ...តើអ្នកជឿទេ? បើអ៊ីចឹង ចូរប្រកាសទៅ»។ **យ៉ូសែប ព្រីនស៍** (Joseph Prince)

«ចូរប្រកាសទៅ! ទោះអ្នកមិនជឿក៏ប្រកាសចុះ! អ្នកមានអាយុហុកសិបឆ្នាំ ហើយអ្នកមើលទៅក្នុងកញ្ចក់ ហើយឃើញស្នាមជ្រួញ។ តែខ្ញុំឃើញអ្នកគ្មានស្នាមជ្រួញសោះ! អាម៉ែន? អាម៉ែន!»។ **យ៉ូសែប ព្រីនស៍**

«នៅពេលដែលពួកគេចេញមក ព្រះអម្ចាស់អើយ ដើម្បីសាបព្រោះ ព្រះវរបិតា ដោះលែងអំណាចលើពួកគេ ដើម្បីយក ដើម្បីបង្កើត ដើម្បីទទួលភាពចម្រុងចម្រើនក្នុងព្រះនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ»។ **យ៉ូសែប ព្រីនស៍**

«យើងគឺជាព្រះតូច»។ គ្រីហ្វឡូ ដុល្លារ(Creflo Dollar) ខេននែត ហេហ្គិន (Kenneth Hagin) បេននី ហ៊ិន (Benny Hinn) ផឡា ហ្វៃត (Paula White)។ល។

«ព្រះយេស៊ូវបានកើតជាថ្មី»។ ខេននែត ហេហ្គិន (Kenneth Hagin), ចយ ម៉ៃយើ (Joyce Meyer), ប៊ិល ចនសុន (Bill Johnson), ខេននែត កូពឡាន (Kenneth Copeland)។

«ព្រះបានយាងមកពីស្ថានសួគ៌ ហើយបានក្លាយជាមនុស្ស។ [ទ្រង់] បានធ្វើឲ្យមនុស្សទៅជាព្រះតូចៗ។ [បន្ទាប់មក] ទ្រង់បានត្រឡប់ទៅស្ថានសួគ៌វិញក្នុងភាពជាមនុស្ស។ ទ្រង់ប្រឈមមុខនឹងព្រះវរបិតាក្នុងភាពជាមនុស្ស។ តែខ្ញុំប្រឈមមុខនឹងអារក្សជាព្រះរាជបុត្រានៃព្រះ... ខ្ញុំជាមនុស្សព្រះ»។ បេននី ហ៊ិន (Benny Hinn)

«ភាពក្រីក្រ គឺមកពីអារក្សសាតាំង ឯព្រះជាម្ចាស់ចង់ឲ្យគ្រីស្ទបរិស័ទទាំងអស់មានភាពចម្រុងចម្រើន»។ បេននី ហ៊ិន

«ព្រះនឹងមិនធ្វើអ្វីឡើយ លុះត្រាតែខ្ញុំនិយាយ»។ បេននី ហ៊ិន

«អ្នកណាប្រាប់អ្នកឲ្យ លះបង់ខ្លួនឯង គឺមកពីសាតាំង»។ ផឡា ហ្វៃត (Paula White)

> [ប៉ុន្តែព្រះយេស៊ូវទ្រង់មានបន្ទូលថា *«បើអ្នកណាចង់មកតាមខ្ញុំ នោះត្រូវឲ្យលះកាត់ចិត្តខ្លួនឯងចោលចេញ ហើយផ្ទុកឈើឆ្កាងខ្លួនមកតាមខ្ញុំចុះ»* (ម៉ាថាយ ១៦:២៤)]

«ខ្ញុំចង់ឲ្យ អ្នកបានឮពីព្រះ។ អ្នកនឹងសរសេរមូលប្បទានប័ត្ររបស់អ្នកទៅឲ្យក្រុម ផឡា ហ្វៃត (Paula White)។ ប្រសិនបើព្រះប្រាប់អ្នកឲ្យផ្តល់ ១២.៩៩ ដុល្លារ ធ្វើវាចុះ។ អ្វីក៏ដោយដែលព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលមកកាន់អ្នក»។ ផឡា ហ្វៃត

«មានអំណាចនៃការបង្កើតនៅក្នុងមាត់របស់អ្នកឥឡូវនេះ ព្រះបានមានបន្ទូល ហើយបង្កើតសកលលោក។ អ្នកក៏មានអំណាច ដើម្បីនិយាយនិងបង្កើតជីវិត និងសេចក្តីស្លាប់បាន! បើអ្នកជឿលើព្រះ អ្នកអាចបង្កើតអ្វីៗនៅក្នុងជីវិតរបស់អ្នកបាន»។ ផឡា ហ្វៃត

> [ប្រសិនបើនេះជាការពិត ហេតុអ្វីបានជា ផឡា ហ្វៃត នៅតែសុំឲ្យមនុស្សផ្ញើប្រាក់ដង្វាយទៅគាត់?]

«ខ្ញុំចង់ឲ្យ អ្នកដឹងអ្វីមួយ៖ អ័ដាមនៅក្នុងសួនអេដែន គឺជាព្រះជាម្ចាស់ដែលសម្តែងក្នុងភាពជាសាច់ឈាម»។ «អ័ដាមគឺដូចជាព្រះ...ដូចគ្នានឹងព្រះយេស៊ូវដែរ នៅពេលទ្រង់មកផែនដី» ខេននែត កូពឡាន (Kenneth Copeland)។

«ការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង មិនគ្រប់គ្រាន់ដើម្បីសង្គ្រោះយើងទេ»។ ខេននែត កូពឡាន

—ការដកស្រង់មកពី (http://www.letusreason.org/Wf23.htm)

## ធនធានដែលគួរទុកចិត្ត៖

plovpit.com/the-heretical-teaching-of-joseph-prince/
plovpit.com/prosperity-gospel/
www.youtube.com/watch?v=oiCMNT2JrE4&t=143s



*ចូល អូស្ទីន*



*យ៉ូសែប ព្រីនស៍*



*ចយ ម៉ៃយើ*

# ក្រុមជំនុំសាវកថ្មី

## New Apostolic Church

## ក្រុងស៊ូរិច ប្រទេសស្វីស

### ប្រវត្តិ

ក្រុមជំនុំសាវកថ្មីត្រូវបានបង្កើតឡើងនៅប្រទេសអាឡឺម៉ង់ក្នុងឆ្នាំ ១៨៦៣។ ដូចជាចលនាសាសនាថ្មីដទៃទៀតដែរ អ្នកបង្កើតក្រុមជំនុំសាវកថ្មីនេះ បានប្រកាសថា ក្រុមជំនុំគ្រីស្ទបរិស័ទទាំងអស់បានវង្វេងចេញពីគ្រីស្ទសាសនាដើម ហើយឥឡូវនេះ ព្រះបានជ្រើសរើសពួកសាវកថ្មី ដើម្បីនាំគ្រីស្ទសាសនា ត្រឡប់ទៅផែនការដើមរបស់ព្រះវិញ។ ជាពិសេសពួកគេជឿថា ក្រុមជំនុំពិត ត្រូវតែដឹកនាំដោយពួកសាវក ដែលជាអ្នកស្នងតំណែង ពីសាវកដើមរបស់ព្រះយេស៊ូវគ្រីស្ទ។ ពួកគេបានអះអាងថា ក្នុងរយៈពេល ១៨០០ ឆ្នាំ ចាប់តាំងពីសាវកចុងក្រោយ គឺយ៉ូហានបានស្លាប់នៅសតវត្សរ៍ទី១ គ្មានក្រុមជំនុំណាមានសាវកពិតទេ។ តែឥឡូវនេះ ទីបំផុត តាមរយៈក្រុមជំនុំសាវកថ្មី ក្រុមជំនុំរបស់ព្រះគ្រីស្ទនឹងមានសាវកឡើងវិញ ដូចក្រុមជំនុំដើម។ ក្រុមជំនុំសាវកថ្មីអះអាងថា មានតែពួកសាវករបស់ពួកគេប៉ុណ្ណោះ ដែលមានសិទ្ធិអត់ទោសចំពោះអំពើបាប និងធ្វើបុណ្យជ្រមុជទឹកដោយព្រះវិញ្ញាណបរិសុទ្ធ។ ពួកគេអះអាងថា ជាក្រុមជំនុំតែមួយគត់ ដែលអាចរៀបចំគ្រីស្ទបរិស័ទ ឲ្យបានត្រឹមត្រូវ ដើម្បីទទួលការយាងមកលើកទីពីររបស់ព្រះគ្រីស្ទ។

ក្រុមជំនុំសាវកថ្មីបានរីករាលដាលពីប្រទេសអាឡឺម៉ង់ទៅកាន់ប្រទេសជិតខាងនៅទ្វីបអឺរ៉ុប ហើយបន្ទាប់មកទៅដល់អាហ្វ្រិកខាងត្បូង អូស្ត្រាលី និងឥណ្ឌូណេស៊ី។

ឥឡូវនេះ ពួកគេនៅក្នុងប្រទេសរាប់សិប ហើយអះអាងថា មានសមាជិក ៩ លាននាក់នៅទូទាំងពិភពលោក។

## ស្នាមប្រឡាក់បីក្នុងប្រវត្តិសាស្ត្ររបស់ក្រុមជំនុំសាវកថ្មី

១. នៅពេលដែលហ៊ីត្លែរគ្រប់គ្រងប្រទេសអាឡឺម៉ង់ គាត់បានបង្ខំឲ្យក្រុមជំនុំទាំងអស់នៅពេលបញ្ឈប់កម្មវិធីថ្វាយបង្គំត្រូវនិយាយថា «ហែល ហ៊ីត្លែរ» (Heil Hitler)។ ដូច្នេះ ក្រុមជំនុំជាច្រើនបានបដិសេធមិនព្រមធ្វើតាម ហើយត្រូវគេបិទ។ គួរឲ្យស្ដាយណាស់ ក្រុមជំនុំសាវកថ្មីបានសម្របសម្រួលជាមួយពួកណាស៊ីស ដូច្នេះហ៊ីត្លែរបានអនុញ្ញាតឲ្យពួកគេនៅតែបើកបន្ត។ នេះគឺជាស្នាមប្រឡាក់ដ៏គួរឲ្យអាម៉ាស់មួយនៅក្នុងប្រវត្តិសាស្ត្រ នៃក្រុមជំនុំនេះតាំងពីពេលនោះមក។

២. ស្នាមប្រឡាក់គួរឲ្យខ្មាសអៀនមួយទៀត បានកើតឡើងនៅថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ១៩៥១។ «មេសាវក» នៃក្រុមជំនុំសាវកថ្មី ឈ្មោះ ជេជី ប៊ីសសវ (J.G. Bischoff) បានប្រកាសថា ព្រះបានបើកសម្ដែងដល់គាត់ថា គាត់នឹងមិនស្លាប់ទេ រហូតដល់ការយាងមកលើកទីពីររបស់ព្រះគ្រីស្ទ។ គាត់ក៏បានបង្ខំឲ្យក្រុមជំនុំរបស់គាត់ទាំងអស់ជឿ និងបង្រៀនទំនាយនេះ។ នៅឆ្នាំ ១៩៥៤ ទំនាយនេះថែមទាំងបានក្លាយជាផ្នែកមួយនៃគោលលទ្ធិផ្លូវការរបស់ក្រុមជំនុំសាវកថ្មី។ អ្នកដឹកនាំជាច្រើនត្រូវបានបណ្ដេញចេញពីនិកាយ ដោយសារការបដិសេធមិនទទួលយកទំនាយនេះ។ ប៉ុន្តែលោក ជេជី ប៊ីសសវ បានស្លាប់នៅថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ១៩៦០ ហើយព្រះគ្រីស្ទមិនបានយាងមកវិញទេ។ វាគឺជាទំនាយខុសឆ្គង។ សមាជិករាប់ពាន់នាក់បានខកចិត្ត ហើយចាកចេញពីក្រុមជំនុំនៅពេលនោះ។

៣. ស្នាមប្រឡាក់ទី៣ នៅក្នុងប្រវត្តិសាស្ត្រនៃក្រុមជំនុំសាវកថ្មី ជាស្នាមប្រឡាក់គួរឲ្យខ្មាសជាងគេ។ នៅឆ្នាំ ១៩៨៦ «មេសាវក» ឈ្មោះ ហាន់ អួរវ៉ាយឡឺ (Hans Urwyler) បានប្រកាសថា ក្រុមជំនុំសាវកថ្មីនឹងលែងបង្រៀនតាមគម្ពីរថា ការ

ស្រឡាញ់ភេទដូចគ្នា គឺជាអំពើបាប។ ពួកគេបាននិយាយថា អ្នកស្រឡាញ់ភេទដូចគ្នា អាចចូលជាសមាជិកដោយមិនចាំបាច់ប្រែចិត្តពីការរួមភេទ ភេទដូចគ្នាឡើយ។ គេក៏អាចទទួលពិធីលៀងព្រះអម្ចាស់ និងបង្រៀនសាលាថ្ងៃអាទិត្យបាន។ ក្រុមជំនុំថែមទាំងធ្វើពិធីឲ្យពរពិសេស ដល់គូស្វាមីភរិយាភេទដូចគ្នា ដែលបាន «រៀបការ»តាមផ្លូវច្បាប់។

«មេសាវក» នៃក្រុមជំនុំសាវកថ្មីបានការពារការសម្រេចចិត្តនេះ ដោយបង្ខំបទគម្ពីរ ១កូរិនថូស ៦:៩-១០ ដើម្បីធ្វើឲ្យវានិយាយផ្ទុយពីអ្វីដែលសាវកប៉ុលមានបំណង។ នៅក្នុងខនោះសាវក ប៉ុលកំពុងប្រាប់យើងពីអ្នកណាដែលមិនអាចចូលនគរព្រះបាន។ ប៉ុលបានបង្រៀនថា *«បងប្អូនមិនជ្រាបទេឬថា អ្នកប្រព្រឹត្តអំពើទុច្ចរិត ពុំអាចទទួលព្រះរាជ្យ ព្រះជាម្ចាស់ទុកជាមត៌កបានឡើយ! សូមបងប្អូនកុំយល់ច្រឡំអោយសោះ អស់អ្នកដែលប្រព្រឹត្តអំពើប្រាសចាកសីលធម៌ ពួកថ្វាយបង្គំព្រះក្លែងក្លាយ ពួកមានសហាយស្មន់ ពួកជនពាលពួកអ្នករួមសង្វាសនឹងភេទដូចគ្នា [10] ពួកចោរប្លន់ ពួកលោភលន់ចង់បានទ្រព្យគេ ពួកប្រមឹក ពួកជេរប្រមាថ ពួកប្លន់យកទ្រព្យគេ ពុំអាចទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់ទុកជាមត៌កបានឡើយ។ [11] កាលពីដើម បងប្អូនខ្លះក៏ជាមនុស្សប្រភេទនោះដែរ។ ប៉ុន្តែ ព្រះជាម្ចាស់លាងសំអាតបងប្អូន ប្រោសប្រទានអោយបងប្អូនបានវិសុទ្ធ ព្រមទាំងអោយបងប្អូនបានសុចរិត ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រិស្ត តាមរយៈព្រះវិញ្ញាណនៃព្រះជាម្ចាស់របស់យើងរួចស្រេចហើយ។»* (១កូរិនថូស ៦:៩-១១ KSV)។ លោក ហាន់ អួរវ៉ាយឡឺ បានចង្អុលបង្ហាញថា ការលោភលន់ស្ថិតក្នុងចំណោមអំពើបាបដែលបានរៀបរាប់នៅក្នុងបញ្ជីរបស់សាវកប៉ុលនេះ។ គាត់បាននិយាយថា ដោយសារក្រុមជំនុំសាវកថ្មីបានទទួលយកសមាជិកដែលមានបាបនៃការលោភលន់ នោះពួកគេត្រូវតែទទួលយកសមាជិកដែលមានបាបនៃការស្រឡាញ់ភេទដូចគ្នាដែរ។

ប៉ុន្តែតើការលោភលន់ គឺជាការដែលក្រុមជំនុំគួរអត់ធ្មត់ទេ? សាវកប៉ុលឆ្លើយថា «ទេ!» ការលោភលន់ គឺជាអំពើបាបធ្ងន់ធ្ងរដែលនឹងធ្វើឲ្យយើង *«ពុំអាចទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់ទុកជាមត៌កបានឡើយ»* (១កូរិនថូស ៦:១០ KSV) បើយើងមិនព្រមប្រែចិត្ត។ តាមពិតនៅក្នុងគម្ពីរកូល៉ុស ៣:៥ និងអេភេសូរ ៥:៥ សាវកប៉ុលនិយាយថា ការលោភលន់ គឺជាការថ្វាយបង្គំរូបព្រះម្យ៉ាង (បាបនោះ គឺជាអំពើបាបដ៏ធ្ងន់ធ្ងរបំផុតមួយនៅក្នុងព្រះគម្ពីរ)។ តើអ្នកថ្វាយបង្គំរូបព្រះអាច ឡើងទៅស្ថានសួគ៌បានទេ បើគាត់មិនប្រែចិត្ត? ទេ ប្រាកដជាមិនបាន! នៅក្នុង ១កូរិនថូស ៦:៩-១០ សាវកប៉ុលនិយាយយ៉ាងច្បាស់ថា បាបទាំងអស់ក្នុងបញ្ជីរបស់គាត់នេះ រួមទាំងការលោភលន់ និងការស្រឡាញ់ភេទដូចគ្នា នឹងធ្វើឲ្យមនុស្ស *«ពុំអាចទទួលព្រះរាជ្យរបស់ព្រះជាម្ចាស់ទុកជាមត៌កបានឡើយ»*! ប៉ុន្តែ «មេសាវក» អ៊្លូរ៉ាយឡឺ និង «មេសាវក»បច្ចុប្បន្ន ជេ អិល ស្នាយឌឺ (J.L. Sneider) បង្រៀនថា មនុស្សលោភលន់និងមនុស្សស្រឡាញ់ភេទដូចគ្នាអាចចូលនគរព្រះដោយមិនប្រែចិត្ត។ តើអ្នកណាត្រឹមត្រូវ សាវកប៉ុល ឬ «សាវក» នៃក្រុមសាវកថ្មី? មិនអាចត្រូវទាំងពីរទេ។

ព្រះយេស៊ូវនិងពួកសាវកដែលបានសរសេរព្រះគម្ពីរ បានបង្រៀនម្តងហើយម្តងទៀតថា ព្រះហឫទ័យរបស់ព្រះ គឺជាអាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រី ឯទង្វើ និងបំណងប្រាថ្នាស្រឡាញ់ភេទដូចគ្នា គឺជាបាប (ម៉ាថាយ ១៩:៤-៦; រ៉ូម ១:២៦-២៨; ១កូរិនថូស ៦:៩-១១ KSV)។ បើយើងប្រាប់អ្នកស្រឡាញ់ភេទដូចគ្នាថា គាត់មិនចាំបាច់ប្រែចិត្តពីអំពើបាបរបស់គាត់ មិនមែនជាដំណឹងល្អចំពោះគាត់ទេ។ ផ្ទុយទៅវិញវាមានន័យថា យើងកំពុងបញ្ជូនមនុស្សមានបាបនោះទៅស្ថាននរក ពីព្រោះគ្មានអ្នកណាដែលឃើញព្រះ ដោយមិនកែប្រែចិត្តទេ។ ព្រះបានប្រាប់ព្យាការីអ៊ីស្រាអែលនៅអេសេគាល ១៣:២២ ថា ការជំនុំជម្រះរបស់ទ្រង់នឹងមកដល់ពួកគេ ដោយសារពួកគេ *«បានចំរើនកំឡាំងដៃនៃមនុស្សអាក្រក់ ដើម្បីមិនឲ្យគេលះចោល*

*ផ្លូវអាក្រក់របស់ខ្លួន ឲ្យបានសង្គ្រោះរួចជីវិតវិញឡើយ»*។ ដំណឹងល្អពិតប្រកាសដល់អ្នកមានបាបខាងផ្លូវភេទគ្រប់ប្រភេទថា ព្រះយេស៊ូវបានសុគតសម្រាប់អំពើបាបទាំងនោះហើយ ហើយទ្រង់ផ្តល់ការអត់ទោស និងការសង្គ្រោះដល់អ្នកដែលប្រែចិត្តនិងជឿលើទ្រង់។

«មេសាវក» ហាន់ អួរវ៉ាយឡឺ បានអះអាងថា គឺជាព្រះវិញ្ញាណបរិសុទ្ធដែលបានដឹកនាំគាត់ឲ្យផ្លាស់ប្តូរសេចក្តីបង្រៀននៃក្រុមជំនុំរបស់គាត់ អំពីការស្រឡាញ់ភេទដូចគ្នា។ ប៉ុន្តែ ការនោះមិនអាចទៅរួចទេ។ ព្រះវិញ្ញាណបរិសុទ្ធមិនដែលដឹកនាំនរណាម្នាក់ឲ្យបង្រៀនប្រឆាំងនឹងបទគម្ពីរដែលព្រះវិញ្ញាណបរិសុទ្ធបានប្រទានដល់ពួកសាវកដើមនោះឡើយ។ សាវកប៉ុលបានបង្រៀនថា ថា សូម្បីតែខ្លួនគាត់ផ្ទាល់បង្រៀនគោលជំនឿខុសពីគោលជំនឿដើមរបស់ពួកសាវក គាត់នឹងត្រូវបណ្តាសា «មេសាវក»របស់ក្រុមជំនុំសាវកថ្មី គឺជាសាវកក្លែងក្លាយ ពីព្រោះគាត់បានបោះបង់ចោលគោលលទ្ធិរបស់សាវកពិត។ យើងបានរៀននៅក្នុង ១យ៉ូហាន ៤:៦ ថា គ្រូពិតនឹងតែងតែបង្រៀនស្របតាមសាវកដើមរបស់ព្រះយេស៊ូវគ្រីស្ទ៖ *«ឯយើងរាល់គ្នា [ពួកសាវក] ជាអ្នកមកពីព្រះវិញ ហើយអ្នកណាដែលស្គាល់ព្រះ នោះក៏ស្តាប់យើងខ្ញុំ តែអ្នកណាដែលមិនមកពីព្រះទេ នោះមិនព្រមស្តាប់យើងខ្ញុំឡើយ គឺយ៉ាងនោះឯងដែលយើងនឹងស្គាល់វិញ្ញាណនៃសេចក្តីពិត និងវិញ្ញាណនៃសេចក្តីខុសឆ្គងទៅបាន»*។

កំហុសដ៏ធ្ងន់ធ្ងរនេះអំពីបាបនៃការស្រឡាញ់ភេទដូចគ្នា បង្ហាញយើងថា និកាយសាវកថ្មីបានក្លាយជាក្រុមខុសឆ្គងរួចទៅហើយ ហើយមិនយូរមិនឆាប់ ពួកគេនឹងបដិសេធនូវគោលលទ្ធិសំខាន់ៗផ្សេងទៀត។

ទីបំផុតសូមកត់សំគាល់ថា នៅខបន្ទាប់សាវកប៉ុលផ្តល់ក្តីសង្ឃឹមយ៉ាងធំដល់អស់អ្នកដែលមានទោសពីការលោភលន់ ការស្រឡាញ់ភេទដូចគ្នា ការផិតក្បត់ និងអំពើបាបផ្សេងទៀត។ គាត់និយាយថា *«ឯពួកអ្នករាល់គ្នាខ្លះ **ពីដើមក៏ជាមនុស្សយ៉ាងដូច្នោះ***

*ដែរ តែបានលាងស្អាតហើយ ក៏បានញែកជាបរិសុទ្ធ ហើយរាប់ជាសុចរិតផង ដោយនូវព្រះនាមព្រះអម្ចាស់យេស៊ូវ និងព្រះវិញ្ញាណរបស់ព្រះនៃយើងរាល់គ្នា។»* (១កូរិនថូស ៦:១១)។ គ្រីស្ទបរិស័ទនៅក្រុងកូរិនថូសបានប្រែចិត្តពីការលោភលន់ អំពើអសីលធម៌ និងការស្រឡាញ់ភេទដូចគ្នាហើយ និងពួកគេបានជឿលើព្រះយេស៊ូវគ្រីស្ទ ហើយបានទទួលសេចក្ដីសង្គ្រោះ។

## ជំនឿ

បន្ថែមពីការបង្រៀនខុសឆ្គងអំពីបាបស្រឡាញ់ភេទដូចគ្នា ពួកគេក៏បង្រៀនពីគោលជំនឿខុសឆ្គងទាំងនេះដែរ៖

**ពួកគេជឿថា គ្រីស្ទបរិស័ទអាចទទួលពិធីបុណ្យជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់ជំនួសមនុស្សដែលបានស្លាប់ហើយ។** ក្រុមជំនុំសាវកថ្មី ជឿថាអ្នកដែលបានស្លាប់ដោយមិនជឿលើព្រះគ្រីស្ទ នៅតែអាចសង្គ្រោះបាន។ «ព្រលឹងដែលបានចាកចេញហើយ អាចបានសង្គ្រោះ ដោយការសម្លឹងមើលទៅព្រះគ្រីស្ទនៅលើឈើឆ្កាង» (Catechism-QA 547)។ ពួកគេលើកទឹកចិត្តសមាជិករបស់ពួកគេឲ្យទទួលពិធីលៀងព្រះអម្ចាស់ និងបុណ្យជ្រមុជទឹកជំនួសអ្នកដែលបានស្លាប់ហើយ ដោយសង្ឃឹមថានឹងជួយពួកគេនៅជីវិតបន្ទាប់។ ប៉ុន្តែគម្ពីរហេព្រើរ ៩:២៧ មានបន្ទូលថា *«ហើយដោយព្រោះបានតម្រូវឲ្យមនុស្សទាំងអស់ស្លាប់**១ដង** រួចសឹមជាប់**សេចក្តីជំនុំជំរះ**»*។

**ពួកគេជឿថា មានតែសាវកម្នាក់ប៉ុណ្ណោះដែលអាចផ្ដល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធបាន។** គោលលទ្ធិរបស់ពួកគេនិយាយថា «ខ្ញុំជឿថា អ្នកដែលទទួលបុណ្យជ្រមុជទឹកហើយ ត្រូវទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធតាមរយៈសាវកម្នាក់ ដើម្បីក្លាយជាកូនរបស់ព្រះ ហើយបំពេញតម្រូវការសម្រាប់ក្លាយជាកូន[កូនច្បង]» (Article 8)។ ប៉ុន្តែតាមពិត ព្រះគម្ពីរមិនតម្រូវថា ត្រូវការសាវក ដើម្បីទទួលព្រះវិញ្ញាណបរិសុទ្ធនោះទេ ប៉ុន្តែគឺជំនឿលើព្រះគ្រីស្ទវិញ។ សូម

ស្តាប់លោកប៉ុលដែលជាសាវកពិត នៅពេលគាត់ស្តីបន្ទោសអ្នកជឿនៅកាឡាទី ដែលពឹងផ្អែកលើក្រឹត្យវិន័យ៖ *«ឱពួកអ្នកស្រុកកាឡាទីឥតបើគិតអើយ ដែលបានបើកសំដែងព្រះយេស៊ូវគ្រីស្ទមកយ៉ាងច្បាស់ នៅភ្នែកអ្នករាល់គ្នា ហើយទាំងជាប់ឆ្កាងផង នោះតើអ្នកណាបានធ្វើអំពើដាក់អ្នករាល់គ្នា ឲ្យលែងស្តាប់តាមសេចក្តីពិតវិញដូច្នេះ ២ ខ្ញុំចង់សួរអ្នករាល់គ្នាតែប៉ុណ្ណេះថា តើអ្នករាល់គ្នាបានទទួលព្រះវិញ្ញាណដោយប្រព្រឹត្តតាមក្រឹត្យវិន័យ ឬដោយបាន**ស្តាប់ ទាំងមានសេចក្តីជំនឿ**»* (កាឡាទី ៣:១-២)។ តាមខនេះ មានតែការឮដំណឹងល្អរបស់ព្រះយេស៊ូវ ហើយការជឿលើដំណឹងល្អនេះ ដែលជាការចាំបាច់ ដើម្បីក្លាយជាកូនរបស់ព្រះ ហើយនិងទទួលព្រះវិញ្ញាណបរិសុទ្ធ។

រ៉ូម ៨:៩-១១ មានបន្ទូលបួនដងថា  អ្នកជឿ**ទាំងអស់**នៅទីក្រុងរ៉ូមមានព្រះវិញ្ញាណបរិសុទ្ធផ្ទាល់គង់នៅក្នុងពួកគេហើយ៖

> *«តែបើសិនជា**ព្រះវិញ្ញាណនៃព្រះសណ្ឋិតក្នុងអ្នករាល់គ្នា** នោះអ្នករាល់គ្នាមិននៅខាងសាច់ឈាមទៀតទេ គឺនៅខាងវិញ្ញាណវិញ ប៉ុន្តែ បើអ្នកណា**គ្មានព្រះវិញ្ញាណរបស់ព្រះគ្រីស្ទ** អ្នកនោះមិនមែនជារបស់ផងទ្រង់ទេ ហើយបើសិនជា**ព្រះគ្រីស្ទសណ្ឋិតក្នុងអ្នករាល់គ្នា** ...បើ**ព្រះវិញ្ញាណ**នៃព្រះអង្គ ដែលបានប្រោសឲ្យព្រះយេស៊ូវរស់ពីស្លាប់ឡើងវិញ ទ្រង់**សណ្ឋិតក្នុងខ្លួនអ្នករាល់គ្នា** នោះព្រះអង្គនោះឯង ដែលបានប្រោសឲ្យព្រះគ្រីស្ទរស់ពីស្លាប់ឡើង ទ្រង់នឹងប្រោសរូបកាយនៃអ្នករាល់គ្នាដែលទៀងតែស្លាប់ ឲ្យមានជីវិតឡើងដែរ ដោយសារព្រះវិញ្ញាណទ្រង់ ដែល**សណ្ឋិតនៅក្នុងខ្លួនអ្នករាល់គ្នា**»។*

សាវកប៉ុលបាននិយាយដូចនេះ ទោះបីមិនទាន់មានសាវកណាបានទៅលេងនៅក្រុមជំនុំរ៉ូមក៏ដោយ!

**ពួកគេជឿថា ការសង្គ្រោះអាស្រ័យលើការបំពេញបីជំហាន។** «មេសាវក» នៃក្រុមជំនុំសាវកថ្មីនិយាយថា «ដើម្បីទទួលបានរូបកាយដែលរស់ឡើងវិញនៅពេលដែលព្រះគ្រីស្ទយាងមកវិញ មនុស្សត្រូវតែ [១] ទទួលបុណ្យជ្រមុជទឹកដោយទឹក និងព្រះវិញ្ញាណ [២] ប្រារព្ធពិធីលៀងព្រះអម្ចាស់តាមបែបគួរសម ( ១កូរិនថូស ១១:២៧) និង [៣] ផ្តល់កន្លែងទំនេរដល់ព្រះវិញ្ញាណបរិសុទ្ធ ដើម្បីទ្រង់អាចរៀបចំព្រលឹងនិងវិញ្ញាណ ដើម្បីយើងទទួលរូបកាយថ្មី»។ ហាក់ដូចជា ក្រុមជំនុំសាវកថ្មីកំពុងបន្ថែម ការប្រព្រឹត្តទៅលើជំនឿលើព្រះគ្រីស្ទ។

គេជឿថា ឯកសារពី «មេសាវក» នៃក្រុមជំនុំសាវកថ្មីត្រូវបានចាត់ទុកថា មានសិទ្ធិអំណាច ដូចសំបុត្ររបស់សាវកនៅក្នុងព្រះគម្ពីរ។

New Apostolic Church



*ខាងលើនេះ អ្នកនឹងឃើញនិមិត្តសញ្ញានៃក្រុមសាវកថ្មីនិងរូបថតនៃ«មេសាវក» ជេ ជី ប៊ីសសវ ដែលបានធ្វើទំនាយខុសអំពីការយាងមករបស់ព្រះគ្រីស្ទ «មេសាវក» ហាន់ អ៊ូរ៉ាយឡឺ ដែលបានប្រកាសថា ការស្រឡាញ់ភេទដូចគ្នាអាចទទួលយកបាន ហើយ«មេសាវក» បច្ចុប្បន្ន ជេ អិល ស្នាយដឺ ដែលគាំទ្រជំនឿថ្មីនោះ។*

ទីបញ្ចប់សូមកុំភ្លេច ២យ៉ូហាន ១០-១១៖ *«បើអ្នកណាមកឯអ្នករាល់គ្នា តែមិនបង្រៀនចំពោះសេចក្ដីនេះ នោះកុំឲ្យទទួលអ្នកនោះ នៅក្នុងផ្ទះឡើយ កុំឲ្យទាំងជំរាបសួរដល់អ្នកនោះផង ១១ ដ្បិតបើអ្នកណាជំរាបសួរ នោះក៏តែងមានសេចក្ដីប្រកបគ្នាក្នុងការអាក្រក់របស់អ្នកនោះដែរ»*។

# គ្រីស្ទសាសនាសេរីនិយម

## Liberal Christianity

## (គ្រីស្ទសាសនា គ្មានរបង)

លោកអ្នកប្រហែលជាភ្ញាក់ផ្អើលដែលខ្ញុំបញ្ចូលគ្រីស្ទសាសនាសេរីនិយមនៅក្នុងសៀវភៅអំពីក្រុមខុសឆ្គង ប៉ុន្តែវាមិនគួរឲ្យយើងភ្ញាក់ផ្អើលនោះទេ។ ចូរចាំថាក្រុមខុសឆ្គងទាំងអស់ដែលយើងបានសិក្សា គេប្រើពាក្យដែលគ្រីស្ទបរិស័ទស្គាល់ច្បាស់ដូចជា ព្រះជាម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ព្រះវិញ្ញាណបរិសុទ្ធ ការរស់ឡើងវិញ ការសង្គ្រោះ និង ព្រះគម្ពីរ ជាដើម។ ប៉ុន្តែគេចេះតែបំបែរអត្ថន័យនៃពាក្យទាំងនោះ។ គ្រីស្ទសាសនាសេរីនិយមក៏ធ្វើដូចគ្នាដែរ ហើយបានក្លាយជា គ្រីស្ទសាសនាក្លែងក្លាយម្យ៉ាង គឺជាលទ្ធិអង់ទីគ្រីស្ទ។

ខ្ញុំជឿថា រយៈពេល២០០ ឆ្នាំកន្លងមក គ្រីស្ទសាសនាសេរីនិយមបានបណ្តាលឲ្យសមាជិកពួកជំនុំបាត់បង់ជំនឿរបស់ខ្លួន ច្រើនជាងពួកក្រុមខុសឆ្គងទាំងអស់រួមបញ្ចូលគ្នាទៅទៀត។ សូម្បីតែសព្វថ្ងៃនេះ មានមនុស្សរាប់សិបលាននាក់ ដែលជាសមាជិកនៃនិកាយ និងក្រុមជំនុំដែលពីមុនបានកាន់ខ្ជាប់តាមដំណឹងល្អ ប៉ុន្តែឥឡូវនេះលែងផ្សាយដំណឹងល្អ ហើយលែងជឿព្រះគម្ពីរទៀតហើយ។ ទោះបីពួកគេនៅតែហៅខ្លួនឯងថា ជាពួកជំនុំគ្រីស្ទបរិស័ទក៏ដោយ។ ការផ្លាស់ប្តូរនេះបានកើតឡើងយឺតៗសន្សឹមៗ ក្នុងរយៈពេលរាប់សិបឆ្នាំ ដូច្នេះសមាជិកក្រុមជំនុំស្ទើរតែមិនដឹង នូវអ្វីដែលបានកើតឡើងនោះផង។

# ប្រវត្តិ

គ្រីស្ទសាសនាសេរីនិយមបានកើតឡើងក្នុងកំឡុងពេលសម័យកាល Enlightenment (សម័យភ្លឺឡើងនៃចំណេះដឹង) នៃសតវត្សទី ១៧ និង ១៨ នៅពេលដែល *វិចារណញ្ញាណរបស់មនុស្ស* បានជំនួស *ការបើកសម្តែងរបស់ព្រះ* ដែលជាផ្លូវសំខាន់ជាងគេក្នុងការស្វែងរកសេចក្តីពិត។ ការពឹងលើគំនិតមនុស្សនេះគេហៅថា ហេតុផលនិយម (Rationalism)។ ចំពោះគេព្រះលែងជាចំណុចកណ្តាលនៃអ្វីៗទាំងអស់ហើយ ផ្ទុយទៅវិញមនុស្សបានក្លាយទៅជាចំណុចកណ្តាលនៃអ្វីៗទាំងអស់វិញ។ ទស្សនៈនេះហៅថា មនុស្សនិយម (Humanism)។ មនុស្សក៏ចាប់ផ្តើមជឿថា អ្វីៗនៅក្នុងពិភពលោក ទាំងកំណើតលោកិយ ជីវិត និងសាសនា បានកើតឡើងដោយដំណើរធម្មជាតិ មិនមែនតាមការអស្ចារ្យពីព្រះទេ។ ទស្សនៈនេះហៅថា ធម្មជាតិនិយម (Naturalism)។ ទស្សនៈធម្មជាតិនិយម ក៏មានឥទ្ធិពលយ៉ាងខ្លាំងទៅលើគ្រីស្ទសាសនាដែរ ជាពិសេសនៅសតវត្សទី១៨ និង១៩។

នៅសតវត្សរ៍ទី១៩ និងដើមសតវត្សរ៍ទី២០ និកាយទាំងមូលនៅអឺរ៉ុប និងអាមេរិកឈប់ជឿលើគោលជំនឿដែលព្រះគ្រីស្ទ និងពួកសាវកបានបង្រៀន។ ជំនួសការនោះ ពួកគេយល់ថា គ្រីស្ទសាសនាជាអ្វីដែលកើតឡើងដោយដំណើរធម្មជាតិ ដោយមិនត្រូវការអន្តរាគមន៍ និងការអស្ចារ្យពីព្រះទេ។ តែទោះបីជាពួកគេឈប់ជឿលើគ្រីស្ទសាសនាពិតក៏ដោយ ពួកគេនៅតែប្រើពាក្យដែលមកពីគ្រីស្ទសាសនា ប៉ុន្តែមានអត្ថន័យខុសពីមុន៖

- ពួកគេនៅតែប្រើ**ព្រះគម្ពីរ** ប៉ុន្តែវាលែងជាការសម្តែងពីព្រះ ដែលល្អឥតខ្ចោះ និងខ្លាំងពូកែ តែជាសៀវភៅរបស់មនុស្សដែលពេញដោយកំហុស និងរឿងមិនពិត។

- ពួកគេនៅតែជឿលើ**ការអស្ចារ្យ**របស់ព្រះយេស៊ូវ ប៉ុន្តែគ្រាន់តែជានិមិត្តសញ្ញា និងរឿងព្រេង មិនមែនជាប្រវត្តិសាស្ត្រពិតទេ។
- ពួកគេនៅតែនិយាយថា ជឿលើ**ការរស់ឡើងវិញ** ប៉ុន្តែថា វាគឺជាវិញ្ញាណរបស់ព្រះគ្រីស្ទដែលបានរស់ឡើងវិញ មិនមែនជារូបកាយរបស់ទ្រង់ទេ។
- ពួកគេនៅតែនិយាយអំពី**សេចក្ដីសង្គ្រោះ** ប៉ុន្តែវាមកពី ការប្រព្រឹត្តល្អដែលមនុស្សបានប្រព្រឹត្ត មិនមែនជាការអស្ចារ្យ ដែលមានតែព្រះជាម្ចាស់អាចធ្វើក្នុងចិត្តមនុស្សទេ។
- ពួកគេនៅតែផ្សាយ**ដំណឹងល្អ** ប៉ុន្តែជាដំណឹងល្អនៃការប្រព្រឹត្តល្អ មិនមែនជាដំណឹងល្អនៃការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង សម្រាប់អំពើបាបរបស់យើងទេ។

ដំបូងមានតែអ្នកដឹកនាំ និងសាស្ត្រាចារ្យនៃសាលាព្រះគម្ពីរនៃនិកាយ ដែលបាត់បង់ជំនឿពីដំណឹងល្អពិត។ សមាជិកក្រុមជំនុំធម្មតានៅតែជឿដំណឹងល្អ និងព្រះគម្ពីរ។ តើសមាជិកពួកជំនុំបានកែតម្រូវដល់អ្នកដឹកនាំរបស់ពួកគេ ដែលបានឈប់ជឿលើការពិតនោះទេ? ភាគច្រើនពួកគេមិនបានធ្វើទេ។ ហេតុអ្វី មិនបាន?

## មូលហេតុបីដែលសមាជិកក្រុមជំនុំមិនបានកែតម្រង់អ្នកដឹកនាំរបស់គេ

១. ពីព្រោះ អ្នកដឹកនាំរបស់គេអះអាងថា ពួកគេនៅតែជឿគោលជំនឿសំខាន់ៗ នៃជំនឿយើង។ ពួកគេក៏បន្តប្រើពាក្យដូចគ្នានឹងយើង ដូចជា *ដំណឹងល្អ សេចក្តីសង្គ្រោះ និងការរស់ឡើងវិញ* ជាដើម។ ដូច្នេះ វាពិបាកសម្រាប់សមាជិកក្រុមជំនុំធម្មតា ដើម្បីដឹងថា អ្នកដឹកនាំកំពុងចាកចេញពីជំនឿហើយ។

២. សមាជិកក្រុមជំនុំ គ្មានសេចក្ដីក្លាហានក្នុងការកែ អ្នកដឹកនាំរបស់ពួកគេ។ ពួកគេថា «យើងគ្មានជំនាញដូចគេទេ យើងអត់មានចំណេះដឹងគ្រប់គ្រាន់ដើម្បីកែតម្រង់

ពួកគេអំពីគោលជំនឿទេ»។ ពួកគេបានភ្លេចពាក្យលើកទឹកចិត្តរបស់សាវកយ៉ូហាន ចំពោះសមាជិកក្រុមជំនុំសម័យគាត់៖ *«រីឯអ្នករាល់គ្នា បានព្រះដ៏បរិសុទ្ធចាក់លាបឲ្យ ហើយ ក៏ចេះគ្រប់ទាំងអស់ផង»* (១យ៉ូហាន ២:២០)។

៣. សមាជិកក្រុមជំនុំអត់បានកែតម្រង់អ្នកដឹកនាំរបស់ពួកគេ ពីព្រោះពួកគេចង់ធ្វើស្លូតបូត ដូចព្រះយេស៊ូវ ហើយមិនចង់ឲ្យមនុស្សគិតថា ពួកគេជាមនុស្សឆាប់ឈ្លោះគ្នា។ ពួកគេភ្លេចថា ព្រះយេស៊ូវក៏បានប្រឆាំងដោយសេចក្ដីក្លាហាន ទាស់នឹងគ្រូខុសឆ្គងនៅសម័យទ្រង់ដែរ។

ដោយសារ អ្នកជឿពិតបានរង់ចាំយូរពេក មុននឹងកែតម្រង់អ្នកដឹកនាំរបស់ពួកគេ នោះគ្រីស្ទសាសនាសេរីនិយម បានក្លាយជាទស្សនៈភាគច្រើន ក្នុងនិកាយរបស់គេ ហើយគ្រីស្ទបរិស័ទពិត ត្រូវចាកចេញវិញ។ ក្រោយមកនៅដើមសតវត្សរ៍ទី២០ គ្រីស្ទបរិស័ទពិតទាំងនោះបានបង្កើតនិកាយថ្មី ដែលជឿលើគោលជំនឿត្រឹមត្រូវ នៃព្រះយេស៊ូវ និងពួកសាវករបស់ទ្រង់។ ប៉ុន្តែតើនិកាយថ្មីទាំងនោះនឹងនៅតែស្មោះត្រង់ចំពោះជំនឿ ឬក៏នៅទីបំផុតពួកគេនឹងក្លាយជានិកាយសេរីនិយមដែរ? ចូរយើងអធិស្ឋានសូមឲ្យពួកគេ និងយើងផងនៅបន្តភាពស្មោះត្រង់ចំពោះ *«សេចក្ដីជំនឿដែលបានប្រគល់មកពួកបរិសុទ្ធ១ដងជាសំរេច»* (យូដាស ៣)។

ខុសពីក្រុមខុសឆ្គងដែលយើងបានសិក្សាក្នុងសៀវភៅនេះ គ្រីស្ទសាសនាសេរីនិយម មិនព្យាយាមលួចចូលក្រុមជំនុំឯទៀតទេ។ វាដូចជាមហារីកវិញ ដែលរាលដាលសន្សឹមៗ ក្នុងក្រុមជំនុំ និងនិកាយ។ ធម្មតាមហាវិទ្យាល័យដែលបង្វឹកបង្វឹនអ្នកដឹកនាំក្រុមជំនុំ ចាញ់គ្រីស្ទសាសនាសេរីនិយមមុនគេ។ ក្រោយមកនៅពេលសិស្សចេញពីសាលា ដើម្បីធ្វើការក្នុងក្រុមជំនុំ ពួកគេនាំយកលទ្ធិសេរីនិយម រហូតដល់រាលដាលដល់និកាយទាំងមូល។

## គ្រីស្ទសាសនាសេរីនិយមជឿអ្វី?

ទោះបីជាមានទម្រង់ និងកំរិតជាច្រើននៃគ្រីស្ទសាសនាសេរីនិយមក៏ដោយ នេះគឺជាជំនឿទូទៅរបស់គេៈ

**ពួកគេជឿលើធម្មជាតិនិយម។** ជំនឿសំខាន់ជាងគេនៃគ្រីស្ទសាសនាសេរីនិយម គឺថា ជំនឿអំពីព្រះគ្រីស្ទបានកើតឡើងដោយដំណើរការនៃធម្មជាតិ មិនមែនដោយការសម្តែង និងអន្តរាគមន៍ពីព្រះនោះទេ។ គេជឿថា ការអស្ចារ្យដែលបានរៀបរាប់នៅក្នុងព្រះគម្ពីរ មិនមែនជាប្រវត្តិសាស្ត្រពិតនោះទេ ប៉ុន្តែជានិមិត្តរូប និងនិមិត្តសញ្ញាតែប៉ុណ្ណោះ។ គោលការណ៍នៃធម្មជាតិនិយមនេះ នាំមកនូវជំនឿផ្សេងទៀតទាំងអស់ៈ

**ពួកគេជឿលើទ្រឹស្តីវិវត្តន៍។** គ្រីស្ទសាសនាសេរីនិយមជឿថា ទោះបីជាចក្រវាលដើមដំបូងអាចត្រូវបានបង្កើតដោយព្រះក៏ដោយ វាបានមកដល់ស្ថានភាពបច្ចុប្បន្នរបស់វានេះ តាមរយៈតែដំណើរការធម្មជាតិ រួមទាំងជីវិតដំបូង និងមនុស្សដំបូងផង។ ដូច្នេះគ្មានអ័ដាម និងអេវ៉ា ពិតប្រាកដ ដែលធ្លាប់ល្អឥតខ្ចោះ ហើយបន្ទាប់មកធ្លាក់ក្នុងអំពើបាបនោះទេ។ (សូមសម្គាល់៖ គ្រីស្ទបរិស័ទសេរីនិយមស្ទើរតែទាំងអស់ ជឿលើទ្រឹស្តីវិវត្តន៍។ ប៉ុន្តែមានមនុស្សមួយចំនួនដែលជឿលើទ្រឹស្តីវិវត្តន៍ តែមិនទទួលគោលជំនឿជាច្រើននៃគ្រីស្ទសេរីនិយមទេ។)

**ពួកគេជឿថា មនុស្សលោកមានចិត្តល្អ។** ពួកគ្រីស្ទសាសនាសេរីនិយមបង្រៀនថា មនុស្សលោកមានចិត្តគំនិតល្អ ឬគ្រាន់តែឈឺប៉ុណ្ណោះ។ ប៉ុន្តែ គ្រីស្ទសាសនាពិតបង្រៀនថា ចិត្តគំនិតមនុស្សស្លាប់ហើយ ហើយមានតែតាមរយៈការអស្ចារ្យនៃការកើតជាថ្មីប៉ុណ្ណោះទេ ដែលនឹងធ្វើឲ្យចិត្តមនុស្សមានជីវិត (អេភេសូ ២:១-៣)។ ដោយសារគ្រីស្ទសាសនាសេរីនិយមមិនជឿថា មានអ័ដាម និងអេវ៉ាពិត ពួកគេក៏មិនជឿលើការធ្លាក់ចុះរបស់មនុស្ស ឬថា សេចក្តីស្លាប់របស់មនុស្ស បានមកតាមរយៈអំពើបាបនោះទេ។

**ពួកគេជឿថា ព្រះគម្ពីរមិនមែនជាការសម្តែងពីព្រះទេ។** ព្រះគម្ពីរគ្រាន់តែជាសៀវភៅរបស់មនុស្ស ដែលបានមកដល់យើងតាមដំណើរធម្មជាតិតែប៉ុណ្ណោះ។ ដូច្នេះវាពោរពេញទៅដោយកំហុស ហើយមិនរស់ និងមានអំណាចទេ។

**ពួកគេជឿថា ព្រះយេស៊ូវមិនបានកើតពីក្រមុំព្រហ្មចារីនោះទេ។**

**ពួកគេជឿថា ព្រះយេស៊ូវមិនបានលោះយើងនៅលើឈើឆ្កាងទេ។** គ្រីស្ទសាសនាសេរីនិយមមិនជឿថា ការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង គឺជាការសុគតជំនួសអំពើបាបរបស់មនុស្សជាតិទេ។ ពួកគេជឿថា ព្រះគ្រីស្ទបានសុគត ដើម្បីបង្ហាញពីសេចក្តីស្រឡាញ់របស់ព្រះ ហើយផ្តល់ជាគំរូសម្រាប់យើងធ្វើតាម មិនមែនដើម្បីលោះយើងពីអំពើបាបឡើយ។

**ពួកគេជឿថា ព្រះកាយរបស់ព្រះយេស៊ូវមិនបានរស់ពីសុគតឡើងវិញទេ។** ពួកគេអះអាងថា គេនៅជឿលើការរស់ពីសុគតឡើងវិញរបស់ព្រះគ្រីស្ទ ប៉ុន្តែអ្វីដែលពួកគេចង់មានន័យគឺថា **វិញ្ញាណ**របស់ទ្រង់បានបន្តរស់នៅ តែព្រះកាយរបស់ទ្រង់នៅតែស្ថិតក្នុងផ្នូរហើយរលួយទៅ។ នៅពេលពួកគេនិយាយថា ព្រះគ្រីស្ទមានព្រះជន្មរស់ ពួកគេចង់មានន័យថា ទ្រង់មានព្រះជន្មរស់នៅក្នុងចិត្តយើង។

**ពួកគេជឿថា ការសង្គ្រោះគឺដោយអំពើល្អរបស់យើង។** ការសង្គ្រោះកើតឡើងចំពោះយើងដោយការដែលយើងយកតម្រាប់តាមជីវិតរបស់ព្រះគ្រីស្ទ។ ផ្លូវសង្គ្រោះនៅក្នុងគ្រីស្ទសាសនាសេរីនិយម គឺស្រដៀងគ្នាទៅនឹងការសង្គ្រោះនៅក្នុងសាសនានៅតំបន់អាស៊ីរបស់យើងដែរ៖ «ធ្វើល្អ បានល្អ»។ គ្រីស្ទសាសនាសេរីនិយមចាប់ផ្តើមដោយ «យើងត្រូវតែ...»។ តែគ្រីស្ទសាសនាពិតចាប់ផ្តើមនឹង «ព្រះបានធ្វើ...»។ គ្រីស្ទសាសនាសេរីនិយមនិយាយថា ព្រះជាព្រះវរបិតា ជាឪពុករបស់មនុស្សជាតិទាំងអស់។ ដូច្នេះនៅទីបំផុតមនុស្សគ្រប់គ្នា នឹងត្រូវបានសង្គ្រោះ ទោះជាពួកគេមិន

បានឮ និងជឿលើដំណឹងល្អក៏ដោយ នេះគេហៅថា (សកលនិយម Universalism)។

**ពួកគេជឿលើសេរីភាពខាងផ្លូវភេទ។** សព្វថ្ងៃនេះពួកគ្រីស្ទសាសនាសេរីនិយម យល់ស្របជាមួយលោកិយថា ទំនាក់ទំនងភេទដូចគ្នា គឺគាប់ព្រះហឫទ័យព្រះ ហើយការផ្លាស់ប្តូរភេទរបស់មនុស្សក៏ល្អដែរ។ អ្នកដើរតាមគ្រីស្ទសាសនាសេរីនិយម ភាគច្រើនក៏មិនប្រឆាំងនឹងអំពើអសីលធម៌ផ្លូវភេទ ការលែងលះ និងការរំលូតកូនដែរ។

## គ្រីស្ទសាសនាពិត គឺផ្អែកលើប្រវត្តិសាស្ត្រ

ពួកគ្រីស្ទសាសនាសេរីនិយមចង់សម្រេចចិត្តដោយខ្លួនឯងថា គ្រីស្ទសាសនា គឺជាអ្វី។ គំនិតនេះមានបញ្ហា ពីព្រោះគ្រីស្ទសាសនា គឺជាសាសនាពឹងផ្អែកលើប្រវត្តិសាស្ត្រ គឺប្រវត្តិសាស្ត្រពិត អំពីមនុស្សពិត ដែលបានសរសេរឯកសារពិត និងគោលជំនឿពិត។ ប្រសិនបើនរណាម្នាក់ចង់បង្កើតគ្រីស្ទសាសនាថ្មីទាន់សម័យ គាត់មានសេរីភាពក្នុងការធ្វើដូច្នេះ ប៉ុន្តែគាត់មិនអាចហៅថា គ្រីស្ទសាសនាបានទេ។ **គ្រីស្ទសាសនាសេរីនិយមមិនមែនជាគ្រីស្ទសាសនាពិតទេ។** គ្រីស្ទសាសនាសេរីនិយមមានគោលលទ្ធិផ្សេង មានទស្សនៈអំពីមនុស្សជាតិផ្សេង មានព្រះគ្រីស្ទផ្សេង (ដែលមិនបានរស់ពីសុគតឡើងវិញ!) ហើយនិងផ្លូវសង្គ្រោះផ្សេងដែលពឹងផ្អែកលើការប្រព្រឹត្តល្អ។ គ្រីស្ទសាសនាពិត គឺពឹងផ្អែកលើប្រវត្តិសាស្ត្រ ហើយព្រឹត្តិការណ៍នៃប្រវត្តិសាស្ត្រនោះ មិនអាចផ្លាស់ប្តូរទេ។ ឧទាហរណ៍ ជាការពិតនៃប្រវត្តិសាស្ត្រដែលសម្តេចសីហនុ ទាមទារឯករាជ្យកម្ពុជាពីបារាំងនៅឆ្នាំ១៩៥២។ គ្មាននរណាម្នាក់មានសិទ្ធិនិយាយថា រឿងនេះមិនបានកើតឡើងនោះទេ ព្រោះវាជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ។ ដូចគ្នាដែរគ្រីស្ទសាសនាសេរីនិយមមិនមានសិទ្ធិផ្លាស់ប្តូរគ្រីស្ទសាសនាពិតទេ។ ពីព្រោះវាជាសាសនាមានប្រវត្តិសាស្ត្រជាមូលដ្ឋាន។

## តើសាសនារបស់ព្រះយេស៊ូវ ខុសពីសាសនារបស់សាវកប៉ុលឬ?

គ្រីស្ទបរិស័ទសេរីនិយមខ្លះនិយាយថា ពួកគេចូលចិត្តរបៀបសាសនារបស់ព្រះយេស៊ូវ ប៉ុន្តែមិនមែនការបង្រៀនរបស់លោកប៉ុលទេ។ ពួកគេនិយាយថា ព្រះយេស៊ូវបានបង្ហាញផ្លូវជីវិតដល់យើង ប៉ុន្តែក្រោយមកសាវកប៉ុល បានណែនាំមកនូវសាសនាតឹងរ៉ឹង នៃគោលលទ្ធិវិញ។ ប៉ុន្តែប្រវត្តិសាស្រ្តជាក់ស្តែងបង្ហាញថា គោលលទ្ធិគ្រីស្ទសាសនា បានមកពីព្រះយេស៊ូវ និងពួកសាវកដើម។

ឧទាហរណ៍នៅក្នុង១កូរិនថូសជំពូក ១៥ លោកប៉ុលកំពុងពិភាក្សាអំពីគោលលទ្ធិនៃការរស់ឡើងវិញរបស់ព្រះគ្រីស្ទ។ គ្រូក្លែងក្លាយខ្លះបង្រៀនថា ព្រះយេស៊ូវមិនមានព្រះជន្មរស់ឡើងវិញនោះទេ។ តើលោកប៉ុលបានឆ្លើយតបដូចម្តេច? តើគាត់បានថា «ទោះបីជា រូបកាយរបស់ព្រះយេស៊ូវរស់ពីសុគត ឬអត់ មិនសំខាន់ទេ ឲ្យតែទ្រង់រស់ក្នុងចិត្តយើង ហើយយើងព្យាយាមរស់នៅតាមគំរូទ្រង់»? អត់ទេ! លោកប៉ុលបាននិយាយនៅ១កូរិនថូស ១៥:៣-៧ ថា ក្រុមជំនុំរបស់ព្រះគ្រីស្ទ បានទទួលដំណឹងល្អអំពីការសុគត ការបញ្ចុះសព និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ **ពីព្រះគ្រីស្ទផ្ទាល់ និងពីអ្នកជឿដំបូងបង្អស់។** លោកប៉ុលថែមទាំងនិយាយថា អ្នកណាដែលបដិសេធដំណឹងល្អនេះ នោះមិនអាចទទួលបានសេចក្តីសង្គ្រោះទេ!

សាស្រ្តាចារ្យ ជេ គ្រេសាំ មេចិន (J. Gresham Machen) បានពន្យល់អំពីទំនាក់ទំនងប្រវត្តិសាស្រ្តនិងគោលជំនឿដោយរបៀបនេះ៖ «តាំងពីដំបូង ដំណឹងល្អនៃគ្រីស្ទសាសនា...ជាកំណត់ត្រាអំពីព្រឹត្តិការណ៍**ដែលពិតជាបានកើតឡើង** [ក្នុងប្រវត្តិសាស្រ្ត]។ ហើយតាំងពីដំបូងដែរ **អត្ថន័យ**នៃព្រឹត្តិការណ៍នោះ ត្រូវបានប្រកាសដែរ។ ពេលដែល**អត្ថន័យ**នៃព្រឹត្តិការណ៍ប្រវត្តិដែលបានកើតឡើង ត្រូវបានប្រកាស នោះហើយជាគោលលទ្ធិគ្រីស្ទសាសនា។ <ព្រះគ្រីស្ទ បានសុគត> នោះហើយជាប្រវត្តិសាស្រ្ត។ <ព្រះគ្រីស្ទបានសុគតជំនួសអំពើបាបរបស់យើង> នោះហើយជា

គោលលទ្ធិ» (Machen 28)។ តាំងពីសេចក្តីអធិប្បាយដំបូងបំផុតនៅក្នុងកិច្ចការ ២ ពួកសាវកបានប្រកាសពីការពិត នៃការសុគត និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ។ សាវកប៉ុលមិនបានបន្ថែមអ្វីទៅក្នុងការបង្រៀនដើមនេះនោះទេ។

## និកាយគ្រីស្ទសាសនាសេរីនិយម

នៅក្រោមជាបញ្ជីមួយផ្នែក នៃនិកាយដែលអាចហៅថា គ្រីស្ទសាសនាសេរីនិយម។ ខ្ញុំអរគុណព្រះអង្គ ដែលមិនមែនក្រុមជំនុំទាំងអស់ក្នុងនិកាយទាំងនេះ ជាក្រុមគ្រីស្ទសាសនាសេរីនិយមទេ (សូមព្រះជាម្ចាស់ជួយគ្រីស្ទបរិស័ទស្មោះត្រង់ដែលនៅមាន)។ ប៉ុន្តែថ្នាក់ដឹកនាំនៃនិកាយនេះ ភាគច្រើន ខាងគ្រីស្ទសាសនាសេរីនិយម ទាំងសាលាព្រះគម្ពីរ និងក្រុមជំនុំដែរ។ សូមកុំភ្លេចថា និកាយទាំងនេះភាគច្រើន នៅតែមានសេចក្តីថ្លែងការណ៍គោលជំនឿត្រឹមត្រូវ (ដែលសេសសល់ពីជំនាន់មុន) ប៉ុន្តែការសម្រេចចិត្ត និងជំនឿសព្វថ្ងៃនេះរបស់ថ្នាក់ដឹកនាំបានចេញឆ្ងាយពីសេចក្តីពិត។ (បើបញ្ជីខាងក្រោមនេះមានកំហុស សូមជួយប្រាប់យើងខ្ញុំផង)

Episcopal Church in the United States
Evangelical Lutheran Church in America
Evangelical Lutheran Church of Canada
United Church of Canada
Uniting Church of Australia
Lutheran State Churches in Germany
Evangelical Lutheran Church of Finland
Church of Denmark
United Protestant Church of France
United Protestant Church in Belgium
United Reformed Church of Great Britain
Presbyterian Church (USA)
United Church of Christ
Church of the Brethren
Unitarian Church
Methodist Church of Great Britain
Church of Sweden
Church of Iceland
Church of Norway
Church of Scotland
Swiss Reformed Church
។ល។

មាននិកាយផ្សេងទៀតដែលកំពុងឈានទៅជិតគ្រីស្ទសាសនាសេរីនិយមដែរ ដូចជា យូណៃធីត មេតូឌីស (United Methodist Church)។ មានតែសាខាដែលអភិរក្សនិយម ពីអាហ្វ្រិក និងអាស៊ី ដែលរារាំងនិកាយនេះ កុំឲ្យបាត់បង់ជំនឿត្រឹមត្រូវទាំងអស់ ហើយក្លាយជានិកាយគ្រីស្ទសាសនាសេរីនិយមទាំងស្រុង។ សូមព្រះទ្រង់បានប្រទានពរ ដល់ពួកជំនុំ និងអ្នកដឹកនាំស្មោះត្រង់នៅទ្វីបអាហ្វ្រិក អាស៊ី និង អាមេរិកខាងត្បូង ដែលកំពុងរក្សាសេចក្តីពិត ខណៈដែលក្រុមជំនុំនៅអឺរ៉ុប និង អាមេរិកខាងជើង កំពុងងាកចេញពីសេចក្តីពិតរបស់ព្រះ។ (នៅឆ្នាំ ២០២១ និកាយយូណៃធីត មេតូឌីស្ទ ទូទាំងពិភពលោកបានប្រកាសថា ពួកគេមានផែនការបំបែកនិកាយជាពីរ មួយគ្រីស្ទសាសនាសេរីនិយម និងមួយទៀត គ្រីស្ទសាសនាដែលជឿលើដំណឹងល្អពិត)។

## មុខពូថៅ 

តើអ្វីជាមុខពូថៅដែលនាំឲ្យគ្រីស្ទសាសនាសេរីនិយមទទួលបានជោគជ័យក្នុងនិកាយជាច្រើន? តើមេដឹកនាំនៃគ្រីស្ទសាសនាសេរីនិយម បានបន្តរក្សាឋានៈដឹកនាំរបស់គេយ៉ាងដូចម្តេច ប្រសិនបើពួកគេបានបោះបង់ចោលគោលលទ្ធិគ្រីស្ទសាសនាពិតរួចទៅហើយនោះ? ពីព្រោះដូចជាក្រុមខុសឆ្គងដែរ ពួកគេនៅប្រើពាក្យដូចគ្នានឹងពួកគ្រីស្ទបរិស័ទដែលស្មោះត្រង់ដែរ ដូចជា *ការរស់ឡើងវិញ សេចក្តីសង្គ្រោះ ដំណឹងល្អ ព្រះយេស៊ូវ ព្រះគម្ពីរ* ប៉ុន្តែបានឲ្យអត្ថន័យថ្មីសម្រាប់ពាក្យទាំងនោះ។ ការបោកបញ្ឆោតបែបនេះ គឺជាមុខពូថៅរបស់គ្រីស្ទសាសនាសេរីនិយម។ ការបោកប្រាស់នេះ ធ្វើឲ្យគ្រូគង្វាលពិបាកដឹងថា សិក្ខាសាលា ឬមហាវិទ្យាល័យព្រះគម្ពីរដែលគាត់ចង់ចូលរៀននោះ ត្រឹមត្រូវនឹងព្រះបន្ទូលរបស់ព្រះ ឬអត់។ គាត់

ត្រូវតែសួរសំណួរជាក់លាក់ដូចជា «តើសាលានេះមានសាស្ត្រាចារ្យខ្លះដែលជឿថាព្រះគម្ពីរមានកំហុសឬទេ ?» ឬ «តើសាលានេះមានសាស្ត្រាចារ្យខ្លះដែលជឿថារូបកាយរបស់ព្រះយេស៊ូវ មិនមានព្រះជន្មរស់ឡើងវិញទេ ?» ។ល។ ប្រសិនបើអ្នកដឹកនាំសេរីនិយម ក្នុងនិកាយ ក្រុមជំនុំ និងសាលាគម្ពីរមានភាពស្មោះត្រង់ នោះពួកគេនឹងប្រកាសដល់មនុស្សគ្រប់គ្នាថា ពួកគេលែងជឿលើគោលលទ្ធិគ្រីស្ទបរិស័ទដើមទៀត ហើយ ហើយពួកគេនឹងចាកចេញពីនិកាយគ្រីស្ទសាសនារបស់គេ ហើយបង្កើតក្រុមជំនុំសេរីនិយមរបស់គេ។ ប៉ុន្តែពួកគេនឹងមិនធ្វើបែបនេះទេ។ ពួកគេមិនអាចបង្កើតក្រុមជំនុំសេរីនិយមបានទេ ពីព្រោះគ្រីស្ទសាសនាសេរីនិយមគ្មានដំណឹងល្អដើម្បីប្រកាសទេ។ គ្រីស្ទសាសនាសេរីនិយម ប្រៀបដូចជាមេរោគគ្រុនចាញ់ ដែលអាចរស់ដោយសារតែស៊ីអ្វីដែលនៅសេសសល់ពីក្រុមជំនុំគ្រីស្ទសាសនាពិត រហូតដល់វាបានស៊ីយកជីវិតទាំងអស់ចេញពីក្រុមជំនុំនោះ។ ដូច្នេះពួកគ្រីស្ទបរិស័ទសេរីនិយម នឹងបន្តការបោកបញ្ឆោតពួកជំនុំ ដោយប្រើប្រាស់ពាក្យដែលគ្រីស្ទសាសនាប្រើ ប៉ុន្តែបង្វែរអត្ថន័យរបស់ពាក្យនោះ ដើម្បីបោកប្រាស់សមាជិកស្មោះត្រង់ក្នុងក្រុមជំនុំ។ ពួកគេដឹងថា ប្រសិនបើពួកគេស្មោះត្រង់ ហើយប្រាប់សមាជិកនូវអ្វីដែលពួកគេពិតជាជឿ ពួកគេនឹងបាត់បង់ការងារ មុខរបររបស់ពួកគេ។ ការបោកប្រាស់ប្រភេទនេះ គឺមកពីអារក្សសាតាំងផ្ទាល់។

(ជំពូកនេះពឹងផ្អែកលើសៀវភៅ *Christianity and Liberalism [គ្រីស្ទសាសនា និងសាសនាសេរីនិយម]*, J. Gresham Machen, McMillen, NY 1923. https://www.extremetheology.com/files/MachenLiberalism.pdf)

## តើព្រះអាចសង្គ្រោះគ្រីស្ទបរិស័ទសេរីនិយមបានដែរឬទេ?

លោកបណ្ឌិត ថូម៉ាស ស៊ី អូដិន (Thomas C. Oden) គឺជាអ្នកទេវវិទូជាន់ខ្ពស់នៃពួកជំនុំយូណៃធីត មេតូឌីស (United Methodist Church) នៅចុងសតវត្សរ៍ទី២០។ ក្នុងនាមជាអ្នកទេវវិទ្យាសេរីនិយម គាត់បានបដិសេធគោលលទ្ធិស្ទើរតែទាំងអស់ក្នុងគ្រីស្ទសាសនាពិត រួមទាំងគោលលទ្ធិ អំពីការប្រោសលោះ និងការរស់ពីសុគតឡើងវិញរបស់ព្រះគ្រីស្ទ។ គាត់បានបង្រៀនថា គោលបំណងនៃដំណឹងល្អគឺដើម្បីរំដោះយើងពីការជិះជាន់ផ្នែកសេដ្ឋកិច្ច មិនមែនដើម្បីជួយសង្គ្រោះយើងពីអំពើបាប និងស្ថាននរកទេ។ យូរឆ្នាំក្រោយមកគាត់បានទទួលស្គាល់ថា សម្រាប់ពាក់កណ្តាលដំបូងនៃជីវិតរបស់គាត់ «គាត់ស្រឡាញ់គ្រីស្ទសាសនាខុសឆ្គង» គឺគាត់ស្រឡាញ់ការបង្រៀនក្លែងក្លាយ ហើយបានបដិសេធការបង្រៀនរបស់ព្រះគ្រីស្ទ និងពួកសាវក។

ប៉ុន្តែនៅប្រហែលឆ្នាំ ១៩៧០ គាត់បានចាប់ផ្តើមសិក្សាសៀវភៅ និងសេចក្តីអធិប្បាយ របស់គ្រូគង្វាលគ្រីស្ទសាសនានានានៃក្រុមជំនុំដំបូង ដូចជា លោកអាថាណាស៊ីយុស (Athanasius) អហ្គឹស្ទីន (Augustine) ប៉ូលលីខាប (Polycarp) និង អ៊ីរ៉េនេអ៊ូស (Irenaeus) ហើយរាប់សិបនាក់ទៀត។ គាត់បានឃើញថា អ្នកដឹកនាំពួកជំនុំទាំងនេះ បានជឿអ្វីៗទាំងអស់ដែលព្រះគ្រីស្ទ និងពួកសាវកបានបង្រៀន ហើយថា ពួកគេបានផ្តល់ភ័ស្តុតាងដ៏មានឥទ្ធិពលថា គ្រីស្ទសាសនា អូស្សូដក់ (ត្រឹមត្រូវ) គឺជាគ្រីស្ទសាសនាពិតតែមួយ។ គាត់ចាប់ផ្តើមនឹកឃើញថា ការងាររបស់គ្រូបង្រៀនគ្រីស្ទសាសនា មិនមែនដើម្បីបង្កើតគំនិតថ្មីទេ ប៉ុន្តែដើម្បី *«ការពារសេចក្តីជំនឿ ដែលបានប្រគល់មកពួកបរិសុទ្ធ១ដងជាសំរេច»* (យូដាស ៣) និងប្រកាន់ខ្ជាប់នូវ *«អ្វីដែលអ្នកបានឮពីដើមមក»* (១យ៉ូហាន ២:២៤)។ គាត់បានកែប្រែចិត្តពីដំណឹងល្អក្លែងក្លាយ និងព្រះគ្រីស្ទក្លែងក្លាយរបស់

គាត់ ហើយបានក្លាយជាគ្រីស្ទបរិស័ទពិត។ គាត់បានចំណាយពេល ៤០ឆ្នាំចុងក្រោយនៃជីវិតរបស់គាត់ ដើម្បីបង្រៀនដំណឹងល្អពិតរបស់ព្រះគ្រីស្ទ និងពួកសាវកដូចដែលមាននៅក្នុងព្រះគម្ពីរ។ ពិតមែន ព្រះអាចសង្គ្រោះគ្រីស្ទបរិស័ទសេរីនិយម! (ជីវប្រវត្តិរបស់លោក ថូម៉ាស អូដិនៈ *A Change of Heart [ការផ្លាស់ប្តូរចិត្ត]* Thomas C. Oden, IVP, ២០១៤)។

## តើព្រះអាចសង្គ្រោះនិកាយដែលបានក្លាយជាសេរីនិយមបានដែរឬទេ?

សម្ព័ន្ធបាបទីស្ទខាងត្បូង (SBC) គឺជានិកាយប្រូតេស្តង់ដ៏ធំជាងគេនៅអាមេរិក។ អស់រយៈពេល ៥០ឆ្នាំដំបូងនៃនិកាយនោះ ពួកជំនុំ និងអ្នកដឹកនាំនៃនិកាយនោះបានជឿលើ *«សេចក្តីជំនឿ ដែលបានប្រគល់មកពួកបរិសុទ្ធ១ដងជាសំរេច»* (យូដាស ៣)។ ប៉ុន្តែបន្តិចម្តងៗ ដូចជាមហារីក ជំនឿសេរីនិយមបានចាប់ផ្តើមរីករាលដាលក្នុងនិកាយSBC។ ដល់ឆ្នាំ១៩៨០ អ្នកដឹកនាំភាគច្រើន និងសាលាព្រះគម្ពីរទាំងអស់បានក្លាយជាសេរីនិយមហើយ។ ជារៀងរាល់ឆ្នាំសាស្ត្រាចារ្យពីសាលាព្រះគម្ពីរ ត្រូវបានតម្រូវឲ្យចុះហត្ថលេខា លើសេចក្តីថ្លែងការគោលលទ្ធិ ដើម្បីបញ្ជាក់ថា ពួកគេនៅតែជឿលើគោលជំនឿត្រឹមត្រូវ។ ពួកគេទាំងអស់បានចុះហត្ថលេខាលើវា ប៉ុន្តែពួកគេភាគច្រើនបានចុះហត្ថលេខាដោយបោកបញ្ឆោត ព្រោះតាមពិតពួកគេមិនជឿលើអ្វីដែលពួកគេកំពុងចុះហត្ថលេខានោះទេ។

វាហាក់ដូចជាយឺតពេលហើយ ក្នុងការជួយសង្គ្រោះនិកាយនោះ ពីលទ្ធិសេរីនិយម។ ប៉ុន្តែនៅឆ្នាំ១៩៧៩ គ្រូគង្វាលមួយក្រុម បានចាប់ផ្តើមអធិស្ឋាន និងធ្វើការ ដើម្បីនាំនិកាយរបស់ពួកគេ ឲ្យត្រឡប់ទៅដំណឹងល្អពិតវិញ។ ពួកគេបានដឹងថា ជាង ៥០% នៃសមាជិកពួកជំនុំធម្មតា នៅតែជឿលើព្រះគម្ពីរ និងដំណឹងល្អ។ ពួកគេថា «ហេតុអ្វីបានជាអ្នកភាគតិចដែលមិនជឿលើដំណឹងល្អ ដឹកនាំនិកាយទាំងមូលចេញពីព្រះយ៉ាងដូច្នេះ?»។ ដូច្នេះរយៈពេល១៥ ឆ្នាំក្រោយមក ក្រុមនេះបានអធិស្ឋាន និង

ព្យាយាម ឲ្យនិកាយរបស់គេបោះឆ្នោតជ្រើសរើសអ្នកជឿលើព្រះគម្ពីរពិត ឲ្យកាន់តំណែងជាអ្នកដឹកនាំ។ បន្ទាប់មកពួកគេរកសាស្ត្រាចារ្យដែលជឿព្រះគម្ពីរជំនួសអ្នកដែលមិនបានជឿ។ ការនេះមិនងាយស្រួលនោះទេ។ ពួកសេរីនិយមក្នុងនិកាយបានចោទប្រកាន់ពួកគេថា ពួកគេចង់លួចនិកាយនេះ ទោះបីជា ពួកសេរីនិយមដែលបានលួចនិកាយ៥០ឆ្នាំមុនក៏ដោយ។ ពួកសេរីនិយមក៏ចោទប្រកាន់ទៀតថា ពួកគេបានបំផ្លាញការរួបរួមគ្នា។ តាមពិតគឺគ្រូខុសឆ្គងដែលបានបំបាក់បំបែកការរួបរួមគ្នាដោយគោលជំនឿថ្មី។ ទីបញ្ចប់បន្ទាប់ពីការតស៊ូ ២០ឆ្នាំ និកាយបាទីស្ទភាគខាងត្បូង គឺជាពួកជំនុំដែលជឿលើដំណឹងល្អ និងព្រះគម្ពីរឡើងវិញ។

នៅពេលនោះគ្រូគង្វាល និងពួកជំនុំសេរីនិយមភាគច្រើនបានចាកចេញពីនិកាយនោះ។ ប៉ុន្តែ នោះគឺជាការដែលគួរកើតឡើង។ គ្រីស្ទបរិស័ទស្មោះត្រង់គួរនៅ ហើយអ្នកដែលមានគោលលទ្ធិថ្មី គួរតែចាកចេញ ដូចអ្វីដែលបានកើតឡើងនៅក្នុងក្រុមជំនុំរបស់សាវកយ៉ូហាន៖ *«គេបានចេញពីពួកយើងទៅ តែមិនមែនជាពួកយើងទេ ដ្បិតបើគេជាពួកយើងមែន នោះនឹងបាននៅជាប់ជាមួយនឹងយើងហើយ តែដែលគេបានចេញទៅ នោះដើម្បីនឹងសំដែងពីគេថា គ្រប់គ្នាមិនមែនជាពួកយើងទេ»* (១យ៉ូហាន ២:១៩)។ ពិតមែន! ព្រះអាចសង្គ្រោះ ក្រុមជំនុំ និងនិកាយសេរីនិយមបាន!

## តើគ្រីស្ទបរិស័ទគួរឆ្លើយតបដូចម្តេចចំពោះក្រុមខុសឆ្គង?

### ១. ការឆ្លើយតបនៃទុក្ខព្រួយយ៉ាងជ្រាលជ្រៅ

នៅពេលយើងអានអំពីសាសនាខុសឆ្គងទាំងនេះ យើងត្រូវយំសោក។ យើងត្រូវយំសោកសម្រាប់មនុស្សទាំងអស់ដែលត្រូវបានបញ្ឆោត ដោយអ្នកដឹកនាំសាសនាដែលនិយាយកុហកទាំងនេះ។ យើងត្រូវតែស្រក់ទឹកភ្នែកសម្រាប់ស្ត្រីទាំងអស់ដែលត្រូវបានគេបោកបញ្ឆោត និងរំលោភបំពាន ដោយបុរសឃោរឃៅនៃសាសនាទាំងនេះ។ យើងត្រូវយំសោកសម្រាប់មនុស្សទាំងអស់ ដែលត្រូវបានគេយកធ្វើជាទាសករ ដើម្បីរកលុយឲ្យមេដឹកនាំ ដែលមានទ្រព្យសម្បត្តិស្តុកស្តម្ភទាំងនេះ។

យើងគួរមានអារម្មណ៍អាណិតអាសូរយ៉ាងខ្លាំងសម្រាប់អ្នកដែលចាញ់បោក និងចូលក្រុមខុសឆ្គងនេះ ហើយយើងត្រូវមានបំណងចង់ប្រកាសដំណឹងល្អពិតដល់ «ចៀមដែលគ្មានអ្នកគង្វាល» ដើម្បីឲ្យពួកគេអាចរួចផុតពីការកុហករបស់សាតាំង។

ហើយយើងគួរតែទួញសោកដែលព្រះនាមដ៏រុងរឿងរបស់ព្រះនៃយើង ត្រូវបានគេប្រមាថ ហើយលក្ខណៈបរិសុទ្ធរបស់ទ្រង់ត្រូវបានគេបំភ្លៃ និងបដិសេធ។ ទោះជាយ៉ាងណាក៏ដោយសេចក្តីពិតរបស់ព្រះ នឹងឈ្នះលើការកុហក។ ថ្ងៃណាមួយ *«គ្រប់ទាំងអណ្តាត[នឹង]ថ្លែងប្រាប់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់ជាព្រះអម្ចាស់ សំរាប់ជាសិរីល្អដល់ព្រះដ៏ជាព្រះវរបិតា»* (ភីលីព ២:១១)។

## ២. ការឆ្លើយតបនៃការប្រុងប្រយ័ត្ន

យើងគួរតែមានសេចក្តីស្រឡាញ់យ៉ាងខ្លាំង ចំពោះហ្វូងចៀមរបស់យើង ដោយយើងសុខចិត្តធ្វើអ្វីដែលយើងអាចធ្វើបាន ដើម្បីការពារពួកគេពីចចកពាក់រោមចៀមទាំងនេះ។ នេះគឺជាហេតុផលចម្បងដែលខ្ញុំបានសរសេរសៀវភៅនេះឡើង ដើម្បីជួយអ្នកការពារហ្វូងចៀមពីឆ្កែចចក។

យើងត្រូវតែស្រឡាញ់ហ្វូងចៀមរបស់យើងយ៉ាងខ្លាំង ដោយយើងត្រូវហ៊ានប្រាប់ពួកខុសឆ្គង ឲ្យឈប់រំខានដល់ចៀមរបស់យើង។ យើងត្រូវតែប្រឈមមុខប្រឆាំងនឹងអ្នកដែលចង់បំផ្លាញជំនឿរបស់បងប្អូនយើង។

គ្រូគង្វាលខ្លះមានការគួរសម និងសុភាពរាបសារពេក ដើម្បីការពារចៀមរបស់ពួកគេតាមរបៀបនេះ។ ប៉ុន្តែប្រសិនបើនរណាម្នាក់ ព្យាយាមឲ្យថ្នាំពុលដល់កូនរបស់ពួកគេ ពួកគេប្រាកដជាធ្វើអ្វីមួយមិនខាន! ដូចគ្នានេះដែរ យើងដែលជាអ្នកដឹកនាំក្រុមជំនុំ មិនត្រូវទន់ខ្សោយពេក ដែលធ្វើឲ្យយើងមិនបានប្រឆាំងចំពោះមនុស្សទាំងនេះ ដែលចង់ដាក់ថ្នាំពុលក្នុងក្រុមជំនុំរបស់យើង។

## ៣. ការឆ្លើយតបនៃសេចក្តីស្រឡាញ់ និងការផ្សាយដំណឹងល្អ

តាមដែលខ្ញុំដឹង គ្មានស្ថាបនិកនៃក្រុមខុសឆ្គងណាមួយ ដែលធ្លាប់ប្រែចិត្ត ហើយងាកមករកព្រះយេស៊ូវពិតវិញនោះទេ។ ក៏ប៉ុន្តែសមាជិកនៃក្រុមខុសឆ្គងរាប់ម៉ឺននាក់ បានឮដំណឹងល្អ ឬអានព្រះគម្ពីរ ហើយបានងាកត្រឡប់ទៅរកព្រះគ្រីស្ទពិតវិញ។ អ្នកផ្សព្វផ្សាយរបស់ក្រុមខុសឆ្គងភាគច្រើននឹងមិនស្តាប់អ្នកទេ សូម្បីតែ១០វិនាទី។ ពួកគេនឹងនិយាយកាត់អ្នក ហើយបន្តបង្ហាញការទន្ទេញចងចាំរបស់ពួកគេ។ ប្រសិនបើរឿងនោះកើតឡើងចំពោះអ្នក អ្នកត្រូវតែបញ្ចប់ការសន្ទនា ដោយសុភាពរាបសា ហើយឲ្យគ្រូខុសឆ្គងនោះចេញពីផ្ទះរបស់អ្នក។ ប៉ុន្តែម្តងម្កាលពួកខុសឆ្គង

នឹងស្តាប់ដោយគោរព នូវដំណឹងល្អដែលអ្នកចែករំលែក។ ដំណឹងល្អដ៏ពិតរបស់ព្រះយេស៊ូវពិត មានអំណាចខ្លាំងណាស់។

## ៤. ការឆ្លើយតបដោយអធិស្ឋានសម្រាប់សេចក្តីយុត្តិធម៌

គ្រូក្លែងក្លាយនឹងគេចមិនផុតពីការជំនុំជម្រះរបស់ព្រះជាម្ចាស់ឡើយ។ យើងដឹងថា នៅពេលដែលព្រះយេស៊ូវគ្រីស្ទយាងមកវិញ ទ្រង់នឹងវិនិច្ឆ័យគ្រូក្លែងក្លាយទាំងអស់ ដោយយុត្តិធម៌ពេញលេញ។ ទ្រង់នឹងជំនុំជម្រះពួកគេ ពីការប្រមាថមើលងាយ ការកុហក អំពើអសីលធម៌ ការស្រឡាញ់ប្រាក់ ការរំលោភបំពាន និងការធ្វើបាបអ្នកដទៃរបស់ពួកគេ។ *«រួចអារក្សដែលនាំគេឲ្យវង្វេង បានត្រូវបោះទៅក្នុងបឹង ដែលឆេះជាភ្លើង និងស្ពាន់ធ័រ ជាកន្លែងដែលសត្វនោះ និងហោរាក្លែងក្លាយនៅហើយ នោះវារាល់គ្នាត្រូវរងទុក្ខវេទនាទាំងយប់ទាំងថ្ងៃ នៅអស់កល្បជានិច្ចរៀងរាបតទៅ»*
វិវរណៈ ២០:១០។

សូមស្តាប់ពាក្យសម្តីវិនិច្ឆ័យដ៏ធ្ងន់របស់សាវកពេត្រុស ប្រឆាំងនឹងគ្រូក្លែងក្លាយ នៅក្នុង ២ពេត្រុស ២:១-១៥។ សូមសម្គាល់ការពីរយ៉ាងក្នុងវគ្គនេះ៖ ១. សូមសម្គាល់ពាក្យជំនុំជម្រះយ៉ាងច្រើនដែលខ្ញុំបានបញ្ជាក់ ក្នុងអក្សរក្រាស់។ ២. សូមសម្គាល់ពាក្យដែលសំដៅទៅអំពើអសីលធម៌ ការស្រឡាញ់ប្រាក់ ការបោកបញ្ឆោត ការប្រមាថ និងការអួតខ្លួនរបស់ក្រុមខុសឆ្គង។ ខ្ញុំបានបញ្ជាក់ពាក្យនោះដោយដាក់បន្ទាត់ពីក្រោម។

> *«តែកាលពីដើម មានហោរាក្លែងក្លាយ នៅក្នុងពួកជន ដូចជានឹងមានគ្រូក្លែងក្លាយក្នុងពួកអ្នករាល់គ្នាដែរ គេនឹងលួចនាំបញ្ចូលបក្សពួកដែលបង្ខូចបំផ្លាញ គេមិនព្រមស្គាល់ព្រះដ៏ជាម្ចាស់ ដែលបានលោះគេនោះឡើយ ក៏នាំ**សេចក្តីវិនាស**ដ៏ឆាប់រហ័សឲ្យមកលើខ្លួនផង [២] នឹងមានមនុស្សជាច្រើនទៅតាម**ផ្លូវវិនាស**របស់គេ នោះផ្លូវពិតនឹងត្រូវសេចក្តីប្រមាថមើលងាយ ដោយព្រោះគេដែរ [៣] ហើយដោយគេមានចិត្ត*

*លោភ នោះគេនឹងប្រើអ្នករាល់គ្នាឲ្យបានចំណេញ ដោយពោលពាក្យបញ្ឆោត*
*បំពាត តែតាំងពីយូរមកហើយ* ***សេចក្តីជំនុំជំរះ****គេមិននៅស្ងៀមស្ងាត់ទេ ហើយ*
***សេចក្តីហិនវិនាស****របស់គេក៏មិនងុយងោកដែរ ...*

*ពួកព្រហើន មានក្បាលរឹង ដែលមិនខ្លាចនឹងជេរប្រមាថដល់ទាំងពួកប្រសើរឧត្តម*
*ផង ១១ ដែលពួកទេវតាដ៏មានកំឡាំង មានឫទ្ធិលើសជាងគេទៅទៀត ក៏មិនហ៊ាន*
*ប្រមាថដល់ពួកនោះ នៅចំពោះព្រះអម្ចាស់ឡើយ ១២ តែដោយព្រោះគេជេរប្រមាថ*
*ដល់ការដែលគេមិនស្គាល់ នោះគេនឹងត្រូវ****វិនាស****បាត់ក្នុងការខូចអាក្រក់របស់គេ*
*អស់រលីង ដូចជាសត្វតិរច្ឆាន ដែលកើតមកសំរាប់តែឲ្យគេចាប់ ហើយកាប់សំឡាប់*
*ប៉ុណ្ណោះដែរ ១៣ គេហៀបនឹងទទួលរង្វាន់នៃការទុច្ចរិត គេជាពួកអ្នកដែលរាប់ការ*
*ស្រើបស្រាលនៅពេលថ្ងៃ ទុកជាការត្រេកអរសប្បាយ គេជាស្នាមប្រឡាក់ ហើយ*
*ជាសេចក្តីស្មោកគ្រោក គេត្រេកអរដោយសេចក្តីបញ្ឆោតរបស់ខ្លួន ក្នុងពេលកំពុង*
*ដែលគេស៊ីលៀងជាមួយនឹងអ្នករាល់គ្នា ១៤ គេមានចិត្តនឹកឃើញតែស្រីសំផឹង គេ*
*មិនចេះលែងធ្វើបាបឡើយ ក៏បិទនុយចាប់ព្រលឹងមនុស្សដែលមិនខ្ជាប់ខ្ជួន ហើយ*
*មានចិត្តធ្លាប់ខាងឯសេចក្តីលោភ គឺជាមនុស្សដែល****ត្រូវបណ្តាសា*** *១៥ គេបានបោះ*
*បង់ចោលផ្លូវទៀងត្រង់ ហើយវង្វេងទៅតាមផ្លូវរបស់ហោរាបាឡាមជាកូនបេអ៊រ*
*ដែលស្រឡាញ់កំរៃនៃការទុច្ចរិត»។*

ទាំងនេះគឺជាពាក្យធ្ងន់ៗ ប៉ុន្តែមនុស្សដែលនាំអ្នកដទៃ ទៅស្ថាននរកតាមរយៈការកុហក និងការបោកប្រាស់ សមនឹងទទួលបានការជំនុំជម្រះបែបនេះ។

## ៥. ការឆ្លើយតបនៃការជ្រែកនៅក្រោមក្រុមជំនុំ

ចូរចាំថា ការការពារគ្រីស្ទបរិស័ទពីក្រុមខុសឆ្គង ជារឿងក្រុមគ្រួសារ ខ្ញុំនិយាយពីក្រុមជំនុំ។ អ្នកមិនអាចយកឈ្នះលើការបង្រៀនក្លែងក្លាយដោយខ្លួនឯងបានទេ។ ព្រះគ្រីស្ទមិនបានទិញអ្នកដោយព្រះលោហិតរបស់ទ្រង់ផ្ទាល់ ដើម្បីឲ្យអ្នកក្លាយជាគ្រីស្ទបរិស័ទម្នាក់ឯង ឬដើម្បីឲ្យអ្នកចេញពីក្រុមជំនុំមួយទៅក្រុមជំនុំមួយ ដោយគ្មាន

សមាជិកភាពច្បាស់លាស់នោះទេ។ ព្រះគ្រីស្ទបានទិញអ្នកដោយព្រះលោហិតរបស់ទ្រង់ ដើម្បីអ្នកនឹងក្លាយជាសមាជិកដ៏ច្បាស់លាស់នៃក្រុមជំនុំមួយ គឺក្រុមជំនុំដែលផ្សាយដំណឹងល្អច្បាស់លាស់ ហើយយកចិត្តទុកដាក់ចំពោះព្រលឹងរបស់អ្នក។ ប្រសិនបើអ្នកជាមនុស្សដែលចេះតែចេញពីក្រុមជំនុំមួយទៅក្រុមជំនុំមួយ នោះអ្នកងាយនឹងចាញ់បោកក្រុមខុសឆ្គង ព្រោះក្រុមជំនុំនីមួយៗដែលអ្នកចូលរួមនោះ គិតថាក្រុមជំនុំមួយផ្សេងទៀតទទួលខុសត្រូវចំពោះអ្នក តែការពិត គ្មានក្រុមជំនុំណាមួយថែរក្សាអ្នកសោះ។ ការនេះបង្កើតស្ថានភាពគ្រោះថ្នាក់សម្រាប់អ្នក ព្រោះអ្នកគ្មានឆ័ត្រការពារ។

**ឧទាហរណ៍៖** គ្រីស្ទបរិស័ទម្នាក់នៅកម្ពុជា គាត់មិនមានសមាជិកភាពក្រុមជំនុំណាមួយច្បាស់លាស់ទេ គឺតែងទៅពីក្រុមជំនុំមួយទៅក្រុមជំនុំមួយតាមចិត្តគាត់។ នៅពេលដែលគ្រូបង្រៀន ខាង អាន់ សាំងហុង ទៅដល់ផ្ទះគាត់ ដោយកាន់គម្ពីរ គាត់ចាប់អារម្មណ៍យ៉ាងខ្លាំង ព្រោះគាត់ជាមនុស្សដែលស្រឡាញ់ព្រះគម្ពីរ។ មុនដំបូងគេបង្រៀនគាត់ យ៉ាងខ្លាំងអំពីថ្ងៃឈប់សម្រាកនៅថ្ងៃទីប្រាំពីរ(មុខពូថៅ) ហើយពួកគេបានដាក់សម្ពាធលើគាត់ឲ្យទទួលបុណ្យជ្រមុជទឹក ចូលក្រុមរបស់ពួកគេ។ ចុងក្រោយគាត់បានយល់ព្រមទទួល។ ក្រោយគាត់ទទួលបុណ្យជ្រមុជទឹកភ្លាម គេចាប់ផ្តើមនិយាយ អំពី «ព្រះគ្រីស្ទ អាន់ សាំងហុង» និង «ព្រះមាតា» (ខ្នងពូថៅ)។ គាត់បានសួរថា «តើអ្នកកំពុងនិយាយអំពីអ្នកណា?»។ គ្រូក្លែងក្លាយបានលាក់ព័ត៌មាននេះពីគាត់ ព្រោះពួកគេដឹងថា គាត់នឹងមិនទទួលទេ បើគាត់ដឹងពីដំបូង។ អរគុណព្រះអង្គ ដែលគាត់ដឹងភ្លាមថា គាត់បានចូលរួមក្នុងក្រុមខុសឆ្គង ហើយគាត់បានប្រាប់ពួកគេឲ្យចេញទៅវិញភ្លាម ហើយកុំត្រឡប់មកវិញអី។ ហេតុអ្វីបានជាគ្រីស្ទបរិស័ទម៉ាំបែបនេះ បានចាញ់ក្រុមខុសឆ្គងនេះ? ដោយសារតែគាត់មិនមានសមាជិកភាព និងការចូលរួមច្បាស់លាស់ក្នុងក្រុមជំនុំមួយ ដែលនឹងថែរក្សាព្រលឹងរបស់គាត់។

> ក្រុមជំនុំ នីមួយៗដែលគាត់បានចូលរួម ស្មានថា ក្រុមជំនុំផ្សេងទៀត មានទំនួលខុសត្រូវខាងព្រលឹងវិញ្ញាណលើគាត់។ ឥឡូវគាត់បានដឹងខ្លួនថា គាត់បានធ្វើខុស ហើយបានក្លាយជាសមាជិកទៀងទាត់នៃក្នុងក្រុមជំនុំមួយ ដែលអ្នកដឹកនាំស្មោះត្រង់ អាចថែរក្សាព្រលឹងគាត់ និងការពារគាត់។

សាវកយ៉ូហានបានបង្រៀនយើងថា ពួកជំនុំជាក្រុមគ្រួសារ ដែលជួយយើង យកឈ្នះលើគ្រូក្លែងក្លាយ។ វិធីតែមួយគត់ដែលយើងទាំងអស់គ្នាអាចទទួលបានជ័យជំនះ លើក្រុមខុសឆ្គងទាំងនេះ គឺចុះចូល ដោយបន្ទាបខ្លួនចំពោះក្រុមជំនុំមួយ ដែលជឿ និងបង្រៀនគ្រីស្ទសាសនាពិត នោះគឺជាជំនឿនៃព្រះគ្រីស្ទ និងពួកសាវក។

## ៦. ការឆ្លើយតបនៃចិត្តអរគុណយ៉ាងជ្រាលជ្រៅចំពោះដំណឹងល្អពិត

នៅពេលដែលយើងសិក្សាអស់ទាំងដំណឹងល្អក្លែងក្លាយនេះ ហើយរបៀបដែលគ្រូក្លែងក្លាយបន្ថែមបន្ទុកហើយបន្ថែមទៀតទៅលើស្មារបស់អ្នកដែលចាញ់បោកនោះ យើងត្រូវឆ្លើយតបដោយអំណរគុណយ៉ាងខ្លាំងដល់ព្រះជាម្ចាស់ ចំពោះដំណឹងល្អពិត ដែលដកយកបន្ទុកទាំងអស់ ហើយរំដោះយើងឲ្យមានសេរីភាពវិញ។

## អធិស្ឋានបិទ៖

**ឱព្រះយេស៊ូវ** ជាមេនៃអ្នកគង្វាលហ្វូងចៀមអើយ ទ្រង់បានលះបង់ជីវិតរបស់ទ្រង់សម្រាប់យើងខ្ញុំ សូមទ្រង់ជួយឲ្យយើងខ្ញុំលះបង់ជីវិត សម្រាប់គ្រួសារ និងក្រុមជំនុំរបស់យើងខ្ញុំដែរ។

**ឱព្រះវិញ្ញាណបរិសុទ្ធអើយ** សូមទ្រង់ប្រទានឲ្យយើងខ្ញុំនូវភាពក្លាហាន ប្រាជ្ញា និងសេចក្តីស្រឡាញ់ ដើម្បីប្រឈមមុខទាស់នឹងសាសនាក្លែងក្លាយទាំងនេះ ដែលចង់លួចអំណាររបស់យើងខ្ញុំ។

**ឱព្រះវរបិតាអើយ** សូមអរគុណព្រះអង្គ ដែលគ្រូក្លែងក្លាយទាំងនេះ នឹងមិនដែលឈ្នះឡើយ ហើយអរគុណព្រះអង្គ ដែលមិនយូរមិនឆាប់ព្រះគ្រីស្ទដ៏ពិត នឹងយាងត្រលប់មករំដោះហ្វូងចៀមពិតរបស់ព្រះអង្គ ជំនុំជម្រះឆ្កែចចកដែលពាក់រោមចៀម ហើយតាំងបល្ល័ង្ករបស់ទ្រង់នៅលើនគរហិនហោចរបស់អារក្សសាតាំង។ យើងខ្ញុំអធិស្ឋានក្នុងព្រះនាមរបស់ព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

# ឧបសម្ពន្ធទី១

# ក្រុមពីរដែលទទួលយកគោលលទ្ធិនៃព្រះត្រៃឯក តែបន្ថែមគោលលទ្ធិថ្មី

## សេវេន ដេយ អាត់វេនទីស្ទ

**Seventh Day Adventist Church**

**Silver Spring, Maryland, USA**

ទោះបីក្រុម សេវេន ដេយ អាត់វេនទីស្ទ (Seventh Day Adventists) មិនពឹងផ្អែកលើគោលលទ្ធិ ដូចគោលលទ្ធិនៃក្រុមប្រឹក្សាណៃសៀក៏ដោយ ក៏គោលលទ្ធិរបស់ពួកគេជាទូទៅ យល់ស្របនឹងសេចក្តីពិតដែលមាននៅក្នុងគោលលទ្ធិនៃក្រុមប្រឹក្សាណៃសៀដែរ។ ក៏ប៉ុន្តែ ដូចជារ៉ូម៉ាំងកាតូលិកដែរ ពួកសេវេន ដេយក៏បានបន្ថែមគោលលទ្ធិថ្មីៗជាច្រើន ដែលមិនមាននៅក្នុងព្រះគម្ពីរ។ គោល លទ្ធិថ្មីទាំងនោះមិនមែនមកពីសម្តេចប៉ាបទេ តែមកពីការនិមិត្ត និងការយល់សប្តិរបស់ស្ថាបនិកម្នាក់របស់គេ ឈ្មោះលោកស្រី អេលែន ជី វ៉ាយ (Ellen G. White)។

### ប្រវត្តិ

ចលនាក្រុម សេវេន ដេយ អាត់វេនទីស្ទ មានភាពចម្រូងចម្រាសតាំងពីដំបូងមក។ គ្រីស្ទបរិស័ទអាមេរិកកាំងម្នាក់ឈ្មោះ វីល្លៀម មីលឡឺ (William Miller) បានព្យាករណ៍ថា «ព្រះយេស៊ូវគ្រីស្ទនឹងយាងមកដល់ផែនដីនេះម្តងទៀត ដើម្បី សម្អាតបន្សុទ្ធ និងកាន់កាប់ផែនដីជាមួយពួកបរិសុទ្ធទាំងអស់» នៅមុនថ្ងៃទី ២១ ខែមិនា ឆ្នាំ ១៨៤៤។ នៅពេលដែលការព្យាករណ៍នោះបរាជ័យ ក្រុមរបស់លោក មីលឡឺ បានផ្លាស់ប្តូរ កាលបរិច្ឆេទដល់ថ្ងៃទី ២២ ខែតុលា ឆ្នាំ១៨៤៤វិញ ប៉ុន្តែជាថ្មីម្តងទៀត

ព្រះគ្រីស្ទមិនបានយាងមកវិញទេ។ បន្ទាប់ពីការខកចិត្តលើកទី២នោះ អ្នកគាំទ្ររបស់គាត់ខ្លះបានពន្យល់ថា កាលបរិច្ឆេទថ្ងៃទី ២២ ខែតុលា គឺត្រឹមត្រូវហើយ កំហុសមិនមែនជា*ថ្ងៃខែ*នៃការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទទេ ប៉ុន្តែកំហុសជា*កន្លែង*នៃការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទវិញ។ ពួកគេបានអះអាងថា ព្រះគ្រីស្ទមិនបានយាងមករហូតដល់ផែនដីនៅថ្ងៃនោះ ដូចដែលលោក មីលឡឺ បានទាយនោះទេ ប៉ុន្តែថា ទ្រង់បានយាងចូលមកក្នុងទីបរិសុទ្ធនៅស្ថានសួគ៌ ដើម្បីសម្អាតវា ហើយរៀបចំសម្រាប់ការយាងត្រឡប់មក របស់ទ្រង់នៅពេលក្រោយ។ តាមពិតគ្មានអ្នកណានៅផែនដី ដែលអាចឃើញព្រះយេស៊ូវយាងចូលទីបរិសុទ្ធនៅស្ថានសួគ៌ទេ។ ដូច្នេះ មិនអាចមានភ័ស្តុតាងណាដែលបញ្ជាក់ថា ព្រឹត្តិការណ៍នេះ ពិតជាបានកើតឡើងនោះទេ។ ផ្ទុយទៅវិញ គម្ពីរព្រះអង្គមានបន្ទូលថា នៅពេលព្រះយេស៊ូវយាងត្រឡប់មកវិញ *«គ្រប់ទាំងភ្នែកនឹងឃើញទ្រង់»* (វិវរណៈ ១:៧)។

ដូច្នេះលោកមីលឡឺ និងអ្នកដើរតាមគាត់បានបរាជ័យតាមវិធីពីរយ៉ាង។ ទីមួយ ពួកគេបានផ្តល់ការព្យាករណ៍ខុសឆ្គង អំពីការយាងមករបស់ព្រះគ្រីស្ទ ជំនួសឲ្យការស្តាប់ការព្រមានរបស់ព្រះយេស៊ូវថា *«អ្នករាល់គ្នាមិនដឹងជាថ្ងៃណា ឬពេលណា»* (ម៉ាថាយ ២៥:១៣)។ ទីពីរ អ្នកតាមលោកមីលឡឺ បានបង្រៀនការដែលមិនមាននៅក្នុងព្រះគម្ពីរ ដែលថា ព្រះគ្រីស្ទនឹងយាងមកក្នុងរបៀបស្ងាត់ ដើម្បីចូលក្នុងទីបរិសុទ្ធនៅស្ថានសួគ៌ ហើយបន្សុទ្ធកន្លែងនោះ មុនពេលទ្រង់យាងត្រឡប់មកវិញជាសាធារណៈ។ ពីព្រោះព្រះគម្ពីរមិនដែលបង្រៀនការនេះ វាមិនគួរក្លាយជាគោលលទ្ធិសំខាន់មួយនៅក្នុងក្រុមជំនុំសេវេនដេយនោះទេ។ តាមពិតហេព្រើរជំពូក ៩ មានបន្ទូលថា ព្រះគ្រីស្ទបានយាងចូលទៅក្នុងទីបរិសុទ្ធ**ហើយ** ២០០០ ឆ្នាំមុន បន្ទាប់ពីការសុគត និងការរស់ឡើងវិញរបស់ទ្រង់៖ *«ប៉ុន្តែ កាលព្រះគ្រីស្ទបានយាងមក ធ្វើជាសំដេចសង្ឃ ខាងឯសេចក្តីល្អដែលត្រូវមក គឺធ្វើដោយសាររោងឧបោសថដ៏*

*វិសេសជាង ហើយគ្រប់លក្ខណ៍ជាង ដែលមិនបានធ្វើដោយដៃ គឺថា មិនមែនជារបស់ផងលោកីយ៍នេះទេ នោះ**ទ្រង់បានយាងចូលទៅក្នុងទីបរិសុទ្ធបំផុត១ដងជាសំរេច** ទាំងបានសេចក្តីប្រោសលោះ នៅអស់កល្បជានិច្ច មិនមែនដោយយកឈាមពពែឈ្មោល ឬឈាមកូនគោទេ គឺដោយយកព្រះលោហិតនៃអង្គទ្រង់វិញ»* (៩:១១-១២)។ មួយដងជាសំរេច! មិនចាំបាច់ត្រូវការការបន្សុទ្ធ ឬការវិនិច្ឆ័យបន្ថែម នៅស្ថានសួគ៌ទៀតទេ។

បន្ទាប់ពីការព្យាករណ៍បរាជ័យពីរដង អ្នកដើរតាមលោក មីលឡឺ ភាគច្រើនបានចាកចេញពីចលនានេះ។ ប៉ុន្តែអ្នកដែលនៅសេសសល់ រួមមាន លោក ចេម វ៉ាយ (James White) និងភរិយារបស់គាត់លោកស្រី អេលែន ជី វ៉ាយ បានបង្កើតនិកាយ សេវេន ដេយ អាត់វេនទីស្ទ ដែលឥឡូវនេះមានសមាជិក ១៩ លាននាក់ នៅជុំវិញពិភពលោក។ លោកស្រី អេលែន ជី វ៉ាយ (Ellen G. White) បានក្លាយជាគ្រូបង្រៀនដ៏សំខាន់បំផុតនៃនិកាយនោះ។ គាត់បានសរសេរសៀវភៅជាង ៤០ ក្បាល និងអត្ថបទទស្សនាវដ្តីចំនួន ៥០០០។ គាត់អះអាងថា បានទទួលការយល់សប្តិ និងនិមិត្ត ពីព្រះផ្ទាល់ ជាង ២០០០ដង។

## ជំនឿ

ដូចដែលខ្ញុំបាននិយាយហើយថា សេចក្តីថ្លែងការណ៍ជាផ្លូវការរបស់និកាយ សេវេន ដេយ អាត់វេនទីស្ទ អំពីព្រះ ព្រះគម្ពីរ ព្រះត្រៃឯក និងការសង្គ្រោះដោយព្រះគុណតាមរយៈជំនឿ គឺស្របតាមព្រះគម្ពីរ។ ប៉ុន្តែពួកគេបានបន្ថែមជំនឿចម្លែកមួយចំនួនដែលខុសពីជំនឿដែលគ្រីស្ទបរិស័ទបានប្រកាន់ខ្ជាប់អស់រយៈពេល ២០០០ ឆ្នាំមកហើយ។

## តើការថ្វាយបង្គំនៅថ្ងៃអាទិត្យជា «ទីសម្គាល់របស់សត្វសាហាវ» ឬ?

នៅគម្ពីរវិវរណៈ ១៣ៈ១១-១៨ មានបន្ទូលថា នៅថ្ងៃចុងក្រោយ មេសេចក្តីអាក្រក់ដែលហៅថា *«សត្វសាហាវ»* នឹងបង្ខំមនុស្សឲ្យទទួលសញ្ញាសម្គាល់នៅលើដៃ ឬក៏ថ្ងាសរបស់ពួកគេ។ នេះគម្ពីរហៅថា *«ទីសំគាល់របស់សត្វ»* (វិវរណៈ ១៦ៈ២; ១៩ៈ២០)។ អេលែន ជី វ៉ាយ និងក្រុម សេវេន ដេយ បានបង្រៀនម្តងហើយម្តងទៀត នៅក្នុងសៀវភៅ និងទស្សនាវដ្តីរបស់ពួកគេថា «ទីសំគាល់របស់សត្វ» គឺជាសកម្មភាពផ្លាស់ប្តូរថ្ងៃឈប់សម្រាក ពីថ្ងៃសៅរ៍ ទៅថ្ងៃអាទិត្យវិញ! អេលែន ជី វ៉ាយ បាននិយាយថា «នៅទីនេះយើងរកឃើញទីសំគាល់របស់សត្វ។ គឺសកម្មភាពនៃការផ្លាស់ប្តូរថ្ងៃឈប់សម្រាកទៅថ្ងៃអាទិត្យ របស់ក្រុមជំនុំកាតូលិក ដោយគ្មានសិទ្ធិអំណាចពីព្រះគម្ពីរឡើយ»។ (Ellen G. White, The Mark of the Beast, ទំព័រទី ២៣)។ អរគុណព្រះអង្គណាស់ សព្វថ្ងៃនេះ ពួក សេវេន ដេយ ជាច្រើនលែងជឿទៀតថា គ្រីស្ទបរិស័ទដែលថ្វាយបង្គំនៅថ្ងៃអាទិត្យបានទទួល «ទីសំគាល់របស់សត្វ» ប៉ុន្តែក៏នៅមានមនុស្សជាច្រើននៅតែជឿដដែល។

ខ្ញុំធ្លាប់សួរមិត្តខ្ញុំដែលជាបេសកជនរបស់និកាយ សេវេន ដេយ ថា តើខ្ញុំមានទីសំគាល់របស់សត្វ ដោយព្រោះខ្ញុំថ្វាយបង្គំនៅថ្ងៃអាទិត្យឬ។ គាត់បាននិយាយថា «មិនទាន់ទេ។ ប៉ុន្តែប្រសិនបើអ្នកនៅតែបន្តប្រព្រឹត្តអំពើខុសឆ្គងនោះ អ្នកនឹងបង្ហាញថា អ្នកពិតជាមាន»។

ទាក់ទងនឹងថ្ងៃថ្វាយបង្គំ គម្ពីររ៉ូម ១៤ៈ៥ មានបន្ទូលថា គ្រីស្ទបរិស័ទមានសេរីភាពក្នុងការជ្រើសរើស ថ្ងៃពិសេសណាមួយ ឬក៏គ្មានថ្ងៃពិសេសសោះ *«ម្នាក់រាប់ថា ថ្ងៃ១ល្អជាងថ្ងៃ១ ម្នាក់ទៀតរាប់ថា ថ្ងៃណាក៏ដូចជាថ្ងៃណា ត្រូវឲ្យគ្រប់គ្នាជឿពិតប្រាកដក្នុងចិត្តខ្លួន»*។ គម្ពីរ រ៉ូម ៦ៈ១៤ បង្រៀនថា គ្រីស្ទបរិស័ទមិនស្ថិតនៅក្រោមក្រឹត្យវិន័យទៀតឡើយ។ ទោះបីជាយើងស្រឡាញ់ក្រឹត្យវិន័យទាំង ១០ប្រការ

ក៏ដោយ កិច្ចព្រមព្រៀងថ្មីរបស់គ្រីស្ទបរិស័ទយើង គឺពឹងផ្អែកលើព្រះលោហិតរបស់ព្រះគ្រីស្ទ មិនមែនក្រឹត្យវិន័យនៃភ្នំស៊ីណាយទេ។ ព្រះយេស៊ូវបាននាំមកនូវកិច្ចព្រមព្រៀងថ្មីដែលប្រសើរជាង (ហេព្រើរ ៧:២២) ដែលមានមូលដ្ឋានលើភ្នំកាល់វ៉ារី ដែលជំនួសឲ្យកិច្ចព្រមព្រៀងមុនដែលមានមូលដ្ឋានលើភ្នំស៊ីណាយ៖ *«ទ្រង់ជាអ្នកកណ្ដាលរបស់សេចក្ដីសញ្ញា១ដ៏ប្រសើរជាងប៉ុណ្ណា ដែលសេចក្ដីសញ្ញានោះបានតាំងឡើង លើពាក្យសន្យាប្រសើរជាងផង»* (ហេព្រើរ ៨:៦)។ រយៈពេលជិត២០០០ឆ្នាំ ក្រុមជំនុំរបស់គ្រីស្ទបរិស័ទបានថ្វាយបង្គំនៅថ្ងៃទីមួយ ដើម្បីប្រារព្ធការរស់ឡើងវិញរបស់ព្រះគ្រីស្ទ។

## តើព្រលឹងរបស់គ្រីស្ទបរិស័ទលែងមាននៅពេលពួកគេស្លាប់ឬ?

គេហទំព័ររបស់ក្រុម សេវេន ដេយ និយាយថា «ព្រះគម្ពីរមិនបង្រៀនថា មនុស្សមានព្រលឹងអមតៈ ដែលនៅតែបន្តមាន បន្ទាប់ពីស្លាប់នោះទេ»។ និយាយម្យ៉ាងទៀត គេជឿថា នៅពេលដែលរូបកាយរបស់មនុស្សម្នាក់ស្លាប់ទៅ នោះចិត្តគំនិត និងព្រលឹងវិញ្ញាណរបស់បុគ្គលនោះ **លែងមាន**រហូតដល់រូបកាយរបស់គាត់ត្រូវបានរស់ឡើងវិញ នៅពេលព្រះគ្រីស្ទយាងមក។ ពេលខ្លះក្រុម សេវេន ដេយ ហៅការនេះថា «ព្រលឹងដេកលក់» ប៉ុន្តែពាក្យនោះមិនត្រឹមត្រូវទេ។ វិញ្ញាណរបស់មនុស្សស្លាប់មិនមែនគ្រាន់តែដេកលក់នោះទេ ពួកគេជឿថា វិញ្ញាណនោះ**លែងមានទៀតហើយ**។ ក៏ប៉ុន្តែ ការបង្រៀននេះផ្ទុយពីព្រះគម្ពីរ និងជំនឿគ្រីស្ទបរិស័ទរយៈពេល ២០០០ឆ្នាំកន្លងមក។

ដើម្បីដឹងថា ការបង្រៀននេះ មិនត្រឹមត្រូវ យើងត្រូវចងចាំព្រះបន្ទូលរបស់ព្រះយេស៊ូវចំពោះពួកសាឌូស៊ី ដែលមានជំនឿស្រដៀងនឹងពួកសេវេនដេយ ត្រង់បញ្ហានេះ។ ដំបូងទ្រង់បានរំឭកពួកគេអំពី ការដែលព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់លោក ម៉ូសេ នៅឯគុម្ពបន្លាដែលកំពុងឆេះ៖ *«អញ**ជា**ព្រះនៃអ័ប្រាហាំ **ជា**ព្រះនៃ*

*អ៊ីសាក ហើយ**ជា**ព្រះនៃយ៉ាកុប»* (មិនមែន *«អញ**ធ្លាប់**ជាព្រះនៃអ័ប្រាហាំ»* ។ល។) នោះទេ។ បន្ទាប់មកព្រះយេស៊ូវបានបញ្ជាក់ថា *«ព្រះអង្គទ្រង់មិនមែនជាព្រះនៃមនុស្សស្លាប់ទេ គឺជាព្រះនៃមនុស្សរស់វិញ»* ព្រះយេស៊ូវកំពុងមានបន្ទូលថា សូម្បីតែ អ័ប្រាហាំ អ៊ីសាក និងយ៉ាកុប បានស្លាប់៤០០ឆ្នាំមុនសម័យម៉ូសេ តែពួកគេនៅរស់ជាមួយព្រះអង្គនៅស្ថានសួគ៌ (ម៉ាថាយ ២២:៣២)។ ពួកគេមិនមែនលែងមានទៀត ដោយសារតែរូបកាយរបស់ពួកគេបានស្លាប់នោះទេ។ ក្រុម សេវេន ដេយ មានជំនឿខុសឆ្គងអំពីរូបកាយ និងព្រលឹង។

សូមចងចាំផងដែរថា លោក ម៉ូសេ បានជួបជាមួយព្រះយេស៊ូវនៅលើភ្នំ នៅពេលទ្រង់ផ្លាស់ប្រែរូបកាយ (ម៉ាថាយ ១៧:១-៩) ១៤០០ឆ្នាំ បន្ទាប់ពីគាត់បានស្លាប់! ដូច្នេះលោក ម៉ូសេ មិនមែនលែងមានទៀត នៅពេលគាត់ស្លាប់នោះទេ។ (ដើម្បីពន្យល់រឿងនេះក្រុមជំនុំ សេវេន ដេយ ទទូចដោយគ្មានភ័ស្តុតាងក្នុងព្រះគម្ពីរថា ព្រះបានប្រោសសាកសព លោកម៉ូសេឡើងវិញ នៅពេលណាមួយបន្ទាប់ពីគាត់ស្លាប់)។

មិនត្រឹមតែប៉ុណ្ណោះ ព្រះយេស៊ូវមានបន្ទូលទៅចោរនៅលើឈើឆ្កាងថា *«**ថ្ងៃនេះ** អ្នកនឹងនៅក្នុងស្ថានបរមសុខជាមួយនឹងខ្ញុំដែរ»* (លូកា ២៣:៤៣)។ តើព្រះយេស៊ូវ និងចោរនោះអាចនៅជាមួយគ្នាក្នុងឋានសួគ៌ដោយរបៀបណា ប្រសិនបើការស្លាប់នៃរូបកាយ ក៏នាំឲ្យលែងមានខាងវិញ្ញាណដែរនោះ?

មួយទៀត នៅក្នុងគម្ពីរវិវរណៈជំពូក ៦ ព្រលឹងនៃអ្នកដែលត្រូវបានគេសម្លាប់កំពុងអធិស្ឋានដល់ព្រះ (វិវរណៈ ៦:៩-១០)។ និយាយម្យ៉ាងទៀត វិញ្ញាណរបស់ពួកគេមិនមែនលែងមាននោះឡើយ នៅពេលដែលរូបកាយរបស់ពួកគេស្លាប់ទៅ។ លើសពីនេះទៅទៀត ព្រះយេស៊ូវបានប្រាប់រឿងមួយនៅក្នុងគម្ពីរលូកាជំពូក១៦ អំពីបុរសអ្នកមានម្នាក់ និងអ្នកសុំទានម្នាក់ ដែលទាំងពីរនាក់នោះនៅតែដឹងខ្លួន បន្ទាប់ពីស្លាប់

ទៅ។ រឿងនោះនឹងគួរឲ្យអស់សំណើច ហើយគ្មានអត្ថន័យ បើព្រះយេស៊ូវជឿថា វិញ្ញាណរបស់មនុស្សស្លាប់លែងមានទៀតហើយ។

ទីបំផុតសាវកប៉ុលបាននិយាយថា *«ដ្បិតឯខ្ញុំ ដែលខ្ញុំរស់នៅ នោះគឺសំរាប់ព្រះគ្រីស្ទទេ ហើយដែលស្លាប់ទៅ នោះជា**កំរៃ**វិញ ប៉ុន្តែបើរស់ខាងឯសាច់ឈាម និងនាំឲ្យការខ្ញុំកើតផល នោះខ្ញុំមិនដឹងរើសយកខាងណាទេ ខ្ញុំមានសេចក្តីបណ្តាលទាំងសងខាង ក៏មានចិត្តចង់**ចេញទៅនៅជាមួយនឹងព្រះគ្រីស្ទ** ដែលល្អជាជាងនោះផង តែបើខ្ញុំនៅក្នុងសាច់ឈាមតទៅទៀត នោះមានប្រយោជន៍ដល់អ្នករាល់គ្នាជាជាង»* (ភីលីព ១:២១-២៤)។ តើការលែងមានព្រលឹងរបស់សាវកប៉ុល អាចល្អប្រសើរជាងការបម្រើព្រះរបស់គាត់យ៉ាងដូចម្តេច? គាត់និយាយស្រដៀងនឹងនេះ ចំពោះគ្រីស្ទបរិស័ទនៅក្រុងកូរិនថូសថា *«ដូច្នេះ យើងខ្ញុំមានចិត្តជឿជាក់ ហើយក៏សុខចិត្តស៊ូចេញពីរូបកាយនេះ ទៅនៅជាមួយនឹងព្រះអម្ចាស់ជាជាង»* (២កូរិនថូស ៥:៨)។

**តើត្រឹមត្រូវទេ ក្នុងការហាមឃាត់ការបរិភោគអាហារមួយចំនួន?**

និកាយសេវេន ដេយ បង្រៀនថា គ្រីស្ទបរិស័ទគួរ «តមម្ហូបដែលគម្ពីរហៅថា មិនស្អាត (ស្មោកគ្រោក)» (ជំនឿមូលដ្ឋាន ២៨)។ ប៉ុន្តែ សាវកប៉ុលបានព្រមានអំពីគ្រូបង្រៀន ដែលហាមឃាត់ការទទួលទានអាហារប្រភេទខ្លះ ដែលព្រះអនុញ្ញាតឲ្យយើងបរិភោគ៖

> *«តែព្រះវិញ្ញាណ ទ្រង់មានព្រះបន្ទូលយ៉ាងជាក់ច្បាស់ថា នៅគ្រាជាន់ក្រោយបង្អស់ អ្នកខ្លះនឹងលាកចាកចេញពីសេចក្តីជំនឿ ដោយស្តាប់តាមវិញ្ញាណបញ្ឆោត និងសេចក្តីបង្រៀនរបស់ពួកអារក្ស ដោយសារពុតមាយារបស់ពួកអ្នកដែលពោលតែពាក្យកុហក ទាំងមានបញ្ញាចិត្តរលោក ព្រមទាំងហាមប្រាមមិនឲ្យយកប្តីប្រពន្ធ ហើយឲ្យត្រូវតមអាហារ ដែលព្រះបានបង្កើតមក សំរាប់ពួកអ្នកជឿ និងពួកអ្នកដែលស្គាល់សេចក្តីពិត ឲ្យបានទទួលដោយអរព្រះគុណ ដ្បិតសត្វ*

*ទាំងអស់ដែលព្រះទ្រង់បង្កើតមក នោះសុទ្ធតែល្អ ហើយមិនត្រូវចោល១ឡើយ ឲ្យគ្រាន់តែទទួលដោយអរព្រះគុណប៉ុណ្ណោះ ដ្បិតបានញែកជាបរិសុទ្ធ ដោយសារព្រះបន្ទូល ហើយសេចក្ដីអធិស្ឋាន»* (១ធីម៉ូថេ ៤:១-៥)។

សាវកប៉ុលនិយាយដូចនេះ ពីព្រោះព្រះយេស៊ូវបានបង្រៀនយូរឆ្នាំមុនថា *«អស់ទាំងអាហារឈ្មោះថា ជារបស់ស្អាត»*។

*«ទ្រង់មានព្រះបន្ទូលថា តើអ្នករាល់គ្នានៅតែមិនយល់ដែរឬអី តើអ្នករាល់គ្នានឹកមិនឃើញទេឬអីថា របស់អ្វីពីខាងក្រៅដែលចូលក្នុងមនុស្ស នោះពុំអាចនឹងធ្វើឲ្យស្មោកគ្រោកបានទេ ដ្បិតរបស់នោះមិនបានចូលទៅក្នុងចិត្ត គឺចូលទៅតែក្នុងពោះប៉ុណ្ណោះ រួចចេញទៅក្នុងបង្គន់ ដូច្នេះ អស់ទាំងអាហារឈ្មោះថា ជារបស់ស្អាតវិញ»* (ម៉ាកុស ៧:១៨-១៩)។

ព្រះយេស៊ូវបានប្រកាសថា *«អស់ទាំងអាហារឈ្មោះថា ជារបស់ស្អាត»*។ តើយើងហ៊ានហាមឃាត់អ្វីដែលព្រះយេស៊ូវផ្ទាល់បានអនុញ្ញាតឬទេ?

គម្ពីររ៉ូមជំពូក ១៤ បញ្ជាក់យ៉ាងច្បាស់ថា គ្រីស្ទបរិស័ទមានសិទ្ធិតមអាហារខ្លះប្រសិនបើគាត់ចង់។ ប៉ុន្តែ សាវក ប៉ុល ក៏ហាមបុគ្គលនោះ មិនឲ្យដាក់សំពាធអ្នកដទៃឲ្យឈប់ទទួលទានអាហារទាំងនោះដែរនោះទេ (រ៉ូម ១៤:៣-៤)។ តែអេលែន ជី វ៉ាយ បាននិយាយជាច្រើនដងថា គ្រីស្ទបរិស័ទត្រូវតែតមអាហារ ដែលគម្ពីរសញ្ញាចាស់មិនអនុញ្ញាត។ គាត់ចង់ដកការមានសេរីភាព ដែលព្រះគ្រីស្ទផ្ទាល់បានប្រទានមកយើងខាងចំណីអាហារ។ តើយើងគួរតឹងតែងជាងព្រះឬទេ?

## ការចាប់ផ្ដើមមិនល្អទាក់ទងនឹងគោលលទ្ធិនៃព្រះត្រៃឯក

មេដឹកនាំដំបូងទាំងអស់នៃក្រុម សេវេន ដេយ បានប្រឆាំងនឹងព្រះត្រៃឯក។ ពួកគេមិនជឿថា ព្រះវិញ្ញាណបរិសុទ្ធ គឺអង្គទីបីនៃព្រះត្រៃឯកទេ។ ហើយពួកគេខ្លះ

ថៃមទាំងជឿថា ព្រះរាជបុត្រានៃព្រះ ត្រូវបានបង្កើតឡើងដោយព្រះវរបិតា ដូចគ្រូខុសឆ្គងអារីយូស បានបង្រៀននៅសតវត្សទី៣ និងទី៤! ប៉ុន្តែ អរគុណព្រះអង្គ ៥០ ឆ្នាំក្រោយមក អេលែន ជី វ៉ាយ និងប្ដីរបស់គាត់ឈ្មោះ ចេម (James) បានចាប់ចាប់ផ្ដើមយល់ថា ព្រះយេស៊ូវ គឺជាព្រះរាជបុត្រាដ៏អស់កល្បរបស់ព្រះ មិនមែនជារបស់ដែលព្រះវរបិតាបានបង្កើតឡើងទេ។ ហើយនៅឆ្នាំ ១៩០៥ ពួកគេក៏ចាប់ផ្ដើមជឿថា ព្រះវិញ្ញាណបរិសុទ្ធ គឺជាព្រះដែរ គឺអង្គទីបីនៃព្រះត្រៃឯក។ វាគឺជាការអស្ចារ្យនៃសេចក្ដីមេត្តាករុណារបស់ព្រះ ដែលនៅទីបំផុតមេដឹកនាំនៃនិកាយ សេវេន ដេយ បានកែតម្រូវទស្សនៈដំបូងរបស់ពួកគេ អំពីព្រះត្រៃឯក។ នៅឆ្នាំ ១៩៤៦ ពួកគេបានបោះពុម្ពផ្សាយសេចក្ដីថ្លែងការណ៍ផ្លូវការដ៏រឹងមាំមួយ ស្ដីអំពីព្រះត្រៃឯក ដែលពួកគេប្រកាន់ខ្ជាប់ដល់បច្ចុប្បន្ន។

ហេតុអ្វីបានជាយើងលើករឿងនេះឡើង បើនិកាយសេវេន ដេយ បានកែគោលជំនឿអំពីព្រះត្រៃឯកជាងចិតសិបឆ្នាំមុនហើយ? មានមូលហេតុពីរ៖ ១. នៅពេលដែលនិកាយនឹកចាំអំពីកំហុសធ្ងន់ធ្ងររបស់ខ្លួន មិនថា កំហុសខាងគោលជំនឿ ឬការអនុវត្តន៍ ការនឹកចាំនោះនាំឲ្យគេចង់បង្ហាញចិត្តសុភាព និងអត់ធ្មត់ ចំពោះក្រុមឯទៀតក្នុងរឿងដែលមិនសូវសំខាន់ ដូចជា ម្ហូបអាហារ និងថ្ងៃពិសេស។ ២. ការនឹកចាំនោះផ្ដល់ឲ្យនិកាយនោះ មានឱកាសគិតពិចារណាម្ដងទៀត អំពីមូលដ្ឋាននៃសេចក្ដីពិតរបស់គេ។ ទំនៀមទម្លាប់ឬ? ការបង្រៀនរបស់មនុស្សឬ? និមិត្តឬ? ព្រះគម្ពីរឬ? ឧទាហរណ៍ បើអេលែន ជី វ៉ាយបានទទួលនិមិត្ត និងយល់សប្តិពីព្រះផ្ទាល់ ២០០០ដង (ជាមធ្យម ២ដង ក្នុងមួយខែ!) ហេតុអ្វីបានជាអស់ ៥០ឆ្នាំ ទំរាំព្រះបើកសម្ដែងគោលលទ្ធិនៃព្រះត្រៃឯក ចំពោះ អេលែន ជី វ៉ាយ គឺជាគោលលទ្ធិដែលគ្រីស្ទបរិស័ទដទៃទៀតបានស្គាល់ និងទទួល តាំងពីសម័យពួកសាវកមកម្ល៉េះ?

## តើ«ប្រភពនៃសេចក្តីពិត» គឺជាអ្វី?

ក្រុមសេវេន ដេយនិយាយថា អេលែន ជី វ៉ាយ (១៨២៧-១៩១៥) គឺជាព្យាការីមកពីព្រះ។ សំណេររបស់នាង «គឺជាប្រភពនៃសេចក្តីពិតដែលបន្ត និងមានសិទ្ធិអំណាច» (ជំនឿមូលដ្ឋាន ២៨)។ ពួកគេអះអាងថា គុណភាព និងកំរិតនៃការបំផុសគំនិតនៅក្នុងសំណេររបស់ អេលែន ជី វ៉ាយ គឺស្មើគ្នានឹងបទគម្ពីរដែរ។ ប៉ុន្តែការសរសេររបស់ អេលែន ជី វ៉ាយ មិនអាចជា «**ប្រភព**នៃសេចក្តីពិតដែលបន្ត និងមានសិទ្ធិអំណាច» ទេ ពីព្រោះមានតែព្រះគម្ពីរចំនួន ៦៦ កណ្ឌតែប៉ុណ្ណោះ ដែលជា**ប្រភព**នៃសេចក្តីពិត ពីព្រោះមានតែព្រះគម្ពីរដែល *«ព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណ»* ហើយគ្មានកំហុស (២ធីម៉ូថេ ៣:១៦)។ ពាក្យរបស់មនុស្ស អាចមានសេចក្តីពិតច្រើន ប៉ុន្តែពាក្យនោះមិនអាចជា **ប្រភព**នៃការពិតទេ។ មានតែព្រះគម្ពីរប៉ុណ្ណោះ ដែលអាចជឿទុកចិត្តបានទាំងស្រុង។

## សេចក្តីសន្និដ្ឋាន

ពួកសេវេន ដេយ ភាគច្រើនជឿថា ការសង្គ្រោះ គឺដោយសារជំនឿតែប៉ុណ្ណោះ។ ពួកគេមិនជឿថា ការថ្វាយបង្គំនៅថ្ងៃអាទិត្យ គឺជាទីសំគាល់របស់សត្វនោះទេ ហើយមិនព្រមនិយាយថា ការបរិភោគសាច់ជ្រូក គឺជាអំពើបាបទេ។ ហើយពួកគេមិនជឿថា សេចក្តីសង្គ្រោះមកតាមតែក្រុម សេវេន ដេយ នោះទេ។

ប៉ុន្តែនេះជាបញ្ហា៖ នៅពេលនិកាយណាមួយលើកតម្កើងច្បាប់អំពីអាហារ និងថ្ងៃឈប់សម្រាកដល់កំរិតមួយ ដែលមានសារៈសំខាន់មែនទែន នោះសមាជិករបស់ពួកគេជាច្រើន នឹងច្រលំ អំពីទំនាក់ទំនងរវាងជំនឿ និងការប្រព្រឹត្ត។ តាមធម្មជាតិមនុស្សទាំងអស់ចាប់អារម្មណ៍ចំពោះសាសនាដែលបង្រៀនថា «ធ្វើល្អ បានល្អ»។ យើងចូលចិត្តគំនិតដែលយើងអាចទទួលការសព្វព្រះហឫទ័យពីព្រះ តាមរយៈការខិតខំរបស់យើង។ ដូចពួកផារិស៊ីដែរ យើងចូលចិត្តគិតថា ខ្លួនល្អជាងអ្នកដែលមិន

បានធ្វើតាមច្បាប់ដូចយើង។ បន្តិចម្តងៗ ក្រុមជំនុំដែលលើកក្បួនច្បាប់របស់មនុស្ស ឲ្យសំខាន់ពេក នឹងក្លាយជាក្រុមជំនុំដែលតម្រូវឲ្យមានការប្រព្រឹត្តល្អដើម្បីបាន សង្គ្រោះ។ អរគុណព្រះអង្គដែល សេចក្តីថ្លែងការណ៍ខាងគោលលទ្ធិនៃក្រុមជំនុំ សេវេន ដេយ  បង្រៀនយ៉ាងច្បាស់អំពីការសង្គ្រោះ ដោយសេចក្តីជំនឿតែប៉ុណ្ណោះ។ (Twenty-eight Fundamental Beliefs of the Seventh Day Adventist church. https://www.adventist.org/wp-content/uploads/2020/06/ADV-28Beliefs2020.pdf)

ចុងក្រោយ នៅពេលខ្ញុំជួបអ្នក សេវេន ដេយ ដែលស្រឡាញ់ព្រះយេស៊ូវ ជឿលើ ដំណឹងល្អ ហើយមិនពឹងផ្អែកលើការធ្វើតាមក្រឹត្យវិន័យ គឺខ្ញុំបានជួបបងប្អូនពិតនៅ ក្នុងព្រះគ្រីស្ទ ហើយខ្ញុំរីករាយ។

# និកាយរ៉ូម៉ាំងកាតូលិក

## The Roman Catholic Church

## ទីក្រុង វ៉ាទីកង់

## Vatican City

ក្រុមជំនុំរ៉ូម៉ាំងកាតូលិកបញ្ជាក់ថា ព្រះគម្ពីរគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយបានរក្សានូវគោលលទ្ធិសំខាន់ៗ អំពីព្រះជាម្ចាស់ រួមទាំងគោលជំនឿអំពីព្រះត្រៃឯកផង។ ទោះយ៉ាងនេះក្តី ក្រុមជំនុំរ៉ូម៉ាំងកាតូលិកបានបន្ថែមគោលលទ្ធិជាច្រើនដែលព្រះគ្រីស្ទ និងសាវករបស់ទ្រង់មិនដែលបង្រៀន។ សំខាន់ជាងគេក្រុមជំនុំរ៉ូម៉ាំងកាតូលិក ហាក់ដូចជាមិនអាចបំពេញការងារសំខាន់ជាងគេ ដែលក្រុមជំនុំគ្រីស្ទបរិស័ទត្រូវបំពេញ គឺការពារដំណឹងល្អនៃសេចក្តីសង្គ្រោះ ដោយសារព្រះគុណតាមរយៈជំនឿលើព្រះគ្រីស្ទ មិនមែនដោយការប្រព្រឹត្តនោះទេ (អេភេសូរ ២:៨-៩) ហើយប្រកាសដំណឹងល្អនោះដល់លោកិយយ៉ាងច្បាស់លាស់។

នៅពេលខ្ញុំជួបរ៉ូម៉ាំងកាតូលិកម្នាក់ ហើយសួរគាត់ថា «តើអ្នកពឹងផ្អែកលើអ្វី ឬសង្ឃឹមលើអ្វី ដើម្បីនឹងមានជីវិតអស់កល្បជានិច្ច?» មានចំនួនតិចប៉ុណ្ណោះ ដែលឆ្លើយដោយប្រើពាក្យថា «ខ្ញុំពឹងលើព្រះយេស៊ូវ» ឬ «ព្រះគ្រីស្ទបានសុគតជំនួសអំពើបាបខ្ញុំ ហើយបានរស់ឡើងវិញ» ឬក៏ «ដំណឹងល្អ»។ សំណួរនេះគួរតែងាយស្រួលឆ្លើយសំរាប់គ្រីស្ទបរិស័ទ ប៉ុន្តែអ្នកកាន់និកាយកាតូលិកភាគច្រើនឆ្លើយដូចនេះវិញ៖ «ខ្ញុំព្យាយាមរក្សាក្រឹត្យវិន័យ១០ ប្រការ» ឬ «ខ្ញុំទៅចូលរួមពិធី ម៉ាស(Mass) រៀងរាល់សប្តាហ៍»។ល។ ជាការសោកស្តាយយ៉ាងខ្លាំងដែលពួកកាតូលិកចំនួនតិចមែនទែន

យល់ពីដំណឹងល្អនៃព្រះគុណរបស់ព្រះ។ (និយាយតាមត្រង់ សមាជិកនៃនិកាយប្រូតេស្តង់ធំៗភាគច្រើន ក៏មានការពិបាកដូចគ្នាក្នុងការផ្តល់ចម្លើយច្បាស់លាស់ចំពោះសំណួរខាងលើនេះដែរ។ សូមមើលជំពូក «គ្រីស្ទសាសនាសេរីនិយម» ខាងលើ)។

## ប្រវត្តិ

ក្នុងរយៈពេល ២០០ ឆ្នាំដំបូងនៃគ្រីស្ទសាសនា ក្រុមជំនុំចំនួន ៥ បានលេចធ្លោ និងមានឥទ្ធិពល។ នៅរាប់សិបឆ្នាំដំបូង ក្រុមជំនុំយេរូសាឡិមមានភាពលេចធ្លោ ពីព្រោះជាក្រុមជំនុំដំបូងគេ។ មិនយូរប៉ុន្មានក្រុមជំនុំនៅអាន់ទីយ៉ូក(៥០០គីឡូម៉ែត្រខាងជើងក្រុងយេរូសាឡិម) ក៏ចាប់ផ្តើមមានឥទ្ធិពលដែរ ជាមួយនឹងក្រុមជំនុំនៅក្រុងអាឡិចសាន់ឌ្រា ក្នុងស្រុកអេហ្ស៊ីប។ បន្ទាប់ពីនោះ ក្រុមជំនុំពីរទៀតក៏បានលេចធ្លោដែរ គឺក្រុមជំនុំនៅទីក្រុងរ៉ូម និងក្រុមជំនុំនៅខនស្តង់ទីណូប៉ូល (Constantinople ឈ្មោះចាស់ ប៊ីហ្សាង់ទីយូន Byzantion)។ ទោះបីជាក្រុមជំនុំទាំង ៥ នេះ មានភាពល្បីល្បាញ និងមានឥទ្ធិពលបំផុតក៏ដោយ ក៏គ្មានក្រុមជំនុំមួយណាក្នុងចំណោមក្រុមជំនុំទាំងនេះ ហ៊ានអះអាងថា ជាក្រុមជំនុំសំខាន់ជាងគេនោះទេ សូម្បីតែក្រុមជំនុំដំបូងគេនៅទីក្រុងយេរូសាឡិម។ ហើយគ្មានមួយណាក្នុងចំណោមក្រុមជំនុំទាំងនោះអះអាងថា មានគ្រូគង្វាល ឬ អ្នកគ្រប់គ្រង(Bishop)ដែលធំជាងគ្រូគង្វាលដទៃទៀត នៅក្នុងពិភពលោកនោះឡើយ។ នេះគឺជាស្ថានភាពដែលគួរតែនៅមានរហូតក្នុងប្រវត្តិសាស្ត្រនៃក្រុមជំនុំ។

ប៉ុន្តែមិនយូរប៉ុន្មានក្រុមជំនុំមួយ គឺក្រុមជំនុំនៅទីក្រុងរ៉ូមបានចាប់ផ្តើមតាំងខ្លួនថាធំជាងក្រុមជំនុំផ្សេងទៀតទាំងអស់ ដោយសារការអះអាងថា សាវកពេត្រុសផ្ទាល់បានធ្វើជាគ្រូគង្វាលរបស់ពួកគេ។ ក្រោយមកក្រុមជំនុំរ៉ូមបានក្លាយជាក្រុមជំនុំរ៉ូម៉ាំងកាតូលិក។

## តើពាក្យ «កាតូលិក» មានន័យដូចម្ដេច?

ពាក្យកាតូលិកមានន័យថា «ទូទាំងពិភពលោក» ឬ «ទទួលយក ឬទទួលស្គាល់ទូទៅ»។ នៅគ្រប់ជំនាន់ក្រុមជំនុំទាំងអស់នៅក្នុងពិភពលោក ដែលជឿលើដំណឹងល្អ និងគោលលទ្ធិរបស់ព្រះគ្រីស្ទ និងពួកសាវក រួមជាក្រុមជំនុំកាតូលិកពិតរបស់ព្រះ។ ប៉ុន្ដែពីរបីរយឆ្នាំបន្ទាប់ពីព្រះគ្រីស្ទ ក្រុមជំនុំនៅរ៉ូមបានចាប់ផ្ដើមអះអាងថា មានតែក្រុមជំនុំ ដែលបានចុះចូលនឹងអំណាចរបស់ក្រុមជំនុំរ៉ូម ហើយអ្នកគ្រប់គ្រងរបស់ពួកគេប៉ុណ្ណោះ ដែលជាកាតូលិក គឺត្រូវបានទទួលយក ឬទទួលស្គាល់។ ក្រុមជំនុំឯទៀត គេរាប់ថា ជាក្រុមជំនុំបែកចេញ។ ប៉ុន្ដែការអះអាងរបស់ក្រុមជំនុំរ៉ូមផ្ទុយពីអត្ថន័យ នៃពាក្យ«កាតូលិក»។ កាតូលិក មានន័យថា ទូទាំងពិភពលោក តែការអះអាងរបស់គេ ធ្វើឲ្យភាពកាតូលិក អាស្រ័យលើការចុះចូលចំពោះសិទ្ធិអំណាចនៃក្រុមជំនុំតែមួយ និងគ្រូគង្វាលតែមួយ ក្នុងទីក្រុងតែមួយ និង ក្នុងប្រទេសតែមួយ។ ការនោះមានភាពផ្ទុយពីអត្ថន័យកាតូលិក។ តើអ្នកគិតយ៉ាងម៉េច បើក្រុមជំនុំនៅក្រុងយេរូសាឡិមបានចាប់ផ្ដើមហៅខ្លួនឯងថា «ក្រុមជំនុំកាតូលិកយេរូសាឡិម» ដោយអះអាងថា មានតែក្រុមជំនុំដែលបានចុះចូលចំពោះអ្នកដឹកនាំរបស់គេប៉ុណ្ណោះ ដែលជាកាតូលិក? ក្រុមជំនុំរាប់ពាន់ផ្សេងទៀត ពិតជានឹងបដិសេធការអះអាងនេះ។ ហើយពិតមែន នៅពេលដែលក្រុមជំនុំរ៉ូមបានចាប់ផ្ដើមអះអាង ពីភាពជាអធិបតេយ្យរបស់ខ្លួនលើក្រុមជំនុំដទៃទៀត ក្រុមជំនុំផ្សេងទៀតពិតជាបានបដិសេធការអះអាងនោះ៖

«ក្នុងរយៈពេលពីរបីសតវត្សដំបូងនៃក្រុមជំនុំ គ្មានភ័ស្ដុតាងណាដែលថា ក្រុមជំនុំអាន់ទីយ៉ូក យេរូសាឡិម ឬអាឡិចសាន់ឌ្រា បានប្រគល់សិទ្ធិឲ្យអ្នកគ្រប់គ្រងក្រុមជំនុំរ៉ូម មានអំណាចលើពួកគេ ឬលើក្រុមជំនុំផ្សេងទៀតនៅក្នុងចក្រភពឡើយ។ តាមពិតមានភ័ស្ដុតាងគ្រប់គ្រាន់ សូម្បីតែសម័យក្រោយនោះទៀត ដែលក្រុមជំនុំនៅ

អាហ្វ្រិកខាងជើង និងនៅកន្លែងដូចជា ទីក្រុងមីឡាន [នៅអ៊ីតាលី] បានច្រានចោលការអះអាងដែលថា អ្នកគ្រប់គ្រងក្រុមជំនុំរ៉ូមមានអំណាចលើពួកគេ។ (https://www.trinityfoundation.org/journal.php?id=313#_ftn5)

រយៈពេលជាច្រើនឆ្នាំបន្ទាប់មក ក្រុមជំនុំរ៉ូមបានបន្តទទូចអំពីអធិបតេយ្យភាពរបស់ខ្លួន ហើយក្រុមជំនុំផ្សេងទៀតក៏បានបន្តបដិសេធការអះអាងនោះដែរ។ ឧទាហរណ៍ បន្ទាប់ពីក្រុមប្រឹក្សា ណៃសៀ (គ.ស ៣២៥) ក្រុមជំនុំរ៉ូមបានយកឯកសារផ្លូវការពីក្រុមប្រឹក្សាណៃសៀ ហើយបានចម្លងជាច្បាប់របស់ខ្លួនឯង។ ប៉ុន្តែគេបានបន្ថែមពាក្យទាំងនេះទៅក្នុងឯកសារនោះថា «ក្រុមជំនុំរ៉ូមតែងតែមានអាទិភាពជានិច្ច»! ១២៥ឆ្នាំក្រោយមកនៅឯក្រុមប្រឹក្សា កាលសេដូន (Chalcedon) ក្នុងឆ្នាំ ៤៥១ នៅពេលដែលអ្នកតំណាងមកពីក្រុមជំនុំរ៉ូមបានអានជាសាធារណៈនូវឯកសារណៃសៀច្បាប់របស់ខ្លួន (ដោយមានទាំងពាក្យបន្ថែមអំពីអាទិភាពរបស់ក្រុមជំនុំរ៉ូម) នោះក្រុមប្រឹក្សាទាំងមូលបានក្រោកឈរឡើងតវ៉ា និងទទូចទាមទារច្បាប់ដើមនៃឯកសារណៃសៀ។ គ្រូគង្វាលជាង៥០០នាក់នៅក្រុមប្រឹក្សា កាលសេដូន (Chalcedon) មិនព្រមទទួលការអះអាងអំពីអាទិភាពរបស់ក្រុមជំនុំរ៉ូមនោះឡើយ។ ដូច្នេះយើងឃើញថា ក្រោយបួនសតវត្សនៃគ្រីស្ទសាសនា ក្រុមជំនុំនៅលើពិភពលោក នៅតែមិនព្រមទទួលស្គាល់អធិបតេយ្យភាពរបស់ក្រុមជំនុំរ៉ូមលើក្រុមជំនុំផ្សេងទៀតនោះឡើយ។

**អំនួតនៃក្រុមជំនុំរ៉ូម៉ាំងកាតូលិក**

ដូចជាបុគ្គលម្នាក់ៗដែរ ក្រុមជំនុំក៏អាចធ្លាក់ក្នុងអំពើបាបនៃអំនួតដែរ។ សូមចងចាំការព្រមានរបស់ព្រះគ្រីស្ទចំពោះក្រុមជំនុំនៅឡៅឌីសេថា *«ដោយព្រោះឯងអួតថា ឯងជាអ្នកមានបានកាន់តែស្តុកស្តម្ភឡើងហើយ ក៏មិនត្រូវការនឹងអ្វីសោះ តែឯងមិនដឹងថា ឯងវេទនា លំបាក ទ័លក្រ ខ្វាក់ភ្នែក ហើយអាក្រាតវិញនោះទេ»* (វិវរណៈ

៣:១៧)។ ដូចក្រុមជំនុំឡៅឌីសេដែរ ក្រុមជំនុំរ៉ូម៉ាំងកាតូលិក ត្រូវល្បួងដោយសេចក្តីអំនួតតាំងពីឆ្នាំដំបូង។ ម្តងហើយម្តងទៀត ក្រុមជំនុំរ៉ូមបានព្យាយាមទាមទារសិទ្ធិអំណាចពិសេស លើក្រុមជំនុំផ្សេងទៀតទាំងអស់នៅក្នុងពិភពលោក។ នៅទីបំផុតពួកគេទទួលបានជោគជ័យ ពីព្រោះទីក្រុងរ៉ូមជារាជធានីនៃចក្រភពរ៉ូមដែលជាមហាអំណាច ហើយព្រះចៅអធិរាជរ៉ូម៉ាំង អាចប្រើឥទ្ធិពលរបស់ទ្រង់ ដើម្បីគាំទ្រការអះអាងរបស់ក្រុមជំនុំរ៉ូម ឲ្យធ្វើជាមេនៃក្រុមជំនុំទាំងអស់។

ទង្វើដ៏ក្រអឺតក្រទមបំផុតមួយនៅក្នុងប្រវត្តិសាស្ត្រក្រុមជំនុំ គឺក្រុមជំនុំរ៉ូម៉ាំងកាតូលិកបាន**បន្ថែមពាក្យទៅក្នុងគោលជំនឿណៃសៀ** (**Nicene Creed**)! (នេះគឺជា «ភាពចម្រូងចម្រាស ហ្វីឡូវគ្វេ (Filoque)»)។ ពួកគេបានធ្វើការនេះ ដោយខ្លួនឯងដោយមិនហៅ ក្រុមប្រឹក្សាសាសនា ដើម្បីធ្វើការសម្រេចចិត្តរួមគ្នាលើបញ្ហានេះទេ។ ដោយសារហេតុផលនេះ និងហេតុផលដែលទាក់ទងគ្នាទៀត នៅឆ្នាំ ១០៥៤ នៃគ.ស ក្រុមជំនុំនៅផ្នែកខាងកើតនៃពិភពលោកបានបែកចេញពីក្រុមជំនុំដែលមានភក្តីភាពនឹងរ៉ូមនៅភាគខាងលិច។ ហើយការបែកគ្នាដ៏ក្រៀមក្រំនេះ បានអូសបន្លាយដល់សព្វថ្ងៃ។ អំនួតតែងតែនាំឲ្យមានការបែកបាក់គ្នា។

នៅពេលដែលក្រុមជំនុំរ៉ូមកាន់តែខ្លាំងឡើងៗ គេតម្រូវឲ្យក្រុមជំនុំទូទាំងពិភពលោកចុះចូលចំពោះអ្នកគ្រប់គ្រងរបស់ក្រុមជំនុំរ៉ូម (សម្តេចប៉ាប)។ ប្រសិនបើពួកគេមិនចុះចូល នោះក្រុមជំនុំរ៉ូមនឹងប្រកាសថា ពួកគេលែងជាកាតូលិកទៀតហើយ ថែមទាំងចោទប្រកាន់ពួកគេថា ជាក្រុមដែលនាំឲ្យបែកបាក់ ទោះបីគោលលទ្ធិរបស់ពួកគេត្រឹមត្រូវ ហើយអ្នកដឹកនាំរបស់ពួកគេបរិសុទ្ធជាងសម្តេចប៉ាបក៏ដោយ! អ្នកគ្រប់គ្រងនៃក្រុមជំនុំរ៉ូមត្រូវបានគេស្គាល់ថា ជាឪពុកនៃសាសនាគ្រីស្ទ ឬ«ប៉ាប» (ប៉ាប៉ា) ទោះបីជានៅក្នុងម៉ាថាយ ២៣:៩ ព្រះយេស៊ូវបានហាមមេដឹកនាំក្រុមជំនុំមិនឲ្យទទួលងារជា *«ឪពុក»* ក៏ដោយ។

## អំនួតនៃការបន្ថែមគោលលទ្ធិ

របៀបធំជាងគេដែលក្រុមជំនុំរ៉ូមបង្ហាញអំពីអំនួតរបស់ខ្លួន គឺដោយការបន្ថែមគោលលទ្ធិថ្មី ដែលមិនមែនជាគោលជំនឿដែលព្រះគ្រីស្ទ និងពួកសាវកបានប្រគល់មក *«១ដងជាសំរេច»* (យូដាស ៣) នោះទេ។ ក្រុមជំនុំរ៉ូម៉ាំងកាតូលិក អះអាងថា ទំនៀមទំលាប់ថ្មីរបស់ក្រុមជំនុំកាតូលិក គឺមានសិទ្ធិអំណាចដូចជាព្រះគម្ពីរផ្ទាល់។ នៅក្នុងតារាងនេះអ្នកនឹងឃើញនូវគោលលទ្ធិដែលបន្ថែមដោយក្រុមជំនុំរ៉ូម៉ាំងកាតូលិក ដែលមិនមាននៅក្នុងការបង្រៀនរបស់ព្រះគ្រីស្ទ និងពួកសាវករបស់ទ្រង់ឡើយ។ សេចក្តីថ្លែងការណ៍ទាំងនេះ ដកស្រង់ពីឯកសាររ៉ូម៉ាំងកាតូលិក។ ក្បែរនឹងចំណុចនីមួយៗ ខ្ញុំបានបញ្ចូលការបង្រៀនមកពីព្រះគម្ពីរ។

| **គោលលទ្ធិដែលបន្ថែមដោយក្រុមជំនុំរ៉ូម៉ាំងកាតូលិក** | **សេចក្តីបង្រៀនរបស់ព្រះគ្រីស្ទ និងពួកសាវក** |
|---|---|
| ក្រុមជំនុំមិនមែនពឹងលើតែបទគម្ពីរតែប៉ុណ្ណោះ ដើម្បីយល់អំពីសេចក្តីពិតនោះទេ គឺត្រូវពឹងលើទំនៀមទំលាប់របស់ក្រុមជំនុំផងដែរ។ ទាំងបទគម្ពីរ និងទំនៀមទំលាប់ត្រូវតែទទួលយក ហើយនិងគោរពដោយភាពស្មើគ្នា។ (Catechism of the Catholic Church. 82) | គ្មានកន្លែងណាក្នុងព្រះគម្ពីរដែលនិយាយថា ទំនៀមទំលាប់របស់មនុស្ស និងក្រុមជំនុំ ស្មើនឹងបទគម្ពីរនោះទេ។ |
| មនុស្សអាចទទួលសេចក្តីសង្គ្រោះតាមរយៈជំនឿ បុណ្យជ្រមុជទឹក និង ការធ្វើតាមក្រឹត្យវិន័យ (ccc 2068) | នៅគម្ពីរកាឡាទី សាវកប៉ុលបានថ្កោលទោសឲ្យធ្លាក់នរក ចំពោះអ្នកណាដែលបន្ថែមការប្រព្រឹត្តតាមក្រឹត្យវិន័យជាមួយនឹងជំនឿលើព្រះគ្រីស្ទ។ |
| «ដោយមានការជំរុញពីព្រះវិញ្ញាណបរិសុទ្ធ យើងអាចសន្សំបុណ្យកុសលសម្រាប់ខ្លួនឯង និងសម្រាប់អ្នកដទៃ ដើម្បីទទួលបាននូវព្រះគុណទាំងអស់ដែលត្រូវការ ដើម្បីបានជីវិតអស់កល្បជានិច្ច...» (ccc 2027) | ព្រះគម្ពីរមានបន្ទូលថា គ្មានអ្នកបាបណាមានបុណ្យកុសល ឬសេចក្តីសុចរិតផ្ទាល់ខ្លួន ដែលនឹងជួយគាត់ ឬអ្នកដទៃនៅថ្ងៃជំនុំជម្រះនោះឡើយ។ |

| | |
|---|---|
| នាងម៉ារាមាតារបស់ព្រះយេស៊ូវ រួមជាមួយគ្រីស្ទបរិស័ទល្បីៗ ផ្សេងទៀត ដែលគេហៅថា «ពួកបរិសុទ្ធ» បានសន្សំបុណ្យកុសលលើសលប់ ដែលអាចប្រើសម្រាប់គ្រីស្ទបរិស័ទដទៃទៀត។ (CCC 1477) | ព្រះគម្ពីរប្រាប់ថា មានតែសេចក្ដីសុចរិតរបស់ព្រះគ្រីស្ទប៉ុណ្ណោះ ដែលអាចជួយសង្គ្រោះយើងពីអំពើបាប និងនរកបាន។ ម៉ារា និងពួកបរិសុទ្ធ គឺជាមនុស្សមានបាបដូចយើងដែរ ហើយគ្មានសេចក្ដីសុចរិតទេ ក្រៅពីសេចក្ដីសុចរិតព្រះគ្រីស្ទប៉ុណ្ណោះ។ |
| មានកន្លែងមួយដែលគេហៅថា ធីហ្គាថូរី (Purgatory) ជាកន្លែងដែលគ្រីស្ទបរិស័ទភាគច្រើនត្រូវទៅ ក្រោយពេលស្លាប់ ដើម្បីទទួលការដាក់ទណ្ឌកម្មដែលនឹងសម្អាតអំពើបាបរបស់ពួកគេចេញ។ (CCC 1031 និង 1475) | ព្រះគម្ពីរប្រាប់ថា ព្រះគ្រីស្ទបានសម្អាតអំពើបាបរបស់យើងទាំងអស់នៅលើឈើឆ្កាង។ មិនមានអ្វីនៅសល់សម្រាប់យើង ដែលត្រូវសម្អាតនៅក្នុង ធីហ្គាថូរី (Purgatory) នោះទេ។ ហើយនៅក្នុងព្រះគម្ពីរមិនមាននិយាយអំពី ធីហ្គាថូរីទេ។ |
| មានឃ្លាំងបុណ្យកុសលយ៉ាងធំ ដែលព្រះគ្រីស្ទ និងពួកបរិសុទ្ធបានសន្សំឡើង។ ក្រុមជំនុំរ៉ូម៉ាំងកាតូលិកចែករំលែកបុណ្យកុសលនេះ ដើម្បីសងការជំនុំជម្រះបាបបណ្ដោះអាសន្ននៅ ធីហ្គាថូរី(Purgatory)។ (CCC 1471) | ព្រះគម្ពីរប្រាប់ថា គ្មានមនុស្សណាដែលមានសេចក្ដីសុចរិត ឬបុណ្យកុសលនោះឡើយ។ មានតែព្រះគ្រីស្ទទេ ដែលមានសេចក្ដីសុចរិត។ គឺព្រះគ្រីស្ទ (មិនមែនក្រុមជំនុំ) ដែលចែករំលែកសេចក្ដីសុចរិតរបស់ទ្រង់ដោយឥតគិតថ្លៃ ដល់អស់អ្នកដែលអំពាវនាវដល់ទ្រង់ដោយជំនឿ។ |
| នាងម៉ារាគឺជាអ្នកសង្រ្គបសង្រ្គមមួយរវាងព្រះ និងមនុស្ស ដែលនាង«នាំមកនូវអំណោយនៃការសង្គ្រោះអស់កល្បជានិច្ចដល់យើង»។ ការអធិស្ឋានរបស់នាង «រំដោះព្រលឹងយើងពីសេចក្ដីស្លាប់»។ (CCC 969 និង 966) | ព្រះគម្ពីរប្រាប់ថា មានអ្នកសង្រ្គបសង្រ្គមតែម្នាក់គត់រវាងព្រះ និងមនុស្ស គឺព្រះយេស៊ូវគ្រីស្ទ។ គ្មានសេចក្ដីសង្គ្រោះនៅក្នុងអ្នកណាផ្សេងឡើយ។ (១ធីម៉ូថេ ២:៥; កិច្ចការ ៤:១២) |
| «តាមរយៈការសុំឲ្យម៉ារាអធិស្ឋានសម្រាប់យើង នោះយើងទទួលស្គាល់ថា ខ្លួនជាមនុស្សមានបាប ដែលនិយាយចំពោះ <មាតានៃសេចក្ដីមេត្តាករុណា> ដែលជាអ្នកបរិសុទ្ធទាំងស្រុង»។ (CCC 2677) | ព្រះគម្ពីរមានបន្ទូលថា មានតែ ព្រះជាម្ចាស់ដែលបរិសុទ្ធទាំងស្រុង។ ជាង ៥០ដង ព្រះគម្ពីរហៅព្រះ និងព្រះរាជបុត្រាថា «ព្រះដ៏បរិសុទ្ធ» តែមិនដែលប្រើពាក្យបរិសុទ្ធសម្រាប់នាងម៉ារាឡើយ។ |

| | |
|---|---|
| នាងម៉ារាកើតមកគ្មានបាប។ (នេះត្រូវបានប្រកាសជាផ្លូវការនៅឆ្នាំ ១៨៥៤) | នាងម៉ារាខ្លួនឯងផ្ទាល់បានទទួលស្គាល់នៅក្នុងការអធិស្ឋានរបស់នាងថា នាងជាមនុស្សមានបាបដែលត្រូវការ *«ព្រះដ៏ជាព្រះអង្គសង្គ្រោះនៃខ្ញុំ»* (លូកា ១:៤៧)។ |
| នៅចុងបញ្ចប់នៃជីវិតរបស់គាត់ នាងម៉ារាត្រូវបានបញ្ជូនទៅស្ថានសួគ៌តែម្តងដោយមិនបានស្លាប់។ (នេះត្រូវបានប្រកាសជាផ្លូវការនៅឆ្នាំ ១៩៥០) | ព្រះគម្ពីរមិនបានបង្រៀនរឿងនេះទេ។ |
| ជាធម្មតា សមាជិកក្រុមជំនុំមិនអាចទទួលពែង នៃពិធីលៀងព្រះអម្ចាស់ឡើយ។ (នេះត្រូវបានប្រកាសជាផ្លូវការនៅឆ្នាំ ១៤១៤) | ព្រះយេស៊ូវបង្គាប់ឲ្យគ្រីស្ទបរិស័ទទាំងអស់ទទួលទាននំប៉័ង និងពែង។ ជាបាបធំមែនទែន ដែលហាមមិនឲ្យគ្រីស្ទបរិស័ទទទួលពែង។ |
| ក្រុមប្រឹក្សារ៉ូម៉ាំងកាតូលិកនៃ ទូលូស (Toulouse) នៅឆ្នាំ ១២២៩ បានចេញបញ្ញាថា សមាជិកក្រុមជំនុំធម្មតានៅស្រុកបារាំង នឹងមិនត្រូវបានអនុញ្ញាតឲ្យអានព្រះគម្ពីរជាភាសារបស់ខ្លួនឡើយ។ នៅឆ្នាំ ១៥៥៩ សម្តេចប៉ាបបានអនុញ្ញាតឲ្យតែអ្នកដែលទទួលបានច្បាប់អនុញ្ញាតពីរ៉ូមឲ្យអានព្រះគម្ពីរជាភាសាខ្លួន។ (ក្រោយមកច្បាប់ទាំងនេះត្រូវបានលុបចោលវិញ)។ | ព្រះគម្ពីរ គឺសម្រាប់អ្នកជឿទាំងអស់ គ្រប់ពេលវេលាទាំងអស់ គ្រប់ភាសាទាំងអស់។ |

## គោលលទ្ធិ និងច្បាប់ថ្មីទាំងនេះ ត្រូវបានបន្ថែមរាប់រយឆ្នាំបន្ទាប់ពីព្រះគ្រីស្ទ

ក្នុងកំឡុងពេល ៣០០ ឆ្នាំដំបូងនៃក្រុមជំនុំ ពួកជំនុំនិងអ្នកដឹកនាំក្រុមជំនុំ បានជួបប្រជុំគ្នា ហើយថ្វាយបង្គំ និងរស់នៅតាមរបៀបដ៏សាមញ្ញ ដូចអ្វីដែលបានពិពណ៌នានៅក្នុងគម្ពីរកិច្ចការ។ មិនមានគ្រូគង្វាលដ៏មានអំណាចម្នាក់ ដែលរស់នៅដូចជាស្តេច ហើយដែលពួកជំនុំទាំងអស់ត្រូវចុះចូល ហើយថែមទាំងថើបជើងរបស់គាត់ទៀតផងនោះទេ។ នៅពេលអ្នកអានបន្ទាត់ពេលវេលានៅខាងក្រោមនេះ នោះអ្នក

នឹងឃើញថាក្រុមជំនុំរ៉ូម៉ាំងកាតូលិកបានបង្កើត គោលលទ្ធិថ្មី និងប្លែកទាំងនេះ រាប់រយឆ្នាំបន្ទាប់ពីសម័យព្រះគ្រីស្ទ។ ច្បាប់នេះក៏បានបង្កើតឡើង ដោយគ្មានការសម្រេចចិត្តពីក្រុមប្រឹក្សាក្រុមជំនុំទូទាំងពិភពលោកឡើយ៖

**គ.ស ៥៩៣** ក្រុមជំនុំកាតូលិកបានបង្កើតគោលលទ្ធិអំពីស្ថាន ផឺហ្គាថូរី (Purgatory)។

**គ.ស ៦០០** ការអធិស្ឋានបានចាប់ផ្ដើមសំដៅទៅនាងម៉ារា និងពួកបរិសុទ្ធដទៃទៀត។

**គ.ស ៦១០** គ្រូគង្វាលក្រុមជំនុំរ៉ូមបានទទួល ងារសម្ដេច ប៉ាប(Pope)។

**គ.ស ៧០៩** ទំនៀមទម្លាប់ថើបជើងរបស់សម្ដេច ប៉ាប បានចាប់ផ្ដើម។

**គ.ស ៧៨៨** ក្រុមជំនុំកាតូលិកបានឲ្យច្បាប់ លុតជង្គង់គោរពឈើឆ្កាង រូបភាព និងឆ្អឹងរបស់ពួកបរិសុទ្ធ។

**គ.ស ១០៧៩** ក្រុមជំនុំកាតូលិកមិនអនុញ្ញាតឲ្យលោកសង្ឃរៀបការទេ។

**គ.ស ១០៩០** ក្រុមជំនុំកាតូលិកបានចាប់ផ្ដើមប្រើ ខ្សែអង្កាំ ដើម្បីរាប់ការអធិស្ឋាន (រ៉ូសារី Rosary)។

**គ.ស ១១៨៤** ក្រុមជំនុំកាតូលិកបានចាប់ផ្ដើម ចាប់ខ្លួន ជំនុំជម្រះ និងដាក់ទោសអ្នកដែលមិនព្រមចុះចូលជាមួយនឹងសម្ដេចប៉ាបនៅទីក្រុងរ៉ូម។

**គ.ស ១១៩០** ដើម្បីរៃអង្គាសប្រាក់ ក្រុមជំនុំកាតូលិកបានចាប់ផ្ដើមលក់ក្រដាសដែលចែងថា ម្ចាស់ក្រដាសនោះបានទទួលការអភ័យទោសពីក្រុមជំនុំកាតូលិក ចំពោះការដាក់ទណ្ឌកម្មបាបបណ្ដោះអាសន្ននៅលើផែនដី និងនៅស្ថានផឺហ្គាថូរី (Purgatory)។

**គ.ស ១៤១៤** ក្រុមជំនុំរ៉ូមលែងអនុញ្ញាតឲ្យសមាជិកក្រុមជំនុំទទួលពែងនៃពិធីលៀងព្រះអម្ចាស់ សូម្បីព្រះអម្ចាស់របស់យើងបានបង្គាប់ឲ្យយើងទទួលទាំងនំប៉័ង និងពែងក៏ដោយ។

**គ.ស ១៤៣៩** ក្រុមជំនុំរ៉ូមបានប្រកាសជាផ្លូវការនូវគោលលទ្ធិអំពីស្ថាន ផឺហ្គាថូរី។

**គ.ស ១៥៤៥** ក្រុមប្រឹក្សា ត្រេន(Trent) បានប្រកាសថា ប្រពៃណីជាផ្លូវការរបស់ក្រុមជំនុំ មានសិទ្ធិអំណាចស្មើនឹងព្រះគម្ពីរ។

**គ.ស ១៨៥៤** សម្ដេចប៉ាបបានប្រកាសថា នាងម៉ារាបានកើតមកដោយគ្មានបាប។

**គ.ស ១៩៥០** សម្ដេចប៉ាបបានប្រកាសថា នាងម៉ារាមិនស្លាប់ទេ គឺបានលើកឡើងទៅស្ថានសួគ៌តែម្ដង។

លោកយូដាសបានប្រាប់យើងនៅក្នុង យូដាស ខ ៣ ថា គោលលទ្ធិគ្រីស្ទសាសនាទាំងមូល ដែលព្រះគ្រីស្ទ និងពួកសាវកបានបង្រៀន ត្រូវបានប្រគល់មកយើង

*«១ដងជាសំរេច» «ពួកស្ងួនភ្ងាអើយ កំពុងដែលខ្ញុំខ្មីឃ្មាតសរសេរពីសេចក្ដីសង្គ្រោះដែលសំរាប់យើងទាំងអស់គ្នា នោះខ្ញុំមានសេចក្ដីបង្ខំនឹងសរសេរ ផ្ញើមកអ្នករាល់គ្នាទាំងទូន្មានឲ្យខំតយុទ្ធ ដើម្បីការពារសេចក្ដីជំនឿ ដែលបានប្រគល់មកពួកបរិសុទ្ធ១ដងជាសំរេច»*។ យើងមិនត្រូវបន្ថែមអ្វីទៅលើគោលលទ្ធិនៃព្រះគ្រីស្ទ និងពួកសាវករបស់ទ្រង់ឡើយ។

## កំណែទម្រង់ប្រូតេស្តង់

គោលលទ្ធិថ្មីទាំងនេះដែលក្រុមជំនុំរ៉ូមបានបន្ថែម បានចាប់ផ្តើមធ្វើឲ្យរាំងស្ទះដល់ដំណឹងល្អនៃសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ។ នៅក្រុមជំនុំជាច្រើនដំណឹងល្អបានបាត់បង់ទាំងស្រុង។ មិនតែប៉ុណ្ណោះ សម្តេចប៉ាប និងមេដឹកនាំសាសនាជាច្រើនបានរស់នៅក្នុងជីវិតដ៏អាក្រក់ក្រៃលែង ដោយមានស្រីកំណាន់ និងស្រីពេស្យាជាច្រើននាក់។ ដូច្នេះចាប់ពីគ.ស ១២០០ ដល់ គ.ស.១៧០០ គ្រីស្ទបរិស័ទជាច្រើនបានតវ៉ាប្រឆាំងនឹងគោលលទ្ធិ និងភាពជាអ្នកដឹកនាំអាក្រក់របស់ក្រុមជំនុំរ៉ូម៉ាំងកាតូលិក (ពាក្យ «ប្រូតេស្តង់» Protestant មានន័យថា ប្រឆាំង ឬចង់បានការកែទម្រង់)។ ប្រសិនបើក្រុមជំនុំរ៉ូម៉ាំងកាតូលិកបានបន្ទាបខ្លួន ហើយស្តាប់ការអង្វរករទាំងនេះ ដើម្បីធ្វើកំណែទម្រង់ក្រុមជំនុំ នោះគ្រីស្ទសាសនាប្រហែលជាមិនត្រូវបានបំបែកទៅជាក្រុមកាតូលិក និងប្រូតេស្តង់ទេ។ ប៉ុន្តែ ផ្ទុយទៅវិញ អំនួតរបស់ក្រុមជំនុំកាតូលិក បាននាំឲ្យពួកគេតបតត្រឡប់មកវិញរឹតតែខ្លាំងឡើង។ ពួកគេថែមទាំងកោះប្រជុំក្រុមប្រឹក្សារ៉ូម៉ាំងកាតូលិក ដែលបានថ្កោលទោសពួកប្រូតេស្តង់។ ក្រុមប្រឹក្សានេះបានប្រកាសថា អស់អ្នកដែលនិយាយថា ការសង្គ្រោះ គឺដោយសារព្រះគុណតាមរយៈជំនឿតែប៉ុណ្ណោះ គឺស្ថិតនៅក្រោមបណ្តាសារបស់ព្រះហើយ!

## តើពេត្រុសជាសម្តេចប៉ាបដំបូងឬ?

ក្រុមជំនុំរ៉ូម៉ាំងកាតូលិកតែងតែប្រកាន់ខ្ជាប់ថា លោកពេត្រុសផ្ទាល់ គឺជាអ្នកគ្រប់គ្រង ឬ«ប៉ាប»ដំបូងគេ នៅក្រុមជំនុំរ៉ូម។ ក៏ប៉ុន្តែ ទោះបីជាមានភ័ស្តុតាងដែលថា លោកពេត្រុសបានចំណាយពេលខ្លះនៅទីក្រុងរ៉ូមក៏ដោយ ក៏មិនមានភ័ស្តុតាងបញ្ជាក់ថា គាត់គឺជាគ្រូគង្វាល ឬអ្នកគ្រប់គ្រងរបស់ក្រុមជំនុំរ៉ូមដែរ។ យើងរៀនពីប្រវត្តិសាស្រ្តក្រុមជំនុំនៅក្រុងយេរូសាឡិមក្នុងកណ្ឌគម្ពីរកិច្ចការ គឺពួកសាវកមិនបានហៅខ្លួនឯងថាជាគ្រូគង្វាល ឬអ្នកគ្រប់គ្រងនៃក្រុមជំនុំនោះទេ ប៉ុន្តែមានមុខងារផ្សេង ដែលហៅថាពួកសាវក។ «សូម្បីតែអ្នកប្រាជ្ញរ៉ូម៉ាំងកាតូលិកសម័យបច្ចុប្បន្ន គឺលោក អេច. ប៊ើន-ម៉ើដុក (H. Burn-Murdock) ដែលគាំទ្រការមានសម្តេចប៉ាប បានប្រកាសយ៉ាងច្បាស់នៅក្នុងសៀវភៅស្រាវជ្រាវយ៉ាងល្អរបស់គាត់ ឈ្មោះ *ការអភិវឌ្ឍន៍នៃងារសម្តេចប៉ាប* ថា គ្មានភ័ស្តុតាងដើម្បីបង្ហាញថា លោកពេត្រុសធ្លាប់ជា អ្នកគ្រប់គ្រងនៃក្រុមជំនុំនៅទីក្រុងរ៉ូមនោះឡើយ។ គាត់និយាយថា <គ្មានសំណេរណាមួយឡើយក្នុងពីរសតវត្សរ៍ដំបូង ដែលពិពណ៌នាអំពី សាវកពេត្រុសថា ជាអ្នកគ្រប់គ្រងនៃក្រុមជំនុំរ៉ូម>» (H. Burn-Murdock, The Development of the Papacy, London:Faber & Faber, 1954, p.130)។

## តើមានឃ្លាំងសន្សំបុណ្យកុសល និងសេចក្តីសុចរិតរបស់ពួកបរិសុទ្ធ ដែលក្រុមជំនុំកាតូលិកអាចចែករំលែកបុណ្យកុសលទាំងនោះដល់គ្រីស្ទបរិស័ទបានទេ?

សាវកពេត្រុសដែលក្រុមជំនុំរ៉ូម៉ាំងកាតូលិកអះអាងថា ជាសម្តេចប៉ាបដំបូងគេ គាត់មិនបាននិយាយអ្វីទាំងអស់ នៅក្នុងសំណេរ និងសេចក្តីអធិប្បាយរបស់គាត់ អំពីការមានបុណ្យកុសល ឬសេចក្តីសុចរិតផ្ទាល់របស់គាត់ ដែលអាចចែកដល់គ្រីស្ទបរិស័ទដទៃទៀតនោះឡើយ។ ផ្ទុយទៅវិញ គាត់ប្រាប់គ្រីស្ទបរិស័ទថា តាមរយៈជំនឿលើព្រះគ្រីស្ទ និងសេចក្តីសុចរិតរបស់ព្រះគ្រីស្ទ ពួកគេបានទទួល ជំនឿចំពោះព្រះជា

ម្ចាស់ ដែលស្មើនឹងជំនឿរបស់ពេត្រុស! *«ខ្ញុំ ស៊ីម៉ូនពេត្រុស ជាអ្នកបំរើ និងជាសាវក *របស់ព្រះយេស៊ូគ្រិស្ត សូមជំរាបមកបងប្អូនដែលបានទទួលជំនឿ ដោយសារសេចក្ដីសុចរិត របស់ព្រះយេស៊ូគ្រិស្ដជាព្រះជាម្ចាស់ និងជាព្រះសង្គ្រោះរបស់យើង។ ជំនឿរបស់បងប្អូន ក៏មានតម្លៃដូចជំនឿរបស់យើងដែរ»* (២ពេត្រុស ១:១ KSV)។

ដូចគ្នាដែរ សាវកប៉ុលក៏បានបដិសេធថា គាត់មិនមានបុណ្យកុសល ឬសេចក្ដីសុចរិតផ្ទាល់ខ្លួន ដើម្បីចែករំលែកដល់អ្នកដទៃបានទេ៖ *«ដែលដោយយល់ដល់ទ្រង់ ខ្ញុំបានខាតគ្រប់ទាំងអស់ ហើយបានរាប់ទាំងអស់ទុកដូចជាសំរាម ប្រយោជន៍ឲ្យបានព្រះគ្រីស្ទវិញ ៩ ហើយឲ្យគេបានឃើញខ្ញុំនៅក្នុងទ្រង់ ដោយសេចក្ដីសុចរិតដែលមកពីសេចក្ដីជំនឿដល់ព្រះគ្រីស្ទ មិនមែនដោយសេចក្ដីសុចរិតរបស់ខ្លួនខ្ញុំ ដែលមកពីក្រឹត្យវិន័យនោះទេ គឺជាសេចក្ដីសុចរិតដែលមកពីព្រះ ដោយសេចក្ដីជំនឿវិញ...»* (ភីលីព ៣:៨-៩)។

ពិតជាមានឃ្លាំងសន្សំបុណ្យកុសល និងសេចក្ដីសុចរិតដែលមិនចេះអស់សម្រាប់យើងមែន! ប៉ុន្តែមានតែនៅក្នុងព្រះគ្រីស្ទប៉ុណ្ណោះ ហើយមានតែព្រះគ្រីស្ទដែលមានសិទ្ធិចែករំលែក មិនមែនក្រុមជំនុំទេ។ តាមរយៈជំនឿលើព្រះយេស៊ូវគ្រីស្ទ នោះគ្រីស្ទបរិស័ទទាំងអស់អាចទទួលបាននូវកំណប់ទ្រព្យនៃសេចក្ដីសុចរិតគ្មានទីបញ្ចប់របស់ព្រះគ្រីស្ទដដែល ដូចជាសាវកប៉ុល និងពេត្រុសបានទទួលដែរ។ វាគឺជាការបង្រៀនខុសឆ្គងហើយដែលថា នរណាម្នាក់ក្រៅពីព្រះគ្រីស្ទមានបុណ្យកុសល ឬសេចក្ដីសុចរិតដែលត្រូវចែកចំពោះអ្នកដទៃនោះ។ *«គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង»* (រ៉ូម ៣:១០)។ សូម្បីតែស្ត្រីក្រមុំព្រហ្មចារីម៉ារាហៅព្រះជាម្ចាស់ថា *«ព្រះដ៏ជាព្រះអង្គសង្គ្រោះនៃខ្ញុំ»* (លូកា ១:៤៧)។

## សម្តេចប៉ាបរស់នៅដូចជាស្តេច

រយៈពេលមួយពាន់ឆ្នាំកន្លងមកនេះ សម្តេចប៉ាបភាគច្រើន និងអ្នកគ្រប់គ្រងល្បីៗដទៃទៀត នៃក្រុមជំនុំរ៉ូម៉ាំងកាតូលិក បានរស់នៅដូចជាស្តេច នៅក្នុងវិមានដ៏ស្រស់ស្អាត ដោយមានអ្នកបម្រើ និងអង្គរក្ស ហើយពេលខ្លះថែមទាំងមានកងទ័ពទៀត។ ពួកគេរស់នៅបែបនេះ សូម្បីតែព្រះអម្ចាស់យេស៊ូវគ្រីស្ទបានស្តីបន្ទោសពួកសាវកយ៉ាងខ្លាំង នៅពេលដែលពួកគេបានសុំអង្គុយនៅបល្ល័ង្កខាងស្តាំ និងខាងឆ្វេងទ្រង់។ *«តែព្រះយេស៊ូវទ្រង់ហៅអ្នកទាំងនោះមក មានព្រះបន្ទូលថា អ្នករាល់គ្នាដឹងថា ពួកចៅហ្វាយនៃសាសន៍ដទៃតែងគ្រប់គ្រងលើសាសន៍របស់ខ្លួន ហើយពួកអ្នកធំក៏មានអំណាចលើគេដែរ ប៉ុន្តែមិនត្រូវឲ្យមានដូច្នោះក្នុងពួកអ្នករាល់គ្នាឡើយ គឺអ្នកណាក្នុងពួកអ្នករាល់គ្នា ដែលចង់ធ្វើជាធំ នោះនឹងត្រូវធ្វើជាអ្នកបំរើដល់អ្នករាល់គ្នាវិញ ហើយអ្នកណាក្នុងពួកអ្នកដែលចង់បានជាលេខ១ អ្នកនោះត្រូវធ្វើជាបាវដល់អ្នករាល់គ្នាវិញដែរ ដូចជាកូនមនុស្សបានមក មិនមែនឲ្យគេបំរើលោកទេ គឺនឹងបំរើគេវិញ ហើយនិងឲ្យជីវិតខ្លួន ទុកជាថ្លៃលោះមនុស្សជាច្រើនផង»* (ម៉ាថាយ ២០:២៥-២៨)។

ផ្ទុយពីនេះ សម្តេចប៉ាបបានតម្រូវឲ្យ សមាជិករបស់ពួកគេ ថើបចិញ្ចៀនរបស់ពួកគេ ហើយថែមទាំងថើបជើងទៀតផង! សម្តេចប៉ាបភាគច្រើនបានរស់នៅក្នុងភាពអភិជន និងភាពស្តុកស្តម្ភ។ របៀបមួយដែលយើងដឹងថា គ្រូបង្រៀនមួយ គឺជាគ្រូបង្រៀនពិត គឺគាត់រស់នៅក្នុងជីវិតបន្ទាបខ្លួន នៃមនុស្សសាមញ្ញ ដូចជាព្រះអម្ចាស់យេស៊ូវគ្រីស្ទដែរ។ គ្មានមនុស្សសំខាន់បំផុត ឬ VIP នៅក្នុងគ្រីស្ទសាសនានោះទេ។

## សេចក្តីសន្និដ្ឋាន

ក្រុមខុសឆ្គងតែងតែបដិសេធនូវគោលលទ្ធិសំខាន់ខ្លះនៃគ្រីស្ទសាសនា ដូចជាគោលលទ្ធិនៃព្រះត្រៃឯក ឬការរស់ពីសុគតឡើងវិញរបស់ព្រះគ្រីស្ទជាដើម។ ប៉ុន្តែក្រុមជំនុំរ៉ូម៉ាំងកាតូលិកទទួលយកនូវរាល់គោលលទ្ធិធំៗ ដែលមាននៅក្នុង

គោលជំនឿណែសៀ។ បញ្ញាចម្បងនៃក្រុមជំនុំរ៉ូម៉ាំងកាតូលិក មិនមែនការដក គោលលទ្ធិចេញនោះទេ ប៉ុន្តែជាការបន្ថែមគោលលទ្ធិវិញ។ ពួកគេបានបន្ថែម គោលលទ្ធិថ្មីរាប់សិប ដែលមិនមាននៅក្នុងព្រះគម្ពីរ។ គោលលទ្ធិថ្មីនីមួយៗ បាន បិទបាំងដំណឹងល្អនៃព្រះគុណបន្តិចម្តងៗ រហូតដល់ទីបំផុតដំណឹងល្អត្រូវបាន លាក់បាំងទាំងស្រុង។ នេះជាមូលហេតុដែលសមាជិកក្រុមជំនុំរ៉ូម៉ាំងកាតូលិកភាគ ច្រើន មិនអាចពន្យល់ពីដំណឹងល្អនៃជំនឿលើព្រះគ្រីស្ទ និងក្តីសង្ឃឹមនៃជីវិត អស់កល្បជានិច្ចបាន។

ប៉ុន្តែនៅពេលដែលខ្ញុំជួបជាមួយសមាជិករ៉ូម៉ាំងកាតូលិកម្នាក់ ដែលស្គាល់ព្រះយេស៊ូវ ហើយជឿលើដំណឹងល្អ ខ្ញុំបានជួបបងប្អូនពិតប្រាកដនៅក្នុងព្រះគ្រីស្ទ ហើយខ្ញុំ រីករាយ។

# ឧបសម្ពន្ធ ២

## សាសនាឥស្លាម

(ពួកមូស្លីម)

អ្នកប្រហែលជាភ្ញាក់ផ្អើលដែលខ្ញុំបញ្ចូលឥស្លាមនៅក្នុងសៀវភៅនេះ។ អ្នកអាចសួរថា «តើលោកមហាម៉ាត់មិនបានអះអាងថា បង្កើតសាសនាថ្មីទាំងស្រុងឬ?» តាមពិតគាត់មិនបានអះអាងដូច្នេះនោះទេ។ មហាម៉ាត់បានអះអាងថា សាសនាឥស្លាម គឺជាការសម្រេចចុងក្រោយរបស់សាសនាយូដា និងគ្រីស្ទសាសនាវិញ ហើយថា គាត់គឺជាព្យាការីចុងក្រោយ និងធំបំផុតនៅក្នុងចំណោមព្យាការីទាំងឡាយតាំងពីអ័ដាមមក។ សូមចាំថា សាសនាថ្មីជាច្រើនចូលចិត្តអះអាងថា ពួកគេគឺជាការសម្រេចចុងក្រោយរបស់គ្រីស្ទសាសនា (សាសនា មរមន ស្មរបន្ទាល់ព្រះយេហូវ៉ាជាដើម) ឬថា មេដឹកនាំរបស់ពួកគេ គឺជាព្រះគ្រីស្ទដែលយាងមកចុងក្រោយ (សាន់ ម៉្យុង មូន និង អាន់ សាំងហុង ជាដើម)។ តាមពិត មហាម៉ាត់ បានទទួលស្គាល់ អ័ដាម ណូអេ អាប្រាហាំ ម៉ូសេ ដាវីឌ និងព្រះយេស៊ូវ គឺជាអ្នកនាំសារមកពីព្រះ។ ទោះយ៉ាងណាក៏ដោយគាត់អះអាងថា គាត់ផ្ទាល់ជាព្យាការីចុងក្រោយ និងល្អបំផុតរបស់ព្រះជាម្ចាស់។

### ប្រវត្តិ

លោក មហាម៉ាត់ បានរស់នៅក្នុងទីក្រុងមេកកា (Mecca) ជាទីក្រុងមួយនៅក្នុងប្រទេស ដែលសព្វថ្ងៃនេះហៅថា អារ៉ាប៊ីសាអ៊ូឌីត (Saudi Arabia) ខាងកើតប្រទេសអ៊ីស្រាអែល។ គាត់បានបង្រៀនមនុស្សមួយក្រុមតូចថា មានព្រះតែមួយ គឺ

អុលឡោះ (Allah) ហើយថា គាត់គឺជាព្យាការីចុងក្រោយរបស់អុលឡោះ។ ក៏ប៉ុន្តែប្រជាជននៅមេកកាបានធ្វើទុក្ខបុកម្នេញដល់ក្រុមថ្មីនេះ ដូច្នេះពួកគេក៏បានផ្លាស់ទៅទីក្រុងមេឌីណា (Medina) នៅ គ.ស ៦២២ ជាកន្លែងដែលពួកគេចាប់ផ្តើមរីកចម្រើន។ នៅឆ្នាំ ៦២៩ មហាម៉ាត់បានប្រមូលកងទ័ពដ៏ធំមួយ នៃសមាជិកគាត់ពីមេឌីណា ហើយបានវាយលុក និងយកឈ្នះមេកកា ដែលបន្ទាប់មកក្លាយជាមជ្ឈមណ្ឌលនៃសាសនាឥស្លាម។ បីឆ្នាំក្រោយមកនៅឆ្នាំ ៦៣២ មហាម៉ាត់បានធ្លាក់ខ្លួនឈឺ ហើយបានស្លាប់ ប៉ុន្តែនៅពេលនោះសាសនាឥស្លាមបានរីករាលដាលពាសពេញតំបន់អារ៉ាប់ហើយ។ គេបញ្ចុះសពគាត់នៅក្រុងមេឌីណា។

បន្ទាប់ពីមរណភាពរបស់មហាម៉ាត់ សាសនាឥស្លាមបានបែងចែកជាពីរក្រុម។ អ្នកខ្លះគិតថា អាប៊ូបាកគី (Abu Bakr) ដែលជាមិត្ត និងជាពុកក្មេករបស់មហាម៉ាត់ គួរតែដឹកនាំជំនឿឥស្លាម។ ក្រោយមកក្រុមនេះបានក្លាយជានិកាយ ស៊ុននី (Sunni) ដែលជាក្រុមមូស្លីមធំបំផុតនៅលើពិភពលោក។ អ្នកផ្សេងទៀតបានជឿថា លោក មហាម៉ាត់ បានជ្រើសរើស អាលី អ៊ីបិន អាប៊ី ថាលិប (Ali ibn Abi Talib) ដែលជាជីដូនមួយ និងជាកូនប្រសាររបស់គាត់ ដើម្បីស្នងតំណែងគាត់។ ក្រុមនោះត្រូវបានគេស្គាល់ថា ជានិកាយ ឈីអា (Shia)។ រហូតមកដល់សព្វថ្ងៃនេះមានការប៉ះទង្គិច និងអំពើហិង្សាជាច្រើនរវាងក្រុមទាំងពីរនេះ។

នៅទីបំផុតសាសនារបស់មហាម៉ាត់បានរីករាលដាលពាសពេញតំបន់មជ្ឈិមបូព៌ា និងអាហ្វ្រិក។ ឥឡូវនេះមានអ្នកកាន់សាសនាឥស្លាមជាងមួយពាន់លាននាក់ នៅលើពិភពលោក។ ហើយសៀវភៅរបស់មហាម៉ាត់ ឈ្មោះ គូរ៉ាន បានក្លាយជាគម្ពីរបរិសុទ្ធនៃសាសនាថ្មីនេះ។

លោក មហាម៉ាត់ បានទទួលសេចក្តីពិតជាច្រើនពីព្រះគម្ពីរ ដែលគាត់បានឮពីគ្រីស្ទបរិស័ទ និងជនជាតិយូដា។ ឧទាហរណ៍ គាត់ជឿថា...

- ព្រះជាម្ចាស់បានបង្កើតអ្វីៗទាំងអស់ ចេញពីរបស់ដែលគ្មាន។
- ព្រះជាម្ចាស់បានបង្កើតអ័ដាម និងអេវ៉ា។
- អ័ដាម និងអេវ៉ាបានធ្វើបាប។
- ព្រះជាម្ចាស់បានត្រាស់ហៅអ័ប្រាហាំ។
- ព្រះជាម្ចាស់ត្រាស់ហៅម៉ូសេឲ្យរំដោះអ៊ីស្រាអែលចេញពីអេហ្ស៊ីប។
- ព្រះយេស៊ូវបានប្រសូតពីស្រីក្រមុំព្រហ្មចារី គឺម៉ារា។
- ព្រះយេស៊ូវគ្មានបាបសោះ។
- ព្រះយេស៊ូវជាព្រះមែស៊ី (Isa al-Masih)។
- ថ្ងៃណាមួយព្រះយេស៊ូវនឹងយាងត្រឡប់មកវិញ ដើម្បីជំនុំជម្រះពិភពលោក ហើយធ្វើឲ្យអ្វីៗទាំងអស់ត្រូវបញ្ចប់។

ថែមពីនោះទៀត សាសនាឥស្លាមក៏ទទួលស្គាល់គម្ពីរដែលលោកម៉ូសេបានសរសេរ គម្ពីរទំនុកដំកើង និងគម្ពីរសញ្ញាថ្មី (ស៊ូរ៉ា ៣:៣) ប៉ុន្តែពួកគេជឿថា ច្បាប់ចម្លងនៃបទគម្ពីរនេះបានផ្លាស់ប្តូរបន្តិចម្តងៗ។ (ពួកគេមិនមានភ័ស្តុតាងសម្រាប់រឿងនេះទេ)។

និយាយម្យ៉ាងទៀត សាសនាឥស្លាមស្រដៀងសេចក្តីពិតរបស់ព្រះ ដែលបានបើកសម្តែងនៅក្នុងគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មី ជាងក្រុមខុសឆ្គងជាច្រើន ដែលយើងបានរៀននៅក្នុងសៀវភៅនេះ។ ទោះយ៉ាងណាក្តី មហាម៉ាត់ និងអ្នកដែលដើរតាមគាត់ ក៏បានបដិសេធចំណុចសំខាន់ៗជាច្រើននៃគ្រីស្ទសាសនា។

## តើសាសនាឥស្លាមបដិសេធអ្វីខ្លះនៅក្នុងគ្រីស្ទសាសនា?

**គោលជំនឿអំពីព្រះត្រៃឯក។** សាសនាឥស្លាមបដិសេធគោលជំនឿអំពីព្រះត្រៃឯក។ ពួកគេជឿថា ព្រះយេស៊ូវមិនមែនជាព្រះទេ ប៉ុន្តែជាព្យាការីដែលគ្មានបាប ហើយព្រះវិញ្ញាណបរិសុទ្ធមិនមែនជាព្រះទេ តែជាមហាទេវតាកាព្រីយ៉ែល។ (មួយទៀត គម្ពីរកូរ៉ានយល់ច្រឡំថា ព្រះត្រៃឯកជា ព្រះវរបិតា ព្រះយេស៊ូវ និងម៉ារា នៅក្នុង ស៊ូរ៉ា ៥:៧៣-៧៥ និង ៥:១១៦)។

**ព្រះគម្ពីរ។** សាសនាឥស្លាមមិនជឿថា ឯកសារបុរាណនៃព្រះគម្ពីរ ត្រូវបានចម្លងយ៉ាងត្រឹមត្រូវ ពីមួយជំនាន់ទៅមួយជំនាន់នោះទេ។ ក៏ប៉ុន្តែ ភ័ស្តុតាងតាមលក្ខណៈវិទ្យាសាស្រ្តបង្ហាញថា ព្រះគម្ពីរត្រូវបានចម្លងយ៉ាងយកចិត្តទុកដាក់ និងត្រឹមត្រូវណាស់។

**តើព្រះគម្ពីរបានផ្លាស់ប្តូរច្រើន បន្ទាប់ពីឯកសារដើមឬ?** រហូតមកដល់ឆ្នាំ ១៩៤៧ ច្បាប់ចម្លងចាស់បំផុតនៃគម្ពីរសញ្ញាចាស់ជាភាសាហេព្រើរដែលយើងមាន បានចម្លងនៅឆ្នាំ ៩០០ នៃគ.ស។ អ៊ីចឹង ឯកសារនោះត្រូវបានគេចម្លង ១៣០០ ឆ្នាំ ក្រោយពីគម្ពីរសញ្ញាចាស់ត្រូវបានសរសេរចប់។ អ្នកវិទ្យាសាស្រ្តស្តាយដែលគេអត់មានឯកសារចាស់ជាងនោះទៀត ដែលគេអាចប្រៀបធៀប ដើម្បីដឹងថា គម្ពីរផ្លាស់ប្តូរត្រង់ណាខ្លះតាំងពីឯកសារដើមមក។

ថ្ងៃមួយមានអ្នកគង្វាលសត្វពពែម្នាក់នៅជិតសមុទ្រស្លាប់ បានគប់ដុំថ្មមួយដុំចូលទៅក្នុងរូងភ្នំនៅលើច្រាំងថ្មចោទ ហើយបានឮសំឡេងបែក។ នៅពេលដែលគាត់ឡើងទៅមើល គាត់បានរកឃើញពាងដីតដ្ឋរាប់សិបដែលមានសំណៅបុរាណរាប់រយច្បាប់ ដែលក្នុងនោះ មានទាំងរមូរគម្ពីរសញ្ញាចាស់ចំនួន ២០០ច្បាប់ដែរ។ នៅពេលដែលពួកអ្នកវិទ្យាសាស្រ្តស្រាវជ្រាវរមូរគម្ពីរសញ្ញាចាស់នោះ ពួកគេឃើញថារមូរខ្លះចាស់ជាងរមូរ

ដែលគេមានហើយ១៣០០ឆ្នាំ ចាស់ជាងសម័យព្រះយេស៊ូវទៀត។ ឥឡូវ អ្នកវិទ្យាសាស្រ្តអាចប្រៀបធៀប រមូរបុរាណនោះដើម្បីដឹងថា តើសញ្ញាចាស់បានផ្លាស់ប្តូរច្រើនប៉ុន្មានក្នុងរយៈពេលមួយពាន់បីរយឆ្នាំនៃការចម្លង។

តើពួកគេបានរកឃើញអ្វី? គ្មានការផ្លាស់ប្តូរធំដុំទេ! ឧទាហរណ៍ រមូរនៃកណ្ឌអេសាយដែលគេបានរកឃើញនៅក្នុងរូងភ្នំ ស្ទើរតែដូចគ្នា នឹងអេសាយដែលត្រូវបានចម្លងមួយពាន់បីរយឆ្នាំក្រោយ។ ខុសគ្នាតែការប្រកបអក្សរបន្តិចបន្តួច។ គំនិតដែលថា ព្រះគម្ពីរបានផ្លាស់ប្តូរច្រើនមិនមែនជាការពិតទេ។

សាសនាឥស្លាមមិនជឿថា គម្ពីរសញ្ញាថ្មី គឺជាគម្ពីរចុងក្រោយមកពីព្រះទេ។ ពួកគេជឿថា គម្ពីរកូរ៉ានដែលបានសរសេរ ៦០០ ឆ្នាំបន្ទាប់ពីព្រះគ្រីស្ទ គឺជាព្រះគម្ពីរចុងក្រោយ ហើយល្អជាងគេទាំងអស់។

**មនុស្សជាតិ**។ សាសនាឥស្លាមមិនជឿថា មនុស្សត្រូវបានបង្កើតតាមរូបភាពរបស់ព្រះជាម្ចាស់នោះឡើយ។ គេក៏មិនជឿថាមនុស្សទាំងអស់កើតមកជាមនុស្សមានបាបដោយសារបាបរបស់អ័ដាម និងអេវ៉ាទេ។ ពួកគេជឿថា ទារកទាំងអស់ តាមធម្មជាតិ គឺចុះចូលចំពោះអុលឡោះ តាំងពីកំណើត ប៉ុន្តែការចិញ្ចឹមបីបាច់របស់ពួកគេធ្វើឲ្យពួកគេខូចត្រឡប់ទៅជា គ្រីស្ទបរិស័ទ អ្នកកាន់សាសនាជ្វីហ្វ ឬអ្នកមិនជឿសាសនា ។ល។

**សេចក្តីសង្គ្រោះ**។ សាសនាឥស្លាមបដិសេធដង្វាយធួននឹងបាបរបស់ព្រះគ្រីស្ទសម្រាប់បាបរបស់យើង។ គេជឿថា អុលឡោះ មានសិទ្ធិអត់ទោសទទេ ដល់អស់អ្នកណាដែលក្លាយជាមូស្លីម ដោយមិនគិតពីតម្រូវការនៃក្រឹត្យវិន័យរបស់អុលឡោះឡើយ។

**ការសុគតលើឈើឆ្កាង។** សាសនាឥស្លាម បដិសេធភ័ស្តុតាងក្នុងគម្ពីរសញ្ញាថ្មី ដែលថា ព្រះយេស៊ូវបានសុគតលើឈើឆ្កាង។ មូស្លីមភាគច្រើនជឿថា ហៀបនឹងឆ្កាងព្រះយេស៊ូវ គេដាក់យូដាសលើឈើឆ្កាងជំនួសព្រះយេស៊ូវវិញ។ ពេលនោះព្រះយេស៊ូវត្រូវបានលើកឡើងទៅឋានសួគ៌តែម្តង ដោយមិនបានសុគតទេ (ស៊ូរ៉ា ៤:១៥៧)។ និយាយម្យ៉ាងទៀត ព្រះយេស៊ូវមិនបានសុគតជំនួសមនុស្សមានបាបទេ គឺមនុស្សមានបាបម្នាក់បានស្លាប់ជំនួសព្រះយេស៊ូវវិញ! មួយទៀត ដោយព្រោះពួកគេជឿថា ព្រះយេស៊ូវគ្រីស្ទមិនបានសុគត នោះពួកគេក៏បដិសេធការរស់ឡើងវិញនៃព្រះគ្រីស្ទដែរ។

**ព្រះយេស៊ូវគ្រីស្ទ។** ពួកគេជឿថា ព្រះយេស៊ូវមិនមែនជាព្រះរាជបុត្រានៃព្រះទេ ប៉ុន្តែគ្រាន់តែជាហោរាដ៏អស្ចារ្យម្នាក់ប៉ុណ្ណោះ។

ព្រឹត្តិការណ៍សំខាន់បំផុតនៅក្នុងសាសនាឥស្លាម គឺពេលអុលឡោះបើកសម្តែងកូរ៉ានដល់មហាម៉ាត់។ ប៉ុន្តែព្រឹត្តិការណ៍សំខាន់បំផុតនៅក្នុងគ្រីស្ទសាសនា គឺកំណើតជីវិតរស់នៅ ការសុគត និងការរស់ឡើងវិញរបស់ព្រះគ្រីស្ទ។

ដើម្បីក្លាយជាអ្នកកាន់សាសនាឥស្លាម មនុស្សត្រូវតែប្រកាស ហ្សាហាដា (Shahadah)៖ «គ្មានព្រះក្រៅពីអុលឡោះទេ ហើយមហាម៉ាត់ គឺជាព្យាការីរបស់អុលឡោះ»។

សាសនាឥស្លាមក៏បង្រៀនថា អ័ប្រាហាំបានយកអ៊ីស្មាអែល មិនមែនអ៊ីសាកទេ មកបូជានៅលើភ្នំម៉ូរីយ៉ា។

## សេចក្តីសង្គ្រោះនៅក្នុងសាសនាឥស្លាម

«ដោយសារពួកម៉ូស្លីមមិនទទួលយកគោលលទ្ធិនៃការធ្លាក់ចុះរបស់មនុស្ស ឬក៏និស្ស័យបាប នោះមិនត្រូវការការប្រោសលោះនោះទេ។ <ការសង្គ្រោះ> នៃ

សាសនាឥស្លាម ត្រូវបានគេយល់ស្ទើរតែទាំងស្រុងថា ជាការរំដោះនាពេលអនាគតពីការជំនុំជម្រះចុងក្រោយ។ ពួកមូស្លីមជាច្រើនជឿថា អ្នកណាដែលជឿលើភាពតែមួយនៃព្រះ (ថហិដ Tawhid) និងងារព្យាការីរបស់មហាម៉ាត់ នឹងត្រូវបានសង្គ្រោះពីភ្លើងនៃការជំនុំជម្រះ។ អ្នកកាន់សាសនាឥស្លាមផ្សេងទៀតទទូចថា មនុស្សត្រូវចុះចូលចំពោះអុលឡោះ តាមរយៈការប្រកាន់ខ្ជាប់នូវសសរស្តម្ភទាំង ៥ របស់សាសនាឥស្លាម៖ ការថ្លែងពីជំនឿ (ហ្សាហាដា Shahadah) ការអធិស្ឋានប្រចាំថ្ងៃ (សាឡាត់ Salat) ការធ្វើទាន (ហ្សាកាត់ Zakat) ការតមអាហារក្នុងអំឡុងខែរ៉ាម៉ាដន (សម Sawm) និងធម្មយាត្រាទៅទីក្រុង មេកកា (ហាជ Hajj)។ តាមប្រពៃណីសាសនាឥស្លាមដែលហៅថា ហាឌីដ (Hadith) ពួកមូស្លីមខ្លះជឿថាអុលឡោះផ្តល់កិត្តិយសដល់មហាម៉ាត់ ក្នុងការអង្វរករសម្រាប់សហគមន៍ឥស្លាមទាំងមូល នៅថ្ងៃជំនុំជម្រះចុងក្រោយ ដើម្បីអនុញ្ញាតឲ្យពួកមូស្លីមទាំងអស់បានសង្គ្រោះ»។ (Timothy C. Tennent, “The Bible and Islam,” *ESV Study Bible,* Crossway)

ដូចជាសាសនាខុសឆ្គងភាគច្រើនដែរ សាសនាឥស្លាមអះអាងថា ជាជំនឿ ដែលស័ក្តិសមនឹងរស់ដើម្បី និងស្លាប់ដើម្បី។ ប៉ុន្តែដោយសារសាសនាឥស្លាមបង្ហាញពីព្រះគ្រីស្ទខុសពីព្រះគ្រីស្ទពិតនៅក្នុងព្រះគម្ពីរ សាវកយ៉ូហាន ហៅវាថា ជាសាសនា «អង់ទីគ្រីស្ទ» (១យ៉ូហាន ៤:៣)។

## តើធ្វើដូចម្តេចដើម្បីលើកទឹកចិត្តពួកមូស្លីមឲ្យជឿលើព្រះយេស៊ូវគ្រីស្ទ

សូមអធិស្ឋានសម្រាប់មិត្តភក្តិមូស្លីមរបស់អ្នក ហើយធ្វើជាអ្នកជិតខាងដ៏ល្អចំពោះពួកគេ។ លើកទឹកចិត្តពួកគេ ឲ្យអានព្រះគម្ពីរប៊ីបទាំងមូល។ ទិញ «សៀវភៅរឿងព្រះយេស៊ូវតាមរយៈព្រះគម្ពីរ» ជាអំណោយដល់ពួកគេ។ គម្ពីរកូរ៉ានពិបាកអានណាស់ ព្រោះវាគ្មានដំណើររឿងប្រវត្តិសាស្ត្រ ដូចគម្ពីរយើងទេ។ បើប្រៀបធៀបទៅ

នឹងគម្ពីរកូរ៉ាន ដំណើររឿងព្រះគម្ពីរយើង គួរអោយចាប់អារម្មណ៍ណាស់ ព្រោះវាពោរពេញទៅដោយរឿងពិតដែលមានការរៀបចំតាមកាលប្បវត្តិ ហើយពួកមូស្លីមក៏ស្គាល់រឿងទាំងនោះជាច្រើនហើយ។ សូមសួរពួកគេថា តើគេចង់រៀនពីព្រះគម្ពីរព្រះអង្គ តាមរយៈសៀវភៅគ្រឹះមាំទេ។ សូមជឿទុកចិត្តថា ព្រះបន្ទូលរបស់ព្រះ ដែលខ្លាំងពូកែ ហើយរស់ នឹងធ្វើឲ្យមិត្តភក្តិមូស្លីមរបស់អ្នកជឿលើដំណឹងល្អ។

អ្នកក៏អាចប្រាប់គេពីទីបន្ទាល់របស់អ្នក អំពីការដែលព្រះគ្រីស្ទបានរំដោះអ្នកពីសេចក្ដីភ័យខ្លាចចំពោះគ្រូមន្តអាគម បណ្ដាសា និងអារក្សអ្នកតាជាដើម។ នៅស្រុកខ្មែរ មានគ្រូមន្តអាគមក្នុងចំណោមអ្នកកាន់ព្រះពុទ្ធសាសនា និងអ្នកកាន់ឥស្លាមសាសនា តែគ្មានគ្រូមន្តអាគមក្នុងចំណោមគ្រីស្ទបរិស័ទទេ។ ក្នុងសង្គមដែលជឿលើព្រះជាម្ចាស់ពិតប្រាកដ មិនត្រូវការគ្រូមន្តអាគមទេ។ ហេតុអ្វីបានជាគ្រីស្ទសាសនាអាចរំដោះអ្នកជឿឲ្យរួចពីសេចក្ដីភ័យខ្លាច ចំពោះគ្រូមន្តអាគម ជិន អារក្ស ខ្មោច អំពើ និងសេចក្ដីស្លាប់? ចម្លើយគឺថា ព្រះដែលគង់នៅក្នុងគ្រីស្ទបរិស័ទម្នាក់ៗ គឺជាអ្នកបង្កើតពិភពលោក និងជាអ្នកបង្កើតវិញ្ញាណទាំងអស់មក។ បើប្រៀបធៀបទៅនឹងព្រះយេស៊ូវ វិញ្ញាណដែលមានអំណាចទាំងអស់ ដែលមនុស្សភ័យខ្លាច គឺដូចជាស្រមោចដ៏តូច។ ដូច្នេះអ្នកដែលជឿលើព្រះយេស៊ូវ គ្មានអ្វីត្រូវខ្លាចឡើយ ហើយមិនពឹងលើគ្រូមន្តអាគមឡើយ។ ព្រះដែលបង្កើតអ្វីៗទាំងអស់ គង់នៅក្នុងរូបកាយរបស់គ្រីស្ទបរិស័ទទាំងអស់!

ទីបញ្ចប់ យើងត្រូវបង្ហាញសេចក្ដីស្រឡាញ់ និងចិត្តសប្បុរសចំពោះ ពួកម៉ាក និងអ្នកជិតខាងដែលកាន់សាសនាឥស្លាម។ ពួកគេត្រូវបានបង្កើតមកក្នុងរូបភាពព្រះ។ ព្រះជាម្ចាស់ស្រឡាញ់ពួកគេ ហើយចង់ឲ្យពួកគេផ្សះផ្សាជាមួយទ្រង់វិញ តាមរយៈព្រះយេស៊ូវ ដែលជាព្រះមែស៊ី និងព្រះប្រោសលោះ។

# ឧបសម្ពន្ធ ៣

## ខគម្ពីរអំពីគ្រូក្លែងក្លាយនិងការបង្រៀនខុសឆ្គង

| | | |
|---|---|---|
| ចោទិយកថា ១៣ៈ១-៥ | ចោទិយកថា ១៨ៈ២០-២២ | អេសាយ ៨ៈ២០ |
| យេរេមា ៥ៈ៣០-៣១ | យេរេមា ១៤ៈ១៤ | យេរេមា ២៣ៈ១៦-២១ |
| យេរេមា ២៧ៈ៩-១៥ | យេរេមា ២៨ៈ១៥ | ការទួញសោក ២ៈ១៤ |
| អេសេគាល ២២ៈ២៨ | ម៉ាថាយ ៧ៈ១៥-២៣ | ម៉ាថាយ ២៤ៈ៤-៥ |
| ម៉ាថាយ ២៤ៈ១១ | ម៉ាថាយ ២៤ៈ២៤ | ម៉ាកុស ៧ៈ៦-៩ |
| ម៉ាកុស ១៣ៈ២១-២៣ | លូកា ៦ៈ២៦ | យ៉ូហាន ៨ៈ៤៤ |
| កិច្ចការ ២០ៈ២៩-៣២ | រ៉ូម ១៦ៈ១៧-១៨ | ១កូរិនថូស ១១ៈ១៨-១៩ |
| ២កូរិនថូស ៤ៈ១-២ | ២កូរិនថូស ១១ៈ៣-៤ | ២កូរិនថូស ១១ៈ១៣-១៥ |
| កាឡាទី ១ៈ៦-៩ | អេភេសូរ ៤ៈ១៤-១៥ | កូល៉ុស ២ៈ៨ |
| កូល៉ុស ២ៈ១៦-២៣ | ១ថែស្សាឡូនីច ៥ៈ២១ | ២ថែស្សាឡូនីច ២ៈ៣-១ |
| ១ធីម៉ូថេ ១ៈ៣-៤ | ១ធីម៉ូថេ ១ៈ១៨-២០ | ១ធីម៉ូថេ ៤ៈ១-៣ |
| ១ធីម៉ូថេ ៦ៈ៥ | ២ធីម៉ូថេ ៣ៈ១-១៤ | ២ធីម៉ូថេ ៤ៈ២-៥ |
| ទីតុស ៣ៈ១០-១១ | ហេព្រើរ ១៣ៈ៩ | ២ពេត្រុស ២ៈ១-២ |
| ១យ៉ូហាន ២ៈ១៨-២២ | ១យ៉ូហាន ៤ៈ១ | ១យ៉ូហាន ៤ៈ១-៦ |
| ២យ៉ូហាន ខ ១០-១១ | យូដាស ខ ៣-៥ | យូដាស ខ ៨-១៩ |
| វិវរណៈ ២ៈ២ | វិវរណៈ ២ៈ២០ | វិវរណៈ ១៣ៈ១៤ |
| វិវរណៈ ២០ៈ១០ | | |

# ឧបសម្ពន្ធ ៤

## ១ យ៉ូហានៈ ទំនាក់ទំនងជាក្រុមគ្រួសារក្នុងក្រុមជំនុំ

### ប៉ារបស់យើង

ទ្រង់ជាឪពុករបស់យើង ១:៣; ២:១

ទ្រង់ជាពន្លឺ ១:៥

ទ្រង់ជាសេចក្តីស្រឡាញ់ ៤:៨

ទ្រង់ជាសេចក្តីសុចរិត ២:២៩

ទ្រង់ធំជាងចិត្តយើង ៣:២០

ទ្រង់ជ្រាបគ្រប់ទាំងអស់ ៣:២០

ទ្រង់ចាត់ព្រះរាជបុត្រាទ្រង់តែ១ ៤:៩,១០

ទ្រង់ស្រឡាញ់យើង ៤:១០,១១,១៩

ទ្រង់បានប្រទានព្រះវិញ្ញាណទ្រង់មកយើង ៤:១៣

ទ្រង់បានប្រទាន ជីវិតដ៏នៅអស់កល្បជានិច្ចមកយើង ៥:១១

ទ្រង់ថែរក្សាអ្នកជឿ ៥:១៨

### បងប្រុសរបស់យើង គឺព្រះយេស៊ូវ

ព្រះយេស៊ូវគង់នៅតាំងពីដើមរៀងមក ១:១

ព្រះយេស៊ូវជាព្រះបន្ទូលនៃជីវិត ១:១

ព្រះយេស៊ូវជាជីវិត ១:២

ព្រះយេស៊ូវជាជីវិតដ៏នៅអស់កល្បជានិច្ច ១:២, ៥:២០

ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ ១:៣; ៤:១៥; ៥:៥; ៥:៩,១០; ៥:១៣; ៥:២០

ព្រះយេស៊ូវជាព្រះដ៏ជាជំនួយរបស់យើង ២:១

ព្រះយេស៊ូវជាព្រះដ៏សុចរិត ២:១; ៣:៧

ព្រះយេស៊ូវជាដង្វាយធួននឹងបាបរបស់យើង ២:២; ៤:១០
ព្រះយេស៊ូវគ្មានបាបសោះ ៣:៥
ព្រះយេស៊ូវបានមកក្នុងសាច់ឈាម ៤:២
ព្រះយេស៊ូវជាព្រះអង្គសង្គ្រោះនៃមនុស្សលោក ៤:១៤
ព្រះយេស៊ូវជាព្រះគ្រីស្ទ ៥:១
ព្រះយេស៊ូវយាងមកដោយទឹក ហើយនិងឈាម ៥:៦

## បងប្រុសរបស់យើងបានសង្គ្រោះយើង

ព្រះយេស៊ូវជាព្រះដ៏ជាជំនួយរបស់យើង ២:១
ព្រះយេស៊ូវជាដង្វាយធួននឹងបាបរបស់យើង ២:២; ៤:១០
ព្រះយេស៊ូវបានយាងមកដើម្បីដោះបាបចេញ ៣:៥
ព្រះយេស៊ូវបានយាងមកដើម្បីនឹងបំផ្លាញការរបស់អារក្សចេញ ៣:៨
ព្រះយេស៊ូវបានស៊ូប្ដូរព្រះជន្មទ្រង់ជំនួសយើង ៣:១៦

## ដោយសារយើងនៅក្នុងគ្រួសាររបស់ព្រះ...

យើងមានសេចក្ដីប្រកបនឹងព្រះវរបិតា ១:៣; ១:៦
យើងមានសេចក្ដីប្រកបនឹងព្រះរាជបុត្រានៃព្រះ គឺព្រះយេស៊ូវគ្រីស្ទ ១:៣
យើងស្គាល់ទ្រង់ ១:៣; ២:៤; ២:១៣; ៤:៧; ៥:២០
យើងនៅក្នុងទ្រង់/នៅជាប់ក្នុងទ្រង់ ២:៥-៦, ២៤; ៣:៦; ៣:២៤; ៤:១៣; ៤:១៥; ៥:២០
យើងនៅក្នុងពន្លឺ ២:៩; ២:១០
យើងត្រូវបានព្រះវិញ្ញាណបរិសុទ្ធចាក់លាបឲ្យ ២:២០; ២:២៧; ៤:១៣
យើងមានព្រះវរបិតា ២:២៣
យើងមានព្រះរាជបុត្រា ៥:១២
យើងកើតពីព្រះ ២:២៩; ៣:៩; ៤:៧; ៥:១; ៥:៤; ៥:១៨
យើងជាកូនរបស់ព្រះ ៣:១, ២; ៣:១០
យើងមានព្រះគង់នៅក្នុងយើង ៣:២៤; ៤:១២; ៤:១៥

យើងមានពូជព្រះនៅក្នុងយើង ៣:៩
យើងបានសុចរិត ៣:៧
យើងមានជីវិត/ជីវិតអស់កល្ប ២:២៥; ៣:១៤; ៣:១៥; ៤:៩; ៥:១១-១៣
យើងជារបស់ព្រះ ៣:១០
យើងកើតពីសេចក្ដីពិត ៣:១៩
យើងមកពីព្រះ ៤:២; ៤:៤; ៤:៦; ៥:១៩

## មុនពេលយើងបានចូលក្នុងគ្រួសាររបស់ព្រះ...

យើងដើរក្នុងសេចក្ដីងងឹត ១:៦; ២:១១
យើងមិនប្រព្រឹត្តតាមសេចក្ដីពិត ១:៦
សេចក្ដីពិតមិនស្ថិតនៅក្នុងយើងទេ ១:៨; ២:៤
ព្រះបន្ទូលទ្រង់មិននៅក្នុងយើងទេ ១:១០
យើងមិនកាន់តាមបញ្ញត្តិទ្រង់ទេ ២:៤
យើងនៅក្នុងសេចក្ដីងងឹត ២:៩; ២:១១
យើងប្រព្រឹត្តអំពើបាប(ធ្វើបាប) ៣:៤; ៣:៨; ៣:៩
យើងប្រព្រឹត្តរំលងក្រឹត្យវិន័យ ៣:៤
យើងធ្វើបាប ៣:៦
យើងជាកូនអារក្ស ៣:១០
យើងមិនប្រព្រឹត្តសេចក្ដីសុចរិត ៣:១០
យើងមិនស្រឡាញ់ដល់បងប្អូន ៣:១០
យើងកើតពីមេកំណាច ៣:១២
យើងនៅជាប់ក្នុងសេចក្ដីស្លាប់ ៣:១៤
យើងមិនស្គាល់ព្រះ ៤:៨

## ដំណឹងល្អ៖ របៀបដែលយើងបានចូលក្នុងគ្រួសាររបស់ព្រះ

សេចក្តីដែលយើងខ្ញុំបានឃើញ ហើយឮនោះ ១:៣

ព្រះលោហិតនៃព្រះយេស៊ូវសម្អាតយើងពីគ្រប់អំពើបាបទាំងអស់ ១:៧

ព្រះអត់ទោសបាបឲ្យយើង ១:៩; ២:១២

ព្រះសម្អាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ ១:៩

ព្រះយេស៊ូវបង្វែរសេចក្តីក្រោធរបស់ព្រះចេញ (ដង្វាយធួននឹងបាប) ២:២

សេចក្តីដែលអ្នករាល់គ្នាបានឮពីដើមមក ២:២៤

ជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ ៣:២៣; ៥:១០

## លក្ខណៈគ្រួសារ

យើងដើរក្នុងពន្លឺ ១:៧

យើងលន់តួអំពើបាបរបស់យើង ១:៩

យើងមិននិយាយថា យើងគ្មានបាប ១:៨

យើងមិននិយាយថា យើងមិនបានធ្វើបាប ១:១០

យើងអត់ចង់ធ្វើបាប ២:១

យើងបានឈ្នះមេកំណាចហើយ ២:១៣, ១៤

ព្រះបន្ទូលនៃព្រះស្ថិតនៅក្នុងយើង ២:១៤

យើងនៅជាប់អស់កល្បជានិច្ច ២:១៧

យើងត្រូវបានព្រះវិញ្ញាណបរិសុទ្ធចាក់លាបឲ្យ ២:២០

យើងស្គាល់សេចក្តីពិត ២:២១

យើងស្រឡាញ់គ្នា ៣:២៣; ៤:៧, ១១, ១២, ១៩; ៤:២១; ៥:១

## ច្បាប់គ្រួសារ

ចូរកាន់តាមបញ្ញត្តិរបស់ព្រះវរបិតា ២:៣; ២:៥; ៣:២២; ៥:២,៣

ចូរឈ្នះលើមេកំណាច ២:១៣

ចូរនៅជាប់ក្នុងទ្រង់ ២:២៧; ២:២៨

ចូរឲ្យសេចក្តីដែលអ្នករាល់គ្នាបានឮពីដើមមក បាននៅជាប់ក្នុងខ្លួនចុះ ២:២៤
អស់អ្នកណាដែលមានសេចក្តីសង្ឃឹមយ៉ាងនេះដល់ទ្រង់ នោះក៏តែងជំរះសម្អាតចិត្តខ្លួន ៣:៣
ចូរប្រព្រឹត្តសេចក្តីសុចរិត (អនុវត្តសេចក្តីសុចរិត) ៣:៧
ចូរប្រព្រឹត្តអំពើសុចរិត ៣:១២
ចូរយើងប្តូរជីវិតយើងជំនួសបងប្អូន ៣:១៦
ត្រូវស្រឡាញ់គ្នាទៅវិញទៅមក ៣:២៣; ៤:៧; ១១, ១២, ១៩; ៤:២១; ៥:១
ចូរប្រព្រឹត្តការដែលគាប់ព្រះហឫទ័យដល់ព្រះ ៣:២២
ចូរជឿដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ ៣:២៣, ៥:១០
កុំឲ្យជឿគ្រប់ទាំងវិញ្ញាណឡើយ/ចូរល្បងវិញ្ញាណទាំងអស់វិញ ៤:១
ចូររក្សាខ្លួនឲ្យផុតពីរូបព្រះ ៥:២១

## ទំនាក់ទំនងផ្សេងទៀតនៃគ្រួសារ

កូន៖  ២:១, ១២, ១៣, ១៨, ២៨; ៣:១, ២; ៥:២១
ឪពុក/ម្តាយ៖  ២:១៣, ១៤
បងប្អូន៖  ២:៩-១១; ៣:១០; ៣:១៣-១៧; ៤:២០, ២១; ៥:១៦

# ឧបសម្ពន្ធ ៥

## យ៉ូហានទី១៖ ប្រយោគវិនិច្ឆ័យ

ព្រះគម្ពីរយ៉ូហានទី ១ មាន ១០៥ ខ។ ពាក្យ «បើ» ឬ «បើសិនជា» កើតឡើង ២៤ ដងក្នុង ១០៥ ខ។ នេះគឺជាអត្រាខ្ពស់បំផុតនៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ ពាក្យទាំងនោះជួយយើងធ្វើការវិនិច្ឆ័យដើម្បីសាកល្បងគ្រូក្លែងក្លាយនិងសាកល្បងខ្លួនឯងផងដែរ។ ប្រសិនបើយើងបូកសរុបប្រយោគវិនិច្ឆ័យទាំងអស់នៅក្នុង ១យ៉ូហាន នោះមានប្រហែល ៦០ ដង ក្នុងចំណោម ១០៥ ខ។ នេះគឺជាបញ្ជីពេញលេញ៖

### «បើ» ឬ «ដោយ»

*១:៦ **បើសិនជាយើង**រាល់គ្នាថា យើងមានសេចក្ដីប្រកបនឹងទ្រង់ តែដើរក្នុងសេចក្ដីងងឹតវិញ នោះឈ្មោះថាយើងកុហក ហើយមិនប្រព្រឹត្តតាមសេចក្ដីពិតទេ។*

*១:៧ តែ**បើយើង**រាល់គ្នាដើរក្នុងពន្លឺវិញ ដូចជាទ្រង់ក៏គង់ក្នុងពន្លឺដែរ នោះយើងមានសេចក្ដីប្រកបនឹងគ្នាទៅវិញទៅមក ហើយព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃទ្រង់ ក៏សំអាតយើងរាល់គ្នា ពីគ្រប់អំពើបាបទាំងអស់។*

*១:៨ **បើសិនជាយើង**ថា យើងគ្មានបាបសោះ នោះឈ្មោះថាយើងបញ្ឆោតដល់ខ្លួន ហើយសេចក្ដីពិតមិនស្ថិតនៅក្នុងយើងទេ។*

*១:៩ **បើយើង**លន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ហើយនិងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង*

*១:១០ **បើយើង**ថា យើងមិនដែលធ្វើបាបសោះ នោះឈ្មោះថាយើងធ្វើឲ្យទ្រង់ទៅជាអ្នកកុហកវិញ ហើយព្រះបន្ទូលទ្រង់មិននៅក្នុងយើងទេ។*

*២:១ខ តែ**បើសិនជាអ្នកណា**ភ្លាត់ធ្វើបាបវិញ នោះយើងមានព្រះដ៏ជាជំនួយ១អង្គហើយ ដែលទ្រង់គង់នៅចំពោះព្រះវរបិតា គឺជាព្រះយេស៊ូវគ្រីស្ទ ជាព្រះដ៏សុចរិត។*

២:១៥ខ **បើអ្នកណា**ស្រឡាញ់លោកីយ៍ អ្នកនោះគ្មានសេចក្តីស្រឡាញ់របស់ព្រះវរបិតានៅក្នុងខ្លួនឡើយ។

២:១៩ខ ដ្បិត**បើគេ**ជាពួកយើងមែន នោះនឹងបាននៅជាប់ជាមួយនឹងយើងហើយ តែដែលគេបានចេញទៅ នោះដើម្បីនឹងសំដែងពីគេថា គ្រប់គ្នាមិនមែនជាពួកយើងទេ។

២:២៤ខ **បើសិនជា**សេចក្តីដែលឮតាំងពីដើមមក បាននៅជាប់ក្នុងអ្នករាល់គ្នាមែន នោះអ្នករាល់គ្នានឹងនៅជាប់ក្នុងព្រះរាជបុត្រា ហើយក្នុងព្រះវរបិតាដែរ។

២:២៩ **បើអ្នករាល់គ្នា**ដឹងថា ទ្រង់សុចរិត នោះត្រូវតែយល់ឃើញថា អស់អ្នកណាដែលប្រព្រឹត្តតាមសេចក្តីសុចរិតនោះ គេបានកើតពីទ្រង់មកដែរ។

៣:១៧ **បើអ្នកណា**មានភោគសម្បត្តិរបស់លោកីយ៍នេះ ហើយឃើញបងប្អូនណាដែលខ្វះខាត តែមិនចេះអាណិតមេត្តាសោះ នោះធ្វើដូចម្តេច ឲ្យសេចក្តីស្រឡាញ់នៃព្រះ បានស្ថិតនៅក្នុងអ្នកនោះបាន។

៣:២១ ពួកស្ងួនភ្ងាអើយ **បើចិត្តយើង**មិនចោទប្រកាន់ចំពោះខ្លួនទេ នោះយើងមានសេចក្តីក្លាហាននៅចំពោះព្រះ។

៤:១២ខ តែ**បើយើង**ស្រឡាញ់គ្នាទៅវិញទៅមក នោះព្រះទ្រង់គង់នៅក្នុងយើង ហើយសេចក្តីស្រឡាញ់របស់ទ្រង់ បានពេញខ្នាតក្នុងយើងដែរ។

៤:២០ **បើអ្នកណា**ថា ខ្លួនស្រឡាញ់ព្រះ តែស្អប់ដល់បងប្អូនវិញ អ្នកនោះជាអ្នកកុហក។

៥:៩ **បើសិនជាយើង**បានទទួលសេចក្តីបន្ទាល់របស់មនុស្សទៅហើយ នោះសេចក្តីបន្ទាល់របស់ព្រះក៏ប្រសើរជាងទៅទៀត។

## «យើងដឹងថា...» «យើងស្គាល់...»

២:៣ **យើងរាល់គ្នាដឹងថា** យើងស្គាល់ទ្រង់ ដោយសារសេចក្តីនេះ គឺដោយយើងកាន់តាមបញ្ញត្តរបស់ទ្រង់។

២:៥-៦ គឺដោយសេចក្តីនោះឯង ដែល**យើងដឹងថា** យើងនៅក្នុងទ្រង់ អ្នកណាដែលថាខ្លួននៅក្នុងទ្រង់ នោះត្រូវតែប្រព្រឹត្តដូចជាទ្រង់ដែរ។

៣:១៦ **យើងរាល់គ្នាបានស្គាល់**សេចក្តីស្រឡាញ់ គឺដោយទ្រង់បានស៊ូប្តូរព្រះជន្មទ្រង់ជំនួសយើង។

*៣:១៩ គឺយ៉ាងនោះឯងដែល**យើងនឹងដឹងថា** យើងកើតមកពីសេចក្តីពិត ហើយយើងនឹងបានកំឡាចិត្ត នៅចំពោះទ្រង់ផង។*

*៣:២៤ខ **យើងដឹងថា** ទ្រង់គង់នៅក្នុងយើង ដោយសារព្រះវិញ្ញាណដែលទ្រង់ប្រទានមក។*

*៣:២៤ខ **យើងដឹងថា** ទ្រង់គង់នៅក្នុងយើង ដោយសារព្រះវិញ្ញាណដែលទ្រង់ប្រទានមក។*

*៤:៦ ឯយើងរាល់គ្នា ជាអ្នកមកពីព្រះវិញ ហើយអ្នកណាដែលស្គាល់ព្រះនោះក៏ស្តាប់យើងខ្ញុំ តែអ្នកណាដែលមិនមកពីព្រះទេ នោះមិនព្រមស្តាប់យើងខ្ញុំឡើយ គឺយ៉ាងនោះឯង ដែល**យើងនឹងស្គាល់**វិញ្ញាណនៃសេចក្តីពិត និងវិញ្ញាណនៃសេចក្តីខុសឆ្គងទៅបាន។*

*៤:១៣ គឺយ៉ាងនោះឯងដែល**យើងដឹងថា** យើងនៅជាប់ក្នុងទ្រង់ ហើយទ្រង់ក៏គង់នៅក្នុងយើង ពីព្រោះទ្រង់បានប្រទានព្រះវិញ្ញាណទ្រង់មកយើងរាល់គ្នា។*

*៥:១៨ **យើងដឹងថា** អ្នកណាដែលកើតពីព្រះមក នោះមិនចេះធ្វើបាបទេ អ្នកនោះឯងជាអ្នករក្សាខ្លួនវិញ ហើយមេកំណាចនឹងពាល់អ្នកនោះមិនបានឡើយ។*

*៥:១៩ **យើងដឹងថា** យើងមកពីព្រះពិត តែលោកីយ៍ទាំងមូលដេកនៅក្នុងឱវាទនៃមេកំណាចវិញ។*

*៥:២០ **យើងក៏ដឹងថា** ព្រះរាជបុត្រានៃព្រះបានយាងមកហើយ ក៏បានប្រទានឲ្យយើងរាល់គ្នាមានប្រាជ្ញា ដើម្បីឲ្យបានស្គាល់ព្រះដ៏ពិតប្រាកដ។*

## «អ្នកណាដែលថា...»

*២:៤ **អ្នកណាដែលថា** បានស្គាល់ទ្រង់ តែមិនកាន់តាមបញ្ញត្តទ្រង់ទេ អ្នកនោះឈ្មោះថាជាអ្នកកុហក ហើយសេចក្តីពិតមិននៅក្នុងអ្នកនោះឡើយ។*

*២:៥ខ-៦ **អ្នកណាដែលថា**ខ្លួននៅក្នុងទ្រង់ នោះត្រូវតែប្រព្រឹត្តដូចជាទ្រង់ដែរ។*

*២:៩ **អ្នកណាដែលថា** ខ្លួននៅក្នុងពន្លឺ តែស្អប់ដល់បងប្អូន នោះឈ្មោះថានៅក្នុងសេចក្តីងងឹត ដរាបដល់សព្វថ្ងៃនេះ។*

## «**អ្នកណា...**»

*២:៥ តែ**អ្នកណា**ដែលកាន់តាមព្រះបន្ទូលទ្រង់វិញ នោះប្រាកដជាសេចក្ដីស្រឡាញ់នៃព្រះបានពេញខ្នាត។*

*២:១០ ឯ**អ្នកណា**ដែលស្រឡាញ់ដល់បងប្អូនខ្លួន នោះតែងនៅក្នុងពន្លឺវិញ ហើយនៅក្នុងអ្នកនោះគ្មានហេតុណា នឹងបង្អាក់បង្អន់ចិត្ត គេឡើយ។*

*២:១១ តែ**អ្នកណា**ដែលស្អប់ដល់បងប្អូន នោះឈ្មោះថានៅក្នុងសេចក្ដីងងឹតវិញ ក៏ដើរក្នុងសេចក្ដីងងឹត ហើយមិនដឹងជាខ្លួនទៅឯណាផង ពីព្រោះសេចក្ដីងងឹតនោះបានបំបាំងភ្នែកហើយ។*

*២:១៧ខ **អ្នកណា**ដែលធ្វើតាមព្រះហឫទ័យព្រះ នោះនឹងនៅជាប់អស់កល្បជានិច្ចវិញ។*

*២:២៣ ឯ**អស់អ្នក**ដែលមិនព្រមទទួលស្គាល់ព្រះរាជបុត្រា នោះក៏គ្មានព្រះវរបិតាដែរ តែ**អ្នកណា**ដែលព្រមទទួលស្គាល់ព្រះរាជបុត្រា នោះក៏មានទាំងព្រះវរបិតាផង។*

*២:២៩ខ បើអ្នករាល់គ្នាដឹងថា ទ្រង់សុចរិត នោះត្រូវតែយល់ឃើញថា **អស់អ្នកណា**ដែលប្រព្រឹត្តតាមសេចក្ដីសុចរិតនោះ គេបានកើតពីទ្រង់មកដែរ។*

*៣:៣ **អស់អ្នកណា**ដែលមានសេចក្ដីសង្ឃឹមយ៉ាងនេះដល់ទ្រង់ នោះក៏តែងជំរះសំអាតចិត្តខ្លួន ឲ្យដូចទ្រង់ដែលស្អាតដែរ។*

*៣:៤ **ឯអស់អ្នកណា**ដែលប្រព្រឹត្តអំពើបាបវិញ នោះក៏ឈ្មោះថាប្រព្រឹត្តរំលងក្រឹត្យវិន័យដែរ ដ្បិតអំពើបាបជាការរំលងក្រឹត្យវិន័យហើយ។*

*៣:៧ កូនតូចៗ រាល់គ្នាអើយ ចូរកុំឲ្យអ្នកណានាំអ្នករាល់គ្នាឲ្យវង្វេងឡើយ **អ្នកណា**ដែលប្រព្រឹត្តសេចក្ដីសុចរិត នោះឈ្មោះថាសុចរិតហើយ ដូចជាទ្រង់ក៏សុចរិតដែរ។*

*៣:៨ តែ**អ្នកណា**ដែលប្រព្រឹត្តអំពើបាបវិញ នោះគឺមកពីអារក្សទេ ពីព្រោះអារក្សបានធ្វើបាប ចាប់តាំងពីដើមរៀងមក។*

*៣:១០ខ **ឯអ្នកណា**ដែលមិនប្រព្រឹត្តសេចក្ដីសុចរិត ហើយមិនស្រឡាញ់ដល់បងប្អូន នោះមិនមែនមកពីព្រះទេ។*

*៣:១៤ខ **ឯអ្នកណា**ដែលមិនស្រឡាញ់បងប្អូន អ្នកនោះជាអ្នកនៅជាប់ក្នុងសេចក្ដីស្លាប់នៅឡើយ។*

*៣:១៥ **អ្នកណា**ដែលមានចិត្តស្អប់ដល់បងប្អូន នោះឈ្មោះថាជាអ្នកសំឡាប់គេ។*

៣:២៤ **អ្នកណា**ដែលកាន់តាមបញ្ញត្តទ្រង់ នោះឈ្មោះថានៅជាប់ក្នុងទ្រង់ ហើយទ្រង់ក៏គង់នៅក្នុងអ្នកនោះដែរ។

៤:៦ ឯយើងរាល់គ្នា ជាអ្នកមកពីព្រះវិញ ហើយ**អ្នកណា**ដែលស្គាល់ព្រះនោះក៏ស្តាប់យើងខ្ញុំ តែ**អ្នកណា**ដែលមិនមកពីព្រះទេ នោះមិនព្រមស្តាប់យើងខ្ញុំឡើយ។

៤:៧ ពួកស្ងួនភ្ងាអើយ យើងត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដ្បិតសេចក្តីស្រឡាញ់មកពីព្រះ **ឯអស់អ្នកណា**ដែលមានសេចក្តីស្រឡាញ់ នោះឈ្មោះថាមកពីព្រះ ហើយក៏ស្គាល់ទ្រង់ដែរ។

៤:១៥ **អ្នកណា**ដែលយល់ព្រមថា ព្រះយេស៊ូវ ជាព្រះរាជបុត្រានៃព្រះ អ្នកនោះឈ្មោះថា មានព្រះគង់នៅក្នុងខ្លួនពិត ហើយខ្លួនក៏នៅក្នុងព្រះដែរ។

៤:១៦ ឯ**អ្នកណា**ដែលនៅជាប់ក្នុងសេចក្តីស្រឡាញ់ នោះក៏បាននៅជាប់ក្នុងព្រះ ហើយព្រះទ្រង់គង់នៅក្នុងអ្នកនោះដែរ។

៤:១៨ខ **អ្នកណា**ដែលមានសេចក្តីភ័យខ្លាច នោះមិនទាន់បានពេញខ្នាត ខាងឯសេចក្តីស្រឡាញ់នៅឡើយទេ។

៤:២១ មួយទៀត យើងបានទទួលបញ្ញត្តនេះពីព្រះមកថា **អ្នកណា**ដែលស្រឡាញ់ដល់ព្រះ នោះត្រូវតែស្រឡាញ់ដល់បងប្អូនដែរ។

៥:១ **អស់អ្នកណា**ដែលជឿថា ព្រះយេស៊ូវជាព្រះគ្រីស្ទ អ្នកនោះបានកើតពីព្រះមក ហើយ**អស់ទាំងអ្នកណា**ដែលស្រឡាញ់ព្រះដ៏បង្កើតខ្លួនមក នោះក៏រមែងស្រឡាញ់ដល់អស់អ្នកឯទៀត ដែលកើតពីទ្រង់មកដែរ។

៥:៤ ពីព្រោះ**គ្រប់ទាំងអស់**ដែលកើតពីព្រះមក នោះបានឈ្នះលោកីយ៍ហើយ។

៥:១០ **អ្នកណា**ដែលជឿដល់ព្រះរាជបុត្រានៃព្រះ នោះមានសេចក្តីបន្ទាល់ នៅក្នុងខ្លួនហើយ តែ**អ្នកណា**ដែលមិនជឿសោះ នោះឈ្មោះថា បានធ្វើឲ្យទ្រង់ទៅជាអ្នកកុហកវិញ។

៥:១១-១២ ឯ**អ្នកណា**ដែលមានព្រះរាជបុត្រា នោះក៏មានជីវិតដែរ តែអ្នកណាដែលគ្មានព្រះរាជបុត្រានៃព្រះទេ នោះគ្មានជីវិតឡើយ។

៥:១៨ **អ្នកណា**ដែលកើតពីព្រះមក នោះមិនចេះធ្វើបាបទេ អ្នកនោះឯងជាអ្នករក្សាខ្លួនវិញ ហើយមេកំណាចនឹងពាល់អ្នកនោះមិនបានឡើយ។

# គោលជំនឿរបស់ពួកសាវក

**ខ្ញុំជឿលើព្រះវរបិតា**ដ៏មានគ្រប់អំណាចព្រះចេស្ដា
ព្រះអង្គគឺជាព្រះអាទិករបង្កើតផ្ទៃមេឃ និង ផែនដី។

**ខ្ញុំជឿលើព្រះយេស៊ូវគ្រីស្ទ** គឺជាព្រះបុត្រាតែមួយនៃព្រះបិតា ដែលជាព្រះជាម្ចាស់របស់យើង
ព្រះអង្គបានកើតជាមនុស្ស ដោយឫទ្ធានុភាពព្រះវិញ្ញាណដ៏វិសុទ្ធ
ហើយបានប្រសូតចេញពីនាងក្រមុំព្រហ្មចារី ម៉ារា។
ព្រះអង្គបានរងទុក្ខវេទនា នៅក្រោមកណ្ដាប់ដៃរបស់ប៉ុនទាសពីឡាត់
ដោយជាប់លើឈើឆ្កាង ហើយបានសុគត ហើយព្រះបរមសពបានទទួលការបញ្ចុះ។
ព្រះអង្គបានយាងចុះទៅស្ថានឃុំព្រលឹងមនុស្សស្លាប់។
នៅថ្ងៃទីបី ព្រះអង្គបានមានព្រះជន្មរស់ឡើងវិញ។
ព្រះអង្គបានយាងទៅកាន់ឋានសួគ៌ ហើយគង់នៅខាងស្ដាំព្រះបិតា
ព្រះអង្គនឹងយាងត្រឡប់មកវិញ ដើម្បីវិនិច្ឆ័យមនុស្សទាំងអស់
ទោះទាំងមនុស្សរស់ និង មនុស្សស្លាប់។

**ខ្ញុំជឿលើព្រះវិញ្ញាណបរិសុទ្ធ** និង ជឿលើពួកជំនុំដ៏វិសុទ្ធ
ហើយការចងសម្ពន្ធជាមួយពួកដ៏វិសុទ្ធ
ហើយការលើកលែងទោសពីអំពើបាប
ហើយការរស់ឡើងវិញនៃរូបកាយ
និង ជីវិតអស់កល្បជានិច្ច។ អាម៉ែន។

# គោលជំនឿក្រុមប្រឹក្សាណៃសៀ គ.ស. 381

**យើងជឿលើព្រះតែមួយ**

គឺព្រះបិតា ដ៏មានគ្រប់អំណាចព្រះចេស្តា

ជាព្រះបង្កើតផ្ទៃមេឃ និងផែនដី ទាំងអ្វីៗដែលមើលឃើញនិងមើលមិនឃើញ។

**យើងជឿលើព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទតែមួយ**

ជាព្រះបុត្រាតែមួយនៃព្រះ ដែលមានព្រះជន្មគង់នៅ រួមជាមួយព្រះបិតា តាំងពីអស់កល្បជានិច្ច

ជា ព្រះនៃព្រះ ជាពន្លឺនៃពន្លឺ ជាព្រះដ៏ពិតនៃព្រះដ៏ពិត

ដែលមានព្រះជន្មគង់នៅតែមិនមែនដោយការបង្កើតទេ

ព្រះអង្គមាននិស្ស័យតែមួយនឹងព្រះបិតា ហើយអ្វីៗសព្វសារពើក៏កើតមកដោយសារព្រះអង្គដែរ

ព្រះអង្គយាងមកពីស្ថានសួគ៌ ដើម្បីមនុស្សយើង និងសេចក្តីសង្គ្រោះរបស់យើង

ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ នោះព្រះអង្គបានយករូបកាយជាមនុស្ស

តាមរយៈនាងក្រមុំព្រហ្មចារី ម៉ារា ហើយបានត្រឡប់ជាមនុស្ស

ព្រះអង្គត្រូវគេឆ្កាងជំនួសយើង នៅជំនាន់លោកប៉ុនទាសពីឡាត់

ទ្រង់បានរងទុក្ខវេទនាដល់សុគត ហើយព្រះសពព្រះអង្គត្រូវគេបញ្ចុះ

នៅថ្ងៃទីបីព្រះអង្គបានមានព្រះជន្មរស់ឡើងវិញស្របតាមបទគម្ពីរ

ព្រះអង្គបានយាងឡើងទៅឋានសួគ៌ និង គង់នៅខាងស្តាំព្រះបិតា

ព្រះអង្គនឹងយាងមកវិញក្នុងសិរីរុងរឿង

ដើម្បីជំនុំជម្រះមនុស្សលោកទាំងអស់ ទាំងមនុស្សរស់ និង មនុស្សស្លាប់

ហើយព្រះរាជ្យព្រះអង្គ ស្ថិតស្ថេរអស់កល្បជានិច្ច។

**យើងជឿលើព្រះវិញ្ញាណបរិសុទ្ធ**

ដែលជាព្រះអម្ចាស់ ហើយជាព្រះអង្គប្រទានជីវិត

ដែលបានយាងមកពីព្រះបិតា និង ព្រះបុត្រា

ព្រះអង្គជាព្រះដែលត្រូវទទួលការថ្វាយបង្គំ និង ការសរសើរតម្កើង រួមជាមួយព្រះបិតា និង ព្រះបុត្រា

ព្រះអង្គបានថ្លែងព្រះបន្ទូល តាមរយៈពួកព្យាការី។

យើងជឿលើពួកជំនុំសកលដ៏វិសុទ្ធតែមួយ ដែលបន្តពីជំនឿពួកសាវក

យើងទទួលស្គាល់ពិធីបុណ្យជ្រមុជទឹកតែមួយ សម្រាប់ការអត់ទោសបាប

យើងទន្ទឹងរង់ចាំការរស់ឡើងវិញនៃអស់អ្នកដែលបានស្លាប់និង ជីវិតនៃគ្រាថ្មី

ដែលនឹងត្រូវមកដល់។ អាម៉ែន។

## តើព្រឹត្តិការណ៍ណាខ្លះត្រូវកើតឡើង នៅពេលព្រះគ្រីស្ទពិតយាងមកវិញ?

ព្រះគម្ពីរបាននិយាយច្បាស់ណាស់ អំពីព្រឹត្តិការណ៍ដែលត្រូវតែកើតឡើងនៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ។ យើងអាចប្រើប្រាស់បទទំនាយទាំងនេះ ដើម្បីល្បងមើល ព្រះគ្រីស្ទក្លែងក្លាយ។

១. ពេលដែលព្រះគ្រីស្ទពិតប្រាកដយាងមកវិញ ទ្រង់នឹង *«សងសេចក្តីទុក្ខលំបាក»* ដល់ពួកអ្នកដែលធ្វើទុក្ខដល់គ្រីស្ទបរិស័ទ ហើយប្រទានការ *«សំរាក»* និងសេចក្តីសង្គ្រោះ ដល់ពួកអ្នកដែលត្រូវគេធ្វើទុក្ខ។ ទ្រង់នឹងមក *«ជាមួយនឹងពួកទេវតានៃព្រះចេស្តាទ្រង់ នៅក្នុងអណ្តាតភ្លើង ទាំងសងសឹកនឹងពួកអ្នកដែលមិនស្គាល់ព្រះ ហើយនិងពួកអ្នកដែលមិនស្តាប់តាមដំណឹងល្អ ពីព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើង»*។ (២ថែស្សាឡូនីច ១:៦-៨) **តើការនេះបានកើតឡើងទេ នៅពេលព្រះគ្រីស្ទក្លែងក្លាយបានមកនោះ? អត់សោះ!**

២. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងមិនយាងមកដោយស្ងាត់ៗទេ។ «គ្រប់ទាំងភ្នែកនឹងឃើញទ្រង់» (វិវរណៈ ១:៧; ម៉ាថាយ ២៤:២៧; ១ថែស្សាឡូនីច ៤:១៦)។ **តើការនេះបានកើតឡើងទេ នៅពេលព្រះគ្រីស្ទក្លែងក្លាយបានមកនោះ មកនោះ? អត់សោះ!**

៣. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ នោះនៅលើមេឃនឹងត្រូវកក្រើករំពើក។ *«ស្រាប់តែថ្ងៃនឹងទៅជាងងឹត ខែនឹងលែងភ្លឺ អស់ទាំងផ្កាយនឹងធ្លាក់ចុះពីលើមេឃ ហើយអស់ទាំងអំណាចនៅលើមេឃនឹងត្រូវកក្រើករំពើក»* (ម៉ាថាយ ២៤:២៩)។ **តើការនេះបានកើតឡើងទេ នៅពេលដែលព្រះគ្រីស្ទក្លែងក្លាយបានមកនោះ? អត់សោះ!**

៤. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងយាងមកដោយអំណាច និងសិរីល្អ ហើយមនុស្សមានបាបទាំងអស់នៅលើផែនដីនឹងសោកសៅ (ម៉ាថាយ ២៤:៣០)។ **តើការនេះបានកើតឡើងទេ នៅពេលដែលព្រះគ្រីស្ទក្លែងក្លាយបានមកនោះ? អត់សោះ!**

៥. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់ *«នឹងចាត់ពួកទេវតារបស់លោក ឲ្យមកដោយសូរផ្លុំត្រែជាខ្លាំង ទេវតាទាំងនោះនឹងប្រមូលពួករើសតាំងរបស់លោកពីទិសទាំង៤ ចាប់តាំងពីជើងមេឃម្ខាង រហូតដល់ជើងមេឃម្ខាង»* (ម៉ាថាយ ២៤:៣១)។ **តើការនេះបានកើតឡើងទេ នៅពេលដែលព្រះគ្រីស្ទក្លែងក្លាយបានមកនោះ? អត់សោះ!**

៦. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងបំផ្លាញអាទទឹងនឹងព្រះគ្រីស្ទ (២ថែស្សាឡូនីច ២:៣-៤, ៨)។ **តើការនេះបានកើតឡើងទេ នៅពេលដែលព្រះគ្រីស្ទក្លែងក្លាយបានមកនោះ? អត់សោះ!**

៧. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងចាក់សេចក្ដីក្រោធរបស់ទ្រង់ទៅលើអស់អ្នកមានបាបទាំងអស់គ្នា (១ថែស្សាឡូនីច ៥:២-៣)។ **តើការនេះបានកើតឡើងទេ នៅពេលដែលព្រះគ្រីស្ទក្លែងក្លាយបានមកនោះ? អត់សោះ!**

៨. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មកវិញ ទ្រង់នឹងកាត់ទោសគ្រប់គ្នាភ្លាមៗ (ម៉ាថាយ ២៥:៣១-៣២)។ **តើការនេះបានកើតឡើងទេ នៅពេលដែលព្រះគ្រីស្ទក្លែងក្លាយបានមកនោះ? អត់សោះ!**

៩. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មក ទ្រង់នឹងប្រោសរូបកាយអ្នកស្លាប់ទាំងអស់ដែលជាគ្រីស្ទបរិស័ទ។ (១ថែស្សាឡូនីច ៤:១៦-១៧)។ **តើការនេះបានកើតឡើងទេ នៅពេលដែលព្រះគ្រីស្ទក្លែងក្លាយបានមកនោះ? អត់សោះ!**

១០. នៅពេលដែលព្រះគ្រីស្ទពិតប្រាកដយាងត្រឡប់មក ទ្រង់នឹងមិនកើតមកជាទារកតូចទេ ប៉ុន្តែទ្រង់នឹងយាងមកពីស្ថានសួគ៌ជាអ្នកចម្បាំងដ៏មានអំណាចព្រះចេស្ដា ដើម្បីវិនិច្ឆ័យជំនុំជម្រះផែនដី (វិវរណៈ ១៩:១១-១៦)។ **តើការនេះបានកើតឡើងទេ នៅពេលដែលព្រះគ្រីស្ទក្លែងក្លាយបានមកនោះ? អត់សោះ!**

**គ្មានព្រឹត្តិការណ៍ណាមួយសោះបានកើតឡើង! ពួកគេសុទ្ធតែក្លែងក្លាយ!**


ចូរបរិសុទ្ធ
ព្រះជាពន្លឺ
ជឿការពិត
កើតពីព្រះ
ស្រឡាញ់ព្រះ
ស្រឡាញ់គ្នា
ព្រះជាសេចក្ដីស្រឡាញ់

## Ahn Sahng-hong - អាន់ សាំងហុង

ពីប្រទេស កូរ៉េ

បុរសជនជាតិកូរ៉េម្នាក់ដែលបានស្លាប់ដោយសារជំងឺ ហើយមិនបានរស់ឡើងវិញទេ គឺជាព្រះ។ ហើយប្រពន្ធរបស់គាត់អះអាងថាជាព្រះមាតាដែរ។ ដើម្បីបានសង្គ្រោះមនុស្សត្រូវរក្សាបុណ្យរំលង និងការថ្វាយបង្គំនៅថ្ងៃសៅរ៍ ។



WORLD MISSION SOCIETY CHURCH OF GOD

សំណួរៈ

- តើ អាន់ សាំងហុង បានរស់ពីស្លាប់ឡើងវិញទេ ?
- បើគាត់មិនរស់ឡើងវិញទេ តើគាត់អាចជួយយើងឲ្យយកឈ្នះលើសេចក្តីស្លាប់បានយ៉ាងដូចម្តេច ?
- តើមួយណាខ្លាំងជាង សេចក្តីស្លាប់ ឬ អាន់ សាំងហុង ?
- បើស្ត្រីនេះជា «ព្រះមាតា» ហេតុអ្វីបានជាគាត់មិនប្រោសប្តីឲ្យរស់ឡើងវិញ ?
- ប្រសិនបើ «ព្រះមាតា»ស្លាប់ ហើយមិនរស់ឡើងវិញទេ តើអ្នកនឹងឈប់ជឿលើគាត់ទេ ?
- ព្រះគម្ពីរចែងថា មានតែជនជាតិអ៊ីស្រាអែលដែលកាត់ស្បែកប៉ុណ្ណោះ ទើបអាចរក្សាបុណ្យរំលងបាន។ តើអ្នកសុខចិត្តទទួលការកាត់ស្បែកទេ ?

## Apollo Quiboloy - អាប៉ូឡូ គីបូឡូយ

ពីប្រទេស ហ្វីលីពីន

បុរសជនជាតិហ្វីលីពីនម្នាក់បានក្លាយជាអ្នកមានដោយអះអាងថាខ្លួនជាព្រះរាជបុត្រានៃព្រះដែលគ្មានបាបសោះ។ គាត់អះអាងថាគាត់បានមកដើម្បីបំពេញនូវអ្វីដែលព្រះយេស៊ូវបានបរាជ័យ។ គាត់ក៏បដិសេធគោលលទ្ធិនៃព្រះត្រៃឯកដែរ។



JESUS CHRIST NEW JERUSALEM PASTOR APOLLO C. QUIBOLOY THE NAME ABOVE EVERY NAME

សំណួរៈ

- ព្រះយេស៊ូវមានបន្ទូលថា «ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត។ បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ» ( យ៉ូហាន ១៤:៦ ) ប៉ុន្តែ អាប៉ូឡូ គីបូឡូយ អះអាងថា ខគម្ពីរនេះគឺនិយាយអំពីគាត់វិញ។ តើអាប៉ូឡូ គីបូឡូយកុហក ឬ ព្រះយេស៊ូវកុហក ?
- ពេលដែលព្រះគ្រីស្ទពិតប្រាកដយាងមកវិញ ទ្រង់នឹងមក «ជាមួយនឹងពួកទេវតា» ដើម្បីជំនុំជំរះពិភពលោក ហើយកាត់ទោសមនុស្សទាំងអស់ភ្លាម។ តើ អាប៉ូឡូ គីបូឡូយ បានជំនុំជំរះពិភពលោកឬទេ ?
- បើសិន អាប៉ូឡូ គីបូឡូយ មិនរស់ពីស្លាប់ឡើងវិញ តើគាត់ជាព្រះក្លែងក្លាយឬ ? តើអ្នកនឹងឈប់ជឿលើគាត់ឬ ?

## Eastern Lightning - ផ្លេកបន្ទោរទិសខាងកើត

ពួកជំនុំនៃព្រះដ៏មានគ្រប់ព្រះចេស្តា -- ពីប្រទេស ចិន

ស្ត្រីជនជាតិចិនម្នាក់បានហៅខ្លួនឯងថា ជាព្រះគ្រីស្ទ ហើយជាព្រះដ៏មានគ្រប់ព្រះចេស្តា។ ប៉ុន្តែនាងបានលាក់ខ្លួនពីមនុស្សទាំងអស់។ ហេតុអ្វីបានជា«ព្រះដ៏មានគ្រប់ព្រះចេស្តា» មិនព្រមបង្ហាញខ្លួននាងឲ្យមនុស្សទាំងអស់អាចមើលឃើញ ?



THE CHURCH OF ALMIGHTY GOD

សំណួរៈ

- តើនាង យ៉ាង ស៊ីងប៊ិន ( Yang Xiangbin ) គឺជាព្រះគ្រីស្ទដែលយាងមកលើកទីពីរឬ? តែនៅពេលនាងបានមកផែនដីនេះ តើ «គ្រប់ទាំងភ្នែកបានឃើញនាង» ឬ? (វិវរណៈ ១:៧)។ ឬក៏នាងបានលាក់ខ្លួនដោយស្ងៀមស្ងាត់វិញ ?
- បើនាងជា «ព្រះដ៏មានគ្រប់ព្រះចេស្តា» ហេតុអ្វីនាងលាក់ខ្លួន ?
- តើក្រុមនេះជឿថា ព្រះយេស៊ូវបានរស់ពីសុគតឡើងវិញទេ ? ( មិនជឿទេ )
- ប្រសិនបើនាងមិនរស់ពីស្លាប់ឡើងវិញទេ តើអ្នកនឹងឈប់ជឿលើនាងទេ ?

## Mormons - មរមន

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទពួកបរិសុទ្ធថ្ងៃចុងក្រោយ

ពួកគេថា ពីមុន ព្រះជាមនុស្សធម្មតា ដែលបានក្លាយជាព្រះ។

ព្រះយេស៊ូវក៏ជាមនុស្សធម្មតា ដែលបានក្លាយជាព្រះដែរ។

បុរសមរមនក៏អាចក្លាយជាព្រះដែរ។

Joseph Smith
ស្ថាបនិក





Brigham Young
ស្ថាបនិកទីពីរ

សំណួរៈ

- តើក្រុមរបស់អ្នកជឿថា ពីមុនព្រះជាមនុស្សធម្មតា តែបានក្លាយជាព្រះឬ ?
- តើក្រុមរបស់អ្នកជឿថា ព្រះយេស៊ូវ និងអារក្សសាតាំងជាបងប្អូនបង្កើតឬ ?
- តើព្រះយេស៊ូវជាមនុស្សដែលបានក្លាយជាព្រះ ឬក៏ទ្រង់គឺជាព្រះជានិច្ច ?
- តើគ្រូមរមនល្បីៗខ្លះបានបង្រៀនថា ព្រះវរបិតាបានរួមរស់ជាមួយនឹងនាងម៉ារា ដើម្បីបង្កើតរូបកាយសម្រាប់ព្រះយេស៊ូវឬ ? ( ពិតមែន )
- តើពួកអ្នកជឿថា វាជាការល្អដែលអ័ដាមមិនស្តាប់បង្គាប់ព្រះឬ ? ( ពិតមែន )
- តើព្រះមានប្រពន្ធច្រើននៅស្ថានសួគ៌ទេ ?
- តើស្ថាបនិក យ៉ូសែប ស្មីត បានយកប្រពន្ធប៉ុន្មាននាក់ ? ( ២៧-៤០ នាក់ ) ចុះស្ថាបនិកព្រិកហាំ យ៉ង់ ? ( ជាង ៥០ នាក់ ) តើគេមានប្រពន្ធខ្លះដែលនៅតែជាប្រពន្ធស្របច្បាប់ជាមួយនឹងប្តីដើមឬ ? ( បាទ មាន )

## Lee Man-hee - លី ម៉ាន់ហ៊ី

Shincheonji ស៊ីនឆន់ជី

ពីក្រុង Daegu ប្រទេស កូរ៉េ

លី ម៉ាន់ហ៊ី អះអាងថា ខ្លួនជាព្រះគ្រីស្ទ ហើយមានតែខ្លួនម្នាក់គត់នៅលើពិភពលោកនេះ ដែលអាចបកស្រាយព្រះគម្ពីរបានត្រឹមត្រូវ។ ការសង្គ្រោះមានតែតាមរយៈគាត់ប៉ុណ្ណោះ។ ប៉ុន្តែគាត់មានអាយុ ៩០ ឆ្នាំហើយ។ មិនយូរប៉ុន្មាន គាត់នឹងស្លាប់ ហើយមិនរស់ឡើងវិញទេ ពីព្រោះគាត់ជាព្រះគ្រីស្ទក្លែងក្លាយ។



សំណួរៈ

- តើ លី ម៉ាន់ហ៊ី គឺជាផ្លូវតែមួយដើម្បីទទួលបានសេចក្តីសង្គ្រោះឬ?
- តើ លី ម៉ាន់ហ៊ី គឺជាព្រះគ្រីស្ទឬ?
- តើ លី ម៉ាន់ហ៊ី ព្រមស្លាប់សម្រាប់ទោសនៃអំពើបាបជំនួសមនុស្សឬ?
- នៅពេល លី ម៉ាន់ហ៊ី ស្លាប់ក្នុងរយៈពេលប៉ុន្មានឆ្នាំទៀត តើគាត់នឹងរស់ឡើងវិញដូចព្រះគ្រីស្ទពិតប្រាកដឬទេ?
- ប្រសិនបើគាត់មិនរស់ឡើងវិញទេ តើអ្នកនឹងឈប់ជឿលើគាត់ឬ?
- តើ លី ម៉ាន់ហ៊ី គឺជាមនុស្សតែម្នាក់គត់ដែលអាចបកស្រាយព្រះបន្ទូលរបស់ព្រះបានត្រឹមត្រូវឬ? (មើល ១យ៉ូហាន ២:២០,២៧)

## Sun Myung Moon - សាន់ ម៊្យុង មូន

ពីប្រទេស កូរ៉េ

លោកសាន់ ម៊្យុង មូន បានអះអាងថា ខ្លួនជាព្រះគ្រីស្ទ។ ប៉ុន្តែលោកបានស្លាប់ហើយ (នៅឆ្នាំ២០១២) ហើយគាត់មិនបានរស់ឡើងវិញទេ។ ឥឡូវដល់វេនប្រពន្ធគាត់ធ្វើជា«ព្រះ»ម្តង។ តែប្រពន្ធគាត់ក៏នឹងមិនរស់ពីស្លាប់ឡើងវិញដែរ។



សំណួរៈ

- តើលោក សាន់ ម៊្យុង មូន គឺជាព្រះគ្រីស្ទឬ?
- តើគាត់បានស្លាប់នៅលើឈើឆ្កាងសម្រាប់ទោសនៃអំពើបាបជំនួសយើងឬ?
- ពេល សាន់ ម៊្យុង មូន ស្លាប់ក្នុងឆ្នាំ ២០១២ តើបីថ្ងៃក្រោយមក គាត់បានរស់ឡើងវិញ ដូចព្រះគ្រីស្ទពិតដែរឬទេ?
- តើមនុស្សស្លាប់អាចជួយអ្នកឲ្យយកឈ្នះលើសេចក្តីស្លាប់បានដែរឬទេ?
- បើប្រពន្ធគាត់ជាព្រះ ហេតុអ្វីបានជានាងមិនប្រោសប្តីឲ្យរស់ឡើងវិញ?
- ពេលប្រពន្ធគាត់ស្លាប់ តើនាងនឹងរស់ឡើងវិញទេ? ប្រសិនបើនាងមិនរស់ឡើងវិញទេ តើអ្នកនឹងឈប់ជឿលើនាងឬ?

## Jehovah's Witnesses - ស្មរបន្ទាល់ព្រះយេហូវ៉ា

ពីប្រទេស អាមេរិក

ពួកគេថា ព្រះគ្រីស្ទគឺជាទេវតា «មីកែល» ដែលព្រះបានបង្កើតពីសូន្យមក។ ព្រះគ្រីស្ទមិនបានយកអំពើបាបទាំងអស់របស់មនុស្សជាតិទៅដាក់លើទ្រង់ទេ។ ក្រោយពីការសុគតរបស់ព្រះគ្រីស្ទ នោះរូបកាយរបស់ទ្រង់មិនបានរស់ឡើងវិញចេញពីផ្នូរទេ។ ស្ថាបនិករបស់ក្រុមនេះបានធ្វើទំនាយខុសជាច្រើន។ គាត់គឺជាគ្រូក្លែងក្លាយ។

JW .ORG Watchtower (ប៉មយាម)

សំណួរៈ

- តើព្រះវរបិតាបានបង្កើតព្រះរាជបុត្រានៃព្រះពីសូន្យមក ឬក៏ព្រះរាជបុត្រានៃព្រះគង់នៅតាំងពីអស់កល្បជានិច្ច?
- តើរូបកាយរបស់ព្រះយេស៊ូវបានរស់ពីស្លាប់ឡើងវិញទេ? (ជារូបកាយដដែលដែលបានចូលក្នុងផ្នូរឬ?)
- តើសពរបស់ព្រះយេស៊ូវនៅឯណា? ហេតុអ្វីផ្នូរនោះនៅទទេ?
- តើព្រះយេស៊ូវបានប្រើរូបកាយអ្វីពេលទ្រង់បរិភោគត្រី ក្រោយពីទ្រង់បានរស់ឡើងវិញ?
- បើសិនរូបកាយព្រះយេស៊ូវនៅតែស្លាប់រហូត តើយើងអាចហៅថា ជាការរស់ឡើងវិញបានដែរឬទេ? (មិនបានទេ)

## Pak Ock Soo - ប៉ាក អុក ស៊ូ

បេសកកម្មដំណឹងល្អ / ការប្រកបអ្នកដឹកនាំគ្រីស្ទបរិស័ទ / ការប្រកបយុវជនអន្តរជាតិ

Good News Mission / Christian Leaders Forum / International Youth Fellowship

ពីក្រុង Seoul ប្រទេស កូរ៉េ

គាត់ថា អ្នកណាលន់តួអំពើបាបរបស់ខ្លួនរាល់ថ្ងៃ អ្នកនោះមិនមែនជាគ្រីស្ទបរិស័ទពិតទេ។ ហើយអ្នកណាមិនដឹងពីថ្ងៃខែដែលខ្លួនបានសង្គ្រោះទេ អ្នកនោះក៏មិនមែនជាគ្រីស្ទបរិស័ទពិតដែរ។



GOOD NEWS MISSION CLF CLFUSA.ORG IYF

សំណួរៈ

- តើមនុស្សអាចបានសង្គ្រោះក្រៅពី ប៉ាក អុក ស៊ូ (បេសកកម្មដំណឹងល្អ)ឬទេ?
- តើពួក ប៉ាក អុក ស៊ូ លួចចៀមពីក្រុមជំនុំផ្សេងទៀតទេ?
- តើព្រះគម្ពីរបង្គាប់គ្រីស្ទបរិស័ទ ឲ្យសារភាពអំពើបាបរបស់ខ្លួនឬទេ? (ម៉ាថាយ ៦:១២; ១យ៉ូហាន ១:៩)
- ប្រសិនបើខ្ញុំមិនអាចជឿទុកចិត្តលើគំនិតផ្ទាល់ខ្លួនរបស់ខ្ញុំបាន តើធ្វើដូចម្តេចទើប ប៉ាក អុក ស៊ូ ដឹងថា គាត់អាចជឿទុកចិត្តលើគំនិតផ្ទាល់ខ្លួនរបស់គាត់បាន?

©2021 TrueReligionCounterfeitReligion@yahoo.com

## សៀវភៅឯទៀតដែលត្រូវបាននិពន្ធឬបកប្រែដោយអ្នកនិពន្ធសៀវភៅនេះ ៖



**សង់លើគ្រឹះមាំ** ដោយ Trevor McIlwain, ប្រភពប្រាជ្ញា, ៦៨ មេរៀន ពីលោកុប្បត្តិ ដល់ព្រះយេស៊ូវ, Ethnos360.com



**ព្រះរាជ្យរបស់ព្រះ** ដោយ J.D. Crowley. ៦៤ មេរៀន ពីគម្ពីរម៉ាថាយ (ភាសាខ្មែរ និងអង់គ្លេសក្នុងសៀវភៅ១)




**បានល្អ ធ្វើល្អ** អត្ថាធិប្បាយពី គម្ពីររ៉ូម ដោយ J.D. Crowley, ប្រភពប្រាជ្ញា ២០១៤ (ភាសាខ្មែរ អង់គ្លេស វៀតណាម និងភូមា)



**ទេវសាស្រ្តសម្រាប់ក្រុមគ្រួសារ និង ក្រុមជំនុំ** ដោយ Dr. Bruce Ware, EMU, ៦០ មេរៀនងាយៗ (ភាសាខ្មែរ) (English title: *Big Truths for Young Hearts*)




**មានផ្លូវតែពីរ** ដោយ J.D. Crowley. កូនសៀវភៅផ្សាយដំណឹងល្អ ៣២ទំព័រ. ៥០ច្បាប់ តម្លៃ ២៥,០០០រៀល។




**មនសិការ** តើវាគឺជាអ្វី? ដោយ Andy Naselli និង J.D. Crowley, Crossway, 2016 (English, German)។

### សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងនិងអ្នកនិពន្ធនៅ៖

**TrueReligionCounterfeitReligion@yahoo.com**